# ព្រះត្រៃបិដក

## ប្រែរួមនឹង ព្រះអដ្ឋកថា

## ភាគ៦៧

បាលីប្រែ ៨០

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# អភិធម្មបិដក

## និង

# សម្មោហវិនោទនី អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# វិភង្គ

## បឋមភាគ

# ៦៧

## បាលីប្រែ ៨០



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៦៧

# វិភង្គ បឋមភាគ

*សូមនមស្ការ ចំពោះព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ អង្គនោះ*

## ខន្ធវិភង្គ

*[ ១ ] ខន្ធ ៥ គឺរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ។*

*[ ២ ] បណ្ដាខន្ធទាំង ៥ នោះ រូបក្ខន្ធ តើដូចម្ដេច ។ រូបណាមួយជាអតីត អនាគត បច្ចុប្បន្ន ដែលជាអជ្ឈត្តរូប ( រូបខាងក្នុង ) ក្ដី ពហិទ្ធារូប ( រូបខាងក្រៅ ) ក្ដី ឱឡារិករូប ( រូបគ្រោតគ្រាត ) ក្ដី សុខុមរូប ( រូបល្អិត ) ក្ដី ហីនរូប ( រូបថោកទាប ) ក្ដី បណីតរូប ( រូបថ្លៃថ្លា ) ក្ដី ទូររូប ( រូបក្នុងទីឆ្ងាយ ) ក្ដី សន្តិកេរូប ( រូបក្នុងទីជិត ) ក្ដី នេះហៅថា រូបក្ខន្ធ ព្រោះប្រមូលរួបរួមនូវរូបទាំងអស់នោះ ក្នុងទីជាមួយគ្នា ។*

*[ ៣ ] បណ្ដារូបទាំងនោះ រូបជាអតីត តើដូចម្ដេច ។ រូបណាកន្លងទៅ រលត់ទៅ ប្រាសទៅ ប្រែប្រួលទៅ អស់ទៅ បាត់បង់ទៅ កើតហើយប្រាសទៅវិញ ជាអតីត សង្គ្រោះដោយចំណែកជាអតីត បានដល់មហាភូតរូប ៤ ផង ឧបាទាយរូបនៃមហាភូតរូប ៤ ផង នេះហៅថា រូបជាអតីត ។ បណ្ដារូបទាំងនោះ រូបជាអនាគត តើដូចម្ដេច ។ រូបណាមិនទាន់កើត មិនទាន់មាន មិនទាន់ដុះដាល មិនទាន់វិលមក មិនទាន់ត្រឡប់មក មិនទាន់ប្រាកដ មិនទាន់លេចឡើង មិនទាន់ដុះឡើង មិនទាន់តាំងឡើង មិនទាន់ស្ទុះឡើង ជាអនាគត សង្គ្រោះដោយចំណែកជាអនាគត បានដល់មហាភូតរូប*

ទាំង ៤ ផង ឧបាទាយរូបនៃមហាភូតរូប ៤ ផង នេះហៅថា រូបជាអនាគត ។ បណ្ដារូបទាំងនោះ រូបជាបច្ចុប្បន្ន តើដូចម្ដេច ។ រូបណាកំពុងកើត កំពុងមាន កំពុងដុះដាល កំពុងវិលមក កំពុងត្រឡប់មក កំពុងប្រាកដ កំពុងលេចឡើង កំពុងដុះឡើង កំពុងតាំងឡើង កំពុងស្ទុះឡើង ជាបច្ចុប្បន្ន សង្គ្រោះដោយចំណែកជាបច្ចុប្បន្ន បានដល់ មហាភូតរូបទាំង ៤ ផង ឧបាទាយរូបនៃមហាភូតរូប ៤ ផង នេះហៅថា រូបជាបច្ចុប្បន្ន ។

[ ៤ ] បណ្ដារូបទាំងនោះ អជ្ឈត្តរូប តើដូចម្ដេច ។ រូបណាជាខាងក្នុង អាស្រ័យខ្លួន កើតចំពោះខ្លួន ជារូបរបស់បុគ្គលម្នាក់ៗ ដែលឧបាទានក្ដួចកាន់មាំរបស់សត្វទាំងឡាយនោះៗ បានដល់មហាភូតរូបទាំង ៤ ផង ឧបាទាយរូបនៃមហាភូតរូប ៤ ផង នេះហៅថា អជ្ឈត្តរូប ។ បណ្ដារូបទាំងនោះ ពហិទ្ធារូប តើដូចម្ដេច ។ រូបណាជាខាងក្រៅ អាស្រ័យខ្លួន កើតចំពោះខ្លួន ជារូបរបស់បុគ្គលម្នាក់ៗ ដែលឧបាទានក្ដួចកាន់មាំ របស់ពួកសត្វដទៃ របស់ពួកបុគ្គលដទៃនោះៗ បានដល់មហាភូតរូបទាំង ៤ ផង ឧបាទាយរូបនៃមហាភូតរូប ៤ ផង នេះហៅថា ពហិទ្ធារូប ។

[ ៥ ] បណ្ដារូបទាំងនោះ ឱឡារិករូប តើដូចម្ដេច ។ ចក្ខាយតនៈ ( អាយតនៈគឺចក្ខុ ) ។បេ។ ផោដ្ឋព្វាយតនៈ ( អាយតនៈគឺផ្សព្វ ) នេះហៅថា ឱឡារិករូប ។ បណ្ដារូបទាំងនោះ សុខុមរូប តើដូចម្ដេច ។ ឥត្ថិន្ទ្រិយ ( ឥន្ទ្រិយ គឺស្ត្រី ) ។បេ។ កពឡិង្ការាហារ ( អាហារដែលជាពំនូត ) នេះហៅថា សុខុមរូប ។

[ ៦ ] បណ្ដារូបទាំងនោះ ហីនរូប តើដូចម្ដេច ។ រូបណារបស់សត្វទាំងឡាយនោះៗ ជារូបដែលគេមើលងាយ គេបៀតបៀន គេគ្របសង្កត់ គេមិនធ្វើសេចក្ដីគោរព ជារូបថោកថយ ដែលគេដឹងថា ថោកថយ ដែលគេសន្មតថា ថោកថយ ជារូបមិនគួរប្រាថ្នា មិនគួរត្រេកអរ មិនជាទីពេញចិត្ត បានដល់ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ នេះហៅថា ហីនរូប ។ បណ្ដារូបទាំងនោះ បណីតរូប តើដូចម្ដេច ។ រូបណារបស់សត្វទាំងឡាយនោះៗ ជារូបដែលគេមិនមើលងាយ គេមិនបៀតបៀន គេមិនគ្របសង្កត់ គេធ្វើសេចក្ដីគោរព ជារូបថ្លៃថ្លា ដែលគេដឹងថាថ្លៃថ្លា ដែលគេសន្មតថាថ្លៃថ្លា ជារូបគួរប្រាថ្នា គួរត្រេកអរ គួរពេញចិត្ត បានដល់ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ នេះហៅថា បណីតរូប ។ មួយទៀត ហីនរូប បើប្រៀបផ្ទឹមនឹងរូបនោះៗ បណ្ឌិតគប្បីជ្រាបថា ជាបណីតរូបដែរ ។

[ ៧ ] បណ្ដារូបទាំងនោះ ទូររូប តើដូចម្ដេច ។ ឥត្ថិន្ទ្រិយ ។បេ។ កពឡិង្ការាហារ ឬក៏រូបដទៃណា ទោះបីមានក្នុងទីមិនជិត ក្នុងទីមិនប្រាកដ ក្នុងទីឆ្ងាយ ក្នុងទីមិនបង្កើយ នេះហៅថា ទូររូប ។ បណ្ដារូបទាំងនោះ សន្តិកេរូប តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ ឬក៏រូបដទៃណា មានក្នុងទីជិត ក្នុងទីប្រាកដ ក្នុងទីមិនឆ្ងាយ ក្នុងទីបង្កើយ នេះហៅថា សន្តិកេរូប ។ មួយទៀត ទូររូប បើប្រៀបផ្ទឹមនឹងរូបនោះៗ បណ្ឌិតគប្បីជ្រាបថា ជាសន្តិកេរូបដែរ ។

[ ៨ ] បណ្ដាខន្ធទាំងនោះ វេទនាខន្ធ តើដូចម្ដេច ។ វេទនាណាមួយ

ជាអតីត អនាគត បច្ចុប្បន្ន ដែលអជ្ឈត្តវេទនាក្តី ពហិទ្ធាវេទនាក្តី ឱឡារិក-វេទនាក្តី សុខុមវេទនាក្តី ហីនវេទនាក្តី បណីតវេទនាក្តី ទូរេវេទនាក្តី សន្តិកេវេទនាក្តី នេះហៅថា វេទនាខន្ធ ព្រោះប្រមូលរួបរួមនូវវេទនាទាំងអស់នោះ ក្នុងទីជាមួយគ្នា ។

[ ៩ ] បណ្តាវេទនាទាំងនោះ វេទនាជាអតីត តើដូចម្តេច ។ វេទនាណាកន្លងទៅ រលត់ទៅ ប្រាសទៅ ប្រែប្រួលទៅ អស់ទៅ បាត់បង់ទៅ កើតហើយប្រាសទៅវិញ ជាអតីត សង្គ្រោះដោយចំណែកជាអតីត បានដល់ សុខវេទនា ទុក្ខវេទនា អទុក្ខមសុខវេទនា នេះហៅថា វេទនាជាអតីត ។ បណ្តាវេទនាទាំងនោះ វេទនាជាអនាគត តើដូចម្តេច ។ វេទនាណា មិនទាន់កើត មិនទាន់មាន មិនទាន់ដុះដាល មិនទាន់វិលមក មិនទាន់ត្រឡប់មក មិនទាន់ប្រាកដ មិនទាន់លេចឡើង មិនទាន់ដុះឡើង មិនទាន់តាំងឡើង មិនទាន់ស្ទុះឡើង ជាអនាគត សង្គ្រោះដោយចំណែកជាអនាគត បានដល់ សុខ-វេទនា ទុក្ខវេទនា អទុក្ខមសុខវេទនា នេះហៅថា វេទនាជាអនាគត ។ បណ្តាវេទនាទាំងនោះ វេទនាជាបច្ចុប្បន្ន តើដូចម្តេច ។ វេទនាណា កំពុងកើត កំពុងមាន កំពុងដុះដាល កំពុងវិលមក កំពុងត្រឡប់មក កំពុងប្រាកដ កំពុងលេចឡើង កំពុងដុះឡើង កំពុងតាំងឡើង កំពុងស្ទុះឡើងជាបច្ចុប្បន្ន សង្គ្រោះដោយចំណែកជាបច្ចុប្បន្ន បានដល់ សុខវេទនា ទុក្ខវេទនា អទុក្ខមសុខវេទនា នេះហៅថា វេទនាជាបច្ចុប្បន្ន ។

[ ១០ ] បណ្តាវេទនាទាំងនោះ អជ្ឈត្តវេទនា តើដូចម្តេច ។ វេទនា

ណាប្រព្រឹត្តទៅខាងក្នុង អាស្រ័យខ្លួន កើតចំពោះខ្លួន ជាវេទនារបស់បុគ្គលម្នាក់ៗ ដែលឧបាទានក្ខន្ធកាន់មាំ របស់សត្វទាំងឡាយនោះៗ បានដល់សុខវេទនា ទុក្ខវេទនា អទុក្ខមសុខវេទនា នេះហៅថា អជ្ឈត្តវេទនា ។ បណ្តាវេទនាទាំងនោះ ពហិទ្ធាវេទនា តើដូចម្តេច ។ វេទនាណា ប្រព្រឹត្តទៅខាងក្នុង អាស្រ័យខ្លួន កើតចំពោះខ្លួន ជាវេទនារបស់បុគ្គលម្នាក់ៗ ដែលឧបាទានក្ខន្ធកាន់មាំ របស់ពួកសត្វដទៃ របស់ពួកបុគ្គលដទៃនោះៗ បានដល់សុខវេទនា ទុក្ខវេទនា អទុក្ខមសុខវេទនា នេះហៅថា ពហិទ្ធាវេទនា ។

[ ១១ ] បណ្តាវេទនាទាំងនោះ ឱឡារិកវេទនា និងសុខុមវេទនា តើដូចម្តេច ។ វេទនាជាអកុសល ហៅថា ឱឡារិកវេទនា វេទនាជាកុសល និងអព្យាក្រឹត ហៅថា សុខុមវេទនា វេទនាជាកុសល និងអកុសល ហៅថា ឱឡារិកវេទនា វេទនាជាអព្យាក្រឹត ហៅថា សុខុមវេទនា វេទនាជាទុក្ខ ហៅថា ឱឡារិកវេទនា វេទនាជាសុខផង មិនមែនទុក្ខមិនមែនសុខផង ហៅថា សុខុមវេទនា វេទនាជាសុខនិងទុក្ខហៅថាឱឡារិកវេទនា វេទនាជាអទុក្ខមសុខ ហៅថា សុខុមវេទនា វេទនារបស់បុគ្គលអ្នកមិនមានសមាបត្តិ ហៅថា ឱឡារិកវេទនា វេទនារបស់បុគ្គលអ្នកមានសមាបត្តិ ហៅថា សុខុមវេទនា វេទនាប្រកបដោយអាសវៈ ហៅថា ឱឡារិកវេទនា វេទនាមិនមានអាសវៈ ហៅថា សុខុមវេទនា មួយទៀត ឱឡារិកវេទនា បើប្រៀបផ្ទឹមនឹងវេទនានោះៗ បណ្ឌិតគប្បីជ្រាបថា ជាសុខុមវេទនាដែរ ។

[ ១២ ] បណ្តាវេទនាទាំងនោះ ហីនវេទនា និងបណីតវេទនា តើដូចម្តេច ។

វេទនាជាអកុសល ហៅថា ហីនវេទនា វេទនាជាកុសល និងអព្យាក្រឹត ហៅថា បណីតវេទនា វេទនាជាកុសល និងអកុសល ហៅថា ហីនវេទនា វេទនាជាអព្យាក្រឹត ហៅថា បណីតវេទនា វេទនាជាទុក្ខ ហៅថា ហីនវេទនា វេទនាជាសុខផង ជាអទុក្ខមសុខផង ហៅថា បណីតវេទនា វេទនាជាសុខ និងទុក្ខ ហៅថា ហីនវេទនា វេទនាជាអទុក្ខមសុខ ហៅថា បណីតវេទនា វេទនារបស់បុគ្គលអ្នកមិនមានសមាបត្តិ ហៅថា ហីនវេទនា វេទនារបស់បុគ្គលអ្នកមានសមាបត្តិ ហៅថា បណីតវេទនា វេទនាប្រកបដោយអាសវៈ ហៅថា ហីនវេទនា វេទនាមិនមានអាសវៈ ហៅថា បណីតវេទនា មួយទៀត ហីនវេទនា បើប្រៀបផ្ទឹមនឹងវេទនានោះៗ បណ្ឌិតគប្បីជ្រាបថា ជាបណីតវេទនាដែរ ។

[ ១៣ ] បណ្តាវេទនាទាំងនោះ ទូរេវេទនា តើដូចម្តេច ។ វេទនាជាអកុសល ឆ្ងាយអំពីវេទនាជាកុសល និងអព្យាក្រឹត វេទនាជាកុសល និងអព្យាក្រឹត ឆ្ងាយអំពីវេទនាជាអកុសល វេទនាជាកុសល ឆ្ងាយអំពីវេទនាជាអកុសល និងអព្យាក្រឹត វេទនាជាអកុសល និងអព្យាក្រឹត ឆ្ងាយអំពីវេទនាជាកុសល វេទនាជាអព្យាក្រឹត ឆ្ងាយអំពីវេទនាជាកុសល និងអកុសល វេទនាជាកុសល និងអកុសល ឆ្ងាយអំពីវេទនាជាអព្យាក្រឹត វេទនាជាទុក្ខ ឆ្ងាយអំពីវេទនាជាសុខ និងអទុក្ខមសុខ វេទនាជាសុខ និងអទុក្ខមសុខ ឆ្ងាយអំពីវេទនាជាទុក្ខ វេទនាជាសុខ ឆ្ងាយអំពីវេទនាជាទុក្ខ និងអទុក្ខមសុខ វេទនាជាទុក្ខ និងអទុក្ខមសុខ ឆ្ងាយអំពីវេទនាជាសុខ វេទនាជាអទុក្ខមសុខ ឆ្ងាយអំពីវេទនាជាសុខ និងទុក្ខ វេទនាជាសុខ និងទុក្ខ ឆ្ងាយអំពីវេទនាជាអទុក្ខម-

សុខ វេទនារបស់បុគ្គលអ្នកមិនមានសមាបត្តិ ឆ្ងាយអំពីវេទនារបស់បុគ្គលអ្នកមានសមាបត្តិ វេទនារបស់បុគ្គល អ្នកមានសមាបត្តិ ឆ្ងាយអំពីវេទនារបស់បុគ្គល អ្នកមិនមានសមាបត្តិ វេទនាប្រកបដោយអាសវៈ ឆ្ងាយអំពីវេទនាមិនមានអាសវៈ វេទនាមិនមានអាសវៈ ឆ្ងាយអំពីវេទនាប្រកបដោយអាសវៈ នេះហៅថា ទូរេវេទនា ។ បណ្តាវេទនាទាំងនោះ សន្តិកេវេទនា តើដូចម្តេច ។ វេទនាជាអកុសល តាំងនៅក្នុងទីជិតនៃវេទនាជាអកុសល វេទនាជាកុសល តាំងនៅក្នុងទីជិតនៃវេទនាជាកុសល វេទនាជាអព្យាក្រឹត តាំងនៅក្នុងទីជិតនៃវេទនាជាអព្យាក្រឹត វេទនាជាទុក្ខ តាំងនៅក្នុងទីជិតនៃវេទនាជាទុក្ខ វេទនាជាសុខ តាំងនៅក្នុងទីជិតនៃវេទនាជាសុខ វេទនាជាអទុក្ខមសុខ តាំងនៅក្នុងទីជិតនៃវេទនាជាអទុក្ខមសុខ វេទនារបស់បុគ្គលមិនមានសមាបត្តិ តាំងនៅក្នុងទីជិតនៃវេទនារបស់បុគ្គលមិនមានសមាបត្តិ វេទនារបស់បុគ្គលមានសមាបត្តិ តាំងនៅក្នុងទីជិតនៃវេទនារបស់បុគ្គលមានសមាបត្តិ វេទនាប្រកបដោយអាសវៈ តាំងនៅក្នុងទីជិតនៃវេទនាប្រកបដោយអាសវៈ វេទនាមិនមានអាសវៈ តាំងនៅក្នុងទីជិតនៃវេទនាមិនមានអាសវៈ នេះហៅថា សន្តិកេ-វេទនា ។ មួយទៀត ទូរេវេទនា បើប្រៀបផ្ទឹមនឹងវេទនានោះៗ បណ្ឌិតគប្បីឃើញថា ដូចសន្តិកេវេទនាដែរ ។

[ ១៤ ] បណ្តាខន្ធទាំងនោះ សញ្ញាខន្ធ តើដូចម្តេច ។ សញ្ញាណាមួយជាអតីត អនាគត បច្ចុប្បន្ន ដែលជាអជ្ឈត្តសញ្ញាក្តី ពហិទ្ធាសញ្ញាក្តី ឱឡា-រិកសញ្ញាក្តី សុខុមសញ្ញាក្តី ហីនសញ្ញាក្តី បណីតសញ្ញាក្តី ទូរេសញ្ញាក្តី

សន្តិកេសញ្ញាក្តី នេះហៅថា សញ្ញាខន្ធ ព្រោះប្រមូលរួបរួមនូវសញ្ញានោះ ក្នុងទី ជាមួយគ្នា ។

[ ១៥ ] បណ្តាសញ្ញាទាំងនោះ សញ្ញាជាអតីត តើដូចម្តេច ។ សញ្ញាណាកន្លងទៅ រលត់ទៅ ប្រាសទៅ ប្រែប្រួលទៅ អស់ទៅ បាត់បង់ទៅ កើតហើយប្រាសទៅវិញជាអតីត សង្គ្រោះដោយចំណែកជាអតីត បានដល់ សញ្ញាកើតអំពីចក្ខុសម្ផស្ស សញ្ញាកើតអំពីសោតសម្ផស្ស សញ្ញាកើតអំពីឃានសម្ផស្ស សញ្ញាកើតអំពីជិវ្ហាសម្ផស្ស សញ្ញាកើតអំពីកាយសម្ផស្ស សញ្ញាកើតអំពីមនោសម្ផស្ស នេះហៅថា សញ្ញាជាអតីត ។ បណ្តាសញ្ញាទាំងនោះ សញ្ញាជាអនាគត តើដូចម្តេច ។ សញ្ញាណា មិនទាន់កើត មិនទាន់មាន មិនទាន់ដុះដាល មិនទាន់វិលមក មិនទាន់ត្រឡប់មក មិនទាន់ប្រាកដ មិនទាន់លេចឡើង មិនទាន់ដុះឡើង មិនទាន់តាំងឡើង មិនទាន់ស្ទុះឡើង ជាអនាគត សង្គ្រោះដោយចំណែកជាអនាគត បានដល់ សញ្ញាកើតអំពីចក្ខុសម្ផស្ស ។បេ។ សញ្ញាកើតអំពីមនោសម្ផស្ស នេះហៅថា សញ្ញាជាអនាគត ។ បណ្តាសញ្ញាទាំងនោះ សញ្ញាជាបច្ចុប្បន្ន តើដូចម្តេច ។ សញ្ញាណា កំពុងកើត កំពុងមាន កំពុងដុះដាល កំពុងវិលមក កំពុងត្រឡប់មក កំពុងប្រាកដ កំពុងលេចឡើង កំពុងដុះឡើង កំពុងតាំងឡើង កំពុងស្ទុះឡើង ជាបច្ចុប្បន្ន សង្គ្រោះដោយចំណែកជាបច្ចុប្បន្ន បានដល់ សញ្ញាកើតអំពីចក្ខុសម្ផស្ស ។បេ។ សញ្ញាកើតអំពីមនោសម្ផស្ស នេះហៅថា សញ្ញាជាបច្ចុប្បន្ន ។

[ ១៦ ] បណ្ដាសញ្ញាទាំងនោះ អជ្ឈត្តសញ្ញា តើដូចម្ដេច ។ សញ្ញាណា ជាខាងក្នុង អាស្រ័យខ្លួន កើតចំពោះខ្លួន ជាសញ្ញារបស់បុគ្គលម្នាក់ៗ ដែលកួចកាន់មាំ របស់សត្វទាំងឡាយនោះៗ បានដល់ សញ្ញាដែលកើតអំពីចក្ខុសម្ផស្ស ។បេ។ សញ្ញាដែលកើតអំពីមនោសម្ផស្ស នេះហៅថា អជ្ឈត្តសញ្ញា ។ បណ្ដាសញ្ញាទាំងនោះ ពហិទ្ធាសញ្ញា តើដូចម្ដេច ។ សញ្ញាណា ជាខាងក្នុង អាស្រ័យខ្លួន កើតចំពោះខ្លួន ជាសញ្ញារបស់បុគ្គលម្នាក់ៗ ដែលកួចកាន់មាំរបស់សត្វដទៃ របស់បុគ្គលដទៃនោះៗ បានដល់ សញ្ញាដែលកើតអំពីចក្ខុសម្ផស្ស ។បេ។ សញ្ញាដែលកើតអំពីមនោសម្ផស្ស នេះហៅថា ពហិទ្ធាសញ្ញា ។

[ ១៧ ] បណ្ដាសញ្ញាទាំងនោះ ឱឡារិកសញ្ញា និងសុខុមសញ្ញា តើដូចម្ដេច ។ សញ្ញាដែលកើតអំពីបដិឃសម្ផស្ស ហៅថា ឱឡារិកសញ្ញា សញ្ញាដែលកើតអំពីអធិវចនសម្ផស្ស ហៅថា សុខុមសញ្ញា សញ្ញាជាអកុសល ហៅថា ឱឡារិកសញ្ញា សញ្ញាជាកុសល និងអព្យាក្រឹត ហៅថា សុខុមសញ្ញា សញ្ញាជាកុសល និងអកុសល ហៅថា ឱឡារិសញ្ញា សញ្ញាជាអព្យាក្រឹត ហៅថា សុខុមសញ្ញា សញ្ញាដែលសម្បយុត្តដោយវេទនាជាទុក្ខ ហៅថា ឱឡារិកសញ្ញា សញ្ញាសម្បយុត្តដោយវេទនាជាសុខ និងអទុក្ខមសុខ ហៅថា សុខុមសញ្ញា សញ្ញាសម្បយុត្តដោយវេទនាជាសុខ និងទុក្ខ ហៅថា ឱឡារិកសញ្ញា សញ្ញាសម្បយុត្តដោយវេទនាជាអទុក្ខមសុខ ហៅថា សុខុមសញ្ញា សញ្ញារបស់បុគ្គលមិនមានសមាបត្តិ ហៅថា ឱឡារិកសញ្ញា សញ្ញារបស់

បុគ្គលមានសមាបត្តិ ហៅថា សុខុមសញ្ញា សញ្ញាប្រកបដោយអាសវៈ ហៅថា ឱឡារិកសញ្ញា សញ្ញាមិនមានអាសវៈ ហៅថា សុខុមសញ្ញា មួយទៀត ឱឡារិកសញ្ញា បើប្រៀបផ្ទឹមនឹងសញ្ញានោះៗ បណ្ឌិតគប្បីឃើញថា ដូចសុខុមសញ្ញាដែរ ។

[ ១៨ ] បណ្តាសញ្ញាទាំងនោះ ហីនសញ្ញា និងបណីតសញ្ញា តើដូចម្តេច ។ សញ្ញាជាអកុសល ហៅថា ហីនសញ្ញា សញ្ញាជាកុសល និងអព្យាក្រឹត ហៅថាបណីតសញ្ញា សញ្ញាជាកុសល និងអកុសល ហៅថា ហីនសញ្ញា សញ្ញាជាអព្យាក្រឹត ហៅថា បណីតសញ្ញា សញ្ញាដែលសម្បយុត្តដោយវេទនាជាទុក្ខ ហៅថា ហីនសញ្ញា សញ្ញាសម្បយុត្តដោយវេទនា ជាសុខផង ជាអទុក្ខមសុខផង ហៅថា បណីតសញ្ញា សញ្ញាសម្បយុត្តដោយវេទនាជាសុខ និងទុក្ខ ហៅថា ហីនសញ្ញា សញ្ញាសម្បយុត្តដោយវេទនាជាអទុក្ខមសុខ ហៅថា បណីតសញ្ញា សញ្ញារបស់បុគ្គលមិនមានសមាបត្តិ ហៅថា ហីនសញ្ញា សញ្ញារបស់បុគ្គលមានសមាបត្តិ ហៅថា បណីតសញ្ញា សញ្ញាប្រកបដោយអាសវៈ ហៅថា ហីនសញ្ញា សញ្ញាមិនប្រកបដោយអាសវៈ ហៅថា បណីតសញ្ញា មួយទៀត ហីនសញ្ញា បើប្រៀបផ្ទឹមនឹងសញ្ញានោះៗ បណ្ឌិតគប្បីឃើញថា ដូចបណីតសញ្ញាដែរ ។

[ ១៩ ] បណ្តាសញ្ញាទាំងនោះ ទូរេសញ្ញា តើដូចម្តេច ។ សញ្ញាជាអកុសល ឆ្ងាយអំពីសញ្ញាជាកុសល និងអព្យាក្រឹត សញ្ញាជាកុសល និងអព្យាក្រឹត ឆ្ងាយអំពីសញ្ញាជាអកុសល សញ្ញាជាកុសល ឆ្ងាយអំពីសញ្ញា

ជាអកុសល និងអព្យាក្រឹត សញ្ញាជាអកុសល និងអព្យាក្រឹត ច្ចាយអំពីសញ្ញាជាកុសល សញ្ញាជាអព្យាក្រឹត ច្ចាយអំពីសញ្ញាជាកុសល និងអកុសល សញ្ញាជាកុសល និងអកុសល ច្ចាយអំពីសញ្ញាជាអព្យាក្រឹត សញ្ញាដែលសម្បយុត្តដោយវេទនាជាទុក្ខ ច្ចាយអំពីសញ្ញាដែលសម្បយុត្តដោយវេទនាជាសុខផង ជាអទុក្ខមសុខផង សញ្ញាដែលសម្បយុត្តដោយវេទនាជាសុខផង ជាអទុក្ខ-មសុខផង ច្ចាយអំពីសញ្ញាដែលសម្បយុត្តដោយវេទនាជាទុក្ខ សញ្ញាសម្ប-យុត្តដោយវេទនាជាសុខ ច្ចាយអំពីសញ្ញាដែលសម្បយុត្តដោយវេទនាជាទុក្ខផង ជាអទុក្ខមសុខផង សញ្ញាដែលសម្បយុត្តដោយវេទនាជាទុក្ខផង ជាអទុក្ខមសុខផង ច្ចាយអំពីសញ្ញាដែលសម្បយុត្តដោយវេទនាជាសុខ សញ្ញាដែលសម្បយុត្តដោយវេទនាជាអទុក្ខមសុខ ច្ចាយអំពីសញ្ញាដែលសម្បយុត្តដោយវេទនាជាសុខ និងទុក្ខ សញ្ញាដែលសម្បយុត្តដោយវេទនាជាសុខ និងទុក្ខ ច្ចាយអំពីសញ្ញាដែលសម្បយុត្តដោយវេទនាជាអទុក្ខមសុខ សញ្ញារបស់បុគ្គលមិនមានសមាបត្តិ ច្ចាយអំពីសញ្ញារបស់បុគ្គលមានសមាបត្តិ សញ្ញារបស់បុគ្គលមានសមាបត្តិ ច្ចាយអំពីសញ្ញារបស់បុគ្គលមិនមានសមាបត្តិ សញ្ញាប្រកបដោយអាសវៈ ច្ចាយអំពីសញ្ញាមិនមានអាសវៈ សញ្ញាមិនមានអាសវៈ ច្ចាយអំពីសញ្ញាប្រកបដោយអាសវៈ នេះហៅថា ទូរេសញ្ញា ។ បណ្តាសញ្ញាទាំងនោះ សន្តិកេសញ្ញា តើដូចម្តេច ។ សញ្ញាជាអកុសល តាំងនៅក្នុងទីជិតនៃសញ្ញាជាអកុសល សញ្ញាជាកុសល តាំងនៅក្នុងទីជិតនៃសញ្ញាជាកុសល សញ្ញាជាអព្យាក្រឹត តាំងនៅក្នុងទីជិតនៃសញ្ញាជាអព្យាក្រឹត

សញ្ញាសម្បយុត្តដោយវេទនាជាទុក្ខ តាំងនៅក្នុងទីជិតនៃសញ្ញាសម្បយុត្តដោយវេទនាជាទុក្ខ សញ្ញាសម្បយុត្តដោយវេទនាជាសុខ តាំងនៅក្នុងទីជិតនៃសញ្ញាសម្បយុត្តដោយវេទនាជាសុខ សញ្ញាសម្បយុត្តដោយវេទនាជាអទុក្ខម-សុខ តាំងនៅក្នុងទីជិតនៃសញ្ញា សម្បយុត្តដោយវេទនាជាអទុក្ខមសុខ សញ្ញារបស់បុគ្គលមិនមានសមាបត្តិ តាំងនៅក្នុងទីជិតនៃសញ្ញា របស់បុគ្គលមិនមានសមាបត្តិ សញ្ញារបស់បុគ្គលមានសមាបត្តិ តាំងនៅក្នុងទីជិតនៃសញ្ញារបស់បុគ្គលមានសមាបត្តិ សញ្ញាប្រកបដោយអាសវៈ តាំងនៅក្នុងទីជិតនៃសញ្ញាប្រកបដោយអាសវៈ សញ្ញាមិនមានអាសវៈ តាំងនៅក្នុងទីជិតនៃសញ្ញាមិនមានអាសវៈ នេះហៅថា សន្តិកេសញ្ញា ។ មួយទៀត ទូរេសញ្ញា បើប្រៀបផ្ទឹមនឹងសញ្ញានោះៗ បណ្ឌិតគប្បីឃើញថា ដូចសន្តិកេសញ្ញាដែរ ។

[ ២០ ] បណ្ដាខន្ធទាំងនោះ សង្ខារក្ខន្ធ តើដូចម្ដេច ។ សង្ខារទាំងឡាយណាមួយ ជាអតីត អនាគត បច្ចុប្បន្នដែលជាអជ្ឈត្តសង្ខារក្ដី ពហិទ្ធា-សង្ខារក្ដី ឱឡារិកសង្ខារក្ដី សុខុមសង្ខារក្ដី ហីនសង្ខារក្ដី បណីតសង្ខារក្ដី ទូរេសង្ខារក្ដី សន្តិកេសង្ខារក្ដី នេះហៅថា សង្ខារក្ខន្ធ ព្រោះប្រមូលរួបរួមនូវសង្ខារក្ខន្ធនោះ ក្នុងទីជាមួយគ្នា ។

[ ២១ ] បណ្ដាសង្ខារទាំងនោះ សង្ខារជាអតីត តើដូចម្ដេច ។ សង្ខារទាំងឡាយកន្លងទៅ រលត់ទៅ ប្រាសទៅ ប្រែប្រួលទៅ អស់ទៅ បាត់បង់ទៅ កើតហើយប្រាសទៅវិញជាអតីត សង្គ្រោះដោយចំណែកជាអតីត បានដល់ ចេតនាកើតអំពីចក្ខុសម្ផស្ស ចេតនាកើតអំពីសោតសម្ផស្ស ចេតនា

កើតអំពីឃានសម្ផស្ស ចេតនាកើតអំពីជិវ្ហាសម្ផស្ស ចេតនាកើតអំពីកាយ-សម្ផស្ស ចេតនាកើតអំពីមនោសម្ផស្ស នេះហៅថា សង្ខារជាអតីត ។ បណ្ដាសង្ខារទាំងនោះ សង្ខារជាអនាគត តើដូចម្ដេច ។ សង្ខារទាំងឡាយណា មិនទាន់កើត មិនទាន់មាន មិនទាន់ដុះដាល មិនទាន់វិលមក មិនទាន់ត្រឡប់មក មិនទាន់ប្រាកដ មិនទាន់លេចឡើង មិនទាន់ដុះឡើង មិនទាន់តាំងឡើង មិនទាន់ស្ទុះឡើង ជាអនាគត សង្គ្រោះដោយចំណែកជាអនាគត បានដល់ ចេតនាកើតអំពីចក្ខុសម្ផស្ស ។បេ។ ចេតនាកើតអំពីមនោសម្ផស្ស នេះហៅថា សង្ខារជាអនាគត ។ បណ្ដាសង្ខារទាំងនោះ សង្ខារជាបច្ចុប្បន្ន តើដូចម្ដេច ។ សង្ខារទាំងឡាយណា កំពុងកើត កំពុងមាន កំពុងដុះដាល កំពុងវិលមក កំពុងត្រឡប់មក កំពុងប្រាកដ កំពុងលេចឡើង កំពុងដុះឡើង កំពុងតាំងឡើង កំពុងស្ទុះឡើង ជាបច្ចុប្បន្ន សង្គ្រោះដោយចំណែកជាបច្ចុប្បន្ន បានដល់ ចេតនាកើតអំពីចក្ខុសម្ផស្ស ។បេ។ ចេតនាកើតអំពីមនោសម្ផស្ស នេះហៅថា សង្ខារជាបច្ចុប្បន្ន ។

[ ២២ ] បណ្ដាសង្ខារទាំងនោះ អជ្ឈត្តសង្ខារ តើដូចម្ដេច ។ សង្ខារទាំងឡាយណា ជាខាងក្នុង អាស្រ័យខ្លួន កើតចំពោះខ្លួន ជាសង្ខាររបស់បុគ្គលម្នាក់ៗ ដែលកួចកាន់មាំនៃសត្វទាំងឡាយនោះៗ បានដល់ ចេតនាកើតអំពីចក្ខុសម្ផស្ស ។បេ។ ចេតនាកើតអំពីមនោសម្ផស្ស នេះហៅថា អជ្ឈត្ត-សង្ខារ ។ បណ្ដាសង្ខារទាំងនោះ ពហិទ្ធាសង្ខារ តើដូចម្ដេច ។ សង្ខារទាំងឡាយណាជាខាងក្នុង អាស្រ័យខ្លួន កើតចំពោះខ្លួន ជាសង្ខាររបស់បុគ្គល

ម្នាក់ៗ ដែលកួចកាន់មាំនៃសត្វដទៃ នៃបុគ្គលដទៃនោះៗ បានដល់ ចេតនាកើតអំពីចក្ខុសម្ផស្ស ។បេ។ ចេតនាកើតអំពីមនោសម្ផស្ស នេះហៅថាពហិទ្ធា សង្ខារ ។

[ ២៣ ] បណ្តាសង្ខារទាំងនោះ ឱឡារិកសង្ខារ និងសុខុមសង្ខារ តើដូចម្តេច ។ សង្ខារជាអកុសល ហៅថា ឱឡារិកសង្ខារ សង្ខារជាកុសលនិងអព្យាក្រឹត ហៅថា សុខុមសង្ខារ សង្ខារជាកុសល និងអកុសល ហៅថាឱឡារិកសង្ខារ សង្ខារជាអព្យាក្រឹត ហៅថា សុខុមសង្ខារ សង្ខារដែលសម្បយុត្តដោយវេទនាជាទុក្ខ ហៅថា ឱឡារិកសង្ខារ សង្ខារដែលសម្បយុត្តដោយវេទនាជាសុខផង ជាអទុក្ខមសុខផង ហៅថា សុខុមសង្ខារ សង្ខារដែលសម្បយុត្តដោយវេទនាជាសុខ និងទុក្ខ ហៅថា ឱឡារិកសង្ខារ សង្ខារដែលសម្បយុត្តដោយវេទនាជាអទុក្ខមសុខ ហៅថា សុខុមសង្ខារ សង្ខាររបស់បុគ្គលមិនមានសមាបត្តិ ហៅថា ឱឡារិកសង្ខារ សង្ខាររបស់បុគ្គលមានសមាបត្តិ ហៅថា សុខុមសង្ខារ សង្ខារប្រកបដោយអាសវៈ ហៅថាឱឡារិកសង្ខារ សង្ខារមិនមានអាសវៈ ហៅថា សុខុមសង្ខារ មួយទៀតឱឡារិកសង្ខារ បើប្រៀបផ្ទឹមនឹងសង្ខារនោះៗ បណ្ឌិតគប្បីឃើញថា ដូចសុខុមសង្ខារដែរ ។

[ ២៤ ] បណ្តាសង្ខារទាំងនោះ ហីនសង្ខារ និងបណីតសង្ខារ តើដូចម្តេច ។ សង្ខារជាអកុសល ហៅថា ហីនសង្ខារ សង្ខារជាកុសល និងអព្យា-ក្រឹត ហៅថាប ណីតសង្ខារ សង្ខារជាកុសល និងអកុសល ហៅថា ហីនសង្ខារ

សង្ខារជាអព្យាក្រឹត ហៅថា បណីតសង្ខារ សង្ខារដែលសម្បយុត្តដោយវេទនាជាទុក្ខ ហៅថា ហីនសង្ខារ សង្ខារដែលសម្បយុត្តដោយវេទនាជាសុខផង ជាអទុក្ខមសុខផង ហៅថា បណីតសង្ខារ សង្ខារដែលសម្បយុត្តដោយវេទនាជាសុខ និងទុក្ខ ហៅថា ហីនសង្ខារ សង្ខារដែលសម្បយុត្តដោយវេទនាជាអទុក្ខមសុខ ហៅថា បណីតសង្ខារ សង្ខាររបស់បុគ្គលមិនមានសមាបត្តិ ហៅថា ហីនសង្ខារ សង្ខាររបស់បុគ្គលមានសមាបត្តិ ហៅថា បណីតសង្ខារ សង្ខារប្រកបដោយអាសវៈ ហៅថា ហីនសង្ខារ សង្ខារមិនមានអាសវៈ ហៅថា បណីតសង្ខារ មួយទៀត ហីនសង្ខារ បើប្រៀបផ្ទឹមនឹងសង្ខារនោះៗ បណ្ឌិតគប្បីឃើញថា ដូចបណីតសង្ខារដែរ ។

[ ២៥ ] បណ្តាសង្ខារទាំងនោះ ទូរេសង្ខារ តើដូចម្តេច ។ សង្ខារជាអកុសល ឆ្ងាយអំពីសង្ខារជាកុសល និងអព្យាក្រឹត សង្ខារជាកុសល និងអព្យាក្រឹត ឆ្ងាយអំពីសង្ខារជាអកុសល សង្ខារជាកុសល ឆ្ងាយអំពីសង្ខារជាអកុសល និងអព្យាក្រឹត សង្ខារជាអកុសល និងអព្យាក្រឹត ឆ្ងាយអំពីសង្ខារជាកុសល សង្ខារជាអព្យាក្រឹត ឆ្ងាយអំពីសង្ខារជាកុសល និងអកុសល សង្ខារជាកុសល និងអកុសល ឆ្ងាយអំពីសង្ខារជាអព្យាក្រឹត សង្ខារដែលសម្បយុត្តដោយវេទនាជាទុក្ខ ឆ្ងាយអំពីសង្ខារដ៏សម្បយុត្តដោយវេទនាជាសុខផង ជាអទុក្ខមសុខផង សង្ខារដែលសម្បយុត្តដោយវេទនាជាសុខផង ជាអទុក្ខមសុខផង ឆ្ងាយអំពីសង្ខារដ៏សម្បយុត្តដោយវេទនាជាទុក្ខ សង្ខារដែលសម្បយុត្តដោយវេទនាជាសុខ ឆ្ងាយអំពីសង្ខារដ៏សម្បយុត្តដោយវេទនា

ជាទុក្ខផង ជាអទុក្ខមសុខផង សង្ខារដែលសម្បយុត្តដោយវេទនាជាទុក្ខផង ជាអទុក្ខមសុខផង ច្វាយអំពីសង្ខារដ៏សម្បយុត្តដោយវេទនាជាសុខ សង្ខារដែលសម្បយុត្តដោយវេទនាជាអទុក្ខមសុខ ច្វាយអំពីសង្ខារដ៏សម្បយុត្តដោយវេទនាជាសុខ និងទុក្ខ សង្ខារដែលសម្បយុត្តដោយវេទនាជាសុខ និងទុក្ខ ច្វាយអំពីសង្ខារដ៏សម្បយុត្តដោយវេទនាជាអទុក្ខមសុខ សង្ខាររបស់បុគ្គលមិនមានសមាបត្តិ ច្វាយអំពីសង្ខាររបស់បុគ្គលមានសមាបត្តិ សង្ខាររបស់បុគ្គលមានសមាបត្តិ ច្វាយអំពីសង្ខាររបស់បុគ្គលមិនមានសមាបត្តិ សង្ខារប្រកបដោយអាសវៈ ច្វាយអំពីសង្ខារមិនមានអាសវៈ សង្ខារមិនមានអាសវៈ ច្វាយអំពីសង្ខារដ៏ប្រកបដោយអាសវៈ នេះហៅថា ទូរេសង្ខារ ។ បណ្តាសង្ខារទាំងនោះ សន្តិកេសង្ខារ តើដូចម្តេច ។ សង្ខារជាអកុសល តាំងនៅក្នុងទីជិតនៃសង្ខារជាអកុសល សង្ខារជាកុសល តាំងនៅក្នុងទីជិតនៃសង្ខារជាកុសល សង្ខារជាអព្យាក្រឹត តាំងនៅក្នុងទីជិតនៃសង្ខារជាអព្យា-ក្រឹត សង្ខារដែលសម្បយុត្តដោយវេទនាជាទុក្ខ តាំងនៅក្នុងទីជិតនៃសង្ខារដ៏សម្បយុត្តដោយវេទនាជាទុក្ខ សង្ខារដែលសម្បយុត្តដោយវេទនាជាសុខ តាំងនៅក្នុងទីជិតនៃសង្ខារដ៏សម្បយុត្តដោយវេទនាជាសុខ សង្ខារដែលសម្បយុត្តដោយវេទនា ជាអទុក្ខមសុខ តាំងនៅក្នុងទីជិតនៃសង្ខារដ៏សម្បយុត្តដោយវេទនាជាអទុក្ខមសុខ សង្ខាររបស់បុគ្គលមិនមានសមាបត្តិ តាំងនៅក្នុងទីជិតនៃសង្ខាររបស់បុគ្គលមិនមានសមាបត្តិ សង្ខាររបស់បុគ្គលមានសមាបត្តិ តាំងនៅក្នុងទីជិតនៃសង្ខាររបស់បុគ្គលមានសមាបត្តិ សង្ខារប្រកបដោយអាសវៈ

តាំងនៅក្នុងទីជិតនៃសង្ខារប្រកបដោយអាសវៈ សង្ខារមិនមានអាសវៈ តាំងនៅក្នុងទីជិតនៃសង្ខារមិនមានអាសវៈ នេះហៅថា សន្តិកេសង្ខារ ។ មួយទៀត ទូរេសង្ខារ បើប្រៀបផ្ទឹមនឹងសង្ខារនោះៗ បណ្ឌិតគប្បីឃើញថា ដូចសន្តិកេសង្ខារដែរ ។

[ ២៦ ] បណ្តាខន្ធទាំងនោះ វិញ្ញាណក្ខន្ធ តើដូចម្តេច ។ វិញ្ញាណណាមួយជាអតីត អនាគត បច្ចុប្បន្ន ដែលជាអជ្ឈត្តវិញ្ញាណក្តី ពហិទ្ធាវិញ្ញាណក្តី ឱឡារិកវិញ្ញាណក្តី សុខុមវិញ្ញាណក្តី ហីនវិញ្ញាណក្តី បណីតវិញ្ញាណក្តី ទូរេវិញ្ញាណក្តី សន្តិកេវិញ្ញាណក្តី នេះហៅថា វិញ្ញាណក្ខន្ធ ព្រោះប្រមូលរួបរួមនូវវិញ្ញាណនោះ ក្នុងទីជាមួយគ្នា ។

[ ២៧ ] បណ្តាវិញ្ញាណទាំងនោះ វិញ្ញាណជាអតីត តើដូចម្តេច ។ វិញ្ញាណណាកន្លងទៅ រលត់ទៅ ប្រាសទៅ ប្រែប្រួលទៅ អស់ទៅ បាត់បង់ទៅ កើតហើយប្រាសទៅវិញ ជាអតីត សង្គ្រោះដោយចំណែកជាអតីត បានដល់ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយ-វិញ្ញាណ មនោវិញ្ញាណ នេះហៅថា វិញ្ញាណជាអតីត ។ បណ្តាវិញ្ញាណទាំងនោះ វិញ្ញាណជាអនាគត តើដូចម្តេច ។ វិញ្ញាណណា មិនទាន់កើត មិនទាន់មាន មិនទាន់ដុះដាល មិនទាន់វិលមក មិនទាន់ត្រឡប់មក មិនទាន់ប្រាកដ មិនទាន់លេចឡើង មិនទាន់ដុះឡើង មិនទាន់តាំងឡើង មិនទាន់ស្ទុះឡើង ជាអនាគត សង្គ្រោះដោយចំណែកជាអនាគត បានដល់ ចក្ខុ-វិញ្ញាណ ។បេ។ មនោវិញ្ញាណ នេះហៅថា វិញ្ញាណជាអនាគត ។ បណ្តា

វិញ្ញាណទាំងនោះ វិញ្ញាណជាបច្ចុប្បន្ន តើដូចម្តេច ។ វិញ្ញាណណាកំពុងកើត កំពុងមាន កំពុងដុះដាល កំពុងវិលមក កំពុងត្រឡប់មក កំពុងប្រាកដ កំពុងលេចឡើង កំពុងដុះឡើង កំពុងតាំងឡើង កំពុងស្ទុះឡើង ជាបច្ចុប្បន្ន សង្គ្រោះដោយចំណែកជាបច្ចុប្បន្ន បានដល់ ចក្ខុវិញ្ញាណ ។បេ។ មនោវិញ្ញាណ នេះហៅថា វិញ្ញាណជាបច្ចុប្បន្ន ។

[ ២៨ ] បណ្តាវិញ្ញាណទាំងនោះ អជ្ឈត្តវិញ្ញាណ តើដូចម្តេច ។ វិញ្ញាណណា ជាខាងក្នុង អាស្រ័យខ្លួន កើតចំពោះខ្លួន ជាវិញ្ញាណរបស់បុគ្គលម្នាក់ៗ ដែលក្តួចកាន់មាំ របស់សត្វទាំងឡាយនោះៗ បានដល់ ចក្ខុ-វិញ្ញាណ ។បេ។ មនោវិញ្ញាណ នេះហៅថា អជ្ឈត្តវិញ្ញាណ ។ បណ្តាវិញ្ញាណទាំងនោះ ពហិទ្ធាវិញ្ញាណ តើដូចម្តេច ។ វិញ្ញាណណា ជាខាងក្នុង អាស្រ័យខ្លួន កើតចំពោះខ្លួន ជាវិញ្ញាណរបស់បុគ្គលម្នាក់ៗ ដែលក្តួចកាន់មាំរបស់សត្វដទៃ របស់បុគ្គលដទៃនោះៗ បានដល់ ចក្ខុវិញ្ញាណ ។បេ។ មនោវិញ្ញាណ នេះហៅថា ពហិទ្ធាវិញ្ញាណ ។

[ ២៩ ] បណ្តាវិញ្ញាណទាំងនោះ ឱឡារិកវិញ្ញាណ និងសុខុមវិញ្ញាណ តើដូចម្តេច ។ វិញ្ញាណជាអកុសល ហៅថា ឱឡារិកវិញ្ញាណ វិញ្ញាណជាកុសល និងអព្យាក្រឹត ហៅថា សុខុមវិញ្ញាណ វិញ្ញាណជាកុសល និងអកុ-សល ហៅថា ឱឡារិកវិញ្ញាណ វិញ្ញាណជាអព្យាក្រឹត ហៅថា សុខុមវិញ្ញាណ វិញ្ញាណដែលសម្បយុត្តដោយវេទនាជាទុក្ខ ហៅថា ឱឡារិកវិញ្ញាណ វិញ្ញាណដែលសម្បយុត្តដោយវេទនាជាសុខផង ជាអទុក្ខមសុខផង ហៅថា សុខុម-

វិញ្ញាណ វិញ្ញាណដែលសម្បយុត្តដោយវេទនាជាសុខ និងទុក្ខ ហៅថា ឱឡារិកវិញ្ញាណ វិញ្ញាណដែលសម្បយុត្តដោយវេទនាជាអទុក្ខមសុខ ហៅថា សុខុមវិញ្ញាណ វិញ្ញាណរបស់បុគ្គលមិនមានសមាបត្តិ ហៅថា ឱឡារិកវិញ្ញាណ វិញ្ញាណរបស់បុគ្គលមានសមាបត្តិ ហៅថា សុខុមវិញ្ញាណ វិញ្ញាណប្រកបដោយអាសវៈ ហៅថា ឱឡារិកវិញ្ញាណ វិញ្ញាណមិនមានអាសវៈ ហៅថា សុខុមវិញ្ញាណ មួយទៀត ឱឡារិកវិញ្ញាណ បើប្រៀបផ្ទឹមនឹងវិញ្ញាណនោះៗ បណ្ឌិតគប្បីឃើញថា ដូចសុខុមវិញ្ញាណដែរ ។

[ ៣០ ] បណ្តាវិញ្ញាណទាំងនោះ ហីនវិញ្ញាណ និងបណីតវិញ្ញាណ តើដូចម្តេច ។ វិញ្ញាណជាអកុសល ហៅថា ហីនវិញ្ញាណ វិញ្ញាណជាកុសល និងអព្យាក្រឹត ហៅថា បណីតវិញ្ញាណ វិញ្ញាណជាកុសល និងអកុសល ហៅថា ហីនវិញ្ញាណ វិញ្ញាណជាអព្យាក្រឹត ហៅថា បណីតវិញ្ញាណ វិញ្ញាណដែលសម្បយុត្តដោយវេទនាជាទុក្ខ ហៅថា ហីនវិញ្ញាណ វិញ្ញាណដែលសម្បយុត្តដោយវេទនាជាសុខផង ជាអទុក្ខមសុខផង ហៅថា បណីតវិញ្ញាណ វិញ្ញាណដែលសម្បយុត្តដោយវេទនាជាសុខ និងទុក្ខ ហៅថា ហីនវិញ្ញាណ វិញ្ញាណដែលសម្បយុត្តដោយវេទនាជាអទុក្ខមសុខ ហៅថា បណីតវិញ្ញាណ វិញ្ញាណរបស់បុគ្គលមិនមានសមាបត្តិ ហៅថា ហីនវិញ្ញាណ វិញ្ញាណរបស់បុគ្គលមានសមាបត្តិ ហៅថា បណីតវិញ្ញាណ វិញ្ញាណដែលប្រកបដោយអាសវៈ ហៅថា ហីនវិញ្ញាណ វិញ្ញាណមិនមានអាសវៈ ហៅថា បណីតវិញ្ញាណ មួយទៀត ហីនវិញ្ញាណ បើប្រៀបផ្ទឹមនឹងវិញ្ញាណនោះៗ បណ្ឌិត

គប្បីឃើញថា ដូចបណីតវិញ្ញាណដែរ ។

[ ៣១ ] បណ្ដាវិញ្ញាណទាំងនោះ ទូរេវិញ្ញាណ តើដូចម្ដេច ។ វិញ្ញាណជាអកុសល ឆ្ងាយអំពីវិញ្ញាណជាកុសល និងអព្យាក្រឹត វិញ្ញាណជាកុសលនិងអព្យាក្រឹត ឆ្ងាយអំពីវិញ្ញាណជាអកុសល វិញ្ញាណជាកុសល ឆ្ងាយអំពីវិញ្ញាណជាអកុសល និងអព្យាក្រឹត វិញ្ញាណជាអកុសល និងអព្យាក្រឹត ឆ្ងាយអំពីវិញ្ញាណជាកុសល វិញ្ញាណជាអព្យាក្រឹត ឆ្ងាយអំពីវិញ្ញាណជាកុសលនិងអកុសល វិញ្ញាណជាកុសល និងអកុសល ឆ្ងាយអំពីវិញ្ញាណជាអព្យា-ក្រឹត វិញ្ញាណដែលសម្បយុត្តដោយវេទនាជាទុក្ខ ឆ្ងាយអំពីវិញ្ញាណដ៏សម្ប-យុត្តដោយវេទនាជាសុខផង ជាអទុក្ខមសុខផង វិញ្ញាណដែលសម្បយុត្តដោយវេទនាជាសុខផង ជាអទុក្ខមសុខផង ឆ្ងាយអំពីវិញ្ញាណដ៏សម្បយុត្តដោយវេទនាជាទុក្ខ វិញ្ញាណដែលសម្បយុត្តដោយវេទនាជាសុខ ឆ្ងាយអំពីវិញ្ញាណដ៏សម្បយុត្តដោយវេទនាជាទុក្ខផង ជាអទុក្ខមសុខផង វិញ្ញាណដែលសម្បយុត្តដោយវេទនាជាទុក្ខផង ជាអទុក្ខមសុខផង ឆ្ងាយអំពីវិញ្ញាណដ៏សម្បយុត្តដោយវេទនាជាសុខ វិញ្ញាណដែលសម្បយុត្តដោយវេទនា ជាអទុក្ខមសុខ ឆ្ងាយអំពីវិញ្ញាណដ៏សម្បយុត្តដោយវេទនាជាសុខ និងទុក្ខ វិញ្ញាណដែលសម្បយុត្តដោយវេទនាជាសុខ និងទុក្ខ ឆ្ងាយអំពីវិញ្ញាណដ៏សម្បយុត្តដោយវេទនាជាអទុក្ខមសុខ វិញ្ញាណរបស់បុគ្គលមិនមានសមា-បត្តិ ឆ្ងាយអំពីវិញ្ញាណរបស់បុគ្គលមានសមាបត្តិ វិញ្ញាណរបស់បុគ្គលមានសមាបត្តិ ឆ្ងាយអំពីវិញ្ញាណរបស់បុគ្គលមិនមានសមាបត្តិ វិញ្ញាណប្រកប

ដោយអាសវៈ ឆ្ងាយអំពីវិញ្ញាណមិនមានអាសវៈ វិញ្ញាណមិនមានអាសវៈ ឆ្ងាយអំពីវិញ្ញាណប្រកបដោយអាសវៈ នេះហៅថា ទូរេវិញ្ញាណ ។ បណ្ដាវិញ្ញាណទាំងនោះ សន្តិកេវិញ្ញាណ តើដូចម្ដេច ។ វិញ្ញាណជាអកុសល តាំងនៅក្នុងទីជិតនៃវិញ្ញាណជាអកុសល វិញ្ញាណជាកុសល តាំងនៅក្នុងទីជិតនៃវិញ្ញាណជាកុសល វិញ្ញាណជាអព្យាក្រឹត តាំងនៅក្នុងទីជិតនៃវិញ្ញាណ ជាអព្យាក្រឹត វិញ្ញាណដែលសម្បយុត្តដោយវេទនាជាទុក្ខ តាំងនៅក្នុងទីជិតនៃវិញ្ញាណដ៏សម្បយុត្តដោយវេទនាជាទុក្ខ វិញ្ញាណដែលសម្បយុត្តដោយវេទនាជាសុខ តាំងនៅក្នុងទីជិតនៃវិញ្ញាណដ៏សម្បយុត្តដោយវេទនាជាសុខ វិញ្ញាណដែលសម្បយុត្តដោយវេទនាជាអទុក្ខមសុខ តាំងនៅក្នុងទីជិតនៃវិញ្ញាណដ៏សម្បយុត្តដោយវេទនាជាអទុក្ខមសុខ វិញ្ញាណរបស់បុគ្គលមិនមានសមាបត្តិ តាំងនៅក្នុងទីជិតនៃវិញ្ញាណរបស់បុគ្គលមិនមានសមាបត្តិ វិញ្ញាណរបស់បុគ្គលមានសមាបត្តិ តាំងនៅក្នុងទីជិតនៃវិញ្ញាណរបស់បុគ្គលមានសមាបត្តិ វិញ្ញាណប្រកបដោយអាសវៈ តាំងនៅក្នុងទីជិតនៃវិញ្ញាណប្រកបដោយអាសវៈ វិញ្ញាណមិនមានអាសវៈ តាំងនៅក្នុងទីជិតនៃវិញ្ញាណមិនមានអាសវៈ នេះហៅថា សន្តិកេវិញ្ញាណ ។ មួយទៀត ទូរេវិញ្ញាណ បើប្រៀបផ្ទឹមនឹងវិញ្ញាណនោះៗ បណ្ឌិតគប្បីឃើញថា ដូចសន្តិកេវិញ្ញាណដែរ ។

## សុត្តន្តភាជនីយ ចប់

# អដ្ឋកថា

# សម្មោហវិនោទនី វិភង្គ

## អារម្ភកថា

*សូមនមស្ការចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ អង្គនោះ*

## ពាក្យប្រារព្ធ

ព្រះសម្ពុទ្ធដ៏ជានាថ ទ្រង់ឃើញសច្ចៈទាំង ៤ ទើបទ្រង់ប្រកាសធម្មសង្គណី ៤ កណ្ឌ ( ចិត្តុប្បាទកណ្ឌ ១ រូបកណ្ឌ ១ និក្ខេបកណ្ឌ ១ អត្ថុទ្ធារកណ្ឌ ១ ) ហើយព្រះលោកនាយក ទ្រង់ប្រកបដោយពុទ្ធធម៌ ១៨ ប្រការ ទ្រង់ជាព្រះបរមសាស្តា ទ្រង់សម្តែងវិភង្គឯណាដោយអំណាចវិភង្គ ១៨ ប្រការ មានខន្ធវិភង្គជាដើម ក្នុងលំដាប់នៃធម្មសង្គណីនោះឯង ឥឡូវនេះ លំដាប់នៃកិច្ចពណ៌នាវិភង្គនោះ ដល់ព្រមហើយ ព្រោះហេតុនោះ ខ្ញុំនឹងកាន់យកន័យរបស់បុរាណដ្ឋកថា នឹងរៀបរៀងអដ្ឋកថាវិភង្គនេះ សូមសាធុជនទាំងឡាយ តាំងចិត្តធ្វើសេចក្តីគោរពក្នុងព្រះសទ្ធម្ម ស្តាប់អដ្ឋកថាវិភង្គនោះហោង ។

# អដ្ឋកថា

## ខន្ធវិភង្គ សុត្តន្តភាជនីយ

[ ១ ] ពាក្យថា ខន្ធ ៥ គឺរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ នេះឈ្មោះថា សុត្តន្តភាជនីយ គឺចែកខន្ធវិភង្គតាមន័យព្រះសូត្រ ក្នុងខន្ធវិភង្គ ដែលជាវិភង្គដើមនៃវិភង្គប្បករណ៍ ។ បណ្ដាពាក្យទាំងនោះ ពាក្យថា **បញ្ច** ជាពាក្យកំណត់ចំនួន ព្រះមានព្រះភាគ ទ្រង់សម្ដែងថា ខន្ធទាំងឡាយ មានមិនតិចជាងនោះ មិនច្រើនជាងនោះ ។ ដោយពាក្យថា ខន្ធ ៥ នោះ ។ ពាក្យថា **ខន្ធា** ជាពាក្យសម្ដែងធម៌ដែលទ្រង់កំណត់ ។

ក្នុងព្រះបាលីខន្ធវិភង្គនោះ សព្ទថា **ខន្ធ** នេះ ប្រើក្នុងឋានៈច្រើនយ៉ាង គឺក្នុងឋានៈថា **រាសិម្ហិ** គឺគំនរ ក្នុងឋានៈថា **គុណេ** គឺគុណ ក្នុងឋានៈថា **បណ្ណត្តិយំ** គឺបញ្ញត្តិ និងក្នុងឋានៈថា **រុឡ្ហិយំ** គឺពាក្យនិយាយផ្សេងតែមានន័យផ្សេង[១] ។

ពិតហើយ ឈ្មោះថា **ខន្ធ** ដោយឋានៈថា គំនរ ដូចក្នុងប្រយោគជាដើម **សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទេ ន សុករំ ឧទកស្ស បមាណំ គហេតុំ ឯត្តកានិ ឧទកឡ្ហកា នីតិ វា ឯត្តកានិ ឧទកាឡ្ហកសតានីតិ វា ឯត្តកានិ ឧទកាឡ្ហកសហស្សានីតិ វា ឯត្តកានិ ឧទកាឡ្ហកសតសហស្សានីតិ វា អថ ខោ អសង្ខ្យេយ្យោ អប្បមេយ្យោ មហាឧទកក្ខន្ធោ ត្វេវ សង្ខ្យំ គច្ឆតិ ។** ម្នាលភិក្ខុទាំងឡាយបុគ្គល មិនងាយរាប់នូវប្រមាណ

---

១- ដូចជាពាក្យថា ស្ករដើមអន្រ្ទង ទឹកត្នោតទឹកនោមគោជាដើម ។

នៃទឹកក្នុងមហាសមុទ្ទថា ទឹកមានប៉ុណ្ណោះអាឡ្ហក ទឹកមានប៉ុណ្ណោះរយអាឡ្ហក ទឹកមានប៉ុណ្ណោះពាន់អាឡ្ហក ទឹកមានប៉ុណ្ណោះសែនអាឡ្ហកបានឡើយ តាមពិតនោះ គឺដល់នូវការរាប់ថា គំនរទឹកធំដែលបុគ្គលរាប់មិនបាន ប្រមាណមិនអស់យ៉ាងណាមិញ ដូច្នេះ ព្រោះមិនមែនទឹកបន្តិចបន្តួច គឺជាទឹកចំនួនច្រើននោះឯង ទើបហៅថា **ឧទកក្ខន្ធ** ។ ម្យ៉ាងទៀត ធូលីសូម្បីមានប្រមាណមិនតិច ក៏ហៅថា **រជ្ជក្ខន្ធ** គឺគំនរធូលី ។ គោមានប្រមាណមិនតិច ក៏ហៅថា **គវក្ខន្ធ** គឺគំនរគោ ។ ពលមានប្រមាណមិនតិច ក៏ហៅថា **ពលក្ខន្ធ** គឺគំនរនៃកងពល ។ បុណ្យមានប្រមាណមិនតិច ក៏ហៅថា **បុញ្ញក្ខន្ធ** គឺគំនរបុណ្យ ។ ព្រោះធូលីមានច្រើន ទើបលោកពោលថា **រជ្ជក្ខន្ធ** គោជាដើម មានប្រមាណច្រើន ទើបលោកពោលថា **គវក្ខន្ធ** ពលមានប្រមាណច្រើន និងបុណ្យមានប្រមាណច្រើន លោកក៏ហៅ **ពលក្ខន្ធ** និង **បុញ្ញក្ខន្ធ** ។

ម្យ៉ាងទៀត ឈ្មោះថា **ខន្ធ** ដោយឋានៈជាគុណ ដូចក្នុងប្រយោគជាដើមថា **សីលក្ខន្ធោ** គុណ គឺសីល **សមាធិក្ខន្ធោ** គុណ គឺសមាធិ ដូច្នេះ ។ ឈ្មោះថា **ខន្ធ** ដោយឋានៈជាបញ្ញត្តិ ដូចក្នុងប្រយោគជាដើមថា **អទ្ទសា ខោ ភគវា មហន្តំ ទារុក្ខន្ធំ គង្គាយ នទិយា តីរេ សោតេន វុយ្ហមានំ** ព្រះមានព្រះភាគ ទ្រង់បានទតឃើញកំណាត់ឈើដ៏ធំ កំពុងអណ្តែតតាមខ្សែទឹកក្នុងច្រាំងទន្លេគង្គា ដូច្នេះ ។ ឈ្មោះថា **ខន្ធ** ក្នុងឋានៈពាក្យនិយាយផ្សេងតែមានន័យផ្សេង ដូចក្នុងប្រយោគជាដើមថា **ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនោ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ** ចិត្ត

*សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ផូរផង់ គឺកវង្គចិត្ត មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ ដូច្នេះ ។ ក្នុងអធិការនេះ ខន្ធនេះ ទ្រង់បំណាងយកដោយឋានៈថា ជាគំនរ ព្រោះថា ឈ្មោះថា អត្ថនៃខន្ធនេះ មានអត្ថថា ជាដុំ ជាក្រុម ជាគំនរ ជាកង ព្រោះហេតុនោះ គប្បីជ្រាបថា ខន្ធទាំងឡាយ មានលក្ខណៈជាគំនរ ។ ទោះបីពោលថា អត្ថនៃខន្ធ មានអត្ថជាកោដ្ឋាស គឺជាចំណែកដូច្នេះក៏គួរ ព្រោះជនទាំងឡាយក្នុងលោក ខ្ចីបំណុលគេមកហើយ កាលត្រូវម្ចាស់បំណុលតឹងទារ ក៏ពោលថា ពួកខ្ញុំនឹងឲ្យពីរខន្ធ បីខន្ធ គឺ ២ ចំណែក ៣ ចំណែក ដូច្នេះ ។ សូម្បីការពោលថា ខន្ធទាំងឡាយ មានលក្ខណៈជាកោដ្ឋាស គឺជាចំណែក ដូច្នេះក៏គួរ ដោយប្រការដូច្នេះ ។ ទើបពាក្យថា* **រូបក្ខន្ធ** *ក្នុងសុត្តន្តភាជនីយនេះ បានដល់ គំនរនៃរូប គឺចំណែកនៃរូប ។ ពាក្យថា* **វេទនាក្ខន្ធ** *បានដល់ គំនរនៃវេទនា ចំណែកនៃវេទនា ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបអត្ថនៃខន្ធ មានសញ្ញាខន្ធជាដើម ដោយន័យនេះឯង ។*

*ដោយពាក្យមានប្រមាណប៉ុណ្ណេះ ព្រះសម្មាសម្ពុទ្ធ ទ្រង់បានប្រមូលរូបទាំងអស់ ធ្វើឲ្យជាគំនរនៃរូបមានប្រភេទយ៉ាងនេះ គឺចំណែកនៃរូប ២៥[១] និងចំណែកនៃរូប ៩៦[២] ដែលទ្រង់ចែកទុកក្នុងឱកាស ១១ យ៉ាង មានរូប*

---

*១- គឺអាយតនៈខាងក្នុង និងអាយតនៈខាងក្រៅ ១០ និងសុខុមរូប ១៥ ។*

*២- កម្មជរូប បានដល់ ចក្ខុទសកៈ សោតទសកៈ ឃានទសកៈ ជិវ្ហាទសកៈ កាយទសកៈ ឥត្ថីភាវទសកៈ បុរិសភាវទសកៈ រួមជា ៧០ និងសុទ្ធដ្ឋករូប ៨ កើតអំពីចិត្ត ឧតុ អាហារ រួមជា ២៤ សទ្ទរូប ២ ដែលកើតអំពីចិត្ត និងឧតុ រួមទាំងអស់ជា ៩៦ ។*

ដែលកើតអំពីអតីត អនាគតនិងបច្ចុប្បន្នជាដើមដោយព្រះតម្រាស់ថា មហាភូតរូបទាំង ៤ ផង ឧបាទាយរូបនៃមហាភូតរូប ៤ ផង ដូច្នេះ ហើយទ្រង់សម្តែងទុកថា ឈ្មោះថា **រូបក្ខន្ធ** ។

ម្យ៉ាងទៀត ទ្រង់ប្រមូលវេទនាទាំងអស់ ធ្វើឲ្យជាគំនរនៃវេទនា ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដែលទ្រង់ចែកទុកក្នុងឱកាស ១១ នោះឯងថា សុខវេទនា ទុក្ខវេទនា អទុក្ខមសុខវេទនា ដូច្នេះហើយ ទ្រង់សម្តែងថា ឈ្មោះថា **វេទនាខន្ធ** ។ ទ្រង់ប្រមូលសញ្ញាទាំងអស់ ធ្វើឲ្យជាគំនរនៃសញ្ញាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដែលទ្រង់ចែកទុកក្នុងឱកាស ១១ ថា សញ្ញាណាកន្លងទៅ រលត់ទៅ ប្រាសទៅ ប្រែប្រួលទៅ អស់ទៅ បាត់បង់ទៅ កើតហើយប្រាសទៅវិញ ជាអតីត សង្គ្រោះដោយចំណែកជាអតីត បានដល់ចេតនាកើតអំពីចក្ខុសម្ផស្ស ។បេ។ ចេតនាកើតអំពីមនោសម្ផស្ស ដូច្នេះហើយទ្រង់សម្តែងថា ឈ្មោះថា **សញ្ញាខន្ធ** ។ ទ្រង់ប្រមូលសង្ខារទាំងអស់ ធ្វើឲ្យជាគំនរនៃចេតនា ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដែលទ្រង់ចែកទុកក្នុងឱកាស ១១ នោះឯងថា ចេតនាកើតអំពីចក្ខុសម្ផស្ស ។បេ។ ចេតនាកើតអំពីមនោសម្ផស្ស ដូច្នេះហើយ ទ្រង់សម្តែងថា ឈ្មោះថា **សង្ខារក្ខន្ធ** ។ ទ្រង់ប្រមូលវិញ្ញាណទាំងអស់ ធ្វើឲ្យជាគំនរនៃចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដែលទ្រង់ចែកទុកក្នុងឱកាស ១១ នោះឯងថា បានដល់ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោធាតុ មនោវិញ្ញាណធាតុ ដូច្នេះហើយ ទ្រង់សម្តែងថា ឈ្មោះថា **វិញ្ញាណក្ខន្ធ** ។

ម្យ៉ាងទៀត ក្នុងអធិការនៃខន្ធ ៥ នេះ រូបទាំងអស់ ដែលកើតអំពីសមុដ្ឋានទាំង ៤ គឺកម្ម ចិត្ត ឧតុ អាហារ ឈ្មោះថា **រូបក្ខន្ធ** វេទនាដែលកើតព្រមជាមួយចិត្ត ៨៩ ដួង មានកាមាវចរកុសលចិត្ត ៨ ដួងជាដើម ឈ្មោះថា **វេទនាខន្ធ** សូម្បីសញ្ញាក៏ឈ្មោះថា **សញ្ញាខន្ធ** ធម៌ មានផស្សៈជាដើម ក៏ឈ្មោះថា **សង្ខារក្ខន្ធ** ចិត្ត ៨៩ ដួង ឈ្មោះថា **វិញ្ញាណក្ខន្ធ** គប្បីជ្រាបការកំណត់ធម៌ក្នុងខន្ធ ៥ យ៉ាងនេះ ដោយប្រការដូច្នេះ ។

## រូបក្ខន្ធនិទ្ទេស

[ ២ ] ឥឡូវនេះ ព្រះមានព្រះភាគ មានបំណងនឹងសម្ដែងរូបក្ខន្ធជាដើមនោះ ទើបត្រាស់ពាក្យជាដើមថា **តត្ថ កតមោ រូបក្ខន្ធោ** ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងខន្ធវិភង្គនោះដូច្នេះ

បទថា **តត្ថ** បានដល់ ក្នុងខន្ធទាំង ៥ នោះ ។ បទថា **កតមោ** ជាកថេតុកម្យតាបុច្ឆា ។ បទថា **រូបក្ខន្ធោ** ជាបទសម្ដែងធម៌ដែលទ្រង់បុច្ឆា ។ ព្រះមានព្រះភាគកាលទ្រង់ចែករូបក្ខន្ធនោះ ទើបឥឡូវនេះ ត្រាស់ពាក្យជាដើមថា **យំ កិញ្ចិ រូបំ** ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **យំ កិញ្ចិ** ជាពាក្យដែលទ្រង់កាន់យក ដោយមិនមានសេសសល់ ។ បទថា **រូបំ** ជាពាក្យកំណត់ធម៌ដែលទាក់ទងគ្នា ដោយបទទាំងពីរនេះ ឈ្មោះថា ទ្រង់ធ្វើការកំណត់យករូប ដោយមិនមានចំណែកសេសសល់ ។

*សួរថា ក្នុងរូបក្ខន្ធនោះ ធម៌ដែលឈ្មោះថា **រូប** ដោយអត្ថដូចម្តេច ឆ្លើយថា ដែលឈ្មោះថា **រូប** ដោយអត្ថថា បែកធ្លាយ សមដូចព្រះតម្រាស់ថា*

> *ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយ ហៅថា រូប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ របស់ណាវិនាស របស់នោះហៅថា រូប ។ ចុះវិនាសដោយអ្វី ។ វិនាសដោយត្រជាក់ក៏មាន វិនាសដោយក្តៅ ក៏មាន វិនាសដោយគម្ងាន ក៏មាន វិនាសដោយស្រេក ក៏មាន វិនាសដោយសម្ផស្សនៃរបោម មូសខ្យល់ និងកម្តៅថ្ងៃ ពស់តូចពស់ធំ ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ របស់ណាវិនាស របស់នោះ ហៅថា រូប ទើបហៅថា **រូប** ដូច្នេះ ។*

*ក្នុងព្រះតម្រាស់ទាំងនោះ ពាក្យថា **កឹ** ជាពាក្យសួរដល់ហេតុ អធិប្បាយថា ពួកអ្នកហៅ **រូប** ដោយហេតុអ្វី គឺឈ្មោះថា **រូប** នោះដោយហេតុអ្វី ។ **ឥតិ** សព្ទ ក្នុងបទថា **រុប្បីតិ** នេះ ជាសព្ទលើកហេតុឡើងសម្តែង អធិប្បាយថា ព្រោះហេតុដែលរូបរមែងបែកធ្លាយ ហេតុនោះ ទើបហៅថា **រូប** ។ បទថា **រុប្បតិ** អធិប្បាយថា រូប រមែងកម្រើក ដែលបច្ច័យទាំងឡាយតែងប៉ះខ្ទប់ ដែលបច្ច័យតែងបៀតបៀន បែកធ្លាយដោយឋានៈ មានប្រមាណប៉ុណ្ណោះ **រូប** ដែលព្រះមានព្រះភាគត្រាស់ហើយដោយអត្ថថា បែកធ្លាយទៅ ដោយប្រការដូច្នេះ ទោះពោលថា ឈ្មោះថា **រូប***

ដោយលក្ខណៈដែលបែកធ្លាយ ដូច្នេះក៏គួរ ព្រោះរូបនេះ មានការបែកធ្លាយ ជាលក្ខណៈ ។

ម្យ៉ាងទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា រូបរមែងបែកធ្លាយទៅព្រោះត្រជាក់ជាដើម ដូច្នេះ ក្នុងខាងដើម ភាពដែលរូបរមែងបែកធ្លាយទៅដោយភាពត្រជាក់ប្រាកដក្នុងលោកន្តរិកនរក ។ ពិតហើយ នរកនីមួយៗ នៅត្រង់ចន្លោះនៃចក្កវាឡ ៣ មានទំហំប្រមាណ ៨ ពាន់យោជន៍ ខាងក្រោម មិនមានផែនដី ខាងលើមិនមានពន្លឺនៃព្រះចន្ទ ព្រះអាទិត្យ ប្រទីប កែវមណី ងងឹតឈ្លុបជានិច្ច ឈ្មោះថា **លោកន្តរិកនរក** ។ អត្តភាពរបស់សត្វដែលកើតក្នុងលោកន្តរិកនរកនោះ ប្រមាណ ៣ គាវុត សត្វទាំងនោះ មានក្រចកវែងតោងតាមជើងភ្នំ សំយុងក្បាលចុះក្រោមដូចប្រចៀវ កាលណាសត្វទាំងនោះ វារមកលូមលូកដៃដល់គ្នានិងគ្នា ក៏សម្គាល់ថា ពួកយើងបានអាហារហើយ ក៏នាំគ្នាខ្វល់ខ្វាយក្នុងវត្ថុដែលខ្លួនគិតថា នោះជាអាហារ ទើបស្ទុះទៅរកគ្នាដោយជុំវិញ ហើយក៏ធ្លាក់ទៅក្នុងទឹក ដែលទ្រផែនដី កាលត្រូវខ្យល់ត្រជាក់បក់មកក៏របេះធ្លាក់ទៅក្នុងទឹក ដូចផ្លែស្រគំទុំ ដូច្នោះ ។ គ្រាន់តែធ្លាក់ទៅប៉ុណ្ណោះ ស្បែក សរសៃ សាច់ ឆ្អឹងរបស់សត្វនោះ ក៏ត្រូវទឹកក្រុតធ្វើឲ្យរលួយជាកំណាត់តូចធំ ដូចដុំម្សៅដែលគេទម្លាក់ទៅក្នុងខ្លាញ់ក្តៅ ការបែកធ្លាយទៅនៃរូប ដោយភាពត្រជាក់ ប្រាកដក្នុងលោកន្តរិកនរកយ៉ាងនេះ ការបែកធ្លាយនៃរូបនេះ ប្រាកដក្នុងប្រទេសទាំងឡាយ ដែលមានភាពត្រជាក់ដែលកើតអំពីព្រិលធ្លាក់ មានដែន ឈ្មោះថា **មហិស្សរក** ជាដើម ព្រោះ

*សត្វទាំងឡាយក្នុងប្រទេសនោះ មានរាងកាយត្រូវត្រជាក់ទម្លាយហើយ តែង ដល់នូវការអស់ជីវិត ដូច្នេះ ។*

*កាលដែលរូបវិនាសទៅដោយកម្តៅ ប្រាកដក្នុងអវីចិមហានរក ។ ពិត ហើយ ក្នុងអវីចិមហានរកនោះ សត្វនរករមែងសោយទុក្ខធំ ក្នុងពេលត្រូវ ធ្វើកម្មករណ៍ មានការឲ្យដេកលើបន្ទះលោហៈដែលក្តៅ ហើយចងដោយ ចំណង ៥ ជាដើម ។*

*កាលដែលរូបវិនាសទៅដោយការស្រេកប្រាកដហើយក្នុងបិត្តិវិស័យ និង ក្នុងពេលកើតទុព្ភិក្ខភ័យ ។ ពិតហើយ ពួកសត្វក្នុងកំណើតប្រេត ឈ្មោះថា យកដៃកាន់អាមិសណាមួយដាក់ចូលក្នុងមាត់មិនបាន មិនមាន អស់ ២-៣ ពុទ្ធន្តរ ខាងក្នុងពោះ ដូចដើមឈើប្រហោងដែលឆេះដោយភ្លើងទូទៅ ។ ក្នុងពេលកើតទុព្ភិក្ខភ័យ ឈ្មោះថា សត្វទាំងឡាយ មិនបានសូម្បីត្រឹមតែទឹក បាយ ដល់នូវការស្លាប់ទៅ រាប់ប្រមាណមិនបាន ។*

*កាលដែលរូបវិនាសទៅដោយការឃ្លាន ប្រាកដហើយក្នុងអសុរកាយទាំង ឡាយ មានកាលកញ្ជិកាសុរជាដើម ។ ពិតហើយ សត្វទាំងឡាយ ក្នុងពួក កាលកញ្ជិកាសុរជាដើមនោះ រមែងមិនអាចបានតំណក់ទឹក ត្រឹមតែញាំង បេះដូងឲ្យសើម ឬត្រឹមតែសើមចុងអណ្តាតអស់ ២-៣ ពុទ្ធន្តរ សត្វពួកខ្លះ ទៅដល់ស្ទឹង ដោយគិតថា ពួកយើងនឹងផឹកទឹក ដូច្នេះ ទឹកនោះ ក៏ក្លាយជា ពំនូកខ្សាច់នៃស្ទឹង សត្វពួកខ្លះរត់ទៅដល់មហាសមុទ្រ មហាសមុទ្រក៏ក្លាយជា ថ្មដា ទើបសត្វទាំងនោះស្គាំងស្គម ត្រូវទុក្ខមានកម្លាំងបៀតបៀនគ្រាប់ទៅ ។*

បានឮថា កាលកញ្ជិកាសុរម្នាក់ មិនអាចអត់ធន់នឹងការស្រេកបាន ទើបចុះទៅកាន់ស្ទឹងធំផង ជ្រៅផង ទទឹងមួយយោជន៍ ក្នុងទីដែលកាលកញ្ជិកាសុរនោះចុះទៅហើយ ទឹកក៏រីងស្ងួត ផ្សែងក៏ហុយឡើង ដូចដើរលើថ្មដាដ៏ក្តៅដូច្នោះ កាលអសុរនោះបានឮសំឡេងទឹក ទើបស្ទុះទៅមកនោះឯង រាត្រីក៏អស់ហើយ ។ ក្នុងខណៈនោះ ពួកភិក្ខុ ៣០ រូប ត្រាច់បិណ្ឌបាតជាវត្ត កំពុងត្រាច់ភិក្ខាចារ អំពីព្រលឹម ឃើញអសុរនោះហើយ ទើបសួរថា នែសប្បុរស អ្នកជានរណា អសុរនោះប្រាប់ថា ខ្ញុំជាប្រេត ភិក្ខុសួរថា អ្នកស្វែងរកអ្វី អសុរកាយពោលថា ខ្ញុំរកទឹកផឹក ពួកភិក្ខុពោលថា ស្ទឹងនេះមានទឹកពេញ អ្នកមិនឃើញទេឬ អសុរពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនអាចផឹកបាន ពួកភិក្ខុពោលថា បើដូច្នោះ ចូរអ្នកដេកត្រង់ស្ទឹងចុះ ពួកអាត្មានឹងចាក់ទឹកចូលក្នុងមាត់របស់អ្នក ។ អសុរនោះ ក៏ដេកផ្ងារលើឆ្នេរខ្សាច់ ពួកភិក្ខុបាននាំគ្នាយកបាត្រ ៣០ ដងទឹកចាក់ក្នុងមាត់របស់អសុរនោះ កាលភិក្ខុទាំងនោះធ្វើយ៉ាងនោះ ពេលបិណ្ឌបាតក៏ខិតចូលមកហើយ ទើបពួកភិក្ខុពោលថា នែសប្បុរស ដល់ពេលភិក្ខាចាររបស់ពួកអាត្មាហើយ អ្នកបាននូវការពេញចិត្តខ្លះដែរឬទេ អសុរនោះឆ្លើយថា បពិត្រលោកម្ចាស់ បើទឹកត្រឹមមួយទូកដៃ អំពីទឹកដែលចាក់ដោយបាត្រ ៣០ របស់លោកម្ចាស់ទាំង ៣០ អង្គ កន្ទងបំពង់ករបស់ខ្ញុំចូលទៅបានសោត សូមការផុតចាកអត្តភាពប្រេតកុំបីមានដល់ខ្ញុំឡើយ ដូច្នេះ ។ ភាពដែលរូបបែកធ្លាយ ដោយការស្រេកប្រាកដហើយក្នុងបិត្តិវិស័យ ដោយប្រការដូច្នេះ ។

ភាពដែលរូបវិនាសព្រោះសម្ផស្សរបោមជាដើម ប្រាកដហើយក្នុងបទេស ទាំងឡាយដែលសម្បូរដោយរបោម និងមូសជាដើម ។ ក្នុងអធិការនេះ ពាក្យថា **ឌំសា** បានដល់ រុយដែលមានក្បាលពណ៌លឿង ពាក្យថា **មកសា** បានដល់ មូសនោះឯង ពាក្យថា **វាត** គប្បីជ្រាបដោយអំណាចនៃខ្យល់ មានខ្យល់ដែលធ្វើឲ្យចុករួយខ្នងជាដើម ។ ពិតហើយ រោគខ្យល់កើតឡើងក្នុងរាងកាយហើយរមែងទម្លាយដៃ ជើង និងខ្នងជាដើម ធ្វើឲ្យជាមនុស្សខ្វាក់ ធ្វើឲ្យជាមនុស្សគម និងជាមនុស្សខ្វិនជាដើម ។

បទថា **អាតបោ** បានដល់ កម្ដៅរបស់ព្រះអាទិត្យ ភាពដែលរូបបែកធ្លាយទៅដោយកម្ដៅនោះ ប្រាកដក្នុងផ្លូវកន្ដារ មានសមុទ្រខ្សាច់ជាដើម ។ បានឮថា មានស្រីម្នាក់ដើរក្រោយពួករទេះ ក្នុងពេលរាត្រី ក្នុងវាលខ្សាច់ កាលព្រះអាទិត្យគោចរទៅ ដល់ថ្ងៃត្រង់ មិនអាចដាក់ជើងត្រង់ខ្សាច់ក្ដៅបាន ក៏ដាក់កំប្រោងពីលើក្បាលហើយជាន់ កាលមិនអាចឈរលើកំប្រោង ព្រោះក្ដៅ ក៏ដាក់សំពត់សាដកលើកំប្រោងនោះ ហើយជាន់ កាលសាដកនោះក្ដៅសព្វហើយ ក៏យកកូនតូចដែល-ពមកនោះ ដាក់ឲ្យដេកផ្កាប់ ហើយជាន់លើកូនតូចដែលកំពុងយំ ទើបស្លាប់ មួយអន្លើដោយកូនតូចក្នុងទីនោះ ព្រោះកម្ដៅធ្វើឲ្យក្ដៅហើយ ។

បទថា **សរីសបា** បានដល់ សត្វទាំងឡាយ មានខ្លួនវែងណាមួយលូនទៅ ភាពដែលរូបបែកធ្លាយ ព្រោះសម្ផស្សនៃសត្វទាំងនោះ បណ្ឌិតគប្បីជ្រាបដោយអំណាចក្នុងពេលដែលត្រូវអាសិរពិសចឹកជាដើម ។

ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់បំណងនឹងប្រមូលរូបទាំងអស់ ដែលមាន ២៥ កោដ្ឋាស និង ៩៦ កោដ្ឋាស ដែលទ្រង់ប្រមូលដោយបទថា **យំ កិញ្ចិ រូបំ** ចូលក្នុងចំណែកនៃរូបដែលជាអតីតជាដើម ទើបត្រាស់ពាក្យថា **អតីតានាគតបច្ចុប្បន្នំ** ដូច្នេះ បន្ទាប់អំពីនោះ ទ្រង់បំណងនឹងសម្ដែងរួមរូបនោះឯង ទុកក្នុង ៤ ទុកៈ មាន **អជ្ឈត្តទុក** ជាដើម ទើបត្រាស់ថា **អជ្ឈត្តំ វា ពហិទ្ធា វា** ជាដើម បន្ទាប់អំពីនោះ កាលទ្រង់ប្រមូលរូបទាំងអស់នោះ ដែលទ្រង់កំណត់ទុកក្នុងកោដ្ឋាស ១១ សម្ដែងរួមតែមួយ ទើបត្រាស់ថា **តទេកជ្ឈំ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តទេកជ្ឈំ** កាត់បទជា **តំ ឯកជ្ឈំ** ។ បទថា **អភិសញ្ញូហិត្វា** បានដល់ ប្រមូលមក ។ បទថា **អភិសង្ខិបិត្វា** បានដល់ ធ្វើនូវការសង្ខេប ពាក្យនេះ អធិប្បាយថា រូបមានប្រការដូចពោលហើយទាំងអស់នោះ បណ្ឌិតហៅថា **រូបក្ខន្ធ** ព្រោះរួមជាគំនរតែមួយ ក្នុងភាវៈតែមួយ ពោល គឺមានការបែកធ្លាយទៅជាលក្ខណៈ ដូច្នេះ ។ ដោយពាក្យនេះ រមែងជាការសម្ដែងថា រូបទាំងអស់ ឈ្មោះថា **រូបក្ខន្ធ** ដោយការចូលដល់ភាពជាគំនរ ក្នុងលក្ខណៈនៃការបែកធ្លាយទៅ ព្រោះឈ្មោះថា **រូបក្ខន្ធ** ដទៃក្រៅអំពីរូប មិនមាន ។ រូបយ៉ាងណា ធម៌ មានវេទនាជាដើម ក៏ឈ្មោះថា វេទនាខន្ធជាដើមយ៉ាងនោះ ព្រោះការចូលដល់ភាពជាគំនរ ក្នុងលក្ខណៈ មានការសោយអារម្មណ៍ជាលក្ខណៈជាដើម ព្រោះឈ្មោះថា វេទនាខន្ធជាដើម ដទៃអំពីវេទនាខន្ធជាដើម មិនមាន ។

[ ៣ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ចែករូបដែលទ្រង់ចាត់ចូលក្នុងឱកាសនីមួយៗ ឲ្យជាចំណែកៗ ទើបត្រាស់ពាក្យជាដើមថា **តត្ថ កតមំ រូបំ អតីតំ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តត្ថ** ជាសត្តមីវិភត្តិ ក្នុងមាតិកាតាមដែលទ្រង់ចែកទុកក្នុងឱកាស ១១ យ៉ាង ពាក្យនេះ មានអធិប្បាយថា ពាក្យណាថា រូបអតីតដែលត្រាស់ទុកក្នុងមាតិកាតាមដែលទ្រង់តាំងទុក ដោយន័យជាដើមថា **អតីតានាគតប្បច្ចុប្បន្នំ** ដូច្នេះ រូបនោះដូចម្ដេច បណ្ឌិតគប្បីជ្រាបអត្ថក្នុងបុច្ឆាទាំងអស់ ដោយឧបាយនេះ ។

បទទាំងឡាយ មានពាក្យជាដើមថា **អតីតំ និរុទ្ធំ** រូបណា កន្លងទៅលេតទៅ ដូច្នេះ ខ្ញុំពោលហើយ ក្នុងការអធិប្បាយបទភាជនីយអតីតត្តិកៈនៃនិក្ខេបកណ្ឌនោះឯង ។

បទថា **ចត្តារោ ច មហាភូតា** នេះ ជាពាក្យសម្ដែងសភាវលក្ខណៈរបស់រូបដែលត្រាស់ថា **អតីត** ដូច្នេះ ។ ម្យ៉ាងទៀត ក្នុងអធិការនេះ ពាក្យដែលខ្ញុំបានពោលហើយយ៉ាងណា ពាក្យដែលពោលក្នុងទីគ្រប់អន្លើ ក៏គប្បីជ្រាបយ៉ាងនោះ ។ ដោយពាក្យនេះ រមែងសម្ដែងអត្ថនេះថា មហាភូតរូបនិងឧបាទាយរូប ជារូបអតីតខ្លះ ជារូបអនាគតខ្លះ ។បេ។ ជារូបឆ្ងាយ និងរូបជិតខ្លះ ព្រោះឈ្មោះថា រូបដទៃក្រៅអំពីមហាភូតរូប និងឧបាទាយរូបប្រព្រឹត្តទៅ មិនមាន ។

ន័យម្យ៉ាងទៀត បទថា **អតីតំសេន សង្គហិតំ** បានដល់ រូបដែល

សង្គ្រោះដោយចំណែកអតីតនោះឯង គឺសង្គ្រោះចូលបានក្នុងចំណែកដែលជាអតីតនោះឯង ។ សួរថា រូបអ្វី ឆ្លើយថា មហាភូតរូប ៤ និងរូបដែលអាស្រ័យមហាភូតរូប ៤ គប្បីជ្រាបអត្ថក្នុងទីទាំងពួងយ៉ាងនេះ ។ បទអធិប្បាយរូបដែលជាអនាគត និងបច្ចុប្បន្ន ក៏មានអត្ថតាមដែលពោលហើយខាងដើមនោះឯង ។

រូបនេះ ដែលឈ្មោះថា ជាអតីត អនាគត បច្ចុប្បន្ន មាន ២ យ៉ាង គឺ រូបដោយបរិយាយនៃព្រះសូត្រ ១ រូបដោយនិទ្ទេសនៃព្រះអភិធម្ម ១ ។

ពោលដោយបរិយាយនៃព្រះសូត្រ ទ្រង់កំណត់រូបដែលជាអតីត អនាគត បច្ចុប្បន្ននោះទុកដោយភព ។ ពិតហើយ រូបដែលកើតក្នុងភពអតីតចាប់តាំងអំពីបដិសន្ធិ ( ក្នុងភពបច្ចុប្បន្ន ) ឬរូបដែលកើតហើយ ក្នុងភពបន្ទាប់ ឬរូបដែលកើតហើយក្នុងភពទីបំផុតនៃសែនកោដិកប្បក៏ដោយ ទាំងអស់ ឈ្មោះថា រូបអតីត ។ រូបដែលនឹងកើតក្នុងភពអនាគត ចាប់តាំងអំពីចុតិហើយ ឬរូបដែលនឹងកើតក្នុងភពតទៅ ឬរូបដែលនឹងកើតក្នុងភពទីបំផុតនៃសែនកោដិក្តី ទាំងអស់នោះ ឈ្មោះថា រូបអនាគត ។ រូបដែលប្រព្រឹត្តទៅក្នុងចន្លោះចុតិ បដិសន្ធិ តាំងពីកើតដល់ស្លាប់ក្នុងបច្ចុប្បន្នភព ឈ្មោះថា រូបបច្ចុប្បន្ន ។

ឯក្នុងនិទ្ទេសនៃព្រះអភិធម្ម ទ្រង់កំណត់រូបដោយខណៈ ដ្បិតថា ខណៈនៃរូប មាន ៣ យ៉ាង គឺឧប្បាទក្ខណៈ ឋិតិក្ខណៈ ភង្គក្ខណៈ រូបដែលដល់ខណៈទាំង ៣ នេះ ហើយរលត់ទៅ ឬរូបដែលរលត់ក្នុងខណៈជិតៗ ឬរូប

វេលត់ក្នុងខណៈទីបំផុតនៃសែនកោដិកប្បក្តី ទាំងអស់ឈ្មោះថា រូបអតីតនោះឯង រូបដែលមិនទាន់ដល់ខណៈទាំង ៣ ឬមិនទាន់ដល់ខណៈនៃចិត្ត ១ ដួង ឬមិនទាន់ដល់ខណៈក្នុងទីបំផុតនៃសែនកោដិកប្បក្តី ក្នុងអនាគតក្តី ទាំងអស់ ឈ្មោះថា រូបអនាគតនោះឯង តែរូបដែលដល់ខណៈទាំង ៣ នេះហើយ ឈ្មោះថា រូបបច្ចុប្បន្ន ។

ក្នុងខន្ធវិភង្គនោះ រូបនេះ ជាការចែកតាមព្រះសូត្រក៏ពិត តែគប្បីជ្រាប ថា រូបដែលជាអតីត អនាគត និងបច្ចុប្បន្ន សម្តែងហើយ ដោយនិទ្ទេសនៃ ព្រះអភិធម្មនោះឯង ដូច្នេះ ។

ន័យម្យ៉ាងទៀត រូបនេះ ឈ្មោះថា រូបអតីត ដោយចំណែកទាំង ៤ ដោយអំណាចអទ្ធា ១ សន្តតិ ១ សម័យ ១ ខណៈ ១ ។ ឈ្មោះថា រូបអនាគត និងរូបបច្ចុប្បន្ន ក៏ដោយចំណែកទាំង ៤ ដូចគ្នា ។

ពោលដោយអំណាចអទ្ធា រូបក្នុងកាលមុនអំពីបដិសន្ធិក្នុងភពមួយរបស់ បុគ្គលម្នាក់ ឈ្មោះថា រូបអតីត រូបក្នុងបន្ទាប់អំពីចុតិ ឈ្មោះថា រូបអនាគត រូបក្នុងរវាងទាំង ២ នោះ ឈ្មោះថា រូបបច្ចុប្បន្ន ។

ពោលដោយអំណាចសន្តតិ រូបដែលមានឧតុជាមួយគ្នា មានចំណែកស្មើ គ្នា ជាសមុដ្ឋាន និងរូបដែលមានអាហារតែមួយដូចគ្នា ជាសមុដ្ឋាន សូម្បី កំពុងប្រព្រឹត្តទៅដោយអំណាចកើតបន្តមកអំពីខាងដើម ឈ្មោះថា រូបបច្ចុប្បន្ន ។ រូបដែលមានឧតុ និងអាហារមិនស្មើគ្នាជាសមុដ្ឋាន ដែលកើតមុនរូប បច្ចុប្បន្ននោះ ឈ្មោះថា រូបអតីត រូបដែលមានឧតុ និងអាហារមិនស្មើគ្នា ជា

សមុដ្ឋានដែលកើតក្រោយបច្ចុប្បន្ន ឈ្មោះថា រូបអនាគត ចិត្តជរូបមានវិថីជាមួយគ្នា មានជវ័នជាមួយគ្នា និងមានសមាបត្តិជាមួយគ្នា ជាសមុដ្ឋាន ឈ្មោះថា រូបបច្ចុប្បន្ន ចិត្តជរូបដែលកើតមុនរូបបច្ចុប្បន្ននោះ ឈ្មោះថា រូបអតីត ចិត្តជរូបដែលកើតក្រោយរូបបច្ចុប្បន្ន ឈ្មោះថា រូបអនាគត ។ រូបដែលមានកម្មជាសមុដ្ឋាន មិនមានការផ្សេងគ្នានៃរូប មានអតីតជាដើមដោយអំណាចសន្តិមួយដោយចំពោះ តែគប្បីជ្រាបការផ្សេងគ្នានៃរូប មានរូបអតីតជាដើម របស់រូបដែលមានកម្មជាសមុដ្ឋាននោះ ដោយអំណាចនៃឧតុជរូប អាហារជរូប ចិត្តជរូបទាំងនោះ ជាគ្រឿងឧបត្ថម្ភនោះឯង ។

ពោលដោយអំណាចសម័យ សម័យនោះៗ កំពុងប្រព្រឹត្តទៅ ដោយអំណាចការបន្តក្នុងសម័យទាំងឡាយ មានខណៈ យាម ពេលព្រឹក ពេលល្ងាច ពេលយប់ និងពេលថ្ងៃជាដើមនីមួយៗ ឈ្មោះថា បច្ចុប្បន្ន ។ មុនអំពីសម័យនោះ ឈ្មោះថា អតីត ក្រោយសម័យនោះ ឈ្មោះថា រូបអនាគត ។

ពោលដោយអំណាចខណៈ រូបដែលទាក់ទងដោយខណៈទាំង ៣ មានឧប្បាទក្ខណៈជាដើម ឈ្មោះថា បច្ចុប្បន្ន រូបដែលកើតមុនខណៈទាំង ៣ នោះ ឈ្មោះថា រូបអតីត រូបដែលកើតក្រោយខណៈទាំង ៣ នោះ ឈ្មោះថា រូបអនាគត ។

ម្យ៉ាងទៀត រូបដែលមានកិច្ចនៃហេតុ និងបច្ច័យកន្លងទៅហើយ ឈ្មោះថា រូបអតីត រូបដែលមានកិច្ចនៃហេតុសម្រេចហើយ តែមានកិច្ចនៃបច្ច័យ

មិនទាន់សម្រេច ឈ្មោះថា រូបបច្ចុប្បន្ន រូបដែលមានកិច្ចទាំង ២ មិនទាន់មកដល់ ឈ្មោះថា រូបអនាគត ។ ម្យ៉ាងទៀត រូបដែលប្រព្រឹត្តទៅ ក្នុងខណៈកិច្ចរបស់ខ្លួន ឈ្មោះថា រូបបច្ចុប្បន្ន រូបដែលប្រព្រឹត្តទៅមុនកិច្ចរបស់ខ្លួននោះ ឈ្មោះថា រូបអតីត រូបដែលប្រព្រឹត្តទៅខាងក្រោយកិច្ចរបស់ខ្លួននោះ ឈ្មោះថា រូបអនាគត ។ ក្នុងនិទ្ទេសនៃរូបដែលជាអតីតត្តិកៈនេះ កថាពោលដោយខណៈជាដើម ជាកថាមិនអម កថាដ៏សេសមានបរិយាយដោយអម ក្នុងកថាទាំង ២ នោះ និប្បរិយាយកថា ( បរិយាយដោយត្រង់ ) ទ្រង់បំណងយកក្នុងសុត្តន្តភាជនីយនេះ ។ និទ្ទេសនៃបទរូបពួកអជ្ឈត្តទុកៈក៏មានអត្ថតាមដែលពោល ក្នុងនិទ្ទេសនៃអជ្ឈត្តិកៈ ខាងដើមនោះឯង ។ រូបគ្រោតគ្រាតជាដើម មានអត្ថតាមដែលខ្ញុំបានពោលហើយ ក្នុងកិច្ចពណ៌នារូបកណ្ឌនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃរូបហីនទុកៈដូចតទៅ

[ ៦ ] បទថា **តេសំ តេសំ សត្តានំ** នេះ ជាឆដ្ឋីវិភត្តិ ប្រព្រឹត្តទៅក្នុងសត្វច្រើន ព្រោះកាលត្រាស់ថា របស់សត្វដទៃ របស់សត្វដទៃ ដូច្នេះ ត្រាស់អស់មួយថ្ងៃក្តី អស់មួយសែនកប្បក្តី ក៏រមែងត្រាស់មានប្រមាណប៉ុណ្ណោះឯង ព្រោះហេតុនោះ ព្រះសាស្តាកាលទ្រង់កំណត់យកសត្វដោយមិនសេសសល់ដោយបទទាំង ២ នោះឯង ទើបត្រាស់ថា **តេសំ តេសំ សត្តានំ** ដូច្នេះ ។ ដោយបទមានប្រមាណប៉ុណ្ណោះ រមែងសម្រេចការសម្តែងដល់សត្វដទៃៗ ទាំងអស់ ។ បទថា **ឧញ្ញាតំ** បានដល់ ដែលគេប្រមាថ ។ បទថា

**អវញ្ញាតំ** បានដល់ រូបដែលគេចំអក មិនដឹងថាជារូប ។ បទថា **ហីឡិតំ** បានដល់ រូបដែលគេលះបង់ចោល ដែលគេទុកចោល ដោយអត្ថថា មិនគួរកាន់យក អាចារ្យពួកខ្លះពោលថា រូបដែលគួរខ្ពើម ដូច្នេះក៏មាន ។ បទថា **បរិភូតំ** បានដល់ រូបដែលគេតិះដៀលដោយពាក្យថា មានប្រយោជន៍អ្វីដោយរូបនេះ ដូច្នេះ ។ បទថា **អចិត្តីកតំ** បានដល់ រូបដែលមិនគួរគោរព ។ បទថា **ហីនំ** បានដល់ រូបដែលអាក្រក់ ។ បទថា **ហីនមតំ** បានដល់ រូបដែលគេដឹងថា អាក្រក់ បានដល់ រូបដែលគេធ្វើឲ្យដឹងថា លាមក ។ បទថា **ហីនសម្មតំ** បានដល់ រូបដែលគេសន្មតក្នុងលោកថា អាក្រក់ ឬរូបដែលបុគ្គលអាក្រក់ស្គាល់ដោយល្អ ដូចលាមក ដែលសត្វមានលាមកជាអាហារសម្គាល់ថាល្អ ។ បទថា **អនិដ្ឋំ** បានដល់ រូបដែលមិនគួរស្រឡាញ់ ឬរូបដែលគេមិនស្វែងរកដើម្បីនឹងបាន ។ បើបុគ្គលណា នឹងគប្បីស្វែងរករូបនោះ ក៏ចូរស្វែងរកចុះ តែរូបដែលមិនគួរប្រាថ្នានេះឯង ជាឈ្មោះនៃអារម្មណ៍នោះ ។ បទថា **អកន្តំ** បានដល់ រូបដែលមិនគួរត្រេកអរ ឬមិនមានសិរី ។ បទថា **អមនាបំ** បានដល់ រូបដែលមិនជាទីពេញចិត្ត ។ ពិតហើយ រូបបែបនោះរមែងមិនជាទីពេញចិត្ត ។ម្យ៉ាងទៀត រូបណា ញ៉ាំងចិត្តឲ្យត្រេកអរ គឺឲ្យចម្រើន ព្រោះហេតុនោះ ទើបរូបនោះ ឈ្មោះថា **មនាប** រូបដែលញ៉ាំងចិត្តឲ្យត្រេកអរមិនបាន ឈ្មោះថា **អមនាប ។**

ន័យម្យ៉ាងទៀត រូប ឈ្មោះថា មិនគួរប្រាថ្នា ព្រោះវៀរចាកសម្បត្តិ ។ ក្នុងរូបទាំងឡាយដែលមានកម្មជាសមុដ្ឋាន រូបដែលមិនគួរប្រាថ្នានោះ មាន

អកុសលកម្ម ជាសមុដ្ឋានដោយចំណែកមួយ ។ រូបដែលឈ្មោះថា មិនគួរត្រេកអរ ព្រោះមិនមានហេតុនៃសេចក្ដីសុខ រូបដែលឈ្មោះថា មិនជាទីពេញចិត្ត ព្រោះជាហេតុនៃទុក្ខ ។

បទថា **រូបា សទ្ទា** ជាដើម ជាពាក្យសម្ដែងសភាវៈនៃរូបគ្រោតគ្រាតនោះ ។ ពិតហើយ ក្នុងបទនេះ ទ្រង់ចែកកាមគុណ ៥ ដែលមិនគួរប្រាថ្នាដោយអំណាចនៃរូបដែលកើតអំពីអកុសលកម្ម ។ ព្រោះថា រូបដែលកើតអំពីកុសលកម្ម ឈ្មោះថា មិនគួរប្រាថ្នា មិនមាន រូបទាំងអស់ដែលកើតអំពីកុសលកម្ម ជារូបដែលគួរប្រាថ្នាទាំងអស់ ។

ក្នុងបណិតបទនិទ្ទេស គប្បីជ្រាបដោយន័យផ្ទុយគ្នា តាមដែលពោលហើយ តែក្នុងបទនេះ ទ្រង់ចែកកាមគុណ ៥ ដែលគួរប្រាថ្នាដោយអំណាចនៃរូបដែលកើតអំពីកុសលកម្ម ព្រោះរូបដែលកើតអំពីកុសលកម្ម ឈ្មោះថាជារូបដែលមិនគួរប្រាថ្នា មិនមាន រូបទាំងអស់គួរប្រាថ្នានោះឯង ។ ក្នុងរូបកើតអំពីកម្មយ៉ាងណា សូម្បីក្នុងរូបទាំងឡាយ ដែលមានឧតុជាសមុដ្ឋានជាដើមក៏យ៉ាងនោះ រមែងមានទាំងភាពជារូបដែលគួរប្រាថ្នា និងមិនគួរប្រាថ្នា បណ្ឌិតគប្បីជ្រាបថា អដ្ឋកថាចារ្យចែកចំពោះឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ក្នុងទុកៈនេះ ដោយប្រការដូច្នេះ ។

នេះជាកថាមានអត្ថស្មើគ្នា របស់អាចារ្យទាំងឡាយ ។ ចំណែកអាចារ្យវិតណ្ឌវាទីពោលថា ឈ្មោះថា ឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ដែលចែកចំពោះដោយចំណែកមួយ មិនមាន ពាក្យនោះ ពោលទុកហើយតាមគាប់ចិត្ត

របស់អាចារ្យនោះៗ ដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ សគាថវគ្គ ) ថា បពិត្រមហារាជ បណ្ដាកាមគុណទាំង ៥ តថាគត ពោលសំដៅត្រង់របស់ជាទីគាប់ចិត្តបំផុតថា ប្រសើរជាងគេ បពិត្រមហារាជ ព្រោះថា រូបទាំងឡាយណា ជាទីគាប់ចិត្តរបស់បុគ្គលខ្លះ រូបទាំងនោះ ទៅជាមិនគាប់ចិត្តរបស់បុគ្គលខ្លះក៏មាន ។ បពិត្រមហារាជ ក្លិនទាំងឡាយណា ... បពិត្រមហារាជ រសទាំងឡាយណា ... បពិត្រមហារាជ ផ្សព្វទាំងឡាយណា ជាទីគាប់ចិត្តបុគ្គលខ្លះ ផ្សព្វទាំងនោះ ទៅជាមិនជាទីគាប់ចិត្តបុគ្គលខ្លះ ក៏មាន ដូច្នេះ ។ ដោយព្រះតម្រាស់យ៉ាងនេះ ព្រោះបុគ្គលណាម្នាក់ រមែងពេញចិត្ត រមែងត្រេកអរក្រៃលែងនូវរូបទាំងនោះឯងជាដើម បុគ្គលនោះ រមែងញុំាងសេចក្ដីលោភឲ្យកើតឡើងក្នុងរូបជាដើមនោះ បុគ្គលពួកមួយ រមែងក្រោធ រមែងអាក់អន់ រមែងញុំាងទោសៈ ឲ្យកើតឡើងក្នុងរូបជាដើមនោះ ។ រូបជាដើមនោះ រមែងគួរប្រាថ្នា រមែងគួរស្រឡាញ់ រមែងពេញចិត្តដល់បុគ្គលពួកខ្លះ តែមិនជាទីប្រាថ្នា មិនជាទីស្រឡាញ់ មិនជាទីពេញចិត្តដល់បុគ្គលពួកខ្លះ ។ ម្យ៉ាងទៀត បុគ្គលពួកខ្លះ រមែងកាន់យក គាប់ចិត្តថា រូបទាំងនេះ គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត តែបុគ្គលខ្លះទៀត កាន់យករូបទាំងនោះឯង តាមដែលមិនពេញចិត្តថា រូបទាំងនោះ មិនគួរប្រាថ្នា មិនគួរស្រឡាញ់ មិនគួរពេញចិត្ត ហេតុនោះ ឈ្មោះថា រូបដែលជាឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ដែលចែកទុកចំពោះ ទើបមិនមាន ។ ពិតហើយ ជនទ្វេទទាំងឡាយ រមែងជាវត្ថុគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្តរបស់ពួកបុគ្គលដែលនៅក្នុងបច្ចន្តប្បទេស

តែជារបស់គួរខ្ពើមក្រៃលែងរបស់ពួកជនដែលនៅក្នុងមជ្ឈិមប្បទេស ។ ម្យ៉ាងទៀត សាច់របស់ក្ងោកជាដើម រមែងជាវត្ថុគួរប្រាថ្នារបស់បុគ្គលដែលនៅក្នុងមជ្ឈិមប្បទេសប៉ុណ្ណោះ តែជាទីខ្ពើមរអើមនៃបុគ្គលក្នុងបច្ចន្តប្បទេស ដូច្នេះ ។

គប្បីសួរអាចារ្យវិតណ្ឌវាទីនោះថា លោកម្ចាស់ពោលថា ឈ្មោះថា រូបដែលជាឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ដែលទ្រង់ចែកចំពោះ មិនមាន ដូច្នេះឬ អាចារ្យវិតណ្ឌវាទីនោះ ក៏នឹងពោលថា ពិតហើយ ខ្ញុំពោលថា មិនមាន ។ ហើយបញ្ឆាក់យ៉ាងនោះឯងទៀត អស់វារៈ ៣ ដង ហើយគួរសួរថា ធម្មតាព្រះនិព្វាន ជាឥដ្ឋារម្មណ៍ ឬអនិដ្ឋារម្មណ៍ ។ អាចារ្យវិតណ្ឌវាទី កាលជ្រាបក៏នឹងប្រាប់ថាជាឥដ្ឋារម្មណ៍ បើអាចារ្យវិតណ្ឌវាទីនោះឆ្លើយមិនបាន អាចារ្យសកវាទីក៏មិនគប្បីប្រាប់ តែព្រះនិព្វានជាឥដ្ឋារម្មណ៍តែម្យ៉ាងប៉ុណ្ណោះ គប្បីពោលបន្តថា បុគ្គលពួកមួយ កាលមានបុគ្គលណាម្នាក់ ពោលដល់គុណនៃព្រះនិព្វាន ក៏នឹងក្រោធ ហើយសួរថា លោកពោលសរសើរព្រះនិព្វានក្នុងនិព្វាននោះមានបាយទឹក មានផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក គ្រឿងស្លៀកដណ្តប់ មានកាមគុណ ៥ សម្រេចព្រមហើយឬ កាលបុគ្គលនោះពោលថា មិនមាន ក៏នឹងគប្បីពោលថា កុំឡើយ ដោយនិព្វានរបស់លោក កាលបុគ្គលនោះពោលសរសើរនិព្វានតទៅ ក៏ក្រោធ យកដៃបិទត្រចៀកទាំង ២ ព្រោះហេតុនោះ និព្វាននោះ ជាឥដ្ឋារម្មណ៍ឬ ដោយសេចក្តីនោះ ( ឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ដែលចែកចំពោះដោយចំណែកមួយ មិនមាន ) នេះ និព្វានក្នុងវាទៈរបស់លោក រមែងឈ្មោះថា ជាអនិដ្ឋា-

ម្មណ៍ តែបុគ្គលណាម្នាក់ មិនគប្បីកាន់យកពាក្យរបស់វិតណ្ឌវាទីនោះយ៉ាង នេះ ព្រោះបុគ្គលនេះ រមែងពោលដោយសម្គាល់វិបរិតថា អារម្មណ៍នោះឯង ជាឥដ្ឋារម្មណ៍ ដល់បុគ្គលពួកខ្លះ ជាអនិដ្ឋារម្មណ៍ ដល់បុគ្គលពួកខ្លះ ដោយ សញ្ញាវិបល្លាស តែឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ដែលចែកចំពោះ មាន ។

សួរថា ចែកដោយអំណាចអ្នកណា ឆ្លើយថា ដោយអំណាចនៃសត្វ ដែលជាកណ្តាល ។ ពិតហើយ ឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍នេះ មិនបាន ចែកដោយអំណាចឥស្សរជន ដែលធំក្រៃលែង ដូចព្រះបាទមហាសម្មតៈ ព្រះបាទមហាសុទស្សនៈ និងព្រះបាទធម្មាសោករាជជាដើម ព្រោះអារម្មណ៍ ប្រៀបជាមួយរបស់ដែលជាទិព្វ ក៏ប្រាកដជារបស់មិនគួរពេញចិត្ត ដល់ជន ទាំងនោះ ។ ទាំងមិនបានចែកដោយអំណាចនៃបុគ្គល ដែលមានទុក្ខលំបាក ក្រៃលែងដែលរកបាយ និងទឹកបានដោយលំបាក ព្រោះជនដែលមានទុក្ខច្រើន ក្រៃលែងទាំងនោះ សូម្បីតែបាយចុងអង្ករ ឬសាច់ស្អុយ ក៏ជាអាហារឆ្ងាញ់ ក្រៃលែងដូចគ្នានឹងអមតរស តែទ្រង់ចែកដោយអំណាចជនជាកណ្តាល ដូច ជាមេស្រុក មហាមាត្យ សេដ្ឋី កុដុម្ពិកៈ និងអ្នកជំនួញជាដើម ដែល ជួនកាល បាននូវឥដ្ឋារម្មណ៍ ជួនកាល ក៏បាននូវអនិដ្ឋារម្មណ៍ ព្រោះជន ជាកណ្តាលបែបនេះ អាចកំណត់ឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍បាន ។

តែព្រះចូឡនាគត្ថេរ ជាអ្នកទ្រទ្រង់ព្រះត្រៃបិដកពោលថា ធម្មតា ឥដ្ឋា-រម្មណ៍ និងអនិដ្ឋារម្មណ៍ កំណត់បានដោយអំណាចវិបាកប៉ុណ្ណោះ មិនមែន កំណត់ដោយអំណាចជវនចិត្ត តែជវនចិត្តរមែងត្រេកអរក្នុងឥដ្ឋារម្មណ៍ រមែង

មិនត្រេកអរក្នុងឥដ្ឋារម្មណ៍ រមែងត្រេកអរក្នុងអនិដ្ឋារម្មណ៍ រមែងមិនត្រេក-អរក្នុងអនិដ្ឋារម្មណ៍នោះឯង ដោយសញ្ញាវិបល្លាស ដូច្នេះ ។ ឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍នេះ រមែងកំណត់ដោយអំណាចនៃវិបាកដោយចំណែកមួយប៉ុណ្ណោះ ព្រោះបុគ្គលណាម្នាក់ មិនអាចកន្លងវិបាកចិត្តបានឡើយ បើជាឥដ្ឋារម្មណ៍ កុសលវិបាករមែងកើតឡើង បើជាអនិដ្ឋារម្មណ៍ អកុសលវិបាករមែងកើតឡើង ។ ពិតហើយ ពួកមិច្ឆាទិដ្ឋិឃើញព្រះពុទ្ធ ឬព្រះសង្ឃ ឬឃើញអារម្មណ៍ដ៏ឱឡារ មានមហាចេតិយជាដើម រមែងបិទភ្នែក រមែងដល់នូវទោមនស្ស ឬស្ដាប់សំឡេងសម្ដែងធម៌ក៏រមែងបិទត្រចៀកក៏ពិត តែវិញ្ញាណទាំងឡាយ មានចក្ខុវិញ្ញាណ និងសោតវិញ្ញាណជាដើមរបស់ពួកមិច្ឆាទិដ្ឋិទាំងនោះ រមែងជាកុសលវិបាកប៉ុណ្ណោះ ។ សត្វទាំងឡាយដែលបរិភោគលាមកមានជ្រូកជាដើម ហិតក្លិនលាមកហើយ ក៏កើតសេចក្ដីត្រេកអរថា អញនឹងបានទំពាស៊ី ដូច្នេះក៏ពិត តែក្នុងការឃើញលាមក ចក្ខុវិញ្ញាណរបស់ពួកជ្រូកក៏ជាអកុសលវិបាកប៉ុណ្ណោះ ក្នុងការហិតក្លិន ឃានវិញ្ញាណរបស់ជ្រូក ក៏ជាអកុសលវិបាក ក្នុងការលិទ្ធភក្ស ជិវ្ហាវិញ្ញាណរបស់ជ្រូកក៏ជាអកុសលវិបាកនោះឯង ។ ជ្រូកដែលចងឲ្យដេក លើដំណេកដ៏ប្រសើរ រមែងបន្លឺសំឡេងខ្លាំង ទោមនស្សរបស់ជ្រូក រមែងកើតក្នុងជវនចិត្តប៉ុណ្ណោះ ដោយសញ្ញា-វិបល្លាស កាយវិញ្ញាណរបស់ជ្រូក រមែងជាកុសលវិបាកប៉ុណ្ណោះ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះអារម្មណ៍នោះ ជាឥដ្ឋារម្មណ៍ ។ ម្យ៉ាងទៀត គប្បីជ្រាបភាពដែលឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ប្រាថ្នាដោយ

អំណាចទ្វារ ។ ពិតហើយ លាមកដែលរាវមានសម្ផស្សជាសុខ ជាអនិដ្ឋា-រម្មណ៍ក្នុងចក្ខុទ្វារ និងឃានទ្វារ ជាឥដ្ឋារម្មណ៍ក្នុងកាយទ្វារ ។ កាលបុគ្គលត្រូវវាយដោយកែវមណីរបស់ស្តេចចក្កពត្តិ ត្រូវធ្វើឲ្យតក់ស្លុត លើអណ្តោតមាស កែវមណី និងអណ្តោតមាសជាឥដ្ឋារម្មណ៍ក្នុងចក្ខុទ្វារ ជាអនិដ្ឋារម្មណ៍ក្នុងកាយទ្វារ ព្រោះហេតុអ្វី ព្រោះការកើតឡើងនៃទុក្ខធំ ។ ដោយប្រការដូច្នេះ បណ្ឌិតគប្បីជ្រាបថា ឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ រមែងកំណត់ដោយវិបាកប៉ុណ្ណោះ ដោយចំណែកមួយ ។

ក្នុងបទថា **តំ តំ វា បន** នេះ មិនគប្បីសម្លឹងមើលន័យដែលពោលខាងដើម ។ ព្រះមានព្រះភាគ ទ្រង់មិនចែកការពេញចិត្តតាមសម្បត្តិ តែទ្រង់ចែកការពេញចិត្តតាមបុគ្គល ព្រោះហេតុនោះ ដោយអំណាច **តំ តំ វា បនក** ន័យនោះឯង ទើបព្រះមានព្រះភាគ ត្រាស់ភាពដែលរូបថោកទាប និងរូបប្រណីត ព្រោះអាស្រ័យការប្រៀបធៀបជាលំដាប់ៗ ( ការពេញចិត្តរបស់បុគ្គល ) ។

ពិតហើយ រូបនៃពួកសត្វនរក ឈ្មោះថា រូបដែលថោកទាបបំផុត រូបរបស់នាគ និងគ្រុឌ ក្នុងសត្វតិរច្ឆានទាំងឡាយ ឈ្មោះថា ប្រណីត ព្រោះប្រៀបធៀបនឹងរូបរបស់ពួកសត្វនរកនោះ ។ រូបរបស់នាគ និងគ្រុឌទាំងនោះជារូបថោកទាប រូបប្រេតទាំងឡាយ ឈ្មោះថា ប្រណីត ព្រោះប្រៀបធៀបនឹងរបស់នាគ និងគ្រុឌនោះ ។ រូបរបស់ប្រេតទាំងនោះក៏ជារូបថោកទាប រូបរបស់អ្នកជនបទ ឈ្មោះថា ប្រណីត ព្រោះប្រៀបធៀបនឹងរូបប្រេតនោះ ។

រូបរបស់អ្នកជនបទទាំងនោះក៏ថោកទាប រូបរបស់មេស្រុកទាំងឡាយ ឈ្មោះ ថា ប្រណីត ព្រោះប្រៀបធៀបនឹងរូបរបស់អ្នកជនបទនោះ ។ រូបរបស់ពួក មេស្រុកទាំងនោះ ក៏ជារូបថោកទាប រូបរបស់អ្នកជំក្នុងជនបទ ( មេខេត្ត ) ឈ្មោះថា ប្រណីត ព្រោះប្រៀបធៀបនឹងរូបរបស់មេស្រុកនោះ ។ រូបរបស់ អ្នកជំក្នុងជនបទទាំងនោះ ក៏ជារូបថោកទាប រូបរបស់ស្តេចបទេសរាជទាំង ឡាយ ឈ្មោះថា ប្រណីត ព្រោះប្រៀបធៀបនឹងរូបរបស់អ្នកជំក្នុងជនបទ នោះ ។ រូបរបស់ស្តេចបទេសរាជទាំងនោះ ក៏ជារូបថោកទាប រូបរបស់ ស្តេចចក្កពត្តិ ឈ្មោះថាប្រណីត ព្រោះប្រៀបធៀបនឹងរូបរបស់ស្តេចបទេស-រាជនោះ ។ រូបរបស់ស្តេចចក្កពត្តិនោះ ក៏ជារូបថោកទាប រូបរបស់ភុម្ម-ទេវតា ឈ្មោះថា ប្រណីត ព្រោះប្រៀបធៀបនឹងរូបរបស់ស្តេចចក្កពត្តិនោះ ។ រូបរបស់ពួកភុម្មទេវតាទាំងនោះក៏ជារូបថោកទាប រូបរបស់ស្តេចចាតុម្មហារាជ ឈ្មោះថា ប្រណីត ព្រោះប្រៀបនឹងរូបរបស់ភុម្មទេវតានោះ ។ រូបរបស់ ស្តេចចាតុម្មហារាជទាំងនោះ ក៏ជារូបថោកទាប រូបរបស់ពួកទេវតាជាន់តា-វត្តិង្ស ឈ្មោះថា ប្រណីត ព្រោះប្រៀបធៀបនឹងរូបរបស់ស្តេចចតុម្មហារាជ នោះ ។បេ។ រូបរបស់ពួកទេវតាជាន់អកនិដ្ឋ ឈ្មោះថា ប្រណីតបំផុត ។

[ ៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃទូរទុករូបដូចតទៅ

រូបដែលជាឥត្ថិន្ទ្រិយជាដើម ព្រះមានព្រះភាគទ្រង់ចែកខាងដើមហើយ នោះឯង ក្នុងទុកៈនេះ ត្រាស់សុខុមរូប ថាជាទូររូប ព្រោះជារូបដែលមាន លក្ខណៈយល់បានលំបាក ដោយអត្ថថា កំណត់ជាអារម្មណ៍បានដោយក្រ

ត្រាស់ឱឡារិករូប ថាជាសន្តិកេរូប ព្រោះជារូបដែលមានលក្ខណៈយល់បាន ងាយ ដោយអត្ថថា កំណត់ជាអារម្មណ៍បានងាយ ។ ព្រះមានព្រះភាគ ទ្រង់មិនបានកំណត់ពាក្យថា នេះហៅថា **ទូរេ** រូបសូម្បីក្នុងទីជាទីជាប់ត ត្រង់ទីមានកពឡិង្ការពហារជាទីបំផុត ។ ព្រោះហេតុអ្វី ព្រោះឈ្មោះថា រូបឆ្ងាយមាន ២ យ៉ាង គឺឆ្ងាយដោយលក្ខណៈ និងឆ្ងាយដោយឱកាស ។

ក្នុងទីដែលជាទីបំផុតនៃកពឡិង្ការពហារនោះ មិនបានត្រាស់ពាក្យថា **ទូរេ** ដោយលក្ខណៈ តែត្រាស់ទូរេរូបនោះ ដោយឱកាស ព្រោះហេតុនោះ ទើបមិនត្រាស់ថា **ទូរេ** ។

ព្រះមានព្រះភាគ ទ្រង់មិនបំណងសម្ដែងឱឡារិករូប ថាជារូបឆ្ងាយដោយឱកាស ទើបត្រាស់ពាក្យជាដើមថា **យំ វា បនញ្ញម្បិ** ។ សូម្បីក្នុងនិទ្ទេសនៃពាក្យថា រូបជិត ក៏មានន័យនេះឯង ។

ក្នុងបាលីនោះ បទថា **អនាសន្នេ** កាត់បទជា **ន អាសន្នេ** ។ បទថា **អនុបកដ្ឋេ** បានដល់ ក្នុងទីមិនជិត ។ បទថា **ទូរេ** បានដល់ ក្នុងទីឆ្ងាយ ។ បទថា **អសន្តិកេ** បានដល់ ក្នុងទីមិនមែនជិត ។ បទថា **ឥទំ វុច្ចតិ រូបំ ទូរេ** សេចក្ដីថា សុខុមរូប ១៥ យ៉ាងនេះ ហៅថា រូបឆ្ងាយដោយលក្ខណៈ ចំណែកឱឡារិករូប ១០ យ៉ាង ហៅថា រូបឆ្ងាយដោយឱកាស ដោយអំណាចយេវាបនកន័យ ។ និទ្ទេសនៃពាក្យថា រូបជិត មានអត្ថងាយយល់ហើយ ។

បទថា **ឥទំ វុច្ចតិ រូបំ សន្តិកេ** សេចក្ដីថា ឱឡារិករូប ១០ នេះ ហៅថា រូបជិតដោយលក្ខណៈ ចំណែកសុខុមរូប ១៥ ហៅថា រូបជិតដោយ

ឱកាស ដោយអំណាចយេវាបទកន័យ ។

សួរថា រូបដែលឈ្មោះថា ជិត និងឈ្មោះថា ឆ្ងាយ ដោយអំណាចឱកាសត្រឹមចម្ងាយប៉ុនណា ឆ្លើយថា បើបុគ្គលនិយាយដោយសំឡេងប្រក្រតី ១២ ហត្ថ ឈ្មោះថា ឧបចារៈដោយការបានឮ ។ រូបខាងក្នុងនៃឧបចារៈដោយការបានឮនោះ ជារូបជិត ឆ្ងាយជាងនោះជារូបឆ្ងាយ ។ បណ្ដារូបជិតនិងរូបឆ្ងាយនោះ សុខុមរូប កាលនៅក្នុងទីឆ្ងាយ ឈ្មោះថា ជារូបឆ្ងាយដោយលក្ខណៈ ដោយឱកាស តែកាលនៅក្នុងទីជិត ឈ្មោះថា ជារូបជិត ដោយឱកាសប៉ុណ្ណោះ មិនឈ្មោះថា ជិតដោយលក្ខណៈ ។ ឱឡារិករូប កាលនៅក្នុងទីជិត ឈ្មោះថា ជារូបជិតដោយលក្ខណៈផង ដោយឱកាសផង កាលនៅក្នុងទីឆ្ងាយ ឈ្មោះថា ជារូបឆ្ងាយដោយឱកាសប៉ុណ្ណោះ មិនឈ្មោះថាឆ្ងាយដោយលក្ខណៈ ។

ក្នុងបទថា **តំ តំ វា បន** នេះ មិនគប្បីសម្លឹងមើលន័យដែលមានខាងដើម ព្រោះន័យខាងដើម ជាន័យដែលទ្រង់ចែកស្រេចហើយ ។ តែក្នុងទីនេះ មិនបានចែករូបឆ្ងាយដោយលក្ខណៈ ចែករូបឆ្ងាយដោយឱកាសតែម្យ៉ាង ព្រោះក្នុងខន្ធវិភង្គនិទ្ទេសនេះ ទ្រង់សម្ដែងរូបឆ្ងាយ និងរូបជិត ដោយការប្រៀបធៀបគ្នា ។ ពិតហើយ រូបរបស់ខ្លួន ឈ្មោះថា រូបជិត រូបរបស់អ្នកដទៃសូម្បីកើតខាងក្នុងពោះ ក៏ឈ្មោះថា រូបឆ្ងាយ រូបរបស់អ្នកដទៃដែលកើតក្នុងពោះ ឈ្មោះថា រូបជិត រូបរបស់អ្នកដទៃដែលនៅខាងក្រៅ ឈ្មោះថា រូបឆ្ងាយ ។ រូបរបស់អ្នកដទៃដែលដេកគ្រែជាមួយគ្នា ឈ្មោះថា រូបជិត រូប

របស់អ្នកដទៃ ដែលឈរខាងក្រោយមុខ ឈ្មោះថា រូបឆ្ងាយ រូបខាងក្នុងបរិវេណ ឈ្មោះថា រូបជិត រូបខាងក្រៅបរិវេណ ឈ្មោះថា រូបឆ្ងាយ ។ រូបខាងក្នុងសង្ឃារាម ឈ្មោះថា រូបជិត រូបខាងក្រៅសង្ឃារាម ឈ្មោះថា រូបឆ្ងាយ ។ រូបខាងក្នុងសីមា ឈ្មោះថា រូបជិត រូបខាងក្រៅសីមា ឈ្មោះថា រូបឆ្ងាយ ។ រូបខាងក្នុងស្រុក ឈ្មោះថា រូបជិត រូបខាងក្រៅស្រុក ឈ្មោះថា រូបឆ្ងាយ ។ រូបខាងក្នុងជនបទ ឈ្មោះថា រូបជិត រូបខាងក្រៅជនបទ ឈ្មោះថា រូបឆ្ងាយ ។ រូបខាងក្នុងរដ្ឋសីមា ឈ្មោះថា រូបជិត រូបខាងក្រៅរដ្ឋសីមា ឈ្មោះថា រូបឆ្ងាយ ។ រូបខាងក្នុងសមុទ្ទ ឈ្មោះថា រូបជិត រូបខាងក្រៅសមុទ្ទ ឈ្មោះថា រូបឆ្ងាយ ។ រូបខាងក្នុងចក្កវាឡ ឈ្មោះថា រូបជិត រូបខាងក្រៅចក្កវាឡ ឈ្មោះថា រូបឆ្ងាយ ដូច្នេះ ។

**នេះជារូបកណ្ឌនិទ្ទេស**

# វេទនាខន្ធនិទ្ទេស

[ ៨-១៣ ] ក្នុងនិទ្ទេសនៃវេទនាខន្ធជាដើម ខ្ញុំវៀរពាក្យដែលដូចគ្នាតាមដែលពោលហើយខាងដើម អធិប្បាយចំពោះពាក្យ ដែលមិនទាន់អធិប្បាយប៉ុណ្ណោះ ។

បទថា **យា កាចិ វេទនា** បានដល់ ទ្រង់កាន់យកវេទនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ បទថា **សុខា វេទនា** ជាដើម ព្រះមានព្រះភាគ ត្រាស់ដើម្បីសម្តែងវេទនា ដែលទ្រង់អធិប្បាយដោយអំណាចវេទនាជាអតីតជាដើម ដោយសភាវៈ ។ បណ្តាសុខវេទនាជាដើមនោះ សុខវេទនាផ្លូវកាយក៏មាន សុខវេទនាផ្លូវចិត្តក៏មាន ទុក្ខវេទនាក៏យ៉ាងនោះ ។ ឯអទុក្ខមសុខ-វេទនា ដែលត្រាស់ថា ប្រព្រឹត្តទៅផ្លូវកាយក៏មាន ដោយអម សំដៅដល់ក្រុមបសាទ មានចក្ខុជាដើម ប្រព្រឹត្តទៅផ្លូវចិត្តក៏មាន ។ បណ្តាវេទនាទាំងនោះ វេទនាដែលប្រព្រឹត្តទៅផ្លូវកាយទាំងអស់ ជាកាមាវចរ ទុក្ខវេទនាផ្លូវចិត្ត ក៏ជាកាមាវចរដូចគ្នា តែសុខវេទនាផ្លូវចិត្តប្រព្រឹត្តទៅក្នុងភូមិ ៣ អទុក្ខ-មសុខវេទនាជាដើម ប្រព្រឹត្តទៅក្នុងភូមិ ៤ គប្បីជ្រាបភាពដែលវេទនាមានប្រការទាំងអស់នោះជាអតីតជាដើម ដោយអំណាចសន្តតិ និងដោយអំណាចខណៈជាដើម ។

បណ្តាវេទនាទាំងនោះ ពោលដោយអំណាចសន្តតិ វេទនាដែលទាក់ទងក្នុងវិថីជាមួយគ្នា ក្នុងជវនជាមួយគ្នា ក្នុងសមាបត្តិជាមួយគ្នា និងប្រព្រឹត្តទៅដោយប្រកបនៅក្នុងអារម្មណ៍ជាមួយគ្នា ឈ្មោះថា វេទនាបច្ចុប្បន្ន វេទនាមុនបច្ចុប្បន្ន ឈ្មោះថា វេទនាអតីត វេទនាក្រោយបច្ចុប្បន្ន ឈ្មោះថា

វេទនាអនាគត ។ ពោលដោយអំណាចខណៈជាដើម វេទនាដែលទាក់ទង ក្នុងខណៈទាំង ៣ វេទនាដែលដល់កណ្តាលនៃខាងដើម និងខាងចុង និង វេទនាដែលកំពុងធ្វើកិច្ចរបស់ខ្លួន ឈ្មោះថា វេទនាបច្ចុប្បន្ន វេទនាមុននោះ ឈ្មោះថា វេទនាអតីត វេទនាក្រោយបច្ចុប្បន្ននោះ ឈ្មោះថា វេទនាអនាគត ។ ក្នុងអធិការនេះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់ធ្វើនិទ្ទេស នេះ សំដៅយកវេទនាអតីតជាដើម ដោយអំណាចខណៈជាដើម ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងនិទ្ទេសនៃវេទនាគ្រោតគ្រាត និងវេទនាល្អិត ដូចតទៅ

បទថា **អកុសលា វេទនា** ជាដើម ព្រះមានព្រះភាគ ត្រាស់ដើម្បី សម្តែងភាពជាវេទនាគ្រោតគ្រាត និងវេទនាល្អិតដោយជាតិ ។ បទថា **ទុក្ខា វេទនា ឱឡារិកា** ជាដើម ទ្រង់ត្រាស់ដើម្បីសម្តែងវេទនាគ្រោតគ្រាត និង វេទនាល្អិតដោយសភាវៈ ។ បទថា **អសមាបន្នស្ស វេទនា** ជាដើម ទ្រង់ ត្រាស់ដើម្បីសម្តែងភាពជាវេទនាគ្រោតគ្រាត និងល្អិតដោយបុគ្គល ។ បទថា **សាសវា** ជាដើម ទ្រង់ត្រាស់ដើម្បីសម្តែងភាពជាវេទនាគ្រោតគ្រាត និង ល្អិត ដោយលោកិយ និងលោកុត្តរ ។

បណ្តាវេទនាទាំងនោះ វេទនាដែលជាអកុសល ឈ្មោះថា ជាវេទនា គ្រោតគ្រាត ដោយអត្ថថា មានសេចក្តីក្រវល់ក្រវាយ និងដោយអត្ថថា មាន ទុក្ខជាវិបាក ។ វេទនាដែលជាកុសល ឈ្មោះថា វេទនាល្អិត ដោយអត្ថថា មិនមានសេចក្តីក្រវល់ក្រវាយ និងដោយអត្ថថា មានសុខជាវិបាក ។ វេទនា

ដែលជាអព្យាកតៈ ឈ្មោះថា វេទនាល្អិត ដោយអត្ថថា មិនមានឧស្សាហៈ និងដោយអត្ថថា មិនមានវិបាក ។ វេទនាដែលជាកុសល និងវេទនាដែលជាអកុសល ឈ្មោះថា វេទនាគ្រោតគ្រាត ដោយអត្ថថា មានឧស្សាហៈ និងដោយអត្ថថា មានវិបាក ។ វេទនាដែលជាអព្យាកតៈ ឈ្មោះថា វេទនាល្អិត ដោយន័យដែលពោលហើយនោះឯង ។ ទុក្ខវេទនា ឈ្មោះថា វេទនាគ្រោតគ្រាត ដោយអត្ថថា មិនមានសេចក្តីត្រេកអរ និងដោយអត្ថថា ជាទុក្ខ ។ សុខវេទនា ឈ្មោះថា វេទនាល្អិត ដោយអត្ថថា មានសេចក្តីត្រេកអរ និងដោយអត្ថថា ជាសុខ ។ អទុក្ខមសុខវេទនា ឈ្មោះថា វេទនាល្អិត ដោយអត្ថថា ស្ងប់ និងដោយអត្ថថា ប្រណីត ។ សុខវេទនា និងទុក្ខវេទនា ឈ្មោះថា វេទនាគ្រោតគ្រាត ដោយអត្ថថា ញាប់ញ័រ និងដោយអត្ថថា ផ្សាយចេញទៅ ។ ពិតហើយ សូម្បីសុខវេទនាក៏ញាប់ញ័រ ផ្សាយចេញទៅ សូម្បីទុក្ខវេទនាក៏ដូចគ្នា ។ ព្រោះសុខវេទនា កាលកើត រមែងញុំាងសរីរៈទាំងមូល ឲ្យញាប់ញ័រ ឲ្យរញ្ជួយ ឲ្យកក្រើករំពើក ឲ្យស្រើង ឲ្យត្រេកអរ កើតឡើងដូចស្រោចដោយទឹកត្រជាក់អំពីក្អម ។ ទុក្ខវេទនា កាលកើតឡើង រមែងកើតឡើង ដូចជាពេលដែលដាក់កាជនៈក្តៅទុកខាងក្នុង និងដូចយកគប់ភ្លើងស្មៅដែលដុតខាងក្រៅ ។ ចំណែកអទុក្ខមសុខវេទនា ឈ្មោះថា វេទនាល្អិត ដោយន័យដែលពោលហើយ ។ វេទនារបស់បុគ្គល ដែលមិនចូលសមាបត្តិ ឈ្មោះថា វេទនាគ្រោតគ្រាត ព្រោះថា ចិត្តរសាត់ទៅក្នុងអារម្មណ៍ផ្សេងៗ វេទនារបស់បុគ្គល ដែលចូលសមាបត្តិ ឈ្មោះថា វេទនាល្អិត

ព្រោះត្រាច់ទៅក្នុងនិមិត្តដែលមានសភាពតែមួយ ( ឯកគ្គតា ) នោះឯង ។ វេទនាដែលជាអារម្មណ៍របស់អាសវៈ ឈ្មោះថា វេទនាគ្រោតគ្រាត ព្រោះជាហេតុនៃកាកើតឡើងរបស់អាសវៈ ។ ឈ្មោះថា ភាវៈនៃអាសវៈ រមែងជាសភាវៈគ្រោតគ្រាតដោយចំណែក ១ ។ វេទនាដែលមិនជាអារម្មណ៍របស់អាសវៈ ឈ្មោះថា វេទនាល្អិត ដោយបរិយាយផ្ទុយគ្នានឹងពាក្យដែលពោលហើយ ។

បណ្តាវេទនាគ្រោតគ្រាត និងល្អិតទាំងនោះ បុគ្គលខ្លះមិនឈ្លាសក្នុងកុសលត្តិកៈ មិនឈ្លាសក្នុងវេទនាតិកៈ ។ បុគ្គលនោះបំណងនឹងរក្សាកុសលត្តិកៈ រមែងទម្លាយវេទនាតិកៈ បំណងនឹងរក្សាវេទនាតិកៈរមែងទម្លាយកុសលត្តិកៈ បុគ្គលខ្លះបំណងនឹងរក្សាតិកៈ រមែងទម្លាយធម៌ក្ខមិដទៃ ។ បុគ្គលខ្លះ រមែងមិនទម្លាយ ។ សេចក្តីនេះ ដូចម្តេច ព្រះមានព្រះភាគ ត្រាស់ទុកក្នុងវេទនាតិកៈថា សុខវេទនា និងទុក្ខវេទនា ជាវេទនាគ្រោតគ្រាត អទុក្ខមសុខវេទនា ជាវេទនាល្អិត ដូច្នេះ ព្រះតម្រាស់នោះ បុគ្គលពួកខ្លះរមែងជំទាស់ថា អទុក្ខមសុខវេទនាទាំងអស់ មិនមែនជាវេទនាល្អិត ព្រោះអទុក្ខមសុខវេទនានោះ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន បណ្តាអទុក្ខមសុខវេទនា ៣ ប្រភេទនោះ អទុក្ខមសុខវេទនា ដែលជាកុសល និងអកុសលជាវេទនាគ្រោតគ្រាត ដែលជាអព្យាកតៈ ជាវេទនាល្អិត ព្រោះហេតុអ្វី ព្រោះថា ដែលវេទនានោះមកក្នុងព្រះបាលី ក្នុងពួកកុសលត្តិកៈហើយ ។ ដោយអាការយ៉ាងនេះ បុគ្គលនោះរមែងរក្សាកុសលត្តិកៈ តែទម្លាយវេទនាតិកៈ ។

សូម្បីក្នុងព្រះតម្រាស់ដែលត្រាស់ទុក ក្នុងកុសលត្តិកៈថា កុសលវេទនា និងអកុសលវេទនា ជាវេទនាគ្រោតគ្រាត អព្យាកតវេទនា ជាវេទនាល្អិត ព្រះតម្រាស់នោះ បុគ្គលខ្លះក៏ជំទាស់ថា អព្យាកតវេទនាទាំងអស់ មិនមែនវេទនាល្អិត ព្រោះអព្យាកតវេទនានោះ ជាសុខក៏មាន ជាទុក្ខក៏មាន ជាអទុក្ខមសុខក៏មាន ។ បណ្ដាអព្យាកតវេទនា ៣ ប្រភេទនោះ អព្យាកតវេទនាដែលជាសុខ និងជាទុក្ខ ជាវេទនាគ្រោតគ្រាត ដែលជាអទុក្ខមសុខជាវេទនាល្អិត ព្រោះហេតុអ្វី ព្រោះថា អព្យាកតវេទនានោះ មកក្នុងព្រះបាលី ក្នុងវេទនាតិកៈហើយ ។ ដោយអាការយ៉ាងនេះ បុគ្គលនោះរមែងរក្សាវេទនាតិកៈ តែទម្លាយកុសលត្តិកៈ ។ កាលបុគ្គលមិនដាក់ចិត្តក្នុងវេទនាតិកៈ ក្នុងទីមានកុសលត្តិកៈ មិនដាក់ចិត្តក្នុងកុសលត្តិកៈ ក្នុងទីមានវេទនាតិកៈ ពោលភាពដែលកុសលជាដើម ជាវេទនាគ្រោតគ្រាត និងវេទនាល្អិត ដោយលក្ខណៈនៃកុសលត្តិកៈ និងភាពដែលសុខវេទនាជាដើម ជាវេទនាគ្រោតគ្រាត និងល្អិត ដោយលក្ខណៈនៃវេទនាតិកៈ ឈ្មោះថា រមែងមិនទម្លាយ ។

ក្នុងព្រះតម្រាស់ ដែលត្រាស់ក្នុងកុសលត្តិកៈថា វេទនាដែលជាកុសល និងអកុសល ជាវេទនាគ្រោតគ្រាត អព្យាកតវេទនា ជាវេទនាល្អិត បុគ្គលខ្លះ រមែងពោលថា វេទនាដែលជាកុសល ទោះបីជាលោកុត្តរវេទនា ក៏ឈ្មោះថា វេទនាគ្រោតគ្រាត វេទនាដែលជាវិបាក ដោយហោចសូម្បីវេទនាដែលកើតព្រមជាមួយនឹងទ្វិបញ្ចវិញ្ញាណ ឈ្មោះថា វេទនាល្អិត បុគ្គលនោះធ្វើលោកុត្តរវេទនាដែលស្ងប់ប្រណីតបែបនេះ ឲ្យជាវេទនាគ្រោតគ្រាត ធ្វើ

វេទនាដែលសម្បយុត្តដោយទ្វិបញ្ចវិញ្ញាណដែលជាអហេតុកៈ ដែលជាវេទនាថោកថយ ឲ្យជាវេទនាល្អិត បំណាំងនឹងវក្សាតិកៈ ឈ្មោះថា រមែងទម្លាយធម៌ភូមិដទៃ តែបុគ្គលកាលពោលប្រកបកុសលក្នុងភូមិនោះៗ ជាមួយនឹងវិបាកក្នុងភូមិនោះៗ ឈ្មោះថា រមែងមិនទម្លាយ ។

បណ្តាន័យទាំងនោះ មានន័យដែលគប្បីជ្រាបដូចតទៅ

ពិតហើយ បុគ្គលកាលពោលដោយទំនងនេះថា វេទនាដែលជាកាមាវចរកុសល ជាវេទនាគ្រោតគ្រាត វេទនាដែលជាកាមាវចរវិបាក ជាវេទនាល្អិត វេទនាដែលជារូបាវចរកុសល អរូបាវចរកុសល និងលោកុត្តរកុសល ជាវេទនាគ្រោតគ្រាត វេទនាដែលជារូបាវចរវិបាក អរូបាវចរវិបាក និងលោកុត្តរវិបាក ជាវេទនាល្អិត ឈ្មោះថា រមែងមិនទម្លាយ តែព្រះចូឡនាគត្ថេរដែលទ្រទ្រង់ព្រះត្រៃបិដក ពោលថា ក្នុងអកុសល មិនគួរលើកឈ្មោះវេទនាថា គ្រោតគ្រាត និងល្អិត ព្រោះអកុសលនោះជាសភាវៈគ្រោតគ្រាត ដោយចំណែកមួយប៉ុណ្ណោះ សូម្បីក្នុងលោកុត្តរ ក៏មិនគួរលើកភាពដែលវេទនានោះជាវេទនាគ្រោតគ្រាត និងល្អិត ព្រោះលោកុត្តរនោះ ជាសភាវៈល្អិតដោយចំណែកមួយ ដូច្នេះ ។ ពួកអន្តេវាសិក បាននាំពាក្យនេះមកប្រាប់ដល់ព្រះចូឡាភយត្ថេរ ដែលទ្រទ្រង់ព្រះត្រៃបិដកថា ព្រះថេរៈពោលយ៉ាងនេះ ។

ឯព្រះចូឡាភយត្ថេរដែលទ្រទ្រង់ព្រះត្រៃបិដក ពោលថា ព្រះសម្មាសម្ពុទ្ធត្រាស់ព្រះអភិធម្មទុកហើយ ឈ្មោះថា ការមិនបានប្រទានន័យ ក្នុងទីដែលគួរប្រទាន ការមិនបានធ្វើន័យក្នុងទីដែលគួរធ្វើន័យ ក្នុងមួយបទក្តី បទពីរក្តី

មកហើយ រមែងមិនមាន តែភិក្ខុរូបខ្លះក្នុងធម្មវិន័យនេះ ត្រាច់ពោលថា ខ្ញុំជាអាចារ្យ កាលនឹងលើកភាពដែលវេទនាក្នុងអកុសលជាវេទនាគ្រោតគ្រាតនិងល្អិតឡើងក៏វង្វេង តែព្រះសម្មាសម្ពុទ្ធ ទ្រង់លើកភាពដែលវេទនាទាំងនោះ ជាវេទនាគ្រោតគ្រាត និងល្អិត ទុកក្នុងលោកុត្តរនោះឯង កាលពោលយ៉ាងនេះហើយ ក៏លើកព្រះសូត្រ ( ក្នុងទីឃនិកាយ បាដិកវគ្គ ) មកថា បពិត្រព្រះអង្គដ៏ចម្រើន បដិបទានេះឯង រមែងប្រាកដថា ថោកទាបដោយចំណែកទាំងពីរ គឺប្រកបដោយសេចក្ដីលំបាកផង យឺតយូរផង ដូច្នេះ ។ សេចក្ដីពិត ក្នុងព្រះសូត្រនេះ ត្រាស់បដិសម្ភិទា ៤ ជាបដិបទាលាយឡំគ្នាដោយលោកិយផង ដោយលោកុត្តរផង ។

បទថា **តំ តំ វា បន** នេះ មិនគប្បីសម្ងឹងដល់ន័យដែលត្រាស់ខាងដើម ។ បណ្ឌិតគប្បីពោលដោយអំណាចនៃ **តំ តំ វា បនក** ន័យប៉ុណ្ណោះ ។

ពិតហើយ វេទនាដែលជាអកុសល មាន ២ យ៉ាង គឺវេទនាដែលសហគតៈដោយលោភៈ និងវេទនាដែលសហគតៈដោយទោសៈ ។ ក្នុងវេទនាទាំង ២ នោះ វេទនាដែលសហគតៈដោយទោសៈ ជាវេទនាគ្រោតគ្រាតដែលសហគតៈដោយលោភៈ ជាវេទនាល្អិត វេទនាដែលសហគតៈដោយទោសៈ ក៏មាន ២ យ៉ាង គឺនិយតវេទនា ១ អនិយតវេទនា ១ ។ បណ្ដាវេទនាទាំង ២ នោះ និយតវេទនា ជាវេទនាគ្រោតគ្រាត អនិយតវេទនាជាវេទនាល្អិត និយតវេទនាដែលតាំងនៅអស់កប្បជាវេទនាគ្រោតគ្រាត ដែល

មិនតាំងនៅអស់កប្ប ជាវេទនាល្អិត ។ វេទនាដែលតាំងនៅដរាបអស់កប្ប ដែលជាអសង្ខារិក ក៏ជាវេទនាគ្រោតគ្រាត ដែលជាសសង្ខារិក ក៏ជាវេទនាល្អិត ។

វេទនាដែលសហគតៈដោយលោភៈ មាន ២ យ៉ាង គឺវេទនាដែលសម្បយុត្តដោយទិដ្ឋិ ១ ដែលវិប្បយុត្តចាកទិដ្ឋិ ១ ។ ក្នុងវេទនាទាំង ២ នោះ វេទនាដែលសម្បយុត្តដោយទិដ្ឋិ ជាវេទនាគ្រោតគ្រាត វេទនាដែលមិនវិប្បយុត្តចាកទិដ្ឋិ ជាវេទនាល្អិត ។ វេទនាដែលសម្បយុត្តដោយទិដ្ឋិ ដែលជានិយតក៏ជាវេទនាគ្រោតគ្រាត ដែលជាអនិយត ក៏ជាវេទនាល្អិត វេទនាដែលសម្បយុត្តដោយទិដ្ឋិនោះ ដែលជាអសង្ខារិក ក៏ជាវេទនាគ្រោតគ្រាត ដែលជាសសង្ខារិក ក៏ជាវេទនាល្អិត ។ ពោលដោយសង្ខេប វេទនាណាដល់អកុសល ហើយឲ្យវិបាកច្រើន វេទនានោះ ជាវេទនាគ្រោតគ្រាត ដែលឲ្យវិបាកតិច ជាវេទនាល្អិត ឯវេទនាដែលដល់កុសលហើយឲ្យវិបាកតិច ជាវេទនាគ្រោតគ្រាត ដែលឲ្យវិបាកច្រើន ជាវេទនាល្អិត ។ ក្នុងកុសល ៤ យ៉ាង វេទនាដែលជាកាមាវចរកុសល ជាវេទនាគ្រោតគ្រាត វេទនាដែលជារូបាវចរកុសល ជាវេទនាល្អិត វេទនាដែលជារូបាវចរកុសលនោះ ជាវេទនាគ្រោតគ្រាត ដែលជាអរូបាវចរកុសល ជាវេទនាល្អិត ។ វេទនាដែលជាអរូបាវចរកុសលនោះក៏ជាវេទនាគ្រោតគ្រាត វេទនាដែលជាលោកុត្តរកុសល ជាវេទនាល្អិត នេះជាន័យដោយមិនផ្សេងគ្នា ក្នុងភូមិទាំងឡាយ ។

តែពោលដោយន័យដែលផ្សេងគ្នា វេទនាដែលជាកាមាវចរ មាន ៣

យ៉ាង ដោយអំណាចទានមយៈ សីលមយៈ ភាវនាមយៈ ។

បណ្តាវេទនាទាំង ៣ នោះ វេទនាដែលសម្រេចដោយការឲ្យទាន ជាវេទនាគ្រោតគ្រាត វេទនាដែលសម្រេចដោយការរក្សាសីល ជាវេទនាល្អិត វេទនាដែលសម្រេចដោយការរក្សាសីលនោះ ក៏នៅជាវេទនាគ្រោតគ្រាត វេទនាដែលសម្រេចដោយភាវនា ជាវេទនាល្អិត ។ វេទនាដែលសម្រេចដោយភាវនានោះ មាន ២ យ៉ាង គឺជាទុហេតុកៈ ១ តិហេតុកៈ ១ ក្នុង ២ យ៉ាងនោះ វេទនាដែលប្រកបដោយហេតុ ២ ជាវេទនាគ្រោតគ្រាត វេទនាដែលប្រកបដោយហេតុ ៣ ជាវេទនាល្អិត វេទនាដែលប្រកបដោយហេតុ ៣ ក៏មាន ២ យ៉ាង គឺសសង្ខារិក ១ អសង្ខារិក ១ ។ បណ្តាវេទនាទាំង ២ នោះ វេទនាជាសសង្ខារិក ជាវេទនាគ្រោតគ្រាត ដែលជាអសង្ខារិក ជាវេទនាល្អិត ។ ក្នុងរូបាវចរ វេទនាដែលជាបឋមជ្ឈានកុសល ជាវេទនាគ្រោតគ្រាត វេទនាដែលជាទុតិយជ្ឈានកុសល ជាវេទនាល្អិត ។បេ។ វេទនាដែលជាចតុត្ថជ្ឈានកុសល ជាវេទនាល្អិត វេទនាដែលជាចតុត្ថជ្ឈានកុសលនោះក៏នៅគ្រោតគ្រាត វេទនាដែលជាអាកាសានញ្ចាយតនកុសល ជាវេទនាល្អិត វេទនាដែលជាអាកាសានញ្ចាយតនកុសលនោះ ក៏នៅជាវេទនាគ្រោតគ្រាត ។បេ។ វេទនាដែលជានេវសញ្ញានាសញ្ញាយតនកុសល ជាវេទនាល្អិត ។ វេទនាដែលជានេវសញ្ញានាសញ្ញាយតនកុសលនោះក៏នៅគ្រោតគ្រាត វេទនាដែលកើតព្រមជាមួយទីឃវិបស្សនា ជាវេទនាល្អិត វេទនាដែលកើតព្រមជាមួយវិបស្សនានោះ ក៏នៅគ្រោតគ្រាត វេទនាដែលកើតព្រមជាមួយ

សោតាបត្តិមគ្គ ជាវេទនាល្អិត វេទនាដែលកើតព្រមជាមួយសោតាបត្តិមគ្គនោះ ក៏នៅគ្រោតគ្រាត ។បេ។ វេទនាដែលកើតព្រមជាមួយនឹងអរហត្តមគ្គ ជាវេទនាល្អិត ។

ក្នុងវិបាក ៤ យ៉ាង វេទនាដែលជាកាមាវចរវិបាក ជាវេទនាគ្រោតគ្រាត វេទនាដែលជារូបាវចរវិបាក ជាវេទនាល្អិត វេទនាដែលជារូបាវចរវិបាកនោះ ក៏ជាវេទនាគ្រោតគ្រាត ។បេ។ វេទនាដែលជាលោកុត្តរវិបាក ជាវេទនាល្អិត នេះជាន័យដោយការមិនផ្សេងគ្នាប៉ុណ្ណោះ ។

បើពោលដោយន័យផ្សេងគ្នា វេទនាដែលជាកាមាវចរវិបាកជាអហេតុកៈក៏មាន ដែលជាសហេតុកៈក៏មាន វេទនាដែលជាសហេតុកៈ មាន ២ គឺវេទនាដែលជាទុហេតុកៈក៏មាន ដែលជាតិហេតុកៈក៏មាន ។

បណ្តាវេទនាទាំងនោះ វេទនាដែលជាអហេតុកៈ ជាវេទនាគ្រោតគ្រាត ដែលជាសហេតុកៈ ជាវេទនាល្អិត ។ វេទនាដែលជាសហេតុកៈនោះ ដែលជាទុហេតុកៈ ជាវេទនាគ្រោតគ្រាត ដែលជាតិហេតុកៈ ជាវេទនាល្អិត ។ ក្នុងវេទនាដែលជាតិហេតុកៈនោះ វេទនាដែលជាសសង្ខារិក ជាវេទនាគ្រោតគ្រាត ដែលជាអសង្ខារិក ជាវេទនាល្អិត វេទនាដែលជាបឋមជ្ឈានវិបាក ជាវេទនាគ្រោតគ្រាត ដែលជាទុតិយជ្ឈានវិបាក ជាវេទនាល្អិត ។បេ។ ដែលជាចតុត្ថជ្ឈានវិបាក ជាវេទនាល្អិត ។ វេទនាដែលជាចតុត្ថជ្ឈានវិបាកនោះ ក៏នៅគ្រោតគ្រាត វេទនាដែលជារបស់អាកាសានញ្ចាយតនវិបាក ជាវេទនាល្អិត ។ វេទនាដែលជាអាកាសានញ្ចាយតនវិបាកនោះក៏នៅគ្រោតគ្រាត ។បេ។ វេទនា

ដែលជានេវសញ្ញានាសញ្ញាយតនវិបាក ជាវេទនាល្អិត វេទនាដែលជានេវ-សញ្ញានាសញ្ញាយតនវិបាកនោះ ក៏នៅជាវេទនាគ្រោតគ្រាត វេទនាដែលកើតព្រមជាមួយសោតាបត្តិផល ជាវេទនាល្អិត វេទនាដែលកើតព្រមជាមួយនឹងសោតាបត្តិផលនោះ ក៏នៅជាវេទនាគ្រោតគ្រាត វេទនាដែលកើតព្រមជាមួយសកទាគាមិផល ជាវេទនាល្អិត ។បេ។ វេទនាដែលកើតព្រមជាមួយអរហត្ត-ផល ជាវេទនាល្អិត ។

បណ្ដាកិរិយាទាំង ៣ ភូមិ វេទនាដែលជាកាមាវចរកិរិយា ជាវេទនាគ្រោតគ្រាត វេទនាដែលជារូបាវចរកិរិយា ជាវេទនាល្អិត វេទនាដែលជារូបាវចរកិរិយានោះ ក៏នៅគ្រោតគ្រាត វេទនាដែលជាអរូបាវចរកិរិយា ជាវេទនាល្អិត នេះជាន័យដោយការមិនផ្សេងគ្នា ។

តែបើពោលដោយន័យដែលផ្សេងគ្នា ក្នុងកាមាវចរកិរិយា ដែលចែកទុកដោយអំណាចវេទនា ដែលជាអហេតុកៈជាដើម វេទនាដែលជាអហេតុក-កិរិយា ជាវេទនាគ្រោតគ្រាត ដែលជាសហេតុកកិរិយា ជាវេទនាល្អិត ។ វេទនាដែលជាសហេតុកកិរិយានោះ ដែលជាទុហេតុកៈ ក៏ជាវេទនាគ្រោតគ្រាត ដែលជាតិហេតុកៈ ជាវេទនាល្អិត ។ ក្នុងវេទនាដែលជាតិហេតុកៈនោះ វេទនាដែលជាសសង្ខារិកជាវេទនាគ្រោតគ្រាត ដែលជាអសង្ខារិកជាវេទនាល្អិត ។ វេទនាដែលជាបឋមជ្ឈានកិរិយា ជាវេទនាគ្រោតគ្រាត វេទនាដែលជាទុតិ-យជ្ឈានកិរិយា ជាវេទនាល្អិត ។ វេទនាដែលជាទុតិយជ្ឈានកិរិយានោះ ក៏ជាវេទនាគ្រោតគ្រាត វេទនាដែលជាតតិយជ្ឈានកិរិយាជាវេទនាល្អិត ។បេ។

វេទនាជាចតុត្ថជ្ឈានកិរិយា ជាវេទនាល្អិត ។ វេទនាដែលជាចតុត្ថជ្ឈានកិរិយានោះ ក៏ជាវេទនាគ្រោតគ្រាត វេទនាដែលជាអាកាសានញ្ចាយតនកិរិយា ជាវេទនាល្អិត ។ វេទនាដែលជាអាកាសានញ្ចាយតនកិរិយានោះ ក៏ជាវេទនាគ្រោតគ្រាត វេទនាដែលជាវិញ្ញាណញ្ចាយតនកិរិយា ជាវេទនាល្អិត ។បេ។ វេទនាដែលជានេវសញ្ញានាសញ្ញាយតនកិរិយា ជាវេទនាល្អិត ។ វេទនាណាគ្រោតគ្រាត វេទនានោះថោកទាប ។ វេទនាណាល្អិត វេទនានោះប្រណីត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសវេទនាទូរេទុកៈដូចតទៅ

វេទនាដែលជាអកុសល ឈ្មោះថា វេទនាឆ្ងាយអំពីវេទនាដែលជាកុសល និងអព្យាកតៈ ដោយអត្ថថា មិនស្មើគ្នា និងដោយអត្ថថា មិនទាក់ទងគ្នា ។ បណ្ឌិតគប្បីជ្រាបភាពដែលវេទនាជាសភាវៈឆ្ងាយ ក្នុងបទទាំងពួង ដោយន័យនេះ ។

ពិតហើយ បើបុគ្គល ៣ នាក់ ជាអ្នកដល់ព្រមដោយវេទនាជាអកុសលជាដើម និងដល់ព្រមដោយវេទនា មានទុក្ខជាដើម អង្គុយលើគ្រែជាមួយគ្នាសោត វេទនាទាំងនោះ របស់បុគ្គលទាំងនោះ ក៏ឈ្មោះថា ឆ្ងាយគ្នានោះឯងដោយអត្ថថា មិនស្មើគ្នា និងដោយអត្ថថា មិនទាក់ទងគ្នា ។ ក្នុងបុគ្គលដែលដល់ព្រមដោយវេទនានៃបុគ្គលដែលចូលសមាបត្តិជាដើម ក៏ន័យនេះឯង ។

ឯវេទនាដែលជាអកុសល ឈ្មោះថា វេទនាជិត ដោយអត្ថថា មានចំណែកស្មើគ្នា និងដោយអត្ថថា ដូចអកុសលវេទនា ។ បណ្ឌិតគប្បីជ្រាបភាពដែលវេទនាជាសភាវៈជិត ក្នុងបទទាំងពួង ដោយន័យនេះឯង ។ បើ

បុគ្គល ៣ នាក់ ដល់ព្រមដោយវេទនាដែលជាអកុសលជាដើម បុគ្គលម្នាក់កើតក្នុងកាមភព បុគ្គលម្នាក់កើតក្នុងរូបភព ម្នាក់កើតក្នុងអរូបភព វេទនារបស់បុគ្គលទាំងនោះ ឈ្មោះថា វេទនាជិតគ្នានោះឯង ដោយអត្ថថា ស្មើគ្នានិងដោយអត្ថថា ដូចគ្នា សូម្បីក្នុងបុគ្គលដែលដល់ព្រមដោយកុសលវេទនាជាដើម ក៏ន័យនេះដូចគ្នា ។

ក្នុងបទថា **តំ តំ វា បន** នេះ មិនគប្បីសម្លឹងមើលន័យដែលពោលខាងដើម គប្បីពោលដោយអំណាច **តំ តំ វាបនក** ន័យនោះឯង តែកាលនឹងពោល មិនគួរលើកយកវេទនាអំពីទីឆ្ងាយ មកកាន់ទីជិត តែគប្បីលើកវេទនាអំពីទីឆ្ងាយ ទៅកាន់ទីជិត ដ្បិតថា វេទនាដែលជាអកុសលមាន ២ យ៉ាង គឺវេទនាដែលសហគតៈដោយលោភៈ និងសហគតៈដោយទោសៈ ។ ក្នុងវេទនាទាំង ២ នោះ វេទនាដែលសហគតៈដោយលោភៈ ឈ្មោះថា វេទនាជិតជាមួយវេទនាដែលសហគតៈដោយលោភៈ ឈ្មោះថា វេទនាឆ្ងាយអំពីវេទនាដែលសហគតៈដោយទោសៈ ។ វេទនាដែលសហគតៈដោយទោសៈ ឈ្មោះថា វេទនាជិតជាមួយវេទនាដែលសហគតៈដោយទោសៈ ឈ្មោះថា វេទនាឆ្ងាយអំពីវេទនាដែលសហគតៈដោយលោភៈ ។ សូម្បីវេទនាដែលសហគតៈដោយទោសៈ ដែលជានិយត ឈ្មោះថា វេទនាជិតជាមួយវេទនាដែលជានិយត ដែលជាអនិយតក៏យ៉ាងនោះ ។ គប្បីជ្រាបវេទនាតែមួយចំណែកថា ជាវេទនាជិតជាមួយវេទនាចំណែកនោះៗ និងគប្បីជ្រាបវេទនាក្រៅអំពីនេះ ឈ្មោះថា ជាវេទនាឆ្ងាយអំពីវេទនាក្រៅអំពីនេះ អនុ-

លោមតាមវេទនាទាំងពួង មានវេទនាដែលតាំងនៅអស់មួយកប្ប ដែលជាអសង្ខារិក និងសសង្ខារិក និងដោយវេទនាដែលសម្បយុត្តដោយមានៈ ទិដ្ឋិជាដើម ក្នុងវេទនាដែលសហគតៈដោយលោភៈជាដើម ដោយអំណាចនៃពាក្យដែលខ្ញុំឲ្យពិស្តារហើយ ក្នុងនិទ្ទេសឱឡារិកទុកៈនោះឯង ។

**នេះជាវេទនាខន្ធនិទ្ទេស**

## សញ្ញាខន្ធនិទ្ទេស

[ ១៤-១៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសញ្ញាខន្ធនិទ្ទេសដូចតទៅ

ដោយបទថា **យា កាចិ សញ្ញា** នេះ ព្រះមានព្រះភាគ ទ្រង់កំណត់សញ្ញាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ បទថា **ចក្ខុសម្ផស្សជា សញ្ញា** ជាដើម ត្រាស់ដើម្បីសម្តែងសញ្ញា ដែលទ្រង់លើកឡើងសម្តែងដោយអំណាចសញ្ញាដែលជាអតីតជាដើមដោយសភាវៈ ។ បណ្តាសញ្ញាទាំងនោះ សញ្ញាដែលកើតអំពីចក្ខុសម្ផស្ស ឬក្នុងចក្ខុសម្ផស្ស ឈ្មោះថា ចក្ខុសម្ផស្សជា ។ ក្នុងសញ្ញាដ៏សេសក៏ន័យនេះឯង ។ ក្នុងសញ្ញាទាំង ៦ នោះ សញ្ញា ៥ ខាងដើម មានចក្ខុបសាទជាដើម ជាទីអាស្រ័យកើតដោយចំពោះ ឯមនោសម្ផស្សជាសញ្ញា មានហទយវត្ថុជាទីអាស្រ័យកើតខ្លះ មិនមានហទយវត្ថុជាទីអាស្រ័យកើតខ្លះ សញ្ញាទាំងអស់ប្រព្រឹត្តទៅក្នុងភូមិ ៤ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងឱឡារិកទុកនិទ្ទេសដូចតទៅ

បទថា **បដិឃសម្ផស្សជា** សេចក្តីថា ផស្សៈដែលធ្វើចក្ខុបសាទជាដើម ដែលប៉ះខ្ទប់បាន ឲ្យជាទីអាស្រ័យកើត ប្រារព្ធរូបជាដើមដែលប៉ះខ្ទប់បានកើតឡើង ឈ្មោះថា បដិឃសម្ផស្ស សញ្ញាកើតអំពីបដិឃសម្ផស្សនោះ ឬកើតក្នុងបដិឃសម្ផស្សនោះ ឈ្មោះថា បដិឃសម្ផស្សជា ។ ពាក្យថា សញ្ញាដែលកើតអំពីចក្ខុសម្ផស្ស ។បេ។ សញ្ញាដែលកើតអំពីកាយសម្ផស្ស ក៏ជាឈ្មោះនៃបដិឃសញ្ញានោះឯងដោយវត្ថុ ។ សូម្បីពាក្យថា រូប សញ្ញា ។បេ។ ផោដ្ឋព្វសញ្ញា ក៏ជាឈ្មោះនៃបដិឃសញ្ញានោះឯងដោយអារម្មណ៍ តែពាក្យថា បដិឃសម្ផស្សជានេះ ជាឈ្មោះនៃសញ្ញា ទាំងដោយវត្ថុ និងអារម្មណ៍ ។ ពិតហើយ សញ្ញានេះ ត្រាស់ហៅថា សញ្ញាដែលកើតអំពីបដិឃសម្ផស្ស ព្រោះអាស្រ័យវត្ថុដែលប៉ះខ្ទប់បាន និងប្រារព្ធអារម្មណ៍ដែលប៉ះខ្ទប់បានកើតឡើង ។ ពាក្យថា ដែលកើតអំពីមនោសម្ផស្សនេះ ក៏ជាឈ្មោះរបស់បដិឃ-សញ្ញានេះ ដោយបរិយាយដូចគ្នា ។ ចក្ខុវិញ្ញាណ ឈ្មោះថា **មនោ** ។ ផស្សៈកើតព្រមនឹងមនោនោះ ឈ្មោះថា **មនោសម្ផស្ស** ។ សញ្ញាកើតក្នុងមនោសម្ផស្សនោះ ឬកើតអំពីមនោសម្ផស្សនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **មនោសម្ផស្សជា** ។ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ និងកាយវិញ្ញាណ ក៏ឈ្មោះថា **មនោ** ដូចគ្នា ។ ផស្សៈដែលកើតព្រមជាមួយមនោនោះ ឈ្មោះថា **មនោសម្ផស្ស** សញ្ញាកើតក្នុងមនោសម្ផស្សនោះ ឬកើតអំពីមនោសម្ផស្សនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **មនោសម្ផស្សជា** ។ បទថា **អធិវចនសម្ផស្សជា** ក៏ជាឈ្មោះនៃមនោសម្ផស្សជានេះ ដោយអម

នោះឯង ព្រោះថា នាមក្ខន្ធ ៣ គឺវេទនាខន្ធ សង្ខារខន្ធ និងវិញ្ញាណក្ខន្ធ ជាសភាវៈវិលទៅនៅខាងក្រោយឯង ធ្វើឈ្មោះសញ្ញាដែលកើតព្រមជាមួយខ្លួនថា សញ្ញាដែលកើតអំពីអធិវចនសម្ផស្ស ។

តែបើពោលដោយត្រង់ សញ្ញាដែលប្រព្រឹត្តទៅក្នុងបញ្ចទ្វារ ឈ្មោះថា សញ្ញា ដែលកើតអំពីបដិឃសម្ផស្ស ។ សញ្ញាដែលប្រព្រឹត្តទៅតាមមនោទ្វារ ឈ្មោះថា សញ្ញាដែលកើតអំពីអធិវចនសម្ផស្ស ។ បណ្តាសញ្ញាទាំង ២ នោះ សញ្ញាដែលប្រព្រឹត្តទៅតាមបញ្ចទ្វារ សូម្បីបុគ្គលណាម្នាក់សម្លឹងមើលហើយក៏អាចដឹងបាន ព្រោះហេតុនោះ ទើបជាសញ្ញាដែលគ្រោតគ្រាត ។ ពិតហើយ មនុស្សទាំងឡាយ សម្លឹងមើលបុគ្គលដែលកំពុងត្រេកត្រអាលក៏ដឹងថា បុគ្គលនេះកំពុងត្រេកត្រអាល ឬសម្លឹងមើលបុគ្គលក្រោធក៏ដឹងថា បុគ្គលនេះក្រោធ ដូច្នេះ ក្នុងសេចក្តីនេះ មានរឿងជាបុគ្គលាធិដ្ឋានដូច្នេះ

បានឮថា ស្ត្រី ២ នាក់ កំពុងអង្គុយរវៃអំបោះក្នុងផ្ទះ ភិក្ខុ ២ រូបត្រាច់ទៅក្នុងផ្ទះ មួយរូបដើរខាងមុខ បានឃើញស្ត្រីម្នាក់ ស្រីម្នាក់ទៀតសួរស្រីនោះថា ព្រោះហេតុអ្វីហ្ន៎ ទើបភិក្ខុកំលោះរូបនេះសម្លឹងមើលនាង ដូច្នេះ ស្រីនោះឆ្លើយថា ភិក្ខុនេះមិនមែនសម្លឹងមើលខ្ញុំដោយចិត្តដែលជាវិសភាគារម្មណ៍ទេ តែសម្លឹងមើលដោយសម្គាល់ថាជាប្អូនស្រី ដូច្នេះ កាលភិក្ខុទាំង ២ ត្រាច់បិណ្ឌបាតក្នុងស្រុក ហើយមកអង្គុយត្រង់រោងឆាន់ ភិក្ខុមួយអង្គទៀតសួរភិក្ខុនោះថា លោកម្ចាស់សម្លឹងមើលស្រីនោះឬ ភិក្ខុនោះឆ្លើយថា អើ ខ្ញុំ

សម្លឹងមើល ភិក្ខុនោះសួរថា លោកមើលដើម្បីប្រយោជន៍អ្វី ភិក្ខុនោះឆ្លើយថា ខ្ញុំមើលដោយគិតថា ទារិកានោះដូចប្អូនស្រីរបស់ខ្ញុំ ដោយអាការយ៉ាងនេះ សញ្ញាដែលប្រព្រឹត្តទៅតាមបញ្ចទ្វារ បណ្ឌិតគប្បីជ្រាបថា បុគ្គលណាមួយសម្លឹងមើលហើយ ក៏គប្បីជ្រាបបាន ។ សញ្ញានេះ មានបសាទជាទីតាំងដែលកើតនោះឯង ។ អាចារ្យពួកខ្លះសម្តែងថា សញ្ញានោះ ប្រព្រឹត្តទៅតាមផ្លូវជវន ។ សញ្ញាដែលប្រព្រឹត្តទៅតាមមនោទ្វារ ឈ្មោះថា ជាសញ្ញាល្អិត ព្រោះសញ្ញានោះដែលបុគ្គលគប្បីសួរបុគ្គលដទៃ សូម្បីអង្គុយគិត និងត្រិះរិះលើគ្រែតែមួយ ឬតាំងតែមួយថា លោកគិតអ្វី ត្រិះរិះអ្វី ដូច្នេះ ទើបដឹងបានដោយអំណាចពាក្យប្រាប់នៃបុគ្គលនោះឯង ។ ពាក្យដ៏សេសមានន័យដូចគ្នានឹងវេទនាខន្ធនោះឯង ។

នេះជាសញ្ញាខន្ធនិទ្ទេស

## សង្ខារក្ខន្ធនិទ្ទេស

[ ២០-២៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសង្ខារក្ខន្ធនិទ្ទេសដូចតទៅ

បទថា **យេ កេចិ សង្ខារា** នេះ ព្រះមានព្រះភាគ ទ្រង់កំណត់សង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ បទថា **ចក្ខុសម្ផស្សជា ចេតនា** ជាដើម ព្រះមានព្រះភាគ ត្រាស់ដើម្បីសម្តែងសង្ខារ ដែលទ្រង់លើកឡើងសម្តែងដោយអំណាចសង្ខារដែលជាអតីតជាដើម ដោយសង្ខេប ។ បទថា **ចក្ខុ-សម្ផស្សជា** ជាដើម មានអត្ថតាមដែលពោលហើយនោះឯង ។ បទថា

**ចេតនា** នេះ ព្រះមានព្រះភាគត្រាស់ដោយអំណាចបធានសង្ខារ យ៉ាងទាបបំផុត ព្រោះសង្ខារ ៤ មកក្នុងព្រះបាលីដោយហោចជាមួយចក្ខុវិញ្ញាណ យ៉ាងទាបបំផុត រមែងកើតឡើង បណ្ដាសង្ខារទាំងនោះ ចេតនា ឈ្មោះថា បធាន ព្រោះប្រាកដដោយអត្ថថា ជាហេតុប្រមូលមក ព្រោះហេតុនោះ ចេតនានេះប៉ុណ្ណោះ ទ្រង់កាន់យកហើយ ។ សង្ខារដែលសម្បយុត្តដោយចេតនានោះ ឈ្មោះថា ទ្រង់កាន់យកហើយក្នុងកាលចេតនានោះត្រូវកាន់យកហើយនោះឯង ។ ក្នុងទីនេះ ចេតនា ៥ ខាងដើម មានចក្ខុបសាទជាដើម ជាទីអាស្រ័យកើតតែម្យ៉ាង ចេតនាដែលកើតអំពីមនោសម្ផស្ស មានហទយវត្ថុជាទីអាស្រ័យកើតខ្លះ មិនមានហទយវត្ថុជាទីអាស្រ័យកើតខ្លះ ចេតនាទាំងអស់ ជាចេតនាប្រព្រឹត្តទៅក្នុងភូមិ ៤ ពាក្យដ៏សេសដូចវេទនាខន្ធនោះឯង ។

នេះជាសង្ខារក្ខន្ធនិទ្ទេស

## វិញ្ញាណក្ខន្ធនិទ្ទេស

[ ២៦-៣១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវិញ្ញាណក្ខន្ធនិទ្ទេសដូចតទៅ

បទថា **យំ កិញ្ចិ វិញ្ញាណំ** នេះ ព្រះមានព្រះភាគទ្រង់កំណត់វិញ្ញាណដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ បទថា **ចក្ខុវិញ្ញាណំ** ជាដើម ទ្រង់ត្រាស់ដើម្បីសម្ដែងវិញ្ញាណ ដែលទ្រង់លើកឡើងសម្ដែងដោយអំណាចនៃវិញ្ញាណដែលជាអតីតជាដើម ដោយសភាវៈ ។ ក្នុងព្រះបាលីនេះ វិញ្ញាណ ៥ មានចក្ខុវិញ្ញាណជាដើម មានចក្ខុបសាទជាដើម ជាទីអាស្រ័យកើតនោះឯង ។

មនោវិញ្ញាណ មានហទយវត្ថុដែលជាទីអាស្រ័យកើតខ្លះ មិនមានហទយវត្ថុដែលជាទីអាស្រ័យកើតខ្លះ វិញ្ញាណទាំងអស់ប្រព្រឹត្តទៅក្នុងភូមិ ៤ ។ ពាក្យដ៏សេសដូចគ្នានឹងវេទនាខន្ធនោះឯង ។

**នេះវិញ្ញាណក្ខន្ធនិទ្ទេស**

## បកិណ្ណកកថា

ឥឡូវនេះ គប្បីជ្រាបបកិណ្ណកៈក្នុងខន្ធទាំង ៥ ដោយអាការ ១៦ យ៉ាង គឺដោយសមុគ្គមតោ គឺការកើតដំបូង ១ បុព្វាបរតោ គឺការកើតមុន និងក្រោយ ១ អទ្ធានបរិច្ឆេទតោ គឺកំណត់កាល ១ ឯកុប្បាទនានានិរោធតោ គឺការកើតក្នុងខណៈតែមួយ រលត់ផ្សេងខណៈគ្នា ១ នានុប្បាទឯកនិរោធតោ គឺកើតខណៈខុសគ្នា រលត់ក្នុងខណៈតែមួយ ១ ឯកុប្បាទឯកនិរោធតោ គឺកើតព្រមគ្នា រលត់ព្រមគ្នា ១ នានុប្បាទនានានិរោធតោ គឺកើតមិនព្រមគ្នា រលត់មិនព្រមគ្នា ១ អតីតានាគតប្បច្ចុប្បន្នតោ គឺអតីត អនាគត បច្ចុប្បន្ន ១ អជ្ឈត្តិកពាហិរតោ គឺធម៌ខាងក្នុង និងខាងក្រៅ ១ ឱឡារិកសុខុមតោ គឺសភាវៈគ្រោតគ្រាត និងល្អិត ១ ហីនបណីតតោ គឺជាធម៌ថោកទាប និងប្រណីត ១ ទូរសន្តិកតោ គឺធម៌ឆ្ងាយ និងជិត ១ បច្ចយតោ គឺបច្ច័យ ១ សមុដ្ឋានតោ គឺសមុដ្ឋាន ១ បរិនិប្ផន្នតោ គឺការសម្រេច ១ សង្ខតតោ គឺមានបច្ច័យតាក់តែង ១ ។

បណ្ដាបកិណ្ណកៈទាំងនោះ ពាក្យថា ដោយការកើតឡើងដំបូងនេះ ការ

កើតឡើងដំបូងមាន ២ យ៉ាង គឺការកើតឡើងដំបូងរបស់គព្ភសេយ្យកសត្វ និងការកើតឡើងគ្រាដំបូងរបស់ឱបបាតិកសត្វ ។ បណ្តាការកើត ២ នោះ គប្បីជ្រាបការកើតឡើងដំបូងនៃគព្ភសេយ្យកសត្វយ៉ាងនេះ ពិតហើយ ខន្ធ ៥ នៃគព្ភសេយ្យកសត្វ រមែងប្រាកដព្រមគ្នា មិនមុន មិនក្រោយ ក្នុងបដិសន្ធិក្ខណៈ សេចក្តីនេះលោកពោលថា ការបន្តនៃរូប ពោល គឺកលលៈ ដែលប្រាកដក្នុងខណៈនោះ ជារបស់បន្តិចបន្តួច ល្មមតែរុយមួយ ផឹកបាន ដោយការព្យាយាមត្រឹមតែម្តងប៉ុណ្ណោះ ហើយពោលទៀតថា ទុំះក៏នៅច្រើន ពេក កលលៈ មានប្រមាណប៉ុនតំណក់ទឹកនោះ ដែលហូរចេញហើយជាប់ត្រង់ចុងម្ជុល ដែលតូចឆ្មារ ដែលគេជ្រលក់ក្នុងប្រេង ហើយលើកឡើង ។ តំណក់ប្រេងនោះក៏លោកបដិសេធថា កាលគេយកសក់មួយសរសៃជ្រលក់ ហើយលើកឡើងអំពីប្រេង កលលៈ ក៏មានប្រមាណប៉ុនតំណក់ប្រេងដែលហូរចេញហើយ ជាប់ត្រង់ចុងសក់នោះ ។ តំណក់ប្រេងនោះ លោកពោលបដិសេធថា កាលច្រៀកសក់ របស់មនុស្សអ្នកជនបទ ជា ៨ ចំណែក សរសៃសក់របស់អ្នកឧត្តរកុរុទ្វីប មានប្រមាណប៉ុនចំណែកមួយអំពីចំណែក ៨ នោះ កលលៈនោះ មានប្រមាណប៉ុនតំណក់ប្រេងដែលជាប់ត្រង់ចុងសក់ របស់មនុស្សអ្នកឧត្តរកុរុទ្វីបនោះ ដែលគេជ្រលក់ហើយលើកឡើងអំពីប្រេងល្ងថ្លា ។ តំណក់ប្រេងល្ងថ្លានោះ ក៏លោកបដិសេធថា ទុំះក៏នៅច្រើន ធម្មតារោមទ្រាយជាធម្មជាតិល្អិត កលលៈនោះ ត្រឹមជាតំណក់ទឹកដែលហូរចេញអំពីចុងរោមទ្រាយមួយសរសៃ ដែលគេជ្រលក់ក្នុងប្រេងល្ង ហើយលើក

ឡើង ដូច្នេះ ។ កលលៈនេះថាស្អាត មិនល្អក់ បរិសុទ្ធ ដូចតំណក់ប្រេង ល្ងដ៏ថ្លា សេចក្ដីនេះ សមដូចពាក្យដែលលោកពោលថា

តំណក់ប្រេងល្ងថ្លាដូចសប្បិមិនល្អក់ យ៉ាងណា លោកពោល

ថា កលលរូបមានចំណែកប្រៀបដោយវណ្ណរូបយ៉ាងនោះ ។

ក្នុងសន្តតិរូបបន្ទិចបន្តួចយ៉ាងនេះ នៅមានសន្តតិរូបដែលជាប្រធាន ៣ កលាបៈ គឺវត្ថុទសកៈ ១ កាយទសកៈ ១ ភាវទសកៈ ដោយអំណាចឥត្ថិន្ទ្រិយ ឬបុរិសិន្ទ្រិយ ១ ។ បណ្ដាសន្តតិរូបទាំង ៣ កលាបៈនេះ រូបទាំងនេះ គឺវត្ថុរូប ១ មហាភូតរូប ៤ ជាទីអាស្រ័យនៃវត្ថុរូបនោះ និងវណ្ណៈ គន្ធៈ រស ឱជា រូមជា ៤ ដែលអាស្រ័យមហាភូតរូបនោះ និងជីវិតរូប ១ ឈ្មោះថា វត្ថុទសកៈ រូបនេះ គឺកាយបសាទ ១ មហាភូតរូប ៤ ដែលជាទីអាស្រ័យនៃកាយបសាទនោះ វណ្ណៈ គន្ធ រស ឱជា រូមជា ៤ ដែលអាស្រ័យមហាភូតរូបនោះ និងជីវិតរូប ១ ឈ្មោះថា កាយទសកៈ ។ រូបនេះ គឺឥត្ថីភាវៈ ឬបុរិសភាវៈ ១ មហាភូតរូប ៤ ដែលជាទីអាស្រ័យរបស់ភាវរូបនោះ វណ្ណៈ គន្ធ រស ឱជា រូមជា ៤ ដែលអាស្រ័យមហាភូតរូបនោះ និងជីវិតរូប ១ ឈ្មោះថា ភាវទសកៈ ។ កម្មជរូបក្នុងបដិសន្ធិនៃគព្ភសេយ្យកសត្វ កំណត់ដោយខ្ពស់បំផុត មាន ៣០ ឈ្មោះថា រូបក្ខន្ធ ដោយប្រការដូច្នេះ ។ វេទនា ដែលកើតព្រមគ្នានឹងបដិសន្ធិចិត្ត ឈ្មោះថា វេទនាខន្ធ សញ្ញា ... ឈ្មោះថា សញ្ញាខន្ធ សង្ខារ ... ឈ្មោះថា សង្ខារក្ខន្ធ បដិសន្ធិចិត្ត ឈ្មោះថា វិញ្ញាណក្ខន្ធ ព្រោះហេតុនោះ ក្នុងបដិសន្ធិក្ខណៈនៃ

គព្ភសេយ្យកសត្វ ទើបខន្ធ ៥ មានគ្រប់បរិបូណ៌ដោយអាការយ៉ាងនេះ ។ បើជាបដិសន្ធិរបស់ទ្បើយ ភាវទសកៈរមែងមិនមាន ។ កម្មជរូប ២០ ដោយអំណាចទសកៈទាំង ២ ឈ្មោះថា រូបក្ខន្ធ ធម៌ មានវេទនាខន្ធជាដើម ក៏មានប្រការតាមដែលពោលហើយនោះឯង ព្រោះហេតុនោះ ក្នុងបដិសន្ធិ-ក្ខណៈនៃគព្ភសេយ្យកសត្វ ទើបខន្ធ ៥ មានគ្រប់បរិបូណ៌ ដោយអាការយ៉ាងនេះ ។ ក្នុងឋានៈនេះ បណ្ឌិតគួរពោលបវេណីរបស់រូបមានសមុដ្ឋានទាំង ៣ ផងដែរ ។

ឈ្មោះថា ការកើតឡើងដំបូង របស់ឱបបាតិកសត្វ លោកសម្តែងទុកដោយមិនបានពោលដល់បវេណី របស់រូបដែលមានសមុដ្ឋាន ៣ នោះ ។ ពិតហើយ ក្នុងបដិសន្ធិក្ខណៈរបស់សត្វដែលជាឱបបាតិកៈ មានអាយតនៈបរិបូណ៌ គឺមានរូបសន្តតិដែលជាប្រធាន ៧ កលាបៈ បានដល់ កម្មជរូបតាមដែលពោលខាងដើម ៣ កលាបៈ និងចក្ខុទសកៈ សោតទសកៈ ឃានទសកៈ ជិវ្ហាទសកៈ រមែងកើតឡើង ។ បណ្តារូបសន្តតិ ៧ កលាបៈនោះ ចក្ខុទសកៈជាដើម ដូចគ្នានឹងកាយទសកៈនោះឯង តែភាវទសកៈរមែងមិនមានដល់ឱបបាតិកសត្វដែលមិនមានភេទ ។ ដោយប្រការយ៉ាងនេះ កម្មជរូបរបស់ឱបបាតិកសត្វ ដែលមានអាយតនៈបរិបូណ៌ ទើបមាន ៧០ ខ្លះ ៦០ ខ្លះ ឈ្មោះថា រូបក្ខន្ធ ។ ធម៌ មានវេទនាខន្ធជាដើម ក៏មានប្រការតាមដែលពោលហើយនោះឯង ព្រោះហេតុនោះ ក្នុងបដិសន្ធិក្ខណៈរបស់ឱបបាតិកសត្វ ទើបខន្ធ ៥ មានគ្រប់បរិបូណ៌ ដោយអាការយ៉ាងនេះ នេះឈ្មោះថា ការ

កើតឡើងដំបូងនៃឱបបាតិកសត្វ ។

គប្បីជ្រាបខន្ធ ៥ ដោយការកើតឡើងដំបូងយ៉ាងនេះ ។

ពាក្យថា ដោយការកើតមុន និងក្រោយ មានពាក្យសួរថា ខន្ធ ៥ នៃគព្ភសេយ្យកសត្វដែលកើតឡើង មិនមុន មិនក្រោយយ៉ាងនេះ សួរថា រូបធ្វើរូបឲ្យតាំងឡើងមុន ឬអរូបធ្វើរូបឲ្យតាំងឡើងមុន ឆ្លើយថា រូបនោះឯងធ្វើរូបឲ្យតាំងឡើង អរូបមិនបានធ្វើរូបឲ្យតាំងឡើងទេ ព្រោះហេតុអ្វី ព្រោះបដិសន្ធិធ្វើរូបឲ្យកើតឡើងមិនបាន ។

ពិតហើយ ចិត្ត ១៦ ដួង គឺបដិសន្ធិចិត្តនៃសត្វទាំងអស់ ១ ចុតិចិត្តនៃព្រះខីណាស្រព ១ ទ្វិបញ្ចវិញ្ញាណ ១០ អរូបវិបាកចិត្ត ៤ ធ្វើរូបឲ្យតាំងឡើងមិនបាន ។

បណ្ដាចិត្ត ១៦ ដួងនោះ ពោលដោយបដិសន្ធិចិត្តមុន រមែងធ្វើរូបឲ្យតាំងឡើងមិនបានព្រោះវត្ថុទុព្វល ១ ព្រោះមិនតាំងមាំ ១ ព្រោះមានបច្ច័យមិនគ្រប់គ្រាន់ ១ ព្រោះជាចិត្តទើបតែចរមកថ្មី ១ ដ្បិតថា វត្ថុដែលកើតព្រមជាមួយបដិសន្ធិចិត្តនោះ ជាសភាវៈទុព្វលក្នុងខណៈកើតឡើង ព្រោះហេតុនោះ ទើបបដិសន្ធិចិត្តនោះ ឈ្មោះថា ធ្វើរូបឲ្យតាំងឡើងមិនបាន ព្រោះវត្ថុជារបស់ទុព្វល ។ មួយវិញទៀត បុរសដែលកំពុងធ្លាក់ទៅក្នុងជ្រោះ រមែងមិនអាចជាទីពឹងរបស់អ្នកដទៃបានយ៉ាងណា ចិត្តនេះក៏យ៉ាងនោះ ជាចិត្តមិនតាំងមាំ ដូចកំពុងធ្លាក់ទៅក្នុងជ្រោះព្រោះត្រូវកម្មបន្សាត់ទៅ ហេតុនោះ ទើបបដិសន្ធិចិត្តនោះ ឈ្មោះថា ធ្វើរូបឲ្យតាំងឡើងមិនបាន សូម្បីហេតុដែលមិនទាន់

តាំងមាំ ព្រោះត្រូវកម្មបន្សាត់ទៅ ។

ម្យ៉ាងទៀត បដិសន្ធិចិត្តកើតឡើងព្រមជាមួយវត្ថុមិនមុនមិនក្រោយ ទើបវត្ថុនៃបដិសន្ធិចិត្តនោះ មិនអាចជាបុរេជាតប្បច្ច័យ តែបើអាច ក៏នឹងគប្បីធ្វើរូបឲ្យតាំងឡើង ។ ក្នុងខណៈដែលវត្ថុអាចជាបច្ច័យដែលកើតមុន និងប្រវេណីនៅបន្តនៅឡើយ ចិត្តដែលមិនសាបសូន្យ ចាកចំណែកអង្គឈានប៉ុណ្ណោះ ទើបធ្វើរូបឲ្យកើតឡើង ។ ពិតហើយ បើចិត្តធ្វើរូបឲ្យតាំងឡើងបានក្នុងឋិតិក្ខណៈ ឬក្នុងភង្គក្ខណៈ បដិសន្ធិចិត្តក៏គប្បីធ្វើរូបឲ្យតាំងឡើងបាន តែចិត្តរមែងធ្វើរូបឲ្យតាំងឡើងក្នុងខណៈទាំង ២ នោះ មិនបាន ។ ដូចផ្សិតកាលផុសឡើងអំពីផែនដី រមែងនាំយកធូលីជាប់មកផង យ៉ាងណា ចិត្តក៏យ៉ាងនោះ អាស្រ័យវត្ថុដែលកើតមុន ហើយកាន់យករូប ៨ តាំងឡើងក្នុងឧប្បាទក្ខណៈ តែក្នុងបដិសន្ធិក្ខណៈ ( វត្ថុ ) រូប មិនអាចជាបុរេជាតប្បច្ច័យបាន ព្រោះហេតុនោះ ទើបបដិសន្ធិចិត្ត ឈ្មោះថា ធ្វើរូបឲ្យតាំងឡើងមិនបាន ព្រោះខ្វះបច្ច័យ ។

ម្យ៉ាងទៀត បុគ្គលមកថ្មី ដល់ប្រទេសដែលខ្លួនមិនធ្លាប់មក រមែងមិនអាចនិយាយដល់បុគ្គលដទៃៗ ថា នែអ្នកទាំងឡាយ ចូរពួកអ្នកមកក្នុងស្រុកចុះ ខ្ញុំនឹងឲ្យបាយទឹក គ្រឿងក្រអូប ផ្កាកម្រងជាដើម ដល់ពួកអ្នក ព្រោះស្រុកនោះមិនមែនជាវិស័យរបស់ខ្លួន ព្រោះថា ខ្លួនមិនបានជាធំក្នុងស្រុកនោះ យ៉ាងណា បដិសន្ធិចិត្តជាចិត្តចរមកថ្មី ក៏យ៉ាងនោះដូចគ្នា ព្រោះហេតុនោះ ទើបបដិសន្ធិចិត្តនោះ ធ្វើរូបឲ្យតាំងឡើងមិនបាន ព្រោះខ្លួនជាអ្នកមកថ្មី ។

ម្យ៉ាងទៀត កម្មជរូប ៣០ កាន់យកឋានៈនៃរូបដែលមានចិត្តជាសមុដ្ឋានតាំងនៅហើយ ព្រោះហេតុនោះ ទើបបដិសន្ធិចិត្ត មិនធ្វើរូបឲ្យតាំងឡើងបាន ។

ចុតិចិត្តរបស់ព្រះខីណាស្រព ធ្វើរូបឲ្យតាំងឡើងមិនបាន ព្រោះមូលនៃវដ្តៈរបស់លោកស្ងប់ហើយ ។ ពិតហើយ ព្រះខីណាស្រពនោះ មានមូលនៃវដ្តៈក្នុងភពទាំងពួង ស្ងប់ហើយ មិនគួរកើតឡើង ឈ្មោះថា ពូជនៃការកើតឡើងទៀតមិនមាន តែព្រះសោតាបន្នវៀរ ៧ ភព ភពទី ៨ របស់លោក មានមូលនៃវដ្តៈនោះស្ងប់ហើយ ព្រោះហេតុនោះ ទើបចុតិចិត្តរបស់ព្រះសោតាបន្ននោះ ធ្វើរូបឲ្យតាំងឡើងបាន ៧ ភព ។ របស់ព្រះសកទាគាមីធ្វើរូបឲ្យតាំងឡើងបាន ២ ភព របស់ព្រះអនាគាមីធ្វើរូបឲ្យតាំងឡើង ១ ភព ចុតិរបស់ព្រះខីណាស្រពធ្វើរូបឲ្យតាំងឡើងមិនបាន ព្រោះមូលនៃវដ្តៈក្នុងភពទាំងពួងស្ងប់ហើយ ។

ម្យ៉ាងទៀត ក្នុងទ្វិបញ្ចវិញ្ញាណទាំងឡាយ អង្គឈានមិនមាន អង្គមគ្គក៏មិនមាន ហេតុក៏មិនមាន ព្រោះហេតុនោះ ទើបចំណែកប្រកបរបស់ចិត្ត ជារបស់ទុព្វល ព្រោះហេតុនោះ ទើបទ្វិបញ្ចវិញ្ញាណទាំងនោះ ធ្វើរូបឲ្យតាំងឡើងមិនបាន ព្រោះអង្គរបស់ចិត្តជាសភាវៈទុព្វល ។

ចំណែកអរូបាវចរវិបាកចិត្ត ៤ ក៏ធ្វើរូបឲ្យតាំងឡើងមិនបាន ព្រោះរូបក្នុងភពនោះ មិនមាន ។ មិនមែនតែអរូបាវចរវិបាកចិត្ត ៤ ប៉ុណ្ណោះទេដែលធ្វើរូបឲ្យតាំងឡើងមិនបាន សូម្បីចិត្ត ៤២ ដួងដទៃទៀត គឺកាមាវចរកុសល-ចិត្ត ៨ អកុសលចិត្ត ១០ កិរិយាចិត្ត ៩ អរូបកុសលចិត្ត ៤ អរូប-

កិរិយាចិត្ត ៤ មគ្គចិត្ត ៣ ផលចិត្ត ៤ ដែលកើតក្នុងភពនោះ ក៏ធ្វើរូបឲ្យតាំងឡើងមិនបាន ព្រោះក្នុងអរូបភពនោះមិនមានរូប បដិសន្ធិចិត្តរមែងធ្វើរូបឲ្យតាំងឡើងមិនបាន ដោយប្រការដូច្នេះ ។

ឧតុរមែងឲ្យរូបដំបូងតាំងឡើង សួរថា ឈ្មោះថា ឧតុនេះ គឺអ្វី ឆ្លើយថា គឺតេជោធាតុខាងក្នុងកម្មជរូប ៣០ ដែលកើតឡើងក្នុងបដិសន្ធិក្ខណៈ ។ តេជោធាតុនោះដល់ឋានៈហើយ ក៏ធ្វើរូប ៨ ឲ្យតាំងឡើង ។ ម្យ៉ាងទៀត ឈ្មោះថា ឧតុនេះ រលត់យឺត ចិត្តរលត់រហ័ស កាលឧតុជរូបកំពុងតាំងនៅនោះឯង ចិត្តក៏កើតរលត់ ១៦ ដួង ។ បណ្ដាចិត្ត ១៦ ដួងនោះ ភវង្គចិត្តដួងទី ១ ដែលកើតបន្ទាប់អំពីបដិសន្ធិចិត្តរមែងធ្វើរូប ៨ យ៉ាងឲ្យតាំងឡើងក្នុងឧប្បាទក្ខណៈនោះឯង តែកាលណាមានការកើតឡើងនៃសំឡេង កាលនោះ ឧតុ និងចិត្តក៏ធ្វើរូប ឈ្មោះថាសទ្ទនវកៈឲ្យតាំងឡើង ។ កពឡិង្ការាហារដល់ឋានៈហើយ ក៏ធ្វើរូប ៨ យ៉ាងឲ្យតាំងឡើង ។

សួរថា កពឡិង្ការាហាររបស់គព្ភសេយ្យកសត្វនោះ មកអំពីទីណា ។ ឆ្លើយថា មកអំពីមាតា សេចក្ដីនេះសមដូចព្រះតម្រាស់ដែលត្រាស់ ( ក្នុងសំយុត្តនិកាយ សគាថវគ្គ ) ថា

> ឯមាតារបស់សត្វនោះ បរិភោគភោជនណា ទោះបាយក្ដី ទឹកក្ដី សត្វនោះ ដែលស្ថិតនៅក្នុងផ្ទៃនៃមាតានោះ ក៏ញុំាង អត្តភាពឲ្យប្រព្រឹត្តទៅដោយភោជននោះ ដូច្នេះ ។

ទារកដែលនៅក្នុងគភ៌ រមែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយឱជានៃ

បាយ និងទឹកដែលមាតាលេបចូលទៅ ដោយប្រការដូច្នេះ ឱជានោះ ដល់ឋានៈហើយ ក៏ធ្វើរូប ៨ ឲ្យតាំងឡើង ។

សួរថា ឱជានោះ ជារបស់គ្រោតគ្រាត វត្ថុជារបស់ល្អិតមិនមែនឬ នឹងតាំងនៅក្នុងវត្ថុនោះបានដូចម្ដេច ឆ្លើយថា ដំបូងមិនទាន់តាំងនៅ តែពេលវេលាកន្លងទៅ ត្រឹមតែមួយ ឬពីរសប្ដាហ៍ទើបតាំងនៅបាន តែឱជានោះតាំងនៅមុន ឬក្រោយអំពីវេលានោះ ។ កាលណា ឱជានៃបាយ និងទឹក ដែលមាតាលេបចូលទៅ តាំងនៅក្នុងសរីរៈរបស់ទារក កាលនោះ ក៏ធ្វើរូប ៨ ឲ្យតាំងឡើង ។

សូម្បីឱបបាតិកសត្វដែលកើតក្នុងទីមានខាទនីយៈ និងភោជនីយៈ ដែលវិបាកតាក់តែងទុកតាមប្រក្រតី កាលកាន់យកអាហារទាំងនោះទំពាស៊ី ឱជាដែលដល់ឋានៈហើយ ក៏ធ្វើរូបឲ្យតាំងឡើង ។ ឱបបាតិកសត្វពួកខ្លះ កើតក្នុងព្រៃ មិនមានបាយ និងទឹក មានសេចក្ដីស្រេកឃ្លានខ្លាំង ទើបយកអណ្ដាតប្រមូលទឹកមាត់លេបចូលទៅ ឱជាដែលដល់ឋានៈហើយ របស់ឱបបាតិក-សត្វនោះ ក៏ធ្វើរូបឲ្យតាំងឡើងក្នុងទីនោះ ។

ដោយអាការយ៉ាងនេះ បណ្ដារូប ២៥ កោដ្ឋាស រូប ២ យ៉ាង គឺតេជោធាតុ និងកពឡិង្ការាហារប៉ុណ្ណោះ រមែងធ្វើរូបឲ្យតាំងឡើង ក្នុងអរូបសោត ធម៌ ២ ប៉ុណ្ណោះ គឺចិត្ត និងចេតនាកម្ម រមែងធ្វើរូបឲ្យតាំងឡើង ។ បណ្ដារូបធម៌ និងនាមធម៌ទាំងនោះ រូបជាសភាវៈទុព្វលក្នុងឧប្បាទក្ខណៈ និងភង្គក្ខណៈ ជាសភាវៈមានកម្លាំងក្នុងឋិតក្ខណៈ ព្រោះហេតុនោះ ទើបរូប

ដែលមានកម្លាំងនោះ ធ្វើឲ្យរូបតាំងឡើងបានក្នុងឋិតិក្ខណៈ ។ ចិត្តជាសភាវៈទុព្វលក្នុងឋិតិក្ខណៈ និងក្នុងភង្គក្ខណៈ ជាសភាវៈមានកម្លាំងក្នុងឧប្បាទក្ខណៈនោះឯង ព្រោះហេតុនោះ ទើបចិត្តនោះធ្វើរូបឲ្យតាំងឡើង ក្នុងឧប្បាទក្ខណៈប៉ុណ្ណោះ ។ ចេតនាកម្មរលត់ទៅហើយនោះឯង ទើបជាបច្ច័យបាន ព្រោះកម្មដែលបុគ្គលបានធ្វើហើយក្នុងអតីត សូម្បីក្នុងទីបំផុតនៃសែនកោដិកប្បក៏ជាបច្ច័យក្នុងបច្ចុប្បន្នបាន កម្មដែលធ្វើក្នុងបច្ចុប្បន្ន ក៏ជាបច្ច័យក្នុងអនាគតសូម្បីក្នុងទីបំផុតសែនកោដិកប្ប ។ គប្បីជ្រាបខន្ធ ៥ ដោយការកើតមុន និងក្រោយដូចពណ៌នាមក ដូច្នេះ ។

ពាក្យថា ដោយកំណត់កាលនេះ សួរថា រូបតាំងនៅយូរប៉ុនណា អរូបតាំងនៅយូរប៉ុនណា ឆ្លើយថា រូប មានការប្រែប្រួលយូរ រលត់ក៏យូរ អរូបប្រែប្រួលរហ័ស រលត់ក៏រហ័ស កាលរូបកំពុងតាំងនៅនោះឯង ចិត្តកើតរលត់ ១៦ ដួង តែរូបនោះនឹងរលត់ ព្រមជាមួយចិត្តដួងទី ១៧ ប្រៀបដូចបុរសគិតថា អញនឹងឲ្យផ្លែឈើធ្លាក់ ទើបយកដំបងគ្រវែងមែកឈើ ផ្លែ និងស្លឹកទាំងឡាយក៏ជ្រុះចាកទងដំណាលគ្នានោះឯង បណ្តាផ្លែ និងស្លឹកឈើទាំងនោះ ផ្លែទាំងឡាយ រមែងធ្លាក់ដល់ដីមុន ព្រោះផ្លែជារបស់ធ្ងន់ ស្លឹកទាំងឡាយធ្លាក់មកឯក្រោយ ព្រោះស្លឹកជារបស់ស្រាលយ៉ាងណា ការប្រាកដនៃរូបធម៌ និងអរូបធម៌ក្នុងខណៈជាមួយគ្នា ក្នុងបដិសន្ធិដូចពេលដែលស្លឹក និងផ្លែទាំងឡាយជ្រុះចាកទង ក្នុងខណៈតែមួយ ដោយការគ្រវែងដោយដំបងយ៉ាងនោះដូចគ្នា កាលរូបកំពុងតាំងនៅនោះឯង ចិត្តក៏កើតរលត់ទៅ ១៦ ដួង

ដូចផ្លែឈើធ្លាក់ចុះកាន់ផែនដីមុន ព្រោះផ្លែឈើជារបស់ធ្ងន់ ការដែលរូបរលត់ដំណាលគ្នានឹងចិត្តដួងទី ១៧ ដូចស្លឹកឈើធ្លាក់ដល់ដីខាងក្រោយ ព្រោះស្លឹកឈើទាំងឡាយជារបស់ស្រាល ។

បណ្ដារូប និងចិត្តទាំងនោះ ទោះបីរូបរលត់យឺត ប្រែប្រួលយូរ ចិត្តរលត់រហ័ស ប្រែប្រួលរហ័សក៏ពិត ទោះជាយ៉ាងនោះ រូបលះបង់អរូបហើយ ក៏មិនអាចប្រព្រឹត្តទៅបាន អរូបលះបង់រូបហើយ ក៏មិនអាចប្រព្រឹត្តទៅបាន ការប្រព្រឹត្តទៅនៃរូប និងអរូបទាំង ២ មានប្រមាណស្មើគ្នានោះឯង ក្នុងសេចក្ដីនេះ គប្បីជ្រាបឧបមាដូចតទៅ

បុរសម្នាក់មានជើងខ្លី បុរសម្នាក់មានជើងវែង កាលជនទាំង ២ នោះដើរផ្លូវរួមគ្នា មនុស្សជើងវែងឈាន ១ ជំហាន មនុស្សជើងខ្លីឈានបាន ១៦ ជំហាន ក្នុងការឈានទៅលើកទី ១៦ នៃមនុស្សជើងខ្លី មនុស្សជើងវែងក៏លើកជើងរបស់ខ្លួនធ្វើការឈានទៅព្រមគ្នា ដោយប្រការដូច្នេះ សូម្បីមនុស្សម្នាក់ ក៏មិនអាចហួសមនុស្សម្នាក់ទៅបាន ការទៅនៃមនុស្សទាំង ២ ឈ្មោះថា មានប្រមាណស្មើគ្នានោះឯង យ៉ាងណា ឧបមេយ្យនេះ គប្បីឃើញយ៉ាងនោះ ដ្បិតថា អរូបដូចមនុស្សជើងខ្លី រូបដូចមនុស្សជើងវែង កាលរូបកំពុងតាំងនៅនោះឯង ចិត្តក្នុងអរូបធម៌ក៏កើតរលត់ ១៦ ដួង ដូចពេលដែលមនុស្សជើងវែងឈានទៅម្ដង មនុស្សជើងខ្លីក្រៅអំពីនេះឈានទៅ ១៦ ដង ។ ការដែលរូបរលត់ព្រមជាមួយនឹងចិត្តដួងទី ១៧ ដូចក្នុងការដែលបុរសជើងខ្លី ឈានទៅ ១៦ ជំហាន បុរសជើងវែងឈានជើង ១ ជំហាន

ដូច្នោះ កាលដែលអរូបមិនលះបង់រូប រូបមិនលះបង់អរូប ប្រព្រឹត្តទៅដោយប្រមាណស្មើគ្នា ដូចការដែលបុរស ២ នាក់មិនលះបង់គ្នាដើរទៅ ដោយប្រមាណព្រមគ្នានោះឯង ដូច្នេះ ។ គប្បីជ្រាបខន្ធ ៥ ដោយការកំណត់កាលយ៉ាងនេះ ។

ពាក្យថា ដោយការកើតក្នុងខណៈតែមួយរលត់ផ្សេងខណៈគ្នានេះ បណ្ឌិតគប្បីសម្តែងរៀកម្មជរូប ដួងចុងក្រោយ ។ ពិតហើយ ចិត្តដួងទី ១ ជាបដិសន្ធិចិត្ត ចិត្តដួងទី ២ ជាភវង្គ ដួងទី ៣ ក៏ជាភវង្គ ។បេ។ ដួងទី ១៦ ក៏ជាភវង្គ ។ បណ្តាចិត្ត ១៦ ដួងនោះ ចិត្ត ១ ដួង មាន ៣ ខណៈ គឺឧប្បាទក្ខណៈ ឋិតិក្ខណៈ និងភង្គក្ខណៈ ក្នុង ៣ ខណៈនៃចិត្តនីមួយៗ នោះមានកម្មជរូបកើតឡើង ៣០ បណ្តាកម្មជរូបទាំងនោះ កម្មជរូបដែលតាំងឡើងក្នុងឧប្បាទក្ខណៈនៃបដិសន្ធិចិត្ត រមែងរលត់ក្នុងឧប្បាទក្ខណៈនៃភវង្គចិត្តដួងទី ១៧ នោះឯង កម្មជរូបដែលតាំងឡើង ក្នុងឋិតិក្ខណៈនៃបដិសន្ធិចិត្ត រមែងរលត់ក្នុងឋិតិក្ខណៈរបស់ភវង្គចិត្តដួងទី ១៧ នោះឯង ។ កម្មជរូបដែលតាំងឡើងក្នុងភង្គក្ខណៈនៃបដិសន្ធិចិត្ត រមែងរលត់ក្នុងភង្គក្ខណៈនៃភវង្គចិត្តដួងទី ១៧ នោះឯង ។

ដោយអាការយ៉ាងនេះ គប្បីធ្វើភវង្គចិត្តដួងទី ២ ( បដិសន្ធិចិត្តជាដួងទី ១ ) ប្រកបជាមួយចិត្តដួងទី ១៧ រៀងៗ ខ្លួននោះឯង ហើយពង្រីកន័យទៅ ។ ពួកបី ១៦ ដង ទើបជា ៤៨ ខណៈ ដោយប្រការដូច្នេះ ។ នេះឈ្មោះថាបវេណី គឺនិយាមនៃកម្មជរូប ៤៨ ខណៈ ។ បវេណីរបស់កម្មជរូបនេះ

រមែងប្រព្រឹត្តទៅដល់អ្នកកំពុងទំពាស៊ី និងដល់អ្នកបរិភោគ និងដល់អ្នកដេកលក់ ដល់បុគ្គលប្រមាទ ទាំងពេលយប់ និងពេលថ្ងៃ ដូចក្រសែនៃទឹកស្ទឹងកំពុងហូរទៅដូច្នោះឯង ។

គប្បីជ្រាបភាព ដែលខន្ធ ៥ មានការកើតខណៈតែមួយ រលត់ខណៈផ្សេងគ្នាយ៉ាងនេះ ។

ភាពដែលខន្ធ ៥ កើតខណៈខុសគ្នា រលត់ក្នុងខណៈតែមួយ បណ្ឌិតគប្បីសម្តែងដោយកម្មជរូប ដែលកើតចុងក្រោយ ។ ក្នុងពាក្យនោះ ទីបំផុតនៃអាយុសង្ខារ កាលមានវារចិត្ត ១៦ ដួង ក៏គប្បីប្រកបចិត្ត ២ ពួក គឺពួកចិត្ត ១៦ ដួងខាងដើម និងពួកចិត្ត ១៦ ខាងចុង រួមជាមួយគ្នា ។ ដ្បិតថា កម្មជរូប ៣០ ដែលតាំងឡើងក្នុងឧប្បាទក្ខណៈនៃបឋមចិត្ត ក្នុងពួកចិត្ត ១៦ ដួងខាងដើម រមែងរលត់ក្នុងឧប្បាទក្ខណៈនៃបឋមចិត្តក្នុងពួកចិត្ត ១៦ ដួងខាងចុងនោះឯង ។ កម្មជរូប ៣០ ដែលតាំងឡើងក្នុងឋិតិក្ខណៈនៃបឋម-ចិត្តខាងដើម រមែងរលត់ទៅក្នុងឋិតិក្ខណៈនៃបឋមចិត្ត ខាងចុងនោះឯង ។ កម្មជរូប ៣០ ដែលតាំងឡើងក្នុងភង្គក្ខណៈនៃបឋមចិត្តខាងដើម រមែងរលត់ទៅក្នុងភង្គក្ខណៈនៃបឋមចិត្តខាងចុងដូចគ្នា ។ ឯកម្មជរូប ៣០ ដែលតាំងឡើងក្នុងឧប្បាទក្ខណៈនៃចិត្តដួងទី ២ ។បេ។ នៃចិត្តដួងទី ១៦ ក្នុងពួកចិត្ត ១៦ ដួងខាងដើម រមែងរលត់ទៅក្នុងឧប្បាទក្ខណៈនៃចុតិចិត្តនោះឯង ដែលតាំងឡើងក្នុងឋិតិក្ខណៈនៃចិត្តដួងទី ១៦ ខាងដើមនោះ រមែងរលត់ទៅក្នុងឋិតិក្ខណៈរបស់ចុតិចិត្តនោះឯង ដែលតាំងឡើងក្នុងភង្គក្ខណៈចិត្តដួងទី ១៦

ខាងដើមនោះ តាំងឡើងរលត់ទៅក្នុងភង្គក្ខណៈនៃចុតិចិត្តនោះឯង ខាងមុខអំពីនោះ ការបន្តនៃកម្មជរូប រមែងមិនប្រព្រឹត្តទៅ ។ បើនឹងប្រព្រឹត្តទៅទៀតសោត សត្វទាំងឡាយគប្បីឈ្មោះថា ជាអ្នកមិនអស់ មិនវិនាស មិនចាស់ មិនស្លាប់ ។

ម្យ៉ាងទៀត ក្នុងសេចក្ដីនេះ ពាក្យដែលខ្ញុំពោលដោយន័យជាដើមថា រមែងរលត់ក្នុងឧប្បាទក្ខណៈនៃភវង្គចិត្តដួងទី ១៧ នោះឯង ព្រោះមកក្នុងអដ្ឋកថាថា រូបដែលកើតឡើងក្នុងឧប្បាទក្ខណៈនៃចិត្តដួងទី ១ នោះឯង រមែងរលត់ទៅក្នុងឧប្បាទក្ខណៈនៃចិត្តដួងដទៃ រមែងខុសចាកព្រះបាលីនេះ ( ក្នុងអភិធម្មយមកៈ ) ថា កាយសង្ខាររបស់សត្វណា រលត់ទៅក្នុងទីណា ចិត្តសង្ខាររបស់សត្វនោះ រលត់ហើយក្នុងទីនោះឬ ។ អើ ដូច្នេះ ។ សួរថា ត្រូវគ្នាដូចម្ដេច ឆ្លើយថា ព្រោះកាយសង្ខារ គឺខ្យល់អស្សាសៈ និងបស្សាសៈ មានចិត្តជាសមុដ្ឋាន រូបដែលមានចិត្តជាសមុដ្ឋាន កើតឡើងក្នុងឧប្បាទក្ខណៈនៃចិត្តហើយ រមែងតាំងនៅរហូតដល់ចិត្ត ១៦ ដួងដទៃកើតឡើង ។ រមែងរលត់ទៅព្រមជាមួយចិត្ត ដួងចុងក្រោយបង្អស់នៃចិត្ត ១៦ ដួងទាំងនោះ ព្រោះហេតុនោះ រូបដែលមានចិត្តជាសមុដ្ឋាន កើតឡើងព្រមជាមួយចិត្តដួងណា ក៏រលត់ព្រមជាមួយចិត្តដួងទី ១៧ រាប់អំពីចិត្តនោះ មិនមែនរលត់ក្នុងឧប្បាទក្ខណៈ ឬឋិតិក្ខណៈនៃចិត្តដួងណាមួយ និងរមែងមិនកើតក្នុងឋិតិក្ខណៈ ឬក្នុងភង្គក្ខណៈ ។ នេះជាធម្មតារបស់រូប ដែលមានចិត្តជាសមុដ្ឋាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា អើ ដូច្នេះ

ព្រោះរលត់ក្នុងខណៈជាមួយគ្នានឹងចិត្តសង្ខារដោយពិតប្រាកដ ។

ឯការកំណត់ខណៈរបស់រូបដែលមានចិត្តជាសមុដ្ឋាន ដែលខ្ញុំពោលនេះ ជាការកំណត់ខណៈនៃរូបដែលមានកម្មជាដើមជាសមុដ្ឋានដូចគ្នា ព្រោះហេតុនោះ បណ្ឌិតគប្បីធ្វើការប្រកបអត្ថ ក្នុងអធិការនេះ ដោយន័យនោះឯងថា កម្មជរូប ដែលកើតព្រមជាមួយនឹងបដិសន្ធិចិត្ត រមែងរលត់ព្រមជាមួយចិត្តជួងទី ១៧ រាប់អំពីបដិសន្ធិនោះ កម្មជរូបដែលកើតក្នុងឋិតិក្ខណៈរបស់បដិ-សន្ធិចិត្ត រមែងរលត់ទៅក្នុងឧប្បាទក្ខណៈរបស់ចិត្តជួងទី ១៨ កម្មជរូបដែលកើតក្នុងភង្គក្ខណៈនៃបដិសន្ធិចិត្ត ដល់ឋិតិក្ខណៈនៃចិត្តជួងទី ១៨ ហើយ ក៏រលត់ទៅ ដូច្នេះ ។ ខាងមុខអំពីនេះទៅ ការបន្តរបស់រូប ដែលមានឧតុជាសមុដ្ឋានប៉ុណ្ណោះ រមែងតាំងនៅ រូបរមែងជារបស់ដែលបុគ្គលគប្បីពោលថា ចូរពួកលោកយកសរីរៈនេះទៅដុតចុះ ដូច្នេះ ។ គប្បីជ្រាបភាពដែលខន្ធ ៥ កើតខណៈខុសគ្នា រលត់ក្នុងខណៈតែមួយ ដោយប្រការដូច្នេះ ។

ពាក្យថា ដោយកើតព្រមគ្នា រលត់ព្រមគ្នា សេចក្តីថា រូបកើតព្រមជាមួយរូប រលត់ព្រមជាមួយរូប អរូបកើតព្រមជាមួយអរូប រលត់ព្រមជាមួយអរូប គប្បីជ្រាបភាពដែលខន្ធ ៥ កើតព្រមគ្នា និងរលត់ព្រមគ្នា ដោយប្រការដូច្នេះ ។

ភាពដែលខន្ធ ៥ កើតមិនព្រមគ្នា រលត់មិនព្រមគ្នា បណ្ឌិតគប្បីសម្តែងដោយសន្តតិរូប ៤ ( គឺកម្មជរូប ១ ចិត្តជរូប ១ ឧតុជរូប ១ អាហារជរូប ១ ) ។ ពិតហើយ សន្តតិរូបទាំង ៤ ក្នុងចំណែកនោះៗ របស់សរីរៈនេះ

ខាងលើអំពីបាតជើងឡើង ខាងក្រោមអំពីចុងសក់ចុះ ជុំវិញដោយស្បែក រមែងប្រព្រឹត្តទៅដោយភាពជាយនៈ ( ជាដុំ ជាក្រុម ) កាលសន្តតិរូប ៤ នោះប្រព្រឹត្តទៅយ៉ាងនេះ ក៏គប្បីកំណត់ភាពដែលរូបទាំងនោះ មានការកើតឡើងព្រមគ្នាជាដើមមិនបាន ។ ដូចជួរនៃកណ្តៀរ ឬជួរនៃស្រមោចក្រហម កាលបុគ្គលសម្លឹងមើលក៏ដូចជាប់គ្នាតែមួយ តែមិនមែនជាប់គ្នាតែមួយឡើយ ព្រោះក្នុងទីជិតក្បាលរបស់ស្រមោចមួយ នឹងមានក្បាលខ្លះ ពោះខ្លះ ជើងខ្លះរបស់ស្រមោចដទៃៗ ក្នុងទីជិតពោះរបស់ស្រមោចមួយ នឹងមានក្បាលខ្លះ ពោះខ្លះ ជើងខ្លះរបស់ស្រមោចដទៃៗ ក្នុងទីជិតជើងរបស់ស្រមោចមួយ ក៏នឹងមានក្បាលខ្លះ ពោះខ្លះ ជើងខ្លះរបស់ស្រមោចដទៃៗ យ៉ាងណា សូម្បីសន្តតិរូប ៤ ក៏យ៉ាងនោះដូចគ្នា ក្នុងឧប្បាទក្ខណៈរបស់សន្តតិរូប ១ នឹងមានឧប្បាទខ្លះ ឋិតិខ្លះ ភង្គៈខ្លះ របស់សន្តតិរូបដទៃៗ ក្នុងឋិតិក្ខណៈរបស់សន្តតិរូប ១ នឹងមានឧប្បាទខ្លះ ឋិតិខ្លះ ភង្គៈខ្លះ របស់សន្តតិរូបដទៃៗ ក្នុងភង្គក្ខណៈរបស់សន្តតិរូប ១ នឹងមានឧប្បាទខ្លះ ឋិតិខ្លះ ភង្គៈខ្លះ របស់សន្តតិរូបដទៃៗ ។ គប្បីជ្រាបភាពដែលខន្ធ ៥ កើតខណៈផ្សេងៗ គ្នា រលត់ខណៈផ្សេងគ្នាក្នុងសន្តតិរូបនេះ ដោយប្រការដូច្នេះ ។

ខន្ធ ៥ ដែលជាអតីតជាដើម មានទូរទុកៈជាទីបំផុត មកក្នុងបាលីហើយ សូម្បីបច្ច័យ និងសមុដ្ឋានទាំងឡាយ ខ្ញុំក៏បានពោលខាងដើមហើយ ដោយន័យជាដើមថា រូបកើតអំពីកម្ម មានកម្មជាបច្ច័យ មានឧតុជាសមុដ្ឋាន កើតអំពីកម្មជាបច្ច័យជាដើម ។ ខន្ធទាំង ៥ ជារបស់សម្រេចហើយអំពីកម្មជា

បច្ច័យ មិនមែនជារបស់មិនសម្រេចហើយ ជាសង្ខតៈប៉ុណ្ណោះ មិនមែនជាអសង្ខតៈ ម្យ៉ាងទៀត ខន្ធ ៥ នោះ ឈ្មោះថា កើតឡើងអំពីកម្មជាបច្ច័យពិត ព្រោះក្នុងសភាវធម៌ទាំងឡាយ ព្រះនិព្វានតែម្យ៉ាងប៉ុណ្ណោះ ជាធម៌មិនសម្រេចអំពីកម្មជាបច្ច័យ ជាធម៌មិនកើតឡើងអំពីកម្មជាបច្ច័យ ។ សួរថា និរោធសមាបត្តិ និងនាមបញ្ញត្តិដូចម្តេច ឆ្លើយថា និរោធសមាបត្តិ បុគ្គលណាម្នាក់ មិនគប្បីហៅថាជាលោកិយ ឬលោកុត្តរ ជាសង្ខតៈ ឬអសង្ខតៈ ជារបស់សម្រេចហើយ ឬមិនសម្រេចហើយ តែនិរោធសមាបត្តិនោះ ជារបស់សម្រេច មិនជារបស់មិនសម្រេច ព្រោះជាធម៌ ដែលបុគ្គលបានសមាបត្តិគប្បីចូលបាន ។ នាមបញ្ញត្តិក៏យ៉ាងនោះ ព្រោះនាមបញ្ញត្តិនោះ រមែងមិនបានការចែកថា លោកិយជាដើម ។ តែជាសភាវៈសម្រេច មិនជាសភាវៈមិនសម្រេច ព្រោះកាលបុគ្គលដាក់ឈ្មោះក៏ដាក់ឯង ដូច្នេះ ។

# កថាពោលលំដាប់ជាដើម

អ្នកប្រាជ្ញកាលជ្រាបខន្ធ ៥ ដោយបកិណ្ណកៈយ៉ាងនេះហើយ ដើម្បីការបែកធ្លាយនៃញាណក្នុងខន្ធទាំង ៥ នេះឯងទៀត គប្បីជ្រាបអត្ថនៃការវិនិច្ឆ័យឲ្យល្អ ដោយលំដាប់ ១ ដោយការប្លែកគ្នា ១ ដោយការមិនខ្វះមិនលើស ១ ដោយឧបមា ១ ដោយគប្បីឃើញដោយឧបមា ២ យ៉ាង ១ ដោយសម្រេចប្រយោជន៍ដល់អ្នកឃើញ ១ ។

ដោយអត្ថនៃការវិនិច្ឆ័យទាំង ៦ នោះ លំដាប់ក្នុងពាក្យថា ដោយលំដាប់នេះ មានច្រើនយ៉ាង គឺ **ឧប្បត្តិក្កមោ** លំដាប់នៃការកើត ១ **បហានក្កមោ** លំដាប់នៃការលះ ១ **បដិបត្តិក្កមោ** លំដាប់នៃបដិបត្តិ ១ **ភូមិក្កមោ** លំដាប់នៃភូមិ ១ **ទេសនាក្កមោ** លំដាប់នៃទេសនា ១ ។

ក្នុងលំដាប់ទាំង ៥ នោះ លំដាប់នៃការកើតឡើង មានព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ សគាថវគ្គ ) យ៉ាងនេះថា កលលរូបកើតជាដំបូង ត អំពីកលលរូបមកកើតជាអម្ពុទរូប ដូច្នេះជាដើម ។ លំដាប់នៃការលះ ដូចព្រះតម្រាស់ ( ក្នុងធម្មសង្គណី ) យ៉ាងនេះថា ពួកធម៌ដែលត្រូវលះដោយទស្សនៈ ពួកធម៌ដែលត្រូវលះដោយភាវនា ដូច្នេះជាដើម ។ លំដាប់នៃការបដិបត្តិ ដូចព្រះតម្រាស់ ( ក្នុងខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ) យ៉ាងនេះថា សីលវិសុទ្ធិ ចិត្តវិសុទ្ធិ ដូច្នេះជាដើម ។ លំដាប់នៃភូមិ ដូចព្រះតម្រាស់ ( ក្នុងធម្មសង្គណី ) យ៉ាងនេះថា កាមាវចរ រូបាវចរ ដូច្នេះជាដើម ។ លំដាប់នៃទេសនា ដូចព្រះតម្រាស់ ( ក្នុងទីឃនិកាយ បាដិកវគ្គ ) យ៉ាងនេះ

ថា សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ និងព្រះតម្រាស់ ( ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ) ថា ទានកថា សីលកថា ដូច្នេះជាដើម ។ ក្នុងលំដាប់ទាំង ៥ នោះ ក្នុងទីនេះ លំដាប់នៃការកើតឡើង រមែងមិនគួរ ព្រោះខន្ធទាំងឡាយ មិនកើតឡើងដោយការកំណត់ការមុនក្រោយ ដូចកលលរូបជាដើម ។ លំដាប់នៃការលះក៏មិនគួរ ព្រោះខន្ធដែលជាកុសល និងអព្យាកតៈជាសភាពមិនគួរលះ លំដាប់នៃការបដិបត្តិក៏មិនគួរ ព្រោះខន្ធដែលជាអកុសល ជារបស់មិនគប្បីបដិបត្តិ លំដាប់នៃភូមិក៏មិនគួរ ព្រោះវេទនាជាដើមជាធម៌ដែលទាក់ទងក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។

តែលំដាប់នៃទេសនា រមែងគួរ ព្រោះព្រះមានព្រះភាគទ្រង់ប្រាថ្នា ក្នុងប្រយោជន៍ មានបំណងនឹងដោះវេនេយ្យជនណាដែលធ្លាក់ទៅក្នុងការប្រកាន់ខន្ធ ៥ ថាជាអត្តា ចាកការប្រកាន់ថាជាអត្តា ដោយការសម្តែងចែកឃនៈដើម្បីការកាន់យកដោយងាយនៃជននោះ ទើបទ្រង់សម្តែងរូបក្ខន្ធដែលគ្រោតគ្រាតមុន ដែលជាអារម្មណ៍របស់ចក្ខុវិញ្ញាណជាដើម ដោយមិនផ្សេងគ្នា ។ បន្ទាប់អំពីនោះ ទ្រង់ក៏សម្តែងវេទនាដែលដឹងព្រមដែលមានរូបគួរជាទីប្រាថ្នានិងមិនគួរប្រាថ្នាជាអារម្មណ៍ ទ្រង់សម្តែងសញ្ញាដែលកាន់យកដោយអាការរបស់អារម្មណ៍វេទនា យ៉ាងនេះថា សោយនូវអារម្មណ៍ណា ក៏ចាំបាននូវអារម្មណ៍នោះ ដូច្នេះ ទ្រង់សម្តែងសង្ខារទាំងឡាយ ដែលមានសភាពតាក់តែងដោយអំណាចនៃសញ្ញា ទ្រង់សម្តែងវិញ្ញាណដែលជាទីអាស្រ័យ និងជាធំនៃខន្ធ មានវេទនាជាដើមនោះ ។ គប្បីជ្រាបអត្ថនៃការវិនិច្ឆ័យដោយលំដាប់

យ៉ាងនេះ ។

ពាក្យថា ដោយការប្រែកគ្នា បានដល់ ដោយការប្រែកគ្នានៃខន្ធ និងឧបាទានក្ខន្ធ ។ អ្វីជាការប្រែកគ្នានៃខន្ធ និងឧបាទានក្ខន្ធទាំងនោះ បណ្ដាខន្ធ និងឧបាទានក្ខន្ធទាំងនេះ ខន្ធទាំងឡាយ ត្រាស់ដោយមិនប្រែកគ្នា ឧបាទានក្ខន្ធទាំងឡាយ ត្រាស់ឲ្យប្រែកគ្នា ដោយជាខន្ធមានអាសវៈ និងជាទីតាំងនៃឧបាទាន ដូចព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវខន្ធទាំង ៥ ផង នូវឧបាទានក្ខន្ធទាំង ៥ ផង ចូរអ្នកទាំងឡាយ ប្រុងស្ដាប់នូវធម៌នោះចុះ ។ ម្នាលភិក្ខុទាំងឡាយ ខន្ធទាំង ៥ តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ រូបណាមួយជាអតីត អនាគត បច្ចុប្បន្ន ។បេ។ ក្នុងទីជិតក្ដី ។ នេះហៅថា រូបក្ខន្ធ ។ វេទនាណាមួយ ។បេ។ វិញ្ញាណណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ។បេ។ ក្នុងទីជិតក្ដី ។ នេះហៅថា វិញ្ញាណក្ខន្ធ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ហៅថា ខន្ធ ៥ ដូច្នេះ ។

ម្នាលភិក្ខុទាំងឡាយ រូបណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ។បេ។ ក្នុងទីជិតក្ដី ប្រកបដោយអាសវៈ ជាបច្ច័យនៃឧបាទាន ។ នេះហៅថា រូបូបាទានក្ខន្ធ ។ វេទនាណាមួយ ។បេ។ វិញ្ញាណណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ។បេ។ ក្នុងទីជិតក្ដី ប្រកបដោយអាសវៈ ជាបច្ច័យនៃឧបាទាន ។ នេះហៅថា វិញ្ញាណូបាទានក្ខន្ធ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ហៅថា ឧបាទានក្ខន្ធ ៥ ដូច្នេះ ។

ម្យ៉ាងទៀត ក្នុងខន្ធ ៥ និងឧបាទានក្ខន្ធ ៥ នេះ នាមក្ខន្ធ ៤ មាន

វេទនាជាដើម ដែលមិនមានអាសវៈក៏មាន ដែលមានអាសវៈក៏មាន យ៉ាងណា រូបក្ខន្ធយ៉ាងនោះក៏មិនមែន ។ ព្រោះភាពដែលរូបនេះគួរជាខន្ធ ដោយអត្ថថា គំនរ ហេតុនោះ ទើបត្រាស់ក្នុងពួកខន្ធទាំងឡាយ និងព្រោះភាពដែលរូបគួរជាឧបាទានក្ខន្ធ ដោយអត្ថថា ជាគំនរ និងអត្ថថា មានអាសវៈ ហេតុនោះ ទើបត្រាស់រូបនោះក្នុងឧបាទានក្ខន្ធ ។ ចំណែកនាមក្ខន្ធ មានវេទនាជាដើម ដែលមិនមានអាសវៈប៉ុណ្ណោះ ត្រាស់ក្នុងពួកខន្ធ ដែលមានអាសវៈ ត្រាស់ក្នុងពួកឧបាទានក្ខន្ធ ។

ក្នុងពាក្យថា ឧបាទានក្ខន្ធនេះ គប្បីជ្រាបសេចក្ដីយ៉ាងនេះថា ខន្ធ មានឧបាទានជាអារម្មណ៍ ឈ្មោះថា ឧបាទានក្ខន្ធ តែក្នុងអធិការនេះ ទ្រង់បំណងរួមខន្ធទាំងអស់នោះ ថាជាខន្ធ ។

ពាក្យថា ដោយការមិនខ្វះ មិនលើសនេះ សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់ខន្ធថា មាន ៥ ប៉ុណ្ណោះ មិនខ្វះ មិនលើស ដូច្នេះ ឆ្លើយថា ព្រោះទ្រង់សង្គ្រោះសង្ខតធម៌ទាំងអស់ ដែលមានចំណែកស្មើគ្នា ចូលជាពួកតែមួយ ព្រោះវត្ថុជាគ្រឿងប្រកាន់ថាខ្លួន ជារបស់ទាក់ទងដោយខ្លួននេះ មានខន្ធ ៥ យ៉ាងក្រៃលែង និងព្រោះភាពដែលធម៌ដទៃៗ ក៏មិនក្រៅអំពីខន្ធ ៥ នោះ ។ ពិតហើយ ព្រះមានព្រះភាគ កាលទ្រង់សង្គ្រោះសង្ខតធម៌ មានប្រភេទមិនមែនតិច ចូលដោយអំណាចដែលមានចំណែកស្មើគ្នា រូបក៏ជាខន្ធ ១ ដោយអំណាចការសង្គ្រោះរូប ដែលមានចំណែកស្មើគ្នា ចូលជាពួកតែមួយ វេទនាក៏ជាខន្ធ ១ ដោយអំណាចការសង្គ្រោះវេទនា

ដែលមានចំណែកស្មើគ្នាចូលជាពួកតែមួយ ក្នុងសញ្ញាខន្ធជាដើម ក៏ន័យនេះឯង ។ ព្រោះហេតុនោះ ទើបត្រាស់ខន្ធ ៥ ប៉ុណ្ណោះ ព្រោះទ្រង់សង្គ្រោះសង្ខតធម៌ទាំងអស់ ដែលមានចំណែកស្មើគ្នាជាពួកតែមួយ ។ម្យ៉ាងទៀត វត្ថុនៃការប្រកាន់ថាជាខ្លួន ជារបស់ទាក់ទងដោយខ្លួន មានខន្ធ ៥ មានរូបជាដើម យ៉ាងក្រៃលែង សេចក្ដីនេះ សមនឹងព្រះតម្រាស់ ដែលត្រាស់ ( ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ កាលបើរូបមាន ព្រោះអាស្រ័យនូវរូប ប្រកាន់នូវរូប ទើបទិដ្ឋិកើតឡើងយ៉ាងនេះថា នុ៎ះរបស់អញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញ ។ កាលបើវេទនាមាន ។បេ។ កាលបើសញ្ញាមាន ។បេ។ កាលបើសង្ខារទាំងឡាយមាន ។បេ។ កាលបើវិញ្ញាណមាន ព្រោះអាស្រ័យនូវវិញ្ញាណ ប្រកាន់នូវវិញ្ញាណ ទើបទិដ្ឋិកើតឡើង យ៉ាងនេះថា នុ៎ះរបស់អញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញ ដូច្នេះ ។

ព្រោះហេតុនោះ ទើបត្រាស់ខន្ធ ៥ ប៉ុណ្ណោះ ព្រោះវត្ថុនៃការប្រកាន់ជាខ្លួន និងទាក់ទងដោយខ្លួន ក៏មានខន្ធ ៥ នេះ យ៉ាងក្រៃលែង ។ ម្យ៉ាងទៀត ធម្មក្ខន្ធ ៥[១] មានសីលក្ខន្ធជាដើមណា ដែលត្រាស់ធម្មក្ខន្ធទាំងនោះ ក៏ដល់នូវការសង្គ្រោះចូលក្នុងខន្ធ ៥ នេះប៉ុណ្ណោះ ព្រោះធម្មក្ខន្ធ ជាធម៌ទាក់ទងក្នុងសង្ខារក្ខន្ធ ។ ព្រោះហេតុនោះ ទើបត្រាស់ខន្ធ ៥ ប៉ុណ្ណោះ ព្រោះធម៌ដទៃៗ មិនផុតអំពីខន្ធ ៥ នោះ ព្រោះហេតុនោះ គប្បីជ្រាបន័យវិនិច្ឆ័យ

---

១- សីលក្ខន្ធ ១ សមាធិក្ខន្ធ ១ បញ្ញាខន្ធ ១ វិមុត្តិក្ខន្ធ ១ វិមុត្តិញ្ញាណទស្សនក្ខន្ធ ១ ។

ដោយមិនខ្វះ មិនលើស ដោយប្រការដូច្នេះ ។

ក្នុងពាក្យថា ដោយឧបមានេះ រូបូបាទានក្ខន្ធ ប្រៀបដូចមន្ទីរពេទ្យ ព្រោះជាលំនៅដោយជាវត្ថុ ទ្វារ និងអារម្មណ៍របស់វិញ្ញាណូបាទានក្ខន្ធ ដែលប្រៀបដូចអ្នកជំងឺ ។ វេទនូបាទានក្ខន្ធ ប្រៀបដូចការឈឺ ព្រោះជាគ្រឿងបៀតបៀន ។ សញ្ញូបាទានក្ខន្ធ ប្រៀបដូចសមុដ្ឋាននៃជំងឺ ព្រោះជាដែនកើតនៃវេទនាដែលសម្បយុត្តដោយកិលេស មានរាគៈជាដើម ដោយអំណាចកាមសញ្ញាជាដើមនោះឯង ។ សង្ខារូបាទានក្ខន្ធ ប្រៀបដូចការសេពអសប្បាយ ព្រោះជាហេតុនៃជំងឺ គឺវេទនា សមដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ) ថា តាក់តែងនូវសង្ខតធម៌ គឺវេទនា តាមសភាពវេទនូវអារម្មណ៍ ដូច្នេះ និងព្រះតម្រាស់ ( ក្នុងអភិធម្មវិភង្គ ) ថា កាយវិញ្ញាណប្រឡំដោយទុក្ខ មានផ្សព្វជាអារម្មណ៍កើតឡើងហើយ ព្រោះភាពនៃអកុសលកម្មដែលសត្វធ្វើហើយ សន្សំហើយ ដូច្នេះ ។ វិញ្ញាណូបាទានក្ខន្ធ ប្រៀបដូចអ្នកជំងឺ ព្រោះមិនរួចផុតចាកការឈឺ គឺវេទនា ។ម្យ៉ាងទៀត ឧបាទានក្ខន្ធទាំង ៥ នេះ មានឧបមាដូចបុគ្គលដែលត្រាច់ទៅ ដូចការណៈ គឺហេតុ ដូចកំហុស ដូចអ្នកបង្កហេតុ ដូចអ្នកមានកំហុស និងប្រៀបដូចភាជនៈ ដូចភោជន ដូចម្ហូប ដូចអ្នកអង្គាសអាហារ ដូចអ្នកបរិភោគ ព្រោះហេតុនោះ គប្បីជ្រាបដោយន័យការវិនិច្ឆ័យខន្ធ ៥ ដោយឧបមាយ៉ាងនេះ ដូច្នេះ ។

# អធិប្បាយគប្បីឃើញដោយឧបមា ២ យ៉ាង

ពាក្យថា គប្បីឃើញដោយឧបមា ២ យ៉ាងនេះ បណ្ឌិតគប្បីជ្រាបន័យវិនិច្ឆ័យក្នុងខន្ធ ៥ នេះ ដោយគប្បីឃើញដោយឧបមា ២ យ៉ាង យ៉ាងនេះ គឺដោយសង្ខេប និងដោយពិស្តារ ។

កាលពោលដោយសង្ខេប ឧបាទានក្ខន្ធ ៥ បណ្ឌិតគប្បីឃើញដោយភាពជាសត្រូវដែលងាជាវ តាមន័យដែលត្រាស់នៅក្នុងអាសីវិសូបមសូត្រ ដោយជាភារៈ ដោយអំណាចភារសូត្រ ដោយភាពជាអ្នកទំពាស៊ី ដោយអំណាចខជ្ជនីយបរិយាយសូត្រ និងដោយភាពជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ជាសង្ខត: ជាអ្នកសម្លាប់ដោយអំណាចយមកសូត្រ ។ ឯដោយពិស្តារ ក្នុងឧបាទានក្ខន្ធ ៥ នេះ គប្បីឃើញរូប ដូចដុំពពុះទឹក គប្បីឃើញវេទនា ដូចក្រពេញទឹក គប្បីឃើញសញ្ញា ដូចថ្ងៃបណ្ដើរកូន គប្បីឃើញសង្ខារទាំងឡាយ ដូចដើមចេក គប្បីឃើញវិញ្ញាណ ដូចកល សមដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ ) ថា

> ព្រះពុទ្ធមានផៅពង្ស ដូចជាព្រះអាទិត្យសម្ដែងហើយថា រូបដូចជាដុំនៃពពុះទឹក វេទនាដូចជាក្រពេញទឹក សញ្ញាដូចជាព្រេញថ្ងៃ សង្ខារដូចជាដើមចេក វិញ្ញាណដូចជាកិច្ចកល ដូច្នេះ ។

ក្នុងព្រះបាលីនោះ គប្បីជ្រាបឧបាទានក្ខន្ធ ៥ មានរូបជាដើមដូចគ្នានឹងដុំពពុះទឹកជាដើមយ៉ាងនេះ ។ ដុំពពុះទឹកជារបស់មិនមានសារៈយ៉ាងណា រូបក៏យ៉ាងនោះ មិនមានសារៈ ព្រោះវៀរចាកនិច្ចសារៈ ជាវសារៈ អត្តាសារៈ

ដោយពិត ។ ម្យ៉ាងទៀត ដុំនៃពពុះទឹកនោះ បុគ្គលណាម្នាក់ មិនអាចកាន់យកដោយគិតថា អញនឹងធ្វើបាត្រ ឬភាជនៈ ដោយដុំនៃពពុះទឹកនេះ ទោះបីកាន់យកបាន ក៏មិនសម្រេចប្រយោជន៍នោះ រមែងបែកទៅយ៉ាងណា រូបក៏យ៉ាងនោះ បុគ្គលមិនអាចកាន់យកថា រូបនេះជារបស់ទៀង ស្ថិតស្ថេរ ឬថា រូបនេះជាអញ ជារបស់អញ ទោះបីកាន់យក រូបក៏មិនតាំងនៅយ៉ាងនោះ រមែងជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ជាអសុភទាំងអស់ ព្រោះហេតុនោះ ទើបរូបនោះ ដូចដុំពពុះទឹកយ៉ាងនេះ ។

ម្យ៉ាងទៀត ដុំពពុះទឹកមានប្រហោងតូចធំ ជាដុំជាប់គ្នាដោយទីតមិនមែនតិច ជាទីអាស្រ័យនៅរបស់សត្វមានពស់ទឹកជាដើមច្រើន យ៉ាងណា រូបក៏យ៉ាងនោះ មានប្រហោងតូចធំ ជាដុំជាប់តគ្នាដោយទីតមិនមែនតិច ត្រកូលនៃដង្កូវ ៨០ រមែងរស់នៅជាពួក ក្នុងរូបនេះឯង រូបនេះជាផ្ទះសម្រាប់កើតខ្លះ ជាបង្គន់ខ្លះ ជាមន្ទីរពេទ្យខ្លះ ជាទីចោលសាកសពខ្លះរបស់ត្រកូលដង្កូវទាំងនោះ ពួកត្រកូលដង្កូវទាំងនោះ មិនទៅធ្វើការប្រសូតក្នុងទីដទៃជាដើម ។ រូបដូចគ្នានឹងដុំនៃពពុះទឹកយ៉ាងនេះ ។

ម្យ៉ាងទៀត ដុំនៃពពុះទឹក ចាប់ផ្ដើមពីប៉ុនផ្លែពុទ្រា ហើយមានប្រមាណប៉ុនកំពូលភ្នំដោយលំដាប់ក៏មាន យ៉ាងណា រូបក៏យ៉ាងនោះ ផ្ដើមអំពីប៉ុនកលលៈប៉ុណ្ណោះ ហើយមានប្រមាណមួយព្យាមដោយលំដាប់ក៏មាន មានប្រមាណប៉ុនវត្ថុទាំងឡាយ មានកំពូលភ្នំជាដើម ដោយអំណាចនៃសត្វ មានគោ ក្របី ដំរីជាដើមក៏មាន មានប្រមាណច្រើនរយយោជន៍ ដោយអំណាច

នៃសត្វ មានត្រី និងអណ្តើកជាដើមក៏មាន រូបនោះ ក៏ឈ្មោះថា ដូចគ្នានឹងដុំនៃពពុះទឹកយ៉ាងនេះ ។

ម្យ៉ាងទៀត ដុំនៃពពុះទឹកតាំងឡើង រមែងបែកទៅក៏មាន តាំងឡើងបានបន្តិចបែកទៅក៏មាន កាលមិនបែកទៅក្នុងចន្លោះ លុះដល់សមុទ្រហើយ ក៏ត្រូវបែកទៅដោយឥតសង្ស័យយ៉ាងណា រូបក៏យ៉ាងនោះដូចគ្នា រមែងបែកទៅក្នុងពេលជាកលលៈក៏មាន ក្នុងពេលជាអព្វុទៈជាដើមក៏មាន បើមិនបែកទៅក្នុងចន្លោះ លុះដល់ ១០០ ឆ្នាំហើយ សម្រាប់សត្វដែលមានប្រមាណអាយុ ១០០ ឆ្នាំ ក៏ត្រូវបែកទៅដោយពិតនោះឯង រមែងក្លាយជាលម្អិតតូចធំ ធ្លាក់ក្នុងមាត់នៃមច្ចុរាជ ដោយអាការយ៉ាងនេះ រូបក៏ឈ្មោះថា ដូចគ្នានឹងដុំនៃពពុះទឹក ។

ម្យ៉ាងទៀត ក្រពេញទឹកមិនមានខ្លឹម យ៉ាងណា វេទនាក៏យ៉ាងនោះ ក្រពេញទឹកនោះ មិនមានកម្លាំង ចូលដល់ភាពជារបស់ដែលកាន់យកមិនបាន បុគ្គលណាម្នាក់ មិនអាចកាន់យកក្រពេញទឹកនោះ ដើម្បីធ្វើជាបន្ទះក្តារ ឬធ្វើជាអាសនៈបានឡើយ ទោះបីកាន់យកហើយក្រពេញទឹកក៏បែកទៅមួយរំពេចយ៉ាងណា វេទនាក៏យ៉ាងនោះ ជារបស់មិនមានកម្លាំង ជារបស់កាន់យកមិនបាន បុគ្គលណាម្នាក់ មិនអាចប្រកាន់វេទនាថា ទៀង ស្ថិតស្ថេរ ទោះបីកាន់យកហើយ ក៏មិនតាំងនៅយ៉ាងនោះបានឡើយ វេទនាដែលបុគ្គលកាន់យកមិនបានយ៉ាងនេះ ឈ្មោះថា ដូចគ្នានឹងក្រពេញទឹក ។

ម្យ៉ាងទៀត ក្រពេញទឹក រមែងកើតឡើង និងបែកទៅក្នុងតំណក់នៃទឹក

នោះៗ ជារបស់មិនតាំងនៅយូរ យ៉ាងណា វេទនាក៏យ៉ាងនោះ រមែងកើតឡើង និងរមែងរលត់ទៅ ជារបស់មិនតាំងនៅយូរ គឺវេទនានោះ ដែលបណ្ឌិតគប្បីរាប់បានសែនកោដិ កើតឡើងហើយ ក៏រលត់ទៅ ក្នុងមួយជួរនៃការផ្ទាត់ម្រាមដៃម្តង ។

ម្យ៉ាងទៀត ក្រពេញទឹកអាស្រ័យហេតុ ៤ គឺផ្ទៃទឹក ១ តំណក់ទឹក ១ ការសើមនៃទឹក ១ ខ្យល់ប៉ះខ្ទប់ធ្វើឲ្យប្រហោងក្នុង ១ ទើបកើតឡើង វេទនាក៏យ៉ាងនោះ អាស្រ័យហេតុ ៤ យ៉ាង គឺវត្ថុ ១ អារម្មណ៍ ១ បណ្តាញ គឺកិលេស ១ ការប៉ះខ្ទប់នៃផស្សៈ ១ ទើបកើតឡើង វេទនា ឈ្មោះថា ដូចគ្នានឹងក្រពេញទឹក ដោយប្រការដូច្នេះ ។

សញ្ញា ឈ្មោះថា ដូចគ្នានឹងថ្ងៃបណ្តើរកូន ដោយអត្ថថា មិនមានសារៈ និងដោយអត្ថថា ចូលដល់ភាពជារបស់ដែលបុគ្គលកាន់យកមិនបាន ព្រោះថាបុគ្គលណាម្នាក់ មិនអាចកាន់យកថ្ងៃបណ្តើរកូននោះមកដើម្បីផឹក ឬដើម្បីងូត ឬដើម្បីដាក់ឲ្យពេញភាជនៈបានឡើយ ម្យ៉ាងទៀត ថ្ងៃបណ្តើរកូន រមែងប្រែប្រួលទៅ គឺរមែងប្រាកដ ដូចក្រសែរលកដែលកើតឡើងឯង យ៉ាងណា សូម្បីសញ្ញា មានពណ៌ខៀវជាដើមក៏យ៉ាងនោះ រមែងប្រែប្រួល គឺផ្លាស់ប្តូរទៅ ដើម្បីសោយអារម្មណ៍នៃពណ៌ខៀវជាដើម ។

ម្យ៉ាងទៀត ថ្ងៃបណ្តើរកូន រមែងបញ្ឆោតមហាជន រមែងឲ្យពោលថាទីនោះហាក់ដូចជាបឹងពេញដោយទឹក ដូចស្ទឹងពេញដោយទឹក ដូច្នេះ យ៉ាងណា សញ្ញាក៏យ៉ាងនោះ រមែងបោកបញ្ឆោត រមែងឲ្យពោលថា នេះពណ៌

ខៀវ នេះស្អាត នេះសុខ នេះទៀង ដូច្នេះ ។ ក្នុងពណ៌លឿងជាដើមក៏ន័យនេះដូចគ្នា ។ សញ្ញា ឈ្មោះថា ដូចគ្នានឹងថ្ងៃបណ្តើរកូន ដោយការបោកបញ្ឆោតផ្សេងៗ ដោយប្រការដូច្នេះ ។

សង្ខារទាំងឡាយ ឈ្មោះថា ដូចគ្នានឹងដើមចេក ព្រោះអត្ថថា មិនមានសារៈ និងព្រោះអត្ថថា ដល់នូវការកាន់យកមិនបាន បុគ្គលមិនអាចកាន់យកអ្វីមួយអំពីដើមចេក បង្អោនទៅដើម្បីជាប្រយោជន៍ដល់ទព្វសម្ភារទាំងឡាយ មានបន្ទន់ជំបូលជាដើម សូម្បីបង្អោនចូលទៅហើយ ក៏មិនសម្រេចដោយប្រការនោះយ៉ាងណា សង្ខារទាំងឡាយក៏យ៉ាងនោះ បុគ្គលណាម្នាក់មិនអាចកាន់យកដោយអំណាចនៃការទៀងជាដើម ទោះបីកាន់យកហើយ ក៏មិនប្រព្រឹត្តទៅដោយប្រការនោះ ។

ម្យ៉ាងទៀត ដើមចេករមែងជាទីប្រជុំរបស់ស្រទបច្រើនយ៉ាងណា សង្ខារក្ខន្ធក៏ជាទីប្រជុំរបស់ធម៌ច្រើន ក៏យ៉ាងនោះ ។ ដើមចេកនោះ មានលក្ខណៈផ្សេងៗ គ្នា គឺពណ៌របស់ស្រទប ខាងក្រៅមួយបែប ពណ៌ស្រទបខាងក្នុងបន្ទាប់អំពីនោះក៏មួយបែបយ៉ាងណា សង្ខារក្ខន្ធក៏យ៉ាងនោះដូចគ្នា លក្ខណៈរបស់ផស្សៈក៏មួយបែប របស់ធម៌ មានចេតនាជាដើមក៏មួយបែប ព្រះមានព្រះភាគ ទ្រង់សង្គ្រោះហៅថា សង្ខារក្ខន្ធទាំងអស់ ព្រោះហេតុនោះ ទើបសង្ខារក្ខន្ធ ឈ្មោះថា ដូចគ្នានឹងដើមចេក ដោយប្រការដូច្នេះ ។

វិញ្ញាណ ឈ្មោះថា ដូចគ្នានឹងកលមាយា ព្រោះអត្ថថា មិនមានសារៈ និងព្រោះអត្ថថា ចូលដល់ការកាន់យកមិនបាន ។ កលមាយាជារបស់ប្រែ

ប្រួល មានការប្រាកដយ៉ាងរហ័សយ៉ាងណា វិញ្ញាណ ក៏យ៉ាងនោះ ព្រោះ វិញ្ញាណនោះ ជារបស់ប្រែប្រួលរហ័សជាង ប្រាកដរហ័សជាង ជាងកល-មាយានោះ ព្រោះថា មាយានោះ រមែងដូចជាមនុស្សមកហើយ ទៅហើយ ឈរហើយ អង្គុយហើយ ដោយចិត្តដួងនោះឯង តែចិត្តក្នុងពេលមកមួយ បែប ក្នុងពេលទៅជាដើមក៏មួយបែប ដូច្នេះ ទើបវិញ្ញាណ ឈ្មោះថា ដូចគ្នានឹងកលមាយាយ៉ាងនេះ ។

ម្យ៉ាងទៀត មាយារមែងបញ្ឆោតមហាជន ឲ្យកាន់យកវត្ថុណាមួយថា នេះមាស នេះប្រាក់ នេះកែវមុក្តាជាដើម វិញ្ញាណក៏បញ្ឆោតមហាជន ឲ្យប្រកាន់ ធ្វើហាក់ដូចមនុស្សកំពុងមក កំពុងទៅ ឈរហើយ អង្គុយហើយ ដោយចិត្តដួងនោះឯង តែចិត្តក្នុងកាលមកមួយបែប ក្នុងកាលទៅជាដើម ក៏មួយបែប វិញ្ញាណ ក៏ឈ្មោះថា ដូចគ្នានឹងកលមាយាយ៉ាងនេះ ។

ម្យ៉ាងទៀត ពោលដោយពិសេស បណ្ឌិតគប្បីជ្រាបអជ្ឈត្តិករូបដែលជាសុភារម្មណ៍ក្តី ដែលជាអារម្មណ៍ប្រសើរក្តី ថាជាអសុភ គប្បីឃើញវេទនាថាជាទុក្ខ ព្រោះមិនផុតចាកភាពជាទុក្ខទាំង ៣ គប្បីឃើញសញ្ញា និងសង្ខារទាំងឡាយថា ជាអនត្តា ព្រោះភាពជារបស់ដែលបុគ្គលគប្បីឲ្យទ្រទ្រង់នៅមិនបាន គប្បីឃើញវិញ្ញាណថា ជារបស់មិនទៀង ព្រោះមានការកើតឡើង និងវិនាសទៅជាធម្មតា ។

កាលបុគ្គលឃើញយ៉ាងនេះ រមែងសម្រេចប្រយោជន៍បាន ។ ការសម្រេចប្រយោជន៍ណា រមែងមានដល់បុគ្គលដែលឃើញ ២ យ៉ាង ដោយ

អំណាចនៃអត្ថដោយសង្ខេប និងដោយពិស្តារយ៉ាងនេះ បណ្ឌិតគប្បីជ្រាបទ័យ វិនិច្ឆ័យដោយការសម្រេចប្រយោជន៍នោះ ។ សេចក្តីនេះដូចម្តេច គឺពោល ដោយសង្ខេបមុន បុគ្គលកាលឃើញឧបាទានក្ខន្ធ ៥ ដោយភាពដូចជាសត្រូវ កំពុងផាដាវជាដើម រមែងមិនក្តៅក្រហាយព្រោះខន្ធ ៥ ។ កាលបើពោល ដោយពិស្តារ បុគ្គលកាលឃើញនូវអារម្មណ៍ មានរូបជាដើមដោយភាពដូច គ្នានឹងដុំពពុះទឹកជាដើម រមែងមិនជាអ្នកឃើញខន្ធដែលមិនមានសារៈ ថាជា ខន្ធមានសារៈ ។

តែបើពោលដោយពិសេស បុគ្គលកាលឃើញនូវរូបខាងក្នុងដោយភាព ជារបស់មិនស្អាត រមែងកំណត់ដឹងកពឡិង្ការាហារ រមែងលះវិបល្លាស ថា ស្អាតក្នុងវត្ថុដែលមិនស្អាត រមែងឆ្លងផុតកាមោឃៈ រមែងប្រាសចាកកាមោយៈ ជាអ្នកមិនមានកាមាសវៈ រមែងទម្លាយកាយគន្ថៈ គឺអភិជ្ឈា រមែងមិនប្រកាន់ មាំក្នុងកាមុបាទាន ។ កាលឃើញវេទនាដោយភាពជាទុក្ខ រមែងកំណត់ដឹង ផស្សាហារ រមែងលះបង់វិបល្លាសថាជាសុខក្នុងវត្ថុដែលជាទុក្ខ រមែងឆ្លង ផុតភវោឃៈ រមែងប្រាសចាកភវយោគៈ ជាអ្នកមិនមានអាសវៈ រមែង ទម្លាយព្យាបាទកាយគន្ថៈ រមែងមិនប្រកាន់មាំ ក្នុងសីលព្វតុបាទាន កាល ឃើញសញ្ញា និងសង្ខារទាំងឡាយ ដោយភាពជាអនត្តា រមែងកំណត់ដឹង មនោសញ្ចេតនាហារ រមែងលះវិបល្លាសថាជាអត្តាក្នុងវត្ថុដែលមិនមែនអត្តា រមែងឆ្លងផុតទិដ្ឋោឃៈ រមែងប្រាសចាកទិដ្ឋិយោគៈ ជាអ្នកមិនមានទិដ្ឋាសវៈ រមែងទម្លាយកាយគន្ថៈ គឺការប្រកាន់មាំថា វត្ថុនេះពិត រមែងមិនប្រកាន់មាំ

ក្នុងអត្តវាទុបាទាន ។ កាលឃើញវិញ្ញាណដោយភាពមិនទៀង រមែងកំណត់ដឹងវិញ្ញាណាហារ រមែងលះវិបល្លាស ថាទៀងក្នុងវត្ថុដែលមិនទៀង រមែងឆ្លងផុតអវិជ្ជោឃៈ រមែងប្រាសចាកអវិជ្ជាយោគៈ ជាអ្នកមិនមានអវិជ្ជាសវៈ រមែងទម្លាយកាយគន្ថៈ គឺសីលព្វតបរាមាស រមែងមិនប្រកាន់មាំក្នុងទិដ្ឋុបាទាន រមែងឃើញខន្ធ ៥ ថាជាអ្នកសម្លាប់ជាដើម មានអានិសង្សច្រើន ហេតុនោះ អ្នកប្រាជ្ញគប្បីឃើញខន្ធទាំងឡាយ ដោយអំណាចភាពជាអ្នកសម្លាប់ជាដើមចុះ ។

## អធិប្បាយសុត្តន្តភាជនីយ ចប់

# អភិធម្មបិដក

## អភិធម្មភាជនីយ

[ ៣២ ] ខន្ធ ៥ គឺរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ និងវិញ្ញា-ណក្ខន្ធ ។

បណ្តាខន្ធទាំងនោះ រូបក្ខន្ធ តើដូចម្តេច ។

[ ៣៣ ] រូបក្ខន្ធមានប្រការ ១ បានដល់ រូបទាំងពួង មិនមែនហេតុ ឥតហេតុ ប្រាសចាកហេតុ ប្រកបដោយបច្ច័យ ត្រូវបច្ច័យតាក់តែង រូបជាលោកិយ ប្រកបដោយអាសវៈ ជាប្រយោជន៍ដល់សំយោជនៈ ដែលគន្ថៈគប្បីដោតក្រង ដែលឱឃៈគប្បីប្រព្រឹត្តកន្លង ដែលយោគៈគប្បីប្រព្រឹត្តកន្លង ជាប្រយោជន៍ដល់នីវរណៈ ដែលបរាមាសស្ទាបអង្អែល ជាប្រយោជន៍ដល់ឧបាទាន គួរដល់សេចក្តីសៅហ្មង ជាអព្យាក្រឹត មិនមែនអារម្មណ៍ មិនមែនចេតសិក ប្រាសចាកចិត្ត ជាសភាវៈមិនមែនវិបាក មិនមែនមានវិបាកជាប្រក្រតី ជារូបមិនសៅហ្មង តែគួរដល់សេចក្តីសៅហ្មង ជារូបប្រកបដោយវិតក្ក ប្រកបដោយវិចារក៏មិនមែន មិនមានវិតក្ក មានត្រឹមតែវិចារក៏មិនមែន មិនមានវិតក្ក មិនមានវិចារ មិនប្រកបដោយបីតិ មិនប្រកបដោយសុខ មិនប្រកបដោយឧបេក្ខា ជារូបមិនត្រូវលះដោយទស្សនៈ ទាំងមិនត្រូវលះបង់ដោយភាវនា ជារូបមានហេតុ មិនត្រូវលះដោយទស្សនៈ ទាំងមិនត្រូវលះដោយភាវនា មិនដល់នូវការសន្សំកពូនឡើង មិនដល់នូវការមិនសន្សំកពូនឡើង មិនមែនជារបស់សេក្ខបុគ្គល មិនមែនជារបស់អសេក្ខបុគ្គល ជារូបមានប្រមាណតូចឆ្មារ ជាកាមាវចរ មិនមែនរូបាវចរ មិនមែនអរូបាវចរ ជា

បរិយាបន្ន មិនមែនអបរិយាបន្ន ជាអនិយតៈ ជាអនិយ្យានិកៈដែលកើត ឡើងហើយ ដែលគួរដឹងដោយវិញ្ញាណ ៦ ជារូបមិនទៀង ត្រូវជរាគ្រប សង្កត់ រូបក្ខន្ធមានប្រការមួយយ៉ាងនេះឯង ។

[ ៣៤ ] រូបក្ខន្ធមានប្រការ ២ គឺរូបជាឧបាទាក៏មាន រូបមិនមែនជា ឧបាទាក៏មាន ។ រូបជាឧបាទិន្នក៏មាន រូបជាអនុបាទិន្នក៏មាន ។ រូបជាឧបា-ទិន្នុបាទានីយៈក៏មាន រូបជាអនុបាទិន្នុបាទានីយៈក៏មាន ។ រូបជាសនិទស្សនៈ ក៏មាន រូបជាអនិទស្សនៈក៏មាន ។ រូបជាសប្បដិឃៈក៏មាន រូបជាអប្បដិឃៈ ក៏មាន ។ រូបជាឥន្ទ្រិយក៏មាន រូបមិនមែនជាឥន្ទ្រិយក៏មាន ។ រូបជាមហាភូត ក៏មាន រូបមិនមែនជាមហាភូតក៏មាន ។ រូបជាវិញ្ញត្តិក៏មាន រូបមិនមែនជា វិញ្ញត្តិក៏មាន ។ រូបជាចិត្តសមុដ្ឋានក៏មាន រូបមិនមែនជាចិត្តសមុដ្ឋានក៏មាន ។ រូបជាចិត្តសហភូក៏មាន រូបមិនមែនជាចិត្តសហភូក៏មាន ។ រូបជាចិត្តានុបរិវត្តិ ក៏មាន រូបមិនមែនជាចិត្តានុបរិវត្តិក៏មាន ។ រូបជាខាងក្នុងក៏មាន រូបជាខាង ក្រៅក៏មាន ។ រូបគ្រោតគ្រាតក៏មាន រូបល្អិតក៏មាន ។ រូបតាំងនៅក្នុងទី ឆ្ងាយក៏មាន រូបតាំងនៅក្នុងទីជិតក៏មាន ។បេ។ រូបជាកពឡិង្ការាហារក៏មាន រូបមិនមែនជាកពឡិង្ការាហារក៏មាន ។ រូបក្ខន្ធមានប្រការ ២ យ៉ាងនេះឯង ។

[ ៣៥ ] រូបក្ខន្ធមានប្រការ ៣ គឺរូបណាខាងក្នុង រូបនោះ ជាឧបាទា រូបណាខាងក្រៅ រូបនោះ ជាឧបាទាក៏មាន មិនមែនជាឧបាទាក៏មាន ។ រូប ណាខាងក្នុង រូបនោះ ជាឧបាទិន្ន រូបណាខាងក្រៅ រូបនោះ ជាឧបាទិន្នក៏មាន ជាអនុបាទិន្នក៏មាន ។ រូបណាខាងក្នុង រូបនោះជាឧបាទិន្នុបាទានីយៈ រូប

ណាខាងក្រៅ រូបនោះ ជាឧបាទិន្នុបាទានីយៈក៏មាន ជាអនុបាទិន្នុបាទានីយៈក៏មាន ។បេ។ រូបណាខាងក្នុង រូបនោះ មិនមែនជាកពឡិង្ការាហារ រូបណាខាងក្រៅ រូបនោះ ជាកពឡិង្ការាហារក៏មាន មិនមែនជាកពឡិង្ការាហារក៏មាន រូបក្ខន្ធមានប្រការ ៣ យ៉ាងនេះឯង ។

[ ៣៦ ] រូបក្ខន្ធមានប្រការ ៤ គឺរូបណាជាឧបាទា រូបនោះ ជាឧបាទិន្នក៏មាន ជាអនុបាទិន្នក៏មាន រូបណាជាអនុបាទា រូបនោះ ជាឧបាទិន្នក៏មាន ជាអនុបាទិន្នក៏មាន រូបណាជាឧបាទា រូបនោះ ជាឧបាទិន្នុបាទានីយៈក៏មាន ជាអនុបាទិន្នុបាទានីយៈក៏មាន រូបណាជាអនុបាទា រូបនោះ ជាឧបាទិន្នុបាទានីយៈក៏មាន ជាអនុបាទិន្នុបាទានីយៈក៏មាន ។ រូបណាជាឧបាទា រូបនោះ ជាសប្បដិឃៈក៏មាន ជាអប្បដិឃៈក៏មាន រូបណាជាអនុបាទា រូបនោះ ជាសប្បដិឃៈក៏មាន ជាអប្បដិឃៈក៏មាន ។ រូបណាជាឧបាទា រូបនោះ ជាឱឡារិកៈក៏មាន ជាសុខុមក៏មាន រូបណាជាអនុបាទា រូបនោះ ជាឱឡារិកក៏មាន ជាសុខុមក៏មាន ។ រូបណាជាឧបាទា រូបនោះ ជាទូរេក៏មាន ជាសន្តិកេក៏មាន រូបណាជាអនុបាទា រូបនោះ ជាទូរេក៏មាន ជាសន្តិកេក៏មាន ។បេ។ រូបដែលបុគ្គលឃើញ ឮ លិទ្ធភ្លក្សដឹងច្បាស់ហើយ រូបក្ខន្ធមានប្រការ ៤ យ៉ាងនេះឯង ។

[ ៣៧ ] រូបក្ខន្ធមានប្រការ ៥ គឺបឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ និងឧបាទារូប រូបក្ខន្ធមានប្រការ ៥ យ៉ាងនេះឯង ។

[ ៣៨ ] រូបក្ខន្ធមានប្រការ ៦ គឺរូបដែលគប្បីដឹងដោយភ្នែក រូបដែលគប្បីដឹងដោយត្រចៀក រូបដែលគប្បីដឹងដោយច្រមុះ រូបដែលគប្បីដឹងដោយ

អណ្ណាត រូបដែលគប្បីដឹងដោយកាយ រូបដែលគប្បីដឹងដោយចិត្ត រូបក្ខន្ធមានប្រការ ៦ យ៉ាងនេះឯង ។

[ ៣៩ ] រូបក្ខន្ធមានប្រការ ៧ គឺរូបដែលគប្បីដឹងដោយភ្នែក ។បេ។ រូបដែលគប្បីដឹងដោយមនោធាតុ រូបដែលគប្បីដឹងដោយមនោវិញ្ញាណធាតុ រូបក្ខន្ធមានប្រការ ៧ យ៉ាងនេះឯង ។

[ ៤០ ] រូបក្ខន្ធមានប្រការ ៨ គឺរូបដែលគប្បីដឹងដោយភ្នែក ។បេ។ រូបដែលគប្បីដឹងដោយកាយ មានសម្ផស្សជាសុខក៏មាន មានសម្ផស្សជាទុក្ខក៏មាន រូបដែលគប្បីដឹងដោយមនោធាតុ រូបដែលគប្បីដឹងដោយមនោវិញ្ញាណ-ធាតុ រូបក្ខន្ធមានប្រការ ៨ យ៉ាងនេះឯង ។

[ ៤១ ] រូបក្ខន្ធមានប្រការ ៩ គឺចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ ទាំងរូបណា ដែលមិនមែនឥន្ទ្រិយ រូបក្ខន្ធមានប្រការ ៩ យ៉ាងនេះឯង ។

[ ៤២ ] រូបក្ខន្ធមានប្រការ ១០ គឺចក្ខុន្ទ្រិយ ។បេ។ ជីវិតិន្ទ្រិយ រូបមិនមែនឥន្ទ្រិយ រូបប្រកបដោយការប៉ះពាល់ក៏មាន មិនប្រកបដោយការប៉ះពាល់ក៏មាន រូបក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

[ ៤៣ ] រូបក្ខន្ធមានប្រការ ១១ គឺចក្ខ្វាយតនៈ សោតាយតនៈ

ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ទាំងរូបណា ដែលមិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ រាប់បញ្ចូលក្នុងធម្មាយតនៈ រូបក្ខន្ធមានប្រការ ១១ យ៉ាងនេះឯង ។

នេះហៅថារូបក្ខន្ធ ។

បណ្តាខន្ធទាំងនោះ វេទនាខន្ធ តើដូចម្តេច ។

[ ៤៤ ] វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធ ប្រកបដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធ ប្រកបដោយហេតុក៏មាន មិនប្រកបដោយហេតុក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ វេទនាខន្ធមានប្រការ ៤ គឺវេទនាខន្ធជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន ។ វេទនាខន្ធមានប្រការ ៥ គឺជាសុខិន្ទ្រិយក៏មាន ជាទុក្ខិន្ទ្រិយក៏មាន ជាសោមនស្សិន្ទ្រិយក៏មាន ជាទោមនស្សិន្ទ្រិយក៏មាន ជាឧបេក្ខិន្ទ្រិយក៏មាន ។ វេទនាខន្ធមានប្រការ ៦ គឺវេទនាកើតអំពីចក្ខុសម្ផស្ស វេទនាកើតអំពីសោតសម្ផស្ស វេទនាកើតអំពីឃានសម្ផស្ស វេទនាកើតអំពីជិវ្ហាសម្ផស្ស វេទនាកើតអំពីកាយសម្ផស្ស វេទនាកើតអំពីមនោសម្ផស្ស វេទនាខន្ធមានប្រការ ៦ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ៧ គឺវេទនាកើតអំពីចក្ខុសម្ផស្ស ។បេ។ វេទនាកើតអំពីកាយ-

សម្ផស្ស វេទនាកើតអំពីមនោធាតុសម្ផស្ស វេទនាកើតអំពីមនោវិញ្ញាណ-ធាតុសម្ផស្ស វេទនាខន្ធមានប្រការ ៧ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ៨ គឺវេទនាកើតអំពីចក្ខុសម្ផស្ស ។បេ។ វេទនាកើតអំពីកាយ-សម្ផស្ស ជាសុខក៏មាន ជាទុក្ខក៏មាន វេទនាកើតអំពីមនោធាតុសម្ផស្ស វេទនាកើតអំពីមនោវិញ្ញាណធាតុសម្ផស្ស វេទនាខន្ធមានប្រការ ៨ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ៩ គឺវេទនាកើតអំពីចក្ខុសម្ផស្ស ។បេ។ វេទនាកើតអំពីកាយសម្ផស្ស វេទនាកើតអំពីមនោធាតុសម្ផស្ស វេទនាកើតអំពីមនោវិញ្ញាណធាតុសម្ផស្ស ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន វេទនាខន្ធមានប្រការ ៩ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១០ គឺវេទនាកើតអំពីចក្ខុសម្ផស្ស ។បេ។ វេទនាកើតអំពីកាយ-សម្ផស្ស ជាសុខក៏មាន ជាទុក្ខក៏មាន វេទនាកើតអំពីមនោធាតុសម្ផស្ស វេទនាកើតអំពីមនោវិញ្ញាណធាតុសម្ផស្ស ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

[ ៤៥ ] វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមានហេតុក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធ ជាវិបាកក៏មាន ជាធម៌មានវិបាកជាប្រក្រតីក៏មាន មិនមែនជាវិបាកមិនមែនមានធម៌ជាវិបាកជាប្រក្រតីក៏មាន មានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមានកម្មប្រកប

ដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន ។ ប្រកបដោយសេចក្តីសៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មងក៏មាន មិនប្រកបដោយសេចក្តីសៅហ្មង តែគួរដល់សេចក្តីសៅហ្មងក៏មាន មិនប្រកបដោយសេចក្តីសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន ប្រព្រឹត្តទៅជាមួយនឹងវិតក្ក ប្រព្រឹត្តទៅជាមួយនឹងវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន គួរលះដោយទស្សនៈក៏មាន គួរលះដោយភាវនាក៏មាន មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាក៏មាន មានហេតុគួរលះដោយទស្សនៈក៏មាន មានហេតុគួរលះដោយភាវនាក៏មាន មានហេតុមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាក៏មាន ដល់នូវការសន្សំកពូនឡើងក៏មាន ដល់នូវការមិនសន្សំកពូនឡើងក៏មាន មិនដល់នូវការសន្សំកពូនឡើង មិនដល់នូវការមិនសន្សំកពូនឡើងក៏មាន ជារបស់សេក្ខបុគ្គលក៏មាន ជារបស់អសេក្ខបុគ្គលក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គលក៏មាន មានសភាពតូចថ្មាក៏មាន ដល់នូវសភាពធំក៏មាន ប្រមាណមិនបានក៏មាន មានអារម្មណ៍តូចថ្មាក៏មាន មានអារម្មណ៍ដល់នូវសភាពធំក៏មាន មានអារម្មណ៍ប្រមាណមិនបានក៏មាន ថោកទាបក៏មាន យ៉ាងកណ្តាលក៏មាន យ៉ាងឧត្តមក៏មាន មានសភាពខុស និងទៀងក៏មាន មានសភាពត្រូវ និងទៀងក៏មាន មានសភាពមិនទៀងក៏មាន មានមគ្គជា

អារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន កើតហើយក៏មាន មិនទាន់កើតក៏មាន ប្រុងនឹងកើតឡើងក៏មាន ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន មានអារម្មណ៍ជាអតីតក៏មាន មានអារម្មណ៍ជាអនាគតក៏មាន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ជាខាងក្នុង និងខាងក្រៅក៏មាន មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង និងខាងក្រៅក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

[ ៤៦ ] វេទនាខន្ធ មានប្រការ ១ បានដល់ វេទនាខន្ធប្រកបដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធប្រកបដោយហេតុក៏មាន ប្រាសចាកហេតុក៏មាន មិនមែនហេតុ តែប្រកបដោយហេតុក៏មាន មិនមែនហេតុ ទាំងមិនមានហេតុក៏មាន ជាលោកិយក៏មាន ជាលោកុត្តរក៏មាន គប្បីដឹងដោយវិញ្ញាណណាមួយក៏មាន មិនគប្បីដឹងដោយវិញ្ញាណណាមួយក៏មាន ប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន មិនមានអាសវៈក៏មាន ប្រកបដោយអាសវៈក៏មាន ប្រាសចាកអាសវៈក៏មាន ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រាសចាកអាសវៈទាំងមិនមានអាសវៈក៏មាន ជាប្រយោជន៍ដល់សំយោជនៈក៏មាន មិនជាប្រយោជន៍ដល់សំយោជនៈក៏មាន ប្រកបដោយសំយោជនៈក៏មាន ប្រាសចាកសំយោជនៈក៏មាន ប្រាសចាកសំយោជនៈ តែជាប្រយោជន៍ដល់សំយោជនៈក៏មាន ប្រាសចាកសំយោជនៈទាំងមិនជាប្រយោជន៍ដល់សំយោជនៈក៏មាន ដែលគន្ថៈគប្បីដោតក្រងក៏មាន

ដែលគន្ថៈមិនគប្បីដោតក្រង៏ក៏មាន ប្រកបដោយគន្ថៈក៏មាន ប្រាសចាកគន្ថៈ ក៏មាន ប្រាសចាកគន្ថៈ តែជាធម៌ដែលគន្ថៈគប្បីដោតក្រង៏ក៏មាន ប្រាសចាកគន្ថៈ ទាំងជាធម៌ដែលគន្ថៈមិនគប្បីដោតក្រង៏ក៏មាន ដែលឱឃៈគប្បីប្រព្រឹត្តកន្លង៏ក៏មាន ដែលឱឃៈមិនគប្បីប្រព្រឹត្តកន្លង៏ក៏មាន ប្រកបដោយឱឃៈក៏មាន ប្រាសចាកឱឃៈក៏មាន ប្រាសចាកឱឃៈ តែជាធម៌ដែលឱឃៈ គប្បីប្រព្រឹត្តកន្លង៏ក៏មាន ប្រាសចាកឱឃៈ ទាំងជាធម៌ដែលឱឃៈមិនគប្បីប្រព្រឹត្តកន្លង៏ក៏មាន ដែលយោគៈគប្បីប្រព្រឹត្តកន្លង៏ក៏មាន ដែលយោគៈមិនគប្បីប្រព្រឹត្តកន្លង៏ក៏មាន ប្រកបដោយយោគៈក៏មាន ប្រាសចាកយោគៈក៏មាន ប្រាសចាកយោគៈ តែជាប្រយោជន៍ដល់យោគៈក៏មាន ប្រាសចាកយោគៈ ទាំងមិនជាប្រយោជន៍ដល់យោគៈក៏មាន ជាប្រយោជន៍ដល់នីវរណៈក៏មាន មិនជាប្រយោជន៍ដល់នីវរណៈក៏មាន ប្រកបដោយនីវរណៈក៏មាន ប្រាសចាកនីវរណៈក៏មាន ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈក៏មាន ប្រាសចាកនីវរណៈ ទាំងមិនជាប្រយោជន៍ដល់នីវរណៈក៏មាន ដែលបរាមាសស្ទាបអង្អែលក៏មាន បរាមាសមិនស្ទាបអង្អែលក៏មាន ប្រកបដោយបរាមាសក៏មាន ប្រាសចាកបរាមាសក៏មាន ប្រាសចាកបរាមាស តែជាធម៌ដែលបរាមាសស្ទាបអង្អែលក៏មាន ប្រាសចាកបរាមាស ទាំងជាធម៌ដែលបរាមាសមិនស្ទាបអង្អែលក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយក៏មាន ជាប្រយោជន៍ដល់ឧបាទានក៏មាន មិនជាប្រយោជន៍

ដល់ឧបាទានក៏មាន ប្រកបដោយឧបាទានក៏មាន ប្រាសចាកឧបាទានក៏មាន ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទានក៏មាន ប្រាសចាកឧបាទាន ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន គួរដល់សេចក្តីសៅហ្មងក៏មាន មិនគួរដល់សេចក្តីសៅហ្មងក៏មាន សៅហ្មងហើយក៏មាន មិនសៅហ្មងហើយក៏មាន ប្រកបដោយកិលេសក៏មាន ប្រាសចាកកិលេសក៏មាន ប្រាសចាកកិលេស តែគួរដល់សេចក្តីសៅហ្មងក៏មាន ប្រាសចាកកិលេស ទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន គួរលះដោយទស្សនៈក៏មាន មិនគួរលះដោយទស្សនៈក៏មាន គួរលះដោយភាវនាក៏មាន មិនគួរលះដោយភាវនាក៏មាន មានហេតុគួរលះដោយទស្សនៈក៏មាន មានហេតុមិនគួរលះដោយទស្សនៈក៏មាន មានហេតុគួរលះដោយភាវនាក៏មាន មានហេតុមិនគួរលះដោយភាវនាក៏មាន ប្រព្រឹត្តទៅជាមួយនឹងវិតក្កក៏មាន មិនមានវិតក្កក៏មាន ប្រព្រឹត្តទៅជាមួយនឹងវិចារក៏មាន មិនមានវិចារក៏មាន ប្រព្រឹត្តទៅជាមួយនឹងបីតិក៏មាន មិនមានបីតិក៏មាន កើតព្រមដោយបីតិក៏មាន មិនកើតព្រមដោយបីតិក៏មាន ជាកាមាវចរក៏មាន មិនមែនកាមាវចរក៏មាន ជារូបាវចរក៏មាន មិនមែនរូបា-វចរក៏មាន ជាអរូបាវចរក៏មាន មិនមែនអរូបាវចរក៏មាន ជាបរិយាបន្នក៏មាន ជាអបរិយាបន្នក៏មាន ជានិយ្យានិកៈក៏មាន ជាអនិយ្យានិកៈក៏មាន ជានិយតៈក៏មាន ជាអនិយតៈក៏មាន ប្រកបដោយឧត្តរៈក៏មាន មិនមានឧត្តរៈក៏មាន ប្រកបដោយរណៈ ( សេចក្តីសៅហ្មង ) ក៏មាន មិនមានរណៈក៏មាន ។

វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជា

អព្យាក្រឹតក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

[ ៤៧ ] វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធប្រកបដោយរណៈក៏មាន មិនមានរណៈក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធជាវិបាកក៏មាន ជាធម៌មានវិបាកជាប្រក្រតីក៏មាន មិនមែនជាវិបាក មិនមែនមានធម៌ជាវិបាកជាប្រក្រតីក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ខាងក្នុង និងខាងក្រៅក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

## ទុកមូលកៈ ចប់

[ ៤៨ ] វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធប្រកបដោយហេតុក៏មាន មិនមានហេតុក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធប្រកបដោយរណៈក៏មាន មិនមានរណៈក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១ បានដល់ វេទនា-ខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធប្រកប

ដោយហេតុក៏មាន មិនមានហេតុក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនា-ខន្ធជាវិបាកក៏មាន ជាធម៌មានវិបាកជាប្រក្រតីក៏មាន មិនមែនជាវិបាកមិនមែនមានធម៌ជាវិបាកជាប្រក្រតីក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធប្រកបដោយរណៈក៏មាន មិនមានរណៈក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធជាវិបាកក៏មាន ជាធម៌មានវិបាកជាប្រក្រតីក៏មាន មិនមែនជាវិបាក មិនមែនជាធម៌មានវិបាកជាប្រក្រតីក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

**តិកមូលកៈ ចប់**

[ ៤៩ ] វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធប្រកបដោយហេតុក៏មាន មិនមានហេតុក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដ៏សម្ប-យុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធប្រកបដោយហេតុក៏មាន ប្រាសចាកហេតុក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនា-

ខន្ធជាវិបាកក៏មាន ជាធម៌មានវិបាកជាប្រក្រតីក៏មាន មិនមែនជាវិបាក មិនមែនជាធម៌មានវិបាកជាប្រក្រតីក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធមិនមែនហេតុ តែប្រកបដោយហេតុក៏មាន មិនមែនហេតុទាំងមិនមានហេតុក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធជាលោកិយក៏មាន ជាលោកុត្តរក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធសៅហ្មងហើយ ទាំងគួរដល់សេចក្តីសៅហ្មងក៏មាន មិនសៅហ្មងហើយ តែគួរដល់សេចក្តីសៅហ្មងក៏មាន មិនសៅហ្មងហើយ ទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធ ដែលគប្បីដឹងដោយវិញ្ញាណណាមួយក៏មាន ដែលមិនគប្បីដឹងដោយវិញ្ញាណណាមួយក៏មាន ។ វេទនាខន្ធមានប្រការ ៣

គឺវេទនាខន្ធ ប្រព្រឹត្តទៅជាមួយនឹងវិតក្ក ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារក៏មាន មិនមានវិតក្កមានត្រឹមតែវិចារក៏មាន មិនមានវិតក្កទាំងមិនមានវិចារក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធប្រកបដោយអាសវៈក៏មាន មិនមានអាសវៈក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធគួរលះដោយទស្សនៈក៏មាន គួរលះដោយភាវនាក៏មាន មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធប្រកបដោយអាសវៈក៏មាន ប្រាសចាកអាសវៈក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធមានហេតុគួរលះដោយទស្សនៈក៏មាន មានហេតុគួរលះដោយភាវនាក៏មាន មានហេតុមិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដែលសម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រាសចាកអាសវៈទាំងមិនមានអាសវៈក៏មាន ។ វេទនាខន្ធ មានប្រការ ៣ គឺវេទនាខន្ធដល់នូវការសន្សំកពូនឡើងក៏មាន ដល់នូវការមិនសន្សំកពូនឡើងក៏មាន មិនដល់នូវការសន្សំកពូនឡើង ទាំងមិនដល់នូវការសន្សំកពូនឡើងក៏មាន ។បេ។ វេទនាខន្ធមាន

ប្រការ ១០ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដែលសម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធជាប្រយោជន៍ដល់សំយោជនៈក៏មាន មិនជាប្រយោជន៍ដល់សំយោជនៈក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធជារបស់សេក្ខបុគ្គលក៏មាន ជារបស់អសេក្ខបុគ្គលក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គលក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធប្រកបដោយសំយោជនៈក៏មាន ប្រាសចាកសំយោជនៈក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធមានសភាពតូចថ្មារក៏មាន ដល់នូវសភាពធំក៏មាន ប្រមាណមិនបានក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដែលសម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺ វេទនាខន្ធ ប្រាសចាកសំយោជនៈ តែជាប្រយោជន៍ដល់សំយោជនៈក៏មាន ប្រាសចាកសំយោជនៈ ទាំងមិនជាប្រយោជន៍ដល់សំយោជនៈក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធ មានអារម្មណ៍តូចថ្មារក៏មាន មានអារម្មណ៍ដល់នូវសភាពធំក៏មាន មានអារម្មណ៍ប្រមាណមិនបានក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺ វេទនាខន្ធ ដែលគន្ថៈគប្បីដោតក្រងក៏មាន ដែលគន្ថៈមិនគប្បីដោតក្រងក៏

មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធថោកទាបក៏មាន កណ្តាលក៏មាន ថ្លៃថ្លាក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធប្រកបដោយគន្ថៈក៏មាន ប្រាសចាកគន្ថៈក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធមានសភាពខុស និងទៀងក៏មាន មានសភាពត្រូវ និងទៀងក៏មាន មានសភាពមិនទៀងក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រងក៏មាន ប្រាសចាកគន្ថៈ តែគន្ថៈមិនគប្បីដោតក្រងក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធមានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធដែលឱឃៈគប្បីប្រព្រឹត្តកន្លងក៏មាន ដែលឱឃៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធកើតហើយក៏មាន មិនទាន់កើតហើយក៏មាន ដែលប្រុងនឹងកើតក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធប្រកបដោយឱឃៈក៏មាន ប្រាសចាកឱឃៈក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនា-

ខន្ធជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធប្រាសចាកឱយៈ តែឱយៈគប្បីប្រព្រឹត្តកន្លងក៏មាន ប្រាសចាកឱយៈ ទាំងឱយៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធមានអារម្មណ៍ជាអតីតក៏មាន មានអារម្មណ៍ជាអនាគតក៏មាន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធ ដែលយោគៈគប្បីប្រព្រឹត្តកន្លងក៏មាន ដែលយោគៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ទាំងខាងក្នុងទាំងខាងក្រៅក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ១ បានដល់ វេទនាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វេទនាខន្ធមានប្រការ ២ គឺវេទនាខន្ធប្រកបដោយយោគៈក៏មាន ប្រាសចាកយោគៈក៏មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធមានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុងទាំងខាងក្រៅក៏មាន ។បេ។ វេទនាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

ឧភតោវឌ្ឍកៈ ចប់

[ ៥០ ] វេទនាខន្ធមានប្រការ ៧ គឺវេទនាខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន វេទនាខន្ធមានប្រការ ៧ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ៧ ដទៃទៀត គឺវេទនាខន្ធជាវិបាកក៏មាន ជាធម៌មានវិបាកជាប្រក្រតីក៏មាន មិនមែនជាធម៌មានវិបាក ទាំងមិនមែនមានវិបាកជាប្រក្រតីក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុងទាំងខាងក្រៅក៏មាន ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន វេទនាខន្ធមានប្រការ ៧ យ៉ាងនេះឯង ។

[ ៥១ ] វេទនាខន្ធមានប្រការ ២៤ គឺវេទនាខន្ធព្រោះចក្ខុសម្ផស្សជាបច្ច័យជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន វេទនាខន្ធព្រោះសោតសម្ផស្សជាបច្ច័យ ។បេ។ វេទនាខន្ធព្រោះឃានសម្ផស្សជាបច្ច័យ ។បេ។ វេទនាខន្ធព្រោះជិវ្ហាសម្ផស្សជាបច្ច័យ វេទនាខន្ធព្រោះកាយ-សម្ផស្សជាបច្ច័យ ។បេ។ វេទនាខន្ធព្រោះមនោសម្ផស្សជាបច្ច័យ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន វេទនាកើតអំពីចក្ខុសម្ផស្ស វេទនាកើតអំពីសោតសម្ផស្ស វេទនាកើតអំពីឃានសម្ផស្ស វេទនាកើតអំពីជិវ្ហាសម្ផស្ស វេទនាកើតអំពីកាយសម្ផស្ស វេទនាកើតអំពីមនោសម្ផស្ស វេទនាខន្ធមានប្រការ ២៤ យ៉ាងនេះឯង ។ វេទនាខន្ធមានប្រការ ២៤ ដទៃទៀត គឺវេទនាខន្ធព្រោះចក្ខុសម្ផស្សជាបច្ច័យជាវិបាកក៏មាន ជាធម៌មាន

វិបាកជាប្រក្រតីក៏មាន មិនមែនជាធម៌មានវិបាក ទាំងមិនមែនមានវិបាកជាប្រក្រតីក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុងទាំងខាងក្រៅក៏មាន វេទនាខន្ធព្រោះសោតសម្ផស្សជាបច្ច័យ ។បេ។ វេទនាខន្ធព្រោះឃានសម្ផស្សជាបច្ច័យ ។បេ។ វេទនាខន្ធព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ។បេ។ វេទនាខន្ធព្រោះកាយសម្ផស្សជាបច្ច័យ ។បេ។ វេទនាខន្ធព្រោះមនោសម្ផស្សជាបច្ច័យ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុងទាំងខាងក្រៅក៏មាន វេទនាកើតអំពីចក្ខុសម្ផស្ស ។បេ។ វេទនាកើតអំពីមនោសម្ផស្ស វេទនាខន្ធមានប្រការ ២៤ យ៉ាងនេះឯង ។

[ ៥២ ] វេទនាខន្ធមានប្រការ ៣០ គឺវេទនាខន្ធព្រោះចក្ខុសម្ផស្សជាបច្ច័យ ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន វេទនាខន្ធព្រោះសោតសម្ផស្សជាបច្ច័យ ។បេ។ ព្រោះឃានសម្ផស្សជាបច្ច័យ ។បេ។ ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ។បេ។ ព្រោះកាយសម្ផស្សជាបច្ច័យ ។បេ។ ព្រោះមនោសម្ផស្សជាបច្ច័យ ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន វេទនាកើតអំពីចក្ខុសម្ផស្ស ។បេ។ វេទនាកើតអំពីមនោសម្ផស្ស វេទនាខន្ធមានប្រការ ៣០ យ៉ាងនេះឯង ។

[ ៥៣ ] វេទនាខន្ធមានច្រើនប្រការ គឺវេទនាខន្ធព្រោះចក្ខុសម្ផស្សជាបច្ច័យ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ជា

កាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន វេទនាខន្ធ ព្រោះសោតសម្ផស្សជាបច្ច័យ ។បេ។ ព្រោះឃានសម្ផស្សជាបច្ច័យ ។បេ។ ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ។បេ។ ព្រោះកាយសម្ផស្សជាបច្ច័យ ។បេ។ ព្រោះមនោសម្ផស្សជាបច្ច័យ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបា-វចរក៏មាន ជាអបរិយាបន្នក៏មាន វេទនាកើតអំពីចក្ខុសម្ផស្ស ។បេ។ វេទនាកើតអំពីមនោសម្ផស្ស វេទនាខន្ធមានច្រើនប្រការយ៉ាងនេះឯង ។ វេទនាខន្ធមានច្រើនប្រការដទៃទៀត គឺវេទនាខន្ធព្រោះចក្ខុសម្ផស្សជាបច្ច័យ ជាវិបាកក៏មាន ជាធម៌មានវិបាកជាប្រក្រតីក៏មាន មិនមែនជាធម៌មានវិបាក ទាំងមិនមែនមានវិបាកជាប្រក្រតីក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុងទាំងខាងក្រៅក៏មាន ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន វេទនាខន្ធ ព្រោះសោតសម្ផស្សជាបច្ច័យ ។បេ។ ព្រោះឃានសម្ផស្សជាបច្ច័យ ។បេ។ ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ។បេ។ ព្រោះកាយសម្ផស្សជាបច្ច័យ ។បេ។ ព្រោះមនោសម្ផស្សជាបច្ច័យ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុងទាំងខាងក្រៅក៏មាន ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន វេទនាកើតអំពីចក្ខុសម្ផស្ស ។បេ។ វេទនាកើតអំពីមនោសម្ផស្ស វេទនាខន្ធមានច្រើនប្រការយ៉ាងនេះឯង ។

**នេះហៅថាវេទនាខន្ធ ។**

បណ្ដាខន្ធទាំងនោះ សញ្ញាខន្ធ តើដូចម្ដេច ។

[ ៥៤ ] សញ្ញាខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្ត ដោយផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញាខន្ធប្រកបដោយហេតុក៏មាន មិនមានហេតុក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ សញ្ញាខន្ធមានប្រការ ៤ គឺសញ្ញាខន្ធជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន ។ សញ្ញាខន្ធមានប្រការ ៥ គឺសញ្ញាខន្ធប្រកបដោយសុខិន្ទ្រិយក៏មាន ប្រកបដោយទុក្ខិន្ទ្រិយក៏មាន ប្រកបដោយសោមនស្សិន្ទ្រិយក៏មាន ប្រកបដោយទោមនស្សិន្ទ្រិយក៏មាន ប្រកបដោយឧបេក្ខិន្ទ្រិយក៏មាន ។ សញ្ញាខន្ធមានប្រការ ៦ គឺសញ្ញាកើតអំពីចក្ខុសម្ផស្ស សញ្ញាកើតអំពីសោតសម្ផស្ស សញ្ញាកើតអំពីឃានសម្ផស្ស សញ្ញាកើតអំពីជិវ្ហាសម្ផស្ស សញ្ញាកើតអំពីកាយសម្ផស្ស សញ្ញាកើតអំពីមនោសម្ផស្ស សញ្ញាខន្ធមានប្រការ ៦ យ៉ាងនេះឯង ។ សញ្ញាខន្ធមានប្រការ ៧ គឺសញ្ញាកើតអំពីចក្ខុសម្ផស្ស ។បេ។ សញ្ញាកើតអំពីកាយសម្ផស្ស សញ្ញាកើតអំពីមនោធាតុសម្ផស្ស សញ្ញាកើតអំពីមនោវិញ្ញាណធាតុសម្ផស្ស សញ្ញាខន្ធមានប្រការ ៧ យ៉ាងនេះឯង ។ សញ្ញាខន្ធមានប្រការ ៨ គឺសញ្ញាកើតអំពីចក្ខុសម្ផស្ស ។បេ។ សញ្ញាកើតអំពីកាយសម្ផស្សកើតព្រមដោយសុខក៏មាន កើតព្រមដោយទុក្ខក៏មាន សញ្ញាកើតអំពីមនោធាតុសម្ផស្ស សញ្ញាកើតអំពីមនោវិញ្ញាណធាតុសម្ផស្ស សញ្ញាខន្ធមានប្រការ ៨ យ៉ាងនេះឯង ។

សញ្ញាខន្ធមានប្រការ ៩ គឺសញ្ញាកើតអំពីចក្ខុសម្ផស្ស ។បេ។ សញ្ញាកើតអំពីកាយសម្ផស្ស សញ្ញាកើតអំពីមនោធាតុសម្ផស្ស សញ្ញាកើតអំពីមនោ-វិញ្ញាណធាតុសម្ផស្ស ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន សញ្ញាខន្ធមានប្រការ ៩ យ៉ាងនេះឯង ។ សញ្ញាខន្ធមានប្រការ ១០ គឺសញ្ញាកើតអំពីចក្ខុសម្ផស្ស ។បេ។ សញ្ញាកើតអំពីកាយសម្ផស្ស កើតព្រមដោយសុខក៏មាន កើតព្រមដោយទុក្ខក៏មាន សញ្ញាកើតអំពីមនោធាតុ-សម្ផស្ស សញ្ញាកើតអំពីមនោវិញ្ញាណធាតុសម្ផស្ស ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

[ ៥៥ ] សញ្ញាខន្ធ មានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញាខន្ធប្រកបដោយហេតុក៏មាន មិនមានហេតុក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខម-សុខវេទនាក៏មាន ជាវិបាកក៏មាន ជាធម៌មានវិបាកជាប្រក្រតីក៏មាន មិនមែនជាធម៌មានវិបាក ទាំងមិនមែនមានវិបាកជាប្រក្រតីក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន

សៅហ្មងហើយ ទាំងគួរដល់សេចក្ដីសៅហ្មងក៏មាន មិនសៅហ្មងហើយ តែគួរដល់សេចក្ដីសៅហ្មងក៏មាន មិនសៅហ្មងហើយ ទាំងមិនគួរដល់សេចក្ដីសៅហ្មងក៏មាន ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ប្រព្រឹត្តទៅជាមួយនឹងវិចារក៏មាន មិនមានវិតក្កមានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន កើតព្រមដោយបីតិក៏មាន កើតព្រមដោយសុខក៏មាន កើតព្រមដោយឧបេក្ខាក៏មាន គួរលះដោយទស្សនៈក៏មាន គួរលះដោយភាវនាក៏មាន មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន មានហេតុ គួរលះដោយទស្សនៈក៏មាន មានហេតុ គួរលះដោយភាវនាក៏មាន មានហេតុ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន ដល់នូវការសន្សំកពូនឡើងក៏មាន ដល់នូវការមិនសន្សំកពូនឡើងក៏មាន មិនដល់នូវការសន្សំកពូនឡើង ទាំងមិនដល់នូវការមិនសន្សំកពូនឡើងក៏មាន ជារបស់សេក្ខបុគ្គលក៏មាន ជារបស់អសេក្ខបុគ្គលក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គលក៏មាន មានសភាពតូចថ្មារក៏មាន ដល់នូវសភាពធំក៏មាន ប្រមាណមិនបានក៏មាន មានអារម្មណ៍តូចថ្មារក៏មាន មានអារម្មណ៍ដល់នូវសភាពធំក៏មាន មានអារម្មណ៍ប្រមាណមិនបានក៏មាន ថោកទាបក៏មាន យ៉ាងកណ្ដាលក៏មាន យ៉ាងឧត្ដមក៏មាន មានសភាពខុស និងទៀងក៏មាន មានសភាពត្រូវ និងទៀងក៏មាន មានសភាពមិនទៀងក៏មាន មានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន កើតហើយក៏មាន មិនទាន់កើតក៏មាន ប្រុងនឹងកើតឡើងក៏មាន ជាអតីតក៏មាន

ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន មានអារម្មណ៍ជាអតីតក៏មាន មានអា-រម្មណ៍ជាអនាគតក៏មាន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ជាខាងក្នុង និងខាងក្រៅក៏មាន មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុងទាំងខាងក្រៅក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

[ ៥៦ ] សញ្ញាខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញាខន្ធប្រកបដោយហេតុក៏មាន ប្រាសចាកហេតុក៏មាន មិនមែនហេតុតែប្រព្រឹត្តនៅជាមួយនឹងហេតុក៏មាន មិនមែនហេតុទាំងមិនប្រកបដោយហេតុក៏មាន ជាលោកិយក៏មាន ជាលោកុត្តរក៏មាន ដែលគប្បីដឹងដោយវិញ្ញាណណាមួយក៏មាន ដែលមិនគប្បីដឹងដោយវិញ្ញាណណាមួយក៏មាន ប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន មិនមានអាសវៈក៏មាន ប្រកបដោយអាសវៈក៏មាន ប្រាសចាកអាសវៈក៏មាន ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រាសចាកអាសវៈទាំងមិនមានអាសវៈក៏មាន ជាប្រយោជន៍ដល់សំយោជនៈក៏មាន មិនជាប្រយោជន៍ដល់សំយោជនៈក៏មាន ប្រកបដោយសំយោជនៈក៏មាន ប្រាសចាកសំយោជនៈក៏មាន ប្រាសចាកសំយោជនៈ តែជាប្រយោជន៍ដល់សំយោជនៈក៏មាន ប្រាសចាកសំយោជនៈ ទាំងមិនជាប្រយោជន៍ដល់សំយោជនៈក៏មាន ដែលគន្ថៈគប្បីដោតក្រងក៏មាន ដែលគន្ថៈមិនគប្បីដោតក្រងក៏មាន ប្រកបដោយគន្ថៈក៏មាន ប្រាសចាកគន្ថៈក៏មាន ប្រាសចាកគន្ថៈ តែគន្ថៈគប្បី

ជោតក្រេងក៏មាន ប្រាសចាកគន្ថៈ ទាំងគន្ថៈមិនគប្បីជោតក្រេងក៏មាន ដែលឱឃៈគប្បីប្រព្រឹត្តកន្លងក៏មាន ដែលឱឃៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ប្រកបដោយឱឃៈក៏មាន ប្រាសចាកឱឃៈក៏មាន ប្រាសចាកឱឃៈ តែឱឃៈគប្បីប្រព្រឹត្តកន្លងក៏មាន ប្រាសចាកឱឃៈ ទាំងឱឃៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ដែលយោគៈគប្បីប្រព្រឹត្តកន្លងក៏មាន ដែលយោគៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ប្រកបដោយយោគៈក៏មាន ប្រាសចាកយោគៈក៏មាន ប្រាសចាកយោគៈ តែយោគៈគប្បីប្រព្រឹត្តកន្លងក៏មាន ប្រាសចាកយោគៈ ទាំងយោគៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ជាប្រយោជន៍ដល់នីវរណៈក៏មាន មិនជាប្រយោជន៍ដល់នីវរណៈក៏មាន ប្រកបដោយនីវរណៈក៏មាន ប្រាសចាកនីវរណៈក៏មាន ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈក៏មាន ប្រាសចាកនីវរណៈ ទាំងមិនជាប្រយោជន៍ដល់នីវរណៈក៏មាន ដែលបរាមាសស្ទាបអង្អែលក៏មាន បរាមាសមិនស្ទាបអង្អែលក៏មាន ប្រកបដោយបរាមាសក៏មាន ប្រាសចាកបរាមាសក៏មាន ប្រាសចាកបរាមាស តែបរាមាសស្ទាបអង្អែលហើយក៏មាន ប្រាសចាកបរាមាស ទាំងបរាមាសមិនស្ទាបអង្អែលហើយក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយក៏មាន ជាប្រយោជន៍ដល់ឧបាទានក៏មាន មិនជាប្រយោជន៍ដល់ឧបាទានក៏មាន ប្រកបដោយឧបាទានក៏មាន ប្រាសចាកឧបាទានក៏មាន ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទានក៏មាន ប្រាសចាកឧបាទាន ទាំងមិនជាប្រយោជន៍

ដល់ឧបាទានក៏មាន គួរដល់សេចក្តីសៅហ្មងក៏មាន មិនគួរដល់សេចក្តីសៅហ្មងក៏មាន សៅហ្មងហើយក៏មាន មិនសៅហ្មងហើយក៏មាន ប្រកបដោយកិលេសក៏មាន ប្រាសចាកកិលេសក៏មាន ប្រាសចាកកិលេស តែគួរដល់សេចក្តីសៅហ្មងក៏មាន ប្រាសចាកកិលេស ទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន គួរលះដោយទស្សនៈក៏មាន មិនគួរលះដោយទស្សនៈក៏មាន គួរលះដោយភាវនាក៏មាន មិនគួរលះដោយភាវនាក៏មាន មានហេតុគួរលះដោយទស្សនៈក៏មាន មានហេតុមិនគួរលះដោយទស្សនៈក៏មាន មានហេតុគួរលះដោយភាវនាក៏មាន មានហេតុមិនគួរលះដោយភាវនាក៏មាន ប្រព្រឹត្តទៅជាមួយនឹងវិតក្កក៏មាន មិនមានវិតក្កក៏មាន ប្រព្រឹត្តទៅជាមួយនឹងវិចារក៏មាន មិនមានវិចារក៏មាន ប្រព្រឹត្តទៅជាមួយនឹងបីតិក៏មាន មិនមានបីតិក៏មាន កើតព្រមដោយបីតិក៏មាន មិនកើតព្រមដោយបីតិក៏មាន កើតព្រមដោយសុខក៏មាន មិនកើតព្រមដោយសុខក៏មាន កើតព្រមដោយឧបេក្ខាក៏មាន មិនកើតព្រមដោយឧបេក្ខាក៏មាន ជាកាមាវចរក៏មាន មិនមែនជាកាមាវចរក៏មាន ជារូបាវចរក៏មាន មិនមែនជារូបាវចរក៏មាន ជាអរូបាវចរក៏មាន មិនមែនជាអរូ-បាវចរក៏មាន ជាបរិយាបន្នក៏មាន ជាអបរិយាបន្នក៏មាន ជានិយ្យានិកៈក៏មាន ជាអនិយ្យានិកៈក៏មាន ជានិយតៈក៏មាន ជាអនិយតៈក៏មាន ប្រកបដោយឧត្តរៈក៏មាន មិនមានឧត្តរៈក៏មាន ប្រកបដោយរណៈក៏មាន មិនមានរណៈក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។បេ។ សញ្ញាខន្ធ មានប្រការ ១០

យ៉ាងនេះឯង ។

[ ៥៧ ] សញ្ញាខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្ត ដោយផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញាខន្ធប្រកបដោយរណៈក៏មាន មិនមានរណៈក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុងទាំងខាងក្រៅក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

## ទុកមូលកៈ ចប់

[ ៥៨ ] សញ្ញាខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្ត ដោយផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញាខន្ធប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមានហេតុក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញាខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញាខន្ធប្រកបដោយរណៈក៏មាន មិនមានរណៈក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញាខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធមាន

ប្រការ ២ គឺសញ្ញាខន្ធ ប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមានហេតុក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុងទាំងខាងក្រៅក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញាខន្ធ មានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញាខន្ធប្រកបដោយរណៈក៏មាន មិនមានរណៈក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខ-វេទនាក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

## តិកមូលកៈ ចប់

[ ៥៩ ] សញ្ញាខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញាខន្ធមានហេតុក៏មាន មិនមានហេតុក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញាខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញាខន្ធប្រកបដោយហេតុក៏

មាន ប្រាសចាកហេតុក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធប្រកប ដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខម- សុខវេទនាក៏មាន ។បេ។ សញ្ញាខន្ធ មានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញាខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញាខន្ធមិនមែនហេតុ តែប្រព្រឹត្តទៅជាមួយ នឹងហេតុក៏មាន មិនមែនហេតុ ទាំងមិនប្រកបដោយហេតុក៏មាន ។ សញ្ញា- ខន្ធមានប្រការ ៣ គឺសញ្ញាខន្ធជាវិបាកក៏មាន ជាធម៌មានវិបាកជាប្រក្រតីក៏ មាន មិនមែនជាធម៌មានវិបាកទាំងមិនមែនមានវិបាកជាប្រក្រតីក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញាខន្ធមានប្រការ ១ បាន ដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺ សញ្ញាខន្ធជាលោកិយក៏មាន ជាលោកុត្តរក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមានកម្មប្រកបដោយកិលេស មាន តណ្ហាជាដើមកាន់យក តែជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមានកម្ម ប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យក ទាំងមិនជាប្រយោជន៍ដល់ ឧបាទានក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញា- ខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញា ខន្ធមានប្រការ ២ គឺសញ្ញាខន្ធដែលគប្បីដឹងដោយវិញ្ញាណណាមួយក៏មាន ដែលមិនគប្បីដឹងដោយវិញ្ញាណណាមួយក៏មាន ។ សញ្ញាខន្ធមានប្រការ ៣

គឺសញ្ញាខន្ធដែលសៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មងក៏មាន មិនសៅហ្មង តែគួរដល់សេចក្តីសៅហ្មងក៏មាន មិនសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញាខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញាខន្ធមានអាសវៈក៏មាន មិនមានអាសវៈក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធមានវិតក្ក ទាំងមានវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញាខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញាខន្ធប្រកបដោយអាសវៈក៏មាន ប្រាសចាកអាសវៈក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធ កើតព្រមដោយបីតិក៏មាន កើតព្រមដោយសុខក៏មាន កើតព្រមដោយឧបេក្ខាក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញាខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញាខន្ធប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធ ដែលគួរលះដោយទស្សនៈក៏មាន គួរលះដោយភាវនាក៏មាន មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញាខន្ធ មានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយ

ផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញាខន្ធជាប្រយោជន៍ដល់សំយោជនៈ ក៏មាន មិនជាប្រយោជន៍ដល់សំយោជនៈក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធមានហេតុគួរលះដោយទស្សនៈក៏មាន មានហេតុគួរលះដោយភាវនាក៏មាន មានហេតុមិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា ក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញាខន្ធមាន ប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធមាន ប្រការ ២ គឺសញ្ញាខន្ធប្រកបដោយសំយោជនៈក៏មាន ប្រាសចាកសំយោជនៈ ក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធដល់នូវការសន្សំកពូនឡើង ក៏មាន ដល់នូវការមិនសន្សំកពូនឡើងក៏មាន មិនមែនជាដល់នូវការសន្សំ កពូនឡើង ទាំងមិនដល់នូវការមិនសន្សំកពូនឡើងក៏មាន ។បេ។ សញ្ញាខន្ធ មានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញាខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញាខន្ធ ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ប្រាសចាក សញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ។ សញ្ញាខន្ធមាន ប្រការ ៣ គឺសញ្ញាខន្ធជារបស់សេក្ខបុគ្គលក៏មាន ជារបស់អសេក្ខបុគ្គល ក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គលក៏ មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញាខន្ធមាន ប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធមាន ប្រការ ២ គឺសញ្ញាខន្ធ ដែលគន្ថៈគប្បីដោតក្រងក៏មាន ដែលគន្ថៈមិនគប្បី

ដោតត្រងក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធមានសភាពតូចឆ្មារ ក៏មាន ដល់នូវសភាពធំក៏មាន ប្រមាណមិនបានក៏មាន ។បេ។ សញ្ញាខន្ធ មានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញាខន្ធ មានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញា-ខន្ធប្រកបដោយគន្ថៈក៏មាន ប្រាសចាកគន្ថៈក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធមានអារម្មណ៍តូចឆ្មារក៏មាន មានអារម្មណ៍ដល់នូវសភាពធំក៏ មាន មានអារម្មណ៍ប្រមាណមិនបានក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញាខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្ត ដោយផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញាខន្ធប្រាសចាកគន្ថៈ តែ គន្ថៈគប្បីដោតត្រងក៏មាន ប្រាសចាកគន្ថៈ ទាំងគន្ថៈមិនគប្បីដោតត្រងក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធថោកទាបក៏មាន យ៉ាងកណ្ដាលក៏មាន យ៉ាងឧត្តមក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញាខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញាខន្ធ ដែលឱឃៈគប្បីប្រព្រឹត្តកន្លងក៏មាន ដែលឱឃៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺ សញ្ញាខន្ធមានសភាពខុស និងទៀងក៏មាន មានសភាពត្រូវ និងទៀងក៏មាន មានសភាពមិនទៀងក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះ ឯង ។ សញ្ញាខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយ ផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញាខន្ធប្រកបដោយឱឃៈក៏មាន

ប្រាសចាកឱឃៈក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធ មានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញាខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធ មានប្រការ ២ គឺសញ្ញាខន្ធប្រាសចាកឱឃៈ តែឱឃៈគប្បីប្រព្រឹត្តកន្លងក៏មាន ប្រាសចាកឱឃៈទាំងឱឃៈ មិនគប្បីប្រព្រឹត្តកន្លងក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធកើតឡើងហើយក៏មាន មិនទាន់កើតឡើងក៏មាន ប្រុងនឹងកើតឡើងក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញាខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញាខន្ធដែលយោគៈគប្បីប្រព្រឹត្តកន្លងក៏មាន ដែលយោគៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញាខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញាខន្ធ ប្រកបដោយយោគៈក៏មាន ប្រាសចាកយោគៈក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធ មានអារម្មណ៍ជាអតីតក៏មាន មានអារម្មណ៍ជាអនាគតក៏មាន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញាខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធ មានប្រការ ២ គឺសញ្ញាខន្ធប្រាសចាកយោគៈ តែ

យោគៈ គប្បីប្រព្រឹត្តកន្លងក៏មាន ប្រាសចាកយោគៈ ទាំងយោគៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធខាងក្នុងក៏មាន ខាងក្រៅក៏មាន ទាំងខាងក្នុង និងខាងក្រៅក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សញ្ញាខន្ធមានប្រការ ១ បានដល់ សញ្ញាខន្ធដ៏សម្បយុត្តដោយផស្សៈ ។ សញ្ញាខន្ធមានប្រការ ២ គឺសញ្ញាខន្ធ ជាប្រយោជន៍ដល់នីវរណៈក៏មាន មិនជាប្រយោជន៍ដល់នីវរណៈក៏មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធមានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ។បេ។ សញ្ញាខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

## ឧភតោវឌ្ឍកៈ ចប់

[ ៦០ ] សញ្ញាខន្ធ មានប្រការ ៧ គឺសញ្ញាខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន សញ្ញាខន្ធមានប្រការ ៧ យ៉ាងនេះឯង ។ សញ្ញាខន្ធមានប្រការ ៧ ដទៃទៀត គឺសញ្ញាខន្ធប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន សញ្ញាខន្ធ មានប្រការ ៧ យ៉ាងនេះឯង ។

[ ៦១ ] សញ្ញាខន្ធ មានប្រការ ២៤ គឺសញ្ញាខន្ធព្រោះចក្ខុសម្ផស្សជាបច្ច័យ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន សញ្ញាខន្ធព្រោះសោតសម្ផស្សជាបច្ច័យ ។បេ។ ព្រោះឃានសម្ផស្សជាបច្ច័យ ។បេ។ ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ។បេ។ ព្រោះកាយសម្ផស្សជាបច្ច័យ ។បេ។ ព្រោះមនោសម្ផស្សជាបច្ច័យ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន សញ្ញាកើតអំពីចក្ខុសម្ផស្ស សញ្ញាកើតអំពីសោតសម្ផស្ស សញ្ញាកើតអំពីឃានសម្ផស្ស សញ្ញាកើតអំពីជិវ្ហាសម្ផស្ស សញ្ញាកើតអំពីកាយសម្ផស្ស សញ្ញាកើតអំពីមនោសម្ផស្ស សញ្ញាខន្ធ មានប្រការ ២៤ យ៉ាងនេះឯង ។ សញ្ញាខន្ធមានប្រការ ២៤ ដទៃទៀត គឺសញ្ញាខន្ធព្រោះចក្ខុសម្ផស្សជាបច្ច័យ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន សញ្ញាខន្ធ ព្រោះសោតសម្ផស្សជាបច្ច័យ ។បេ។ ព្រោះឃានសម្ផស្សជាបច្ច័យ ។បេ។ ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ។បេ។ ព្រោះកាយសម្ផស្សជាបច្ច័យ ។បេ។ ព្រោះមនោសម្ផស្សជាបច្ច័យ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន សញ្ញាកើតអំពីចក្ខុសម្ផស្ស ។បេ។ សញ្ញាកើតអំពីមនោសម្ផស្ស សញ្ញាខន្ធមានប្រការ ២៤ យ៉ាងនេះឯង ។

[ ៦២ ] សញ្ញាខន្ធមានប្រការ ៣០ គឺសញ្ញាខន្ធ ព្រោះចក្ខុសម្ផស្សជា

បច្ច័យ ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន សញ្ញាខន្ធព្រោះសោតសម្ផស្សជាបច្ច័យ ។បេ។ ព្រោះឃានសម្ផស្សជាបច្ច័យ ។បេ។ ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ។បេ។ ព្រោះកាយសម្ផស្សជាបច្ច័យ ។បេ។ ព្រោះមនោសម្ផស្សជាបច្ច័យ ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន សញ្ញាកើតអំពីចក្ខុសម្ផស្ស ។បេ។ សញ្ញាកើតអំពីមនោសម្ផស្ស សញ្ញាខន្ធមានប្រការ ៣០ យ៉ាងនេះឯង ។

[ ៦៣ ] សញ្ញាខន្ធមានច្រើនប្រការ គឺសញ្ញាខន្ធព្រោះចក្ខុសម្ផស្សជាបច្ច័យ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន ។ សញ្ញាខន្ធ ព្រោះសោតសម្ផស្សជាបច្ច័យ ។បេ។ ព្រោះឃានសម្ផស្សជាបច្ច័យ ។បេ។ ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ។បេ។ ព្រោះកាយសម្ផស្សជាបច្ច័យ ។បេ។ ព្រោះមនោសម្ផស្សជាបច្ច័យ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន សញ្ញាកើតអំពីចក្ខុសម្ផស្ស ។បេ។ សញ្ញាកើតអំពីមនោសម្ផស្ស សញ្ញាខន្ធមានច្រើនប្រការយ៉ាងនេះឯង ។ សញ្ញាខន្ធមានច្រើនប្រការដទៃទៀត គឺសញ្ញាខន្ធ ព្រោះចក្ខុសម្ផស្សជាបច្ច័យ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាង

ក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុងទាំងខាងក្រៅក៏មាន ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន ។ សញ្ញាខន្ធ ព្រោះសោតសម្ផស្សជាបច្ច័យ ។បេ។ ព្រោះឃានសម្ផស្សជាបច្ច័យ ។បេ។ ព្រោះជិវ្හាសម្ផស្សជាបច្ច័យ ។បេ។ ព្រោះកាយសម្ផស្សជាបច្ច័យ ។បេ។ ព្រោះមនោសម្ផស្សជាបច្ច័យ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន សញ្ញាកើតអំពីចក្ខុសម្ផស្ស ។បេ។ សញ្ញាកើតអំពីមនោសម្ផស្ស សញ្ញាខន្ធមានច្រើនប្រការយ៉ាងនេះឯង ។

នេះហៅថាសញ្ញាខន្ធ ។

បណ្ដាខន្ធទាំង ៥ នោះ សង្ខារក្ខន្ធតើដូចម្ដេច ។

[ ៦៤ ] សង្ខារក្ខន្ធ មានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធជាហេតុក៏មាន មិនមែនហេតុក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៤ គឺសង្ខារក្ខន្ធជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៥ គឺសង្ខារក្ខន្ធប្រកបដោយសុខិន្ទ្រិយក៏មាន ប្រកបដោយទុក្ខិន្ទ្រិយក៏មាន ប្រកបដោយសោមនស្សិន្ទ្រិយក៏មាន ប្រកបដោយទោមនស្សិន្ទ្រិយក៏មាន ប្រកបដោយឧបេក្ខិន្ទ្រិយក៏មាន ។ សង្ខា-

រក្ខន្ធមានប្រការ ៦ គឺចេតនាកើតអំពីចក្ខុសម្ផស្ស ចេតនាកើតអំពីសោតសម្ផស្ស ចេតនាកើតអំពីឃានសម្ផស្ស ចេតនាកើតអំពីជិវ្ហាសម្ផស្ស ចេតនាកើតអំពីកាយសម្ផស្ស ចេតនាកើតអំពីមនោសម្ផស្ស សង្ខារក្ខន្ធមានប្រការ ៦ យ៉ាងនេះឯង ។ សង្ខារក្ខន្ធមានប្រការ ៧ គឺចេតនាកើតអំពីចក្ខុសម្ផស្ស ។បេ។ ចេតនាកើតអំពីកាយសម្ផស្ស ចេតនាកើតអំពីមនោធាតុសម្ផស្ស ចេតនាកើតអំពីមនោវិញ្ញាណធាតុសម្ផស្ស សង្ខារក្ខន្ធមានប្រការ ៧ យ៉ាងនេះឯង ។ សង្ខារក្ខន្ធមានប្រការ ៨ គឺចេតនាកើតអំពីចក្ខុសម្ផស្ស ។បេ។ ចេតនាកើតអំពីកាយសម្ផស្ស កើតព្រមដោយសុខក៏មាន កើតព្រមដោយទុក្ខក៏មាន ចេតនាកើតអំពីមនោធាតុសម្ផស្ស ចេតនាកើតអំពីមនោវិញ្ញាណធាតុសម្ផស្ស សង្ខារក្ខន្ធ មានប្រការ ៨ យ៉ាងនេះឯង ។ សង្ខារក្ខន្ធមានប្រការ ៩ គឺចេតនាកើតអំពីចក្ខុសម្ផស្ស ។បេ។ ចេតនាកើតអំពីមនោធាតុសម្ផស្ស ចេតនាកើតអំពីមនោវិញ្ញាណធាតុសម្ផស្ស ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន សង្ខារក្ខន្ធមានប្រការ ៩ យ៉ាងនេះឯង ។ សង្ខារក្ខន្ធ មានប្រការ ១០ គឺចេតនាកើតអំពីចក្ខុសម្ផស្ស ។បេ។ ចេតនាកើតអំពីកាយសម្ផស្ស កើតព្រមដោយសុខក៏មាន កើតព្រមដោយទុក្ខក៏មាន ចេតនាកើតអំពីមនោធាតុសម្ផស្ស ចេតនាកើតអំពីមនោវិញ្ញាណធាតុសម្ផស្ស ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

[ ៦៥ ] សង្ខារក្ខន្ធ មានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្ត

ដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធជាហេតុក៏មាន មិនមែនហេតុក៏មាន ។ សង្ខារក្ខន្ធ មានប្រការ ៣ គឺសង្ខារក្ខន្ធប្រកបដោយសុខ-វេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ជាវិបាកក៏មាន ជាធម៌មានវិបាកជាប្រក្រតីក៏មាន មិនមែនវិបាកទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីក៏មាន សង្ខារក្ខន្ធមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទានទានក៏មាន សៅហ្មងហើយ ទាំងគួរដល់សេចក្តីសៅហ្មងក៏មាន មិនសៅហ្មងហើយ តែគួរដល់សេចក្តីសៅហ្មងក៏មាន មិនសៅហ្មងហើយ ទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារក៏មាន មិនមានវិតក្កៈ មានត្រឹមតែវិចារក៏មាន មិនមានវិតក្កៈ ទាំងមិនមានវិចារក៏មាន កើតព្រមដោយបីតិក៏មាន កើតព្រមដោយសុខក៏មាន កើតព្រមដោយឧបេក្ខាក៏មាន គួរលះដោយទស្សនៈក៏មាន គួរលះដោយភាវនាក៏មាន មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន មានហេតុ គួរលះដោយទស្សនៈក៏មាន មានហេតុ គួរលះដោយភាវនាក៏មាន មានហេតុ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន ដល់នូវការសន្សំកពូនឡើងក៏មាន ដល់នូវការមិនសន្សំកពូនឡើងក៏មាន មិនដល់នូវការសន្សំ

ទាំងមិនដល់នូវការមិនសន្សំកពូនឡើងក៏មាន ជារបស់សេក្ខបុគ្គលក៏មាន ជារបស់អសេក្ខបុគ្គលក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គលក៏មាន មានសភាពតូចច្មារក៏មាន ដល់នូវភាពធំក៏មាន ប្រមាណមិនបានក៏មាន មានអារម្មណ៍តូចច្មារក៏មាន មានអារម្មណ៍ដល់នូវភាពធំក៏មាន មានអារម្មណ៍ប្រមាណមិនបានក៏មាន ថោកទាបក៏មាន យ៉ាងកណ្ដាលក៏មាន យ៉ាងឧត្ដមក៏មាន មានសភាពខុស និងទៀងក៏មាន មានសភាពត្រូវ និងទៀងក៏មាន មានសភាពមិនទៀងក៏មាន មានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន កើតឡើងហើយក៏មាន មិនទាន់កើតឡើងក៏មាន ប្រុងនឹងកើតឡើងក៏មាន ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន មានអារម្មណ៍ជាអតីតក៏មាន មានអារម្មណ៍ជាអនាគតក៏មាន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន ខាងក្នុងក៏មាន ខាងក្រៅក៏មាន ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅ ក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

[ ៦៦ ] សង្ខារក្ខន្ធ មានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធមានហេតុក៏មាន មិនមានហេតុក៏មាន ប្រកបដោយហេតុក៏មាន ប្រាសចាកហេតុក៏មាន ជាហេតុទាំងប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន ប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុក៏មាន ជាហេតុ ទាំងប្រកបដោយហេតុក៏មាន ប្រកបដោយហេតុ

តែមិនមែនហេតុក៏មាន មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមែនហេតុ ទាំងមិនប្រកបដោយហេតុក៏មាន ជាលោកិយក៏មាន ជាលោកុត្តរក៏មាន ដែលគប្បីដឹងដោយវិញ្ញាណណាមួយក៏មាន ដែលមិនគប្បីដឹងដោយវិញ្ញាណណាមួយក៏មាន មានអាសវៈក៏មាន មិនមានអាសវៈក៏មាន ប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន មិនមានអាសវៈក៏មាន ប្រកបដោយអាសវៈក៏មាន ប្រាសចាកអាសវៈក៏មាន មានអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈក៏មាន មានអាសវៈ ទាំងប្រកបដោយអាសវៈក៏មាន ប្រកបដោយអាសវៈ តែមិនមែនអាសវៈក៏មាន ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈក៏មាន ជាសំយោជនៈក៏មាន មិនមែនសំយោជនៈក៏មាន ជាប្រយោជន៍ដល់សំយោជនៈក៏មាន មិនជាប្រ-យោជន៍ដល់សញ្ញោជនៈក៏មាន ប្រកបដោយសញ្ញោជនៈក៏មាន ប្រាសចាកសញ្ញោជនៈក៏មាន ជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនសញ្ញោជនៈក៏មាន ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈក៏មាន ប្រកបដោយសញ្ញោជនៈ តែមិនមែនសញ្ញោជនៈក៏មាន ប្រាសចាកសំយោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ជាគន្ថៈក៏មាន មិនមែនគន្ថៈក៏មាន ដែលគន្ថៈគប្បីដោតក្រងក៏មាន ដែលគន្ថៈមិនគប្បីដោតក្រងក៏មាន ប្រកបដោយគន្ថៈក៏មាន ប្រាសចាកគន្ថៈក៏មាន

ជាគន្ថៈ ទាំងជាធម៌ដែលគន្ថៈគប្បីដោតក្រងក៏មាន ជាធម៌ដែលគន្ថៈគប្បីដោតក្រង តែមិនមែនគន្ថៈក៏មាន ជាគន្ថៈ ទាំងប្រកបដោយគន្ថៈក៏មាន ប្រកបដោយគន្ថៈ តែមិនមែនគន្ថៈក៏មាន ប្រាសចាកគន្ថៈ តែជាសភាពដែលគន្ថៈគប្បីដោតក្រងក៏មាន ប្រាសចាកគន្ថៈ ទាំងជាសភាពដែលគន្ថៈមិនគប្បីដោតក្រងក៏មាន ជាឱឃៈក៏មាន មិនមែនឱឃៈក៏មាន ដែលឱឃៈគប្បីប្រព្រឹត្តកន្លងក៏មាន ដែលឱឃៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ប្រកបដោយឱឃៈក៏មាន ប្រាសចាកឱឃៈក៏មាន ជាឱឃៈ ទាំងជាធម៌ដែលឱឃៈគប្បីប្រព្រឹត្តកន្លងក៏មាន ជាធម៌ដែលឱឃៈគប្បីប្រព្រឹត្តកន្លង តែមិនមែនឱឃៈក៏មាន ជាឱឃៈ ទាំងប្រកបដោយឱឃៈក៏មាន ប្រកបដោយឱឃៈ តែមិនមែនឱឃៈក៏មាន ប្រាសចាកឱឃៈ តែជាសភាពដែលឱឃៈគប្បីប្រព្រឹត្តកន្លងក៏មាន ប្រាសចាកឱឃៈ ទាំងជាសភាពដែលឱឃៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ជាយោគៈក៏មាន មិនមែនយោគៈក៏មាន ដែលយោគៈគប្បីប្រព្រឹត្តកន្លងក៏មាន ដែលយោគៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ប្រកបដោយយោគៈក៏មាន ប្រាសចាកយោគៈក៏មាន ជាយោគៈ ទាំងជាធម៌ដែលយោគៈគប្បីប្រព្រឹត្តកន្លងក៏មាន ជាធម៌ដែលយោគៈគប្បីប្រព្រឹត្តកន្លង តែមិនមែនយោគៈក៏មាន ជាយោគៈ ទាំងប្រកបដោយយោគៈក៏មាន ប្រកបដោយយោគៈ តែមិនមែនយោគៈក៏មាន ប្រាសចាកយោគៈ តែជាសភាពដែលយោគៈគប្បីប្រព្រឹត្តកន្លងក៏មាន ប្រាសចាកយោគៈ ទាំងជាសភាពដែលយោគៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ជានីវរណៈក៏មាន មិនមែននីវរណៈក៏មាន ជាប្រយោជន៍ដល់នីវរណៈក៏មាន មិនមែន

ជាប្រយោជន៍ដល់នីវរណៈក៏មាន ប្រកបដោយនីវរណៈក៏មាន ប្រាសចាក នីវរណៈក៏មាន ជានីវរណៈ ទាំងជាប្រយោជន៍ដល់នីវរណៈក៏មាន ជាប្រយោជន៍ដល់នីវរណៈ តែមិនមែននីវរណៈក៏មាន ជានីវរណៈ ទាំងប្រកបដោយនីវរណៈក៏មាន ប្រកបដោយនីវរណៈ តែមិនមែននីវរណៈក៏មាន ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈក៏មាន ប្រាសចាកនីវរណៈ ទាំងមិនជាប្រយោជន៍ដល់នីវរណៈក៏មាន ជាបរាមាសក៏មាន មិនមែនបរាមាសក៏មាន ដែលបរាមាសស្ទាបអង្អែលក៏មាន ដែលបរាមាសមិនស្ទាបអង្អែលក៏មាន ប្រកបដោយបរាមាសក៏មាន ប្រាសចាកបរាមាសក៏មាន ជាបរាមាស ទាំងជាធម៌ដែលបរាមាសស្ទាបអង្អែលក៏មាន ជាធម៌ដែលបរាមាសស្ទាបអង្អែល តែមិនមែនជាបរាមាសក៏មាន ប្រាសចាកបរាមាសតែជាធម៌ដែលបរាមាសស្ទាបអង្អែលក៏មាន ប្រាសចាកបរាមាស ទាំងជាធម៌ដែលបរាមាសមិនស្ទាបអង្អែលក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយក៏មាន ជាឧបាទានក៏មាន មិនមែនឧបាទានក៏មាន ជាប្រយោជន៍ដល់ឧបាទានក៏មាន មិនជាប្រយោជន៍ដល់ឧបាទានក៏មាន ប្រកបដោយឧបាទានក៏មាន ប្រាសចាកឧបាទានក៏មាន ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនឧបាទានក៏មាន ជាឧបាទាន ទាំងប្រកបដោយឧបាទានក៏មាន ប្រកបដោយឧបាទាន តែមិនមែនឧបាទានក៏មាន ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទានក៏មាន

ប្រាសចាកឧបាទាន ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន ជាសេចក្តីសៅហ្មងក៏មាន មិនមែនសេចក្តីសៅហ្មងក៏មាន គួរដល់សេចក្តីសៅហ្មងក៏មាន មិនគួរដល់សេចក្តីសៅហ្មងក៏មាន សៅហ្មងហើយក៏មាន មិនសៅហ្មងហើយក៏មាន ប្រកបដោយសេចក្តីសៅហ្មងក៏មាន ប្រាសចាកសេចក្តីសៅហ្មងក៏មាន ជាសេចក្តីសៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មងក៏មាន គួរដល់សេចក្តីសៅហ្មង តែមិនមែនសេចក្តីសៅហ្មងក៏មាន ជាសេចក្តីសៅហ្មង ទាំងសៅហ្មងហើយក៏មាន សៅហ្មងហើយ តែមិនមែនសេចក្តីសៅហ្មងក៏មាន ជាសេចក្តីសៅហ្មង ទាំងប្រកបដោយសេចក្តីសៅហ្មងក៏មាន ប្រកបដោយសេចក្តីសៅហ្មង តែមិនមែនសេចក្តីសៅហ្មងក៏មាន ប្រាសចាកសេចក្តីសៅហ្មង តែគួរដល់សេចក្តីសៅហ្មងក៏មាន ប្រាសចាកសេចក្តីសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន គួរលះដោយទស្សនៈក៏មាន មិនគួរលះដោយទស្សនៈក៏មាន គួរលះដោយភាវនាក៏មាន មិនគួរលះដោយភាវនាក៏មាន មានហេតុគួរលះដោយទស្សនៈក៏មាន មានហេតុ មិនគួរលះដោយទស្សនៈក៏មាន មានហេតុ គួរលះដោយភាវនាក៏មាន មានហេតុ មិនគួរលះដោយភាវនាក៏មាន ប្រព្រឹត្តទៅជាមួយនឹងវិតក្កក៏មាន មិនមានវិតក្កក៏មាន ប្រព្រឹត្តទៅជាមួយនឹងវិចារក៏មាន មិនមានវិចារក៏មាន ប្រព្រឹត្តទៅជាមួយនឹងបីតិក៏មាន មិនមានបីតិក៏មាន កើតព្រមដោយបីតិក៏មាន មិនកើតព្រមដោយបីតិក៏មាន កើតព្រមដោយសុខក៏មាន មិនកើតព្រមដោយសុខក៏មាន កើតព្រមដោយឧបេក្ខាក៏មាន មិនកើតព្រមដោយឧបេក្ខាក៏មាន ជាកាមាវចរក៏មាន មិនមែន

កាមាវចរក៏មាន ជារូបាវចរក៏មាន មិនមែនរូបាវចរក៏មាន ជាអរូបាវចរក៏មាន មិនមែនអរូបាវចរក៏មាន ជាបរិយាបន្នក៏មាន ជាអបរិយាបន្នក៏មាន ជានិយ្យានិកៈក៏មាន ជាអនិយ្យានិកៈក៏មាន ជានិយតៈក៏មាន ជាអនិយតៈក៏មាន ប្រកបដោយឧត្តរៈក៏មាន មិនប្រកបដោយឧត្តរៈក៏មាន ប្រកបដោយរណៈក៏មាន មិនមានរណៈក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

[ ៦៧ ] សង្ខារក្ខន្ធ មានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធប្រកបដោយរណៈក៏មាន មិនប្រកបដោយរណៈក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

## ទុកមូលកៈ ចប់

[ ៦៨ ] សង្ខារក្ខន្ធ មានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធជាហេតុក៏មាន មិនមែនហេតុក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។បេ។ សង្ខារក្ខន្ធ មានប្រការ ១០

យ៉ាងនេះឯង ។ សង្ខារក្ខន្ធមានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្ត ដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធប្រកបដោយរណៈក៏មាន មិនមានរណៈក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធ មានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធជាហេតុក៏មាន មិនមែនហេតុក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខ-វេទនាក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធមានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធប្រកបដោយរណៈក៏មាន មិនមានរណៈក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

**តិកមូលកៈ ចប់**

[ ៦៩ ] សង្ខារក្ខន្ធ មានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធជាហេតុក៏មាន មិនមែនហេតុក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធមានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធមានហេតុក៏មាន មិនមានហេតុក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធមានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធ ប្រកបដោយហេតុក៏មាន ប្រាសចាកហេតុក៏មាន ។ សង្ខារក្ខន្ធ មានប្រការ ៣ គឺសង្ខារក្ខន្ធជាវិបាកក៏មាន ជាធម៌មានវិបាកជាប្រក្រតីក៏មាន មិនមែនវិបាក ទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធ មានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន ប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុក៏មាន ។ សង្ខារក្ខន្ធ មានប្រការ ៣ គឺសង្ខារក្ខន្ធដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិន

កាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទានក៏មាន ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធមានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធជាហេតុ ទាំងប្រកបដោយហេតុក៏មាន ប្រកបដោយហេតុ តែមិនមែនជាហេតុក៏មាន ។ សង្ខារក្ខន្ធ មានប្រការ ៣ គឺសង្ខារក្ខន្ធសៅហ្មងហើយ ទាំងគួរដល់សេចក្តីសៅហ្មងក៏មាន មិនសៅហ្មងហើយ តែគួរដល់សេចក្តីសៅហ្មងក៏មាន មិនសៅហ្មងហើយ ទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធ មានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធមិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមែនហេតុ ទាំងមិនប្រកបដោយហេតុក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធមានវិតក្ក ទាំងមានវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធមានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធ មានប្រការ ២ គឺសង្ខារក្ខន្ធ ជាលោកិយក៏មាន ជាលោកុត្តរក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធកើតព្រមដោយបីតិក៏មាន កើតព្រមដោយសុខក៏មាន កើតព្រមដោយឧបេក្ខាក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធ

មានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធដែលគប្បីដឹងដោយវិញ្ញាណណាមួយក៏មាន ដែលមិនគប្បីដឹងដោយវិញ្ញាណណាមួយក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធដែលគួរលះដោយទស្សនៈក៏មាន គួរលះដោយភាវនាក៏មាន មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធ មានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធជាអាសវៈក៏មាន មិនមែនអាសវៈក៏មាន ។ សង្ខារក្ខន្ធ មានប្រការ ៣ គឺសង្ខារក្ខន្ធមានហេតុ គួរលះដោយទស្សនៈក៏មាន មានហេតុ គួរលះដោយភាវនាក៏មាន មានហេតុ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធមានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធ មានប្រការ ២ គឺសង្ខារក្ខន្ធមានអាសវៈក៏មាន មិនមានអាសវៈក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធដល់នូវការសន្សំកពូនឡើងក៏មាន ដល់នូវការមិនសន្សំកពូនឡើងក៏មាន មិនដល់នូវការសន្សំកពូនឡើង ទាំងមិនដល់នូវការមិនសន្សំកពូនឡើងក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធមានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធប្រកបដោយអាសវៈក៏មាន ប្រាសចាកអាសវៈក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធជារបស់

សេក្ខបុគ្គលក៏មាន ជារបស់អសេក្ខបុគ្គលក៏មាន មិនមែនជារបស់សេក្ខ-បុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គលក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធមានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធជាអាសវៈទាំងមានអាសវៈក៏មាន មានអាសវៈ តែមិនមែនអាសវៈក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធ មានសភាពតូចច្មារក៏មាន ដល់នូវសភាពធំក៏មាន ប្រមាណមិនបានក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធមានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធជាអាសវៈ ទាំងប្រកបដោយអាសវៈក៏មាន ប្រកបដោយអាសវៈ តែមិនមែនអាសវៈក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធ មានអារម្មណ៍តូចច្មារក៏មាន មានអារម្មណ៍ដល់នូវសភាពធំក៏មាន មានអារម្មណ៍ប្រមាណមិនបានក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធមានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រាសចាកអាសវៈ ទាំងមិនប្រកបដោយអាសវៈក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធថោកទាបក៏មាន យ៉ាងកណ្តាលក៏មាន យ៉ាងឧត្តមក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធ មានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធជា

សំយោជនៈក៏មាន មិនមែនសំយោជនៈក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធមានសភាពខុស និងទៀងក៏មាន មានសភាពត្រូវ និងទៀងក៏មាន មានសភាពមិនទៀងក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធ មានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធ ជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន មិនជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ។ សង្ខារក្ខន្ធ មានប្រការ ៣ គឺ សង្ខារក្ខន្ធ មានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធ មានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធប្រកបដោយសញ្ញោជនៈក៏មាន ប្រាសចាកសញ្ញោជនៈក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធដែលកើតឡើងហើយក៏មាន ដែលមិនទាន់កើតឡើងក៏មាន ដែលប្រុងនឹងកើតឡើងក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធមានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនសញ្ញោជនៈក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធមានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធ

ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈក៏មាន ប្រកបដោយសញ្ញោជនៈ តែមិនមែនសញ្ញោជនៈក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធមានអារម្មណ៍ជាអតីតក៏មាន មានអារម្មណ៍ជាអនាគតក៏មាន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធមានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធខាងក្នុងក៏មាន ខាងក្រៅក៏មាន ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ សង្ខារក្ខន្ធមានប្រការ ១ បានដល់ សង្ខារក្ខន្ធដ៏សម្បយុត្តដោយចិត្ត ។ សង្ខារក្ខន្ធមានប្រការ ២ គឺសង្ខារក្ខន្ធជាគន្ថៈក៏មាន មិនមែនគន្ថៈក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធមានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ។បេ។ សង្ខារក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

**ឧភតោវឌ្ឍកៈ ចប់**

[ ៧០ ] សង្ខារក្ខន្ធ មានប្រការ ៧ គឺសង្ខារក្ខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន កាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន សង្ខារក្ខន្ធមានប្រការ ៧ យ៉ាងនេះឯង ។ សង្ខារក្ខន្ធមានប្រការ ៧ ដទៃទៀត គឺសង្ខារក្ខន្ធប្រកបដោយសុខ-

វេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន សង្ខារក្ខន្ធមានប្រការ ៧ យ៉ាងនេះឯង ។

[ ៧១ ] សង្ខារក្ខន្ធមានប្រការ ២៤ គឺសង្ខារក្ខន្ធ ព្រោះចក្ខុសម្ផស្សជាបច្ច័យ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន សង្ខារក្ខន្ធព្រោះសោតសម្ផស្សជាបច្ច័យ ។បេ។ ព្រោះឃានសម្ផស្សជាបច្ច័យ ។បេ។ ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ។បេ។ ព្រោះកាយសម្ផស្សជាបច្ច័យ ។បេ។ ព្រោះមនោសម្ផស្សជាបច្ច័យ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ចេតនាកើតអំពីចក្ខុសម្ផស្ស ។បេ។ ចេតនាកើតអំពីមនោសម្ផស្ស សង្ខារក្ខន្ធមានប្រការ ២៤ យ៉ាងនេះឯង ។ សង្ខារក្ខន្ធមានប្រការ ២៤ ដទៃទៀត គឺសង្ខារក្ខន្ធព្រោះចក្ខុសម្ផស្សជាបច្ច័យ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុងទាំងខាងក្រៅក៏មាន សង្ខារក្ខន្ធព្រោះសោតសម្ផស្សជាបច្ច័យ ។បេ។ ព្រោះឃានសម្ផស្សជាបច្ច័យ ។បេ។ ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ។បេ។ ព្រោះកាយសម្ផស្សជាបច្ច័យ ។បេ។ ព្រោះមនោសម្ផស្សជាបច្ច័យ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មាន

អារម្មណ៍ទាំងខាងក្នុងទាំងខាងក្រៅក៏មាន ចេតនាកើតអំពីចក្ខុសម្ផស្ស ។បេ។ ចេតនាកើតអំពីមនោសម្ផស្ស សង្ខារក្ខន្ធមានប្រការ ២៤ យ៉ាងនេះឯង ។

[ ៧២ ] សង្ខារក្ខន្ធមានប្រការ ៣០ គឺសង្ខារក្ខន្ធព្រោះចក្ខុសម្ផស្សជាបច្ច័យ ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន សង្ខារក្ខន្ធព្រោះសោតសម្ផស្សជាបច្ច័យ ។បេ។ ព្រោះឃានសម្ផស្សជាបច្ច័យ ។បេ។ ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ។បេ។ ព្រោះកាយសម្ផស្សជាបច្ច័យ ។បេ។ ព្រោះមនោសម្ផស្សជាបច្ច័យ ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន ចេតនាកើតអំពីចក្ខុសម្ផស្ស ។បេ។ ចេតនាកើតអំពីមនោសម្ផស្ស សង្ខារក្ខន្ធមានប្រការ ៣០ យ៉ាងនេះឯង ។

[ ៧៣ ] សង្ខារក្ខន្ធមានច្រើនប្រការ គឺសង្ខារក្ខន្ធព្រោះចក្ខុសម្ផស្សជាបច្ច័យ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន សង្ខារក្ខន្ធព្រោះសោតសម្ផស្សជាបច្ច័យ ។បេ។ ព្រោះឃានសម្ផស្សជាបច្ច័យ ។បេ។ ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ។បេ។ ព្រោះកាយសម្ផស្សជាបច្ច័យ ។បេ។ ព្រោះមនោសម្ផស្សជាបច្ច័យ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន ចេតនាកើតអំពីចក្ខុសម្ផស្ស ។បេ។ ចេតនាកើតអំពីមនោសម្ផស្ស សង្ខារក្ខន្ធមានច្រើនប្រការយ៉ាងនេះឯង ។ សង្ខារក្ខន្ធ មាន

ច្រើនប្រការដទៃទៀត គឺសង្ខារក្ខន្ធព្រោះចក្ខុសម្ផស្សជាបច្ច័យ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខ-វេទនាក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន សង្ខារក្ខន្ធព្រោះសោតសម្ផស្សជាបច្ច័យ ។បេ។ ព្រោះឃានសម្ផស្សជាបច្ច័យ ។បេ។ ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ព្រោះកាយសម្ផស្សជាបច្ច័យ ។បេ។ ព្រោះមនោ-សម្ផស្សជាបច្ច័យ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ជាកាមាវចរក៏មាន ជារូបា-វចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន ចេតនាកើតអំពីចក្ខុ-សម្ផស្ស ។បេ។ ចេតនាកើតអំពីមនោសម្ផស្ស សង្ខារក្ខន្ធមានច្រើនប្រការយ៉ាងនេះឯង ។

## នេះហៅថា សង្ខារក្ខន្ធ ។

បណ្តាខន្ធទាំង ៥ នោះ វិញ្ញាណក្ខន្ធ តើដូចម្តេច ។

[ ៧៤ ] វិញ្ញាណក្ខន្ធមានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធមានហេតុក៏មាន មិនមានហេតុក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ វិញ្ញាណក្ខន្ធ មានប្រការ ៤ គឺវិញ្ញាណក្ខន្ធជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន

ជាអបរិយាបន្នក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៥ គឺវិញ្ញាណក្ខន្ធ ប្រកប ដោយសុខិន្ទ្រិយក៏មាន ប្រកបដោយទុក្ខិន្ទ្រិយក៏មាន ប្រកបដោយសោមនស្សិន្ទ្រិយក៏មាន ប្រកបដោយទោមនស្សិន្ទ្រិយក៏មាន ប្រកបដោយឧបេក្ខិន្ទ្រិយក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៦ គឺចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ វិញ្ញាណក្ខន្ធ មានប្រការ ៦ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធមានប្រការ ៧ គឺចក្ខុវិញ្ញាណ ។បេ។ កាយវិញ្ញាណ មនោធាតុ មនោវិញ្ញាណធាតុ វិញ្ញាណក្ខន្ធមាន ប្រការ ៧ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធមានប្រការ ៨ គឺចក្ខុវិញ្ញាណ ។បេ។ កាយវិញ្ញាណកើតព្រមដោយសុខក៏មាន កើតព្រមដោយទុក្ខក៏មាន មនោធាតុ មនោវិញ្ញាណធាតុ វិញ្ញាណក្ខន្ធមានប្រការ ៨ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធមានប្រការ ៩ គឺចក្ខុវិញ្ញាណ ។បេ។ កាយវិញ្ញាណ មនោធាតុ មនោវិញ្ញាណធាតុ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន វិញ្ញាណក្ខន្ធមានប្រការ ៩ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធមានប្រការ ១០ គឺ ចក្ខុវិញ្ញាណ ។បេ។ កាយវិញ្ញាណ កើតព្រមដោយសុខក៏មាន កើតព្រម ដោយទុក្ខក៏មាន មនោធាតុ មនោវិញ្ញាណធាតុជាកុសលក៏មាន ជាអកុសល ក៏មាន ជាអព្យាក្រឹតក៏មាន វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

[ ៧៥ ] វិញ្ញាណក្ខន្ធមានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធដ៏សម្បយុត្ត ដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធមានហេតុក៏មាន មិនមានហេតុក៏មាន ។ វិញ្ញាណក្ខន្ធ មានប្រការ ៣ គឺវិញ្ញាណក្ខន្ធប្រកប

ដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ជាវិបាកក៏មាន ជាធម៌មានវិបាកជាប្រក្រតីក៏មាន មិនមែនវិបាក ទាំងមិនមែនជាធម៌ មានវិបាកជាប្រក្រតីក៏មាន មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទានទានក៏មាន សៅហ្មងហើយ ទាំងគួរដល់សេចក្តីសៅហ្មងក៏មាន សៅហ្មងហើយ តែគួរដល់សេចក្តីសៅហ្មងក៏មាន សៅហ្មងហើយ ទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន ប្រព្រឹត្តទៅជាមួយនឹងវិតក្ក ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន កើតព្រមដោយបីតិក៏មាន កើតព្រមដោយសុខក៏មាន កើតព្រមដោយឧបេក្ខាក៏មាន គួរលះដោយទស្សនៈក៏មាន គួរលះដោយភាវនាក៏មាន មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន មានហេតុ គួរលះដោយទស្សនៈក៏មាន មានហេតុ គួរលះដោយភាវនាក៏មាន មានហេតុ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន ដល់នូវការសន្សំកពូនឡើងក៏មាន ដល់នូវការមិនសន្សំកពូនឡើងក៏មាន មិនដល់នូវការសន្សំកពូនឡើង ទាំងមិនដល់នូវការមិនសន្សំកពូនឡើងក៏មាន ជារបស់សេក្ខបុគ្គលក៏មាន ជារបស់អសេក្ខបុគ្គលក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិន

មែនជារបស់អសេក្ខបុគ្គលក៏មាន មានសភាពតូចឆ្មារក៏មាន ដល់នូវសភាពធំក៏មាន ប្រមាណមិនបានក៏មាន មានអារម្មណ៍តូចឆ្មារក៏មាន មានអារម្មណ៍ដល់នូវសភាពធំក៏មាន មានអារម្មណ៍ប្រមាណមិនបានក៏មាន ថោកទាបក៏មាន កណ្តាលក៏មាន ឧត្តមក៏មាន មានសភាពខុស និងទៀងក៏មាន មានសភាពត្រូវ និងទៀងក៏មាន មានសភាពមិនទៀងក៏មាន មានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន កើតឡើងហើយក៏មាន មិនទាន់កើតឡើងក៏មាន ប្រុងនឹងកើតឡើងក៏មាន ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន មានអារម្មណ៍ជាអតីតក៏មាន មានអារម្មណ៍ជាអនាគតក៏មាន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ជាខាងក្នុងទាំងខាងក្រៅក៏មាន មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

[ ៧៦ ] វិញ្ញាណក្ខន្ធមានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធប្រកបដោយហេតុក៏មាន ប្រាសចាកហេតុក៏មាន មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមែនហេតុ ទាំងមិនប្រកបដោយហេតុក៏មាន ជាលោកិយក៏មាន ជាលោកុត្តរក៏មាន ដែលគប្បីដឹងដោយវិញ្ញាណណាមួយក៏មាន ដែលមិនគប្បីដឹងដោយវិញ្ញាណណាមួយក៏មាន ប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន មិនមានអាសវៈក៏មាន ប្រកបដោយអាសវៈក៏មាន ប្រាសចាកអាសវៈ

ក៏មាន ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រាសចាកអាសវៈ ទាំងមិនមែនអាសវៈក៏មាន ជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន មិនជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ប្រកបដោយសញ្ញោជនៈក៏មាន ប្រាសចាកសញ្ញោជនៈក៏មាន ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ដែលគន្ថៈគប្បីដោតក្រងក៏មាន ដែលគន្ថៈមិនគប្បីដោតក្រងក៏មាន ប្រកបដោយគន្ថៈក៏មាន ប្រាសចាកគន្ថៈក៏មាន ប្រាសចាកគន្ថៈ តែជាសភាពដែលគន្ថៈគប្បីដោតក្រងក៏មាន ប្រាសចាកគន្ថៈ ទាំងជាសភាពដែលគន្ថៈមិនគប្បីដោតក្រងក៏មាន ដែលឱឃៈគប្បីប្រព្រឹត្តកន្លងក៏មាន ដែលឱឃៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ប្រកបដោយឱឃៈក៏មាន ប្រាសចាកឱឃៈក៏មាន ប្រាសចាកឱឃៈ តែជាសភាពដែលឱឃៈគប្បីប្រព្រឹត្តកន្លងក៏មាន ប្រាសចាកឱឃៈ ទាំងជាសភាពដែលឱឃៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ដែលយោគៈគប្បីប្រព្រឹត្តកន្លងក៏មាន ដែលយោគៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ប្រកបដោយយោគៈក៏មាន ប្រាសចាកយោគៈក៏មាន ប្រាសចាកយោគៈ តែជាសភាពដែលយោគៈគប្បីប្រព្រឹត្តកន្លងក៏មាន ប្រាសចាកយោគៈ ទាំងជាសភាពដែលយោគៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ជាប្រយោជន៍ដល់នីវរណៈក៏មាន មិនជាប្រយោជន៍ដល់នីវរណៈក៏មាន ប្រកបដោយនីវរណៈក៏មាន ប្រាសចាកនីវរណៈក៏មាន ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈក៏មាន ប្រាសចាកនីវរណៈ ទាំងមិនជាប្រយោជន៍ដល់នីវរណៈក៏មាន ដែល

បរាមាសស្ទាបអង្អែលក៏មាន ដែលបរាមាសមិនស្ទាបអង្អែលក៏មាន ប្រកប ដោយបរាមាសក៏មាន ប្រាសចាកបរាមាសក៏មាន ប្រាសចាកបរាមាស តែជាសភាពដែលបរាមាសស្ទាបអង្អែលក៏មាន ប្រាសចាកបរាមាស ទាំង ជាសភាពដែលបរាមាសមិនស្ទាបអង្អែលក៏មាន មានកម្មប្រកបដោយ កិលេស មានតណ្ហាជាដើមកាន់យកហើយក៏មាន មិនមានកម្មប្រកបដោយ កិលេស មានតណ្ហាជាដើមកាន់យកហើយក៏មាន ជាប្រយោជន៍ដល់ឧបា- ទានក៏មាន មិនជាប្រយោជន៍ដល់ឧបាទានក៏មាន ប្រកបដោយឧបាទានក៏មាន ប្រាសចាកឧបាទានក៏មាន ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទាន ក៏មាន ប្រាសចាកឧបាទាន ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន គួរដល់ សេចក្តីសៅហ្មងក៏មាន មិនគួរដល់សេចក្តីសៅហ្មងក៏មាន សៅហ្មងហើយ ក៏មាន មិនសៅហ្មងហើយក៏មាន ប្រកបដោយសេចក្តីសៅហ្មងក៏មាន ប្រាស ចាកសេចក្តីសៅហ្មងក៏មាន ប្រាសចាកសេចក្តីសៅហ្មង តែគួរដល់សេចក្តី សៅហ្មងក៏មាន ប្រាសចាកសេចក្តីសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មង ក៏មាន គួរលះដោយទស្សនៈក៏មាន មិនគួរលះដោយទស្សនៈក៏មាន គួរលះ ដោយភាវនាក៏មាន មិនគួរលះដោយភាវនាក៏មាន មានហេតុ គួរលះដោយ ទស្សនៈក៏មាន មានហេតុ មិនគួរលះដោយទស្សនៈក៏មាន មានហេតុ គួរលះ ដោយភាវនាក៏មាន មានហេតុ មិនគួរលះដោយភាវនាក៏មាន ប្រព្រឹត្តទៅជា មួយនឹងវិតក្កក៏មាន មិនមានវិតក្កក៏មាន ប្រព្រឹត្តទៅជាមួយនឹងវិចារក៏មាន មិនមានវិចារក៏មាន កើតព្រមដោយបីតិក៏មាន មិនមានបីតិក៏មាន កើតព្រម

ដោយបីតិក៏មាន មិនកើតព្រមដោយបីតិក៏មាន កើតព្រមដោយសុខក៏មាន មិនកើតព្រមដោយសុខក៏មាន កើតព្រមដោយឧបេក្ខាក៏មាន មិនកើតព្រមដោយឧបេក្ខាក៏មាន ជាកាមាវចរក៏មាន មិនមែនកាមាវចរក៏មាន ជារូបាវចរក៏មាន មិនមែនរូបាវចរក៏មាន ជាអរូបាវចរក៏មាន មិនមែនអរូបាវចរក៏មាន ជាបរិយាបន្នក៏មាន ជាអបរិយាបន្នក៏មាន ជានិយ្យានិកៈក៏មាន ជាអនិយ្យានិកៈក៏មាន ជានិយតៈក៏មាន ជាអនិយតៈក៏មាន ជាឧត្តរៈក៏មាន ជាអនុត្តរៈក៏មាន ប្រកបដោយរណៈក៏មាន ជាអរណៈក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

[ ៧៧ ] វិញ្ញាណក្ខន្ធមានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធប្រកបដោយរណៈក៏មាន ជាអរណៈក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

## ទុកមូលកៈ ចប់

[ ៧៨ ] វិញ្ញាណក្ខន្ធមានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធដ៏សម្បយុត្ត

ដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធមានហេតុក៏មាន មិនមានហេតុក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធមានប្រការ ១ បានដល់ វិញ្ញា-ណក្ខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញា-ណក្ខន្ធប្រកបដោយរណៈក៏មាន ជាអរណៈក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធមានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធមានហេតុក៏មាន មិនមានហេតុក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធមានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធដ៏សម្បយុត្តដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធប្រកបដោយរណៈក៏មាន ជាអរណៈក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍

ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាង នេះឯង ។

## តិកមូលកៈ ចប់

[ ៧៩ ] វិញ្ញាណក្ខន្ធមានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធប្រកបដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមានហេតុក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណ-ក្ខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។បេ។ វិញ្ញា-ណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធមានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធប្រកបដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធប្រកបដោយហេតុក៏មាន ប្រាសចាកហេតុក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធប្រកបសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធ មានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធប្រកបដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធមិនមានហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមែនជាហេតុ ទាំងមិនប្រកបដោយហេតុក៏មាន ។ វិញ្ញាណក្ខន្ធ មានប្រការ ៣ គឺវិញ្ញាណក្ខន្ធជាវិបាកក៏មាន ជាធម៌មានវិបាកជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធ មានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធប្រកបដោយ

ផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធជាលោកិយក៏មាន ជាលោកុត្តរក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធដែលមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន ដែលមិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទានក៏មាន ដែលមិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធមានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធដែលប្រកបដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធ ដែលគប្បីដឹងដោយវិញ្ញាណណាមួយក៏មាន មិនគប្បីដឹងដោយវិញ្ញាណណាមួយក៏មាន ។ វិញ្ញាណក្ខន្ធ មានប្រការ ៣ គឺវិញ្ញាណក្ខន្ធដែលសៅហ្មងហើយ ទាំងគួរដល់សេចក្តីសៅហ្មងក៏មាន សៅហ្មងហើយ តែគួរដល់សេចក្តីសៅហ្មងក៏មាន មិនសៅហ្មងហើយ ទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធ មានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធប្រកបដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន មិនមានអាសវៈក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធប្រព្រឹត្តទៅជាមួយនឹងវិតក្ក ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធ

មានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធប្រកបដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធប្រកបដោយអាសវៈក៏មាន ប្រាសចាកអាសវៈក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធ កើតព្រមដោយបីតិក៏មាន កើតព្រមដោយសុខក៏មាន កើតព្រមដោយឧបេក្ខាក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធ មានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធប្រកបដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធដែលគួរលះដោយទស្សនៈក៏មាន គួរលះដោយភាវនាក៏មាន គួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធមានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធប្រកបដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន មិនជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធមានហេតុ គួរលះដោយទស្សនៈក៏មាន មានហេតុ គួរលះដោយភាវនាក៏មាន មានហេតុ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា ក៏មាន ។ បេ ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធមានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធប្រកបដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធប្រកបដោយសញ្ញោជនៈក៏មាន ប្រាសចាកសញ្ញោជនៈក៏មាន ។ វិញ្ញាណក្ខន្ធ

មានប្រការ ៣ គឺវិញ្ញាណក្ខន្ធដល់នូវការសន្សំកពូនឡើងក៏មាន ដល់នូវការមិនសន្សំកពូនឡើងក៏មាន ដល់នូវការសន្សំកពូនឡើង ទាំងមិនដល់នូវការមិនសន្សំកពូនឡើងក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធ មានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធប្រកបដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធប្រាសចាកសញ្ញោជនៈតែជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធជារបស់សេក្ខបុគ្គលក៏មាន ជារបស់អសេក្ខបុគ្គលក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គលក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធមានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធ ប្រកបដោយផស្សៈ ។ វិញ្ញាណក្ខន្ធ មានប្រការ ២ គឺវិញ្ញាណក្ខន្ធដែលគន្ថៈគប្បីដោតក្រងក៏មាន ដែលគន្ថៈមិនគប្បីដោតក្រងក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធមានសភាពតូចថ្មារក៏មាន ដល់នូវសភាពធំក៏មាន ប្រមាណមិនបានក៏មាន ។បេ។ វិញ្ញាណក្ខន្ធ មានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធមានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធប្រកបដោយផស្សៈ ។ វិញ្ញាណក្ខន្ធ មានប្រការ ២ គឺវិញ្ញាណក្ខន្ធប្រកបដោយគន្ថៈក៏មាន ប្រាសចាកគន្ថៈក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធ មានអារម្មណ៍តូចថ្មារក៏មាន មានអារម្មណ៍ដល់នូវសភាពធំក៏មាន មានអារម្មណ៍ប្រមាណមិនបានក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ

១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធមានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធប្រកបដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធ ដែលប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រងក៏មាន ប្រាសចាកគន្ថៈ ទាំងគន្ថៈមិនគប្បីដោតក្រងក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធថោកទាបក៏មាន កណ្តាលក៏មាន ឧត្តមក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធមានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធប្រកបដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធ ដែលឱឃៈគប្បីប្រព្រឹត្តកន្លងក៏មាន ឱឃៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធ មានសភាពខុស និងទៀងក៏មាន មានសភាពត្រូវនិងទៀងក៏មាន មិនទៀងក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធមានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធប្រកបដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធប្រកបដោយឱឃៈក៏មាន ប្រាសចាកឱឃៈក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធមានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធមានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធប្រកបដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធប្រាសចាកឱឃៈ តែឱឃៈគប្បីប្រព្រឹត្តកន្លងក៏មាន ប្រាសចាកឱឃៈ ទាំងឱឃៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធ កើតឡើងហើយក៏មាន មិនទាន់កើតឡើងហើយក៏មាន ប្រុង

នឹងកើតឡើងក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធ មានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធប្រកបដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធដែលយោគៈគប្បីប្រព្រឹត្តកន្លងក៏មាន យោគៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញា-ណក្ខន្ធជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន ។បេ។ វិញ្ញា-ណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធមានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធ ប្រកបដោយផស្សៈ ។ វិញ្ញាណក្ខន្ធ មានប្រការ ២ គឺ វិញ្ញាណក្ខន្ធប្រកបដោយយោគៈក៏មាន ប្រាសចាកយោគៈក៏មាន ។ វិញ្ញា-ណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធមានអារម្មណ៍ជាអតីតក៏មាន មានអា-រម្មណ៍ជាអនាគតក៏មាន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន ។បេ។ វិញ្ញាណក្ខន្ធ មានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធ មានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធប្រកបដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺវិញ្ញាណក្ខន្ធ ប្រាសចាកយោគៈ តែយោគៈគប្បីប្រព្រឹត្តកន្លងក៏មាន ប្រាសចាកយោគៈ ទាំងយោគៈមិនគប្បីប្រព្រឹត្តកន្លងក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺ វិញ្ញាណក្ខន្ធខាងក្នុងក៏មាន ខាងក្រៅក៏មាន ខាងក្នុង និងខាងក្រៅក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធ មានប្រការ ១ បានដល់ វិញ្ញាណក្ខន្ធប្រកបដោយផស្សៈ ។ វិញ្ញាណក្ខន្ធមានប្រការ ២ គឺ វិញ្ញាណក្ខន្ធជាប្រយោជន៍ដល់នីវរណៈក៏មាន មិនជាប្រយោជន៍ដល់នីវរណៈ ក៏មាន ។ វិញ្ញាណក្ខន្ធមានប្រការ ៣ គឺវិញ្ញាណក្ខន្ធមានអារម្មណ៍ខាងក្នុងក៏

មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ។បេ។ វិញ្ញាណក្ខន្ធមានប្រការ ១០ យ៉ាងនេះឯង ។

**ឧកតោវឌ្ឍកៈ ចប់**

[ ៨០ ] វិញ្ញាណក្ខន្ធមានប្រការ ៧ គឺវិញ្ញាណក្ខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន វិញ្ញាណក្ខន្ធមានប្រការ ៧ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធ មានប្រការ ៧ ដទៃទៀត គឺវិញ្ញាណក្ខន្ធប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន វិញ្ញាណក្ខន្ធមានប្រការ ៧ យ៉ាងនេះឯង ។

[ ៨១ ] វិញ្ញាណក្ខន្ធមានប្រការ ២៤ គឺវិញ្ញាណក្ខន្ធព្រោះចក្ខុសម្ផស្សជាបច្ច័យ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន វិញ្ញាណក្ខន្ធ ព្រោះសោតសម្ផស្សជាបច្ច័យ ។បេ។ ព្រោះឃានសម្ផស្សជាបច្ច័យ ។បេ។ ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ។បេ។ ព្រោះកាយសម្ផស្សជាបច្ច័យ ។បេ។ ព្រោះមនោសម្ផស្សជាបច្ច័យ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ចក្ខុវិញ្ញាណ ។បេ។ មនោវិញ្ញាណ វិញ្ញាណក្ខន្ធមានប្រការ ២៤ យ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធមានប្រការ ២៤ ដទៃទៀត

គឺវិញ្ញាណក្ខន្ធ ព្រោះចក្ខុសម្ផស្សជាបច្ច័យ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន វិញ្ញាណក្ខន្ធព្រោះសោតសម្ផស្សជាបច្ច័យ ។បេ។ ព្រោះឃានសម្ផស្សជាបច្ច័យ ។បេ។ ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ។បេ។ ព្រោះកាយសម្ផស្សជាបច្ច័យ ។បេ។ ព្រោះមនោសម្ផស្សជាបច្ច័យ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ចក្ខុវិញ្ញាណ ។បេ។ មនោវិញ្ញាណ វិញ្ញាណក្ខន្ធមានប្រការ ២៤ យ៉ាងនេះឯង ។

[ ៨២ ] វិញ្ញាណក្ខន្ធមានប្រការ ៣០ គឺវិញ្ញាណក្ខន្ធព្រោះចក្ខុសម្ផស្សជាបច្ច័យ ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន វិញ្ញាណក្ខន្ធព្រោះសោតសម្ផស្សជាបច្ច័យ ។បេ។ ព្រោះឃានសម្ផស្សជាបច្ច័យ ។បេ។ ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ។បេ។ ព្រោះកាយសម្ផស្សជាបច្ច័យ ។បេ។ ព្រោះមនោសម្ផស្សជាបច្ច័យ ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន ចក្ខុ-វិញ្ញាណ ។បេ។ មនោវិញ្ញាណ វិញ្ញាណក្ខន្ធមានប្រការ ៣០ យ៉ាងនេះឯង ។

[ ៨៣ ] វិញ្ញាណក្ខន្ធមានច្រើនប្រការ គឺវិញ្ញាណក្ខន្ធព្រោះចក្ខុសម្ផស្សជាបច្ច័យ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏

មាន ។ វិញ្ញាណក្ខន្ធព្រោះសោតសម្ផស្សជាបច្ច័យ ។បេ។ ព្រោះឃានសម្ផស្សជាបច្ច័យ ។បេ។ ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ។បេ។ ព្រោះកាយសម្ផស្សជាបច្ច័យ ។បេ។ ព្រោះមនោសម្ផស្សជាបច្ច័យ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន ចក្ខុវិញ្ញាណ ។បេ។ មនោវិញ្ញាណ វិញ្ញាណក្ខន្ធមានច្រើនប្រការយ៉ាងនេះឯង ។ វិញ្ញាណក្ខន្ធមានច្រើនប្រការដទៃទៀត គឺវិញ្ញាណក្ខន្ធ ព្រោះចក្ខុសម្ផស្សជាបច្ច័យ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។បេ។ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន វិញ្ញាណក្ខន្ធព្រោះសោតសម្ផស្សជាបច្ច័យ ។បេ។ ព្រោះឃានសម្ផស្សជាបច្ច័យ ។បេ។ ព្រោះជិវ្ហាសម្ផស្សជាបច្ច័យ ព្រោះកាយសម្ផស្សជាបច្ច័យ ។បេ។ ព្រោះមនោសម្ផស្សជាបច្ច័យ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ជាកាមាវចរក៏មាន ជារូបាវចរក៏មាន ជាអរូបាវចរក៏មាន ជាអបរិយាបន្នក៏មាន ចក្ខុវិញ្ញាណ ។បេ។ មនោវិញ្ញាណ វិញ្ញាណក្ខន្ធមានច្រើនប្រការយ៉ាងនេះឯង ។

នេះហៅថា វិញ្ញាណក្ខន្ធ

អភិធម្មភាជនីយ ចប់

# អដ្ឋកថា

## អភិធម្មភាជនីយ

[ ៣២ ] ឥឡូវនេះ ជាអភិធម្មភាជនីយ គឺន័យដែលទ្រង់ចែកដោយព្រះអភិធម្ម ក្នុងអភិធម្មភាជនីយនោះ បណ្ឌិតគប្បីជ្រាបរូបក្ខន្ធនិទ្ទេសដោយន័យដែលខ្ញុំឲ្យពិស្តារក្នុងរូបកណ្ឌនៃអដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីនោះឯង ។

[ ៤៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវេទនាខន្ធនិទ្ទេសដូចតទៅ

បទថា **ឯកវិធេន** បានដល់ ចំណែក ១ ។ បទថា **ផស្សសម្បយុត្តោ** បានដល់ ប្រកបដោយផស្សៈ ។ វេទនាទាំងអស់ ប្រព្រឹត្តទៅក្នុងភូមិ ៤ ។ ក្នុងសហេតុកទុកៈ សហេតុកវេទនា ជាវេទនាប្រព្រឹត្តទៅក្នុងភូមិ ៤ អហេតុកវេទនា ជាកាមាវចរតែម្យ៉ាង គប្បីជ្រាបវេទនាដែលត្រាស់ ដោយកុសលបទជាដើម ដោយឧបាយនេះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់សម្តែងវេទនាខន្ធនេះ មានតែម្យ៉ាង ដោយជាធម៌សម្បយុត្តជាមួយនឹងផស្សៈ ទ្រង់សម្តែងវេទនាខន្ធពួក ២ ជាសហេតុកវេទនា និងអហេតុកវេទនា ទ្រង់សម្តែងវេទនាខន្ធពួក ៣ ដោយជាតិ ទ្រង់សម្តែងវេទនាខន្ធពួក ៤ ដោយការផ្សេងគ្នានៃភូមិ ទ្រង់សម្តែងវេទនាខន្ធពួក ៥ ដោយឥន្ទ្រិយ បណ្តាវេទនាពួក ៥ នោះ វេទនាដែលជាសុខិន្ទ្រិយ និងទុក្ខិន្ទ្រិយអាស្រ័យកាយបសាទកើតឡើង ជាកាមាវចរតែម្យ៉ាង វេទនាដែលជាសោមនស្សិន្ទ្រិយ អាស្រ័យវត្ថុទី ៦ កើតឡើងក៏មាន មិនអាស្រ័យវត្ថុកើតឡើងក៏មាន ប្រព្រឹត្តទៅក្នុងភូមិ ៣ វេទនាដែលជាទោម-

នស្សិន្ទ្រិយ អាស្រ័យវត្ថុទី ៦ កើតឡើង ជាកាមាវចរ ។ វេទនាដែលជាឧបេក្ខិន្ទ្រិយ អាស្រ័យបសាទ ៤ មានចក្ខុជាដើមកើតឡើងក៏មាន អាស្រ័យវត្ថុទី ៦ កើតឡើងក៏មាន មិនអាស្រ័យវត្ថុកើតឡើងក៏មាន ប្រព្រឹត្តទៅក្នុងភូមិ ៤ ។ ទ្រង់សម្តែងវេទនាខន្ធពួក ៦ ដោយវត្ថុ ។ បណ្តាវេទនា ៦ នោះ វេទនា ៥ ខាងដើម អាស្រ័យបសាទ ៥ មានចក្ខុជាដើមកើតឡើង ជាកាមាវចរតែម្យ៉ាង វេទនាទី ៦ មិនអាស្រ័យវត្ថុកើតឡើងក៏មាន អាស្រ័យវត្ថុកើតឡើងក៏មាន ប្រព្រឹត្តទៅក្នុងភូមិ ៤ ។ ទ្រង់សម្តែងវេទនាខន្ធពួក ៧ ដោយចែកវេទនា ដែលកើតអំពីមនោសម្ផស្សក្នុងវេទនា ៦ នោះ ។ ទ្រង់សម្តែងវេទនាខន្ធពួក ៨ ដោយចែកវេទនាដែលកើតអំពីកាយសម្ផស្ស ក្នុងវេទនា ៧ យ៉ាងនោះ ។ ទ្រង់សម្តែងវេទនាខន្ធពួក ៩ ដោយចែកវេទនាដែលកើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុ ក្នុងប្រភេទនៃវេទនា ៧ យ៉ាង ។ ទ្រង់សម្តែងវេទនាខន្ធពួក ១០ ដោយចែកវេទនា ដែលកើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុ ក្នុងប្រភេទនៃវេទនា ៨ យ៉ាង ។

ពិតហើយ ក្នុងវេទនាទាំងនេះ មនោសម្ផស្សជាវេទនាក្នុងប្រភេទវេទនាពួក ៧ ចែកជា ២ គឺមនោធាតុសម្ផស្សជាវេទនា និងមនោវិញ្ញាណធាតុ-សម្ផស្សជាវេទនា ។ ក្នុងវេទនាពួក ៨ កាយសម្ផស្សជាវេទនា ចែកជា ២ គឺសុខវេទនា និងទុក្ខវេទនា រួមជាមួយវេទនាក្នុងពួក ៧ នោះ ។ ក្នុងប្រភេទវេទនាពួក ៩ មនោវិញ្ញាណធាតុសម្ផស្សជាវេទនា តាមដែលត្រាស់ក្នុងវេទនាពួក ៧ ចែកជា ៣ ដោយអំណាចកុសលជាដើម ។ ក្នុងវេទនាពួក

១០ មនោវិញ្ញាណធាតុសម្បយុត្តជាវេទនាតាមដែលត្រាស់ទុក ក្នុងវេទនាពួក ៨ ចែកជា ៣ ដោយអំណាចកុសលជាដើមនោះឯង ។ ក្នុងវេទនាខន្ធនេះ ព្រះមានព្រះភាគ ត្រាស់កុសលត្តិកៈ ដើម្បីធ្វើបទឲ្យពេញប៉ុណ្ណោះ តែក្នុងវេទនាពួក ៧ ពួក ៨ និងពួក ៩ ទ្រង់ប្រទានន័យ ក្នុងឋានៈដែលគួរប្រទានន័យហើយ ព្រោះសម្ពីងដល់ព្រះអភិធម្ម ព្រះតថាគត ឈ្មោះថាទ្រង់មិនបានប្រទានន័យទុកក្នុងឋានៈដែលគួរប្រទានន័យ មិនមាន នេះជាវារៈ ១ ក្នុងទុកមូល ។

ពិតហើយ ព្រះសាស្តាកាលទ្រង់ចែកវេទនាខន្ធ ក្នុងអភិធម្មភាជនីយនេះ ទ្រង់កាន់យកធម៌ពួក ៣ ដាក់ក្នុងធម៌ពួក ២ ទ្រង់កាន់យកធម៌ពួក ២ ដាក់ក្នុងធម៌ពួក ៣ ទ្រង់នាំយកធម៌ពួក ៣ និងពួក ២ មកដោយទំនងឲ្យបន្ថែមឡើងទាំង ២ ទ្រង់សម្តែងវេទនាខន្ធច្រើនយ៉ាងក្នុងទីទាំងពួង គឺទ្រង់សម្តែងវេទនាខន្ធពួក ៧ វេទនាខន្ធពួក ២៤ វេទនាខន្ធពួក ៣០ និងវេទនាខន្ធច្រើនយ៉ាង ព្រោះហេតុអ្វី ព្រោះទ្រង់សម្តែងតាមអធ្យាស្រ័យរបស់បុគ្គល និងដើម្បីទេសនាវិលាស ។

ពិតហើយ ទេវបុត្តពួកណាក្នុងទេវបរិស័ទ ដែលអង្គុយស្តាប់ធម៌ អាចត្រាស់ដឹងដោយព្រះតម្រាស់ដែលព្រះសាស្តាទ្រង់សម្តែងកាន់យកធម៌ពួក ៣ ដាក់ចូលក្នុងធម៌ពួក ២ ទ្រង់ក៏សម្តែងយ៉ាងនោះ ដោយអំណាចសប្បាយរបស់ទេវបុត្តទាំងនោះ ។ ទេវបុត្តពួកណា អាចត្រាស់ដឹងនូវធម៌ដែលទ្រង់ត្រាស់ដោយអាការដទៃ ទ្រង់ក៏សម្តែងដោយអាការទាំងនោះ ដល់ទេវបុត្ត

នោះ នេះជាអធ្យាស្រ័យរបស់បុគ្គលក្នុងការសម្ដែងវេទនាខន្ធនេះ ។

ព្រះសម្មាសម្ពុទ្ធទ្រង់អាចសម្ដែងវេទនាខន្ធ តាមដែលទ្រង់ប្រាថ្នាដោយកាន់យកធម៌ពួក ៣ ដាក់ក្នុងធម៌ពួក ២ ឬកាន់យកធម៌ពួក ២ ដាក់ក្នុងធម៌ពួក ៣ ឬបន្ថែមធម៌ពួក ៣ និងធម៌ពួក ២ ឬដោយន័យដែលទ្រង់សម្ដែងវេទនាពួក ៧ ជាដើម ព្រោះទ្រង់មានវិស័យធំ ព្រោះហេតុនោះ ទើបទ្រង់សម្ដែងដោយអាការទាំងនេះ នេះឈ្មោះថា ពុទ្ធទេសនាវិលាស ។

ក្នុងអភិធម្មភាជនីយនេះ បណ្ឌិតគប្បីជ្រាបមហាវារៈទាំង ៤ នេះមុន គឺវារៈដែលទ្រង់កាន់យកធម៌ ៣ ដាក់ក្នុងធម៌ពួក ២ សម្ដែង ឈ្មោះថា **ទុកមូលកវារ** វារៈដែលទ្រង់កាន់យកធម៌ពួក ២ ដាក់ក្នុងធម៌ពួក ៣ សម្ដែង ឈ្មោះថា **តិកមូលកវារ** វារៈដែលទ្រង់បន្ថែមធម៌ពួក ៣ និងធម៌ពួក ២ ទាំង ២ សម្ដែង ឈ្មោះថា **ឧភតោវឌ្ឍិតកវារ** វារៈមានពួក ៧ ជាដើម ក្នុងទីបំផុត ឈ្មោះថា **ពហុវិធវារ** ។

បណ្ដាមហាវារៈទាំង ៤ នោះ ក្នុងទុកមូលវារៈ មានវារៈ ៩៥០ មានវារៈប្រកបដោយតិកៈទី ១ និងទុកៈទី ២ ជាដើម ដោយនាំវេទនាតិកៈ បីតិតិកៈ និងសនិទស្សនតិកៈ ដែលមិនបានក្នុងតិកៈទាំងឡាយចេញ ប្រកបចំពោះតិកៈ ១៩ ដ៏សេសដែលបានជាមួយទុកៈនីមួយៗ ដែលបានក្នុងទុកៈទាំងឡាយ ។

វារៈទាំងអស់នោះ ទ្រង់សង្ខេបត្រាស់ធម៌ដែលគួរសម្ដែងក្នុងទីនោះៗ ក្នុងព្រះបាលីហើយ ។ បុគ្គលដែលមិនវង្វេង គួរជ្រាបដោយពិស្ដារ ។ ក្នុង

តិកមូលកវារៈក៏មានវារៈ ៩៥០ មានវារៈនៃការប្រកបទុកៈទី ២ និងតិកៈទី ១ ជាដើម ដោយនាំទុកៈដំបូងជាដើម ដែលមិនបានក្នុងទុកៈទាំងឡាយចេញ ប្រកបចំពោះទុកៈ ៥០ មានសហេតុកទុកៈជាដើម ដែលសល់ ដែលបានជាមួយតិកៈនីមួយៗ ដែលបានក្នុងតិកៈទាំងឡាយ វារៈទាំងអស់នោះ ទ្រង់សង្ខេបត្រាស់សម្តែងធម៌ដែលគួរសម្តែងក្នុងទីនោះៗ ក្នុងព្រះបាលីហើយ បុគ្គលដែលមិនវង្វេងគួរជ្រាបដោយពិស្តារ ។

ក្នុងឧភតោវឌ្ឍិតកវារៈ ត្រាស់ទុក ១៩ វារៈ មានវារៈប្រកបតិកៈទី ១ និងទុកៈទី ២ ជាដើម ដោយប្រកបតិកៈ ១៩ ដែលបានដោយទុកៈ ១៩ ដែលបានដោយធ្វើទុកៈទី ២ ក្នុងវេទនាមួយពួកៗ ២ និងតិកៈ ១ ក្នុងវេទនាមួយពួកៗ ៣ ឲ្យជាដើម ។ នេះជាមហាវារៈទី ៣ ឈ្មោះថា ឧភតោវឌ្ឍិតកវារៈ ព្រោះបន្ថែមធម៌ពួក ២ និងធម៌ពួក ៣ ជាមួយគ្នា ។

ក្នុងនិទ្ទេសនៃវេទនាខន្ធពួក ៧ របស់ពហុវិធវារៈ ត្រាស់វារៈពោលដោយវេទនាខន្ធពួក ៧ ទុក ១៩ វារៈ ដោយប្រកបភូមិ ៤ ជាមួយតិកៈ ១៩ ដែលបានអំពីតិកៈនីមួយៗ ចាប់តាំងអំពីខាងដើម ។ ក្នុងនិទ្ទេសនៃវេទនាខន្ធពួក ២៤ ក៏ត្រាស់ ១៩ វារៈ ដោយអំណាចតិកៈទាំងនោះឯង ក្នុងពហុវិធវារៈ ក៏ត្រាស់យ៉ាងនោះ ។ វារៈពោលដោយវេទនាពួក ៣០ មានវារៈ ១ ប៉ុណ្ណោះ ព្រោះហេតុនោះ ទើបវារៈទាំងអស់ជា ៥៨ វារៈ នេះជាកិច្ចពណ៌នាព្រះបាលីក្នុងវេទនាខន្ធនេះ ដោយអំណាចការកំណត់វារៈ ។

[ ៥០-៥១ ] ឥឡូវនេះ ជាកិច្ចពណ៌នាអត្ថនៃវេទនាខន្ធ ។ និទ្ទេសនៃ

វេទនាខន្ធពួក ៧ ក្នុងវេទនាខន្ធនោះ មានអត្ថងាយយល់ទាំងអស់ហើយ ។ ក្នុងនិទ្ទេសនៃវេទនាខន្ធ ពួក ២៤ ថា **ចក្ខុ សម្ផស្សប្បច្ចយា វេទនាខន្ធោ អត្ថិ កុសលោ** វេទនាខន្ធ ព្រោះចក្ខុសម្ផស្សជាបច្ច័យ ជាកុសលក៏មាន បណ្ឌិតគប្បីជ្រាបដោយអំណាចកាមាវចរកុសលចិត្ត ៨ ដួង ។ បទថា **អត្ថិ អកុសលោ** គប្បីជ្រាបដោយអំណាចអកុសលចិត្ត ១២ ដួង ។ បទថា **អត្ថិ អព្យាកតោ** គប្បីជ្រាបដោយអំណាចចិត្ត ២៤ ដួង គឺមនោធាតុ ៣ អហេតុកមនោវិញ្ញាណធាតុ ៣ មហាវិបាក ៨ និងកាមាវចរកិរិយា ១០ ។

បណ្ដាចិត្តទាំងនោះ កុសលចិត្ត ៨ និងអកុសលចិត្ត ១២ រមែងបានដោយអំណាចជវន កិរិយាមនោធាតុ ១ រមែងបានដោយអំណាចអាវជ្ជនៈ ។ មនោធាតុដែលជាវិបាក ២ ដួង រមែងបានដោយអំណាចសម្បដិច្ឆនៈ មនោវិញ្ញាណធាតុដែលជាវិបាក ៣ រមែងបានដោយអំណាចសន្តីរណៈ និងតទាលម្ពណៈ កិរិយាអហេតុកមនោវិញ្ញាណធាតុ ១ រមែងបានដោយអំណាចវោដ្ឋព្វនៈ មហាវិបាកចិត្ត ៨ រមែងបានដោយអំណាចតទាលម្ពណៈ កិរិយាចិត្ត ៩ ដួង រមែងបានដោយអំណាចជវន សូម្បីក្នុងសោតទ្វារ ឃានទ្វារ ជិវ្ហាទ្វារ និងកាយទ្វារ ក៏មានន័យនេះដូចគ្នា ។

ក្នុងមនោទ្វារ បទថា **អត្ថិ កុសលោ** នេះ ត្រាស់ដោយអំណាចកុសលចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ បទថា **អត្ថិ អកុសលោ** ត្រាស់ដោយអំណាចអកុសលចិត្ត ១២ ដួង ។ បទថា **អត្ថិ អព្យាកតោ**

គ្រាស់ដោយអំណាចចិត្តុប្បាទ ៣៤ គឺកាមាវចរវិបាកចិត្ត ១១ កិរិយាចិត្ត ១០ រូបាវចរកិរិយាចិត្ត និងអរូបាវចរកិរិយាចិត្ត ៩ ដួង និងសាមញ្ញផល ៤ ។

បណ្ដាចិត្តុប្បាទទាំងនោះ កុសលចិត្តប្រព្រឹត្តទៅក្នុងភូមិ ៤ អកុសល-ចិត្ត រមែងបានដោយអំណាចជវ័ន អហេតុកមនោវិញ្ញាណធាតុដែលជាកិរិយា រមែងបានដោយអំណាចអាវជ្ជនៈ ។ វិបាកចិត្ត ១១ ដួង រមែងបានដោយអំណាចតទាលម្ពណៈ កិរិយាចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៣ និងសាមញ្ញ រមែងបានដោយអំណាចជវ័ន ។ ការពោលដល់ចិត្តទាំងនោះ តាំងទុកក្នុងវេទនាខន្ធទាំងឡាយ មានវេទនាខន្ធពួក ៧ ជាដើមណានីមួយក៏គួរ តែចិត្តទាំងនោះ ព្រះមានព្រះភាគ ទ្រង់សម្ដែងទុកក្នុងវេទនាខន្ធពួក ៣០ រមែងសម្ដែងបានដោយងាយ ព្រោះហេតុនោះ ទើបទ្រង់សម្ដែងចិត្តទាំងនោះក្នុងវេទនាពួក ៣០ នោះឯង ។

ចិត្តទាំងអស់នោះ រមែងបានក្នុងចក្ខុទ្វារដោយអាការ ៣ គឺដោយឧប-និស្សយកោដិ គឺកំណួចរបស់ឧបនិស្ស័យ ១ ដោយអំណាចការឈានកន្លង ( កិលេស ) ១ ដោយអំណាចភាវនា ១ ក្នុងសោតទ្វារ និងមនោទ្វារ ក៏រមែងបានដោយអាការ ៣ យ៉ាងនោះ តែក្នុងឃានទ្វារ ជិវ្ហាទ្វារ និងកាយទ្វារ គប្បីជ្រាបថា បានដោយអាការ ២ យ៉ាង គឺដោយអំណាចការឈានកន្លង និងដោយអំណាចភាវនា ។

រមែងបានដោយអាការ ៣ ដូចម្ដេច គឺភិក្ខុក្នុងធម្មវិន័យនេះ ត្រាច់ចារិកទៅកាន់វិហារ ឃើញមណ្ឌលកសិណ ទើបសួរថា នេះឈ្មោះអ្វី កាលគេ

ប្រាប់ថា មណ្ឌលកសិណា ដូច្នេះ ទើបសួរទៀតថា ពួកគេធ្វើអ្វីដោយមណ្ឌលកសិណានេះ ពេលនោះ ពួកភិក្ខុក៏ប្រាប់ថា ពួកភិក្ខុចម្រើនមណ្ឌល-កសិណានេះ ញុំាងឈានទាំងឡាយឲ្យកើត ហើយចម្រើនវិបស្សនា មានសមាបត្តិជាបទដ្ឋាន ហើយសម្រេចអរហត្ត ដូច្នេះ កុលបុត្តដល់ព្រមដោយអធ្យាស្រ័យ មិនបានកំណត់ថា នេះជាភារៈធ្ងន់ មានការគិតថា សូម្បីអាត្មាអញ ក៏គួរញុំាងគុណនេះឲ្យកើតឡើង គុណនេះដែលបុគ្គលដេកលក់ មិនអាចឲ្យកើតបានឡើយ អញគួរធ្វើសេចក្តីព្យាយាម ជម្រះសីលឲ្យបរិសុទ្ធតាំងអំពីខាងដើម ដូច្នេះ ទើបញុំាងសីលឲ្យបរិសុទ្ធ បន្ទាប់អំពីនោះ ក៏តាំងមាំនៅក្នុងសីល កាត់នូវបលិពោធ ១០ ជាអ្នកសន្តោស ត្រេកអរដោយចីវរ ៣ ក្រៅលែង ធ្វើវត្តបដិបត្តិចំពោះអាចារ្យ និងឧបជ្ឈាយ៍ រៀនកម្មដ្ឋានធ្វើកសិណបរិកម្ម ញុំាងសមាបត្តិឲ្យកើត ហើយចម្រើនវិបស្សនា មានសមាបត្តិជាបទដ្ឋាន ហើយសម្រេចអរហត្ត ។ ក្នុងការសម្រេចអរហត្តនោះ ចក្ខុវិញ្ញាណជាបច្ច័យដែលមានកម្លាំងដល់ការកើតវេទនា ប្រព្រឹត្តទៅក្នុងភូមិ ៤ យ៉ាងនេះ គឺវេទនាក្នុងការបរិកម្មទាំងអស់ជាកាមាវចរ វេទនាក្នុងសមា-បត្តិ ៨ ជារូបាវចរ និងអរូបាវចរ វេទនាក្នុងមគ្គ និងផលជាលោកុត្តរ ព្រោះហេតុនោះ ទើបវេទនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា មានចក្ខុសម្ផស្សជាបច្ច័យ ចិត្តក្នុងចក្ខុទ្វារ រមែងបានដោយអំណាចឧបនិស្ស័យយ៉ាងនេះ ។

ម្យ៉ាងទៀត កាលរូបមកកាន់គន្លងចក្ខុទ្វារហើយ កុលបុត្តដែលតាំងនៅក្នុងការពិចារណា យ៉ាងនេះថា ការត្រេកអរកើតឡើងហើយដល់អាត្មាអញ

ក្នុងអារម្មណ៍ដែលគួរប្រាថ្នា បដិឃៈកើតឡើងហើយដល់អាត្មាអញ ក្នុងអារម្មណ៍ដែលមិនគួរប្រាថ្នា មោហៈកើតឡើងហើយដល់អាត្មាអញ ក្នុងខណៈដែលមិនឃើញតាមសេចក្តីពិត មានះកើតឡើងហើយដល់អាត្មាអញ ដែលមានការជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ ទិដ្ឋិកើតដល់អាត្មាអញដែលមានការប្រកាន់ខុស ឧទ្ធច្ចៈកើតដល់អាត្មាអញដែលមានចិត្តរាយមាយ វិចិកិច្ឆាកើតដល់អាត្មាអញដែលសម្រេចចិត្តមិនបាន អនុស័យកើតដល់អាត្មាអញដែលមានកិលេសខ្លាំងក្លា ដូច្នេះ ដឹងនូវការកើតឡើងនៃកិលេសរបស់ខ្លួនហើយទើបគិតថា កិលេសទាំងនេះ ចម្រើនឡើងដល់អាត្មាអញហើយ នឹងប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស ណ្ហើយចុះ អញនឹងសង្កត់សង្កិនកិលេសទាំងនេះ ទើបពិចារណាថា បុគ្គលដែលដេកលក់មិនអាចសង្កត់កិលេសបាន អញគួរផ្តើមធ្វើនូវសេចក្តីព្យាយាម ដើម្បីជម្រះសីលឲ្យបរិសុទ្ធអំពីខាងដើមនោះឯង ដូច្នេះ ទើបបដិបត្តិដោយន័យដែលពោលហើយនោះឯង រមែងសម្រេចអរហត្តបាន ។ ក្នុងការសម្រេចអរហត្តនោះ វេទនាដែលឈានកន្លងកិលេសដែលកើតឡើងក្នុងរូបារម្មណ៍យ៉ាងនេះ គឺបរិកម្មវេទនាទាំងអស់ ជាកាមាវចរ វេទនាក្នុងសមាបត្តិ ៨ ជារូបាវចរ និងអរូបាវចរ វេទនាដែលប្រព្រឹត្តទៅក្នុងមគ្គផល ជាលោកុត្តរ ព្រោះហេតុនោះ ទើបវេទនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា មានចក្ខុសម្ផស្សជាបច្ច័យ ។ ចិត្តក្នុងចក្ខុទ្វារ រមែងបានដោយអំណាចការឈានកន្លងកិលេសយ៉ាងនេះ ។

ម្យ៉ាងទៀត កាលរូបមកកាន់គន្លងចក្ខុទ្វារហើយ កុលបុត្តម្នាក់ រមែង

ផ្ដើមកំណត់យ៉ាងនេះថា រូបនេះ អាស្រ័យអ្វី បន្ទាប់អំពីនោះ ក៏នឹងជ្រាបរូប ( រូបារម្មណ៍ ) នោះថា អាស្រ័យមហាភូតរូប ហើយក៏កំណត់មហាភូតរូប ៤ និងឧបាទាយរូប ថាជារូប កំណត់ធម៌ទាំងឡាយ មានរូបនោះជាអារម្មណ៍ ថាជាអរូប បន្ទាប់អំពីនោះ ក៏កំណត់នាមរូប ព្រមទាំងបច្ច័យ ហើយលើកឡើងកាន់ត្រៃលក្ខណ៍ ពិចារណាសង្ខារទាំងឡាយ ដោយលំដាប់នៃវិបស្សនា រមែងសម្រេចអរហត្តបាន ។ ក្នុងការសម្រេចអរហត្តនោះ វេទនាដែលព្រះយោគាវចរពិចារណារូបារម្មណ៍ហើយ ឲ្យកើតឡើងយ៉ាងនេះ គឺបរិកម្មវេទនាទាំងអស់ ជាកាមាវចរ វេទនាក្នុងសមាបត្តិ ៨ ជារូបាវចរ និងអរូបាវចរ វេទនាក្នុងមគ្គ និងផលជាលោកុត្តរ ព្រោះហេតុនោះ ទើបវេទនានេះ ឈ្មោះថា មានចក្ខុសម្ផស្សជាបច្ច័យ ចិត្តក្នុងចក្ខុទ្វាររមែងបានដោយអំណាចការនាយ៉ាងនេះ ។

ភិក្ខុមួយរូបទៀត បានស្ដាប់ថា បានឮថា បុគ្គលធ្វើបរិកម្មកសិណ ញុំាងសមាបត្តិឲ្យកើតឡើង ចម្រើនវិបស្សនា មានសមាបត្តិជាបទដ្ឋាន ហើយរមែងសម្រេចអរហត្ត ដូច្នេះ កុលបុត្តដែលដល់ព្រមដោយអធ្យាស្រ័យ មិនបានកំណត់ថា រឿងនេះជាភារៈធ្ងន់ ក៏ត្រិះរិះថា អាត្មាអញក៏គួរឲ្យគុណនេះកើតឡើង ដូច្នេះហើយ បដិបត្តិដោយន័យមុននោះឯង រមែងសម្រេចអរហត្តបាន ។ ក្នុងការសម្រេចអរហត្តនោះ សោតវិញ្ញាណជាបច្ច័យ មានកម្លាំងដល់ការកើតវេទនា ប្រព្រឹត្តទៅក្នុងភូមិ ៤ យ៉ាងនេះ គឺបរិកម្មវេទនាទាំងអស់ ជាកាមាវចរ វេទនាក្នុងសមាបត្តិ ៨ ជារូបាវចរ និងអរូបាវចរ វេទនា

ក្នុងមគ្គ និងផលជាលោកុត្តរ ព្រោះហេតុនោះ ទើបវេទនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា មានសោតសម្ផស្សជាបច្ច័យ ចិត្តក្នុងសោតទ្វារ រមែងបានដោយអំណាចឧបនិស្ស័យយ៉ាងនេះ ។

ចំណែកពាក្យទាំងអស់ថា កាលសំឡេងមកកាន់គន្លងសោតទ្វារ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងចក្ខុទ្វារនោះឯង ។ វេទនាដែលប្រព្រឹត្តទៅ ឈានកន្លងកិលេសដែលកើតឡើងក្នុងសទ្ទារម្មណ៍ ដោយអាការយ៉ាងនេះ ព្រោះហេតុនោះ ទើបវេទនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា មានសោតសម្ផស្សជាបច្ច័យ ។ ចិត្តក្នុងសោតទ្វារ រមែងបានដោយការឈានកន្លង ( កិលេស ) យ៉ាងនេះ ។

ម្យ៉ាងទៀត ពាក្យទាំងអស់ថា កាលសំឡេង មកកាន់គន្លងសោតទ្វារ កុលបុត្តម្នាក់ រមែងផ្ដើមកំណត់យ៉ាងនេះថា សំឡេងនេះ អាស្រ័យអ្វីជាដើម គប្បីជ្រាបដោយន័យ ដែលពោលក្នុងចក្ខុទ្វារនោះឯង ។ វេទនាដែលព្រះយោគាវចរពិចារណាសទ្ទារម្មណ៍ ហើយឲ្យកើតឡើងដោយអាការយ៉ាងនេះ ព្រោះហេតុនោះ ទើបវេទនានេះ ឈ្មោះថា មានសោតសម្ផស្សជាបច្ច័យ ។ ចិត្តក្នុងសោតទ្វារ រមែងបានដោយអំណាចការនាយ៉ាងនេះ ។

ម្យ៉ាងទៀត ពាក្យទាំងអស់ថា កាលគន្ធារម្មណ៍ជាដើម មកកាន់គន្លងឃានទ្វារ ជិវ្ហាទ្វារ កាយទ្វារ ការត្រេកអរក្នុងអារម្មណ៍ដែលគួរប្រាថ្នា កើតឡើងហើយ ដល់អាត្មាអញជាដើម គប្បីជ្រាបដោយន័យដែលពោល ក្នុងចក្ខុទ្វារនោះឯង ។ វេទនាដែលប្រព្រឹត្តទៅ ឈានកន្លងកិលេសដែលកើត

ឡើងក្នុងគន្ធារម្មណ៍ជាដើមយ៉ាងនេះ ព្រោះហេតុនោះ ទើបវេទនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា មានឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយ-សម្ផស្សជាបច្ច័យ ចិត្តទាំងឡាយក្នុងទ្វារ ៣ រមែងបានដោយអំណាចការឈានកន្លងកិលេសយ៉ាងនេះ ។

ពាក្យទាំងអស់ថា កាលក្លិនជាដើម មកកាន់គន្លងឃានទ្វារជាដើមហើយ កុលបុត្តម្នាក់ រមែងផ្តើមកំណត់យ៉ាងនេះថា ក្លិននេះ រសនេះ ផោដ្ឋព្វៈនេះ អាស្រ័យអ្វី ដូច្នេះជាដើម គប្បីជ្រាបដោយន័យដែលពោលក្នុងចក្ខុទ្វារនោះឯង ។ វេទនាដែលព្រះយោគាវចរពិចារណាគន្ធារម្មណ៍ជាដើម ហើយឲ្យកើតឡើងដោយអាការយ៉ាងនេះ ព្រោះហេតុនោះ ទើបវេទនានេះ ឈ្មោះថា មានឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយសម្ផស្សជាបច្ច័យ ។ ចិត្តទាំងឡាយ ក្នុងឃានទ្វារជាដើម រមែងបានដោយអំណាចការនាយ៉ាងនេះ ។

ចិត្តរមែងបានក្នុងមនោទ្វារដោយអាការទាំង ៣ ។ ពិតហើយ កុលបុត្តរូបខ្លះឃើញជាតិ ថាជាភ័យ ឃើញជរា ព្យាធិ មរណៈ ថាជាភ័យ កាលឃើញដោយភាពជាភ័យហើយ ក៏គិតថា អញគួរផុតចាកជាតិ ជរា ព្យាធិ និងមរណៈ តែបុគ្គលដែលដេកលក់ មិនអាចផុតចាកជាតិជាដើមបានឡើយ អញគួរធ្វើសេចក្តីព្យាយាម ជម្រះសីលឲ្យបរិសុទ្ធតាំងអំពីខាងដើមនោះឯង ដូច្នេះហើយ បដិបត្តិដោយន័យ ដែលពោលក្នុងចក្ខុទ្វារនោះឯង ក៏រមែងសម្រេចអរហត្តបាន ។ ក្នុងការសម្រេចអរហត្តនោះ ជាតិ ជរា ព្យាធិ និងមរណៈជាបច្ច័យ មានកម្លាំងដល់ការកើតវេទនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤

យ៉ាងនេះ គឺបរិកម្មវេទនាទាំងអស់ ជាកាមាវចរ វេទនាក្នុងសមាបត្តិ ៨ ជារូបាវចរ និងអរូបាវចរ វេទនាក្នុងមគ្គ និងផល ជាលោកុត្តរ ព្រោះហេតុនោះ ទើបវេទនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា មានមនោសម្ផស្សជាបច្ច័យ ចិត្តក្នុងមនោទ្វារ រមែងបានដោយអំណាចឧបនិស្ស័យយ៉ាងនេះ ។

ពាក្យទាំងអស់ថា កាលធម្មារម្មណ៍មកកាន់គន្លងមនោទ្វារ គប្បីជ្រាបដោយន័យដែលពោល ក្នុងចក្ខុទ្វារនោះឯង ។ វេទនាដែលប្រព្រឹត្តទៅឈានកន្លងកិលេស ដែលកើតឡើងក្នុងធម្មារម្មណ៍ ដោយអាការយ៉ាងនេះ ព្រោះហេតុនោះ ទើបវេទនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា មានមនោសម្ផស្សជាបច្ច័យ ។ ចិត្តក្នុងមនោទ្វារ រមែងបានដោយអំណាចការឈាន កន្លងកិលេសយ៉ាងនេះ ។

ម្យ៉ាងទៀត កាលធម្មារម្មណ៍មកកាន់គន្លងមនោទ្វារហើយ កុលបុត្តម្នាក់កំណត់យ៉ាងនេះថា ធម្មារម្មណ៍នេះអាស្រ័យអ្វី ជ្រាបហើយថា អាស្រ័យវត្ថុ ក៏ពិចារណាថា វត្ថុអាស្រ័យអ្វី ជ្រាបហើយថា អាស្រ័យមហាភូតរូប ដូច្នេះ ទើបកុលបុត្តនោះ កំណត់មហាភូតរូប និងឧបាទាយរូប ថាជារូប កំណត់ធម៌ដែលមានរូបនោះជាអារម្មណ៍ ថាជាអរូប បន្ទាប់អំពីនោះ កំណត់នាមរូប ព្រមទាំងបច្ច័យ លើកឡើងកាន់ត្រៃលក្ខណ៍ ពិចារណាសង្ខារទាំងឡាយ ដោយលំដាប់នៃវិបស្សនាហើយ រមែងសម្រេចអរហត្ត ក្នុងការសម្រេចអរហត្តនោះ វេទនានេះ គឺវេទនាដែលព្រះយោគាវចរពិចារណាធម្មារម្មណ៍ ហើយឲ្យកើតឡើង ដោយអាការយ៉ាងនេះ គឺបរិកម្មវេទនាទាំងអស់ ជាកាមាវចរ

វេទនាក្នុងសមាបត្តិ ៨ ជារូបាវចរ និងអរូបាវចរ វេទនាក្នុងមគ្គ និងផល ជាលោកុត្តរ ព្រោះហេតុនោះ ទើបវេទនានេះ ឈ្មោះថា មានមនោសម្ផស្សជាបច្ច័យ ។ ចិត្តក្នុងមនោទ្វារ រមែងបានដោយអំណាចការនោយ៉ាងនេះ ។

ព្រះមានព្រះភាគ ត្រាស់វេទនា ៦ ( ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ ) ថា ចក្ខុសម្ផស្សជាវេទនា ១ ។បេ។ មនោសម្ផស្សជាវេទនា ១ ដូច្នេះ ក្នុងទីបំផុតនៃវារៈ មានវារៈនៃវេទនាពួក ២៤ ជាដើមដោយអំណាចនៃបច្ច័យធម៌ដែលសម្បយុត្តគ្នា ដូច្នេះ ។

## វេទនាខន្ធនិទ្ទេស ចប់

[ ៥៤-៨៣ ] សញ្ញាខន្ធជាដើម ក៏គប្បីជ្រាបដោយឧបាយនេះ ។ ពិតហើយ ក្នុងនិទ្ទេសនៃសញ្ញាខន្ធ រមែងបានវេទនាតិកៈ និងបីតិតិកៈ ក្នុងតិកៈទាំងឡាយដោយឥតសេសសល់ សុខសហគតទុកៈជាដើម ក៏រមែងបានក្នុងទុកៈទាំងឡាយ ។

ក្នុងនិទ្ទេសនៃសង្ខារក្ខន្ធ ព្រះមានព្រះភាគ មិនត្រាស់ពាក្យថា **ផស្សសម្បយុត្តោ** ព្រោះផស្សៈក៏ជាធម៌ដែលទាក់ទងក្នុងសង្ខារក្ខន្ធ តែត្រាស់ពាក្យថា **ចិត្តសម្បយុត្តោ** និងក្នុងនិទ្ទេសនៃខន្ធនេះ ហេតុកទុកៈជាដើម រមែងបានក្នុងទុកៈទាំងឡាយ ។ ធម៌ពួក ៣ ដូចគ្នានឹងសញ្ញាខន្ធនោះឯង ។

ក្នុងនិទ្ទេសនៃវិញ្ញាណក្ខន្ធ ព្រះមានព្រះភាគមិនត្រាស់ថា **ចក្ខុ សម្ផស្សជា**

ជាដើម តែត្រាស់ពាក្យថា **ចក្ខុវិញ្ញាណំ** ជាដើម ព្រោះបុគ្គលណាម្នាក់ មិនអាចសម្តែងថា វិញ្ញាណកើតអំពីមនោសម្ផស្ស ដូច្នេះ ។ ពាក្យដ៏សេសក្នុងទីនេះ ដូចគ្នានឹងពាក្យដែលពោលក្នុងសញ្ញាខន្ធនោះឯង ។

ក្នុងនិទ្ទេសនៃខន្ធទាំង ៣ នេះ បានធម្មិពួក ៣ និងធម្មិពួក ២ ច្រើនជាងនិទ្ទេសនៃវេទនាខន្ធ ។ បណ្ឌិតគប្បីជ្រាបប្រភេទនៃវារៈដោយអំណាចនៃធម្មិពួក ៣ និងធម្មិពួក ២ ទាំងនោះចុះ ដូច្នេះ ។

**អភិធម្មភាជនីយ ចប់**

# អភិធម្មបិដក

## បញ្ហាបុច្ឆកៈ

[ ៨៤ ] ខន្ធ ៥ គឺរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ។ បណ្ដាខន្ធ ៥ ខន្ធជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។បេ។ ប្រកបដោយសត្រូវប៉ុន្មាន មិនមានសត្រូវប៉ុន្មាន ។

[ ៨៥ ] រូបក្ខន្ធជាអព្យាក្រឹត ឯខន្ធ ៤ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ ខន្ធ ២ មិនគប្បីពោលថា ប្រកបដោយសុខវេទនាផង ជាប្រកបដោយទុក្ខវេទនាផង ជាប្រកបដោយអទុក្ខមសុខវេទនាផងឡើយ ខន្ធ ៣ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។ រូបក្ខន្ធមិនមែនជាវិបាក មិនមែនជាធម៌មានវិបាកជាប្រក្រតី ខន្ធ ៤ ជាវិបាកក៏មាន ជាធម៌មានវិបាកជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីក៏មាន ។ រូបក្ខន្ធ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទានក៏មាន ខន្ធ ៤ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងមិនជាប្រយោជន៍

ដល់ឧបាទានក៏មាន ។ រូបក្ខន្ធមិនសៅហ្មងហើយ តែគួរដល់សេចក្តីសៅហ្មង ខន្ធ ៤ សៅហ្មងហើយ ទាំងគួរដល់សេចក្តីសៅហ្មងក៏មាន មិនសៅហ្មងហើយ តែគួរដល់សេចក្តីសៅហ្មងក៏មាន មិនសៅហ្មងហើយ ទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន ។ រូបក្ខន្ធ មិនមានវិតក្ក មិនមានវិចារ ខន្ធ ៣ មិនមានវិតក្ក តែប្រព្រឹត្តទៅជាមួយនឹងវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន សង្ខារក្ខន្ធ ប្រព្រឹត្តទៅជាមួយនឹងវិតក្ក ជាមួយនឹងវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន មិនគប្បីពោលថា ប្រព្រឹត្តទៅជាមួយនឹងវិតក្ក ជាមួយនឹងវិចារផង ថាមិនមានវិតក្ក មានត្រឹមតែវិចារផង ថាមិនមានវិតក្ក ទាំងមិនមានវិចារផងក៏មាន ។ រូបក្ខន្ធ មិនគប្បីពោលថា កើតព្រមដោយបីតិផង ថាកើតព្រមដោយសុខផង ថាកើតព្រមដោយឧបេក្ខាផងឡើយ វេទនាខន្ធកើតព្រមដោយបីតិ មិនកើតព្រមដោយសុខ មិនកើតព្រមដោយឧបេក្ខាក៏មាន មិនគប្បីពោលថា កើតព្រមដោយបីតិក៏មាន ខន្ធ ៣ កើតព្រមដោយបីតិក៏មាន កើតព្រមដោយសុខក៏មាន កើតព្រមដោយឧបេក្ខាក៏មាន មិនគប្បីពោលថា កើតព្រមដោយបីតិផង ថាកើតព្រមដោយសុខផង ថាកើតព្រមដោយឧបេក្ខាផងក៏មាន ។ រូបក្ខន្ធ មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនាទេ ខន្ធ ៤ គួរលះដោយទស្សនៈក៏មាន គួរលះដោយភាវនាក៏មាន មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន ។ រូបក្ខន្ធ មានហេតុ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះ

ដោយភាវនា ខន្ធ ៤ មានហេតុ គួរលះដោយទស្សនៈក៏មាន មានហេតុ គួរលះដោយភាវនាក៏មាន មានហេតុ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន ។ រូបក្ខន្ធ មិនដល់នូវការសន្សំកពូនឡើង ទាំងមិនដល់នូវការមិនសន្សំកពូនឡើង ខន្ធ ៤ ដល់នូវការសន្សំកពូនឡើងក៏មាន ដល់នូវការមិនសន្សំកពូនឡើងក៏មាន មិនដល់នូវការសន្សំកពូនឡើង ទាំងមិនដល់នូវការមិនសន្សំកពូនឡើងក៏មាន ។ រូបក្ខន្ធ មិនមែនជារបស់សេក្ខ-បុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល ខន្ធ ៤ ជារបស់សេក្ខបុគ្គលក៏មាន ជារបស់អសេក្ខបុគ្គលក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គលក៏មាន ។ រូបក្ខន្ធ មានសភាពតូចថោក ខន្ធ ៤ មានសភាពតូចថោកក៏មាន ដល់សភាពធំក៏មាន ប្រមាណមិនបានក៏មាន ។ រូបក្ខន្ធ មិនមានអារម្មណ៍ ខន្ធ ៤ មានអារម្មណ៍តូចថោកក៏មាន មានអារម្មណ៍ដល់សភាពធំក៏មាន មានអារម្មណ៍ប្រមាណមិនបានក៏មាន មិនគប្បីពោលថា មានអារម្មណ៍តូចថោកផង ថាមានអារម្មណ៍ដល់នូវសភាពធំផង ថាមានអារម្មណ៍ប្រមាណមិនបានផងក៏មាន ។ រូបក្ខន្ធ ជាកណ្តាល ខន្ធ ៤ ថោកទាបក៏មាន កណ្តាលក៏មាន ថ្លៃថ្លាក៏មាន ។ រូបក្ខន្ធ មិនទៀង ខន្ធ ៤ មានសភាពខុស និងទៀងក៏មាន មានសភាពត្រូវ និងទៀងក៏មាន មិនទៀងក៏មាន ។ រូបក្ខន្ធមិនមានអារម្មណ៍ ខន្ធ ៤ មានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគប្បីពោលថា មានមគ្គជាអារម្មណ៍ផង ថាមានមគ្គជាហេតុផង ថាមានមគ្គអធិបតីផងក៏មាន ។ ខន្ធ ៤ កើតឡើង

ហើយក៏មាន មិនទាន់កើតឡើងក៏មាន ប្រុងនឹងកើតឡើងក៏មាន ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន ។ រូបក្ខន្ធមិនមានអារម្មណ៍ ខន្ធ ៤ មានអារម្មណ៍ជាអតីតក៏មាន មានអារម្មណ៍ជាអនាគតក៏មាន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន មិនគប្បីពោលថា មានអារម្មណ៍ជាអតីតផង ជាមានអារម្មណ៍ជាអនាគតផង ជាមានអារម្មណ៍ជាបច្ចុប្បន្នផងក៏មាន ។ ខន្ធ ៤ ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ជាខាងក្នុង និងខាងក្រៅក៏មាន ។ រូបក្ខន្ធមិនមានអារម្មណ៍ ខន្ធ ៤ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន មិនគប្បីពោលថា មានអារម្មណ៍ខាងក្នុងផង ថាមានអារម្មណ៍ខាងក្រៅផង ថាមានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅផងក៏មាន ។ ខន្ធ ៤ មិនប្រកបដោយការឃើញទាំងមិនប្រកបដោយការប៉ះពាល់ទេ រូបក្ខន្ធ ប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ក៏មាន មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ក៏មាន មិនប្រកបដោយការឃើញទាំងមិនប្រកបដោយការប៉ះពាល់ក៏មាន ។

[ ៨៦ ] ខន្ធ ៤ មិនមែនជាហេតុ ឯសង្ខារក្ខន្ធជាហេតុក៏មាន មិនមែនជាហេតុក៏មាន ។ រូបក្ខន្ធមិនមានហេតុ ខន្ធ ៤ ប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមានហេតុក៏មាន ។ រូបក្ខន្ធប្រាសចាកហេតុ ខន្ធ ៤ ប្រកបដោយហេតុក៏មាន ប្រាសចាកហេតុក៏មាន ។ រូបក្ខន្ធ មិនគប្បីពោលថា ជាហេតុទាំងប្រព្រឹត្តទៅជាមួយនឹងហេតុផង ថាប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិន

មែនជាហេតុផងឡើយ ខន្ធ ៣ មិនគប្បីពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ ប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុក៏មាន មិនគប្បីពោលថា ប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុក៏មាន សង្ខារក្ខន្ធជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន ប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុក៏មាន មិនគប្បីពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុផង ជាប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុផងក៏មាន ។ រូបក្ខន្ធមិនគប្បីពោលថា ជាហេតុ ទាំងប្រកបដោយហេតុផង ជាប្រកបដោយហេតុ តែមិនមែនហេតុផងឡើយ ខន្ធ ៣ មិនគប្បីពោលថា ជាហេតុ ទាំងប្រកបដោយហេតុទេ ខន្ធ ៣ ប្រកបដោយហេតុ តែមិនមែនហេតុក៏មាន មិនគប្បីពោលថា ប្រកបដោយហេតុ តែមិនមែនហេតុក៏មាន សង្ខារក្ខន្ធ ជាហេតុ ទាំងប្រកបដោយហេតុក៏មាន ប្រកបដោយហេតុ តែមិនមែនហេតុក៏មាន មិនគប្បីពោលថា ជាហេតុ ទាំងប្រកបដោយហេតុផង ជាប្រកបដោយហេតុ តែមិនមែនហេតុផងក៏មាន ។ រូបក្ខន្ធមិនមែនហេតុ ទាំងមិនមានហេតុ ខន្ធ ៣ មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមែនហេតុ ទាំងមិនមានហេតុក៏មាន សង្ខារក្ខន្ធមិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមែនហេតុ ទាំងមិនមានហេតុក៏មាន មិនគប្បីពោលថា មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុផង ជាមិនមែនជាហេតុ ទាំងមិនមានហេតុផងក៏មាន ។

[ ៨៧ ] ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងបច្ច័យ ត្រូវបច្ច័យប្រជុំតាក់តែង ។

ខន្ធ ៤ មិនប្រកបដោយការឃើញ រូបក្ខន្ធប្រកបដោយការឃើញក៏មាន មិនប្រកបដោយការឃើញក៏មាន ។ ខន្ធ ៤ មិនប្រកបដោយការប៉ះពាល់ រូបក្ខន្ធប្រកបដោយការប៉ះពាល់ក៏មាន មិនប្រកបដោយការប៉ះពាល់ក៏មាន ។ រូបក្ខន្ធជារូប ខន្ធ ៤ ជាអរូប ។ រូបក្ខន្ធជាលោកិយ ខន្ធ ៤ ជាលោកិយ ជាលោកុត្តរក៏មាន ។ ខន្ធដែលគប្បីដឹងច្បាស់ដោយវិញ្ញាណណាមួយ មិនគប្បីដឹងច្បាស់ដោយវិញ្ញាណណាមួយ ។

[ ៨៨ ] ខន្ធ ៤ មិនមែនអាសវៈ សង្ខារក្ខន្ធ ជាអាសវៈក៏មាន មិនមែនអាសវៈក៏មាន ។ រូបក្ខន្ធប្រព្រឹត្តជាមួយនឹងអាសវៈ ខន្ធ ៤ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន មិនមានអាសវៈក៏មាន ។ រូបក្ខន្ធប្រាសចាកអាសវៈ ខន្ធ ៤ ប្រកបដោយអាសវៈក៏មាន ប្រាសចាកអាសវៈក៏មាន ។ រូបក្ខន្ធ មិនគប្បីពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈឡើយ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈ ខន្ធ ៣ មិនគប្បីពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈទេ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈក៏មាន មិនគប្បីពោលថា ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈក៏មាន សង្ខារក្ខន្ធជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈក៏មាន មិនគប្បីពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ជាប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈផងក៏មាន ។ រូបក្ខន្ធមិនគប្បីពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផង ជាប្រកបដោយ

អាសវៈ តែមិនមែនជាអាសវៈផងឡើយ ខន្ធ ៣ មិនគប្បីពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈទេ ប្រកបដោយអាសវៈ តែមិនមែនជាអាសវៈក៏មាន មិនគប្បីពោលថា ប្រកបដោយអាសវៈ ទាំងមិនមែនអាសវៈក៏មាន សង្ខារក្ខន្ធជាអាសវៈ ទាំងប្រកបដោយអាសវៈក៏មាន ប្រកបដោយអាសវៈ តែមិនមែនអាសវៈក៏មាន មិនគប្បីពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផង ជាប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផងក៏មាន ។ រូបក្ខន្ធ ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ ខន្ធ ៤ ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រាសចាកអាសវៈទាំងមិនមែនអាសវៈក៏មាន មិនគប្បីពោលថា ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ជាប្រាសចាកអាសវៈ ទាំងមិនមែនអាសវៈផងក៏មាន ។

[ ៨៩ ] ខន្ធ ៤ មិនមែនសញ្ញោជនៈ សង្ខារក្ខន្ធ ជាសញ្ញោជនៈក៏មាន មិនមែនសញ្ញោជនៈក៏មាន ។ រូបក្ខន្ធ ជាប្រយោជន៍ដល់សញ្ញោជនៈ ខន្ធ ៤ ជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន មិនជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ។ រូបក្ខន្ធ ប្រាសចាកសញ្ញោជនៈ ខន្ធ ៤ ប្រកបដោយសញ្ញោជនៈក៏មាន ប្រាសចាកសញ្ញោជនៈក៏មាន ។ រូបក្ខន្ធ មិនគប្បីពោលថា ជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈទេ ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនសញ្ញោជនៈ ខន្ធ ៣ មិនគប្បីពោលថា ជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈឡើយ ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិន

មែនសញ្ញោជនៈក៏មាន មិនគប្បីពោលថា ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនសញ្ញោជនៈក៏មាន សង្ខារក្ខន្ធ ជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនសញ្ញោជនៈក៏មាន មិនគប្បីពោលថា ជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈផង ជាជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនសញ្ញោជនៈក៏មាន ។ រូបក្ខន្ធ មិនគប្បីពោលថា ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈផង ជាប្រកបដោយសញ្ញោជនៈ តែមិនមែនសញ្ញោជនៈផងទេ ខន្ធ ៣ មិនគប្បីពោលថា ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈឡើយ ប្រកបដោយសញ្ញោជនៈ តែមិនមែនសញ្ញោជនៈក៏មាន មិនគប្បីពោលថា ប្រកបដោយសញ្ញោជនៈ ទាំងមិនមែនសញ្ញោជនៈក៏មាន សង្ខារក្ខន្ធ ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈក៏មាន ប្រកបដោយសញ្ញោជនៈ តែមិនមែនសញ្ញោជនៈក៏មាន មិនគប្បីពោលថា ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈផង ជាប្រកបដោយសញ្ញោជនៈ តែមិនមែនសញ្ញោជនៈផងក៏មាន ។ រូបក្ខន្ធ ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈ ខន្ធ ៤ ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន មិនគប្បីពោលថា ប្រាសចាកសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈផង ជាប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈផងក៏មាន ។

[ ៩០ ] ខន្ធ ៤ មិនមែនគន្ថៈ សង្ខារក្ខន្ធជាគន្ថៈក៏មាន មិនមែនគន្ថៈ

ក៏មាន ។ រូបក្ខន្ធ គន្ថៈគប្បីដោតក្រង ខន្ធ ៤ គន្ថៈគប្បីដោតក្រងក៏មាន គន្ថៈមិនគប្បីដោតក្រងក៏មាន ។ រូបក្ខន្ធ ប្រាសចាកគន្ថៈ ខន្ធ ៤ ប្រកបដោយគន្ថៈក៏មាន ប្រាសចាកគន្ថៈក៏មាន ។ រូបក្ខន្ធ មិនគប្បីពោលថាជាគន្ថៈ ទាំងគន្ថៈគប្បីដោតក្រងឡើយ គន្ថៈគប្បីដោតក្រង តែមិនមែនគន្ថៈ ខន្ធ ៣ មិនគប្បីពោលថា ជាគន្ថៈ ទាំងគន្ថៈគប្បីដោតក្រងទេ គន្ថៈគប្បីដោតក្រង តែមិនមែនគន្ថៈក៏មាន មិនគប្បីពោលថា គន្ថៈគប្បីដោតក្រង តែមិនមែនគន្ថៈក៏មាន សង្ខារក្ខន្ធជាគន្ថៈ ទាំងគន្ថៈគប្បីដោតក្រងក៏មាន គន្ថៈគប្បីដោតក្រង តែមិនមែនគន្ថៈក៏មាន មិនគប្បីពោលថា ជាគន្ថៈ ទាំងគន្ថៈគប្បីដោតក្រងផង ថាគន្ថៈគប្បីដោតក្រង តែមិនមែនជាគន្ថៈផងក៏មាន ។ រូបក្ខន្ធ មិនគប្បីពោលថា ជាគន្ថៈ ទាំងប្រកបដោយគន្ថៈផង ថាប្រកបដោយគន្ថៈ តែមិនមែនគន្ថៈផងឡើយ ខន្ធ ៣ មិនគប្បីពោលថា ជាគន្ថៈ ទាំងប្រកបដោយគន្ថៈទេ ប្រកបដោយគន្ថៈ តែមិនមែនគន្ថៈក៏មាន មិនគប្បីពោលថា ប្រកបដោយគន្ថៈ តែមិនមែនគន្ថៈក៏មាន សង្ខារក្ខន្ធជាគន្ថៈ ទាំងប្រកបដោយគន្ថៈក៏មាន ប្រកបដោយគន្ថៈ តែមិនមែនគន្ថៈក៏មាន មិនគប្បីពោលថា ជាគន្ថៈ ទាំងប្រកបដោយគន្ថៈផង ថាប្រកបដោយគន្ថៈ តែមិនមែនគន្ថៈផងក៏មាន ។ រូបក្ខន្ធ ប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រង ខន្ធ ៤ ប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រងក៏មាន ប្រាសចាកគន្ថៈ ទាំងគន្ថៈមិនគប្បីដោតក្រងក៏មាន មិនគប្បីពោលថា ប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រងផង ថាប្រាសចាកគន្ថៈ ទាំងគន្ថៈមិនគប្បីដោតក្រងផងក៏មាន ។

[ ៩១ ] ខន្ធ ៤ មិនមែនឱឃៈ ។បេ។ មិនមែនយោគៈ ។បេ។ មិនមែននីវរណៈ សង្ខារក្ខន្ធ ជានីវរណៈក៏មាន មិនមែននីវរណៈក៏មាន ។ រូបក្ខន្ធ ជាប្រយោជន៍ដល់នីវរណៈ ខន្ធ ៤ ជាប្រយោជន៍ដល់នីវរណៈក៏មាន មិនមែនជាប្រយោជន៍ដល់នីវរណៈក៏មាន ។ រូបក្ខន្ធ ប្រាសចាកនីវរណៈ ខន្ធ ៤ ប្រកបដោយនីវរណៈក៏មាន ប្រាសចាកនីវរណៈក៏មាន ។ រូបក្ខន្ធ មិនគប្បីពោលថា ជានីវរណៈ ទាំងជាប្រយោជន៍ដល់នីវរណៈឡើយ ជាប្រយោជន៍ដល់នីវរណៈ តែមិនមែននីវរណៈ ខន្ធ ៣ មិនគប្បីពោលថាជានីវរណៈ ទាំងជាប្រយោជន៍ដល់នីវរណៈទេ ជាប្រយោជន៍ដល់នីវរណៈ តែមិនមែននីវរណៈក៏មាន មិនគប្បីពោលថា ជាប្រយោជន៍ដល់នីវរណៈ ទាំងមិនមែននីវរណៈក៏មាន សង្ខារក្ខន្ធជានីវរណៈ ទាំងជាប្រយោជន៍ដល់នីវរណៈក៏មាន ជាប្រយោជន៍ដល់នីវរណៈ តែមិនមែននីវរណៈក៏មាន មិនគប្បីពោលថាជានីវរណៈ ទាំងជាប្រយោជន៍ដល់នីវរណៈផង ថាជាប្រយោជន៍ដល់នីវរណៈ តែមិនមែននីវរណៈផងក៏មាន ។ រូបក្ខន្ធ មិនគប្បីពោលថា ជានីវរណៈ ទាំងប្រកបដោយនីវរណៈផង ថាប្រកបដោយនីវរណៈ តែមិនមែននីវរណៈផងឡើយ ខន្ធ ៣ មិនគប្បីពោលថា ជានីវរណៈ ទាំងប្រកបដោយនីវរណៈទេ ប្រកបដោយនីវរណៈ តែមិនមែននីវរណៈក៏មាន មិនគប្បីពោលថា ប្រកបដោយនីវរណៈ តែមិនមែននីវរណៈក៏មាន សង្ខារក្ខន្ធ ជានីវរណៈ ទាំងប្រកបដោយនីវរណៈក៏មាន ប្រកបដោយនីវរណៈ តែមិនមែននីវរណៈក៏មាន មិនគប្បីពោលថា ជានីវរណៈ ទាំងប្រកបដោយនីវរណៈផង ថាប្រកបដោយ

នីវរណៈ តែមិនមែននីវរណៈផងក៏មាន ។ រូបក្ខន្ធ ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈ ខន្ធ ៤ ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈក៏មាន ប្រាសចាកនីវរណៈ ទាំងមិនជាប្រយោជន៍ដល់នីវរណៈក៏មាន មិនគប្បីពោលថា ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈផង ថាប្រាសចាកនីវរណៈ ទាំងមិនជាប្រយោជន៍ដល់នីវរណៈផងក៏មាន ។

[ ៩២ ] ខន្ធ ៤ មិនមែនបរាមាស សង្ខារក្ខន្ធ ជាបរាមាសក៏មាន មិនមែនបរាមាសក៏មាន ។ រូបក្ខន្ធ បរាមាសស្ទាបអង្អែល ខន្ធ ៤ បរាមាសស្ទាបអង្អែលក៏មាន បរាមាស មិនស្ទាបអង្អែលក៏មាន ។ រូបក្ខន្ធ ប្រាសចាកបរាមាស ខន្ធ ៣ ប្រកបដោយបរាមាសក៏មាន ប្រាសចាកបរាមាសក៏មាន សង្ខារក្ខន្ធ ប្រកបដោយបរាមាសក៏មាន ប្រាសចាកបរាមាសក៏មាន មិនគប្បីពោលថា ប្រកបដោយបរាមាសផង ថាប្រាសចាកបរាមាសផងក៏មាន ។ រូបក្ខន្ធ មិនគប្បីពោលថា ជាបរាមាស ទាំងបរាមាសស្ទាបអង្អែលឡើយ បរាមាសស្ទាបអង្អែល តែមិនមែនបរាមាស ខន្ធ ៣ មិនគប្បីពោលថា ជាបរាមាស ទាំងបរាមាសស្ទាបអង្អែលទេ បរាមាសស្ទាបអង្អែល តែមិនមែនបរាមាសក៏មាន មិនគប្បីពោលថា បរាមាសស្ទាបអង្អែល តែមិនមែនបរាមាសក៏មាន សង្ខារក្ខន្ធ ជាបរាមាស ទាំងបរាមាសស្ទាបអង្អែលក៏មាន បរាមាសស្ទាបអង្អែល តែមិនមែនបរាមាសក៏មាន មិនគប្បីពោលថា ជាបរាមាស ទាំងបរាមាសស្ទាបអង្អែលផង ថាបរាមាសស្ទាបអង្អែល តែមិនមែនបរាមាសផងក៏មាន ។ រូបក្ខន្ធ

ប្រាសចាកបរាមាស តែបរាមាសស្អាបអង្អែល ខន្ធ ៤ ប្រាសចាកបរាមាស តែបរាមាសស្អាបអង្អែលក៏មាន ប្រាសចាកបរាមាស ទាំងបរាមាស មិនស្អាបអង្អែលក៏មាន មិនគប្បីពោលថា ប្រាសចាកបរាមាស តែបរាមាសស្អាបអង្អែលផង ថាប្រាសចាកបរាមាស ទាំងបរាមាសមិនស្អាបអង្អែលផងក៏មាន ។

[ ៩៣ ] រូបក្ខន្ធមិនមានអារម្មណ៍ ខន្ធ ៤ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ។ ខន្ធ ៤ មិនមែនចិត្ត វិញ្ញាណក្ខន្ធជាចិត្ត ។ ខន្ធ ៣ ជាចេតសិក ខន្ធ ២ មិនមែនចេតសិក ។ ខន្ធ ៣ ប្រកបដោយចិត្ត រូបក្ខន្ធ ប្រាសចាកចិត្ត វិញ្ញាណក្ខន្ធ មិនគប្បីពោលថា ប្រកបដោយចិត្តផង ថាប្រាសចាកចិត្តផងឡើយ ។ ខន្ធ ៣ ប្រឡំដោយចិត្ត រូបក្ខន្ធ ប្រាសចាកការប្រឡំដោយចិត្ត វិញ្ញាណក្ខន្ធ មិនគប្បីពោលថា ប្រឡំដោយចិត្តផង ថាប្រាសចាកការប្រឡំដោយចិត្តផងឡើយ ។ ខន្ធ ៣ តាំងឡើងអំពីចិត្ត វិញ្ញាណក្ខន្ធ មិនបានតាំងឡើងអំពីចិត្ត រូបក្ខន្ធ តាំងឡើងអំពីចិត្តក៏មាន មិនតាំងឡើងអំពីចិត្តក៏មាន ។ ខន្ធ ៣ កើតជាមួយនឹងចិត្ត វិញ្ញាណក្ខន្ធ មិនកើតជាមួយនឹងចិត្ត រូបក្ខន្ធ កើតជាមួយនឹងចិត្តក៏មាន មិនកើតជាមួយនឹងចិត្តក៏មាន ។ ខន្ធ ៣ ប្រព្រឹត្តទៅតាមចិត្ត វិញ្ញាណក្ខន្ធ មិនប្រព្រឹត្តទៅតាមចិត្ត រូបក្ខន្ធ ប្រព្រឹត្តទៅតាមចិត្ត ក៏មាន មិនប្រព្រឹត្តទៅតាមចិត្តក៏មាន ។ ខន្ធ ៣ ប្រឡំ ទាំងតាំងឡើងអំពីចិត្ត ខន្ធ ២ មិនប្រឡំ ទាំងមិនតាំងឡើងអំពីចិត្ត ។ ខន្ធ ៣ ប្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ខន្ធ ២ មិនប្រឡំ មិនតាំងឡើង មិនកើតជាមួយ

នឹងចិត្ត ។ ខន្ធ ៣ ប្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ខន្ធ ២ មិនប្រឡំ មិនតាំងឡើង មិនប្រព្រឹត្តទៅតាមចិត្ត ។ ខន្ធ ៣ ជាខាងក្រៅ វិញ្ញាណខន្ធជាខាងក្នុង រូបក្ខន្ធជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ។ ខន្ធ ៤ មិនមែនឧបាទា រូបក្ខន្ធ ជាឧបាទាក៏មាន មិនមែនឧបាទាក៏មាន ជាឧបាទិន្ន ក៏មាន ជាអនុបាទិន្នក៏មាន ។

[ ៩៤ ] ខន្ធ ៤ មិនមែនឧបាទាន សង្ខារក្ខន្ធ ជាឧបាទានក៏មាន មិនមែនឧបាទានក៏មាន ។ រូបក្ខន្ធ ជាប្រយោជន៍ដល់ឧបាទាន ខន្ធ ៤ ជាប្រយោជន៍ដល់ឧបាទានក៏មាន មិនជាប្រយោជន៍ ដល់ឧបាទានក៏មាន ។ រូបក្ខន្ធ ប្រាសចាកឧបាទាន ខន្ធ ៤ ប្រកបដោយឧបាទានក៏មាន ប្រាសចាកឧបាទានក៏មាន ។ រូបក្ខន្ធ មិនគប្បីពោលថា ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានឡើយ ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនឧបាទាន ខន្ធ ៣ មិនគប្បីពោលថា ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានទេ ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនឧបាទានក៏មាន មិនគប្បីពោលថា ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនឧបាទានក៏មាន សង្ខារក្ខន្ធ ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនឧបាទានក៏មាន មិនគប្បីពោលថា ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានផង ថាជាប្រយោជន៍ដល់ឧបាទាន តែមិនមែនឧបាទានផងក៏មាន ។ រូបក្ខន្ធ មិនគប្បីពោលថាជាឧបាទាន ទាំងប្រកបដោយឧបាទានផង ថាប្រកបដោយឧបាទាន តែមិនមែនឧបាទានឡើយ ខន្ធ ៣ មិនគប្បីពោលថា ជា

ឧបាទាន ទាំងប្រកបដោយឧបាទានទេ ប្រកបដោយឧបាទាន តែមិនមែនឧបាទានក៏មាន មិនគប្បីពោលថា ប្រកបដោយឧបាទាន តែមិនមែនឧបាទានក៏មាន សង្ខារក្ខន្ធជាឧបាទាន ទាំងប្រកបដោយឧបាទានក៏មាន ប្រកបដោយឧបាទាន តែមិនមែនឧបាទានក៏មាន មិនគប្បីពោលថា ជាឧបាទាន ទាំងប្រកបដោយឧបាទានផង ជាប្រកបដោយឧបាទាន តែមិនមែនឧបាទានផងក៏មាន ។ រូបក្ខន្ធ ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទាន ខន្ធ ៤ ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទានក៏មាន ប្រាសចាកឧបាទាន ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន មិនគប្បីពោលថា ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទានផង ជាប្រាសចាកឧបាទាន ទាំងមិនជាប្រយោជន៍ដល់ឧបាទានផងក៏មាន ។

[ ៩៥ ] ខន្ធ ៤ មិនមែនកិលេស សង្ខារក្ខន្ធ ជាកិលេសក៏មាន មិនមែនកិលេសក៏មាន ។ រូបក្ខន្ធ គួរដល់សេចក្តីសៅហ្មង ខន្ធ ៤ គួរដល់សេចក្តីសៅហ្មងក៏មាន មិនគួរដល់សេចក្តីសៅហ្មងក៏មាន ។ រូបក្ខន្ធ មិនសៅហ្មងហើយ ខន្ធ ៤ សៅហ្មងហើយក៏មាន មិនសៅហ្មងហើយក៏មាន ។ រូបក្ខន្ធ ប្រាសចាកកិលេស ខន្ធ ៤ ប្រកបដោយកិលេសក៏មាន ប្រាសចាកកិលេសក៏មាន ។ រូបក្ខន្ធ មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មងឡើយ គួរដល់សេចក្តីសៅហ្មង តែមិនមែនសេចក្តីសៅហ្មង ខន្ធ ៣ មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មងទេ គួរដល់សេចក្តីសៅហ្មង តែមិនមែនសេចក្តីសៅហ្មងក៏មាន មិនគប្បីពោលថា

គួរដល់សេចក្តីសៅហ្មង តែមិនមែនសេចក្តីសៅហ្មងក៏មាន សង្ខារក្ខន្ធ ជាសេចក្តីសៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មងក៏មាន គួរដល់សេចក្តីសៅហ្មង តែមិនមែនសេចក្តីសៅហ្មងក៏មាន មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មងផង ជាគួរដល់សេចក្តីសៅហ្មង តែមិនមែនសេចក្តីសៅហ្មងផងក៏មាន ។ រូបក្ខន្ធ មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងសៅហ្មងហើយផង ជាសៅហ្មងហើយ តែមិនមែនសេចក្តីសៅហ្មងផងឡើយ ខន្ធ ៣ មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងសៅហ្មងហើយទេ សៅហ្មងហើយ តែមិនមែនសេចក្តីសៅហ្មងក៏មាន មិនគប្បីពោលថា សៅហ្មងហើយ តែមិនមែនសេចក្តីសៅហ្មងក៏មាន សង្ខារក្ខន្ធ ជាសេចក្តីសៅហ្មង ទាំងសៅហ្មងហើយក៏មាន សៅហ្មងហើយ តែមិនមែនសេចក្តីសៅហ្មងក៏មាន មិនគប្បីពោលថាជាសេចក្តីសៅហ្មង ទាំងសៅហ្មងហើយផង ជាសៅហ្មងហើយ តែមិនមែនសេចក្តីសៅហ្មងផងក៏មាន ។ រូបក្ខន្ធ មិនគប្បីពោលថាជាសេចក្តីសៅហ្មង ទាំងប្រកបដោយសេចក្តីសៅហ្មងផង ជាប្រកបដោយសេចក្តីសៅហ្មង តែមិនមែនសេចក្តីសៅហ្មងផងឡើយ ខន្ធ ៣ មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងប្រកបដោយសេចក្តីសៅហ្មងទេ ប្រកបដោយសេចក្តីសៅហ្មង តែមិនមែនសេចក្តីសៅហ្មងក៏មាន មិនគប្បីពោលថា ប្រកបដោយសេចក្តីសៅហ្មង តែមិនមែនសេចក្តីសៅហ្មងក៏មាន សង្ខារក្ខន្ធ ជាសេចក្តីសៅហ្មង ទាំងប្រកបដោយសេចក្តីសៅហ្មងក៏មាន ប្រកបដោយសេចក្តីសៅហ្មង តែមិនមែនសេចក្តីសៅហ្មងក៏មាន មិនគប្បីពោលថា

ជាសេចក្ដីសៅហ្មង ទាំងប្រកបដោយសេចក្ដីសៅហ្មងផង ថាប្រកបដោយសេចក្ដីសៅហ្មង តែមិនមែនសេចក្ដីសៅហ្មងក៏មាន ។ រូបក្ខន្ធ ប្រាសចាកសេចក្ដីសៅហ្មង តែគួរដល់សេចក្ដីសៅហ្មង ខន្ធ ៤ ប្រាសចាកសេចក្ដីសៅហ្មង តែគួរដល់សេចក្ដីសៅហ្មងក៏មាន ប្រាសចាកសេចក្ដីសៅហ្មង ទាំងមិនគួរដល់សេចក្ដីសៅហ្មងក៏មាន មិនគប្បីពោលថា ប្រាសចាកសេចក្ដីសៅហ្មង តែគួរដល់សេចក្ដីសៅហ្មងផង ថាប្រាសចាកសេចក្ដីសៅហ្មង ទាំងមិនគួរដល់សេចក្ដីសៅហ្មងផងក៏មាន ។

[ ៩៦ ] រូបក្ខន្ធ មិនគួរលះដោយទស្សនៈ ខន្ធ ៤ គួរលះដោយទស្សនៈក៏មាន មិនគួរលះដោយទស្សនៈក៏មាន ។ រូបក្ខន្ធ មិនគួរលះដោយភាវនា ខន្ធ ៤ គួរលះដោយភាវនាក៏មាន មិនគួរលះដោយភាវនាក៏មាន ។ រូបក្ខន្ធ មានហេតុ មិនគួរលះដោយទស្សនៈ ខន្ធ ៤ មានហេតុ គួរលះដោយទស្សនៈក៏មាន មានហេតុមិនគួរលះដោយទស្សនៈក៏មាន ។ រូបក្ខន្ធ មានហេតុមិនគួរលះដោយភាវនា ខន្ធ ៤ មានហេតុគួរលះដោយភាវនាក៏មាន មានហេតុមិនគួរលះដោយភាវនាក៏មាន ។ រូបក្ខន្ធ មិនមានវិតក្កៈ ខន្ធ ៤ ប្រព្រឹត្តទៅជាមួយនឹងវិតក្កក៏មាន មិនមានវិតក្កក៏មាន ។ រូបក្ខន្ធ មិនមានវិចារ ខន្ធ ៤ ប្រព្រឹត្តទៅជាមួយនឹងវិចារក៏មាន មិនមានវិចារក៏មាន ។ រូបក្ខន្ធ មិនមានបីតិ ខន្ធ ៤ ប្រព្រឹត្តទៅជាមួយនឹងបីតិក៏មាន មិនមានបីតិក៏មាន ។ រូបក្ខន្ធ មិនកើតព្រមដោយបីតិ ខន្ធ ៤ កើតព្រមដោយបីតិក៏មាន មិនកើតព្រមដោយបីតិក៏មាន ។ ខន្ធ ២ មិនកើតព្រមដោយសុខ ខន្ធ ៣ កើតព្រមដោយសុខក៏មាន មិន

កើតព្រមដោយសុខក៏មាន ។ ខន្ធ ២ មិនកើតព្រមដោយឧបេក្ខា ខន្ធ ៣ កើតព្រមដោយឧបេក្ខាក៏មាន មិនកើតព្រមដោយឧបេក្ខាក៏មាន ។ រូបក្ខន្ធ ជាកាមាវចរ ខន្ធ ៤ ជាកាមាវចរក៏មាន មិនមែនកាមាវចរក៏មាន ។ រូបក្ខន្ធ មិនមែនរូបាវចរ ខន្ធ ៤ ជារូបាវចរក៏មាន មិនមែនរូបាវចរក៏មាន ។ រូបក្ខន្ធ មិនមែនអរូបាវចរ ខន្ធ ៤ ជាអរូបាវចរក៏មាន មិនមែនអរូបាវចរក៏មាន ។ រូបក្ខន្ធ ជាបរិយាបន្ន ខន្ធ ៤ ជាបរិយាបន្នក៏មាន ជាអបរិយាបន្នក៏មាន ។ រូបក្ខន្ធ ជាអនិយ្យានិកៈ ខន្ធ ៤ ជានិយ្យានិកៈក៏មាន ជាអនិយ្យានិកៈក៏មាន ។ រូបក្ខន្ធ ជាអនិយតៈ ខន្ធ ៤ ជានិយតៈក៏មាន ជាអនិយតៈក៏មាន ។ រូបក្ខន្ធ ជាសឧត្តរៈ ខន្ធ ៤ ជាសឧត្តរៈក៏មាន ជាអនុត្តរៈក៏មាន ។ រូបក្ខន្ធ មិនមានសត្រូវ ខន្ធ ៤ ប្រកបដោយសត្រូវក៏មាន មិនមានសត្រូវក៏មាន ។

បញ្ហាបុច្ឆកៈ ចប់

ខន្ធវិភង្គ ចប់

# អដ្ឋកថា

## បញ្ហាបុច្ឆកៈ

[ ៨៤-៩៦ ] ឥឡូវនេះ ជាបញ្ហាបុច្ឆកៈ ក្នុងបញ្ហាបុច្ឆកៈនោះ បណ្ឌិតគប្បីជ្រាបថា ក្នុងការសួរបញ្ហា កាលត្រាស់សួរបញ្ហា ធម៌ទាំងអស់ដែលបាន និងមិនបានដោយន័យជាដើមថា បណ្តាខន្ធ ៥ ខន្ធជាកុសលប៉ុន្មាន ខន្ធជាអកុសលប៉ុន្មាន ខន្ធជាអព្យាក្រឹតប៉ុន្មាន ដូច្នេះ ក្នុងការវិសជ្ជនា ទ្រង់ចែកធម៌ដែលបានប៉ុណ្ណោះ សម្តែងដោយន័យជាដើមថា **រូបក្ខន្ធោ អព្យាកតោ** ប្រែថា រូបក្ខន្ធជាអព្យាក្រឹត ដូច្នេះ ។ ក្នុងទីណាទ្រង់មិនកំណត់ថា ខន្ធ ១ ឬខន្ធ ២ ទ្រង់តាំងបែបផែនដោយន័យជាដើមថា **សិយា ឧប្បន្នា សិយា អនុប្បន្នា** ខន្ធ ៤ កើតឡើងហើយក៏មាន មិនទាន់កើតឡើងក៏មាន ដូច្នេះ ក្នុងទីនោះៗ គប្បីជ្រាបការកាន់យកខន្ធទាំង ៥ ។ ការចែកខន្ធទាំងនោះថា ជាកុសលជាដើមដ៏សេស ខ្ញុំបានពោលហើយក្នុងអដ្ឋកថា ធម្មសង្គហៈ គឺអដ្ឋសាលិនីខាងដើមនោះឯង ។

ក្នុងអារម្មណតិកៈទាំងឡាយ ខន្ធ ៤ ជាបរិត្តារម្មណៈ ដល់បុគ្គលអ្នកត្រេកត្រអាល អ្នកអាក់អន់ អ្នកវង្វេង អ្នកសង្រួម អ្នកពិចារណា អ្នកសម្លឹងឃើញ ប្រារព្ធកាមាវចរធម៌ ៥៥ ប្រការ ជាមហគ្គតារម្មណៈ ដល់បុគ្គលអ្នកត្រេកត្រអាល អ្នកអាក់អន់ អ្នកវង្វេង អ្នកសង្រួម អ្នកផ្តើមកំណត់ប្រារព្ធរូបាវចរ និងអរូបាវចរធម៌ ២៧ ប្រការ ជាអប្បមាណារម្មណៈ ដល់បុគ្គលដែលពិចារណាមគ្គ ផល និងព្រះនិព្វាន តែជានវត្តព្វារម្មណ៍ គឺ

អារម្មណបញ្ញត្តិមិនបាន ក្នុងពេលពិចារណាបញ្ញត្តិ ដូច្នេះ ។

ខន្ធ ៤ នោះឯង ជាមគ្គារម្មណ៍ក្នុងពេលដែលព្រះសេក្ខៈ និងព្រះអសេក្ខៈ ពិចារណាមគ្គ ។ ជាមគ្គហេតុកៈ គឺមានមគ្គជាហេតុដោយហេតុ ដែលកើតព្រមគ្នា ក្នុងកាលនៃមគ្គជាមគ្គាធិបតីដោយអារម្មណាធិបតី ក្នុងពេលពិចា-រណាធ្វើមគ្គឲ្យធ្ងន់ គឺឲ្យជាធំ ។ ម្យ៉ាងទៀត ខន្ធ ៤ ជាមគ្គាធិបតី ដោយអធិបតីដែលកើតព្រមគ្នា របស់បុគ្គលដែលចម្រើនមគ្គ ដែលមានវីរិយៈជាធំ ឬដែលមានវីមំសាជាធំ តែឈ្មោះថាជានវត្តព្វារម្មណ៍ដល់បុគ្គលដែលចម្រើនមគ្គ ដែលមានឆន្ទៈជាធំ ឬដែលមានចិត្តជាធំ ។

ខន្ធ ៤ ជាអតីតារម្មណ៍ដល់បុគ្គលដែលត្រេកត្រអាល ដែលអាក់អន់ ដែលវង្វេង ដែលសង្រួម ដែលផ្តើមកំណត់ប្រារព្ធខន្ធ ធាតុ អាយតនៈ ដែលកន្លងទៅហើយ ។ ជាអនាគតារម្មណ៍ដល់បុគ្គល ដែលត្រេកត្រអាលជាដើម ប្រារព្ធខន្ធជាដើមដែលមិនទាន់មកដល់ ។ ជាបច្ចុប្បន្នារម្មណ៍ដល់បុគ្គលដែលត្រេកត្រអាលជាដើមនោះឯង ប្រារព្ធខន្ធជាដើម ដែលកើតឡើងចំពោះមុខ ជានវត្តព្វារម្មណ៍ដល់បុគ្គលដែលពិចារណាបញ្ញត្តិ ឬព្រះនិព្វាន ។

ម្យ៉ាងទៀត ខន្ធ ៤ គប្បីជ្រាបថា ជាអជ្ឈត្តារម្មណ៍ ដល់បុគ្គលដែលត្រេកត្រអាល បុគ្គលអាក់អន់ បុគ្គលវង្វេង បុគ្គលសង្រួម បុគ្គលដែលផ្តើមកំណត់ប្រារព្ធខន្ធ ធាតុ អាយតនៈរបស់ខ្លួន ជាពហិទ្ធារម្មណ៍ដល់បុគ្គលដែលប្រារព្ធខន្ធ ធាតុ អាយតនៈរបស់បុគ្គលពួកដទៃ ប្រព្រឹត្តទៅយ៉ាងនោះ ជាពហិទ្ធារម្មណ៍នោះឯង ក្នុងកាលដែលពិចារណាបញ្ញត្តិ ឬព្រះនិព្វាន ជា

អជ្ឈត្តពហិទ្ធារម្មណ៍ ដល់បុគ្គលដែលប្រព្រឹត្តយ៉ាងនោះ ក្នុងអជ្ឈត្តធម៌តាមកាល ក្នុងពហិទ្ធធម៌តាមកាល ជានវត្តព្វារម្មណ៍ក្នុងកាលនៃអាកិញ្ចញ្ញាយតនៈ ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់ចែកខន្ធវិភង្គនេះ នាំចេញជា ៣ បរិវដ្ដៈ ដោយអំណាចសុត្តន្តភាជនីយជាដើម ដោយប្រការដូច្នេះ ។ ក្នុងបរិវដ្ដៈទាំង ៣ មានបរិច្ឆេទ ១ ប៉ុណ្ណោះ ព្រោះរូបក្ខន្ធជាកាមាវចរតែម្យ៉ាងក្នុងទីទាំងពួង ខន្ធ ៤ ត្រាស់ថា ប្រព្រឹត្តទៅក្នុងភូមិ ៤ លាយឡំគ្នាជាលោកិយផង ជាលោកុត្តរផង ដូច្នេះ ។

**អដ្ឋកថាខន្ធវិភង្គ ចប់**

# អភិធម្មបិដក

## អាយតនវិភង្គ

[ ៩៧ ] អាយតនៈ ១២ គឺ ចក្ខាយតនៈ រូបាយតនៈ សោតាយតនៈ សទ្ទាយតនៈ ឃានាយតនៈ គន្ធាយតនៈ ជិវ្ហាយតនៈ រសាយតនៈ កាយាយតនៈ ផោដ្ឋព្វាយតនៈ មនាយតនៈ ធម្មាយតនៈ ។

[ ៩៨ ] ភ្នែកមិនទៀង ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល រូបមិនទៀង ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល ត្រចៀកមិនទៀង ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល សំឡេង មិនទៀង ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល ច្រមុះ មិនទៀង ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល ក្លិន មិនទៀង ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល អណ្តាត មិនទៀង ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល រស មិនទៀង ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល កាយ មិនទៀង ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល សម្ផស្ស មិនទៀង ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល មនោ មិនទៀង ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល ធម៌ មិនទៀង ជាទុក្ខ ជារបស់សោះសូន្យ មានសភាពប្រែប្រួល ។

សុត្តន្តភាជនីយ ចប់

# អដ្ឋកថា

## អាយតនវិភង្គ

## សុត្តន្តភាជនីយ

[ ៩៧ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងសុត្តន្តភាជនីយមុន ក្នុងអាយតននិទ្ទេស ដែលជាលំដាប់បន្ទាប់អំពីខន្ធវិភង្គនិទ្ទេសនោះ ទើបត្រាស់ព្រះបាលីថា **ទ្វាទសាយតនានិ ចក្ខាយតនំ រូបាយតនំ** អាយតនៈ ១២ គឺចក្ខាយតនៈ រូបាយតនៈ ដូច្នេះជាដើម ។ ក្នុងអាយតនៈទាំងនោះ គប្បីជ្រាបដោយន័យបាលីមុត្តកៈជាមុនសិន

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដោយអត្ថ ១ ដោយលក្ខណៈ ១
ដោយការមានត្រឹមប៉ុណ្ណោះ ១ ដោយលំដាប់ ១ ដោយ
សង្ខេប ១ ដោយពិស្តារ ១ ដោយភាពជាធម៌ដែលបណ្ឌិត
គប្បីឃើញ ១ ដូច្នេះ ។

ក្នុងពាក្យវិនិច្ឆ័យទាំងនោះ គប្បីជ្រាបអត្ថដោយប្លែកគ្នាជាមុន ។

**ចក្ខតីតិ ចក្ខុ** ឈ្មោះថា ចក្ខុ ព្រោះអត្ថថា រមែងឃើញ អធិប្បាយថា រមែងពេញចិត្ត គឺធ្វើរូបឲ្យជាក់ច្បាស់ ។

**រូបយតីតិ រូបំ** ឈ្មោះថា រូប ព្រោះអត្ថថា ឲ្យប្រាកដ អធិប្បាយថា រូបកាលដល់វិការនៃវណ្ណៈ រមែងប្រកាសភាវៈដល់ហទយៈ ។

**សុណាតីតិ សោតំ** ឈ្មោះថា **សោត** ព្រោះអត្ថថា បានឮ ។

**សប្បតីតិ សទ្ទោ** ឈ្មោះថា **សទ្ទ** ព្រោះអត្ថថា ចេញទៅ គឺបន្លឺចេញ

ទៅ ។

**យាយតីតិ យានំ** ឈ្មោះថា **យាន** ព្រោះអត្ថថា ហិត ។

**គន្ធយតីតិ គន្ធោ** ឈ្មោះថា **គន្ធ** ព្រោះអត្ថថា ស្រង់ក្លិន គឺរមែងសម្តែងលំនៅរបស់ខ្លួនឲ្យប្រាកដ ។

**ជីវិតំ អវ្ហាយតីតិ ជិវ្ហា** ឈ្មោះថា **ជិវ្ហា** ព្រោះអត្ថថា ហៅរកនូវជីវិត ។

**រសន្តិ តំ សត្តាតិ រសោ** ឈ្មោះថា **រស** ព្រោះអត្ថថា ជាទីត្រេកអរ គឺជាទីពេញចិត្តរបស់សត្វទាំងឡាយ ។

**កុច្ឆិតានំ សាសវធម្មានំ អាយោតិ កាយោ** ឈ្មោះថា **កាយ** ព្រោះអត្ថថា ជាប្រភពកើតនៃធម៌ មានអាសវៈជាដើម ដែលបណ្ឌិតខ្ពើម ។ បទថា **អាយោ** គឺទីកើត ។

**ផុសីយតីតិ ផោដ្ឋព្វំ** ឈ្មោះថា **ផោដ្ឋព្វ** ព្រោះអត្ថថា ដែលកាយរមែងពាល់ត្រូវ ។

**មនតីតិ មនោ** ឈ្មោះថា **មន** ព្រោះអត្ថថា រមែងដឹង ។

**អត្តនោ លក្ខណំ ធារយន្តីតិ ធម្មា** ឈ្មោះថា **ធម្ម** ព្រោះអត្ថថា រមែងទ្រទ្រង់នូវលក្ខណៈរបស់ខ្លួន តែបើពោលដោយអត្ថមិនប្លែកគ្នា គប្បីជ្រាបថា ដែលឈ្មោះថា អាយតនៈ ព្រោះជាគ្រឿង-ត ១ ព្រោះការផ្សាយធម៌ ដែលជាប្រភពកើតនៃអាសវៈទាំងឡាយ ១ ព្រោះនាំទៅកាន់សង្សារដ៏វែងឆ្ងាយតទៅ ១ ។

ពិតហើយ អាយតនៈទាំងឡាយ មានចក្ខុ និងរូបជាដើម ជាទីដែលធម៌

គឺចិត្ត និងចេតសិកដែលមានចក្ខុជាដើមជាទ្វារ និងមានរូបជាដើមជាអារម្មណ៍ នោះៗ ចម្រើនឡើង តាំងឡើង បន្ត ពង្រីកទៅដោយកិច្ច មានការសោយអារម្មណ៍ជាដើមរៀងៗ ខ្លួន នេះជាពាក្យអធិប្បាយក្នុងប្រការទី ១ ។

អាយតនៈទាំងនេះ រមែងផ្សាយទៅ គឺរមែងញ៉ាំងធម៌ដែលជាប្រភពកើតទាំងនោះឲ្យទូលំទូលាយទៅ នេះជាពាក្យអធិប្បាយប្រការទី ២ ។

អាយតនៈទាំងនេះរមែងនាំទៅ គឺរមែងឲ្យប្រព្រឹត្តទៅដោយចំណែកមួយអស់កាលដែលសង្សារទុក្ខដ៏វែងឆ្ងាយ មកអំពីអតីតប្រព្រឹត្តទៅ កន្លងទៅក្នុងសង្សារដែលមានទីបំផុតខាងដើម និងខាងចុងមិនមាន ឲ្យវិលទៅ ត្រឡប់មិនបាន នេះជាពាក្យអធិប្បាយប្រការទី ៣ ។ ព្រោះជាគ្រឿង-ត ព្រោះជាការផ្សាយធម៌ដែលជាប្រភពកើតនៃអាសវៈទាំងឡាយ និងព្រោះនាំទៅកាន់សង្សារដ៏វែងឆ្ងាយតទៅ ។

ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា អាយតនៈ ព្រោះអត្ថថា ជាលំនៅ ព្រោះអត្ថថា ជាប្រភពកើត ព្រោះអត្ថថា ជាទីប្រជុំ ព្រោះអត្ថថា ជាដែនកើត ព្រោះអត្ថថា ជាការណៈ ។

ពិតហើយ លោកវោហារ គេហៅទីនៅអាស្រ័យថា អាយតនៈ ដូចក្នុងប្រយោគជាដើមថា **ឥស្សរាយតនំ** ប្រែថា លំនៅរបស់ព្រះឥស្សរ **វាសុទេវាយតនំ** ប្រែថា លំនៅរបស់ព្រះវាសុទេព ។ **អាករ** គឺប្រភពកើត ហៅថា អាយតនៈ ដូចក្នុងប្រយោគជាដើមថា **សុវណ្ណាយតនំ** ប្រែថា ប្រភពកើតនៃមាស **រជតាយតនំ** ប្រែថា ប្រភពកើតនៃប្រាក់ ។ ក្នុង

សាសនវោហារ លោកហៅទីប្រជុំថា អាយតនៈ ដូចក្នុងប្រយោគជាដើមថា **មនោរមេ អាយតនេ សេវន្តិ នំ វិហង្គមា** ប្រែថា ពួកសត្វតែងអាស្រ័យនឹងដើមឈើនោះ ដែលនៅក្នុងព្រៃរំលោង ជាទីរីករាយចិត្ត ដូច្នេះ ។ ទីកើត ហៅថា អាយតនៈ ដូចក្នុងប្រយោគជាដើមថា **ទក្ខិណាបថោ គុន្នំ អាយតនំ** ទក្ខិណាបថ គឺជនបទទិសខាងត្បូង ជាដែនកើតនៃគោទាំងឡាយ ដូច្នេះ ។ **ការណា** ( ហេតុ ) ហៅថា អាយតនៈ ដូចក្នុងប្រយោគជាដើមថា **តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ** កាលបើមានហេតុមានទំនង បុគ្គលនោះក៏ដល់នូវសេចក្តីជាក់ច្បាស់ ក្នុងធម៌នោះៗ ដូច្នេះ ។

ម្យ៉ាងទៀត ធម៌ គឺចិត្ត និងចេតសិកទាំងនោះ រមែងអាស្រ័យនៅក្នុងអាយតនៈទាំងឡាយ មានចក្ខុជាដើម ព្រោះប្រព្រឹត្តទៅទាក់ទងដោយចក្ខុជាដើមនោះ ព្រោះហេតុនោះ ទើបអាយតនៈ មានចក្ខុជាដើម ឈ្មោះថា ជាលំនៅនៃចិត្ត និងចេតសិកទាំងនោះ ។ ម្យ៉ាងទៀត ចិត្ត និងចេតសិកទាំងនោះ ដេរដាសក្នុងអាយតនៈ មានចក្ខុជាដើម ព្រោះអាស្រ័យចក្ខុជាដើមនោះ និងព្រោះភាពដែលមានរូបជាដើមនោះ ជាអារម្មណ៍ ព្រោះហេតុនោះ ទើបចក្ខាយតនៈជាដើម ឈ្មោះថា ជាប្រភពកើតនៃចិត្ត និងចេតសិកទាំងនោះ ។ ម្យ៉ាងទៀត ចក្ខុជាដើមឈ្មោះថា ជាទីប្រជុំនៃចិត្ត និងចេតសិកទាំងនោះ ព្រោះជាទីប្រជុំដោយអំណាចជាវត្ថុ ទ្វារ និងអារម្មណ៍ក្នុងអាយតនៈនោះៗ ។ ម្យ៉ាងទៀត អាយតនៈ មានចក្ខុជាដើម ជាដែនកើតនៃចិត្ត និងចេតសិកទាំងនោះ

ព្រោះការកើតឡើងក្នុងអាយតនៈនោះឯង ដោយភាពជាទីអាស្រ័យ និងជាអារម្មណ៍របស់ចិត្ត និងចេតសិកទាំងនោះ ។ មា្យ៉ាងទៀត ចក្ខ្វាយតនៈជាដើមជាការណៈ គឺជាហេតុនៃចិត្ត និងចេតសិកទាំងនោះ ព្រោះកាលចក្ខ្វាយតនៈជាដើមនោះ មិនមាន ចិត្ត និងចេតសិកក៏មិនមាន ។

ធម៌ទាំងនេះ ហៅថា អាយតនៈ ដោយហេតុទាំងនេះ គឺព្រោះអត្ថថាជាលំនៅ ព្រោះអត្ថថា ជាប្រភព ព្រោះអត្ថថា ជាទីប្រជុំ ព្រោះអត្ថថា ជាដែនកើត ព្រោះអត្ថថា ជាហេតុ ដោយប្រការដូច្នេះ ព្រោះហេតុនោះ ពោលដោយអត្ថតាមដែលពោលមក ចក្ខុនោះផង ជាអាយតនៈផង ព្រោះហេតុនោះ ទើបឈ្មោះថា ចក្ខ្វាយតនៈ ។បេ។ ធម៌ទាំងនោះផង ជាអាយតនៈផង ព្រោះហេតុនោះ ទើបឈ្មោះថា **ធម្មាយតន** ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងអាយតនៈទាំងនេះដោយអត្ថយ៉ាងនេះ ដោយប្រការយ៉ាងនេះ ។

ពាក្យថា ដោយលក្ខណៈនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងអាយតនៈទាំងនេះដោយលក្ខណៈនៃអាយតនៈ មានចក្ខ្វាយតនៈជាដើម តែលក្ខណៈនោះរបស់អាយតនៈ មានចក្ខ្វាយតនៈជាដើមនោះ គប្បីជ្រាបដោយន័យដែលបានពោលហើយ ក្នុងនិទ្ទេសនៃរូបកណ្ឌខាងដើមនោះឯង ។

ពាក្យថា ដោយការមានត្រឹមប៉ុណ្ណោះ បានដល់ ដោយការមានចំនួនត្រឹមប៉ុណ្ណោះ ពាក្យនេះមានអធិប្បាយថា បើមានអ្នកសង្ស័យថា អាយតនៈមានចក្ខុជាដើម ក៏ជាធម៌នោះឯង កាលបើយ៉ាងនេះ ទ្រង់មិនបានត្រាស់ថា ធម្មាយតនៈប៉ុណ្ណោះ តែត្រាស់អាយតនៈ ១២ ដូច្នេះ ព្រោះហេតុអ្វី ។

ដែលត្រាស់ទុក ១២ យ៉ាង ព្រោះទ្រង់កំណត់ទ្វារ និងអារម្មណ៍ ដែលជាទីកើតឡើងនៃវិញ្ញាណកាយ ៦ ។

ពិតហើយ ក្នុងអាយតនវិភង្គនេះ មានប្រភេទអាយតនៈទាំងនោះដោយកំណត់ភាពជាទ្វារ និងភាពជាអារម្មណ៍របស់វិញ្ញាណកាយ ៦ មានត្រឹមនេះប៉ុណ្ណោះ ព្រោះហេតុនោះ ទើបត្រាស់អាយតនៈ ១២ ព្រោះថា ចក្ខាយតនៈនោះឯង ជាទ្វារកើតឡើងនៃវិញ្ញាណកាយ ដែលទាក់ទងក្នុងវីថិរបស់ចក្ខុវិញ្ញាណ និងរូបាយតនៈនោះឯងជាអារម្មណ៍ ម្យ៉ាងទៀត អាយតនៈក្រៅអំពីនេះ ជាទ្វារកើតឡើងដល់វិញ្ញាណកាយក្រៅអំពីនេះ តែចំណែកមួយនៃមនាយតនៈ ពោល គឺភវង្គចិត្តនោះឯងជាទ្វារកើតឡើងនៃវិញ្ញាណកាយទី ៦ និងធម្មាយតនៈដែលមិនទូទៅ ជាអារម្មណ៍ ព្រោះហេតុនោះ ទើបត្រាស់អាយតនៈ ១២ ព្រោះកំណត់ទ្វារ និងអារម្មណ៍ជាហេតុកើតឡើងនៃវិញ្ញាណកាយ ៦ ដោយប្រការដូច្នេះ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងអាយតនៈនោះ ដោយការមានត្រឹមប៉ុណ្ណោះ យ៉ាងនេះ ។

ពាក្យថា ដោយលំដាប់ សេចក្តីថា ក្នុងលំដាប់ទាំងឡាយ មានលំដាប់នៃការកើតឡើងជាដើម តាមដែលបានពោលហើយក្នុងកាលមុន លំដាប់នៃទេសនាប៉ុណ្ណោះ រមែងគួរក្នុងអាយតនវិភង្គនេះ ព្រោះថា បណ្តាអាយតនៈទាំងឡាយដែលជាខាងក្នុង ចក្ខាយតនៈ ជាធម្មជាតប្រាកដច្បាស់ ព្រោះមានរូបដែលឃើញបាន និងប៉ះខ្ទប់បាន ជាអារម្មណ៍ ព្រោះហេតុនោះ ទើបទ្រង់សម្តែងចក្ខាយតនៈមុន បន្ទាប់អំពីនោះ ទ្រង់សម្តែងសោតាយតនៈជាដើម

មានរូបដែលឃើញមិនបាន និងប៉ះខ្ទប់បានជាអារម្មណ៍ ។

ម្យ៉ាងទៀត បណ្តាអាយតនៈទាំងឡាយ ដែលជាខាងក្នុង ទ្រង់សម្តែងចក្ខាយតនៈ និងសោតាយតនៈមុន ព្រោះថា អាយតនៈទាំង ២ នោះ ជាធម៌មានឧបការៈច្រើន ដោយជាហេតុឲ្យកើតទស្សនានុត្តរិយៈ គឺការឃើញដ៏ប្រសើរ និងសវនានុត្តរិយៈ គឺការស្តាប់ដ៏ប្រសើរ បន្ទាប់អំពីនោះ ទ្រង់សម្តែងអាយតនៈ ៣ មានឃានាយតនៈជាដើម ក្នុងទីបំផុត ទ្រង់សម្តែងមនាយតនៈ ព្រោះភាពដែលធម៌ទាំង ៥ ក៏ជាអារម្មណ៍ដែលប្រព្រឹត្តទៅរបស់មនាយតនៈនោះ ។

ម្យ៉ាងទៀត ក្នុងអាយតនៈទាំងឡាយ ដែលជាខាងក្រៅ ទ្រង់សម្តែងអាយតនៈ មានរូបជាដើម ក្នុងលំដាប់នៃអាយតនៈខាងក្នុងនោះៗ ព្រោះភាពជាអារម្មណ៍របស់ចក្ខាយតនៈជាដើម ។ ម្យ៉ាងទៀត គប្បីជ្រាបលំដាប់របស់អាយតនៈទាំងនោះ យ៉ាងនេះឯង សូម្បីដោយកំណត់ហេតុកើតឡើងរបស់វិញ្ញាណ ។ សេចក្តីនេះសមដូចព្រះបាលី ( ក្នុងមជ្ឈិមនិកាយ ឧបរិ-បណ្ណាសក ) ថា ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យភ្នែក និងរូប ១ ។បេ។ មនោវិញ្ញាណកើតឡើងព្រោះអាស្រ័យចិត្ត និងធម្មារម្មណ៍ ១ ដូច្នេះ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងអាយតនៈទាំងនេះ ដោយលំដាប់យ៉ាងនេះ ។

ពាក្យថា ដោយសង្ខេប និងដោយពិស្តារ សេចក្តីថា បើពោលដោយសង្ខេប ព្រោះមនាយតនៈ និងធម្មាយតនៈចំណែកមួយ ព្រះអង្គទ្រង់សង្គ្រោះចូលជានាម អាយតនៈដ៏សេសបន្ទាប់អំពីនោះ ទ្រង់សង្គ្រោះចូលជារូប ទើប

អាយតនៈទាំង ១២ ត្រឹមតែជានាម និងរូបប៉ុណ្ណោះ តែបើពោលដោយពិស្ដារ បណ្ដាអាយតនៈទាំងឡាយដែលជាខាងក្នុង ចក្ខាយតនៈពោលដោយអំណាចនៃជាតិ ត្រឹមតែជាចក្ខុបសាទប៉ុណ្ណោះ តែបើពោលដោយប្រភេទនៃបច្ច័យ គតិ និកាយ និងបុគ្គល មានប្រភេទរាប់មិនអស់ ។ អាយតនៈ ៤ មានសោតាយតនៈជាដើម ក៏ជាប្រភេទរាប់មិនអស់ដូចគ្នា ។ មនាយតនៈ មាន ៨១ ប្រភេទ មានកុសលវិញ្ញាណ អកុសលវិញ្ញាណ វិបាកវិញ្ញាណ កិរិយាវិញ្ញាណដែលប្រព្រឹត្តទៅក្នុងភូមិ ៣ តែបើពោលដោយប្រភេទនៃវត្ថុ និងបដិបទាជាដើម ក៏ជាប្រភេទរាប់មិនអស់ ។ ពោលដោយប្រភេទនៃសមុដ្ឋាន រូបាយតនៈ គន្ធាយតនៈ រសាយតនៈ មាន ៤ ប្រភេទ សទ្ទាយតនៈ មាន ២ ប្រភេទ តែបើពោលដោយប្រភេទសភាគ និងវិសភាគហើយ អាយតនៈទាំងអស់ ជាប្រភេទរាប់មិនអស់ ផោដ្ឋព្វាយតនៈ មាន ៣ ប្រភេទ ដោយអំណាចនៃបឋវីធាតុ តេជោធាតុ និងវាយោធាតុ តែបើពោលដោយសមុដ្ឋាន មាន ៤ ប្រភេទ បើពោលដោយសភាគនិងវិសភាគ មានប្រភេទរាប់មិនអស់ ។ ធម្មាយតនៈ មានច្រើនប្រភេទ ដោយអំណាចនៃធម្មារម្មណ៍ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ គប្បីជ្រាបវិនិច្ឆ័យអាយតនៈដោយសង្ខេប និងដោយពិស្ដារយ៉ាងនេះ ដោយប្រការដូច្នេះ ។

ក្នុងពាក្យថា ដោយភាពជាធម៌ដែលបណ្ឌិតគប្បីឃើញនេះ បណ្ឌិតគប្បីឃើញអាយតនៈទាំងអស់នោះឯង ដោយការមិនមកដល់ និងដោយការមិនចេញទៅ ។ ពិតហើយ អាយតនៈទាំងនោះ មុនកើតឡើងមិនមកអំពីទីណា

ក្រោយអំពីការបែកធ្លាយហើយ ក៏មិនទៅកាន់ទីណា ដោយពិត មុនកើតឡើង អាយតនៈទាំងនេះ មិនទាន់បានភាវៈនៃខ្លួនដោយចំពោះ ក្រោយអំពីបែកធ្លាយទៅ ក៏មានភាវៈនៃខ្លួនបែកធ្លាយអស់ហើយ ជាសភាវៈ មិនមានអំណាចប្រព្រឹត្តទៅ ព្រោះប្រព្រឹត្តទៅទាក់ទងដោយបច្ច័យ ក្នុងកណ្តាលនៃខាងដើម និងខាងចុង ព្រោះហេតុនោះ គប្បីឃើញអាយតនៈទាំងឡាយដោយការមិនទាន់មកដល់ និងដោយការមិនចេញទៅ ។

ម្យ៉ាងទៀត គប្បីឃើញអាយតនៈទាំងនេះ ដោយការមិនឃ្លាតទៅ និងមិនមានសេចក្តីព្យាយាម ពិតហើយ អាយតនៈទាំងឡាយ មានចក្ខុ និងរូបជាដើម មិនបានគិតយ៉ាងនេះថា ឱហ្ន៎ ឈ្មោះថា វិញ្ញាណ គប្បីកើតឡើងព្រោះពួកយើងប៉ះគ្នា ដូច្នេះក៏មិនមែន ហើយអាយតនៈទាំងនោះ ក៏មិនខ្វល់ខ្វាយដើម្បីការកើតឡើងនៃវិញ្ញាណ ដោយភាពជាទ្វារ ដោយភាពជាវត្ថុ ឬដោយភាពជាអារម្មណ៍ក៏មិនមែន គឺមិនដល់សេចក្តីព្យាយាមដោយពិត នេះជាធម្មតាប៉ុណ្ណោះដែលចក្ខុវិញ្ញាណជាដើម កើតឡើងព្រោះអាយតនៈ មានចក្ខុ និងរូបជាដើមប៉ះគ្នា ព្រោះហេតុនោះ បណ្ឌិតគប្បីឃើញអាយតនៈទាំងឡាយ ដោយការមិនឃ្លាតទៅ និងដោយការមិនមានសេចក្តីព្យាយាម ។

ម្យ៉ាងទៀត បណ្ឌិតគប្បីឃើញលក្ខណៈខាងក្នុងដូចផ្ទះស្ងាត់ ព្រោះវៀរចាកភាពស្ថិតស្ថេរ ការស្អាត សេចក្តីសុខ និងអត្តា គប្បីឃើញអាយតនៈខាងក្រៅដូចពួកចោរប្លន់អ្នកស្រុក ព្រោះប៉ះខ្ទប់អាយតនៈខាងក្នុង ។ សមដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ ) ដែលត្រាស់ថា

ចក្ខុរមែងបៀតបៀនចំពោះរូបទាំងឡាយ ជាទីគាប់ចិត្ត និងមិនជាទីគាប់ចិត្ត ដូច្នេះ បណ្ឌិតគប្បីឲ្យពិស្តារ ។ ម្យ៉ាងទៀត គប្បីឃើញអាយតនៈខាងក្នុង ដូចសត្វ ៦ ប្រភេទ គប្បីឃើញអាយតនៈខាងក្រៅ ដូចទីគោចររបស់សត្វទាំងនោះ ព្រោះហេតុនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងអាយតនៈទាំងនេះ ដោយជាធម៌ដែលបណ្ឌិតគប្បីឃើញ ដោយប្រការដូច្នេះ ។

[ ៩៨ ] ឥឡូវនេះ ព្រះមានព្រះភាគ មានបំណងនឹងសម្ដែងអាការនៃអាយតនៈទាំងនោះ ដែលបណ្ឌិតគប្បីឃើញតាមសេចក្ដីពិត ទើបផ្ដើមពាក្យជាដើមថា **ចក្ខុំ អនិច្ចំ** ដូច្នេះ ។

បណ្ដាអាយតនៈទាំងនោះ បណ្ឌិតគប្បីជ្រាបថា ចក្ខុ ឈ្មោះថា មិនទៀង ដោយអត្ថថា មានហើយ ត្រឡប់ជាមិនមាន ដូច្នេះ ។ ឈ្មោះថា ការមិនទៀង ព្រោះហេតុ ៤ យ៉ាងដទៃទៀត គឺព្រោះមានការកើតឡើង និងមានការវិនាសទៅជាទីបំផុត ១ ព្រោះការប្រែប្រួលទៅ ១ ព្រោះភាពជារបស់មួយជួរខណៈ ១ ព្រោះបដិសេធភាពទៀង ១ ។

ចក្ខុនោះឯង ឈ្មោះថា ជាទុក្ខ ដោយអត្ថថា បៀតបៀន ម្យ៉ាងទៀត ចក្ខុនេះ កើតឡើងហើយ រមែងដល់នូវការតាំងនៅ កាលតាំងនៅ រមែងលំបាកដោយជរា ដល់នូវភាពជរាហើយ រមែងបែកធ្លាយទៅពិត ព្រោះហេតុនោះ ទើបឈ្មោះថា ជាទុក្ខ ព្រោះហេតុ ៤ នេះ គឺព្រោះភាពជារបស់បៀតបៀនរឿយៗ ១ ព្រោះភាពជារបស់អត់ធន់បានដោយក្រ ១ ព្រោះជាទីតាំងនៃទុក្ខ ១ ព្រោះបដិសេធសេចក្ដីសុខ ១ ។

ម្យ៉ាងទៀត ចក្ខុនោះ ឈ្មោះថា ជាអនត្តា ដោយអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាច ។ ម្យ៉ាងទៀត ភាពដែលចក្ខុនោះប្រព្រឹត្តទៅក្នុងអំណាចរបស់បុគ្គលណាម្នាក់ ក្នុងឋានៈ ៣ នេះ គឺចក្ខុនេះកើតឡើងហើយ ចូរកុំដល់ការតាំងនៅ ដល់ការតាំងនៅហើយ ចូរកុំចាស់ ដល់នូវការចាស់ហើយ ចូរកុំបែកធ្លាយ ដូច្នេះ មិនបាន ជារបស់សូន្យទៅចាកអាការដែលប្រព្រឹត្តទៅក្នុងអំណាចនោះ ព្រោះហេតុនោះ ទើបចក្ខុនោះ ឈ្មោះថា ជាអនត្តា ព្រោះហេតុ ៤ ព្រោះជារបស់សូន្យ ១ ព្រោះភាពមិនមានម្ចាស់ ១ ព្រោះជាវត្ថុដែលគួរធ្វើតាមគាប់ចិត្តមិនបាន ១ ព្រោះបដិសេធចំពោះអត្តា ១ ។

ដែលឈ្មោះថា មានសភាពប្រែប្រួល ព្រោះដល់នូវការវិនាស ព្រោះដល់នូវការប្រែប្រួលទៅកាន់កត ដោយអំណាចទៅ និងមក ព្រោះលះភាពជាប្រក្រតី ។ ពាក្យថា មានការប្រែប្រួល នេះជាវេវចនៈរបស់ពាក្យថា មិនទៀងនោះឯង ។ ក្នុងពាក្យទាំងឡាយ មានពាក្យថា **រូបា អនិច្ចា** ជាដើម ក៏ន័យនេះឯង ។

ម្យ៉ាងទៀត ក្នុងអាយតនៈទាំងនេះ វៀរចក្ខុចេញហើយ ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ មិនទៀង មិនមែនជាចក្ខុ តែចក្ខុជាចក្ខុផង ជាសភាវៈមិនទៀងផង ធម៌ដ៏សេសក៏ដូចគ្នា ជាទុក្ខ មិនមែនចក្ខុ តែចក្ខុជាចក្ខុផង ជាទុក្ខផង ។ ធម៌ដ៏សេសជាអនត្តា មិនមែនចក្ខុ តែចក្ខុជាចក្ខុផង ជាអនត្តាផង ដូច្នេះ ។ សូម្បីក្នុងរូបជាដើម ក៏មានន័យដូចគ្នានេះ ។

សួរថា ក្នុងសុត្តន្តភាជនីយនេះ ព្រះសាស្តា ទ្រង់សម្តែងអ្វី ឆ្លើយថា

ទ្រង់សម្តែងអនត្តលក្ខណៈនៃអាយតនៈ ១២ យ៉ាង ។ ពិតហើយ ព្រះសម្មាសម្ពុទ្ធ កាលទ្រង់សម្តែងអនត្តលក្ខណៈ រមែងសម្តែងដោយភាពមិនទៀងខ្លះ ដោយភាពជាទុក្ខខ្លះ ដោយភាពមិនទៀង និងជាទុក្ខខ្លះ ។ ក្នុងលក្ខណៈទាំង ៣ នោះ ទ្រង់សម្តែងអនត្តលក្ខណៈដោយការមិនទៀង ក្នុង (មជ្ឈិមនិកាយ ឧបរិបណ្ណាសក) ថា បុគ្គលណានិយាយយ៉ាងនេះថា ភ្នែកជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ (ព្រោះថា) ភ្នែកគេតែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណាដឹងច្បាស់នូវការកើតឡើង និងការវិនាសទៅវិញថា ខ្លួនរបស់អញកើតឡើងផង វិនាសទៅវិញផង ទើបបុគ្គលនោះឯងឈ្មោះថា យល់ឃើញត្រូវហេតុនោះ បានជាថា បុគ្គលណានិយាយថាភ្នែកជាខ្លួន ពាក្យរបស់បុគ្គលនោះមិនកើតការទេ ។ ព្រោះហេតុនោះ ភ្នែកមិនមែនជាខ្លួនឡើយ ដូច្នេះ ។

ព្រះសាស្តា ទ្រង់សម្តែងអនត្តលក្ខណៈដោយភាពជាទុក្ខ ក្នុង (វិនយបិដក មហាវគ្គ) ថា គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅបញ្ចវគ្គិយភិក្ខុទាំងឡាយមក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រូប គឺរាងកាយជាអនត្តា មិនមែនជារបស់ខ្លួនឡើយ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ រូបនេះ ជារបស់ខ្លួនពិតមែន រូបនេះ ក៏មិនគប្បីប្រព្រឹត្តទៅ ដើម្បីអាពាធ គឺជំងឺតម្កាត់ឡើយ ម្យ៉ាងទៀត បុគ្គលគប្បីបាន (នូវអំណាច) ក្នុងរូបថា សូមឲ្យរូបរបស់អញយ៉ាងនេះទៅ សូមកុំឲ្យរូបរបស់អញយ៉ាងនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ រូបជាអនត្តាពិតមែន ព្រោះហេតុនោះ បានជារូបចេះតែ

ប្រព្រឹត្តទៅ ដើម្បីអាពាធ ម្យ៉ាងទៀត បុគ្គលមិនបាន ( នូវអំណាច ) ក្នុងរូបថា សូមឲ្យរូបរបស់អញយ៉ាងនេះទៅ សូមកុំឲ្យរូបរបស់អញយ៉ាងនេះឡើយ ដូច្នេះ ។

ព្រះសាស្ដា ទ្រង់សម្ដែងអនត្តលក្ខណៈ ដោយមិនទៀងផង ជាទុក្ខផង ក្នុងព្រះសូត្រ ( សំយុត្តនិកាយ ខន្ធវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា របស់ណាជាអនត្តា របស់នោះ បណ្ឌិតត្រូវយល់តាមសេចក្ដីពិតដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះថា នុ៎ះមិនមែនរបស់អញទេ នុ៎ះមិនមែនជាអញទេ នុ៎ះមិនមែនជាខ្លួនអញទេ ដូច្នេះជាដើម ។ សួរថា ទ្រង់សម្ដែងយ៉ាងនេះ ព្រោះហេតុអ្វី ឆ្លើយថា ព្រោះការមិនទៀង និងភាពជាទុក្ខប្រាកដច្បាស់ ។

ពិតហើយ កាលពែង ផ្តិល ឬវត្ថុណាមួយ ធ្លាក់អំពីដៃបែកហើយ ជនទាំងឡាយ រមែងពោលថា ឱ មិនទៀង ការមិនទៀង ឈ្មោះថា ប្រាកដហើយយ៉ាងនេះ កាលបូសជាដើមកើតឡើងក្នុងអត្តភាពហើយ ឬត្រូវជន្លួតបន្ទាមុតហើយ ក៏រមែងពោលថា ឱ ជាទុក្ខ ទុក្ខ ឈ្មោះថា ប្រាកដហើយយ៉ាងនេះ ។

អនត្តលក្ខណៈមិនប្រាកដ ងងឹតមិនជាក់ច្បាស់ ចាក់ធ្លុះបានដោយក្រ សម្ដែងបានដោយក្រ ធ្វើឲ្យយល់បានដោយក្រ តែអនិច្ចលក្ខណៈ និងទុក្ខលក្ខណៈ ព្រះតថាគតទាំងឡាយ ទ្រង់កើតឡើងក្ដី មិនកើតឡើងក្ដី រមែងប្រាកដ ។ អនត្តលក្ខណៈ វៀរចាកការកើតឡើងនៃព្រះពុទ្ធហើយ តែងមិន

ប្រាកដ រមែងប្រាកដក្នុងពុទ្ធុប្បាទប៉ុណ្ណោះ ។

ពិតហើយ តាបស និងបរិព្វាជកទាំងឡាយ ដែលមានឫទ្ធិច្រើន មានអានុភាពច្រើន មានសរភង្គតាបសជាដើម អាចពោលថា អនិច្ចំ ទុក្ខំបាន តែមិនអាចពោលថា អនត្តាបានឡើយ បើពួកតាបសជាដើមនោះអាចពោលថា អនត្តាក្នុងបរិស័ទដែលប្រជុំគ្នាហើយ បរិស័ទដែលប្រជុំគ្នា គប្បីចាក់ធ្លុះមគ្គ និងផលបាន ព្រោះការប្រកាសឲ្យដឹងអនត្តលក្ខណៈ មិនមែនវិស័យនៃបុគ្គលដទៃ ជាសព្វញ្ញុតញ្ញុវិស័យប៉ុណ្ណោះ ទើបអនត្តលក្ខណៈនេះមិនប្រាកដដោយប្រការដូច្នេះ ព្រោះហេតុនោះ ព្រះសាស្តា កាលសម្តែងអនត្តលក្ខណៈ ទើបទ្រង់សម្តែងដោយការមិនទៀងខ្លះ ដោយភាពជាទុក្ខខ្លះ ដោយការមិនទៀង និងទុក្ខខ្លះ តែក្នុងអាយតនវិភង្គនេះ គប្បីជ្រាបថា ទ្រង់សម្តែងអាយតនៈនោះ ដោយការមិនទៀងផង ដោយភាពជាទុក្ខផង ដូច្នេះ ។

សួរថា លក្ខណៈទាំងនេះ រមែងមិនប្រាកដ ព្រោះមិនមនសិការអ្វី មិនចាក់ធ្លុះអ្វី ហើយអ្វីបិទបាំង ឆ្លើយថា អនិច្ចលក្ខណៈមិនប្រាកដ ព្រោះមិនមនសិការ មិនចាក់ធ្លុះនូវការកើតឡើង និងការវិនាសទៅ និងព្រោះសន្តតិបិទបាំង ។ ទុក្ខលក្ខណៈមិនប្រាកដ ព្រោះមិនមនសិការ មិនចាក់ធ្លុះនូវការបៀតបៀនរឿយៗ ព្រោះឥរិយាបថទាំងឡាយបិទបាំង ។ អនត្តលក្ខណៈតែងមិនប្រាកដ ព្រោះមិនមនសិការ មិនចាក់ធ្លុះនូវការបែកធាតុផ្សេងៗ និងឃនសញ្ញាបិទបាំង ។ កាលព្រះយោគាវចរកំណត់ការកើត និងការវិនាសទម្លាយនូវសន្តតិបានហើយ អនិច្ចលក្ខណៈ រមែងប្រាកដដោយកិច្ចតាម

សេចក្តីពិត កាលមនសិការនូវការបៀតបៀនរឿយៗ បើកនូវឥរិយាបថបាន ហើយ ទុក្ខលក្ខណៈរមែងប្រាកដដោយកិច្ចតាមសេចក្តីពិត កាលញែកធាតុ ផ្សេងៗ ហើយធ្វើនូវការចែកឃនៈ អនត្តលក្ខណៈរមែងប្រាកដដោយកិច្ច តាមសេចក្តីពិត ។

ម្យ៉ាងទៀត ក្នុងអធិការនេះ គប្បីជ្រាបវិភាគនេះ គឺអនិច្ចំ ១ អនិច្ច-លក្ខណំ ១ ទុក្ខំ ១ ទុក្ខលក្ខណំ ១ អនត្តា ១ អនត្តលក្ខណំ ១ ។

បណ្តាការចែកទាំង ៦ នោះ ពាក្យថា អនិច្ចំ បានដល់ ខន្ធ ៥ ព្រោះ ហេតុអ្វី ព្រោះខន្ធ ៥ មានការកើត ការវិនាស និងការប្រែប្រួលទៅ ឬ ព្រោះមានហើយ ត្រឡប់ជាមិនមាន ។ ភាពដែលខន្ធ ៥ មានការកើត ការវិនាស និងការប្រែប្រួលទៅ ឬការប្រែប្រួលនៃអាការ ( លក្ខណៈ ) ពោល គឺមានហើយ ត្រឡប់ជាមិនមាន ឈ្មោះថា អនិច្ចលក្ខណៈ ។

បញ្ចក្ខន្ធនោះឯង ឈ្មោះថា ទុក្ខ ព្រោះបាលីថា ធម៌ណាមិនទៀង ធម៌ នោះជាទុក្ខ ដូច្នេះ ព្រោះហេតុអ្វី ព្រោះមានការបៀតបៀនរឿយៗ អាការ ដែលបៀតបៀនរឿយៗ ឈ្មោះថា ទុក្ខលក្ខណៈ ។

បញ្ចក្ខន្ធនោះឯង ឈ្មោះថា អនត្តា ព្រោះបាលីថា ធម៌ណាជាទុក្ខ ធម៌ នោះជាអនត្តា ដូច្នេះ ព្រោះហេតុអ្វី ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាច ។ អាការដែលមិនប្រព្រឹត្តទៅក្នុងអំណាច ឈ្មោះថា អនត្តលក្ខណៈ ព្រោះ ហេតុនោះ អនិច្ចំ ទុក្ខំ និងអនត្តាជារបស់ម្យ៉ាង អនិច្ចលក្ខណៈ ទុក្ខលក្ខណៈ និងអនត្តលក្ខណៈ ជារបស់ម្យ៉ាង ។

ពិតហើយ ពាក្យថា ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ទាំងអស់នេះ ឈ្មោះថា មិនទៀង ជាទុក្ខ ជាអនត្តា តែវិការ គឺការប្រែប្រួលនៃអាការ មានប្រការតាមដែលពោលហើយ ឈ្មោះថា អនិច្ចលក្ខណៈ ទុក្ខលក្ខណៈ និងអនត្តលក្ខណៈ ដូច្នេះឯង ។

ម្យ៉ាងទៀត ពោលដោយសង្ខេប ក្នុងអាយតនវិភង្គនេះ អាយតនៈ ១០ ជាកាមាវចរ អាយតនៈ ២ គឺមនាយតនៈ និងធម្មាយតនៈ ប្រព្រឹត្តទៅក្នុងភូមិ ៣ ។ វារៈពោលអំពីការពិចារណា គប្បីជ្រាបថា ត្រាស់ទុកក្នុងអាយតនៈទាំងអស់នោះឯង ។

អដ្ឋកថាសុត្តន្តភាជនីយ ចប់

# អភិធម្មបិដក

## អភិធម្មភាជនីយ

[ ៩៩ ] អាយតនៈ ១២ គឺចក្ខាយតនៈ សោតាយតនៈ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ មនាយតនៈ រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ធម្មាយតនៈ ។

[ ១០០ ] បណ្តាអាយតនៈទាំងនោះ ចក្ខាយតនៈ តើដូចម្តេច ។ ចក្ខុណា គឺប្រសាទ អាស្រ័យមហាភូត ៤ ។បេ។ ហៅថា ស្រុកទំនេរក៏បាន នេះហៅថា ចក្ខាយតនៈ ។ បណ្តាអាយតនៈទាំងនោះ សោតាយតនៈ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ តើដូចម្តេច ។ កាយណា គឺប្រសាទ អាស្រ័យមហាភូត ៤ ។បេ។ ហៅថា ស្រុកទំនេរក៏បាន នេះហៅថា កាយាយតនៈ ។ បណ្តាអាយតនៈទាំងនេះ មនាយតនៈ តើដូចម្តេច ។ មនាយតនៈមានប្រការមួយ បានដល់ មនាយតនៈដែលប្រកបដោយផស្សៈ ។ មនាយតនៈមានប្រការ ២ គឺមនាយតនៈប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមានហេតុក៏មាន ។ មនាយតនៈមានប្រការ ៣ គឺមនាយតនៈជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។បេ។ មនាយតនៈមានច្រើនប្រការយ៉ាងនេះឯង នេះហៅថា មនាយតនៈ ។ បណ្តាអាយតនៈទាំងនោះ រូបាយតនៈ តើដូចម្តេច ។ រូបណា គឺពណ៌ ឬពន្លឺអាស្រ័យមហាភូត ៤ ។បេ។ ហៅថា រូបធាតុក៏បាន នេះហៅថា រូបាយតនៈ ។ បណ្តាអាយតនៈទាំងនោះ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ តើដូចម្តេច ។ បឋវីធាតុ ។បេ។ ហៅថា ផោដ្ឋព្វធាតុក៏បាន នេះហៅថា ផោដ្ឋព្វាយតនៈ ។

បណ្ដាអាយតនៈទាំងនោះ ធម្មាយតនៈ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ ឬក៏រូបណា ជាអនិទស្សនៈ ជាអប្បដិឃៈ រាប់បញ្ចូលក្នុងធម្មាយតនៈ ជាអសង្ខតធាតុ ។ បណ្ដាខន្ធទាំងនោះ វេទនាខន្ធ តើដូចម្ដេច ។ វេទនាខន្ធ មានប្រការមួយ បានដល់ វេទនាខន្ធប្រកបដោយផស្សៈ ។បេ។ វេទនាខន្ធមានច្រើនប្រការយ៉ាងនេះឯង នេះហៅថា វេទនាខន្ធ ។ បណ្ដាខន្ធទាំងនោះ សញ្ញាខន្ធ តើដូចម្ដេច ។ សញ្ញាខន្ធមានប្រការមួយ បានដល់ សញ្ញាខន្ធប្រកបដោយផស្សៈ ។បេ។ សញ្ញាខន្ធមានច្រើនប្រការយ៉ាងនេះឯង នេះហៅថា សញ្ញាខន្ធ ។ បណ្ដាខន្ធទាំងនោះ សង្ខារក្ខន្ធ តើដូចម្ដេច ។ សង្ខារក្ខន្ធ មានប្រការមួយ បានដល់ សង្ខារក្ខន្ធ ប្រកបដោយចិត្ត ។បេ។ សង្ខារក្ខន្ធមានច្រើនប្រការយ៉ាងនេះឯង នេះហៅថា សង្ខារក្ខន្ធ ។ បណ្ដាខន្ធទាំងនោះ រូបជាអនិទស្សនៈ ជាអប្បដិឃៈ រាប់បញ្ចូលក្នុងធម្មាយតនៈ តើដូចម្ដេច ។ ឥត្ថិន្ទ្រិយ ។បេ។ កពឡិង្ការាហារ នេះហៅថា រូបជាអនិទស្សនៈ ជាអប្បដិឃៈ រាប់បញ្ចូលក្នុងធម្មាយតនៈ ។ បណ្ដាអាយតនៈទាំងនោះ អសង្ខតធាតុ តើដូចម្ដេច ។ ការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈ នេះហៅថា អសង្ខតធាតុ ។ នេះហៅថា ធម្មាយតនៈ ។

**អភិធម្មភាជនីយ ចប់**

# អដ្ឋកថា

## អភិធម្មភាជនីយ

[ ៩៩-១០០ ] ព្រះមានព្រះភាគ ត្រាស់អាយតនៈទាំងឡាយ ទុកខាងដើម ដោយភាពជាអាយតនៈជាគូៗ ថា **ចក្ខាយតនំ រូបាយតនំ** ដូច្នេះជាដើម ទ្រង់បំណងឧបការៈ ដល់ព្រះយោគាវចរទាំងឡាយ ដែលចម្រើនវិបស្សនា ដោយប្រការណាក្នុងអភិធម្មភាជនីយ មិនបានត្រាស់ដោយប្រការនោះ តែត្រាស់ដោយន័យការកំណត់អាយតនៈខាងក្នុង និងអាយតនៈខាងក្រៅ យ៉ាងនេះថា **ចក្ខាយតនំ សោតាយតនំ** ដូច្នេះជាដើម ។

ក្នុងនិទ្ទេសវារនៃអាយតនៈទាំងនោះ គប្បីជ្រាបថា បណ្ដាអាយតនៈទាំងនោះ ចក្ខាយតនៈ តើដូចម្ដេចជាដើម ដោយន័យដែលបានពោលខាងដើមនោះឯង តែក្នុងពាក្យដែលត្រាស់ ក្នុងនិទ្ទេសនៃធម្មាយតនៈថា បណ្ដាអាយតនៈទាំងនោះ អសង្ខតធាតុ តើដូចម្ដេច ។ ការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈ ដូច្នេះជាដើម មានអធិប្បាយដូចតទៅ

បទថា **អសង្ខតា ធាតុ** បានដល់ ព្រះនិព្វានដែលមានអសង្ខតៈ ជាសភាវៈ ដែលកិលេសទាំងឡាយ មានរាគៈជាដើម ដល់ព្រះនិព្វាននេះហើយ រមែងអស់ទៅ ហេតុនោះ ទើបត្រាស់ថា ការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈ ដូច្នេះ នេះជាពាក្យអធិប្បាយអត្ថ ដែលដូចគ្នានៃអាចារ្យទាំងឡាយ ក្នុងនិទ្ទេសអភិធម្មភាជនីយនេះ ។

តែអាចារ្យវិតណ្ឌវាទីពោលថា ធម្មតានិព្វានដោយចំពោះមិនមាន មាន

តែនិព្វាន គឺការអស់ទៅនៃកិលេសប៉ុណ្ណោះ ដូច្នេះ តែបើមានអ្នកសួរថា ចូរនាំសូត្រមក ដូច្នេះ ក៏អាចជម្ពុខាទកសូត្រថា ម្នាលអាវុសោសារីបុត្ត គេតែងនិយាយថា និព្វាន និព្វាន ម្នាលអាវុសោ ដូចម្ដេចហ្ន៎ ហៅថា និព្វាន ។ ព្រះសារីបុត្តតបថា ម្នាលអាវុសោ សភាវៈដែលជាទីអស់ទៅនៃរាគៈ អស់ទៅនៃទោសៈ អស់ទៅនៃមោហៈ នេះហៅថា និព្វាន ដូច្នេះ ហើយពោលថា ដោយសូត្រនេះគប្បីជ្រាបថា ធម្មតានិព្វានដោយចំពោះមិនមាន មានតែនិព្វាន គឺការអស់កិលេសប៉ុណ្ណោះ ដូច្នេះ ។

គប្បីសួរអាចារ្យវិតណ្ឌវាទីថា សេចក្ដីនោះដូចគ្នានឹងសូត្រនេះឬ អាចារ្យវិតណ្ឌវាទីនឹងឆ្លើយថា អើ អត្ថដែលផុតចាកសូត្រមិនមាន ដូច្នេះ ។

លំដាប់នោះ គប្បីពោលនឹងអាចារ្យវិតណ្ឌវាទីថា សូត្រនេះ លោកអាចមកអំពីមុន សូមនាំសូត្របន្ទាប់មកសម្ដែង ដូច្នេះ ។ អាចារ្យវិតណ្ឌវាទីក៏នាំសូត្របន្ទាប់អំពីសូត្រនោះ មកសម្ដែងយ៉ាងនេះថា ម្នាលអាវុសោសារីបុត្ត គេតែងនិយាយថា អរហត្ត អរហត្ត ម្នាលអាវុសោ ដូចម្ដេចហ្ន៎ ហៅថា អរហត្ត ។ ម្នាលអាវុសោ សភាវៈដែលជាទីអស់ទៅនៃរាគៈ អស់ទៅនៃទោសៈ អស់ទៅនៃមោហៈ នេះហៅថា អរហត្ត ដូច្នេះ ។

កាលអាចារ្យវិតណ្ឌវាទី នាំសូត្រនេះមក ជនទាំងឡាយ ក៏នឹងពោលជាមួយអាចារ្យវិតណ្ឌវាទីនោះថា ធម៌ទាក់ទងដោយធម្មាយតនៈ ឈ្មោះថានិព្វាន នាមក្ខន្ធ ៤ ឈ្មោះថា អរហត្ត ព្រះធម្មសេនាបតី ជាអ្នកធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន កាលមានបុគ្គលសួរដល់និព្វានខ្លះ សួរដល់អរហត្ត

ខ្ចះ ក៏ពោលដល់ការអស់កិលេសប៉ុណ្ណោះ ឯនិព្វាន និងអរហត្ត ដូចគ្នា ឬ ផ្សេងគ្នាដូចម្តេច និព្វានដូចគ្នា ឬផ្សេងគ្នាស្មេះសិនចុះ តែក្នុងទីនេះ សេចក្តី ដែលលោកធ្វើឲ្យល្អិតពេក មានបំណងអ្វី លោកមិនដឹងព្រះនិព្វានតែម្យ៉ាង ឬផ្សេងគ្នាទេឬ លោកអាចារ្យវិតណ្ឌវាទីត្រូវសួររឿយៗ ថា កាលដឹងសេចក្តី នេះហើយ ទើបប្រយោជន៍សម្រេចបានមិនមែនឬ កាលមិនអាចវិនិច្ឆ័យបាន ក៏នឹងពោលថា អរហត្ត ហៅថា ការអស់រាគៈ ការអស់ទោសៈ ការអស់ មោហៈ ព្រោះអរហត្តនោះ កើតឡើងក្នុងទីបំផុតនៃការអស់រាគៈជាដើម ។

លំដាប់នោះ ជនទាំងឡាយក៏នឹងពោលជាមួយអាចារ្យវិតណ្ឌវាទីនោះថា លោកធ្វើរឿងធំហើយ បុគ្គលឲ្យថ្លៃឈ្នួលហើយ កាលនឹងពោលរឿងនោះៗ ក៏គប្បីឲ្យពោលពាក្យនេះឯង ពាក្យនេះ លោកចែកពោលទុក ដោយប្រការ ណា ចូរលោកកំណត់ព្រះនិព្វាននេះ ដោយប្រការនោះចុះ ។ ព្រោះកិលេស ទាំងឡាយ មានរាគៈជាដើម ដល់ព្រះនិព្វានហើយ ក៏អស់ទៅ ព្រោះហេតុ នោះ ទើបនិព្វាននោះទ្រង់ត្រាស់ថា ការអស់រាគៈ ការអស់ទោសៈ ការអស់ មោហៈ ដូច្នេះ ព្រោះពាក្យទាំង ៣ នេះ ក៏ជាឈ្មោះរបស់ព្រះនិព្វាននោះ ឯង ។

បើពោលយ៉ាងនេះដល់នូវការយល់បាន នុ៎ះជាការល្អ បើមិនយល់គប្បី ឲ្យធ្វើសការៈជានិព្វានសន្និកសន្ទាប់ សួរថា ធ្វើដូចម្តេច ឆ្លើយថា គប្បីសួរ យ៉ាងនេះថា ឈ្មោះថា ការអស់រាគៈ ជាការអស់ទៅនៃរាគៈតែម្យ៉ាង ឬជា ការអស់ទៅនៃទោសៈ និងមោហៈផងដែរ ឈ្មោះថា ការអស់ទោសៈ ជា

ការអស់ទៅនៃទោសៈតែម្យ៉ាង ឬជាការអស់ទៅនៃរាគៈ និងមោហៈផងដែរ ឈ្មោះថា ការអស់មោហៈ ជាការអស់ទៅនៃមោហៈតែម្យ៉ាង ឬជាការអស់ទៅនៃរាគៈ និងទោសៈផងដែរ ។

ពិតហើយ អាចារ្យវិតណ្ឌវាទីនោះនឹងពោលថា ឈ្មោះថា ជាការអស់រាគៈ ជាការអស់ចំពោះរាគៈ ឈ្មោះថា ជាការអស់ទោសៈ ជាការអស់ចំពោះទោសៈ ឈ្មោះថា ការអស់មោហៈ ជាការអស់ចំពោះមោហៈ ដូច្នេះ ។

លំដាប់នោះ គប្បីពោលនឹងអាចារ្យវិតណ្ឌវាទីថា ក្នុងវាទៈរបស់លោក កាលអស់រាគៈ ជានិព្វាន ១ កាលអស់ទោសៈ ជានិព្វាន ១ កាលអស់មោហៈ ជានិព្វាន ១ កាលអស់អកុសលមូល ៣ ក៏មាននិព្វាន ៣ កាលអស់ឧបាទាន ៤ ក៏មាននិព្វាន ៤ កាលអស់នីវរណៈ ៥ ក៏មាននិព្វាន ៥ កាលអស់គំនរនៃតណ្ហា ៦ ក៏មាននិព្វាន ៦ កាលអស់អនុស័យ ៧ ក៏មាននិព្វាន ៧ កាលអស់មិច្ឆត្តៈ ៨ ក៏មាននិព្វាន ៨ កាលអស់ធម៌ដែលជាមូលនៃតណ្ហា ៩ ក៏មាននិព្វាន ៩ កាលអស់សំយោជនៈ ១០ ក៏មាននិព្វាន ១០ កាលអស់កិលេស ១៥០០ ក៏មាននិព្វានមួយបែបៗ ព្រោះហេតុនោះ ទើបនិព្វានមានច្រើន និព្វានរបស់លោក មិនមានប្រមាណ ។

លោកកុំកាន់យកយ៉ាងនេះ តែចូរកាន់យកថា កិលេសទាំងឡាយ មានរាគៈជាដើម ដល់ព្រះនិព្វានហើយ ក៏អស់ទៅ ព្រោះហេតុនោះ ទើបព្រះនិព្វាន មាន ១ ប៉ុណ្ណោះ គឺការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈ ដូច្នេះ ព្រោះទាំង ៣ នេះ ក៏ជាឈ្មោះរបស់ព្រះនិព្វាន ។

បើជនពួកដទៃពោលយ៉ាងនេះហើយ អាចារ្យវិតណ្ឌវាទីក៏មិនទាន់កំណត់បាន គប្បីធ្វើការអធិប្បាយព្រះនិព្វានដោយប្រៀបធៀបនឹងរបស់គ្រោតគ្រាត សួរថា អធិប្បាយដូចម្ដេច ឆ្លើយថា សត្វល្ងង់ខ្លៅ មានខ្លាឃ្មុំ ខ្លាដំបង ម្រឹគ និងស្វាជាដើម ត្រូវកិលេសចោមរោមហើយ រមែងសេពមេថុន កាលដល់ទីបំផុតនៃការសេពរបស់សត្វទាំងនោះ កិលេសទាំងឡាយក៏ស្ងប់ ក្នុងវាទៈរបស់លោក ពួកសត្វ មានខ្លាឃ្មុំ ខ្លាដំបង ម្រឹគ និងស្វាជាដើម ក៏ឈ្មោះថា ដល់នូវព្រះនិព្វានហើយ និព្វានរបស់លោកគ្រោតគ្រាតហើយ ជារបស់គ្រោតគ្រាត បុគ្គលមិនអាចប្រដាប់ត្រង់ត្រចៀកបាន ។ លោកកុំកាន់យកយ៉ាងនេះ តែចូរកាន់យកថា កិលេសទាំងឡាយ មានរាគៈជាដើម ដល់ព្រះនិព្វានហើយក៏អស់ទៅ ព្រោះហេតុនោះ ទើបព្រះនិព្វានមាន ១ ប៉ុណ្ណោះ ហៅថា ការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈ ព្រោះពាក្យទាំង ៣ នេះ ក៏ជាឈ្មោះនៃព្រះនិព្វាន ។

បើជនពួកដទៃពោលហើយយ៉ាងនេះ អាចារ្យវិតណ្ឌវាទីនោះ នៅតែមិនទាន់កំណត់បាន ក៏គួរអធិប្បាយដោយគោត្រភូ សួរថា អធិប្បាយដូចម្ដេច ឆ្លើយថា គប្បីសួរអាចារ្យវិតណ្ឌវាទីយ៉ាងនេះថា លោកពោលថា ឈ្មោះថាគោត្រភូមានឬ អាចារ្យវិតណ្ឌវាទីក៏នឹងឆ្លើយថា ពិតហើយ ខ្ញុំពោលដូច្នេះហើយ គប្បីសួរថា ក្នុងខណៈនៃគោត្រភូ កិលេសទាំងឡាយអស់ទៅហើយ ឬកំពុងអស់ ឬនឹងអស់ ក៏ឆ្លើយថា កិលេសទាំងឡាយ មិនទាន់អស់ទៅ មិនមែនកំពុងអស់ទៅ ដោយពិត នឹងអស់ទៅ កាលកិលេសទាំងឡាយមិន

ទាន់អស់ទៅ លោករមែងបញ្ញត្តការអស់ទៅនៃកិលេស ថាជាព្រះនិព្វាន កាលមិនទាន់បានលះអនុស័យ លោករមែងបញ្ញត្តការលះអនុស័យ ថាជានិព្វាន ពាក្យនោះរបស់លោកមិនសមគ្នា ។ លោកកុំពោលយ៉ាងនេះ តែចូរកាន់យកថា កិលេសទាំងឡាយ មានរាគៈជាដើម ដល់និព្វានក៏អស់ទៅ ព្រោះហេតុនោះ ទើបព្រះនិព្វានមានតែម្យ៉ាងប៉ុណ្ណោះ ហៅថា ការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈ ព្រោះពាក្យទាំង ៣ នេះ ក៏ជាឈ្មោះរបស់ព្រះនិព្វាននោះឯង ។

បើជនពួកដទៃពោលយ៉ាងនេះ អាចារ្យវិតណ្ឌវាទី ក៏មិនទាន់កំណត់បាន ក៏គួរធ្វើអធិប្បាយដោយមគ្គ ។ សួរថា អធិប្បាយដូចម្តេច ឆ្លើយថា ជាដំបូង គប្បីសួរអាចារ្យវិតណ្ឌវាទីយ៉ាងនេះថា លោកធ្លាប់ពោលដល់មគ្គដែរឬទេ លោកក៏នឹងឆ្លើយថា អើ គប្បីសួរទៀតថា ក្នុងខណៈនៃមគ្គ កិលេសទាំងឡាយអស់ទៅហើយ ឬកំពុងអស់ ឬនឹងអស់ ។ កាលបើលោកដឹងក៏នឹងឆ្លើយថា ក្នុងខណៈនៃមគ្គ មិនគួរពោលថា កិលេសទាំងឡាយ អស់ហើយ ឬថា នឹងអស់ តែគួរពោលថា កិលេសទាំងឡាយ កំពុងអស់ទៅ ដូច្នេះ ក៏គួរពោលនឹងអាចារ្យវិតណ្ឌវាទីថា បើយ៉ាងនោះ និព្វានដែលជាទីអស់កិលេសនៃមគ្គដូចម្តេច កិលេសដែលអស់ទៅដោយមគ្គដូចម្តេច មគ្គធ្វើព្រះនិព្វានដែលជាទីអស់កិលេសឯណា ឲ្យជាអារម្មណ៍ហើយ ធ្វើកិលេសពួកណាឲ្យអស់ទៅ ព្រោះហេតុនោះ លោកកុំកាន់យកយ៉ាងនេះ កិលេសទាំងឡាយ មានរាគៈជាដើមដល់ព្រះនិព្វានក៏អស់ទៅ ព្រោះហេតុនោះ ទើប

ព្រះនិព្វាន មានតែមួយប៉ុណ្ណោះ ហៅថា ការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈ ព្រោះពាក្យទាំង ៣ នេះ ក៏ជាឈ្មោះរបស់ព្រះនិព្វាននោះឯង ។ កាលសកវាទីពោលយ៉ាងនេះហើយ វិតណ្ឌវាទីក៏ពោលយ៉ាងនេះថា លោកពោលថា ដល់ ដល់ ( ព្រះនិព្វាន ) ឬ សកវាទីឆ្លើយថា អើ ខ្ញុំពោលសួរទៀតថា ពាក្យថា ឈ្មោះថា ដល់នេះ លោកបានមកអំពីណា វិតណ្ឌវាទីឆ្លើយថា បានមកអំពីព្រះសូត្រ វិតណ្ឌវាទីពោលថា ចូរនាំសូត្រមក ទើបនាំសូត្រមកថា យ៉ាងនេះឯង អវិជ្ជា និងតណ្ហាដល់ព្រះនិព្វាននោះហើយ ដាច់ទៅក្នុងព្រះនិព្វាននោះ អស់ទៅក្នុងព្រះនិព្វាននោះ នឹងមិនដល់នូវភាពដូចម្ដេចក្នុងទីណាមួយ កាលបើសកវាទីពោលយ៉ាងនេះហើយ បរវាទីវិតណ្ឌវាទី ក៏នឹងដល់នូវភាពជាអ្នកស្ងប់ ។

ក្នុងអភិធម្មភាជនីយនេះ គប្បីជ្រាបថា អាយតនៈ ១០ ជាកាមាវចរ ៦ អាយតនៈ ២ ប្រព្រឹត្តទៅក្នុងភូមិ ៤ លាយឡំដោយលោកិយផងលោកុត្តរផង ដូច្នេះ ។

**អដ្ឋកថាអភិធម្មភាជនីយ ចប់**

# អភិធម្មបិដក

## បញ្ហាបុច្ឆកៈ

[ ១០១ ] អាយតនៈ ១២ គឺចក្ខាយតនៈ រូបាយតនៈ ។បេ។ មនាយតនៈ ធម្មាយតនៈ ។ បណ្ដាអាយតនៈ ១២ អាយតនៈជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។បេ។ ប្រកបដោយសត្រូវប៉ុន្មាន មិនមានសត្រូវប៉ុន្មាន ។

[ ១០២ ] អាយតនៈ ១០ ជាអព្យាក្រឹត អាយតនៈ ២ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ អាយតនៈ ១០ មិនគប្បីពោលថា ប្រកបដោយសុខវេទនាផង ជាប្រកបដោយទុក្ខវេទនាផង ជាប្រកបដោយអទុក្ខមសុខវេទនាផងឡើយ មនាយតនៈ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ធម្មាយតនៈ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន មិនគប្បីពោលថា ប្រកបដោយសុខវេទនាផង ជាប្រកបដោយទុក្ខវេទនាផង ជាប្រកបដោយអទុក្ខមសុខវេទនាផងក៏មាន អាយតនៈ ១០ មិនមែនជាវិបាក ទាំងមិនមែនជាធម៌ មានវិបាកជាប្រក្រតី អាយតនៈ ២ ជាវិបាកក៏មាន ជាធម៌មានវិបាកជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីក៏មាន ។ អាយតនៈ ៥ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន សទ្ទាយតនៈ មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន អាយតនៈ ៤

មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ ទាំងមិនជាប្រ-យោជន៍ដល់ឧបាទានក៏មាន អាយតនៈ ២ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន ។ អាយតនៈ ១០ មិនសៅហ្មង តែគួរដល់សេចក្តីសៅហ្មង អាយតនៈ ២ សៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មងក៏មាន មិនសៅហ្មង តែគួរដល់សេចក្តីសៅហ្មងក៏មាន មិនសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន ។ អាយតនៈ ១០ មិនមានវិតក្ក ទាំងមិនមានវិចារ មនាយតនៈ ប្រព្រឹត្តទៅជាមួយនឹងវិតក្កជាមួយនឹងវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្កទាំងមិនមានវិចារក៏មាន ធម្មាយតនៈ ប្រព្រឹត្តទៅជាមួយនឹងវិតក្ក ជាមួយនឹងវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន មិនគប្បីពោលថា ប្រព្រឹត្តទៅជាមួយនឹងវិតក្ក ជាមួយនឹងវិចារផង ថាមិនមានវិតក្ក មានត្រឹមតែវិចារផង ថាមិនមានវិតក្ក ទាំងមិនមានវិចារផងក៏មាន ។ អាយតនៈ ១០ មិនគប្បីពោលថា កើតព្រមដោយ

បីតិផង ថាកើតព្រមដោយសុខផង ថាកើតព្រមដោយឧបេក្ខាផងឡើយ អាយតនៈ ២ កើតព្រមដោយបីតិក៏មាន កើតព្រមដោយសុខក៏មាន កើតព្រមដោយឧបេក្ខាក៏មាន មិនគប្បីពោលថា កើតព្រមដោយបីតិផង ថាកើតព្រមដោយសុខផង ថាកើតព្រមដោយឧបេក្ខាផងក៏មាន ។ អាយតនៈ ១០ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា អាយតនៈ ២ គួរលះដោយទស្សនៈក៏មាន គួរលះដោយភាវនាក៏មាន មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន ។ អាយតនៈ ១០ មានហេតុ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា អាយតនៈ ២ មានហេតុ គួរលះដោយទស្សនៈក៏មាន មានហេតុ គួរលះដោយភាវនាក៏មាន មានហេតុ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន ។ អាយតនៈ ១០ មិនដល់នូវការសន្សំកពូនឡើង ទាំងមិនមែនមិនដល់នូវការសន្សំកពូនឡើង អាយតនៈ ២ ដល់នូវការសន្សំកពូនឡើងក៏មាន មិនដល់នូវការសន្សំកពូនឡើងក៏មាន មិនដល់នូវការសន្សំកពូនឡើង ទាំងមិនមែនមិនដល់នូវការសន្សំកពូនឡើងក៏មាន ។ អាយតនៈ ១០ មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល អាយតនៈ ២ ជារបស់សេក្ខបុគ្គលក៏មាន ជារបស់អសេក្ខបុគ្គលក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គលក៏មាន ។ អាយតនៈ ១០ មានសភាពតូចឆ្មារ អាយតនៈ ២ មានសភាពតូចឆ្មារក៏មាន ដល់នូវសភាពធំក៏មាន ប្រមាណមិនបានក៏មាន ។ អាយតនៈ ១០ មិនមានអារម្មណ៍ អាយតនៈ ២ មាន

អារម្មណ៍តូចឆ្មារក៏មាន មានអារម្មណ៍ដល់នូវសភាពធំក៏មាន មានអារម្មណ៍ប្រមាណមិនបានក៏មាន មិនគប្បីពោលថា មានអារម្មណ៍តូចឆ្មារផង ថាមានអារម្មណ៍ដល់នូវសភាពធំផង ថាមានអារម្មណ៍ប្រមាណមិនបានផងក៏មាន ។ អាយតនៈ ១០ ជាកណ្តាល អាយតនៈ ២ ថោកទាបក៏មាន កណ្តាលក៏មាន ឧត្តមក៏មាន ។ អាយតនៈ ១០ មិនទៀង អាយតនៈ ២ មានសភាពខុស និងទៀងក៏មាន មានសភាពត្រូវ និងទៀងក៏មាន មិនទៀងក៏មាន ។ អាយតនៈ ១០ មិនមានអារម្មណ៍ អាយតនៈ ២ មានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគប្បីពោលថា មានមគ្គជាអារម្មណ៍ផង ថាមានមគ្គជាហេតុផង ថាមានមគ្គជាអធិបតីផងក៏មាន ។ អាយតនៈ ៥ កើតហើយក៏មាន ប្រុងនឹងកើត តែមិនគប្បីពោលថា មិនទាន់កើតក៏មាន សទ្ទាយតនៈ កើតហើយក៏មាន មិនទាន់កើត តែមិនគប្បីពោលថា ប្រុងនឹងកើតក៏មាន អាយតនៈ ៥ កើតហើយក៏មាន មិនទាន់កើតក៏មាន ប្រុងនឹងកើតក៏មាន ធម្មាយតនៈ កើតហើយក៏មាន មិនទាន់កើតក៏មាន ប្រុងនឹងកើតក៏មាន មិនគប្បីពោលថា កើតហើយផង ថាមិនទាន់កើតផង ថាប្រុងនឹងកើតផងក៏មាន ។ អាយតនៈ ១១ ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន ធម្មាយតនៈ ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន មិនគប្បីពោលថា ជាអតីតផង ថាជាអនាគតផង ថាជាបច្ចុប្បន្នផងក៏មាន ។ អាយតនៈ ១០ មិនមានអារម្មណ៍ អាយតនៈ ២ មានអារម្មណ៍ជាអតីតក៏មាន មានអារម្មណ៍ជាអនាគតក៏មាន មានអារម្មណ៍ជាបច្ចុប្បន្នក៏

មាន មិនគប្បីពោលថា មានអារម្មណ៍ជាអតីតផង ជាមានអារម្មណ៍ជាអនាគតផង ជាមានអារម្មណ៍ជាបច្ចុប្បន្នផងក៏មាន ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ជាខាងក្នុង និងខាងក្រៅក៏មាន ។ អាយតនៈ ១០ មិនមានអារម្មណ៍ អាយតនៈ ២ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុងទាំងខាងក្រៅក៏មាន មិនគប្បីពោលថា មានអារម្មណ៍ខាងក្នុងផង ជាមានអារម្មណ៍ខាងក្រៅផង ជាមានអារម្មណ៍ទាំងខាងក្នុងទាំងខាងក្រៅផងក៏មាន ។ រូបាយតនៈ ប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ អាយតនៈ ៩ មិនប្រកបដោយការឃើញ តែមិនប្រកបដោយការប៉ះពាល់ អាយតនៈ ២ មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ ។

[ ១០៣ ] អាយតនៈ ១១ មិនមែនហេតុ ធម្មាយតនៈ ជាហេតុក៏មាន មិនមែនហេតុក៏មាន ។ អាយតនៈ ១០ មិនមានហេតុ អាយតនៈ ២ ប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមានហេតុក៏មាន ។ អាយតនៈ ១០ ប្រាសចាកហេតុ អាយតនៈ ២ ប្រកបដោយហេតុក៏មាន ប្រាសចាកហេតុក៏មាន ។ អាយតនៈ ១០ មិនគប្បីពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុផង ជាប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុផងឡើយ មនាយតនៈ មិនគប្បីពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ ប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុក៏មាន មិនគប្បីពោលថា ប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុក៏មាន ធម្មាយតនៈ ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយ

នឹងហេតុក៏មាន ប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុក៏មាន មិនគប្បីពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុផង ជាប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុផងក៏មាន ។ អាយតនៈ ១០ មិនគប្បីពោលថា ជាហេតុ ទាំងប្រកបដោយហេតុផង ជាប្រកបដោយហេតុ តែមិនមែនហេតុផងឡើយ មនាយតនៈមិនគប្បីពោលថា ជាហេតុ ទាំងប្រកបដោយហេតុទេ ប្រកបដោយហេតុ តែមិនមែនហេតុក៏មាន មិនគប្បីពោលថា ប្រកបដោយហេតុ តែមិនមែនហេតុក៏មាន ធម្មាយតនៈ ជាហេតុ ទាំងប្រកបដោយហេតុក៏មាន ប្រកបដោយហេតុ តែមិនមែនហេតុក៏មាន មិនគប្បីពោលថា ជាហេតុ ទាំងប្រកបដោយហេតុផង ជាប្រកបដោយហេតុ តែមិនមែនហេតុផងក៏មាន ។ អាយតនៈ ១០ មិនមែនហេតុ ទាំងមិនមានហេតុ មនាយតនៈ មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមែនហេតុ ទាំងមិនមានហេតុក៏មាន ធម្មាយតនៈ មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមែនហេតុ ទាំងមិនមានហេតុក៏មាន មិនគប្បីពោលថា មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុផង ជាមិនមែនហេតុ ទាំងមិនមានហេតុផងក៏មាន ។

[ ១០៤ ] អាយតនៈ ១១ ប្រព្រឹត្តទៅជាមួយនឹងបច្ច័យ ធម្មាយតនៈ ប្រព្រឹត្តទៅជាមួយនឹងបច្ច័យក៏មាន មិនមានបច្ច័យក៏មាន ។ អាយតនៈ ១១ មានបច្ច័យតាក់តែង ធម្មាយតនៈ មានបច្ច័យតាក់តែងក៏មាន ឥតមានបច្ច័យតាក់តែងក៏មាន ។ អាយតនៈ ១១ មិនប្រកបដោយការឃើញ រូបាយតនៈ ប្រកបដោយការឃើញ ។ អាយតនៈ ១០ ប្រកបដោយការប៉ះពាល់

អាយតនៈ ២ មិនប្រកបដោយការប៉ះពាល់ ។ អាយតនៈ ១០ មានរូប មនាយតនៈ មិនមានរូប ធម្មាយតនៈ មានរូបក៏មាន ឥតរូបក៏មាន ។ អាយតនៈ ១០ ជាលោកិយ អាយតនៈ ២ ជាលោកិយក៏មាន ជាលោកុត្តរក៏មាន ។ គប្បីដឹងដោយវិញ្ញាណណាមួយក៏មាន មិនគប្បីដឹងដោយវិញ្ញាណណាមួយក៏មាន ។

[ ១០៥ ] អាយតនៈ ១១ មិនមែនអាសវៈ ធម្មាយតនៈ ជាអាសវៈក៏មាន មិនមែនអាសវៈក៏មាន ។ អាយតនៈ ១០ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ អាយតនៈ ២ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន មិនមានអាសវៈក៏មាន ។ អាយតនៈ ១០ ប្រាសចាកអាសវៈ អាយតនៈ ២ ប្រកបដោយអាសវៈក៏មាន ប្រាសចាកអាសវៈក៏មាន ។ អាយតនៈ ១០ មិនគប្បីពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈឡើយ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈ មនាយតនៈ មិនគប្បីពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈទេ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈក៏មាន មិនគប្បីពោលថា ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈក៏មាន ធម្មាយតនៈ ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈក៏មាន មិនគប្បីពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ជាប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈផងក៏មាន ។ អាយតនៈ ១០ មិនគប្បីពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផង ជាប្រកបដោយ

អាសវៈ តែមិនមែនអាសវៈផងឡើយ មនាយតនៈ មិនគប្បីពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈទេ ប្រកបដោយអាសវៈ តែមិនមែនអាសវៈក៏មាន មិនគប្បីពោលថា ប្រកបដោយអាសវៈ តែមិនមែនអាសវៈក៏មាន ធម្មាយតនៈ ជាអាសវៈ ទាំងប្រកបដោយអាសវៈក៏មាន ប្រកបដោយអាសវៈ តែមិនមែនអាសវៈក៏មាន មិនគប្បីពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផង ថាប្រកបដោយអាសវៈ តែមិនមែនអាសវៈផងក៏មាន ។ អាយតនៈ ១០ ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ អាយតនៈ ២ ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈក៏មាន មិនគប្បីពោលថា ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ថាប្រាសចាកអាសវៈ ទាំងមិនមានអាសវៈផងឡើយ ។

[ ១០៦ ] អាយតនៈ ១១ មិនមែនសញ្ញោជនៈ ធម្មាយតនៈជាសញ្ញោជនៈក៏មាន មិនមែនសញ្ញោជនៈក៏មាន ។ អាយតនៈ ១០ ជាប្រយោជន៍ដល់សញ្ញោជនៈ អាយតនៈ ២ ជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន មិនមែនជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ។ អាយតនៈ ១០ ប្រាសចាកសញ្ញោជនៈ អាយតនៈ ២ ប្រកបដោយសញ្ញោជនៈក៏មាន ប្រាសចាកសញ្ញោជនៈក៏មាន ។ អាយតនៈ ១០ មិនគប្បីពោលថា ជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈឡើយ ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនសញ្ញោជនៈ មនាយតនៈ មិនគប្បីពោលថា ជាសញ្ញោជនៈ ទាំងជា

ប្រយោជន៍ដល់សញ្ញោជនៈទេ ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនសញ្ញោជនៈក៏មាន ធម្មាយតនៈជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនសញ្ញោជនៈក៏មាន មិនគប្បីពោលថា ជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈផង ថាជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនសញ្ញោជនៈផងក៏មាន ។ អាយតនៈ ១០ មិនគប្បីពោលថា ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈផង ថាប្រកបដោយសញ្ញោជនៈ តែមិនមែនសញ្ញោជនៈផងឡើយ មនាយតនៈមិនគប្បីពោលថា ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈទេ ប្រកបដោយសញ្ញោជនៈ តែមិនមែនសញ្ញោជនៈក៏មាន មិនគប្បីពោលថា ប្រកបដោយសញ្ញោជនៈ តែមិនមែនសញ្ញោជនៈក៏មាន ធម្មាយតនៈ ជាសញ្ញោជនៈទាំងប្រកបដោយសញ្ញោជនៈក៏មាន ប្រកបដោយសញ្ញោជនៈ តែមិនមែនសញ្ញោជនៈក៏មាន មិនគប្បីពោលថាជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈផង ថាប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈផងក៏មាន ។ អាយតនៈ ១០ ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈ អាយតនៈ ២ ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន មិនគប្បីពោលថា ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈផង ថាប្រាសចាកសញ្ញោជនៈ តែមិនមែនជាប្រយោជន៍ដល់សញ្ញោជនៈផងក៏មាន ។

[ ១០៧ ] អាយតនៈ ១១ មិនមែនគន្ថៈ ធម្មាយតនៈ ជាគន្ថៈក៏មាន មិនមែនគន្ថៈក៏មាន ។ អាយតនៈ ១០ គន្ថៈគប្បីជោតក្រង អាយតនៈ ២ គន្ថៈគប្បីជោតក្រងក៏មាន មិនគប្បីជោតក្រងក៏មាន ។ អាយតនៈ ១០ ប្រាសចាកគន្ថៈ អាយតនៈ ២ ប្រកបដោយគន្ថៈក៏មាន ប្រាសចាកគន្ថៈក៏មាន ។ អាយតនៈ ១០ មិនគប្បីពោលថា ជាគន្ថៈ ទាំងគន្ថៈគប្បីជោតក្រងឡើយ គន្ថៈគប្បីជោតក្រង តែមិនមែនគន្ថៈ មនាយតនៈ មិនគប្បីពោលថា ជាគន្ថៈ ទាំងគន្ថៈគប្បីជោតក្រងទេ គន្ថៈគប្បីជោតក្រង តែមិនមែនគន្ថៈក៏មាន មិនគប្បីពោលថា គន្ថៈគប្បីជោតក្រង តែមិនមែនគន្ថៈក៏មាន ធម្មាយតនៈ ជាគន្ថៈ ទាំងគន្ថៈគប្បីជោតក្រងក៏មាន គន្ថៈគប្បីជោតក្រង តែមិនមែនគន្ថៈក៏មាន មិនគប្បីពោលថា ជាគន្ថៈ ទាំងគន្ថៈគប្បីជោតក្រងផង ថាគន្ថៈគប្បីជោតក្រង តែមិនមែនគន្ថៈផងក៏មាន ។ អាយតនៈ ១០ មិនគប្បីពោលថា ជាគន្ថៈ ទាំងប្រកបដោយគន្ថៈផង ថាប្រកបដោយគន្ថៈ តែមិនមែនគន្ថៈផងឡើយ មនាយតនៈ មិនគប្បីពោលថា ជាគន្ថៈ ទាំងប្រកបដោយគន្ថៈទេ ប្រកបដោយគន្ថៈ តែមិនមែនគន្ថៈក៏មាន មិនគប្បីពោលថា ប្រកបដោយគន្ថៈ តែមិនមែនគន្ថៈក៏មាន ធម្មាយតនៈ ជាគន្ថៈ ទាំងប្រកបដោយគន្ថៈក៏មាន ប្រកបដោយគន្ថៈ តែមិនមែនគន្ថៈក៏មាន មិនគប្បីពោលថា ជាគន្ថៈ ទាំងប្រកបដោយគន្ថៈផង ថាប្រកបដោយគន្ថៈ តែមិនមែនគន្ថៈផងក៏មាន ។ អាយតនៈ ១០ ប្រាសចាកគន្ថៈ តែគន្ថៈគប្បីជោតក្រង អាយតនៈ ២ ប្រាសចាកគន្ថៈ តែគន្ថៈគប្បីជោតក្រងក៏មាន ប្រាសចាកគន្ថៈ ទាំងគន្ថៈមិនគប្បីជោតក្រងក៏

មាន មិនគប្បីពោលថា ប្រាសចាកគន្ថៈតែគន្ថៈគប្បីជាតក្រែងផង ថាប្រាស ចាកគន្ថៈ ទាំងគន្ថៈមិនគប្បីជាតក្រែងផងឡើយ ។

[ ១០៨ ] អាយតនៈ ១១ មិនមែននីវរណៈ ។បេ។ មិនមែនយោគៈ ។បេ។ មិនមែននីវរណៈ ធម្មាយតនៈ ជានីវរណៈក៏មាន មិនមែននីវរណៈក៏មាន ។ អាយតនៈ ១០ ជាប្រយោជន៍ដល់នីវរណៈ អាយតនៈ ២ ជាប្រយោជន៍ ដល់នីវរណៈក៏មាន មិនជាប្រយោជន៍ដល់នីវរណៈក៏មាន ។ អាយតនៈ ១០ ប្រាសចាកនីវរណៈ អាយតនៈ ២ ប្រកបដោយនីវរណៈក៏មាន ប្រាសចាក នីវរណៈក៏មាន ។ អាយតនៈ ១០ មិនគប្បីពោលថា ជានីវរណៈ ទាំងជា ប្រយោជន៍ដល់នីវរណៈទេ ជាប្រយោជន៍ដល់នីវរណៈ តែមិនមែននីវរណៈ មនាយតនៈ មិនគប្បីពោលថា ជានីវរណៈ ទាំងជាប្រយោជន៍ដល់នីវរណៈ ឡើយ ជាប្រយោជន៍ដល់នីវរណៈ តែមិនមែននីវរណៈក៏មាន មិនគប្បី ពោលថា ជាប្រយោជន៍ដល់នីវរណៈ តែមិនមែននីវរណៈក៏មាន ធម្មាយតនៈ ជានីវរណៈ ទាំងជាប្រយោជន៍ដល់នីវរណៈក៏មាន ជាប្រយោជន៍ដល់នីវរណៈ តែមិនមែននីវរណៈក៏មាន មិនគប្បីពោលថា ជានីវរណៈ ទាំងជាប្រយោជន៍ ដល់នីវរណៈផង ថាជាប្រយោជន៍ដល់នីវរណៈ តែមិនមែនជានីវរណៈផងក៏ មាន ។ អាយតនៈ ១០ មិនគប្បីពោលថា ជានីវរណៈ ទាំងប្រកបដោយ នីវរណៈផង ថាប្រកបដោយនីវរណៈ តែមិនមែននីវរណៈផងឡើយ មនា- យតនៈ មិនគប្បីពោលថា ជានីវរណៈ ទាំងប្រកបដោយនីវរណៈទេ ប្រកប ដោយនីវរណៈ តែមិនមែននីវរណៈក៏មាន មិនគប្បីពោលថា ប្រកបដោយ

នីវរណៈ តែមិនមែននីវរណៈក៏មាន ធម្មាយតនៈ ជានីវរណៈ ទាំងប្រកប ដោយនីវរណៈក៏មាន ប្រកបដោយនីវរណៈ តែមិនមែននីវរណៈក៏មាន មិន គប្បីពោលថា ជានីវរណៈ ទាំងប្រកបដោយនីវរណៈផង ថាប្រកបដោយ នីវរណៈ តែមិនមែនជានីវរណៈផងក៏មាន ។ អាយតនៈ ១០ ប្រាសចាក នីវរណៈ តែជាប្រយោជន៍ដល់នីវរណៈ អាយតនៈ ២ ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈក៏មាន ប្រាសចាកនីវរណៈ ទាំងមិនជា ប្រយោជន៍ដល់នីវរណៈក៏មាន មិនគប្បីពោលថា ប្រាសចាកនីវរណៈ តែជា ប្រយោជន៍ដល់នីវរណៈផង ថាប្រាសចាកនីវរណៈ ទាំងមិនជាប្រយោជន៍ ដល់នីវរណៈផងក៏មាន ។

[ ១០៩ ] អាយតនៈ ១១ មិនមែនបរាមាសទេ ធម្មាយតនៈ ជា បរាមាសក៏មាន មិនមែនបរាមាសក៏មាន ។ អាយតនៈ ១០ បរាមាស ស្ទាបអង្អែល អាយតនៈ ២ បរាមាសស្ទាបអង្អែលក៏មាន បរាមាសមិន ស្ទាបអង្អែលក៏មាន ។ អាយតនៈ ១០ ប្រាសចាកបរាមាស មនាយតនៈ ប្រកបដោយបរាមាសក៏មាន ប្រាសចាកបរាមាសក៏មាន ធម្មាយតនៈ ប្រកបដោយបរាមាសក៏មាន ប្រាសចាកបរាមាសក៏មាន មិនគប្បីពោលថា ប្រកបដោយបរាមាសផង ថាប្រាសចាកបរាមាសផងក៏មាន ។ អាយតនៈ ១០ មិនគប្បីពោលថា ជាបរាមាស ទាំងបរាមាសស្ទាបអង្អែលឡើយ បរាមាសស្ទាបអង្អែល តែមិនមែនបរាមាស មនាយតនៈ មិនគប្បីពោល ថា ជាបរាមាស ទាំងបរាមាសស្ទាបអង្អែលទេ បរាមាសស្ទាបអង្អែល

តែមិនមែនបរាមាសក៏មាន មិនគប្បីពោលថា បរាមាសស្ទាបអង្អែល តែមិនមែនបរាមាសក៏មាន ធម្មាយតនៈ ជាបរាមាស ទាំងបរាមាសស្ទាបអង្អែលក៏មាន បរាមាសស្ទាបអង្អែល តែមិនមែនបរាមាសក៏មាន មិនគប្បីពោលថា ជាបរាមាស ទាំងបរាមាសស្ទាបអង្អែលផង ថាបរាមាសស្ទាបអង្អែល តែមិនមែនបរាមាសផងក៏មាន ។ អាយតនៈ ១០ ប្រាសចាកបរាមាស តែបរាមាសស្ទាបអង្អែល អាយតនៈ ២ ប្រាសចាកបរាមាស តែបរាមាសស្ទាបអង្អែលក៏មាន ប្រាសចាកបរាមាស ទាំងបរាមាសមិនស្ទាបអង្អែលក៏មាន មិនគប្បីពោលថា ប្រាសចាកបរាមាស តែបរាមាសស្ទាបអង្អែលផង ថាប្រាសចាកបរាមាស ទាំងបរាមាសមិនស្ទាបអង្អែលផងក៏មាន ។

[ ១១០ ] អាយតនៈ ១០ មិនមានអារម្មណ៍ មនាយតនៈ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ធម្មាយតនៈ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ក៏មាន មិនមានអារម្មណ៍ក៏មាន ។ មនាយតនៈ ជាចិត្ត អាយតនៈ ១១ មិនមែនចិត្ត ។ អាយតនៈ ១១ មិនមែនចេតសិក ធម្មាយតនៈ ជាចេតសិកក៏មាន មិនមែនចេតសិកក៏មាន ។ អាយតនៈ ១០ ប្រាសចាកចិត្ត ធម្មាយតនៈ ប្រកបដោយចិត្តក៏មាន ប្រាសចាកចិត្តក៏មាន មនាយតនៈ មិនគប្បីពោលថា ប្រកបដោយចិត្តផង ថាប្រាសចាកចិត្តផងឡើយ ។ អាយតនៈ ១០ មិនច្រឡំដោយចិត្ត ធម្មាយតនៈ ច្រឡំដោយចិត្តក៏មាន មិនច្រឡំដោយចិត្តក៏មាន មនាយតនៈ មិនគប្បីពោលថា ច្រឡំដោយចិត្តផង ថាមិនច្រឡំដោយចិត្តផងឡើយ ។

អាយតនៈ ៦ មិនមែនតាំងឡើងដោយចិត្ត អាយតនៈ ៦ តាំងឡើងដោយចិត្តក៏មាន មិនមែនតាំងឡើងដោយចិត្តក៏មាន ។ អាយតនៈ ១១ មិនមែនកើតជាមួយនឹងចិត្ត ធម្មាយតនៈ កើតជាមួយនឹងចិត្តក៏មាន មិនមែនកើតជាមួយនឹងចិត្តក៏មាន ។ អាយតនៈ ១១ មិនមែនប្រព្រឹត្តទៅតាមចិត្ត ធម្មាយតនៈ ប្រព្រឹត្តទៅតាមចិត្តក៏មាន មិនមែនប្រព្រឹត្តទៅតាមចិត្តក៏មាន ។ អាយតនៈ ១១ មិនប្រឡំ មិនតាំងឡើងដោយចិត្ត ធម្មាយតនៈ ប្រឡំ ទាំងតាំងឡើងដោយចិត្តក៏មាន មិនប្រឡំ មិនតាំងឡើងដោយចិត្តក៏មាន អាយតនៈ ១១ មិនប្រឡំ មិនតាំងឡើង មិនកើតជាមួយនឹងចិត្ត ធម្មាយតនៈ ប្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្តក៏មាន មិនប្រឡំ មិនតាំងឡើង មិនកើតជាមួយនឹងចិត្តក៏មាន ។ អាយតនៈ ១១ មិនប្រឡំ មិនតាំងឡើង មិនប្រព្រឹត្តទៅតាមចិត្ត ធម្មាយតនៈ ប្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្តក៏មាន មិនប្រឡំ មិនតាំងឡើង មិនប្រព្រឹត្តទៅតាមចិត្តក៏មាន ។ អាយតនៈ ៦ ជាខាងក្នុង អាយតនៈ ៦ ជាខាងក្រៅ ។ អាយតនៈ ៩ ជាឧបាទា អាយតនៈ ២ មិនមែនជាឧបាទា ធម្មាយតនៈ ជាឧបាទាក៏មាន មិនមែនជាឧបាទាក៏មាន ។ អាយតនៈ ៥ ជាឧបាទិន្ន សទ្ទាយតនៈ ជាអនុបាទិន្ន អាយតនៈ ៦ ជាឧបាទិន្នក៏មាន ជាអនុបាទិន្នក៏មាន ។

[ ១១១ ] អាយតនៈ ១១ មិនមែនឧបាទាន ធម្មាយតនៈ ជាឧបាទានក៏មាន មិនមែនឧបាទានក៏មាន ។ អាយតនៈ ១០ ជាប្រយោជន៍ដល់ឧបាទាន អាយតនៈ ២ ជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមែនជាប្រយោជន៍ដល់

ឧបាទានក៏មាន ។ អាយតនៈ ១០ ប្រាសចាកឧបាទាន អាយតនៈ ២ ប្រកប ដោយឧបាទានក៏មាន ប្រាសចាកឧបាទានក៏មាន ។ អាយតនៈ ១០ មិនគប្បី ពោលថា ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានឡើយ ជាប្រយោជន៍ ដល់ឧបាទាន តែមិនមែនឧបាទាន មនាយតនៈ មិនគប្បីពោលថាជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានទេ ជាប្រយោជន៍ដល់ឧបាទាន តែមិនមែន ឧបាទានក៏មាន មិនគប្បីពោលថា ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជា ឧបាទានក៏មាន ធម្មាយតនៈ ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានក៏ មាន ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនឧបាទានក៏មាន មិនគប្បីពោល ថា ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានផង ថាជាប្រយោជន៍ដល់ ឧបាទាន តែមិនមែនជាឧបាទានផងក៏មាន ។ អាយតនៈ ១០ មិនគប្បីពោល ថា ជាឧបាទាន ទាំងប្រកបដោយឧបាទានផង ថាប្រកបដោយឧបាទាន តែ មិនមែនឧបាទានផងឡើយ មនាយតនៈ មិនគប្បីពោលថា ជាឧបាទាន ទាំង ប្រកបដោយឧបាទានទេ ប្រកបដោយឧបាទាន តែមិនមែនឧបាទានក៏មាន មិនគប្បីពោលថា ប្រកបដោយឧបាទាន តែមិនមែនឧបាទានក៏មាន ធម្មា-យតនៈ ជាឧបាទាន ទាំងប្រកបដោយឧបាទានក៏មាន ប្រកបដោយឧបាទាន តែមិនមែនឧបាទានក៏មាន មិនគប្បីពោលថា ជាឧបាទាន ទាំងប្រកបដោយ ឧបាទានផង ថាប្រកបដោយឧបាទាន តែមិនមែនឧបាទានផងក៏មាន ។ អាយតនៈ ១០ ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទាន អាយតនៈ ២ ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទានក៏មាន ប្រាស

ចាកឧបាទាន ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន មិនគប្បីពោលថា ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទានផង ថាប្រាសចាកឧបាទាន ទាំងមិនជាប្រយោជន៍ដល់ឧបាទានផងក៏មាន ។

[ ១១២ ] អាយតនៈ ១១ មិនមែនកិលេស ធម្មាយតនៈ ជាកិលេសក៏មាន មិនមែនកិលេសក៏មាន ។ អាយតនៈ ១០ គួរដល់សេចក្តីសៅហ្មង អាយតនៈ ២ គួរដល់សេចក្តីសៅហ្មងក៏មាន មិនគួរដល់សេចក្តីសៅហ្មងក៏មាន ។ អាយតនៈ ១០ មិនសៅហ្មង អាយតនៈ ២ សៅហ្មងក៏មាន មិនសៅហ្មងក៏មាន ។ អាយតនៈ ១០ ប្រាសចាកកិលេស អាយតនៈ ២ ប្រកបដោយកិលេសក៏មាន ប្រាសចាកកិលេសក៏មាន ។ អាយតនៈ ១០ មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មងឡើយ គួរដល់សេចក្តីសៅហ្មង តែមិនមែនជាសេចក្តីសៅហ្មង មនាយតនៈ មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មងទេ គួរដល់សេចក្តីសៅហ្មង តែមិនមែនជាសេចក្តីសៅហ្មងក៏មាន មិនគប្បីពោលថា គួរដល់សេចក្តីសៅហ្មង តែមិនមែនជាសេចក្តីសៅហ្មងក៏មាន ធម្មាយតនៈ ជាសេចក្តីសៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មងក៏មាន គួរដល់សេចក្តីសៅហ្មង តែមិនជាសេចក្តីសៅហ្មងក៏មាន មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មងផង ថាគួរដល់សេចក្តីសៅហ្មង តែមិនមែនជាសេចក្តីសៅហ្មងផងក៏មាន ។ អាយតនៈ ១០ មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងសៅហ្មងហើយផង ថាសៅហ្មងហើយ តែមិនមែនជាសេចក្តីសៅហ្មង

ផងទេ មនាយតនៈ មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងសៅហ្មងហើយឡើយ សៅហ្មងហើយ តែមិនមែនជាសេចក្តីសៅហ្មងក៏មាន មិនគប្បីពោលថា សៅហ្មងហើយ តែមិនមែនជាសេចក្តីសៅហ្មងក៏មាន ធម្មាយតនៈ ជាសេចក្តីសៅហ្មង ទាំងសៅហ្មងហើយក៏មាន សៅហ្មងហើយ តែមិនមែនជាសេចក្តីសៅហ្មងក៏មាន មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងសៅហ្មងហើយផង ជាសៅហ្មងហើយ តែមិនមែនជាសេចក្តីសៅហ្មងផងក៏មាន ។ អាយតនៈ ១០ មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងប្រកបដោយសេចក្តីសៅហ្មងផង ជាប្រកបដោយសេចក្តីសៅហ្មង តែមិនមែនសេចក្តីសៅហ្មងផងទេ មនាយតនៈ មិនគប្បីពោលថាជាសេចក្តីសៅហ្មង ទាំងប្រកបដោយសេចក្តីសៅហ្មងឡើយ ប្រកបដោយសេចក្តីសៅហ្មង តែមិនមែនជាសេចក្តីសៅហ្មងក៏មាន មិនគប្បីពោលថា ប្រកបដោយសេចក្តីសៅហ្មង តែមិនមែនជាសេចក្តីសៅហ្មងក៏មាន ធម្មាយតនៈ ជាសេចក្តីសៅហ្មង ទាំងប្រកបដោយសេចក្តីសៅហ្មងក៏មាន ប្រកបដោយសេចក្តីសៅហ្មង តែមិនមែនជាសេចក្តីសៅហ្មងក៏មាន មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងប្រកបដោយសេចក្តីសៅហ្មងផង ជាប្រកបដោយសេចក្តីសៅហ្មង តែមិនមែនជាសេចក្តីសៅហ្មងផងក៏មាន ។ អាយតនៈ ១០ ប្រាសចាកសេចក្តីសៅហ្មង តែគួរដល់សេចក្តីសៅហ្មង អាយតនៈ ២ ប្រាសចាកសេចក្តីសៅហ្មង តែគួរដល់សេចក្តីសៅហ្មងក៏មាន ប្រាសចាកសេចក្តីសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន មិនគប្បីពោលថា ប្រាសចាកសេចក្តីសៅហ្មង

តែគួរដល់សេចក្តីសៅហ្មងផង ជាប្រាសចាកសេចក្តីសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មងផងក៏មាន ។

[ ១១៣ ] អាយតនៈ ១០ មិនគួរលះដោយទស្សនៈ អាយតនៈ ២ គួរលះដោយទស្សនៈក៏មាន មិនគួរលះដោយទស្សនៈក៏មាន ។ អាយតនៈ ១០ មិនគួរលះដោយភាវនា អាយតនៈ ២ គួរលះដោយភាវនាក៏មាន មិនគួរលះដោយភាវនាក៏មាន ។ អាយតនៈ ១០ មានហេតុ មិនគួរលះដោយទស្សនៈ អាយតនៈ ២ មានហេតុ គួរលះដោយទស្សនៈក៏មាន មានហេតុ មិនគួរលះដោយទស្សនៈក៏មាន ។ អាយតនៈ ១០ មានហេតុ មិនគួរលះដោយភាវនា អាយតនៈ ២ មានហេតុ គួរលះដោយភាវនាក៏មាន មានហេតុ មិនគួរលះដោយភាវនាក៏មាន ។ អាយតនៈ ១០ មិនមានវិតក្ក អាយតនៈ ២ ប្រព្រឹត្តទៅជាមួយនឹងវិតក្កក៏មាន មិនមានវិតក្កក៏មាន ។ អាយតនៈ ១០ មិនមានវិចារ អាយតនៈ ២ ប្រព្រឹត្តទៅជាមួយនឹងវិចារក៏មាន មិនមានវិចារក៏មាន ។ អាយតនៈ ១០ មិនមានបីតិ អាយតនៈ ២ ប្រព្រឹត្តទៅជាមួយនឹងបីតិក៏មាន មិនមានបីតិក៏មាន ។ អាយតនៈ ១០ មិនកើតព្រមដោយបីតិ អាយតនៈ ២ កើតព្រមដោយបីតិក៏មាន មិនកើតព្រមដោយបីតិក៏មាន ។ អាយតនៈ ១០ មិនកើតព្រមដោយសុខ អាយតនៈ ២ កើតព្រមដោយសុខក៏មាន មិនកើតព្រមដោយសុខក៏មាន ។ អាយតនៈ ១០ មិនកើតព្រមដោយឧបេក្ខា អាយតនៈ ២ កើតព្រមដោយឧបេក្ខាក៏មាន មិនកើតព្រមដោយឧបេក្ខាក៏មាន ។ អាយតនៈ ១០ ជាកាមាវចរ អាយតនៈ ២ ជាកាមាវចរក៏មាន

មិនមែន កាមាវចរក៏មាន ។ អាយតនៈ ១០ មិនមែនរូបាវចរ អាយតនៈ ២ ជារូបាវចរក៏មាន មិនមែនរូបាវចរក៏មាន ។ អាយតនៈ ១០ មិនមែនអរូបាវចរ អាយតនៈ ២ ជាអរូបាវចរក៏មាន មិនមែនអរូបាវចរក៏មាន ។ អាយតនៈ ១០ ជាបរិយាបន្ន អាយតនៈ ២ ជាបរិយាបន្នក៏មាន ជាអបរិយាបន្នក៏មាន ។ អាយតនៈ ១០ មិនមែននិយ្យានិកៈ អាយតនៈ ២ ជានិយ្យានិកៈក៏មាន មិនមែននិយ្យានិកៈក៏មាន ។ អាយតនៈ ១០ មិនទៀង អាយតនៈ ២ ទៀងក៏មាន មិនទៀងក៏មាន ។ អាយតនៈ ១០ ប្រព្រឹត្តទៅជាមួយនឹងឧត្តរៈ អាយតនៈ ២ ប្រព្រឹត្តទៅជាមួយនឹងឧត្តរៈក៏មាន មិនមានឧត្តរៈក៏មាន ។ អាយតនៈ ១០ មិនមានសត្រូវ អាយតនៈ ២ ប្រព្រឹត្តទៅជាមួយនឹងសត្រូវក៏មាន មិនមានសត្រូវក៏មាន ។

បញ្ហាបុច្ឆកៈ ចប់

អាយតនវិភង្គ ចប់

# អដ្ឋកថា

## បញ្ហាបុច្ឆកៈ

[ ១០១-១១៣ ] ក្នុងបញ្ហាបុច្ឆកៈ ក្នុងអាយតនវិភង្គនេះ អាយតនៈណាដែលបាន អាយតនៈណាដែលមិនបាន ព្រះអង្គត្រាស់សួរអាយតនៈទាំងអស់នោះហើយ ទ្រង់វិសជ្ជនាដោយអំណាចនៃអាយតនៈដែលបានប៉ុណ្ណោះ មិនមែនតែក្នុងទីនេះប៉ុណ្ណោះទេ ក្នុងបញ្ហាបុច្ឆកៈទាំងអស់ ក៏ន័យនេះឯង ។ ក្នុងអាយតនៈទាំងអស់ក្នុងទីនេះ គប្បីជ្រាបថា អាយតនៈ ១០ ជាអព្យាកតដោយភាពជារូប គប្បីជ្រាបថា អាយតនៈ ២ ជាកុសលជាដើម ដូចខន្ធ ៤ ក្នុងខន្ធវិភង្គ ជាកុសលជាដើម ពិតហើយ ខន្ធ ៤ ជាធម៌មានបច្ច័យផងជាសង្ខតៈផង តែធម្មាយតនៈ មកហើយថា ជាអបច្ច័យក៏មាន ជាអសង្ខតៈក៏មាន ។ ម្យ៉ាងទៀត ក្នុងអារម្មណត្តិកៈ ធម្មាយតនៈដែលជាសុខុមរូបដែលជាអនារម្មណៈ រមែងចូលគ្នាបានជាមួយចំណែកនៃអារម្មណ៍ដែលជានវត្តព្វារម្មណៈ ( អារម្មណ៍ដែលគប្បីពោលមិនបាន ) ។ ការប្រែកគ្នាក្នុងអាយតនវិភង្គនេះ គឺធម្មាយតនៈនោះ ចូលគ្នាបាននឹងចំណែកនៃនវត្តព្វារម្មណ៍ ។ រមែងចូលគ្នាមិនបាននឹងចំណែកនៃនវត្តព្វារម្មណ៍ ព្រោះជាធម្មារម្មណ៍ដែលពោលមិនបានដោយភាពជាបរិត្តារម្មណ៍ជាដើម ។ ពាក្យដ៏សេសដូចគ្នានោះឯង ។ អាយតនៈ ២ ក្នុងទីនេះក៏ដូចខន្ធ ៤ រមែងជាបរិត្តារម្មណ៍ដល់បុគ្គល

ដែលត្រេកអរ ដែលអាក់អន់ ដែលវង្វេង ដែលសង្រួម ដែលពិចារណា ដែលសម្លឹងឃើញ ដែលប្រារព្ធកាមាវចរធម៌ ៥៥ ប្រការ ព្រោះហេតុនោះ ពាក្យទាំងអស់ ដូចគ្នានឹងពាក្យដែលបានពោលហើយ ក្នុងខន្ធទាំងឡាយ នោះឯង ដូច្នេះ ។

**អាយតនវិភង្គ ចប់**

# អភិធម្មបិដក

## ធាតុវិភង្គ

[ ១១៤ ] ធាតុ ៦ គឺបឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ អាកាសធាតុ វិញ្ញាណធាតុ ។

[ ១១៥ ] បណ្ដាធាតុ ៦ នោះ បឋវីធាតុ តើដូចម្ដេច ។ បឋវីធាតុមាន ២ គឺបឋវីធាតុខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ បណ្ដាធាតុ ២ នោះ បឋវីធាតុខាងក្នុង តើដូចម្ដេច ។ ធម្មជាតណាជាខាងក្នុង អាស្រ័យនូវខ្លួន រឹង ខះ មានអាការរឹង មានសភាពរឹង ជាខាងក្នុង ដែលវិញ្ញាណចូលទៅកាន់យកបាន គឺសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ឬក៏ធម្មជាតដទៃណាជាខាងក្នុង អាស្រ័យនូវខ្លួន រឹង ខះ មានអាការរឹង មានសភាពរឹង ជាខាងក្នុង ដែលវិញ្ញាណចូលទៅកាន់យកបាន នេះហៅថា បឋវីធាតុខាងក្នុង ។ បណ្ដាធាតុ ២ នោះ បឋវីធាតុខាងក្រៅ តើដូចម្ដេច ។ ធម្មជាតណាជាខាងក្រៅ រឹង ខះ មានអាការរឹង មានសភាពរឹង ជាខាងក្រៅ ដែលវិញ្ញាណមិនចូលទៅកាន់យកបានទេ គឺដែក លោហៈ សំណប៉ាហាំង សំណាកក់ ប្រាក់ កែវមុក្តា កែវមណី កែវពៃទូរ្យ ស័ង្ខ ថ្ម កែវប្រពាល ប្រាក់ មាស កែវក្រហម កែវពព្រុស ស្មៅ ឈើ ក្រួស អំបែង ផែនដី ថ្ម ភ្នំ ឬក៏ធម្មជាតុដទៃណាជាខាងក្រៅ រឹង ខះ មានអាការរឹង មានសភាពរឹង ជាខាងក្រៅ ដែលវិញ្ញាណមិនចូលទៅកាន់យកបានទេ នេះហៅថា បឋវីធាតុខាងក្រៅ ។ បឋវី-

ធាតុណា ជាខាងក្នុងក្តី បឋវីធាតុណា ជាខាងក្រៅក្តី នេះហៅថា បឋវីធាតុ ព្រោះប្រមូលបង្រួញធាតុនោះ ក្នុងទីជាមួយគ្នា ។

[ ១១៦ ] បណ្តាធាតុ ៦ នោះ អាបោធាតុ តើដូចម្តេច ។ អាបោធាតុមាន ២ គឺអាបោធាតុខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ បណ្តាធាតុ ២ នោះ អាបោធាតុខាងក្នុង តើដូចម្តេច ។ ធម្មជាតណា ជាខាងក្នុង អាស្រ័យនូវខ្លួន ជាទឹក ដល់នូវភាពជាទឹក មានសភាពស្អិត ដល់នូវភាពស្អិត មានសភាពជាទីជាប់នៅនៃរូបជាខាងក្នុង ដែលវិញ្ញាណចូលទៅកាន់យកបាន គឺប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករម្អិល ទឹកមូត្រ ឬក៏ធម្មជាតដទៃណា ជាខាងក្នុង អាស្រ័យនូវខ្លួន ជាទឹក ដល់នូវភាពជាទឹក មានសភាពស្អិត ដល់នូវភាពស្អិត មានសភាពជាទីជាប់នៅនៃរូប ជាខាងក្នុង ដែលវិញ្ញាណចូលទៅកាន់យកបាន នេះហៅថា អាបោធាតុខាងក្នុង ។ បណ្តាធាតុ ២ នោះ អាបោធាតុខាងក្រៅ តើដូចម្តេច ។ ធម្មជាតណា ជាខាងក្រៅ ជាទឹក ដល់នូវភាពជាទឹក មានសភាពស្អិត ដល់នូវភាពស្អិត មានសភាពជាទីជាប់នៅនៃរូប ជាខាងក្រៅ ដែលវិញ្ញាណមិនចូលទៅកាន់យកបានទេ គឺរសគល់ រសដើម រសសម្បក រសស្លឹក រសផ្កា រសផ្លែ ទឹកដោះស្រស់ ទឹកដោះជូរ ទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ ទឹកដែលស្ថិតនៅលើផែនដីក្តី ទឹកដែលស្ថិតនៅឰដ៏អាកាសក្តី ឬក៏ធម្មជាតដទៃណា ជាខាងក្រៅ ជាទឹក ដល់នូវភាពជាទឹក មានសភាពស្អិត ដល់នូវភាពស្អិត មានសភាពជាទីជាប់នៅ

នៃរូប ជាខាងក្រៅ ដែលវិញ្ញាណមិនចូលទៅកាន់យកបានទេ នេះហៅថា អាបោធាតុខាងក្រៅ ។ អាបោធាតុណា ជាខាងក្នុងក្ដី អាបោធាតុណា ជាខាងក្រៅក្ដី នេះហៅថា អាបោធាតុ ព្រោះប្រមូលបំព្រួញធាតុនោះ ក្នុងទីជាមួយគ្នា ។

[ ១១៧ ] បណ្ដាធាតុ ៦ នោះ តេជោធាតុ តើដូចម្ដេច ។ តេជោធាតុមាន ២ គឺតេជោធាតុខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ បណ្ដាធាតុ ២ នោះ តេជោធាតុខាងក្នុង តើដូចម្ដេច ។ ធម្មជាតណា ជាខាងក្នុង អាស្រ័យនូវខ្លួន ជាសភាពក្ដៅ ដល់នូវសភាពក្ដៅ ជាចំហាយ ដល់នូវភាពចំហាយ ជាធម្មជាតអប់កម្ដៅ ដល់នូវភាពអប់កម្ដៅជាខាងក្នុង ដែលវិញ្ញាណចូលទៅកាន់យកបាន គឺភ្លើងដែលឲ្យកាយក្ដៅសព្វ ១ ដែលឲ្យកាយគ្រាំគ្រា ១ ដែលឲ្យកាយក្ដៅក្រហាយ ១ ដែលឲ្យវត្ថុគេស៊ី ផឹក ទំពា លិទ្ធភក្សហើយដល់នូវការទ្រុឌទ្រោម រលួយអស់ ១ ឬក៏ធម្មជាតដទៃណា ជាខាងក្នុង អាស្រ័យនូវខ្លួន ជាសភាពក្ដៅ ដល់នូវភាពក្ដៅ ជាចំហាយ ដល់នូវភាពចំហាយ ជាធម្មជាតអប់កម្ដៅ ដល់នូវភាពអប់កម្ដៅជាខាងក្នុង ដែលវិញ្ញាណចូលទៅកាន់យកបាន នេះហៅថា តេជោធាតុខាងក្នុង ។ បណ្ដាធាតុ ២ នោះ តេជោធាតុខាងក្រៅ តើដូចម្ដេច ។ ធម្មជាតណា ជាខាងក្រៅ ជាភាពក្ដៅ ដល់នូវភាពក្ដៅ ជាចំហាយ ដល់នូវភាពចំហាយ ជាធម្មជាតអប់កម្ដៅ ដល់នូវភាពអប់កម្ដៅ ជាខាងក្រៅ ដែលវិញ្ញាណមិនចូលទៅកាន់យកបានទេ គឺភ្លើងឧស ភ្លើងកំកាច់ ភ្លើងស្មៅ ភ្លើងអាចម៍គោ ភ្លើងអង្កាម ភ្លើងសំរាម

ភ្លើងរន្ទះ កម្តៅភ្លើង កម្តៅព្រះអាទិត្យ កម្តៅគំនរឧស កម្តៅគំនរស្មៅ កម្តៅគំនរស្រូវ កម្តៅគំនរផេះ ឬក៏ធម្មជាតដទៃណា ជាខាងក្រៅ ជាសភាពក្តៅ ដល់នូវសភាពក្តៅ ជាចំហាយ ដល់នូវភាពចំហាយ ជាធម្មជាតអប់កម្តៅ ដល់នូវភាពអប់កម្តៅ ជាខាងក្រៅ ដែលវិញ្ញាណមិនចូលទៅកាន់យកបានទេ នេះហៅថា តេជោធាតុខាងក្រៅ ។ តេជោធាតុណា ជាខាងក្នុងក្តី តេជោធាតុណា ជាខាងក្រៅក្តី នេះហៅថា តេជោធាតុ ព្រោះប្រមូលបង្រួញធាតុនោះ ក្នុងទីជាមួយគ្នា ។

[ ១១៨ ] បណ្តាធាតុ ៦ នោះ វាយោធាតុ តើដូចម្តេច ។ វាយោធាតុមាន ២ គឺវាយោធាតុខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ បណ្តាធាតុ ២ នោះ វាយោធាតុខាងក្នុង តើដូចម្តេច ។ ធម្មជាតណា ជាខាងក្នុង អាស្រ័យនូវខ្លួន ជាសភាពបក់ផាត់ ដល់នូវភាពបក់ផាត់ មានភាពធ្វើនូវរូប ឲ្យរឹងប៉ឹង ជាខាងក្នុង ដែលវិញ្ញាណចូលទៅកាន់យកបាន គឺខ្យល់បក់ពីក្រោមឡើងលើ ខ្យល់បក់ពីលើទៅក្រោម ខ្យល់ដេកនៅខាងក្នុងផ្ទៃ ( ខ្យល់ខាងក្រៅពោះវៀន ) ខ្យល់ដេកនៅក្នុងក្រពះ ( ខ្យល់ខាងក្នុងពោះវៀន ) ខ្យល់បក់ផ្សព្វផ្សាយសព្វអវយវៈតូចធំ ខ្យល់ដូចជាសស្ត្រា ខ្យល់ដូចជាកាំបិតកោរ ខ្យល់អាចពន្ទះនូវហឫទ័យ ខ្យល់ដកដង្ហើមចូល ខ្យល់ដកដង្ហើមចេញ ឬក៏ធម្មជាតដទៃណាជាខាងក្នុង អាស្រ័យនូវខ្លួន ជាសភាពបក់ផាត់ ដល់នូវភាពបក់ផាត់ មានភាពធ្វើរូបឲ្យរឹងប៉ឹង ជាខាងក្នុង ដែលវិញ្ញាណចូលទៅកាន់យកបាន នេះហៅថា វាយោធាតុខាងក្នុង ។ បណ្តាធាតុ ២ នោះ វាយោ-

ធាតុខាងក្រៅ តើដូចម្តេច ។ ធម្មជាតណា ជាខាងក្រៅ ជាសភាពបក់ផាត់ ដល់នូវភាពបក់ផាត់ មានភាពផ្សើរឲ្យរឹងប៉ឹង ជាខាងក្រៅ ដែលវិញ្ញាណមិនចូលទៅកាន់យកបានទេ គឺខ្យល់បក់មកអំពីទិសខាងកើត ខ្យល់បក់មកអំពីទិសខាងលិច ខ្យល់បក់មកអំពីទិសខាងជើង ខ្យល់បក់មកអំពីទិសខាងត្បូង ខ្យល់ប្រកបដោយធូលី ខ្យល់មិនមានធូលី ខ្យល់ត្រជាក់ ខ្យល់ក្តៅ ខ្យល់តិច ខ្យល់ខ្លាំង ខ្យល់ខ្មៅ ខ្យល់កំបុតត្បូង ខ្យល់ដែលតាំងឡើងអំពីស្លាបសត្វ ខ្យល់ដែលតាំងឡើងអំពីគ្រុឌ ខ្យល់ដែលតាំងឡើងអំពីស្លឹកត្នោតជាដើម ខ្យល់ដែលតាំងឡើងអំពីផ្លិត ឬក៏ធម្មជាតដទៃណា ជាខាងក្រៅ ជាសភាពបក់ផាត់ ដល់នូវភាពបក់ផាត់ មានភាពផ្សើរឲ្យរឹងប៉ឹង ជាខាងក្រៅ ដែលវិញ្ញាណមិនចូលទៅកាន់យកបានទេ នេះហៅថា វាយោធាតុខាងក្រៅ ។ វាយោធាតុណា ជាខាងក្នុងក្តី វាយោធាតុណា ជាខាងក្រៅក្តី នេះហៅថា វាយោធាតុ ព្រោះប្រមូលបង្រួញធាតុនោះ ក្នុងទីជាមួយគ្នា ។

[ ១១៩ ] បណ្តាធាតុ ៦ នោះ អាកាសធាតុ តើដូចម្តេច ។ អាកាសធាតុមាន ២ គឺអាកាសធាតុខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ បណ្តាធាតុ ២ នោះ អាកាសធាតុខាងក្នុង តើដូចម្តេច ។ ធម្មជាតណា ជាខាងក្នុង អាស្រ័យនូវខ្លួន ជាសភាពទទេ ដល់នូវភាពទទេ ជាធម្មជាតទំនេរ ដល់នូវភាពទំនេរ ជាសភាពចន្លោះ ដល់នូវភាពចន្លោះ ជាធម្មជាតមិនប៉ះពាល់ដោយសាច់ និងឈាម ជាខាងក្នុង ដែលវិញ្ញាណចូលទៅកាន់យកបាន គឺរន្ធត្រចៀក រន្ធច្រមុះ ទ្វារមាត់ អាកាសដែលឲ្យលេបចូលនូវវត្ថុដែលគេស៊ី

ផឹក ទំពា លិទ្ធភ្លក្សហើយក្តី អាកាសដែលឲ្យវត្ថុដែលគេស៊ី ផឹក ទំពា លិទ្ធភ្លក្សហើយក្តី អាកាសដែលឲ្យវត្ថុ ដែលគេស៊ី ផឹក ទំពា លិទ្ធភ្លក្ស ហើយចេញមកតាមចំណែកខាងក្រោមក្តី ឬក៏ធម្មជាតដទៃណា ជាខាងក្នុង អាស្រ័យនូវខ្លួន ជាសភាពទទេ ដល់នូវភាពទទេ ជាធម្មជាតទំនេរ ដល់នូវភាពទំនេរ ជាសភាពចន្លោះ ដល់នូវភាពចន្លោះ មិនប៉ះពាល់ដោយសាច់និងឈាម ជាខាងក្នុង ដែលវិញ្ញាណចូលទៅកាន់យកបាន នេះហៅថា អាកាសធាតុខាងក្នុង ។ បណ្តាធាតុ ២ នោះ អាកាសធាតុខាងក្រៅ តើដូចម្តេច ។ ធម្មជាតណា ជាខាងក្រៅ ជាសភាពទទេ ដល់នូវភាពទទេ ជាធម្មជាតទំនេរ ដល់នូវភាពទំនេរ ជាសភាពចន្លោះ ដល់នូវភាពចន្លោះ មិនប៉ះពាល់ដោយមហាភូតរូប ៤ ជាខាងក្រៅ ដែលវិញ្ញាណមិនចូលទៅកាន់យកបានទេ នេះហៅថា អាកាសធាតុខាងក្រៅ ។ អាកាសធាតុណា ជាខាងក្នុងក្តី អាកាសធាតុណា ជាខាងក្រៅក្តី នេះហៅថា អាកាសធាតុ ព្រោះប្រមូលបង្រួញធាតុនោះ ក្នុងទីជាមួយគ្នា ។

[ ១២០ ] បណ្តាធាតុ ៦ នោះ វិញ្ញាណធាតុ តើដូចម្តេច ។ ធាតុ គឺការដឹងច្បាស់ដោយចក្ខុ ធាតុ គឺការដឹងច្បាស់ដោយត្រចៀក ធាតុ គឺការដឹងច្បាស់ដោយច្រមុះ ធាតុ គឺការដឹងច្បាស់ដោយអណ្តាត ធាតុ គឺការដឹងច្បាស់ដោយកាយ ធាតុ គឺការដឹងច្បាស់ដោយចិត្ត នេះហៅថា វិញ្ញាណធាតុ ។

**នេះធាតុ ៦ ។**

[ ១២១ ] ធាតុ ៦ ដទៃទៀត គឺសុខធាតុ ទុក្ខធាតុ សោមនស្សធាតុ ទោមនស្សធាតុ ឧបេក្ខាធាតុ អវិជ្ជាធាតុ ។ បណ្ដាធាតុ ៦ នោះ សុខធាតុ តើដូចម្ដេច ។ សេចក្ដីឆ្ងាញ់ពីសា ប្រព្រឹត្តទៅក្នុងកាយ សេចក្ដីសុខប្រព្រឹត្តទៅក្នុងកាយ ការទទួលអារម្មណ៍ជាសុខ ជាទីគាប់ចិត្ត ដែលកើតអំពីកាយសម្ផស្ស សុខវេទនាជាទីគាប់ចិត្ត ដែលកើតអំពីកាយសម្ផស្សណា នេះហៅថា សុខធាតុ ។ បណ្ដាធាតុ ៦ នោះ ទុក្ខធាតុ តើដូចម្ដេច ។ សេចក្ដីមិនឆ្ងាញ់ពីសាប្រព្រឹត្តទៅក្នុងកាយ សេចក្ដីទុក្ខប្រព្រឹត្តទៅក្នុងកាយ ការទទួលអារម្មណ៍ជាទុក្ខ មិនជាទីគាប់ចិត្ត ដែលកើតអំពីកាយសម្ផស្ស ទុក្ខវេទនាមិនជាទីគាប់ចិត្តដែលកើតអំពីកាយសម្ផស្សណា នេះហៅថា ទុក្ខធាតុ ។ បណ្ដាធាតុ ៦ នោះ សោមនស្សធាតុ តើដូចម្ដេច ។ សេចក្ដីឆ្ងាញ់ពីសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីសុខប្រព្រឹត្តទៅក្នុងចិត្ត កិរិយាទទួលអារម្មណ៍ជាសុខ ជាទីគាប់ចិត្ត ដែលកើតអំពីចេតោសម្ផស្ស សុខវេទនាជាទីគាប់ចិត្ត ដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា សោមនស្សធាតុ ។ បណ្ដាធាតុ ៦ នោះ ទោមនស្សធាតុ តើដូចម្ដេច ។ សេចក្ដីមិនឆ្ងាញ់ពីសា ប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីទុក្ខប្រព្រឹត្តទៅក្នុងចិត្ត កិរិយាទទួលអារម្មណ៍ជាទុក្ខ មិនជាទីគាប់ចិត្ត ដែលកើតអំពីចេតោសម្ផស្ស ទុក្ខវេទនាមិនជាទីគាប់ចិត្ត ដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា ទោមនស្សធាតុ ។ បណ្ដាធាតុ ៦ នោះ ឧបេក្ខាធាតុ តើដូចម្ដេច ។ សេចក្ដីមិនឆ្ងាញ់ពីសា មិនមែនជាមិនឆ្ងាញ់ពីសា ប្រព្រឹត្តទៅក្នុងចិត្ត កិរិយាទទួលអារម្មណ៍ មិនមែនទុក្ខ មិនមែនសុខ ដែល

កើតអំពីចេតោសម្ផស្ស វេទនាមិនមែនទុក្ខ មិនមែនសុខ ដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា ឧបេក្ខាធាតុ ។ បណ្តាធាតុ ៦ នោះ អវិជ្ជាធាតុ តើដូចម្តេច ។ ការមិនដឹង ការមិនឃើញ ។បេ។ អវិជ្ជាដូចគន្លឹះ គឺមោហៈ ជាឫសនៃអកុសលណា នេះហៅថា អវិជ្ជាធាតុ ។

## នេះធាតុ ៦ ។

[ ១២២ ] ធាតុ ៦ ដទៃទៀត គឺកាមធាតុ ព្យាបាទធាតុ វិហឹសាធាតុ នេក្ខម្មធាតុ អព្យាបាទធាតុ អវិហឹសាធាតុ ។ បណ្តាធាតុ ៦ នោះ កាមធាតុ តើដូចម្តេច សេចក្តីត្រិះរិះ ការត្រិះរិះផ្សេងៗ តម្រិះ ការរំពឹង ការជញ្ជឹង ការលើកឡើងនូវចិត្តដែលប្រកបដោយកាម គឺមិច្ឆាសង្កប្ប នេះហៅថា កាមធាតុ ។ ខាងក្រោមតាំងអំពីអវិចិនរកជាទីបំផុត ខាងលើតាំងអំពីបរនិម្មិតវសវត្តីទេវតាជាទីបំផុត ខន្ធ ធាតុ អាយតនៈ រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណណា មានក្នុងចន្លោះនេះ ត្រាច់ចុះក្នុងចន្លោះនេះ រាប់បញ្ចូលក្នុងចន្លោះនេះ នេះហៅថា កាមធាតុ ។ បណ្តាធាតុ ៦ នោះ ព្យាបាទធាតុ តើដូចម្តេច ។ សេចក្តីត្រិះរិះ ការត្រិះរិះផ្សេងៗ ។បេ។ ដែលប្រកបដោយព្យាបាទ គឺមិច្ឆាសង្កប្ប នេះហៅថា ព្យាបាទធាតុ ។ មួយទៀត សេចក្តីគុំគួន ការចង្អៀតចង្អល់ ការតានតឹង ការថ្នាំងថ្នាក់ ការខឹង ការខឹងខ្លាំង ការខឹងក្រៃលែង ការប្រទូស្ត ការប្រទូស្តខ្លាំង ការប្រទូស្តក្រៃលែងនៃចិត្ត ការព្យាបាទនៃចិត្ត ការប្រទូស្តក្នុងចិត្ត ការក្រោធ អាការក្រោធ ភាពនៃការក្រោធ ការប្រទូស្ត អាការប្រទូស្ត ភាពនៃការប្រទូស្ត ការព្យាបាទ អាការ

ព្យាបាទ ភាពនៃការព្យាបាទ ការពិរោធ ការពិរោធខ្លាំង កំណាច ការមិនពោលពាក្យល្អ ភាពនៃចិត្តមិនត្រេកអរ ក្នុងអាឃាតវត្ថុ ១០ នេះហៅថា ព្យាបាទធាតុ ។ បណ្តាធាតុ ៦ នោះ វិហឹសាធាតុ តើដូចម្តេច ។ សេចក្តីត្រិះរិះ ការត្រិះរិះផ្សេងៗ ។បេ។ ដែលប្រកបដោយវិហឹសា គឺមិច្ឆាសង្កប្ប នេះហៅថា វិហឹសាធាតុ ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ បៀតបៀនពួកសត្វ ដោយដៃក្តី ដោយដុំដីក្តី ដោយដំបងក្តី ដោយសស្ត្រាក្តី ដោយខ្សែក្តី ឬដោយវត្ថុណាមួយក្តី ការធ្វើឲ្យលំបាក ការធ្វើឲ្យលំបាកខ្លាំង ការបៀតបៀន ការបៀតបៀនខ្លាំង ការទឹង ការទឹងខ្លាំង ការបៀតបៀនសត្វដទៃ នេះហៅថា វិហឹសាធាតុ ។ បណ្តាធាតុ ៦ នោះ នេក្ខម្មធាតុ តើដូចម្តេច ។ សេចក្តីត្រិះរិះ ការត្រិះរិះផ្សេងៗ ។បេ។ តម្រិះត្រូវដែលប្រកបដោយនេក្ខម្មៈ គឺសម្មាសង្កប្ប នេះហៅថា នេក្ខម្មធាតុ ។ មួយទៀត កុសលធម៌ទាំងអស់ក៏ឈ្មោះថា នេក្ខម្មធាតុដែរ ។ បណ្តាធាតុ ៦ នោះ អព្យាបាទធាតុ តើដូចម្តេច ។ សេចក្តីត្រិះរិះ ការត្រិះរិះផ្សេងៗ ។បេ។ ដែលប្រកបដោយអព្យាបាទ គឺសម្មាសង្កប្ប នេះហៅថា អព្យាបាទធាតុ ។ ការស្រឡាញ់ អាការប្រព្រឹត្តស្រឡាញ់ ភាពនៃអាការប្រព្រឹត្តស្រឡាញ់ គឺមេត្តាចេតោវិមុត្តិណាក្នុងពួកសត្វ នេះហៅថា អព្យាបាទធាតុ ។ បណ្តាធាតុ ៦ នោះ អវិហឹសាធាតុ តើដូចម្តេច ។ សេចក្តីត្រិះរិះ ការត្រិះរិះផ្សេងៗ តម្រិះ ការរំពឹង ការជញ្ជឹង ការលើកឡើងនូវចិត្តដែលប្រកបដោយអវិហឹសា គឺសម្មាសង្កប្ប នេះហៅថា អវិហឹសាធាតុ ។ ការអាណិត អាការប្រព្រឹត្តអាណិត ភាពនៃ

អាការប្រព្រឹត្តអាណិត គឺករុណាចេតោវិមុត្តិណា ក្នុងសត្វទាំងឡាយ នេះហៅថា អវិហឹសាធាតុ ។

**នេះធាតុ ៦ ។**

[ ១២៣ ] ពួកធាតុ ៦ បីជង់នេះ រួមជាធាតុ ១៨ ព្រោះប្រមូលបង្រួញធាតុទាំងនោះក្នុងទីជាមួយគ្នា ដោយប្រការដូច្នេះ ។

## សុត្តន្តភាជនីយ ចប់

# អដ្ឋកថា

## ធាតុវិភង្គ សុត្តន្តភាជនីយ

[ ១១៤ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សង្ខេបធាតុទាំងអស់ដោយធាតុពួក ៦ សម្ដែងសុត្តន្តភាជនីយដោយធាតុពួក ៦ រួម ៣ ពួក ក្នុងធាតុវិភង្គ ដែលជាលំដាប់បន្ទាប់អំពីអាយតនវិភង្គនោះ ទើបត្រាស់ពាក្យជាដើមថា **ឆ ធាតុយោ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា ឆ ជាពាក្យកំណត់ចំនួន ។ បទថា **ធាតុយោ** ជាពាក្យសម្ដែងធម៌ដែលទ្រង់កំណត់ទុក ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងឡាយ មានពាក្យថា **បឋវីធាតុ** ជាដើម ដូចតទៅ ឈ្មោះថា អត្ថថា ធាតុ មានអត្ថថា ជាសភាវៈ ឈ្មោះថា អត្ថថា សភាវៈ មានអត្ថថា ជារបស់សូន្យ ឈ្មោះថា អត្ថថា ជារបស់សូន្យ មានអត្ថថា មិនមែនសត្វ ព្រោះហេតុនោះ ដោយអត្ថដែលអធិប្បាយមកនេះ ធាតុ គឺបឋវីនោះឯង ឈ្មោះថា បឋវីធាតុ ដោយអត្ថថា មានសភាវៈជារបស់សូន្យ និងមិនមែនសត្វ សូម្បីអាបោធាតុជាដើមក៏ន័យនេះដូចគ្នា បណ្ឌិតគប្បីជ្រាបបទសមាសក្នុងពាក្យថា បឋវីធាតុទាំងនោះយ៉ាងនេះហើយ គប្បីជ្រាបអត្ថដូចតទៅ

ពាក្យថា **បឋវីធាតុ** បានដល់ ធាតុតាំងមាំ ពាក្យថា **អាបោធាតុ** បានដល់ ធាតុប្រមូលផ្ដុំ ពាក្យថា **តេជោធាតុ** បានដល់ ធាតុដុតកំដៅ ពាក្យថា **វាយោធាតុ** បានដល់ ធាតុកម្រើក ពាក្យថា **អាកាសធាតុ** បានដល់ ធាតុដែលប៉ះពាល់មិនបាន ពាក្យថា **វិញ្ញាណធាតុ** បានដល់

ធាតុដឹងច្បាស់ ។

[ ១១៥ ] បទថា **បឋវីធាតុទ្វយំ** បានដល់ បឋវីធាតុនេះ មាន ២ យ៉ាង អធិប្បាយថា ឈ្មោះថា បឋវីធាតុនេះ មិនមែនមានតែម្យ៉ាងប៉ុណ្ណោះទេ តែមាន ២ យ៉ាង ដោយចែកជាបឋវីធាតុខាងក្នុង និងបឋវីធាតុខាងក្រៅ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា បឋវីធាតុខាងក្នុងក៏មាន ខាងក្រៅក៏មាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អជ្ឈត្តិកា** បានដល់ ដែលទាក់ទងក្នុងសន្ដានរបស់សត្វ គឺដែលនៅខាងក្នុងដែលកើតក្នុងខ្លួន ។ បទថា **ពាហិរា** បានដល់ ដែលទាក់ទងក្នុងសន្ដានរបស់សង្ខារ គឺមិនទាក់ទងដោយឥន្ទ្រិយ ។ បទថា **អជ្ឈត្តំ បច្ចត្តំ** ទាំង ២ នេះ ជាឈ្មោះរបស់ធាតុដែលនៅខាងក្នុងដែលកើតក្នុងខ្លួននោះឯង ។

ឥឡូវនេះ ដើម្បីសម្ដែងបឋវីធាតុនោះ ដោយអាការនៃសភាវៈរបស់ខ្លួន ទើបទ្រង់ត្រាស់ពាក្យថា រឹងជាដើម ។ បណ្ដាបទនោះ បទថា **កក្ខឡំ** បានដល់ ធម្មជាតិរឹង ។ បទថា **ខរិគតំ** បានដល់ ធម្មជាតិដែលគ្រោតគ្រាត ។ បទថា **កក្ខឡត្តំ** បានដល់ ភាវៈដែលរឹង ។ បទថា **កក្ខឡ ភាវោ** បានដល់ សភាវៈដែលរឹង ។

បទថា **អជ្ឈត្តំ ឧបាទិន្នំ** បានដល់ ពោល គឺរូបខាងក្នុង កើតក្នុងខ្លួន រូបដែលតាំងនៅក្នុងសរីរៈ ឈ្មោះថា **ឧបាទិន្ន** ។ ពិតហើយ រូបដែលតាំងនៅក្នុងសរីរៈ មានកម្មជាសមុដ្ឋានក្ដី មិនមានកម្មជាសមុដ្ឋានក្ដី ទ្រង់សំដៅ

យករូបដែលតាំងនៅក្នុងសរីរៈនោះ ដែលជាឧបាទិន្នខ្លះ ជាអនុបាទិន្នខ្លះនោះឯង តែដើម្បីសម្តែងថា រូបដែលតាំងនៅក្នុងសរីរៈទាំងអស់នោះជាឧបាទិន្នរូប ដោយអំណាចនៃរូបដែលមានចិត្តគ្រប់គ្រង ដែលត្រូវតណ្ហា និងទិដ្ឋិប្រកាន់ហើយនោះឯង ទើបត្រាស់ពាក្យថា **អជ្ឈត្តំ អនុបាទិន្នំ** ជាដើម ។

ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់បំណងនឹងសម្តែងបឋវីធាតុនោះឯង ដោយអំណាចនៃវត្ថុ ទើបត្រាស់ពាក្យថា **សេយ្យថីទំ កេសា លោមា** ដូច្នេះ ជាដើម ។

ក្នុងព្រះបាលីនោះ បទថា **សេយ្យថីទំ** ជានិបាត បទថា **សេយ្យថីទំ** នេះ មានអធិប្បាយថា បឋវីធាតុខាងក្នុង ដូចម្តេច រូបដែលនៅខាងក្នុងជារបស់ចំពោះខ្លួន ឈ្មោះថា ជាធម្មជាតិរឹង តើដូចម្តេច ។

បទថា **កេសា លោមា** ជាដើម ជាពាក្យសម្តែងប្រភេទនៃបឋវីធាតុដែលជាខាងក្នុងនោះ ដោយអំណាចជាវត្ថុ មានពាក្យអធិប្បាយយ៉ាងនេះថា ឈ្មោះថា **កេសា** របស់ខាងក្នុង ជាឧបាទិន្នរូប ជារបស់តាំងនៅក្នុងសរីរៈ មានការរឹង ជាលក្ខណៈ ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ ។ ឈ្មោះថា **លោមា** ។បេ។ ឈ្មោះថា **ករីស** ។ **មត្ថលុង្គំ** សូម្បីមិនបានត្រាស់ក្នុងធាតុវិភង្គនេះ តែលោកក៏លើកឡើងកាន់បាលី ក្នុងបដិសម្ភិទាមគ្គ ឈ្មោះថា **មត្ថលុង្គំ** ជារបស់ខាងក្នុង ជាឧបាទិន្នរូប ជារបស់តាំងនៅក្នុងសរីរៈមានការរឹងជាលក្ខណៈ ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ ។ ក្នុងប្រមាត់ជាដើម ក្នុងនិទ្ទេសនៃអាបោធាតុខាងមុខជាដើម ក៏មានន័យនេះ

ដូចគ្នា ។

សួរថា ដោយបទថា **កេសា** ជាដើមនេះ ទ្រង់សម្តែងដូចម្តេច ឆ្លើយថា ទ្រង់សម្តែងមនសិការធាតុ ។ សួរថា កុលបុត្តដែលប្រាថ្នាធ្វើកម្មក្នុងមនសិការធាតុនេះ ហើយផ្តើមវិបស្សនាដើម្បីសម្រេចអរហត្ត ដែលជាប្រយោជន៍ដ៏ឧត្តម គប្បីធ្វើដូចម្តេច ឆ្លើយថា គប្បីជម្រះបារិសុទ្ធិសីល ៤ ឲ្យបរិសុទ្ធ ។ ព្រោះថា ការចម្រើនកម្មដ្ឋាន រមែងសម្រេចដល់បុគ្គលអ្នកមានសីល វិធីធ្វើការជម្រះចតុបារិសុទ្ធិសីលនោះ គប្បីជ្រាបដោយន័យដែលបានពោលហើយ ក្នុងវិសុទ្ធិមគ្គនោះឯង ។ កុលបុត្តអ្នកមានសីលបរិសុទ្ធ តាំងនៅក្នុងសីលហើយ គប្បីកាត់បលិពោធខាងដើម ១០ យ៉ាង វិធីកាត់បលិ-ពោធ ១០ យ៉ាងនោះ គប្បីជ្រាបដោយន័យដែលបានពោលក្នុងវិសុទ្ធិមគ្គនោះឯង កុលបុត្តកាត់បលិពោធហើយ គប្បីរៀនកម្មដ្ឋាន មនសិការធាតុ អាចារ្យអ្នកឲ្យអន្តេវាសិករៀនកម្មដ្ឋាន គឺមនសិការធាតុ គប្បីប្រាប់ឧគ្គហ-កោសល ៧ និងមនសិការកោសល ១០ អន្តេវាសិកក៏គួរធ្វើការស្វាធ្យាយក្នុងសម្នាក់នៃអាចារ្យឲ្យច្រើន ហើយធ្វើកម្មដ្ឋានឲ្យស្ទាត់ អស់ទូវការស្ទាត់ស្នាញ សេចក្តីនេះ សមដូចពាក្យដែលលោកបានពោលហើយក្នុងអដ្ឋកថាថា ភិក្ខុដែលផ្តើមកម្មដ្ឋាន ជាអ្នកប្រាថ្នារួចផុតចាកជរា និងមរណៈ គប្បីប្រាថ្នាឧគ្គហកោសលដោយអាការ ៧ គប្បីប្រាថ្នាមនសិការកោសលដោយអាការ ១០ យ៉ាង ។

បណ្តាឧគ្គហកោសល និងមនសិការកោសលទាំងនោះ កុលបុត្តគប្បី

ប្រាថ្នាឧគ្គហកោសលក្នុងកម្មដ្ឋាន គឺមនសិការធាតុដោយអាការ ៧ នេះ គឺ ដោយវាចា ១ ដោយចិត្ត ១ ដោយពណ៌ ១ ដោយសណ្ឋាន ១ ដោយទិស ១ ដោយឱកាស ១ ដោយបរិច្ឆេទ ១ ។

កុលបុត្តគប្បីប្រាថ្នាមនសិការកោសល ដោយអាការ ១០ យ៉ាង គឺ ដោយលំដាប់ ១ ដោយមិនរួសរាន់ពេក ១ ដោយមិនយឺតពេក ១ ដោយហាមការរាយមាយ ១ ដោយឈានកន្លងបញ្ញត្តិ ១ ដោយលះលំដាប់ ១ ដោយលក្ខណៈ ១ ដោយសូត្រទាំងបី ១ ។ កោសលទាំង ២ នឹងជាក់ច្បាស់ក្នុងសតិប្បដ្ឋានវិភង្គខាងមុខ ។

កុលបុត្តដែលរៀនកម្មដ្ឋានយ៉ាងនេះ គប្បីវៀរសេនាសនៈ ដែលមានទោស ១៨ កន្លែង តាមដែលបានពោលក្នុងវិសុទ្ធិមគ្គ ក្នុងសេនាសនៈដែលប្រកបដោយអង្គ ៥ សូម្បីខ្លួនឯង ក៏ប្រកបដោយអង្គនៃភិក្ខុដែលប្រកបព្យាយាម ៥ ត្រឡប់អំពីបិណ្ឌបាត ខាងក្រោយភត្ត ចូលទៅកាន់ឱកាសដ៏ស្ងាត់ មនសិការកម្មដ្ឋាន ។ កុលបុត្តនោះ កាលមនសិការ គប្បីមនសិការកោដ្ឋាសនីមួយៗ ក្នុងកោដ្ឋាសទាំងឡាយ មានសក់ជាដើម ដោយអំណាចនៃពណ៌ សណ្ឋាន ទិស ឱកាស និងបរិច្ឆេទ ក្នុងកាលជាទីបំផុតគប្បីមនសិការប្រព្រឹត្តទៅយ៉ាងនេះ គឺ

ធម្មតាសក់ទាំងឡាយនោះ កើតក្នុងស្បែកដែលស្រោបលលាដ៍ក្បាល ។ ក្នុងសក់ទាំងនោះ ព្រះយោគី គប្បីមនសិការថា បណ្តាស្បូវក្លាំងទាំងឡាយដែលកើតលើជំបូក ជំបូកមិនដឹងថា ស្បូវក្លាំងទាំងឡាយកើតក្នុងអញ ស្បូវ

ភ្នាំងក៏មិនដឹងថា ពួកយើងកើតលើដំបូក ដូច្នេះ យ៉ាងណា ស្បែកដែលស្រោបលលាដ៍ក្បាល ក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា សក់ទាំងឡាយកើតក្នុងអញ សក់ទាំងឡាយសោត ក៏មិនដឹងថា ពួកយើងកើតក្នុងស្បែកលលាដ៍ក្បាល ដូច្នេះ ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណាដល់គ្នានិងគ្នា ព្រោះហេតុនោះ ឈ្មោះថា សក់ទាំងឡាយ ទើបជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតិរឹង ឈ្មោះថា **បឋវីធាតុ** ដូច្នេះ ។

រោមទាំងឡាយ កើតក្នុងស្បែកដែលស្រោបសរីរៈ ក្នុងរោមទាំងឡាយនោះ ព្រះយោគីគប្បីមនសិការថា បណ្ដាស្បូវភ្នាំងទាំងឡាយដែលកើតក្នុងសុញ្ញាគារ សុញ្ញាគារ រមែងមិនដឹងថា ស្បូវភ្នាំងទាំងឡាយ កើតក្នុងអញ ស្បូវភ្នាំងសោតក៏មិនដឹងថា ពួកយើងកើតក្នុងទីសុញ្ញាគារ ដូច្នេះ យ៉ាងណា ស្បែកដែលស្រោបសរីរៈក៏យ៉ាងនោះ រមែងមិនដឹងថា រោមទាំងឡាយកើតក្នុងអញ រោមទាំងឡាយសោតក៏មិនដឹងថា ពួកយើងកើតក្នុងស្បែកស្រោបសរីរៈ ដូច្នេះ ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបឈ្មោះថា រោមទាំងឡាយជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតិរឹង ឈ្មោះថា **បឋវីធាតុ** ។

ក្រចកកើតត្រង់ចុងម្រាមទាំងឡាយ ក្នុងក្រចកទាំងឡាយនោះ ព្រះយោគីគប្បីមនសិការថា ពួកក្មេងៗ យកឈើតូចដោតគ្រាប់ស្រគំលេង មែកឈើ

តូចទាំងឡាយរមែងមិនដឹងថា គ្រាប់ស្រគំតាំងនៅក្នុងពួកយើង សូម្បីគ្រាប់ស្រគំ ក៏មិនដឹងថា ពួកយើងតាំងនៅលើមែកឈើតូចៗ ទាំងឡាយ ដូច្នេះ យ៉ាងណា ម្រាមទាំងឡាយក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា ក្រចកទាំងឡាយ កើតត្រង់ចុងរបស់ពួកយើង ក្រចកទាំងឡាយសោត ក៏មិនដឹងថា ពួកយើងកើតត្រង់ចុងម្រាមទាំងឡាយ ដូច្នេះ ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបក្រចក ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរឹង ឈ្មោះថា **បឋវីធាតុ** ។

ធ្មេញទាំងឡាយ កើតត្រង់ឆ្អឹងចង្កាទាំងឡាយ ក្នុងធ្មេញទាំងឡាយនោះ ព្រះយោគី គប្បីមនសិការថា កាលជាងឈើយកជ័រណាមួយ បិទសសរ តម្កល់ទុកលើត្បាល់ថ្ម ( ជើងសសរ ) ត្បាល់ថ្ម រមែងមិនដឹងថា សសរទាំងឡាយ តាំងនៅត្រង់ពួកយើង សូម្បីសសរសោត ក៏មិនដឹងថា ពួកយើងតាំងនៅលើត្បាល់ថ្មទាំងឡាយ ដូច្នេះ យ៉ាងណា ឆ្អឹងចង្កាទាំងឡាយក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា ធ្មេញទាំងឡាយកើតក្នុងពួកយើង សូម្បីធ្មេញសោតក៏មិនដឹងថា ពួកយើងកើតត្រង់ឆ្អឹងចង្កាទាំងឡាយ ដូច្នេះ ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបធ្មេញទាំងឡាយ ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតិរឹង ឈ្មោះថា **បឋវីធាតុ** ។

ស្បែកស្រោបសរីរៈទាំងមូល ក្នុងស្បែកដែលស្រោបសរីរៈនោះ ព្រះយោគី គប្បីមនសិការថា កាលពិណធំដែលពាសដោយស្បែកគោស្រស់ ពិណធំមិនដឹងថា អញត្រូវស្រោបដោយស្បែកគោស្រស់ សូម្បីស្បែកគោស្រស់សោត ក៏មិនដឹងថា ពិណធំត្រូវអញស្រោប ដូច្នេះ យ៉ាងណា សរីរៈក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា អញត្រូវស្បែកស្រោប សូម្បីស្បែកសោត ក៏មិនដឹងថា អញស្រោបសរីរៈ ដូច្នេះ ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបស្បែក ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតិរឹង ឈ្មោះថា **បឋវីធាតុ** ។

សាច់បូកលាបនូវគ្រោងឆ្អឹង ក្នុងសាច់នោះ ព្រះយោគីគប្បីមនសិការថា កាលគេយកដុំដីស្អិតធំ មកបូកលាបជញ្ជាំងផ្ទះ ដុំដីស្អិតធំ មិនបានដឹងថា ជញ្ជាំងផ្ទះត្រូវអញបូកលាប សូម្បីជញ្ជាំងផ្ទះសោត ក៏មិនដឹងថា អញត្រូវដុំដីស្អិតធំបូកលាប ដូច្នេះ យ៉ាងណា គ្រោងឆ្អឹងនេះក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា អញត្រូវបូកលាបដោយដុំសាច់ ៩០០ ដុំ សូម្បីសាច់សោត ក៏មិនដឹងថា គ្រោងឆ្អឹងត្រូវអញបូកលាប ដូច្នេះ ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបសាច់ ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតិរឹង ឈ្មោះថា **បឋវីធាតុ** ។

សរសៃទាំងឡាយ ចងរឹតឆ្អឹងទាំងឡាយក្នុងសរីរៈ ក្នុងសរសៃទាំងនោះ

ព្រះយោគីគប្បីមនសិការថា ប្រជីសជញ្ជាំង ដែលគេយកវល្លិមកចងជាមេរួ ប្រជីសជញ្ជាំងទាំងឡាយ រមែងមិនដឹងថា ពួកយើងត្រូវវល្លិចង សូម្បីវល្លិ ទាំងឡាយ ក៏មិនដឹងថា ប្រជីសជញ្ជាំង ត្រូវពួកយើងចង ដូច្នេះ យ៉ាងណា ឆ្អឹងទាំងឡាយ ក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា ពួកយើងត្រូវសរសៃ ទាំងឡាយចងរឹត សរសៃទាំងឡាយសោត ក៏មិនដឹងថា ឆ្អឹងទាំងឡាយត្រូវ ពួកយើងចង ដូច្នេះ ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នា និងគ្នា ព្រោះហេតុនោះ ទើបសរសៃទាំងឡាយ ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះ សូន្យ មិនមែនសត្វ ជាធម្មជាតិរឹង ឈ្មោះថា **បឋវីធាតុ** ។

បណ្ដាឆ្អឹងទាំងឡាយ ឆ្អឹងកែងជើងលើកឆ្អឹង-**ក**ជើងតម្កល់ ឆ្អឹង-**ក**ជើង លើកឆ្អឹងស្មងតម្កល់ ឆ្អឹងស្មងលើកឆ្អឹងភ្លៅតម្កល់ ឆ្អឹងភ្លៅលើកឆ្អឹង ចង្កេះតម្កល់ ឆ្អឹងចង្កេះលើកឆ្អឹងខ្នងតម្កល់ ឆ្អឹងខ្នងលើកឆ្អឹង**ក**តម្កល់ ឆ្អឹង-**ក**លើកឆ្អឹងក្បាលតម្កល់ ឆ្អឹងក្បាលតាំងនៅលើឆ្អឹង-**ក** ឆ្អឹង**ក**តាំង នៅលើឆ្អឹងខ្នង ឆ្អឹងខ្នងតាំងនៅលើឆ្អឹងចង្កេះ ឆ្អឹងចង្កេះ តាំងនៅលើឆ្អឹងភ្លៅ ឆ្អឹងភ្លៅតាំងនៅលើឆ្អឹងស្មង ឆ្អឹងស្មងតាំងនៅលើឆ្អឹង-**ក**ជើង ឆ្អឹង-**ក**ជើង តាំងនៅលើឆ្អឹងកែងជើង ។

បណ្ដាឆ្អឹងទាំងនោះ ព្រះយោគីគប្បីមនសិការថា បណ្ដារបស់ទាំងឡាយ ដែលគរលើគ្នា មានឥដ្ឋ ចម្រៀកឈើ និងគោម័យជាដើម របស់ដែលនៅ ខាងក្រោម រមែងមិនដឹងថា ពួកយើងលើករបស់ខាងលើៗ តម្កល់ សូម្បី

របស់ខាងលើក៏មិនដឹងថា ពួកយើង តាំងនៅលើរបស់ខាងក្រោម ដូច្នេះ យ៉ាងណា ឆ្អឹងកែងជើងសោត ក៏មិនដឹងថា អញលើកឆ្អឹង-**ក**ជើងតម្កល់ ឆ្អឹង-**ក**ជើងសោត ក៏មិនដឹងថា អញលើកឆ្អឹងស្មងតម្កល់ ឆ្អឹងស្មងសោត ក៏មិនដឹងថា អញលើកឆ្អឹងភ្លៅតម្កល់ ឆ្អឹងភ្លៅសោត ក៏មិនដឹងថា អញលើកឆ្អឹងចង្កេះតម្កល់ ឆ្អឹងចង្កេះសោត ក៏មិនដឹងថា អញលើកឆ្អឹងខ្នងតម្កល់ ឆ្អឹងខ្នងសោត ក៏មិនដឹងថា អញលើកឆ្អឹង-**ក**តម្កល់ ឆ្អឹង-**ក** សោត ក៏មិនដឹងថា អញលើកឆ្អឹងលលាដ៍ក្បាលតម្កល់ ឆ្អឹងលលាដ៍ក្បាលសោត ក៏មិនដឹងថា អញតាំងនៅលើឆ្អឹង-**ក** ឆ្អឹង-**ក**សោត ក៏មិនដឹងថា អញតាំងនៅលើឆ្អឹងខ្នង ឆ្អឹងខ្នងសោតក៏មិនដឹងថា អញតាំងនៅលើឆ្អឹងចង្កេះ ឆ្អឹងចង្កេះសោត ក៏មិនដឹងថា អញតាំងនៅលើឆ្អឹងភ្លៅ ឆ្អឹងភ្លៅសោត ក៏មិនដឹងថា អញតាំងនៅលើឆ្អឹងស្មង ឆ្អឹងស្មងសោត ក៏មិនដឹងថា អញតាំងនៅលើឆ្អឹង-**ក**ជើង ឆ្អឹង-**ក**ជើងសោត ក៏មិនដឹងថា អញតាំងនៅលើឆ្អឹងកែងជើង ដូច្នេះ ធម៌ទាំងនេះវៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ឈ្មោះថា ឆ្អឹងជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យទទេ មិនមែនសត្វ ជាធម្មជាតិរឹង ឈ្មោះថា **បឋវីធាតុ** ។

ខួរក្នុងឆ្អឹង តាំងនៅខាងក្នុងឆ្អឹងទាំងឡាយនោះ ខួរក្នុងឆ្អឹងទាំងនោះ ព្រះយោគី គប្បីមនសិការថា កាលបុគ្គលយកចុងផ្តៅដែលពេលហើយ ដាក់ចូលទៅខាងក្នុងបំពង់ឫស្សីជាដើម បំពង់ឫស្សីរមែងមិនដឹងថា បណ្តូលផ្តៅ

ជាដើមនៅក្នុងពួកយើង សូម្បីបណ្ណុលផ្កាសោត ក៏មិនដឹងថា ពួកយើងតាំងនៅក្នុងបំពង់ឫស្សីជាដើម យ៉ាងណា ធ្អឹងទាំងឡាយក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា ខួរក្នុងធ្អឹងតាំងនៅក្នុងពួកយើង សូម្បីខួរក្នុងធ្អឹងសោត ក៏មិនដឹងថា អញតាំងនៅខាងក្នុងធ្អឹងទាំងឡាយ ដូច្នេះ ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបខួរក្នុងធ្អឹង ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរឹង ឈ្មោះថា **បឋវីធាតុ** ។

ទាច តាំងនៅជុំវិញសាច់បេះដូង ចងដោយសរសៃធំ មានគល់តែមួយចេញអំពីរណ្ដៅកបន្ទិច ហើយបែកជា ២ ក្នុងទាចនោះ ព្រះយោគីគប្បីធ្វើមនសិការថា គូនៃផ្លែស្វាយដែលមានទងតែមួយ ទងស្វាយ រមែងមិនដឹងថា គូនៃផ្លែស្វាយជាប់ជាមួយអញ សូម្បីផ្លែស្វាយ ក៏មិនដឹងថា អញជាប់ជាមួយទង ដូច្នេះ យ៉ាងណា សរសៃធំទាំងឡាយ ក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា ទាចជាប់ជាមួយអញ សូម្បីទាចសោត ក៏មិនដឹងថា អញជាប់ជាមួយសរសៃធំ ដូច្នេះ ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបទាច ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរឹង ឈ្មោះថា **បឋវីធាតុ** ។

បេះដូង តាំងនៅត្រង់កណ្ដាលធ្អឹងទ្រូងខាងក្នុងសរីរៈ ក្នុងបេះដូងនោះ

ព្រះយោគី គប្បីមនសិការថា កាលដុំសាច់តាំងនៅខាងក្នុងគ្រោងរបស់រំពបុរាណ គ្រោងរំពបុរាណ រមែងមិនដឹងថា ដុំសាច់តាំងនៅក្នុងអញ សូម្បីដុំសាច់ក៏មិនដឹងថា អញអាស្រ័យខាងក្នុងគ្រោងរំពបុរាណ ដូច្នេះ យ៉ាងណា គ្រោងឆ្អឹងទ្រូង ក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា បេះដូងតាំងនៅក្នុងអញ បេះដូងសោត ក៏មិនដឹងថា អញតាំងនៅក្នុងគ្រោងឆ្អឹងទ្រូង ដូច្នេះ ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបបេះដូង ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរឹង ឈ្មោះថា **បឋវីធាតុ ។**

ថ្លើមអាស្រ័យនៅខាងស្តាំចន្លោះកន្សោមដោះទាំង ២ ខាងក្នុងសរីរៈ ។ ថ្លើមនោះ ព្រះយោគី គប្បីមនសិការថា កាលគេសំយុងដុំសាច់ត្រង់ក្អែងឆ្នាំងបាយ ក្អែងឆ្នាំងបាយ រមែងមិនដឹងថា គូនៃដុំសាច់ សំយុងក្នុងអញ សូម្បីគូនៃដុំសាច់ ក៏មិនដឹងថា អញត្រូវព្យួរត្រង់ក្អែងឆ្នាំងបាយ ដូច្នេះ យ៉ាងណា ឆ្អឹងជំនីរខាងស្តាំចន្លោះកន្សោមដោះទាំងគូ ក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា ថ្លើមអាស្រ័យអញតាំងនៅ សូម្បីថ្លើមសោត ក៏មិនដឹងថា អញតាំងនៅចន្លោះឆ្អឹងជំនីរស្តាំនៃដោះទាំងគូ ដូច្នេះ ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបថ្លើម ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកតៈ ជារបស់សូន្យ មិនមែនសត្វ ជាធម្មជាតិរឹង ឈ្មោះថា **បឋវីធាតុ ។**

*វាវទាំងឡាយ វាវដែលបិទបាំង រុំព័ទ្ធបេះដូង និងទាច ហើយតាំងនៅ វាវដែលមិនបិទបាំងបេះដូង និងទាច តែស្រោបសាច់ខាងក្នុងស្បែកក្នុងសរីរៈទាំងមូលតាំងនៅ ។ ក្នុងវាវទាំងនោះ ព្រះយោគី គប្បីមនសិការថា កាលដុំសាច់ត្រូវខ្ចប់ដោយសំពត់ទុកូលចាស់ ដុំសាច់ រមែងមិនដឹងថា អញត្រូវសំពត់ចាស់ខ្ចប់ សូម្បីសំពត់ចាស់ក៏មិនដឹងថា សាច់ត្រូវអញស្រោប ដូច្នេះ យ៉ាងណា ទាច បេះដូង និងសាច់ក្នុងសរីរៈទាំងមូល ក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា អញត្រូវវាវបិទបាំង សូម្បីវាវសោត ក៏មិនដឹងថា ទាច បេះដូង សាច់ក្នុងសរីរៈទាំងមូល ត្រូវអញបិទបាំង ដូច្នេះ ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបវាវ ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរឹង ឈ្មោះថា* **បឋវីធាតុ ។**

*ក្រពះ តាំងនៅខាងលើសាច់ដែលស្រោបពោះ ផ្នែកខាងឆ្វេងនៃបេះដូង ក្រពះនោះ ព្រះយោគី គប្បីមនសិការថា កាលដុំគោម័យដាក់ក្នុងជង្រុកស្រូវ ជង្រុកស្រូវមិនដឹងថា ដុំគោម័យអាស្រ័យអញតាំងនៅ ដុំគោម័យ ក៏មិនដឹងថា អញអាស្រ័យខាងលើជង្រុកស្រូវតាំងនៅ ដូច្នេះ យ៉ាងណា សាច់ដែលស្រោបផ្ទៃពោះក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា ក្រពះអាស្រ័យអញតាំងនៅ ក្រពះសោត ក៏មិនដឹងថា អញអាស្រ័យសាច់ដែលស្រោបផ្ទៃពោះតាំងនៅ ដូច្នេះ ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះ*

ហេតុនោះ ទើបក្រពះ ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរឹង ឈ្មោះថា **បឋវីធាតុ** ។

សួតសំយុងបិទខាងលើបេះដូង និងថ្លើម តាំងនៅក្នុងចន្លោះដោះទាំង ២ ក្នុងសរីរៈ ក្នុងសួតនោះ ព្រះយោគី គប្បីពិចារណាថា សម្បុកបក្សី ដែលសំយុងនៅខាងក្នុងជង្រុកស្រូវ ជង្រុកស្រូវ រមែងមិនដឹងថា សម្បុកបក្សីសំយុងនៅក្នុងអញ សូម្បីសម្បុកបក្សីក៏មិនដឹងថា អញសំយុងនៅខាងក្នុងជង្រុកស្រូវ ដូច្នេះ យ៉ាងណា ខាងក្នុងសរីរៈក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា សួតសំយុងនៅក្នុងអញ សូម្បីសួតក៏មិនដឹងថា អញសំយុងនៅខាងក្នុងសរីរៈបែបនេះ ដូច្នេះ ធម៌ទាំងនេះ វៀរចាកការគិត និងពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបសួត ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរឹង ឈ្មោះថា **បឋវីធាតុ** ។

ពោះវៀនធំ តាំងនៅខាងក្នុងសរីរៈ ចាប់អំពីរណ្ដៅក រហូតដល់ទ្វារធំ ពោះវៀនធំនោះ ព្រះយោគី គប្បីមនសិការថា សរីរៈរបស់ពស់ដែលអាស្រ័យនៅក្នុងផ្ទះ ត្រូវគេកាត់ក្បាល ធ្លាយរង្វេលក្នុងស្នូក ស្នូក រមែងមិនដឹងថា សរីរៈរបស់ពស់ផ្ទះ ( ពស់តុកកែ ) គេដាក់ក្នុងអញ សូម្បីពស់ផ្ទះក៏មិនដឹងថា អញត្រូវគេដាក់ក្នុងស្នូកឈាម ដូច្នេះ យ៉ាងណា ក្នុងសរីរៈក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា ពោះវៀនធំតាំងនៅក្នុងអញ សូម្បី

ពោះវៀនធំសោត ក៏មិនដឹងថា អញតាំងនៅខាងក្នុងសរីរៈ ដូច្នេះ ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបពោះវៀនធំ ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរឹង ឈ្មោះថា **បឋវីធាតុ ។**

ពោះវៀនតូច តាំងនៅក្នុងចន្លោះពោះវៀនធំ ដោយព័ទ្ធព័ន្ធពោះវៀនធំ ២១ ផ្នត់ ។ ក្នុងពោះវៀនតូចនោះ ព្រះយោគី គប្បីមនសិការថា កាលបុគ្គលយកខ្សែជេរមណ្ឌលសម្រាប់ជូតជើងតម្កល់ មណ្ឌលសម្រាប់ជូតជើងរមែងមិនដឹងថា ខ្សែជេរអញតម្កល់ សូម្បីខ្សែក៏មិនដឹងថា ពួកយើងជេរមណ្ឌលសម្រាប់ជូតជើងតម្កល់ ដូច្នេះ យ៉ាងណា ពោះវៀនធំក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា ពោះវៀនតូចព័ទ្ធព័ន្ធអញតម្កល់ ពោះវៀនតូចសោត ក៏មិនដឹងថា អញរុំពោះវៀនធំតម្កល់ ដូច្នេះ ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបពោះវៀនតូចឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរឹង ឈ្មោះថា **បឋវីធាតុ ។**

អាហារថ្មី បានដល់ របស់បរិភោគ របស់ផឹក របស់ទំពា របស់ភក្សដែលនៅក្នុងផ្ទៃ ។ បណ្ដាអាហារថ្មីទាំងនោះ ព្រះយោគី គប្បីមនសិការថា កាលកម្អួតក្អែតាំងនៅក្នុងស្នូកសុនខ ស្នូកសុនខមិនដឹងថា កម្អួតក្អែតាំងនៅ

*ក្នុងអញ្ចសូម្បីកម្ពុតផ្ទៃ ក៏មិនដឹងថា អញតាំងនៅក្នុងស្នូកសុនខ ដូច្នេះ យ៉ាងណា ផ្ទៃពោះក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា អាហារថ្មីតាំងនៅក្នុងអញ អាហារថ្មីសោត ក៏មិនដឹងថា អញតាំងនៅក្នុងផ្ទៃ ដូច្នេះ ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបអាហារថ្មី ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរឹង ឈ្មោះថា* **បឋវីធាតុ ។**

*អាហារចាស់ តាំងនៅក្នុងទីបំផុតនៃពោះវៀនធំ ពោល គឺក្រពះអាហារចាស់ ដូចគ្នានឹងបំពង់ឫស្សីប្រវែង ៨ ធ្នាប់ ។ ក្នុងអាហារចាស់ទាំងនោះ ព្រះយោគី គប្បីមនសិការថា កាលគេយកដីស្អិតពណ៌លឿង ប្របាច់ញាត់ក្នុងបំពង់ឫស្សី បំពង់ឫស្សីមិនដឹងថា ដីស្អិតពណ៌លឿង តាំងនៅក្នុងអញ សូម្បីដីស្អិតពណ៌លឿងសោត ក៏មិនដឹងថា អញតាំងនៅក្នុងបំពង់ឫស្សី ដូច្នេះ យ៉ាងណា ក្រពះអាហារចាស់ ក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា អាហារចាស់តាំងនៅក្នុងអញ អាហារចាស់សោត ក៏មិនដឹងថា អញតាំងនៅក្នុងក្រពះអាហារចាស់ ដូច្នេះ ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបអាហារចាស់ ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរឹង ឈ្មោះថា* **បឋវីធាតុ ។**

*ខួរក្នុងក្បាលតាំងនៅខាងក្នុងលលាដ៍ក្បាល ខួរក្បាលនោះ ព្រះយោគី*

គប្បីមនសិការថា កាលបុគ្គលយកដុំម្សៅដាក់ក្នុងសម្បកឃ្លោកចាស់ សម្បកឃ្លោកចាស់ រមែងមិនដឹងថា ដុំម្សៅតាំងនៅក្នុងអញ សូម្បីដុំម្សៅក៏មិនដឹងថា អញតាំងនៅក្នុងសម្បកឃ្លោកចាស់ ដូច្នេះ យ៉ាងណា លលាដ៍ក្បាលក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា ខួរក្បាល តាំងនៅក្នុងអញ សូម្បីខួរក្បាលសោត ក៏មិនដឹងថា អញតាំងនៅក្នុងលលាដ៍ក្បាល ដូច្នេះ ធម៌ទាំងនេះ វៀរចាកនូវការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបខួរក្បាល ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរឹង ឈ្មោះថា **បឋវីធាតុ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសបឋវីធាតុខាងក្រៅដូច្នេះ

បទថា **អយោ** បានដល់ លោហៈដែលមានពណ៌ខ្មៅ ។

បទថា **លោហំ** បានដល់ លោហៈ ៤ ប្រភេទ គឺជាតិលោហៈ ១ វិជាតិលោហៈ ១ កិត្តិមលោហៈ ១ បិសាចលោហៈ ១ បណ្តាលោហៈ ៤ នោះ លោហៈ ៧ គឺដែក ១ ប្រាក់ ១ មាស ១ គជ់ ១ សំណ ១ ទង់ដែង ១ ស្ពាន់ ១ ឈ្មោះថា **ជាតិលោហៈ** ។ លោហៈមានលក្ខណៈដូចប្រមោយដំរី ឈ្មោះថា **វិជាតិលោហៈ** ។ លោហៈ ៣ យ៉ាង គឺកំស-លោហៈ ១ វដ្តលោហៈ ១ អារកូដៈ ១ ឈ្មោះថា **កិត្តិមលោហៈ** ។ លោហៈ ៨ គឺមោរក្ខកៈ ១ បុថុកៈ ១ មលិនកៈ ១ ចបលកៈ ១ សេលកៈ ១ អាដកៈ ១ ភល្លកៈ ១ ទូសិលោហៈ ១ ឈ្មោះថា **បិសាច-**

**លោហា** ។ បណ្ដាលោហៈទាំងនោះ ជាតិលោហៈ ៥ ខាងដើម ត្រាស់មួយផ្នែកក្នុងព្រះបាលី តែលោហៈដ៏សេស និងជាតិលោហៈទាំង ២ គឺទង់ដែង និងស្ពាន់ គប្បីជ្រាបថា លោហៈ ក្នុងទីនេះ ។

បទថា **តិបុ** បានដល់ គជ់ពណ៌ស ។ បទថា **សីសំ** បានដល់ សំណពណ៌ខ្មៅ ។ បទថា **សជ្ឈុ** បានដល់ ប្រាក់ ។ បទថា **មុត្តា** បានដល់ កែវមុក្តាដែលកើតក្នុងសមុទ្ទ ។ បទថា **មណិ** សេចក្ដីថា កញ្ចក់ កែវពិទូរ្យជាដើម ដែលមកក្នុងព្រះបាលីហើយ ( កែវមានពន្លឺ ) ដ៏សេសទាំងអស់ឈ្មោះថា កែវមណី មានកែវមណីជោតិរសជាដើម ។ បទថា **វេឡុរិយោ** បានដល់ កែវមណីដែលមានពណ៌ដូចសម្បកដើមឫស្សី ។ បទថា **សង្ខោ** បានដល់ ខ្យងដែលកើតក្នុងសមុទ្ទ ។ បទថា **សិលា** បានដល់ ថ្មទាំងអស់មានថ្មខ្មៅ ថ្មពណ៌លឿង និងថ្មពណ៌សជាដើម ។ បទថា **បវាឡំ** បានដល់ កែវប្រពាលនោះឯង ។ បទថា **រជតំ** បានដល់ កហាបណៈ ។ បទថា **ជាតរូបំ** បានដល់ មាស ។ បទថា **លោហិតង្កោ** បានដល់ កែវមណីក្រហម ។ បទថា **មសារគល្លំ** បានដល់ កែវមរកត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងវត្ថុ មានស្មៅជាដើម ព្រឹក្សជាតិដែលខាងក្រៅរឹងដោយហោចសូម្បីដើមដូងជាដើម ក៏ឈ្មោះថា ស្មៅ ។ វត្ថុដែលមានខ្លឹមខាងក្នុង ដោចហោចសូម្បីអន្ទត់ឧស ឈ្មោះថា ឈើ ។ ដុំថ្មដោយប្រមាណប៉ុនគ្រាប់សណ្ដែកបាយ រហូតដល់ប៉ុនមួយក្ដាប់ ឈ្មោះថា ក្រួស តែក្រួសដែលតូចជាងគ្រាប់សណ្ដែកបាយ ឈ្មោះថា ខ្សាច់ ។ បទថា **កឋលា** បាន

ដល់ អំបែងណាមួយ ។ បទថា **ភូមិ** បានដល់ ផែនដី ។ បទថា **ធាសាណោ** បានដល់ ផ្ទាំងថ្មដែលមានទំហំចាប់ពីក្តាប់មិនជុំ រហូតដល់ប៉ុន ដំរី ឈ្មោះថា ដុំថ្ម តែធំជាងដំរីឡើងទៅ ឈ្មោះថា ភ្នំ ។

ដោយបទថា **យំ វា បន** នេះ លោកសង្គ្រោះយកបឋវីដ៏សេស មាន គ្រាប់ត្នោត និងផ្លែដូងជាដើម ។ ដោយបទថា **យា ច អជ្ឈត្តិកា បឋវីធាតុ យា ច ពាហិរា** នេះ ព្រះមានព្រះភាគ ទ្រង់សម្តែងបឋវីធាតុទាំង ២ ជា បឋវីធាតុតែមួយប៉ុណ្ណោះដោយលក្ខណៈ ព្រោះអត្ថថា ជាធម្មជាតិរឹង ដូច្នេះ ។

[ ១១៦ ] ក្នុងនិទ្ទេសអាបោធាតុជាដើម គប្បីជ្រាបដោយន័យដែលពោល ខាងដើមនោះឯង គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **អាបោ អាបោគតំ** ដូចត ទៅ ដែលឈ្មោះថា **អាបោ** ដោយអំណាចប្រមូលផ្តុំ ។ សភាវៈជ្រួតជ្រាប ឈ្មោះថា **អាបោគតំ** ព្រោះដល់សភាវៈជ្រួតជ្រាប ។ ដែលឈ្មោះថា **សិនេហោ** ដោយអំណាចនៃភាពស្អិត ។ សភាពស្អិតនោះឯង ឈ្មោះថា **សិនេហគតំ** ព្រោះដល់នូវសភាពនៃការស្អិត ។

បទថា **ពន្ធនត្តំ រូបស្ស** បានដល់ គ្រឿងចងរបស់អវិនិព្ភោគរូប ( រូប ដែលបំបែកចេញមិនបាន ៨ រូប ) ។ ពាក្យថា **បិត្តំ សេម្ហំ** ជាដើម ព្រះ យោគីកំណត់កាន់យកដោយអំណាចនៃពណ៌ សណ្ឋាន ទិស និងបរិច្ឆេទ ហើយគប្បីមនសិការ ដោយអំណាចនៃភាពជាធាតុនោះឯង ។

ក្នុងវិធីមនសិការនោះ មានន័យដូចតទៅនេះថា

បណ្តាប្រមាត់ទាំងឡាយ ប្រមាត់មិនមានស្រោម ជ្រួតជ្រាបពេញសរីរៈ

ទាំងមូល ដែលទាក់ទងដោយជីវិតិន្ទ្រិយ ។ ប្រមាត់ដែលនៅក្នុងស្រោម តាំងនៅក្នុងស្រោមរបស់ប្រមាត់ ។ បណ្តាប្រមាត់ទាំង ២ នោះ ព្រះយោគី គប្បីមនសិការថា កាលមានខ្លាញ់ប្រេងជ្រាបក្នុងនំ តាំងនៅ នំ រមែងមិនដឹងថា ប្រេងជ្រួតជ្រាបក្នុងអញតាំងនៅ សូម្បីប្រេងក៏មិនដឹងថា អញជ្រួតជ្រាបក្នុងនំ តាំងនៅ ដូច្នេះ យ៉ាងណា សរីរៈក៏យ៉ាងនោះដូចគ្នា តែងមិនដឹងថា ប្រមាត់ដែលមិននៅក្នុងស្រោមជ្រួតជ្រាបក្នុងអញ តាំងនៅ សូម្បីប្រមាត់ដែលមិននៅក្នុងស្រោមសោត ក៏មិនដឹងថា អញជ្រួតជ្រាបក្នុងសរីរៈ តាំងនៅ ដូច្នេះ និងដូចពោះននោងព្រៃ ដែលពេញដោយទឹកភ្លៀង ពោះននោងព្រៃ រមែងមិនដឹងថា ទឹកភ្លៀងតាំងនៅក្នុងអញ សូម្បីទឹកភ្លៀង ក៏មិនដឹងថា អញតាំងនៅក្នុងពោះននោងព្រៃ ដូច្នេះ យ៉ាងណា ថង់ប្រមាត់ក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា ប្រមាត់មានស្រោមតាំងនៅក្នុងអញ សូម្បីប្រមាត់មានស្រោម ក៏រមែងមិនដឹងថា អញតាំងនៅក្នុងថង់ប្រមាត់ ដូច្នេះ ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបប្រមាត់ ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរាវ មានអាការប្រមូលផ្តុំ ឈ្មោះថា **អាបោធាតុ** ។

ស្លេស្មមានប្រមាណមួយកម្បង់ តាំងនៅក្នុងផ្ទៃ ។ ក្នុងស្លេស្មនោះ ព្រះយោគី គប្បីមនសិការថា កាលអណ្តូងទឹកជ្រាំ មានផ្ទាំងសំពត់ប៉ោងឡើងអំពីខាងលើ អណ្តូងទឹកជ្រាំ រមែងមិនដឹងថា ផ្ទាំងសំពត់ប៉ោងឡើងតាំងនៅលើ

អញ្ច ផ្ទាំងសំពត់ក៏មិនដឹងថា អញតាំងនៅលើអណ្ដូងទឹកជ្រាំ ដូច្នេះ យ៉ាង ណា ផ្ទៃពោះ ក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា ស្លេស្មតាំងនៅក្នុងអញ ស្លេស្មសោត ក៏មិនដឹងថា អញតាំងនៅក្នុងផ្ទៃពោះ ដូច្នេះ ធម៌ទាំងនេះ វៀរ ចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបស្លេស្ម ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជា អព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរាវ មានអាការ ប្រមូលផ្ដុំ ឈ្មោះថា **អាបោធាតុ** ។

ខ្ទុះ មិនតាំងនៅប្រចាំ កាលចំណែកនៃរាងកាយត្រូវដង្គត់ បន្លា និង អណ្ដាតភ្លើងជាដើម ពាល់ត្រូវហើយក្នុងទីណា លោហិតក៏ពុះពង ឬបូស និង ពងបែកជាដើម រមែងកើតឡើង ខ្ទុះក៏តាំងនៅក្នុងចំណែកនៃរាងកាយនោះៗ ក្នុងខ្ទុះទាំងនោះ ព្រះយោគី គប្បីមនសិការថា កាលដើមឈើមានជ័រហូរចេញ ដោយអំណាចការប្រហារដោយពូថៅជាដើម ចំណែកនៃដើមឈើដែលត្រូវ ប្រហារដោយពូថៅជាដើម រមែងមិនដឹងថា ជ័រឈើ តាំងនៅក្នុងពួកយើង សូម្បីជ័រឈើ ក៏មិនដឹងថា អញតាំងនៅក្នុងចំណែកនៃដើមឈើ ដែលត្រូវ ប្រហារដោយពូថៅជាដើម ដូច្នេះ យ៉ាងណា ប្រទេសនៃរាងកាយដែលត្រូវ ប៉ះដោយដង្គត់ និងបន្លាជាដើមក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា ខ្ទុះតាំង នៅក្នុងពួកយើង ខ្ទុះសោត ក៏មិនដឹងថា អញតាំងនៅក្នុងចំណែកនៃរាង កាយទាំងនោះ ដូច្នេះ ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នា និងគ្នា ព្រោះហេតុនោះ ទើបខ្ទុះ ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះ

ក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជារបស់រាវ មានអាការប្រមូលផ្តុំ ឈ្មោះថា **អាបោធាតុ** ។

ឈាមដែលហូរទៅមក ជ្រួតជ្រាបពេញសរីរៈទាំងមូល តាំងនៅដូចទឹកប្រមាត់ដែលមិនមានស្រោម ។ ឈាមដែលដក់ក្នុងរាងកាយ មានប្រមាណពេញមួយបាត្រ តាំងនៅខាងក្រោមឋានៈរបស់ថ្លើមធ្វើឲ្យទាប បេះដូង ថ្លើមសួតសើម ក្នុងឈាមទាំងនោះ គប្បីជ្រាបវិនិច្ឆ័យ ឈាមដែលហូរទៅមកដូចគ្នានឹងប្រមាត់មិនមានស្រោមនោះឯង ឯឈាមម្យ៉ាងទៀត ក្រៅអំពីនេះព្រះយោគី គប្បីមនសិការថា ទឹកដែលដក់ក្នុងភាជនៈចាស់ ញ៉ាំងដុំដី និងកំណាត់ឈើខាងក្រោមឲ្យសើម វត្ថុ មានដុំដី និងកំណាត់ឈើជាដើម រមែងមិនដឹងថា ពួកយើងសើមដោយទឹក តាំងនៅ សូម្បីទឹកក៏មិនដឹងថា អញធ្វើដុំដី និងកំណាត់ឈើជាដើម ឲ្យសើម ដូច្នេះ យ៉ាងណា ទីដែលជាចំណែកខាងក្រោមរបស់ថ្លើមក្តី ចំណែកផ្សេងៗ មានទាចជាដើមក្តី ក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា ឈាមដក់នៅក្នុងអញ ឈាមធ្វើអញនោះឯងឲ្យសើម សូម្បីឈាមសោត ក៏មិនដឹងថា អញពេញត្រង់ចំណែកខាងក្រោមរបស់ថ្លើម ធ្វើទាចជាដើម ឲ្យសើម ដូច្នេះ ធម្មជាតិទាំងនេះ វៀរចាកការគិតនិងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបឈាម ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរាវ មានអាការប្រមូលផ្តុំ ឈ្មោះថា **អាបោធាតុ** ។

ញើស រមែងតាំងនៅពេញរន្ធសក់ និងរណ្ដៅរោម រមែងហូរចេញក្នុងពេលដែលក្ដៅដោយភ្លើងជាដើម បណ្ដាញើសទាំងនោះ ព្រះយោគី គប្បីមនសិការថា កាលបុគ្គលដកក្រអៅឈូក ឫសឈូក និងទងផ្កាឈូក-**ស**អំពីទឹក បាច់នៃក្រអៅឈូកជាដើម រមែងមិនដឹងថា ទឹក រមែងហូរចេញអំពីពួកយើង ទឹកដែលហូរចេញអំពីក្រអៅឈូកជាដើម ក៏មិនដឹងថា អញហូរចេញអំពីបាច់នៃក្រអៅឈូកជាដើម ដូច្នេះ យ៉ាងណា សក់ និងរោម ក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា ញើស រមែងហូរចេញអំពីពួកយើង ញើសសោត ក៏មិនដឹងថា អញហូរចេញអំពីរន្ធសក់ និងរណ្ដៅរោម ដូច្នេះ ធម្មជាតិទាំងនេះវៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបញើសឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរាវ មានអាការប្រមូលផ្ដុំ ឈ្មោះថា **អាបោធាតុ** ។

ខ្លាញ់ខាប់ ជាខ្លាញ់ស្អិតខាប់ បើរបស់មនុស្សធាត់ រាត់រាយទៅកាន់សរីរៈទាំងមូល បើមនុស្សស្គម អាស្រ័យសាច់ដុំត្រយូងចេកជាដើម តាំងនៅ បណ្ដាខ្លាញ់ខាប់ទាំងនោះ ព្រះយោគី គប្បីមនសិការថា កាលដុំសាច់ត្រូវបិទដោយផ្ទាំងសំពត់ទុកូលចាស់ មានពណ៌ដូចរមៀត ដុំសាច់ រមែងមិនដឹងថា សំពត់ចាស់ពណ៌ដូចរមៀត អាស្រ័យអញ តាំងនៅ ទាំងសំពត់ចាស់ពណ៌រមៀត ក៏មិនដឹងថា អញអាស្រ័យដុំសាច់ តាំងនៅ ដូច្នេះ យ៉ាងណា សាច់ក្នុងសរីរៈទាំងមូល ឬត្រង់សាច់ដុំត្រយូងចេកជាដើម ក៏យ៉ាងនោះដូច

គ្នា រមែងមិនដឹងថា ខ្លាញ់ខាប់អាស្រ័យអញ តាំងនៅ សូម្បីខ្លាញ់ខាប់សោត ក៏មិនដឹងថា អញអាស្រ័យសាច់ តាំងនៅក្នុងសរីរៈទាំងមូល ឬត្រង់សាច់ដុំត្រយូងចេកជាដើម ដូច្នេះ ធម្មជាតិទាំងនេះ វៀរចាកការគិត និងការពិចា-រណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបខ្លាញ់ខាប់ ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាជ័រខាប់ ជាទឹកខាប់ មានការប្រមូលផ្តុំ ឈ្មោះថា **អាបោធាតុ** ។

ទឹកភ្នែកក្នុងពេលកើត ក៏ដក់ពេញប្រឡង់ភ្នែកខ្លះ ហូរចេញខ្លះ ក្នុងទឹកភ្នែកនោះ ព្រះយោគីគប្បីមនសិការថា កាលប្រឡង់នៃផ្លែត្នោតខ្ចីពេញដោយទឹក ផ្លែត្នោតខ្ចីទាំងឡាយ រមែងមិនដឹងថា ទឹកដក់នៅក្នុងពួកយើង សូម្បីទឹក ក៏មិនដឹងថា អញដក់នៅក្នុងប្រឡង់នៃផ្លែត្នោតខ្ចីទាំងឡាយ ដូច្នេះ យ៉ាងណា ប្រឡង់ភ្នែក ក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា ទឹកភ្នែកតាំងនៅក្នុងពួកយើង ទឹកភ្នែកសោត ក៏មិនដឹងថា អញតាំងនៅក្នុងប្រឡង់ភ្នែកទាំង ២ ដូច្នេះ ធម្មជាតិទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបទឹកភ្នែក ឈ្មោះថា ជាកោដ្ឋាស ១ មានដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរាវ មានអាការប្រមូលផ្តុំ ឈ្មោះថា **អាបោធាតុ** ។

ខ្លាញ់រាវ ជាខ្លាញ់ដែលរលាយក្នុងសរីរៈ តាំងនៅតាមបាតដៃ ខ្នងដៃ បាតជើង ខ្នងជើង ក្តោងច្រមុះ ថ្ងាស និងចុងស្មា ក្នុងពេលត្រូវក្តៅដោយ

ភ្លើងជាដើម ។ បណ្ដាខ្ញាញ់រាវទាំងនោះ ព្រះយោគី គប្បីមនសិការថា ក្នុងបាយក្ដាំងដែលបុគ្គលដាក់ប្រេងចូលទៅហើយ បាយក្ដាំង រមែងមិនដឹងថា ប្រេងលិចអញ តាំងនៅ សូម្បីប្រេងក៏មិនដឹងថា អញលិចបាយក្ដាំង តាំងនៅ ដូច្នេះ យ៉ាងណា ប្រទេស មានបាតដៃជាដើម ក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា ខ្ញាញ់រាវលិចអញ តាំងនៅ សូម្បីខ្ញាញ់រាវ ក៏មិនដឹងថា អញលិចប្រទេស មានបាតដៃជាដើម តាំងនៅ ដូច្នេះ ធម្មជាតិទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបខ្ញាញ់រាវ ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរាវ មានអាការប្រមូលផ្ដុំ ឈ្មោះថា **អាបោធាតុ** ។

ទឹកមាត់ កាលមានបច្ច័យ ដែលនឹងឲ្យកើតណាមួយ ទឹកមាត់នោះ តែងហូរចេញអំពីថ្ពាល់ទាំង ២ មកតាំងនៅត្រង់អណ្ដាត ។ បណ្ដាទឹកមាត់នោះ ព្រះយោគី គប្បីមនសិការថា អណ្ដូងក្បែរមាត់ស្ទឹង មានទឹកហូរមកមិនដាច់ ផ្ទៃអណ្ដូង រមែងមិនដឹងថា ទឹកតាំងនៅក្នុងអញ ទឹក ក៏មិនដឹងថា អញតាំងនៅក្នុងអណ្ដូង ដូច្នេះ យ៉ាងណា ផ្ទៃអណ្ដាតក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា ទឹកមាត់ហូរចេញអំពីថ្ពាល់ទាំង ២ មកតាំងនៅក្នុងអញ សូម្បីទឹកមាត់សោត ក៏មិនដឹងថា អញហូរចេញអំពីថ្ពាល់ទាំង ២ មកតាំងនៅត្រង់ផ្ទៃអណ្ដាត ដូច្នេះ ធម្មជាតិទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបទឹកមាត់ ឈ្មោះថា ជាកោដ្ឋាស ១ ដោយ

ចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរាវ មានអាការប្រមូលផ្តុំ ឈ្មោះថា **អាបោធាតុ** ។

ទឹកសម្បោរ ក្នុងពេលកើត តាំងនៅពេញរន្ធប្រមុះខ្លះ ហូរចេញខ្លះ ក្នុងទឹកសម្បោរនោះ ព្រះយោគី គប្បីមនសិការថា កាលស័ង្ខដែលពេញដោយទឹកដោះជូរ ស័ង្ខ រមែងមិនដឹងថា ទឹកដោះជូរតាំងនៅក្នុងអញ សូម្បីទឹកដោះជូរ ក៏មិនដឹងថា អញតាំងនៅក្នុងស័ង្ខ ដូច្នេះ យ៉ាងណា រន្ធប្រមុះ ក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា សម្បោរតាំងនៅក្នុងពួកយើង សូម្បីទឹកសម្បោរសោត ក៏មិនដឹងថា អញតាំងនៅក្នុងរន្ធប្រមុះ ដូច្នេះ ធម្មជាតិទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបទឹកសម្បោរឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរាវ មានលក្ខណៈប្រមូលផ្តុំ ឈ្មោះថា **អាបោធាតុ** ។

ទឹករម្អិល ធ្វើកិច្ចផ្សែមសន្ទាក់ឆ្អឹង តាំងនៅក្នុងទី-**ត**ទាំង ១៨០ កន្លែង ក្នុងទឹករម្អិលនោះ ព្រះយោគី គប្បីមនសិការថា កាលគេយកប្រេងលាបភ្លៅរទេះ ភ្លៅរទេះ រមែងមិនដឹងថា ប្រេងលាបអញ សូម្បីប្រេង ក៏មិនដឹងថា អញលាបភ្លៅរទេះ ដូច្នេះ យ៉ាងណា ទី-**ត**ឆ្អឹងទាំង ១៨០ ក៏យ៉ាងនោះដូចគ្នា រមែងមិនដឹងថា ទឹករម្អិលលាបពួកយើង ទឹករម្អិលសោត ក៏មិនដឹងថា អញលាបទី-**ត**ទាំង ១៨០ ដូច្នេះ ធម្មជាតិទាំងនេះ វៀរចាកការគិត និងការពិចា-រណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបទឹករម្អិល ឈ្មោះថា ជាកោដ្ឋាស

១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរឹង មានអាការប្រមូលផ្តុំ ឈ្មោះថា **អាបោធាតុ** ។

ទឹកមូត្រ តាំងនៅក្នុងតម្រងបស្សាវៈ ។ ក្នុងទឹកមូត្រនោះ ព្រះយោគីគប្បីមនសិការថា ឆ្នាំងអំបិលដែលគេផ្កាប់មាត់ចុះក្រោម ក្នុងទឹកជ្រាំ ឆ្នាំងអំបិល រមែងមិនដឹងថា រសទឹកជ្រាំតាំងនៅក្នុងអញ រសទឹកជ្រាំ ក៏មិនដឹងថា អញតាំងនៅក្នុងឆ្នាំងអំបិល ដូច្នេះ យ៉ាងណា តម្រងបស្សាវៈ ក៏យ៉ាងនោះដូចគ្នា តែងមិនដឹងថា ទឹកមូត្រ តាំងនៅក្នុងអញ សូម្បីទឹកមូត្រសោត ក៏មិនដឹងថា អញតាំងនៅក្នុងតម្រងបស្សាវៈ ដូច្នេះ ធម្មជាតិទាំងនេះ វៀរចាកការគិត និងការពិចារណានូវគ្នានិងគ្នា ព្រោះហេតុនោះ ទើបទឹកមូត្រ ឈ្មោះថា ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ ជាធម្មជាតិរឹង មានអាការប្រមូលផ្តុំ ឈ្មោះថា **អាបោធាតុ** ។

បទថា **យំ វា បន** នេះ ព្រះមានព្រះភាគត្រាស់សំដៅយកអាបោធាតុក្នុងកោដ្ឋាស ៣ ដ៏សេស ។

គប្បីជ្រាបវិនិច្ឆ័យនិទ្ទេសអាបោធាតុខាងក្រៅដូចតទៅ

រសដែលអាស្រ័យឫសឈើកើតឡើង ឈ្មោះថា **មូលរស** ។ ក្នុងរសទាំងឡាយ មានរសកើតអំពីដើមជាដើម ក៏មានន័យនេះដូចគ្នា ។ វត្ថុមានទឹកដោះស្រស់ជាដើម ជាក់ច្បាស់ហើយនោះឯង តែក្នុងទីនេះ មិនមាន

កំណត់ពិតប្រាកដ ដូចក្នុងសិក្ខាបទ ដែលពោលអំពីភេសជ្ជៈ ។ ទឹកដោះស្រស់ណាមួយ ឈ្មោះថា ខីរៈ នោះឯង ក្នុងបទដ៏សេសទាំងឡាយ ក៏ន័យនេះដូចគ្នា ។

បទថា **កុម្ភានិ** បានដល់ ទឹកដែលនៅក្នុងអណ្តូងជាដើម ។ បទថា **អន្តលិក្ខានិ** បានដល់ ទឹកភ្លៀងដែលមិនទាន់ធ្លាក់ដល់ផែនដី ។ បទថា **យំ វា បន** បានដល់ ទឹកសន្សើម ទឹកញុំាងកប្បឲ្យវិនាស ទឹកទ្រផែនដីជាដើម សង្គ្រោះចូលក្នុងឋានៈយេវាបនកន័យក្នុងទីនេះ ។

[ ១១៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសតេជោធាតុដូចតទៅ

ឈ្មោះថា **តេជោ** ដោយអំណាចធ្វើឲ្យក្តៅ ។ តេជោនោះឯង ឈ្មោះថា **តេជោគតំ** ព្រោះជាធម្មជាតិដល់នូវភាពជារបស់ក្តៅ ។ បទថា **ឧស្មា** បានដល់ អាការក្តៅ ។ ការក្តៅនោះឯង ឈ្មោះថា **ឧស្មាគតំ** ព្រោះជាធម្មជាតិដល់នូវភាពជាអាការក្តៅ ។ បទថា **ឧសុមំ** បានដល់ ការក្តៅដ៏ខ្លាំង ។ កម្តៅយ៉ាងខ្លាំងនោះឯង ឈ្មោះថា **ឧសុមគតំ** ព្រោះជាធម្មជាតិដល់នូវការក្តៅយ៉ាងខ្លាំង ។

បទថា **យេន ច** បានដល់ ធម្មជាតិដែលក្តៅ ដែលកម្រើកហើយ ។ បទថា **សន្តប្បតិ** បានដល់ កាយនេះ រមែងក្តៅ គឺកើតនូវកម្តៅដោយភាវៈដែលមានការចាស់ទៅអស់មួយថ្ងៃជាដើម ។

បទថា **យេន ច ជីរីយតិ** បានដល់ កាយនេះ រមែងទ្រុឌទ្រោម រមែងដល់នូវការខ្វះខាតនៃឥន្ទ្រិយ ការអស់កម្លាំង និងភាវៈមានស្បែកជ្រីវជ្រួញ

និងសក់ស្កូវជាដើម ដោយតេជោធាតុណា ។

ពាក្យថា **យេន ច បរិឌយ្ហតិ** បានដល់ កាយនេះ ត្រូវតេជោធាតុណា ដែលកម្រើកដុតពេល បុគ្គលនោះ ក៏កន្ទក់កន្ទេញថា ខ្ញុំក្តៅៗ ដូច្នេះ បំណង នឹងយកសប្បិដែលចម្រាញ់រាប់រយដង និងចន្ទន៍ក្រហមជាដើមមកលាប ឬ ត្រូវការខ្យល់អំពីផ្លិតស្លឹកត្នោត ។

បទថា **យេន ច អសិតបីតខាយិតសាយិតំ សម្មា បរិណាមំ គច្ឆតិ** សេចក្តីថា របស់បរិភោគ មានបាយជាដើមក្តី របស់ផឹក មានទឹកជាដើមក្តី របស់ទំពា មាននំធ្វើអំពីម្សៅក្តី របស់លិទ្ធភក្ស មានផ្លែស្វាយទុំ ទឹកឃ្មុំ ទឹកអំពៅជាដើមក្តី រមែងដល់នូវការរលួយ គឺរមែងរលួយទៅដោយភាពជារសជាដើមដោយល្អ ដោយតេជោធាតុណា ម្យ៉ាងទៀត ក្នុងតេជោធាតុទាំង ៤ នេះ តេជោធាតុ ៣ ខាងដើម មានសមុដ្ឋាន ៤ យ៉ាង តេជោធាតុក្រោយ មានកម្មជាសមុដ្ឋានតែម្យ៉ាង ។

អធិប្បាយក្នុងតេជោធាតុនេះ មានប្រមាណប៉ុណ្ណោះ ។

វិធីមនសិការតេជោធាតុ មានដូចតទៅនេះ

ភិក្ខុក្នុងធម្មវិន័យនេះ រមែងមនសិការថា កាយនេះ រមែងក្តៅដោយធាតុ ធាតុនេះ ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ មានអាការធ្វើឲ្យក្តៅ ឈ្មោះថា **តេជោធាតុ ។** រមែងមនសិការថា កាយនេះ រមែងទ្រុឌទ្រោម ដោយធាតុណា រមែងក្តៅដោយធាតុណា រមែងញុំាំងរបស់ស៊ី របស់ផឹក របស់

ទំពា របស់លិទ្ធភក្សឲ្យដល់នូវការរលួយដោយល្អដោយធាតុណា ធាតុនេះ ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ មានអាការធ្វើឲ្យក្តៅ ឈ្មោះថា **តេជោធាតុ** ។

បទថា **យំ វា បន** សេចក្តីថា ក្នុងសរីរៈនេះ មានឧតុប្រភេទណាមួយ ជាប្រក្រតី ឧតុនោះ ក៏សង្គ្រោះចូលក្នុងឋានៈរបស់យេវាបនកន័យ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃតេជោធាតុខាងក្រៅដូចតទៅ

ភ្លើងឆេះ ព្រោះអាស្រ័យឈើ មានឈើជាកំញម ឈ្មោះថា **កដ្ឋគ្គិ** ។ ក្នុងពាក្យថា ភ្លើងរំកាច់ជាដើម ក៏មានន័យនេះដូចគ្នា ។

បទថា **សង្ការគ្គិ** បានដល់ ភ្លើងដែលបុគ្គលជញ្ជូនយកសំរាមមកដុត ធ្វើឲ្យឆេះ ឈ្មោះថា ភ្លើងសំរាម ។

បទថា **ឥន្ទគ្គិ** បានដល់ ភ្លើងរន្ទះ ។

បទថា **អគ្គិសន្តាបោ** បានដល់ កម្តៅនៃអណ្តាតភ្លើង ឬរបស់រងើក ភ្លើងដែលប្រាសចាកអណ្តាត ។

បទថា **សូរិយសន្តាបោ** បានដល់ កម្តៅថ្ងៃ ។

បទថា **កដ្ឋសន្និចយសន្តាបោ** បានដល់ កម្តៅក្នុងគំនរឧស ។ ក្នុងបទដ៏សេសក៏មានន័យដូចគ្នា ។

បទថា **យំ វា បន** បានដល់ ភ្លើងឆេះប្រេត ភ្លើងញ៉ាំងកប្បឲ្យវិនាស និងភ្លើងនរកជាដើម ក៏សង្គ្រោះចូលក្នុងឋានៈរបស់យេវាបនកន័យក្នុងទីនេះ ។

[ ១១៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសវាយោធាតុដូចតទៅ ឈ្មោះថា **វាយោ** ដោយអំណាចនៃការបក់ទៅមក ខ្យល់បក់ទៅមកនោះឯង ឈ្មោះថា **វាយោគតំ** ព្រោះដល់នូវភាពជាវាយោ ។

បទថា **ថម្ភិតត្តំ រូបស្ស** បានដល់ ការតឹងនៃអវិនិព្ភោគរូប ។

បទថា **ឧទ្ធង្គមា វាតា** បានដល់ ខ្យល់ដែលបក់ទៅខាងលើធ្វើឲ្យក្អួតឬត្អើកជាដើម ។

បទថា **អធោគមា វាតា** បានដល់ ខ្យល់ដែលបក់ចុះខាងក្រោម ញុំាងឧច្ចារៈ និងបស្សាវៈឲ្យចេញទៅជាដើម ។

បទថា **កុច្ឆិសយា វាតា** បានដល់ ខ្យល់ដែលនៅខាងក្រៅពោះវៀនធំ ។

បទថា **កោដ្ឋាសយា វាតា** បានដល់ ខ្យល់ក្នុងពោះវៀនធំទាំងឡាយ ។

បទថា **អង្គមង្គានុសារិនោ វាតា** បានដល់ ខ្យល់ដែលបក់ទៅតាមអវយវៈតូចធំ ក្នុងសរីរៈទាំងមូល ដោយបក់ទៅតាមប្រហោងសរសៃ ធ្វើឲ្យកើតនូវការបត់ និងការលាដៃជាដើម ។ បទថា **សត្ថកវាតា** បានដល់ ខ្យល់ដែលបក់ទៅ ដូចយកកន្ត្រៃកាត់ទី-ត និងសរសៃ ។ បទថា **ខុរកវាតា** បានដល់ ខ្យល់ដែលពុះបេះដូង ដូចវះដោយកំបិតកោរ ។ បទថា **ឧប្បលកវាតា** បានដល់ ខ្យល់ដែលទម្លាយសាច់បេះដូងនោះឯង ។

បទថា **អស្សាសោ** បានដល់ ខ្យល់ច្រមុះដែលចូលទៅខាងក្នុង ។ បទថា **បស្សាសោ** បានដល់ ខ្យល់ច្រមុះដែលចេញទៅខាងក្រៅ ។ ឯខ្យល់

ខាងក្នុងនេះ ខ្យល់ទាំងអស់ខាងដើម មានសមុដ្ឋាន ៤ ខ្យល់ដង្ហើមចូល និង ខ្យល់ដង្ហើមចេញ មានចិត្តជាសមុដ្ឋានតែម្យ៉ាង ។

អធិប្បាយក្នុងធាតុនេះ មានប្រមាណប៉ុណ្ណេះ ។

ម្យ៉ាងទៀត វិធីមនសិការវាយោធាតុមានដូចតទៅនេះ

ភិក្ខុក្នុងសាសនានេះ កំណត់ខ្យល់ទាំងឡាយ មានខ្យល់បក់ឡើងលើជាដើម ដោយអំណាចការពិចារណាខ្យល់ដែលបក់ឡើងខាងលើជាដើមហើយ មនសិការថា ឈ្មោះថា ខ្យល់បក់ឡើងលើ ជាកោដ្ឋាស ១ ដោយចំពោះក្នុងសរីរៈនេះ មិនមានចេតនា ជាអព្យាកត ជារបស់សោះសូន្យ មិនមែនសត្វ មានអាការតឹង ឈ្មោះថា វាយោធាតុ ។ សូម្បីក្នុងខ្យល់ដ៏សេសក៏មានន័យនេះដូចគ្នា ។

បទថា **យំ វា បន** បានដល់ ខ្យល់ដែលបក់ទៅក្នុងកោដ្ឋាសនៃវាយោធាតុដ៏សេស ក៏សង្គ្រោះចូលក្នុងឋានៈរបស់យេវាបនកន័យក្នុងទីនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសវាយោធាតុខាងក្រៅដូចតទៅ

បទថា **បុរត្ថិមា វាតា** បានដល់ ខ្យល់ដែលបក់មកអំពីទិសខាងកើត សូម្បីក្នុងខ្យល់ដែលបក់មកអំពីទិសខាងលិច ទិសខាងជើង និងទិសខាងត្បូងក៏មានន័យនេះដូចគ្នា ។

បទថា **សរជា វាតា** បានដល់ ខ្យល់ដែលបក់មកជាមួយធូលី ឈ្មោះថា ខ្យល់មានធូលី ។

បទថា **អរជា វាតា** បានដល់ ខ្យល់សុទ្ធ ប្រាសចាកលម្អងធូលី

ឈ្មោះថា ខ្យល់មិនមានធូលី ។

បទថា **សីតា** បានដល់ ខ្យល់ដែលមានរដូវរងាជាសមុដ្ឋាន តាំងឡើងក្នុងវាងពពកដែលត្រជាក់ ។

បទថា **ឧណ្ហា** បានដល់ ខ្យល់ដែលមានរដូវក្តៅជាសមុដ្ឋាន តាំងឡើងខាងក្នុងពពកដែលក្តៅ ។

បទថា **បរិត្តា** បានដល់ ខ្យល់ដែលបក់មករំភើយៗ គឺបក់មកតិចៗ ។

បទថា **អធិមត្តា** បានដល់ ខ្យល់ដែលបក់មកខ្លាំង ។

បទថា **កាឡា** បានដល់ ខ្យល់ដែលតាំងឡើងក្នុងពពកខ្មៅ អាចារ្យពួកខ្លះពោលថា ពាក្យថា ខ្យល់ខ្មៅនេះ ជាឈ្មោះនៃខ្យល់ដែលបក់ធ្វើឲ្យស្បែកខ្មៅក៏មាន ។

បទថា **វេរម្ភវាតា** បានដល់ ខ្យល់ដែលបក់ទៅខាងលើជាង ១ យោជន៍ ។

បទថា **បក្ខវាតា** បានដល់ ខ្យល់ ដែលតាំងឡើងអំពីការទទះស្លាបដោយហោចសូម្បីស្លាបរុយ ។

បទថា **សុបណ្ណវាតា** បានដល់ ខ្យល់ដែលកើតអំពីគ្រុឌ ខ្យល់គ្រុឌនេះ ជាខ្យល់ដែលកើតអំពីស្លាបក៏ពិត តែលោកកាន់យកដោយចំណែកមួយព្រោះជាខ្យល់ខ្លាំង ។

បទថា **តាលវណ្ដវាតា** បានដល់ ខ្យល់ដែលកើតអំពីស្លឹកត្នោត ឬវត្ថុមានសណ្ឋានមូលណាមួយ ។

បទថា **វិជ្ជុបនវាតា** បានដល់ ខ្យល់ដែលកើតឡើងដោយផ្ចិត ខ្យល់ដែលកើតឡើងអំពីស្លឹកត្នោត និងខ្យល់ដែលកើតអំពីផ្ចិតទាំងនេះ រមែងញុំាងខ្យល់ដែលមិនទាន់កើតឲ្យកើតឡើង ស្ងប្បកើតឡើងហើយក៏ឲ្យអន្តរធានទៅ ។

ក្នុងបទថា **យំ វា បន** នេះ បានដល់ ខ្យល់ដ៏សេស វៀរខ្យល់ដែលមកក្នុងបាលី ហើយសង្គ្រោះចូលក្នុងឋានៈជាយេវាបនកន័យ ។

[ ១១៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសអាកាសធាតុដូចតទៅ

ដែលឈ្មោះថា អាកាស ព្រោះអត្ថថា ក្ឈូរមិនបាន ដោយអត្ថថា ប៉ះពាល់មិនបាន ។ អាកាសនោះឯង ឈ្មោះថា **អាកាសគតំ** ព្រោះដល់នូវភាវៈជាអាកាស ។ ដែលឈ្មោះថា **អឃំ** បានដល់ ទទេ ព្រោះជារបស់ដែលប៉ះមិនបាន ។ ភាពទទេនោះឯង ឈ្មោះថា **អឃគតំ** ព្រោះជាធម្មជាតិដល់នូវភាពទទេ ។ បទថា **វិវរោ** បានដល់ ប្រហោងក្នុងចន្លោះ ។ ចន្លោះនោះឯង ឈ្មោះថា **វិវរគតំ** ព្រោះជាធម្មជាតិដល់នូវភាពជាឱកាសទទេ ។ បទថា **អសម្ផុដ្ឋំ មំសលោហិតេហិ** បានដល់ ដែលសាច់ និងឈាម មិនពាល់ត្រូវ ។ បទថា **កណ្ណច្ឆិទ្ទំ** ជាដើមនេះ ជាពាក្យសម្តែងប្រភេទនៃពាក្យដែលសាច់ និងឈាម មិនពាល់ត្រូវនោះឯង ។

បណ្តាបទទាំងនោះ បទថា **កណ្ណច្ឆិទ្ទំ** បានដល់ ឱកាស គឺប្រហោងក្នុងត្រចៀក គឺឱកាសដែលសាច់ និងឈាម មិនពាល់ត្រូវ ។ ក្នុងពាក្យដ៏សេសក៏មានន័យនេះដូចគ្នា ។

បទថា **យេន** សេចក្តីថា សត្វ រមែងលេបនូវវត្ថុដែលគួរលេប មាន

របស់បរិភោគជាដើមនេះ គឺឲ្យចូលទៅខាងក្នុងដោយឱកាសណា ។ បទថា **យត្ថ** សេចក្តីថា អាហារដែលលេបចូលទៅ ៤ យ៉ាងនោះឯង រមែងតាំងនៅក្នុងឱកាស ពោល គឺខាងក្នុងក្រពះណា ។ បទថា **យេន** សេចក្តីថា អាហារ ៤ យ៉ាងនោះ ដែលរលួយហើយ ដល់នូវភាពជាសំណល់ហើយ រមែងចេញទៅតាមឱកាសណា ឱកាសនោះ ចាប់អំពីក្រពះដល់ទ្វារធំ មានប្រមាណ ១ ចំអាម ៤ ធ្នាប់ ជាទីដែលសាច់ និងឈាមមិនពាល់ត្រូវ គឺជាទីដែលសាច់ និងឈាម មិនជាប់គ្នា គប្បីជ្រាបថា ជាអាកាសធាតុ ។

ក្នុងបទថា **យំ វា បន** នេះ បានដល់ ឱកាសទទេទាំងអស់នេះ គឺ ឱកាសរវាងស្បែក ឱកាសរវាងសាច់ ឱកាសរវាងសរសៃ ឱកាសរវាងឆ្អឹង ឱកាសរវាងរោម លោករួមចូលក្នុងឋានៈរបស់យេវាបទកន័យ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសអាកាសធាតុខាងក្រៅដូចតទៅ

ពាក្យថា **អសម្ផុដ្ឋំ ចតូហិ មហាភូតេហិ** នោះ ទុំះបណ្ឌិតគប្បីជ្រាបថា ជាប្រហោងជញ្ជាំងផ្ទះ និងមាត់ទ្វារជាដើម ដែលមហាភូតរូប ៤ មិនដល់គ្នា ។ កាលព្រះយោគាវចរធ្វើបរិកម្មក្នុងអាកាសណា ចតុត្ថជ្ឈាន ឬបញ្ចមជ្ឈាន រមែងកើតឡើងបាន ទ្រង់ត្រាស់ដល់អាកាសនោះ ដោយពាក្យថា អាកាសធាតុខាងក្រៅនេះ ។

[ ១២០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសវិញ្ញាណធាតុដូចតទៅ

ធាតុ ពោល គឺចក្ខុវិញ្ញាណ ឈ្មោះថា ចក្ខុវិញ្ញាណធាតុ ក្នុងធាតុដ៏សេសក៏មានន័យនេះដូចគ្នា ។ កាលព្រះយោគាវចរកំណត់ធាតុ ៦ ដោយ

ប្រការដូច្នេះហើយ ធាតុ ១៨ ឈ្មោះថា ជាការកំណត់ហើយនោះឯង សួរថា កំណត់ដូចម្ដេច ឆ្លើយថា ជាបឋម ផោដ្ឋព្វធាតុ ឈ្មោះថា លោកកាន់យកដោយសព្ទថា **បឋវី តេជោ វាយោ** នោះឯង ធម្មធាតុដែលលោកកាន់យកដោយសព្ទថា **អាបោធាតុ** និង **អាកាសធាតុ** មនោធាតុ ឈ្មោះថា លោកកាន់យកដោយសព្ទថា **វិញ្ញាណធាតុ** ព្រោះមនោធាតុនោះ ជាធម៌កើតឡើងមុន និងកើតក្រោយនៃវិញ្ញាណធាតុនោះឯង ចក្ខុវិញ្ញាណធាតុជាដើម មកហើយក្នុងសូត្រនោះឯង ធាតុ ៩ យ៉ាងដ៏សេស បណ្ឌិតគប្បីនាំមកសម្ដែង ព្រោះថា ចក្ខុធាតុដែលជាទីអាស្រ័យកើតរបស់ចក្ខុវិញ្ញាណធាតុនោះ និងរូបធាតុដែលជាអារម្មណ៍នៃចក្ខុវិញ្ញាណធាតុនោះ ឈ្មោះថា លោកកាន់យកដោយសព្ទថា **ចក្ខុវិញ្ញាណធាតុ** ដោយប្រការដូច្នេះ ដោយសព្ទថា **សោតវិញ្ញាណធាតុ** ជាដើម **សោតធាតុ** ជាដើម ឈ្មោះថា លោកកាន់យកធាតុ ១៨ ចូលផងដែរ ។

បណ្ដាធាតុ ១៨ នោះ លោកកំណត់រូបធាតុ ១០ កំណត់អរូបធាតុ ៧ ដោយធម្មធាតុ លោកកំណត់យករូបធាតុក៏មាន កំណត់យកអរូបធាតុក៏មាន ដោយហេតុនេះ ទើបការកំណត់រូបធាតុ មាន ១០ កន្ទះ ការកំណត់អរូបធាតុ មាន ៧ កន្ទះ ព្រោះហេតុនោះ ការកំណត់រូបធាតុ និងអរូបធាតុ ឈ្មោះថា លោកបានសម្ដែងហើយ ។ រូប និងអរូប គឺបញ្ចក្ខន្ធ បណ្ឌិតគប្បីសម្ដែងយ៉ាងនេះ គឺធម៌ដែលជារូប និងអរូបនោះ ជាទុក្ខសច្ច តណ្ហាក្នុងភពមុនដែលជាហេតុឲ្យទុក្ខសច្ចនោះតាំងឡើង ជាសមុទយសច្ច ការមិនប្រព្រឹត្តទៅនៃ

ទុក្ខសច្ច និងសមុទយសច្ចទាំង ២ ជានិរោធសច្ច មគ្គដែលជាហេតុ ដឹង និរោធសច្ចនោះ ជាមគ្គសច្ច ព្រោះហេតុនោះ កម្មដ្ឋានមានសច្ចៈ ៤ ជាអារម្មណ៍នេះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ឲ្យដល់ទីបំផុត រហូតដល់អរហត្តហើយ ទើបបញ្ចប់ដល់ភិក្ខុដែលត្រូវការដោយអំណាចធាតុ ១៨ ។

[ ១២១ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សំដែងធាតុ ៦ ដោយន័យទី ២ ទើបត្រាស់ថា **អបរាបិ ឆ ធាតុយោ** ជាដើម ។

ក្នុងព្រះបាលីនោះ ពាក្យថា **សុខធាតុ ទុក្ខធាតុ** បានដល់ សុខ និង ទុក្ខ ដែលអាស្រ័យកាយបសាទកើតឡើង ដែលទ្រង់សំដែងធ្វើឲ្យជារបស់គូគ្នាដោយអំណាចជាបដិបក្ខគ្នា ។ ពិតហើយ សុខជាបដិបក្ខចំពោះទុក្ខ ទុក្ខក៏ជាបដិបក្ខចំពោះសុខ ។ ឋានៈដែលសុខផ្សាយទៅហើយ មានប្រមាណប៉ុន្មានក្នុងកាយនេះ ទុក្ខក៏ផ្សាយទៅមានប្រមាណប៉ុណ្ណោះ ។ ឋានៈដែលទុក្ខផ្សាយទៅហើយ មានប្រមាណប៉ុន្មាន សុខក៏ផ្សាយទៅមានប្រមាណប៉ុណ្ណោះ ។

បទថា **សោមនស្សធាតុ ទោមនស្សធាតុ** នេះ ព្រះមានព្រះភាគ ទ្រង់ធ្វើឲ្យជាគូគ្នា ដូចសុខ និងទុក្ខនោះឯង ពិតហើយ សោមនស្ស ជាបដិបក្ខចំពោះទោមនស្ស ។ ទោមនស្សក៏ជាបដិបក្ខចំពោះសោមនស្ស ឋានៈដែលសោមនស្សផ្សាយទៅក្នុងសរីរៈនេះ មានប្រមាណប៉ុន្មាន ទោមនស្ស ក៏ផ្សាយទៅ មានប្រមាណប៉ុណ្ណោះ ឋានៈដែលទោមនស្សផ្សាយទៅ មានប្រមាណប៉ុន្មាន សោមនស្ស ក៏ផ្សាយទៅមានប្រមាណប៉ុណ្ណោះ ។

ម្យ៉ាងទៀត ២ បទនេះថា **ឧបេក្ខាធាតុ អវិជ្ជាធាតុ** ត្រាស់ការធ្វើឲ្យជាគូគ្នា ដោយអំណាចជាធម៌ស្រដៀងគ្នា ។ ពិតហើយ ធាតុទាំង ២ នេះជាធាតុស្រដៀងគ្នា ព្រោះជាធាតុមិនប្រាកដច្បាស់ ។

បណ្តាធាតុទាំងនោះដោយសព្ទថា សុខធាតុ និងទុក្ខធាតុ កាយវិញ្ញាណ-ធាតុ កាយធាតុដែលជាទីអាស្រ័យកើត និងផោដ្ឋព្វធាតុដែលជាអារម្មណ៍ រមែងឈ្មោះថា កាន់យកផងដែរ ។ ដោយសព្ទថា សោមនស្សធាតុ និងទោមនស្សធាតុ មនោវិញ្ញាណធាតុ ដែលសម្បយុត្តដោយសោមនស្សធាតុ និងទោមនស្សធាតុនោះ រមែងឈ្មោះថា កាន់យកហើយ ។ ដោយសព្ទថា អវិជ្ជាធាតុ ធម្មធាតុ រមែងឈ្មោះថា កាន់យកហើយ ។ ដោយសព្ទថា ឧបេក្ខាធាតុ ចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជិវ្ហា-វិញ្ញាណធាតុ និងមនោធាតុ និងចក្ខុធាតុ រូបធាតុជាដើម ដែលជាវត្ថុ និងជាអារម្មណ៍របស់ចក្ខុវិញ្ញាណទាំងនោះឯងជាដើម ឈ្មោះថា កាន់យកហើយ ព្រោះហេតុនោះ ទើបធាតុ ១៨ ឈ្មោះថា កាន់យកហើយនោះឯង ដោយប្រការដូច្នេះ ។

ឥឡូវនេះ គប្បីជ្រាបពាក្យទាំងអស់ មានពាក្យថា បណ្តាធាតុ ១៨ នោះ លោកកំណត់រូបធាតុ ១០ ជាដើម ដោយន័យដែលពោលមកហើយនោះឯង និងគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ដល់ភិក្ខុមួយរូបឲ្យដល់ទីបំផុតរហូតដល់អរហត្តហើយ ទើបទ្រង់បញ្ចប់ដោយប្រការដូច្នេះ ។

បទថា **តត្ថ កតមា សុខធាតុ យំ កាយិកំ សាតំ** ជាដើម មាន

ន័យតាមដែលពោលហើយនោះឯង ។

[ ១២២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសធាតុ ៦ ដោយន័យទី ៣ ដូចតទៅ

ពាក្យថា កាម បានដល់ កាម ២ គឺវត្ថុកាម និងកិលេសកាម បណ្ដាកាមទាំង ២ នោះ ធាតុដែលប្រកបដោយកាម សំដៅដល់ កិលេសកាម ឈ្មោះថា កាមធាតុ កាមធាតុនេះ ជាឈ្មោះនៃកាមវិតក្ក ។ ធាតុ គឺកាម សំដៅដល់ វត្ថុកាម ឈ្មោះថា កាមធាតុ ពាក្យនេះ ជាឈ្មោះនៃកាមាវចរធម៌ ។ ធាតុដែលប្រកបដោយព្យាបាទ ឈ្មោះថា ព្យាបាទធាតុ ពាក្យថា ព្យាបាទ-ធាតុនេះ ជាឈ្មោះនៃព្យាបាទវិតក្ក ។ ធាតុ គឺព្យាបាទនោះ ឈ្មោះថា ព្យា-បាទធាតុ ពាក្យថា ព្យាបាទធាតុនេះ ជាឈ្មោះរបស់បដិឃៈ មានអាឃាតវត្ថុ ១០ ។ ធាតុដែលប្រកបដោយវិហិង្សា ឈ្មោះថា វិហិង្សាធាតុ ពាក្យថា វិហិង្សាធាតុនេះ ជាឈ្មោះរបស់វិហិង្សាវិតក្ក ។ ធាតុ គឺវិហិង្សា ឈ្មោះថា វិហិង្សាធាតុ ពាក្យនេះ ជាឈ្មោះរបស់ការបៀតបៀនសត្វដទៃ ។ មួយវិញទៀត វិហិង្សានេះ ព្រោះមិនធ្លាប់មក ទើបគួរជ្រាបដោយការចែកអត្ថជាដើម ដូចតទៅនេះ ដែលឈ្មោះថា វិហិង្សា ព្រោះអត្ថថា ជាហេតុឲ្យបៀតបៀនសត្វ ឬជាការបៀតបៀនសត្វទាំងឡាយ ។ វិហិង្សានោះ បណ្ឌិតគប្បីជ្រាបថា មានការបៀតបៀនជាលក្ខណៈ ឬមានភាពជាបដិបក្ខចំពោះករុណា ជាលក្ខណៈ មានការឲ្យកើតការតក់ស្លុតក្នុងសន្ដានរបស់សត្វដទៃជាកិច្ច ឬមានការកម្ចាត់ករុណាក្នុងសន្ដានរបស់ខ្លួនជាកិច្ច មានភាពជាប្រភពកើតនៃទុក្ខជា

បច្ចុប្បដ្ឋាន មានបដិឃៈជាបទដ្ឋាន ។

អលោភៈ ហៅថា នេក្ខម្មៈ ព្រោះចេញចាកសេចក្តីលោភ ។ បឋមជ្ឈាន ក៏ហៅថា នេក្ខម្មៈ ព្រោះចេញចាកនីវរណៈទាំងឡាយ កុសលទាំងអស់ ក៏ហៅថា នេក្ខម្មៈ ព្រោះចេញចាកអកុសលទាំងអស់ ។ ធាតុដែលប្រកបដោយនេក្ខម្មៈ ឈ្មោះថា **នេក្ខម្មធាតុ** ពាក្យថា នេក្ខម្មធាតុនេះ ជាឈ្មោះនៃនេក្ខម្មវិតក្ក ។ ធាតុ គឺនេក្ខម្មៈ ឈ្មោះថា **នេក្ខម្មធាតុ** ពាក្យថា នេក្ខម្មធាតុនេះ ជាឈ្មោះរបស់កុសលទាំងអស់ ។ ធាតុដែលប្រកបដោយការមិនអព្យាបាទ ឈ្មោះថា **អព្យាបាទធាតុ** ពាក្យថា អព្យាបាទធាតុនេះ ជាឈ្មោះនៃអព្យាបាទវិតក្ក ។ ធាតុ គឺអព្យាបាទ ឈ្មោះថា អព្យាបាទធាតុ ពាក្យថា អព្យាបាទធាតុនេះ ជាឈ្មោះរបស់មេត្តា ។ ធាតុដែលប្រកបដោយការមិនបៀតបៀន ឈ្មោះថា **អវិហិំសាធាតុ** ពាក្យថា អវិហិំសាធាតុនេះ ជាឈ្មោះនៃអវិហិំសាវិតក្ក ធាតុ គឺអវិហិំសា ឈ្មោះថា **អវិហិំសាធាតុ** ពាក្យថា អវិហិំសាធាតុនេះ ជាឈ្មោះនៃករុណា ។

ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់បំណាននឹងសម្តែងអត្ថនោះឯង ទើបផ្តើមបទភាជនថា **តត្ថ កតមា កាមធាតុ** ជាដើម ។

ក្នុងព្រះបាលីនោះ បទថា **បដិសំយុត្តោ** បានដល់ ប្រកបដោយអំណាចសម្បយុត្ត ។ បទថា **តក្កោ វិតក្កោ** ជាដើម មានអត្ថតាមដែលពោលហើយនោះឯង ។ បទថា **វិហេឋេតិ** បានដល់ ធ្វើឲ្យលំបាក គឺធ្វើឲ្យបានទទួលទុក្ខ ។ ពាក្យថា **ហេឋនា** បានដល់ បៀតបៀនដោយការវាយដោយ

*បាតដែជាដើម គឺញុំាងសេចក្តីទុក្ខឲ្យកើត ។ ការកំហែងយ៉ាងខ្លាំង ឈ្មោះថា* **វិហេឋនា** ។ *ដែលឈ្មោះថា* **ហឹសនា** *ព្រោះអត្ថថា ជាហេតុឲ្យបៀតបៀន ។ សេចក្តីបៀតបៀនដ៏មានកម្លាំង ឈ្មោះថា* **វិហឹសនា** ។ *ពាក្យថា* **រោសនា** *បានដល់ ការប៉ះខ្ទប់ ( អនិដ្ឋារម្មណ៍ ) ។ បទថា* **វិរោសនា** *បានដល់ ការប៉ះខ្ទប់អារម្មណ៍យ៉ាងខ្លាំងក្លា ។ ក្នុងបទទាំងអស់ លោកបន្ថែមដោយ* **វិ** *ឧបសគ្គ ។ ដែលឈ្មោះថា* **ឧបឃាត** *ព្រោះអត្ថថា ជាហេតុឲ្យចូលទៅបៀតបៀន ។ ឧបឃាតចំពោះអ្នកដទៃ ឈ្មោះថា* **បរូបឃាត** ។ *ឈ្មោះថា* **មេត្តិ** *ព្រោះអត្ថថា ជាហេតុឲ្យមានមេត្រី ។ អាការនៃមេត្រី ឈ្មោះថា* **មេត្តាយនា** ។ *ភាវៈរបស់បុគ្គលដែលដល់ព្រមដោយមេត្តា របស់បុគ្គលដែលប្រកបដោយមេត្តា ឈ្មោះថា* **មេត្តាយិតត្តំ** ។ *ការរួចផុតផ្លូវចិត្តនៃបុគ្គលអ្នករួចផុតចាកព្យាបាទ ឈ្មោះថា* **ចេតោវិមុត្តិ** ។ *ក្នុងទីនេះ មេត្តាដែលបានពោលដោយ ៣ បទដំបូង ដល់ឧបចារសមាធិខ្លះ ដល់អប្បនា-សមាធិខ្លះ បទក្រោយ គឺចេតោវិមុត្តិ ដល់អប្បនាប៉ុណ្ណោះ ។*

*ឈ្មោះថា ករុណា ព្រោះអត្ថថា ជាហេតុឲ្យប្រព្រឹត្តករុណា ។ អាការរបស់សេចក្តីករុណា ឈ្មោះថា* **ករុណាយនា** ។ *ភាវៈរបស់បុគ្គលដែលដល់ព្រមដោយករុណារបស់បុគ្គល ដែលប្រកបដោយសេចក្តីករុណា ឈ្មោះថា* **ករុណាយិតត្តំ** ។ *ការរួចផុតផ្លូវចិត្តនៃបុគ្គលរួចផុតចាកការបៀតបៀន ឈ្មោះថា* **ចេតោវិមុត្តិ** ។ *ក្នុងសេចក្តីនេះ គប្បីជ្រាបការផ្សេងគ្នានៃឧប-ចារសមាធិ និងអប្បនាសមាធិ ដោយន័យមុននោះឯង ម្យ៉ាងទៀត ពាក្យថា*

មេត្តា ករុណា ក្នុងបទទាំង ២ ចុងក្រោយ ទ្រង់ត្រាស់ដើម្បីការប្លែកគ្នា នៃចេតោវិមុត្តិ ។

ម្យ៉ាងទៀត បណ្ដាធាតុ ៦ នេះ កាមវិតក្កកើតឡើង ព្រោះសត្វទាំងឡាយខ្លះ ព្រោះសង្ខារទាំងឡាយខ្លះ ។ កាមវិតក្ក ទោះបីកើតឡើង ព្រោះសត្វ និងសង្ខារទាំង ២ ជាការទម្លាយកម្មបថដោយពិត តែព្យាបាទដែលកើតក្នុងសត្វទាំងឡាយតែម្យ៉ាង ទើបទម្លាយកម្មបថ ក្រៅអំពីនេះ មិនទម្លាយ ។ ក្នុងវិហិង្សាក៏មានន័យនេះដូចគ្នា ។ ក្នុងតិកៈ ២ ពួកនេះ មានកថា ២ យ៉ាង គឺ **សព្វសង្គាហិកកថា** ១ **អសម្ភិន្នកថា** ១ ។ ពិតហើយ ព្យាបាទធាតុ និងវិហិង្សាធាតុ ទ្រង់កាន់យកដោយសព្ទថា **កាមធាតុ** ។ **ព្យាបាទ** និង **វិហិង្សា** ទាំង ២ នេះ ក៏ទ្រង់សម្ដែងនាំចេញចាកកាមធាតុនោះឯង ព្រោះហេតុនោះ ទើបកថានេះ ឈ្មោះថា **សព្វសង្គាហិកកថា** ( កថាដែលរួមទាំងអស់ ) ក្នុងទីនេះប៉ុណ្ណោះសិន ។ ឯកថាដែលត្រាស់ថា វៀរព្យាបាទធាតុ និងវិហិង្សាធាតុហើយ ធម៌ដ៏សេសទាំងអស់ ជាកាមធាតុប៉ុណ្ណោះ នេះឈ្មោះថា **អសម្ភិន្នកថា** ( កថាមិនលាយឡំគ្នា ) ។ **អព្យាបាទធាតុ** និង **អវិហឹសាធាតុ** ទ្រង់កាន់យកដោយសព្ទថា **នេក្ខម្មធាតុ** នោះឯង ។ ការមិនព្យាបាទ និងការមិនបៀតបៀនទាំង ២ នោះ ទ្រង់ក៏សម្ដែងនាំចេញចាកនេក្ខម្មធាតុ ព្រោះហេតុនោះ ទើបកថានេះ ឈ្មោះថា **សព្វសង្គាហិកកថា** ក្នុងទីនេះ ។ កថានេះថា វៀរ **អព្យាបាទធាតុ** និង **អវិហឹសាធាតុ** ធាតុដ៏សេសឈ្មោះថា **នេក្ខម្មធាតុ** ដូច្នេះ ឈ្មោះថា **អសម្ភិន្នកថា** ។

[ ១២៣ ] ម្យ៉ាងទៀត ធាតុ ១៨ ក៏ឈ្មោះថា ទ្រង់កំណត់កាន់យកហើយ ដោយធាតុទាំង ៦ នេះ ដែលទ្រង់កំណត់កាន់យកហើយដូចគ្នា ។ ធាតុទាំងអស់នោះ ដែលគប្បីចាត់ឲ្យមានបាន ដោយនាំចេញចាកកាមធាតុ តែម្យ៉ាងក៏បាននូវធាតុ ១៨ ដូចគ្នា ព្រោះហេតុនោះ កាលពោលដោយធាតុពួក ៦ ទាំង ៣ ពួក ក៏រមែងបានធាតុ ១៨ ។ ម្យ៉ាងទៀត ធាតុទាំងអស់កាលមិនចាត់ដូចពោលមកនោះ តែក្នុងពួកធាតុ ៦ មួយពួកៗ ចែកជា ១៨ ធាតុ ដោយន័យដែលពោលហើយ សង្ខេបពួកធាតុ ១៨ នោះ ឲ្យនៅតែមួយ គប្បីជ្រាបថា មានត្រឹមតែ ១៨ ធាតុប៉ុណ្ណោះ ។ ក្នុងសុត្តន្តភាជនីយនេះ ធាតុ ១៦ ជាកាមាវចរ ធាតុ ២ ប្រព្រឹត្តទៅក្នុងភូមិ ៣ ព្រោះហេតុនោះ គប្បីជ្រាបថា វារៈពោលដោយសម្មសនៈ គឺការពិចារណាក្នុងអធិការនៃធាតុវិភង្គនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ដោយប្រការដូច្នេះ ។

**អធិប្បាយ សុត្តន្តភាជនីយ ចប់**

# អភិធម្មបិដក

## អភិធម្មភាជនីយ

[ ១២៤ ] ធាតុ ១៨ គឺចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុ សោតធាតុ សទ្ទធាតុ សោតវិញ្ញាណធាតុ ឃានធាតុ គន្ធធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាធាតុ រសធាតុ ជិវ្ហាវិញ្ញាណធាតុ កាយធាតុ ផោដ្ឋព្វធាតុ កាយ-វិញ្ញាណធាតុ មនោធាតុ ធម្មធាតុ មនោវិញ្ញាណធាតុ ។

[ ១២៥ ] បណ្តាធាតុ ១៨ នោះ ចក្ខុធាតុ តើដូចម្តេច ។ ចក្ខុណា គឺប្រសាទ អាស្រ័យមហាភូត ៤ ។បេ។ ហៅថា ស្រុកទំនេរក៏បាន នេះហៅថា ចក្ខុធាតុ ។ បណ្តាធាតុ ១៨ នោះ រូបធាតុ តើដូចម្តេច ។ រូបណា គឺសម្បុរ និងពន្លឺ អាស្រ័យមហាភូត ៤ ។បេ។ ហៅថា រូបធាតុក៏បាន នេះហៅថា រូបធាតុ ។ បណ្តាធាតុ ១៨ នោះ ចក្ខុវិញ្ញាណធាតុ តើដូចម្តេច ។ សេចក្តីគិត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ថ្លាស្អាត គឺមនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ ចក្ខុវិញ្ញាណធាតុ ដែលកើតអំពីខន្ធនោះ កើតព្រោះអាស្រ័យនូវចក្ខុផង នូវរូបទាំងឡាយផង នេះហៅថា ចក្ខុវិញ្ញាណធាតុ ។

[ ១២៦ ] បណ្តាធាតុ ១៨ នោះ សោតធាតុ តើដូចម្តេច ។ ត្រចៀកណា គឺប្រសាទ អាស្រ័យមហាភូត ៤ ។បេ។ ហៅថា ស្រុកទំនេរក៏បាន នេះហៅថា សោតធាតុ ។ បណ្តាធាតុ ១៨ នោះ សទ្ទធាតុ តើដូចម្តេច ។ សំឡេងណា មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ អាស្រ័យមហាភូតរូប ៤ ។បេ។ ហៅថា សទ្ទធាតុក៏បាន នេះហៅថា សទ្ទធាតុ ។

បណ្ដាធាតុ ១៨ នោះ សោតវិញ្ញាណធាតុ តើដូចម្ដេច ។ សេចក្ដីគិត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ថ្លាស្អាត គឺមនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ សោតវិញ្ញាណធាតុដែលកើតអំពីខន្ធនោះ កើតព្រោះអាស្រ័យនូវត្រចៀកផង នូវសំឡេងទាំងឡាយផង នេះហៅថា សោតវិញ្ញាណធាតុ ។

[ ១២៧ ] បណ្ដាធាតុ ១៨ នោះ ឃានធាតុ តើដូចម្ដេច ។ ច្រមុះណា គឺប្រសាទអាស្រ័យមហាភូត ៤ ។បេ។ ហៅថា ស្រុកទំនេរក៏បាន នេះហៅថា ឃានធាតុ ។ បណ្ដាធាតុ ១៨ នោះ គន្ធធាតុ តើដូចម្ដេច ។ ក្លិនណាមិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ អាស្រ័យមហាភូត ៤ ។បេ។ ហៅថា គន្ធធាតុក៏បាន នេះហៅថា គន្ធធាតុ ។ បណ្ដាធាតុ ១៨ នោះ ឃានវិញ្ញាណធាតុ តើដូចម្ដេច ។ សេចក្ដីគិត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ថ្លាស្អាត គឺមនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ ឃានវិញ្ញាណធាតុដែលកើតអំពីខន្ធនោះ កើតព្រោះអាស្រ័យនូវច្រមុះផង នូវក្លិនទាំងឡាយផង នេះហៅថា ឃានវិញ្ញាណធាតុ ។

[ ១២៨ ] បណ្ដាធាតុ ១៨ នោះ ជិវ្ហាធាតុ តើដូចម្ដេច ។ អណ្ដាតណា គឺប្រសាទ អាស្រ័យមហាភូត ៤ ។បេ។ ហៅថា ស្រុកទំនេរក៏បាន នេះហៅថា ជិវ្ហាធាតុ ។ បណ្ដាធាតុ ១៨ នោះ រសធាតុ តើដូចម្ដេច ។ រសណា មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ អាស្រ័យមហាភូត ៤ ។បេ។ ហៅថា រសធាតុក៏បាន នេះហៅថា រសធាតុ ។ បណ្ដា

ធាតុ ១៨ នោះ ជិវ្ហាវិញ្ញាណធាតុ តើដូចម្តេច ។ សេចក្តីគិត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ថ្លាស្អាត គឺមនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ ជិវ្ហាវិញ្ញាណធាតុដ៏កើតអំពីខន្ធនោះ កើតព្រោះអាស្រ័យនូវអណ្តាតផង នូវរសទាំងឡាយផង នេះហៅថា ជិវ្ហាវិញ្ញាណធាតុ ។

[ ១២៩ ] បណ្តាធាតុ ១៨ នោះ កាយធាតុ តើដូចម្តេច ។ កាយណា គឺប្រសាទ អាស្រ័យមហាភូត ៤ ។បេ។ ហៅថា ស្រុកទំនេរក៏បាន នេះហៅថា កាយធាតុ ។ បណ្តាធាតុ ១៨ នោះ ផោដ្ឋព្វធាតុ តើដូចម្តេច ។ បឋវីធាតុ ។បេ។ ហៅថា ផោដ្ឋព្វធាតុក៏បាន នេះហៅថា ផោដ្ឋព្វធាតុ ។ បណ្តាធាតុ ១៨ នោះ កាយវិញ្ញាណធាតុ តើដូចម្តេច ។ សេចក្តីគិត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ថ្លាស្អាត គឺមនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ កាយវិញ្ញាណធាតុដែលកើតអំពីខន្ធនោះ កើតព្រោះអាស្រ័យនូវកាយផង នូវផស្សៈទាំងឡាយផង នេះហៅថា កាយវិញ្ញាណធាតុ ។

[ ១៣០ ] បណ្តាធាតុ ១៨ នោះ មនោធាតុ តើដូចម្តេច ។ សេចក្តីគិត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ថ្លាស្អាត គឺមនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោធាតុដែលកើតអំពីខន្ធនោះ កើតឡើងក្នុងលំដាប់នៃចក្ខុវិញ្ញាណធាតុ ដែលកើតហើយរលត់ទៅវិញ សេចក្តីគិត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ថ្លាស្អាត

គឺមនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោធាតុដែលកើត អំពីខន្ធនោះ កើតឡើងក្នុងលំដាប់នៃសោតវិញ្ញាណធាតុ ។បេ។ នៃឃាន-វិញ្ញាណធាតុ ។បេ។ នៃជិវ្ហាវិញ្ញាណធាតុ ។បេ។ នៃកាយវិញ្ញាណធាតុដែល កើតហើយរលត់ទៅវិញ មួយទៀត ការពិចារណាជាដំបូង ក្នុងធម៌ទាំងពួង នេះហៅថា មនោធាតុ ។ បណ្ដាធាតុ ១៨ នោះ ធម្មធាតុ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ និងរូបណា មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ រាប់បញ្ចូលក្នុងធម្មាយតនៈ ទាំងអសង្ខតធាតុ ( នេះហៅថា ធម្មធាតុ ) ។ បណ្ដាខន្ធ ៥ នោះ វេទនាខន្ធ តើដូចម្ដេច ។ វេទនាខន្ធមានប្រការ ១ គឺវេទនាខន្ធប្រកបដោយផស្សៈ ។ វេទនាខន្ធមាន ប្រការ ២ គឺវេទនាខន្ធ ប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមានហេតុក៏ មាន ។ វេទនាខន្ធមានប្រការ ៣ គឺវេទនាខន្ធជាកុសលក៏មាន ជាអកុសល ក៏មាន ជាអព្យាក្រឹតក៏មាន ។បេ។ វេទនាខន្ធមានច្រើនប្រការយ៉ាងនេះឯង នេះហៅថា វេទនាខន្ធ ។ បណ្ដាខន្ធ ៥ នោះ សញ្ញាខន្ធ តើដូចម្ដេច ។ សញ្ញាខន្ធមានប្រការ ១ គឺសញ្ញាខន្ធប្រកបដោយផស្សៈ ។ សញ្ញាខន្ធមាន ប្រការ ២ គឺសញ្ញាខន្ធ ប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមានហេតុក៏ មាន ។ សញ្ញាខន្ធមានប្រការ ៣ គឺសញ្ញាខន្ធជាកុសលក៏មាន ជាអកុសល ក៏មាន ជាអព្យាក្រឹតក៏មាន ។បេ។ សញ្ញាខន្ធមានច្រើនប្រការយ៉ាងនេះឯង នេះហៅថា សញ្ញាខន្ធ ។ បណ្ដាខន្ធ ៥ នោះ សង្ខារក្ខន្ធ តើដូចម្ដេច ។ សង្ខារក្ខន្ធមានប្រការ ១ គឺសង្ខារក្ខន្ធប្រកបដោយចិត្ត ។ សង្ខារក្ខន្ធ មាន

ប្រការ ២ គឺសង្ខារក្ខន្ធជាហេតុក៏មាន មិនមែនជាហេតុក៏មាន ។ សង្ខារក្ខន្ធមានប្រការ ៣ គឺសង្ខារក្ខន្ធជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។បេ។ សង្ខារក្ខន្ធ មានច្រើនប្រការយ៉ាងនេះឯង នេះហៅថា សង្ខារក្ខន្ធ ។ បណ្តាខន្ធ ៥ នោះ រូបមិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ រាប់បញ្ចូលក្នុងធម្មាយតនៈ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ ។បេ។ កពឡិង្ការាហារ នេះហៅថា រូបមិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ រាប់បញ្ចូលក្នុងធម្មាយតនៈ ។ បណ្តាធាតុទាំងនោះ អសង្ខតធាតុ តើដូចម្តេច ។ ការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈ នេះហៅថា អសង្ខតធាតុ ។ នេះហៅថា ធម្មធាតុ ។ បណ្តាធាតុទាំងនោះ មនោវិញ្ញាណធាតុ តើដូចម្តេច ។ មនោធាតុ កើតឡើងក្នុងលំដាប់នៃចក្ខុវិញ្ញាណធាតុដែលកើតហើយរលត់ទៅវិញ បន្ទាប់មក សេចក្តីគិត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុដែលកើតអំពីខន្ធនោះក៏កើតក្នុងលំដាប់នៃមនោធាតុ ដែលកើតហើយរលត់ទៅវិញ មនោធាតុកើតក្នុងលំដាប់នៃសោតវិញ្ញាណធាតុ ។បេ។ នៃឃានវិញ្ញាណធាតុ ។បេ។ នៃជិវ្ហាវិញ្ញាណធាតុ ។បេ។ នៃកាយវិញ្ញាណធាតុ ដែលកើតហើយរលត់ទៅវិញ បន្ទាប់មក សេចក្តីគិត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោ-

វិញ្ញាណធាតុដែលកើតអំពីខន្ធនោះ ក៏កើតក្នុងលំដាប់នៃមនោធាតុដែលកើតហើយ រលត់ទៅវិញ ។ សេចក្ដីគិត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នាហឫទ័យ ធម្មជាតដ៏ថ្លាស្អាត គឺមនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុដែលកើតអំពីខន្ធនោះ កើតព្រោះអាស្រ័យនូវភវង្គចិត្តផង នូវធម៌ផង នេះហៅថា មនោវិញ្ញាណធាតុ ។

**អភិធម្មភាជនីយ ចប់**

# អដ្ឋកថា

## អភិធម្មភាជនីយ

[ ១២៤ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងធាតុទាំងអស់ ក្នុងអភិធម្មភាជនីយដោយសរុបនោះឯង ទើបត្រាស់ពាក្យថា **អដ្ឋារស ធាតុយោ ចក្ខុធាតុ រូបធាតុ** ដូច្នេះជាដើម ក្នុងបទទាំងនោះ គប្បីជ្រាបវិនិច្ឆ័យ ក្នុងឧទ្ទេសវារមុន

គប្បីជ្រាបវិនិច្ឆ័យ ដោយអត្ថ ១ ដោយលក្ខណៈជាដើម ១ ដោយលំដាប់ ១ ដោយមានត្រឹមតែប៉ុណ្ណោះ ១ ដោយការរាប់ ១ ដោយបច្ច័យ ១ និងដោយជាធម៌ដែលគួរឃើញ ១ ដូច្នេះ ។

បណ្តាឧទ្ទេសទាំងនោះ ពាក្យថា ដោយអត្ថ គប្បីជ្រាបវិនិច្ឆ័យ ដោយអត្ថដែលប្លែកគ្នានៃធម៌ មានចក្ខុជាដើម ដោយន័យជាដើមយ៉ាងនេះ

ដែលឈ្មោះថា **ចក្ខុ** ព្រោះអត្ថថា ឃើញ ឈ្មោះថា **រូប** ព្រោះអត្ថថា រមែងបង្ហាញខ្លួនឲ្យប្រាកដ ការដឹងតាមចក្ខុ ឈ្មោះថា **ចក្ខុវិញ្ញាណ** ដូច្នេះប៉ុណ្ណោះសិន ។

ឯដោយការមិនប្លែកគ្នា មានវិនិច្ឆ័យដូចតទៅ

ដែលឈ្មោះថា **ធាតុ** ព្រោះអត្ថថា រមែងចាត់ចែង ព្រោះអត្ថថា រមែងទ្រទ្រង់ ព្រោះអត្ថថា ជាការចាត់ចែង ព្រោះអត្ថថា ជាហេតុទ្រទ្រង់ដោយប្រការផ្សេងៗ ឬព្រោះអត្ថថា ជាទីទ្រទ្រង់ ។

ពិតហើយ ធាតុទាំងឡាយ ដែលជាលោកិយ ជាធាតុដែលកំណត់ដោយភាពជាហេតុ រមែងចាត់ចែងសង្សារទុក្ខច្រើនប្រការ ដូចធាតុដែលជាមាស និងប្រាក់ជាដើម ដែលបុគ្គលធ្វើជាមាស និងប្រាក់ជាដើម ម្យ៉ាងទៀត ធាតុទាំងឡាយ ដែលសត្វរមែងទ្រទ្រង់ គឺទទួល ដូចរបស់ធ្ងន់ដែលរែកទៅ ដូច្នោះ ។ ម្យ៉ាងទៀត ធាតុទាំងនេះ ឈ្មោះថា ត្រឹមតែចាត់ចែងសេចក្ដីទុក្ខប៉ុណ្ណោះ ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាច ។ ម្យ៉ាងទៀត ធាតុទាំងនោះ ជាហេតុឲ្យពួកសត្វទាំងឡាយ ត្រាច់ទៅកាន់សង្សារទុក្ខ ម្យ៉ាងទៀត ធាតុដែលជាហេតុទាំងនេះ ជាទីតាំង គឺជាទីស្ថិតនៅនៃសង្សារទុក្ខដែលកម្មចាត់ចែងហើយ ។ បណ្ដាចក្ខុជាដើម ធម៌ណានីមួយ លោកហៅថា **ធាតុ** ដោយអំណាចនៃអត្ថថា ចាត់ចែង ទ្រទ្រង់តាមសេចក្ដីពិត ដូចពណ៌នាមកដូច្នេះ ។

ម្យ៉ាងទៀត ឈ្មោះថា អត្តារបស់ពួកតិត្ថិយ រមែងមិនមានដោយភាវៈរបស់ខ្លួន យ៉ាងណា ធាតុទាំងនេះ មិនមែនយ៉ាងនោះឡើយ ធាតុទាំងនេះឈ្មោះថា **ធាតុ** ព្រោះអត្ថថា ទ្រទ្រង់នូវសភាវៈរបស់ខ្លួន ប្រៀបដូចចំណែកនៃសិលា មានហរតាល និងមនោសិលាជាដើមដែលវិចិត្រក្នុងលោកហៅថា **ធាតុ** យ៉ាងណា **ធាតុ** មានចក្ខុជាដើមនេះ ក៏ឈ្មោះថា **ធាតុ** ដូចធាតុ ( សិលា ) ទាំងឡាយក៏យ៉ាងនោះ ។ ពិតណាស់ ធាតុដែលវិចិត្រទាំងនេះជាចំណែកផ្សេងៗដែលគប្បីដឹងបានដោយញាណប៉ុណ្ណោះ ។ ម្យ៉ាងទៀត ក្នុងចំណែកទាំងឡាយ ដែលកំណត់ដោយលក្ខណៈដែលផ្ទុយគ្នានឹង

គ្នា មានរស និងឈាមជាដើម ដែលជាចំណែកផ្សេងៗ របស់កាយ គឺសរីរៈ លោកហៅថា **ធាតុ** យ៉ាងណា ក្នុងចំណែកផ្សេងៗ នៃអត្តភាព ពោល គឺបញ្ចក្ខន្ធនេះ ក៏គប្បីជ្រាបថា ឈ្មោះថា **ធាតុ** យ៉ាងនោះ ព្រោះថា ចក្ខុ ជាដើមនេះ លោកកំណត់ដោយលក្ខណៈដែលផ្សេងគ្នានិងគ្នា ។

ម្យ៉ាងទៀត ពាក្យថា **ធាតុ** នេះ ត្រឹមតែជាឈ្មោះរបស់ធម៌ដែលប្រាស ចាកជីវៈ ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់បានសម្តែងធាតុ ដើម្បីដក សេចក្តីសម្គាល់ថាមានជីវៈ ( ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសក ) ថា ពាក្យទាំងឡាយថា ម្នាលភិក្ខុ បុរសនេះ មានធាតុ ៦ ដូច្នេះ ព្រោះហេតុ នោះ ដោយអត្ថតាមដែលពោលហើយ ឈ្មោះថា **ចក្ខុធាតុ** ព្រោះអត្ថថា ជាចក្ខុផង ជាធាតុផង ។បេ។ ឈ្មោះថា **មនោវិញ្ញាណធាតុ** ព្រោះអត្ថថា ជាមនោវិញ្ញាណផង ជាធាតុផង គប្បីជ្រាបវិនិច្ឆ័យក្នុងធាតុនេះ ដោយអត្ថ យ៉ាងនេះ ដោយប្រការដូច្នេះ ។

ពាក្យថា ដោយលក្ខណៈជាដើមក្នុងទីនេះ គប្បីជ្រាបវិនិច្ឆ័យ ដោយ លក្ខណៈជាដើមនៃធម៌ មានចក្ខុជាដើម ។ លក្ខណៈជាដើមនៃធម៌ មានចក្ខុ ជាដើមនោះ គប្បីជ្រាបដោយន័យ តាមដែលពោលហើយនោះឯង ។

ក្នុងពាក្យថា ដោយលំដាប់ ក្នុងទីនេះ បណ្តាលំដាប់ទាំងឡាយ មាន លំដាប់នៃការកើតជាដើម តាមដែលពោលទុកមុន លំដាប់ គឺការសម្តែង ប៉ុណ្ណោះសមគួរ ។ លំដាប់នៃការសម្តែងនោះ ព្រះមានព្រះភាគ ត្រាស់ ដោយការកំណត់តាមលំដាប់ហេតុ និងផល ។ ពិតហើយ ២ បទ គឺចក្ខុធាតុ

និងរូបធាតុនេះ ជាហេតុ ពាក្យថា ចក្ខុវិញ្ញាណធាតុនេះ ជាផល គប្បីជ្រាប វិនិច្ឆ័យក្នុងបទទាំងពួងដោយលំដាប់ ដូចពោលមក ដូច្នេះ ។

ពាក្យថា ដោយមានត្រឹមតែប៉ុណ្ណោះ បានដល់ ដោយចំនួនមានត្រឹមប៉ុណ្ណោះ ពាក្យនេះ មានអធិប្បាយថា ក្នុងចំណែកនៃព្រះសូត្រ និងព្រះអភិធម្មទាំងនោះ ធាតុដទៃៗ រមែងប្រាកដយ៉ាងនេះថា អាភាធាតុ សុភធាតុ អាកាសានញ្ចាយតនធាតុ វិញ្ញាណញ្ចាយតនធាតុ អាកិញ្ចញ្ញាយតនធាតុ នេវសញ្ញានាសញ្ញាយតនធាតុ សញ្ញាវេទយិតនិរោធធាតុ កាមធាតុ ព្យាបាទធាតុ វិហិង្សាធាតុ នេក្ខម្មធាតុ អព្យាបាទធាតុ អវិហិង្សាធាតុ សុខធាតុ ទុក្ខធាតុ សោមនស្សធាតុ ទោមនស្សធាតុ ឧបេក្ខាធាតុ អវិជ្ជាធាតុ អារព្ភធាតុ និក្កមធាតុ បរក្កមធាតុ ហីនធាតុ មជ្ឈិមធាតុ បណីតធាតុ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ អាកាសធាតុ វិញ្ញាណធាតុ សង្ខតធាតុ អសង្ខតធាតុ លោកមានធាតុជាច្រើន និងមានធាតុផ្សេងៗ ដូច្នេះ ។

បើមានពាក្យសួរថា កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់មិនកំណត់ចំនួនធាតុទាំងអស់ ទ្រង់កំណត់ត្រឹមតែ ១៨ ធាតុប៉ុណ្ណោះ ឆ្លើយថា ព្រោះធាតុគ្រប់យ៉ាង មានដោយសភាវៈ សង្គ្រោះចូលក្នុងធាតុទាំង ១៨ នោះ ។

ពិតហើយ អាភាធាតុ គឺរូបធាតុនោះឯង សុភធាតុ ជាធាតុដែលទាក់ទងដោយរូបធាតុជាដើម ។ ព្រោះហេតុអ្វី ព្រោះជាសុភនិមិត្ត ពិតហើយ សុភនិមិត្ត ឈ្មោះថា សុភធាតុ សុភនិមិត្តនោះ នឹងផុតទៅអំពីរូបជាដើមក៏មិន

មាន ។ម្យ៉ាងទៀត សុភធាតុ គឺរូបធាតុជាដើម ដែលជាអារម្មណ៍របស់កុសលវិបាកនោះឯង ព្រោះហេតុនោះ ទើបសុភធាតុនេះ ត្រឹមតែជារូបធាតុជាដើមនោះឯង ។ ចិត្តក្នុងអាកាសានញ្ចាយតនធាតុជាដើម បានដល់ មនោ-វិញ្ញាណធាតុ ។ ធាតុដ៏សេស ជាធម្មធាតុ ។ ឯសញ្ញាវេទយិតនិរោធធាតុដោយសភាវៈ រមែងមិនមាន ព្រោះសញ្ញាវេទយិតនិរោធនោះ ត្រឹមតែជាការរលត់ធាតុទាំង ២ គឺសញ្ញា និងវេទនាប៉ុណ្ណោះ ។

ន័យម្យ៉ាងទៀត កាមធាតុត្រឹមតែជាធម្មធាតុ ដូចព្រះតម្រាស់ថា បណ្ដាធាតុ ៦ នោះ កាមធាតុ តើដូចម្ដេច ។ សេចក្ដីត្រិះរិះ ... ដែលប្រកបដោយកាម ។បេ។ គឺមិច្ឆាសង្កប្ប នេះហៅថា កាមធាតុ ។ ម្យ៉ាងទៀត កាមធាតុគឺធាតុ ១៨ យ៉ាង ដូចព្រះតម្រាស់ថា ខាងក្រោម តាំងអំពីអវីចិនរកជាទីបំផុត ខាងលើ តាំងអំពីបរនិម្មិតវសវត្តីទេវតាជាទីបំផុត ខន្ធ ធាតុ អាយតនៈរូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណណា មានក្នុងចន្លោះនេះ រាប់បញ្ចូលក្នុងចន្លោះនេះ នេះហៅថា កាមធាតុ ដូច្នេះ ។

នេក្ខម្មធាតុ គឺធម្មធាតុនោះឯង ។ ម្យ៉ាងទៀត កុសលធម៌ទាំងអស់ ក៏ឈ្មោះថា នេក្ខម្មធាតុដែរ ដូច្នេះ នេក្ខម្មធាតុនោះ ក៏ជាមនោវិញ្ញាណធាតុបានដូចគ្នា ។ ព្យាបាទធាតុ វិហិង្សាធាតុ អព្យាបាទធាតុ អវិហិង្សាធាតុ សុខធាតុ ទុក្ខធាតុ សោមនស្សធាតុ ទោមនស្សធាតុ ឧបេក្ខាធាតុ អវិជ្ជា-ធាតុ អារព្ភធាតុ និក្កមធាតុ បរក្កមធាតុ ជាធម្មធាតុនោះឯង ។ ហីនធាតុមជ្ឈិមធាតុ បណីតធាតុ ត្រឹមតែជាធាតុ ១៨ ប៉ុណ្ណោះ ព្រោះចក្ខុធាតុជាដើម

ដែលជាហីន ឈ្មោះថា ហីនធាតុ ចក្ខុជាដើម ដែលជាមជ្ឈិម និងបណីត ក៏ចាត់ជាមជ្ឈិមធាតុ និងបណីតធាតុ ។

បើពោលដោយត្រង់ ធម្មធាតុនិងមនោវិញ្ញាណធាតុ ដែលជាអកុសល ជាហីនធាតុ ។ ធម្មធាតុ និងមនោវិញ្ញាណធាតុទាំង ២ ដែលជាកុសល និង អព្យាកត ខាងលោកិយក្តី ចក្ខុធាតុជាដើមក្តី ជាមជ្ឈិមធាតុ ឯធម្មធាតុ និង មនោវិញ្ញាណធាតុដែលជាលោកុត្តរ ជាបណីតធាតុ ។ បឋវីធាតុ តេជោធាតុ វាយោធាតុ គឺផោដ្ឋព្វធាតុនោះឯង ។ អាបោធាតុ និងអាកាសធាតុ គឺធម្ម-ធាតុ ។ វិញ្ញាណធាតុ រមែងសង្គ្រោះចូលក្នុងវិញ្ញាណធាតុ ៧ មានចក្ខុវិញ្ញាណ ជាដើម ។ ធាតុ ១៧ និងចំណែក ១ នៃធម្មធាតុ ជាសង្ខតធាតុ ចំណែក ១ នៃធម្មធាតុនោះឯង ជាអសង្ខតធាតុ លោក ដែលជាអនេកធាតុ និងនានា-ធាតុ ត្រឹមតែជាប្រភេទរបស់ធាតុ ១៨ ប៉ុណ្ណោះ ។ ព្រះមានព្រះភាគត្រាស់ ធាតុ ១៨ ប៉ុណ្ណោះ ព្រោះធាតុទាំងអស់មានដោយសភាវៈ គឺសង្គ្រោះ ចូលក្នុងធាតុ ១៨ នោះ ដូចពណ៌នាមក ដូច្នេះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគត្រាស់ធាតុ ១៨ ប៉ុណ្ណោះ ដើម្បីដកនូវ សេចក្តីសម្គាល់ថាមានជីវៈ របស់សត្វដែលមានសេចក្តីសម្គាល់ក្នុងវិញ្ញាណ ដែលមានការដឹងអារម្មណ៍ជាសភាវៈ ថាជាជីវៈ ។ ពិតហើយ សត្វទាំង ឡាយ ដែលមានសេចក្តីសម្គាល់ក្នុងវិញ្ញាណ ដែលមានការដឹងអារម្មណ៍ជា សភាវៈ ថាជាជីវៈមាន ព្រះមានព្រះភាគទ្រង់បំណងដើម្បីប្រកាសភាពមាន ច្រើននៃធាតុនោះ ដោយចែកជាចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ ឃាន-

វិញ្ញាណធាតុ ជិវ្ហាវិញ្ញាណធាតុ កាយវិញ្ញាណធាតុ និងមនោវិញ្ញាណធាតុ និងប្រកាសភាពដែលធាតុទាំងនោះជារបស់មិនទៀង ព្រោះប្រព្រឹត្តទៅទាក់ទង ដោយបច្ច័យ មានចក្ខុ និងរូបជាដើម ហើយដកនូវសេចក្ដីសម្គាល់ថា មាន ជីវៈ ដែលដេកត្រាំអស់កាលយូររបស់សត្វទាំងនោះ ទើបទ្រង់ប្រកាសធាតុ ១៨ យ៉ាង ។ គប្បីជ្រាបបន្ថែមទៀតបន្តិចបន្តួច ។ម្យ៉ាងទៀត ទ្រង់ ប្រកាសធាតុ ១៨ យ៉ាង ដោយអំណាចអធ្យាស្រ័យរបស់វេនេយ្យសត្វ ។ ព្រោះទ្រង់ប្រកាសធាតុ ១៨ ដោយអំណាចអធ្យាស្រ័យរបស់វេនេយ្យសត្វ ដែលគប្បីដឹងបានដោយទេសនា ដែលមិនសង្ខេបពេក និងមិនពិស្ដារពេក ដូច្នេះ ។

ពិតហើយ ងងឹតក្នុងហទយៈរបស់វេនេយ្យសត្វ នឹងដល់នូវ ការវិនាសទៅដោយរួសរាន់ ដែលកម្ចាត់បានដោយតេជៈនៃ ព្រះសទ្ធម្ម របស់ព្រះអង្គ បានដោយប្រការណា ទ្រង់ក៏ ប្រកាសធម៌ដោយន័យដែលសង្ខេប និងពិស្ដារ ដោយប្រការ នោះៗ ឯង ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងធាតុនេះ ដោយមានត្រឹមប៉ុណ្ណោះយ៉ាងនេះ ។

ពាក្យថា ដោយការរាប់ បានដល់ ពោលដោយជាតិ ចក្ខុធាតុ បាន ដល់ ចក្ខុបសាទ រមែងដល់នូវការរាប់ថា ជាធម៌មួយប៉ុណ្ណោះ សោតធាតុ ឃានធាតុ ជិវ្ហាធាតុ កាយធាតុ រូបធាតុ សទ្ទធាតុ គន្ធធាតុ រសធាតុ ក៏ ជាធម៌មួយៗ ដូចគ្នា ដោយអំណាចជាសោតប្បសាទជាដើម ។ តែផោដ្ឋព្វធាតុ

ដល់នូវការរាប់ថា ជាធម៌ ៣ យ៉ាង ដោយអំណាចនៃបវរីធាតុ គេជោធាតុ និងវាយោធាតុ ។

ចក្ខុវិញ្ញាណធាតុ រមែងដល់នូវការរាប់ថា ជាធម៌ ២ យ៉ាង ដោយអំណាចនៃវិបាកដែលជាកុសល និងអកុសល ។ សោតវិញ្ញាណធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាវិញ្ញាណធាតុ កាយវិញ្ញាណធាតុ ក៏ដល់នូវការរាប់ថាជាធម៌នីមួយៗ ២ យ៉ាងដូចគ្នា តែមនោធាតុ រមែងដល់នូវការរាប់ថា ជាធម៌ ៣ យ៉ាង គឺបញ្ចទ្វារាវជ្ជនៈ ១ និងសម្បដិច្ឆន្នៈ ២ ទាំងខាងកុសលវិបាក និងអកុសលវិបាក ។ ធម្មធាតុដល់នូវការរាប់ថា ជាធម៌ ២០ ដោយអំណាចនៃអរូបក្ខន្ធ ៣ ( វេទនា សញ្ញា សង្ខារ ) សុខុមរូប ១៦ និងអសង្ខតធាតុ ១ ។ មនោវិញ្ញាណធាតុ រមែងដល់នូវការរាប់ថា ជាធម៌ ៧៦ យ៉ាង ដោយអំណាចនៃវិញ្ញាណដែលជាកុសល អកុសល និងអព្យាកតដ៏សេស ព្រោះហេតុនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងធាតុនេះ ដោយការរាប់យ៉ាងនេះ ។

ពាក្យថា ដោយបច្ច័យ គប្បីជ្រាបវិនិច្ឆ័យ ដោយភាពដែលចក្ខុធាតុជាដើម ជាបច្ច័យដល់ចក្ខុវិញ្ញាណជាដើម ។ ឯភាពដែលចក្ខុធាតុជាដើមនោះជាបច្ច័យ ជាក់ច្បាស់ក្នុងនិទ្ទេសវារៈ ។

ពាក្យថា ដោយជាធម៌គួរឃើញ គប្បីជ្រាបវិនិច្ឆ័យក្នុងធាតុនេះ ដោយជាធម៌ដែលគួរឃើញ ព្រោះសង្ខតធាតុទាំងអស់ គប្បីឃើញដោយភាពជារបស់ទទេចាកទីបំផុតខាងដើម និងខាងចុង ដោយភាពជារបស់សូន្យចាកការទៀង ស្អាត សុខ អត្តា និងដោយការប្រព្រឹត្តទៅទាក់ទងនឹងបច្ច័យ ។

ពោលដោយការប្ញែកគ្នាក្នុងអធិការនៃធាតុនេះ គប្បីឃើញចក្ខុធាតុ ដូចផ្ទៃស្គរ រូបធាតុ ដូចអន្ទង់ ចក្ខុវិញ្ញាណធាតុ ដូចសំឡេងស្គរ ។ ម្យ៉ាងទៀត គប្បីឃើញ ចក្ខុធាតុ ដូចកញ្ចក់ រូបធាតុ ដូចមុខ ចក្ខុវិញ្ញាណធាតុ ដូចស្រមោលមុខ ។ ម្យ៉ាងទៀត គប្បីឃើញចក្ខុធាតុដូចដើមអំពៅ និងគ្រាប់ល្ង រូបធាតុ ដូចយន្តគាប ចក្ខុវិញ្ញាណធាតុ ដូចទឹកអំពៅ និងគ្រាប់ល្ង ។ ម្យ៉ាងទៀត គប្បីឃើញចក្ខុធាតុ ដូចឈើកួតភ្លើងខាងក្រោម រូបធាតុ ដូចឈើកួតភ្លើងខាងលើ ចក្ខុវិញ្ញាណធាតុ ដូចភ្លើង ។ ក្នុងសោតធាតុជាដើមក៏មានន័យដូចគ្នា ។

ឯមនោធាតុ ពោលតាមកំណើត គប្បីឃើញដូចការត្រាច់ទៅមុន និងត្រាច់ទៅតាមចក្ខុវិញ្ញាណជាដើម ។ ពោលដោយធម្មធាតុគប្បីឃើញវេទនា-ខន្ធ ដូចត្រួសរ និងលំពែង សញ្ញា និងសង្ខារក្ខន្ធ ដូចបុគ្គលសោប់សល់ព្រោះត្រូវព្រួញ និងលំពែង គឺវេទនាចាក់ដោត ។ ម្យ៉ាងទៀត គប្បីឃើញសញ្ញារបស់ពួកបុថុជ្ជន ដូចបាតដៃទទេ ព្រោះកើតសេចក្ដីប្រាថ្នាដែលជាទុក្ខ និងដូចម្រឹគព្រៃ ព្រោះកាន់យកនិមិត្ត តាមសេចក្ដីពិតមិនបាន គប្បីឃើញសង្ខារទាំងឡាយ ដូចបុរសបោះរបស់ដាក់ក្នុងរណ្ដៅរងើកភ្លើង ព្រោះបញ្ចូនចិត្តទៅក្នុងបដិសន្ធិ ដូចពួកចោរត្រូវរាជបុរសដេញតាម ព្រោះការជាប់តាមនៃជាតិទុក្ខ និងគប្បីឃើញដូចគ្រាប់ពូជនៃដើមឈើពុល ព្រោះជាហេតុនៃការបន្តរបស់ខន្ធ ដែលនាំមកនូវការវិនាសទាំងពួង ។ គប្បីឃើញរូប ដូចចក្កក្រុត ព្រោះជាគ្រឿងសម្គាល់របស់ឧបទ្រវច្រើនប្រភេទ ។

តែគប្បីឃើញអសង្ខតធាតុ ដោយភាពជាអមតៈ ដោយភាពជាធម៌ស្ងប់ និងដោយភាពជាធម៌ក្សេម ព្រោះហេតុអ្វី ព្រោះជាបដិបក្ខចំពោះការវិនាសទាំងឡាយ ។ គប្បីឃើញមនោវិញ្ញាណធាតុ ដូចស្វាក្នុងព្រៃធំ ព្រោះលែងអារម្មណ៍ដែលខ្វះចាប់ហើយ ក៏តោងអារម្មណ៍ដទៃទៀត ដូចសេះខូក ព្រោះទូន្មានបានដោយក្រ ដូចដើមឈើ ដែលបោះទៅក្នុងអាកាស ព្រោះធ្លាក់ទៅក្នុងអារម្មណ៍ ដែលចិត្តនោះពេញចិត្ត និងដូចអ្នករាំលើវេទិកា ព្រោះប្រកបដោយកិលេស មានប្រការផ្សេងៗ មានលោភៈ និងទោសៈជាដើម ។

[ ១២៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសវារៈដូចតទៅ

បទថា **ចក្ខុញ្ច បដិច្ច រូបេ ច** អធិប្បាយថា ព្រោះអាស្រ័យចក្ខុបសាទ និងរូបារម្មណ៍ទាំង ២ នេះផង ព្រោះអាស្រ័យធម៌ដទៃ គឺកិរិយាមនោធាតុ និងខន្ធ ៣ ( វេទនា សញ្ញា សង្ខារ ) ដែលសម្បយុត្តគ្នាផង ។ ព្រោះចក្ខុវិញ្ញាណធាតុ មានចក្ខុជានិស្សយប្បច្ច័យ មានរូបជាអារម្មណប្បច្ច័យ មានកិរិយាមនោធាតុជាវិគតប្បច្ច័យ មានអរូបក្ខន្ធ ៣ ជាសហជាតប្បច្ច័យ ព្រោះហេតុនោះ ទើបចក្ខុវិញ្ញាណធាតុនេះ ឈ្មោះថា រមែងកើតព្រោះអាស្រ័យបច្ច័យទាំង ៤ នេះ ។ ក្នុងបទថា **សោតញ្ច បដិច្ច** ជាដើម ក៏មានន័យនេះដូចគ្នា ។

[ ១៣០ ] បទថា **និរុទ្ធសមនន្តរា** បានដល់ ក្នុងលំដាប់នៃការរលត់របស់ចក្ខុវិញ្ញាណធាតុ ។

បទថា **តជ្ជា មនោធាតុ** បានដល់ មនោធាតុ ២ ដោយជាកុសល-

វិបាក និងអកុសលវិបាក ដែលកើតក្នុងអារម្មណ៍នោះធ្វើកិច្ចទទួលអារម្មណ៍ ។

បទថា **សព្វធម្មេសុ វា បន បឋមសមន្នាហារោ** នេះ គប្បីជ្រាបអត្ថយ៉ាងនេះថា ការពិចារណាអារម្មណ៍ដំបូងក្នុងធម៌ទាំងពួង មានចក្ខុវិញ្ញាណជាដើមនេះ ដែលកំពុងកើតឡើង ឬថា ការពិចារណាអារម្មណ៍ដំបូងក្នុងធម៌ទាំងពួង ពោល គឺអារម្មណ៍របស់ចក្ខុវិញ្ញាណធាតុជាដើម ។ គប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់កាន់យកកិរិយាមនោធាតុដែលធ្វើអាវជ្ជនកិច្ច តាមបញ្ចទ្វារដោយបទនេះ ។

**បិ** អក្ខរៈ ក្នុងបទថា **មនោធាតុយាបិ ឧប្បជ្ជិត្វា និរុទ្ធសមនន្តរា** នេះ មានអត្ថថា ប្រមូលមក ព្រោះហេតុនោះ ក្នុងទីនេះ គប្បីជ្រាបអត្ថនេះថា សូម្បីរបស់មនោធាតុ សូម្បីរបស់មនោវិញ្ញាណធាតុ ។ មនោវិញ្ញាណធាតុដែលជាវិបាកណា ដែលធ្វើសន្តីរណកិច្ច កើតឡើងក្នុងលំដាប់នៃការកើតរលត់របស់មនោវិញ្ញាណធាតុដែលជាវិបាក ( សម្បដិច្ឆនចិត្ត ) មនោវិញ្ញាណ-ធាតុដែលជាកិរិយាណា ដែលធ្វើវោដ្ឋព្វនកិច្ច កើតឡើងក្នុងលំដាប់នៃការកើតរលត់របស់មនោវិញ្ញាណធាតុដែលជាវិបាកនោះ និងមនោវិញ្ញាណធាតុណា ដែលធ្វើជវនកិច្ច កើតឡើងក្នុងលំដាប់នៃការកើតរលត់ របស់មនោ-វិញ្ញាណធាតុដែលជាកិរិយានោះ មនោធាតុ និងមនោវិញ្ញាណធាតុទាំងអស់នោះ គប្បីជ្រាបថា ទ្រង់ត្រាស់ដោយពាក្យថា ក៏កើតក្នុងលំដាប់នៃមនោធាតុដែលកើតហើយរលត់ទៅវិញនោះ ដូច្នេះ ។

បទថា **មនញ្ញ បដិច្ច** បានដល់ ភវង្គចិត្ត ។ បទថា **ធម្មេ ច** បានដល់

ធម្មារម្មណ៍ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ ពាក្យថា **ឧប្បជ្ជតិ មនោវិញ្ញាណំ** ( មនោវិញ្ញាណកើតឡើង ) បានដល់ ជវនចិត្ត មួយអន្ទើដោយអាវជ្ជនចិត្ត រមែងកើតឡើង ។ ក្នុងឋានៈនេះ ព្រះមហាថេរៈទាំងឡាយ កាន់យកតាមបញ្ហាដែលធ្លាប់កាន់យកមកហើយ ។ បានឮថា ព្រះមហាធម្មរក្ខិតត្ថេរ បានចាប់ដៃព្រះទីឃភាណកអភយត្ថេរ ពោលថា ក្នុងអាគតដ្ឋាន ឈ្មោះថា **បដិច្ច** ដូច្នេះ មិនគួរធ្វើអាវជ្ជនៈឲ្យបែកគ្នា គួរធ្វើអាវជ្ជនៈឲ្យអាស្រ័យភវង្គប៉ុណ្ណោះ ព្រោះហេតុនោះ បទថា **មនោ** ក្នុងទីនេះ បានដល់ ភវង្គ ព្រមទាំងអាវជ្ជនៈ ។ បទថា **មនោវិញ្ញាណំ** បានដល់ មនោវិញ្ញាណ គឺជវន ដូច្នេះ ។

ក្នុងអភិធម្មភាជនីយនេះ ត្រាស់ធាតុដែលជាកាមាវចរ ១៦ យ៉ាង ធាតុដែលប្រព្រឹត្តទៅក្នុងភូមិ ៤ លាយឡំដោយលោកិយផង លោកុត្តរផង គឺទាំង ២ យ៉ាង ដោយប្រការដូច្នេះ ។

**អដ្ឋកថាអភិធម្មភាជនីយ ចប់**

# អភិធម្មបិដក

## បញ្ហាបុច្ឆកៈ

[ ១៣១ ] ធាតុ ១៨ គឺចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុ សោតធាតុ សទ្ទធាតុ សោតវិញ្ញាណធាតុ ឃានធាតុ គន្ធធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាធាតុ រសធាតុ ជិវ្ហាវិញ្ញាណធាតុ កាយធាតុ ផោដ្ឋព្វធាតុ កាយ-វិញ្ញាណធាតុ មនោធាតុ ធម្មធាតុ មនោវិញ្ញាណធាតុ ។ បណ្ដាធាតុ ១៨ នោះ ធាតុជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។បេ។ ប្រកបដោយសត្រូវប៉ុន្មាន មិនមានសត្រូវប៉ុន្មាន ។

[ ១៣២ ] ធាតុ ១៦ ជាអព្យាក្រឹត ធាតុ ២ ជាកុសលក៏មាន ជាអកុ-សលក៏មាន ជាអព្យាក្រឹតក៏មាន ។ ធាតុ ១០ មិនគប្បីពោលថា ប្រកបដោយសុខវេទនាផង ជាប្រកបដោយទុក្ខវេទនាផង ជាប្រកបដោយអទុក្ខម-សុខវេទនាផងឡើយ ធាតុ ៥ ប្រកបដោយអទុក្ខមសុខវេទនា កាយវិញ្ញាណ-ធាតុ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន មនោ-វិញ្ញាណធាតុ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ធម្មធាតុ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន មិនគប្បីពោលថា ប្រកបដោយសុខវេទនាផង ជាប្រកបដោយទុក្ខវេទនាផង ជាប្រកបដោយអទុក្ខមសុខវេទនាផងក៏មាន ។ ធាតុ ១០ មិនមែនជាវិបាក ទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតី ធាតុ ៥ ជាវិបាក មនោធាតុជាវិបាកក៏មាន មិនមែនជាវិបាក ទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីក៏មាន ធាតុ ២ ជា

វិបាកក៏មាន ជាធម៌មានវិបាកជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនជាធម៌មានវិបាកជាប្រក្រតីក៏មាន ។ ធាតុ ១០ ជាធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន សទ្ទធាតុ ជាធម៌មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ធាតុ ៥ ជាធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន ជាធម៌មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន ធាតុ ២ ជាធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន ជាធម៌មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន ជាធម៌មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន ។ ធាតុ ១៦ មិនសៅហ្មងហើយ តែគួរដល់សេចក្តីសៅហ្មង ធាតុ ២ សៅហ្មងហើយ ទាំងគួរដល់សេចក្តីសៅហ្មងក៏មាន មិនសៅហ្មងហើយ តែគួរដល់សេចក្តីសៅហ្មងក៏មាន មិនសៅហ្មងហើយ ទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន ។ ធាតុ ១៥ មិនមានវិតក្ក មិនមានវិចារ មនោធាតុ ប្រព្រឹត្តទៅជាមួយនឹងវិតក្ក ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារ មនោ-វិញ្ញាណធាតុ ប្រព្រឹត្តទៅជាមួយនឹងវិតក្ក ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារ

ក៏មាន ធម្មធាតុ ប្រព្រឹត្តទៅជាមួយនឹងវិតក្ក ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារក៏មាន មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន មិនគប្បីពោលថា ប្រព្រឹត្តទៅជាមួយនឹងវិតក្ក ទាំងប្រព្រឹត្តទៅជាមួយនឹងវិចារផង ថាមិនមានវិតក្ក មានត្រឹមតែវិចារផង ថាមិនមានវិតក្ក ទាំងមិនមានវិចារផងក៏មាន ។ ធាតុ ១០ មិនគប្បីពោលថា កើតព្រមដោយបីតិផង ថាកើតព្រមដោយសុខផង ថាកើតព្រមដោយឧបេក្ខាផងទេ ធាតុ ៥ កើតព្រមដោយឧបេក្ខា កាយវិញ្ញាណធាតុ មិនកើតព្រមដោយបីតិ កើតព្រមដោយសុខ តែមិនកើតព្រមដោយឧបេក្ខាក៏មាន មិនគប្បីពោលថា កើតព្រមដោយសុខក៏មាន ធាតុ ២ កើតព្រមដោយបីតិក៏មាន កើតព្រមដោយសុខក៏មាន កើតព្រមដោយឧបេក្ខាក៏មាន មិនគប្បីពោលថា កើតព្រមដោយបីតិផង ថាកើតព្រមដោយសុខផង ថាកើតព្រមដោយឧបេក្ខាផងក៏មាន ។ ធាតុ ១៦ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា ធាតុ ២ គួរលះដោយទស្សនៈក៏មាន គួរលះដោយភាវនាក៏មាន មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន ។ ធាតុ ១៦ មានហេតុ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា ធាតុ ២ មានហេតុ គួរលះដោយទស្សនៈក៏មាន មានហេតុ គួរលះដោយភាវនាក៏មាន មានហេតុ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន ។ ធាតុ ១៦ មិនដល់នូវការសន្សំកពូនឡើង ទាំងមិនមែនជាមិនដល់នូវការសន្សំកពូនឡើង ធាតុ ២ ដល់នូវការសន្សំកពូនឡើងក៏មាន មិនដល់នូវការសន្សំកពូនឡើងក៏មាន

មិនមែនដល់នូវការសន្សំកពូនឡើង ទាំងមិនមែនជាមិនដល់នូវការសន្សំកពូនឡើងក៏មាន ។ ធាតុ ១៦ មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល ធាតុ ២ ជារបស់សេក្ខបុគ្គលក៏មាន ជារបស់អសេក្ខ-បុគ្គលក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខ-បុគ្គលក៏មាន ។ ធាតុ ១៦ មានសភាពតូចឆ្មារ ធាតុ ២ មានសភាពតូចឆ្មារក៏មាន ដល់នូវសភាពធំក៏មាន មានសភាពប្រមាណមិនបានក៏មាន ។ ធាតុ ១០ មិនមានអារម្មណ៍ ធាតុ ៦ មានអារម្មណ៍តូចឆ្មារ ធាតុ ២ មានអារម្មណ៍តូចឆ្មារក៏មាន មានអារម្មណ៍ដល់នូវសភាពធំក៏មាន មានអារម្មណ៍ប្រមាណមិនបានក៏មាន មិនគប្បីពោលថា មានអារម្មណ៍តូចឆ្មារផង ថាមានអារម្មណ៍ដល់នូវសភាពធំផង ថាមានអារម្មណ៍ប្រមាណមិនបានផងក៏មាន ។ ធាតុ ១៦ យ៉ាងកណ្តាល ធាតុ ២ ថោកទាបក៏មាន យ៉ាងកណ្តាលក៏មាន យ៉ាងឧត្តមក៏មាន ។ ធាតុ ១៦ មានសភាពមិនទៀង ធាតុ ២ មានសភាពខុស និងទៀងក៏មាន មានសភាពត្រូវ និងទៀងក៏មាន មានសភាពមិនទៀងក៏មាន ។ ធាតុ ១០ មិនមានអារម្មណ៍ ធាតុ ៦ មិនគប្បីពោលថា មានមគ្គជាអារម្មណ៍ផង ថាមានមគ្គជាហេតុផង ថាមានមគ្គជាអធិបតីផងឡើយ ធាតុ ២ មានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគប្បីពោលថា មានមគ្គជាអារម្មណ៍ផង ថាមានមគ្គជាហេតុផង ថាមានមគ្គជាអធិបតីផងក៏មាន ។ ធាតុ ១០ កើតឡើងហើយក៏មាន ប្រុងនឹងកើតឡើង តែមិនគប្បីពោលថា មិនទាន់កើតឡើងហើយក៏មាន សទ្ទធាតុ

កើតឡើងហើយក៏មាន មិនទាន់កើតឡើង តែមិនគប្បីពោលថា ប្រុងនឹងកើតឡើងក៏មាន ធាតុ ៦ កើតឡើងហើយក៏មាន មិនទាន់កើតឡើងក៏មាន ប្រុងនឹងកើតឡើងក៏មាន ធម្មធាតុ កើតឡើងហើយក៏មាន មិនទាន់កើតឡើងក៏មាន ប្រុងនឹងកើតឡើងក៏មាន មិនគប្បីពោលថា កើតឡើងហើយផង ថាមិនទាន់កើតឡើងផង ថាប្រុងនឹងកើតឡើងផងក៏មាន ។ ធាតុ ១៧ ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន ធម្មធាតុ ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន មិនគប្បីពោលថា ជាអតីតផង ថាជាអនាគតផង ថាជាបច្ចុប្បន្នផងក៏មាន ។ ធាតុ ១០ មិនមានអារម្មណ៍ ធាតុ ៦ មានអារម្មណ៍ជាបច្ចុប្បន្ន ធាតុ ២ មានអារម្មណ៍ជាអតីតក៏មាន មានអារម្មណ៍ជាអនាគតក៏មាន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន មិនគប្បីពោលថា មានអារម្មណ៍ជាអតីតផង ថាមានអារម្មណ៍ជាអនាគតផង ថាមានអារម្មណ៍ជាបច្ចុប្បន្នផងក៏មាន ខាងក្នុងក៏មាន ខាងក្រៅក៏មាន ទាំងខាងក្នុងទាំងខាងក្រៅក៏មាន ។ ធាតុ ១០ មិនមានអារម្មណ៍ ធាតុ ៦ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ធាតុ ២ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន មិនគប្បីពោលថា មានអារម្មណ៍ខាងក្នុងផង ថាមានអារម្មណ៍ខាងក្រៅផង ថាមានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅផងក៏មាន ។ រូបធាតុ ប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ ធាតុ ៩ មិនប្រកបដោយការឃើញ តែប្រកបដោយការ

ប៉ះពាល់ ធាតុ ៨ មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការ ប៉ះពាល់ ។

[ ១៣៣ ] ធាតុ ១៧ មិនមែនហេតុ ធម្មធាតុ ជាហេតុក៏មាន មិនមែនហេតុក៏មាន ។ ធាតុ ១៦ មិនមានហេតុ ធាតុ ២ ប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមានហេតុក៏មាន ។ ធាតុ ១៦ ប្រាសចាកហេតុ ធាតុ ២ ប្រកបដោយហេតុក៏មាន ប្រាសចាកហេតុក៏មាន ។ ធាតុ ១៦ មិនគប្បីពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុផង ថាប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុផងឡើយ មនោវិញ្ញាណធាតុ មិនគប្បីពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ ប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុផងក៏មាន មិនគប្បីពោលថា ប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុក៏មាន ធម្មធាតុ ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន ប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុក៏មាន មិនគប្បីពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុផង ថាប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុផងក៏មាន ។ ធាតុ ១៦ មិនគប្បីពោលថា ជាហេតុ ទាំងប្រកបដោយហេតុផង ថាប្រកបដោយហេតុ តែមិនមែនហេតុផងឡើយ មនោ-វិញ្ញាណធាតុ មិនគប្បីពោលថា ជាហេតុ ទាំងប្រកបដោយហេតុទេ ប្រកបដោយហេតុ តែមិនមែនហេតុក៏មាន មិនគប្បីពោលថា ប្រកបដោយហេតុ តែមិនមែនហេតុក៏មាន ធម្មធាតុ ជាហេតុ ទាំងប្រកបដោយហេតុក៏មាន ប្រកបដោយហេតុ តែមិនមែនហេតុក៏មាន មិនគប្បីពោលថា ជាហេតុ ទាំងប្រកប

ដោយហេតុផង ជាប្រកបដោយហេតុ តែមិនមែនហេតុផងក៏មាន ។ ធាតុ ១៦ មិនមែនហេតុ ទាំងមិនមានហេតុ មនោវិញ្ញាណធាតុមិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមែនហេតុ ទាំងមិនមានហេតុក៏មាន ធម្មធាតុ មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមែនហេតុ ទាំងមិនមានហេតុក៏មាន មិនគប្បីពោលថា មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុផង ជាមិនមែនហេតុ ទាំងមិនមានហេតុផងក៏មាន ។

[ ១៣៤ ] ធាតុ ១៧ ប្រព្រឹត្តទៅជាមួយនឹងបច្ច័យ ធម្មធាតុ ប្រព្រឹត្តទៅជាមួយនឹងបច្ច័យក៏មាន មិនមានបច្ច័យក៏មាន ។ ធាតុ ១៧ មានបច្ច័យតាក់តែង ធម្មធាតុ មានបច្ច័យតាក់តែងក៏មាន ឥតបច្ច័យតាក់តែងក៏មាន ។ ធាតុ ១៧ មិនប្រកបដោយការឃើញ រូបធាតុ ប្រកបដោយការឃើញ ។ ធាតុ ១០ ប្រកបដោយការប៉ះពាល់ ធាតុ ៨ មិនប្រកបដោយការប៉ះពាល់ ។ ធាតុ ១០ មានរូប ធាតុ ៧ មិនមានរូប ធម្មធាតុ មានរូបក៏មាន មិនមានរូបក៏មាន ។ ធាតុ ១៦ ជាលោកិយ ធាតុ ២ ជាលោកិយក៏មាន ជាលោកុត្តរក៏មាន ។ គប្បីដឹងច្បាស់ដោយវិញ្ញាណណាមួយក៏មាន មិនគប្បីដឹងច្បាស់ដោយវិញ្ញាណណាមួយក៏មាន ។

[ ១៣៥ ] ធាតុ ១៧ មិនមែនអាសវៈ ធម្មធាតុ ជាអាសវៈក៏មាន មិនមែនអាសវៈក៏មាន ។ ធាតុ ១៦ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ធាតុ ២ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន មិនមានអាសវៈក៏មាន ។ ធាតុ ១៦ ប្រាសចាកអាសវៈ ធាតុ ២ ប្រកបដោយអាសវៈក៏មាន ប្រាសចាកអាសវៈ

ក៏មាន ។ ធាតុ ១៦ មិនគប្បីពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈទេ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈ មនោ-វិញ្ញាណធាតុ មិនគប្បីពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈឡើយ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈក៏មាន មិនគប្បីពោលថា ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈក៏មាន ធម្មធាតុជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈក៏មាន មិនគប្បីពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ជាប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈផងក៏មាន ។ ធាតុ ១៦ មិនគប្បីពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផង ជាប្រកបដោយអាសវៈ តែមិនមែនអាសវៈផងឡើយ មនោវិញ្ញាណធាតុ មិនគប្បីពោលថាជាអាសវៈ ទាំងប្រកបដោយអាសវៈទេ ប្រកបដោយអាសវៈ តែមិនមែនអាសវៈក៏មាន មិនគប្បីពោលថា ប្រកបដោយអាសវៈ តែមិនមែនអាសវៈក៏មាន ធម្មធាតុ ជាអាសវៈ ទាំងប្រកបដោយអាសវៈក៏មាន ប្រកបដោយអាសវៈ តែមិនមែនអាសវៈក៏មាន មិនគប្បីពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផង ជាប្រកបដោយអាសវៈ តែមិនមែនអាសវៈផងក៏មាន ។ ធាតុ ១៦ ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ ធាតុ ២ ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈក៏មាន មិនគប្បីពោលថា ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈផង

ជាប្រាសចាកអាសវៈ ទាំងមិនមានអាសវៈផងក៏មាន ។

[ ១៣៦ ] ធាតុ ១៧ មិនមែនជាសំយោជនៈ ធម្មធាតុ ជាសំយោជនៈក៏មាន មិនមែនសំយោជនៈក៏មាន ។ ធាតុ ១៦ ជាប្រយោជន៍ដល់សំយោជនៈ ធាតុ ២ ជាប្រយោជន៍ដល់សំយោជនៈក៏មាន មិនជាប្រយោជន៍ដល់សំយោជនៈក៏មាន ។ ធាតុ ១៦ ប្រាសចាកសំយោជនៈ ធាតុ ២ ប្រកបដោយសំយោជនៈក៏មាន ប្រាសចាកសំយោជនៈក៏មាន ។ ធាតុ ១៦ មិនគប្បីពោលថា ជាសំយោជនៈ ទាំងជាប្រយោជន៍ដល់សំយោជនៈឡើយ ជាប្រយោជន៍ដល់សំយោជនៈ តែមិនមែនសំយោជនៈ មនោវិញ្ញាណធាតុ មិនគប្បីពោលថា ជាសំយោជនៈ ទាំងជាប្រយោជន៍ដល់សំយោជនៈទេ ជាប្រយោជន៍ដល់សំយោជនៈ តែមិនមែនសំយោជនៈក៏មាន មិនគប្បីពោលថា ជាប្រយោជន៍ដល់សំយោជនៈ តែមិនមែនសំយោជនៈក៏មាន ធម្មធាតុ ជាសំយោជនៈ ទាំងជាប្រយោជន៍ដល់សំយោជនៈក៏មាន ជាប្រយោជន៍ដល់សំយោជនៈ តែមិនមែនជាសំយោជនៈក៏មាន មិនគប្បីពោលថា ជាសំយោជនៈ ទាំងជាប្រយោជន៍ដល់សំយោជនៈផង ថាជាប្រយោជន៍ដល់សំយោជនៈ តែមិនមែនសំយោជនៈផងក៏មាន ។ ធាតុ ១៦ មិនគប្បីពោលថា ជាសំយោជនៈ ទាំងប្រកបដោយសំយោជនៈផង ថាប្រកបដោយសំយោជនៈ តែមិនមែនជាសំយោជនៈផងឡើយ មនោវិញ្ញាណធាតុ មិនគប្បីពោលថា ជាសំយោជនៈ ទាំងប្រកបដោយសំយោជនៈទេ ប្រកបដោយសំយោជនៈ តែមិនមែនសំយោជនៈក៏មាន មិនគប្បីពោលថា ប្រកបដោយសំយោជនៈ តែ

មិនមែនសំយោជនៈក៏មាន ធម្មធាតុ ជាសំយោជនៈ ទាំងប្រកបដោយសំយោជនៈក៏មាន ប្រកបដោយសំយោជនៈ តែមិនមែនសំយោជនៈក៏មាន មិនគប្បីពោលថា ជាសំយោជនៈ ទាំងប្រកបដោយសំយោជនៈផង ថាប្រកបដោយសំយោជនៈ តែមិនមែនសំយោជនៈផងក៏មាន ។ ធាតុ ១៦ ប្រាសចាកសំយោជនៈ តែជាប្រយោជន៍ដល់សំយោជនៈ ធាតុ ២ ប្រាសចាកសំយោជនៈ តែជាប្រយោជន៍ដល់សំយោជនៈក៏មាន ប្រាសចាកសំយោជនៈ ទាំងមិនជាប្រយោជន៍ដល់សំយោជនៈក៏មាន មិនគប្បីពោលថា ប្រាសចាកសំយោជនៈ តែជាប្រយោជន៍ដល់សំយោជនៈផង ថាប្រាសចាកសំយោជនៈ ទាំងមិនជាប្រយោជន៍ដល់សំយោជនៈផងក៏មាន ។

[ ១៣៧ ] ធាតុ ១៧ មិនមែនគន្ថៈ ធម្មធាតុ ជាគន្ថៈក៏មាន មិនមែនគន្ថៈក៏មាន ។ ធាតុ ១៦ គន្ថៈគប្បីដោតក្រង ធាតុ ២ គន្ថៈគប្បីដោតក្រងក៏មាន គន្ថៈមិនគប្បីដោតក្រងក៏មាន ។ ធាតុ ១៦ ប្រាសចាកគន្ថៈ ធាតុ ២ ប្រកបដោយគន្ថៈក៏មាន ប្រាសចាកគន្ថៈក៏មាន ។ ធាតុ ១៦ មិនគប្បីពោលថា ជាគន្ថៈ ទាំងគន្ថៈគប្បីដោតក្រងឡើយ គន្ថៈគប្បីដោតក្រង តែមិនមែនគន្ថៈ មនោវិញ្ញាណធាតុ មិនគប្បីពោលថា ជាគន្ថៈ ទាំងគន្ថៈគប្បីដោតក្រងទេ គន្ថៈគប្បីដោតក្រង តែមិនមែនគន្ថៈក៏មាន មិនគប្បីពោលថា គន្ថៈគប្បីដោតក្រង តែមិនមែនគន្ថៈក៏មាន ធម្មធាតុ ជាគន្ថៈ ទាំងគន្ថៈគប្បីដោតក្រងក៏មាន គន្ថៈគប្បីដោតក្រង តែមិនមែនគន្ថៈក៏មាន មិនគប្បីពោលថា ជាគន្ថៈ ទាំងគន្ថៈគប្បីដោតក្រងផង ថាគន្ថៈគប្បីដោតក្រង តែមិនមែនគន្ថៈផងក៏មាន ។ ធាតុ

១៦ មិនគប្បីពោលថា ជាគន្ថៈ ទាំងប្រកបដោយគន្ថៈផង ជាប្រកបដោយគន្ថៈ តែមិនមែនគន្ថៈផងឡើយ មនោវិញ្ញាណធាតុ មិនគប្បីពោលថា ជាគន្ថៈ ទាំងប្រកបដោយគន្ថៈទេ ប្រកបដោយគន្ថៈ តែមិនមែនជាគន្ថៈក៏មាន មិនគប្បីពោលថា ប្រកបដោយគន្ថៈ តែមិនមែនគន្ថៈក៏មាន ធម្មធាតុ ជាគន្ថៈ ទាំងប្រកបដោយគន្ថៈក៏មាន ប្រកបដោយគន្ថៈ តែមិនមែនគន្ថៈក៏មាន មិនគប្បីពោលថា ជាគន្ថៈ ទាំងប្រកបដោយគន្ថៈផង ជាប្រកបដោយគន្ថៈ តែមិនមែនគន្ថៈផងក៏មាន ។ ធាតុ ១៦ ប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រង ធាតុ ២ ប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រងក៏មាន ប្រាសចាកគន្ថៈ ទាំងគន្ថៈមិនគប្បីដោតក្រងក៏មាន មិនគប្បីពោលថា ប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រងផង ថាប្រាសចាកគន្ថៈ ទាំងគន្ថៈមិនគប្បីដោតក្រងផងក៏មាន ។

[ ១៣៨ ] ធាតុ ១៧ មិនមែនជាឱឃៈ ។បេ។ មិនមែនយោគៈ ។បេ។ មិនមែននីវរណៈ ធម្មធាតុ ជានីវរណៈក៏មាន មិនមែននីវរណៈក៏មាន ។ ធាតុ ១៦ ជាប្រយោជន៍ដល់នីវរណៈ ធាតុ ២ ជាប្រយោជន៍ដល់នីវរណៈក៏មាន មិនជាប្រយោជន៍ដល់នីវរណៈក៏មាន ។ ធាតុ ១៦ ប្រាសចាកនីវរណៈ ធាតុ ២ ប្រកបដោយនីវរណៈក៏មាន ប្រាសចាកនីវរណៈក៏មាន ។ ធាតុ ១៦ មិនគប្បីពោលថា ជានីវរណៈ ទាំងជាប្រយោជន៍ដល់នីវរណៈឡើយ ជាប្រយោជន៍ដល់នីវរណៈ តែមិនមែននីវរណៈ មនោវិញ្ញាណធាតុ មិនគប្បីពោលថា ជានីវរណៈ ទាំងជាប្រយោជន៍ដល់នីវរណៈទេ ជាប្រយោជន៍ដល់នីវរណៈ តែមិនមែននីវរណៈក៏មាន មិនគប្បីពោលថា ជានីវរណៈ តែមិន

មែននីវរណៈក៏មាន ធម្មធាតុ ជានីវរណៈ ទាំងជាប្រយោជន៍ដល់នីវរណៈក៏មាន ជាប្រយោជន៍ដល់នីវរណៈ តែមិនមែននីវរណៈក៏មាន មិនគប្បីពោលថា ជានីវរណៈ ទាំងជាប្រយោជន៍ដល់នីវរណៈផង ថាជាប្រយោជន៍ដល់នីវរណៈ តែមិនមែននីវរណៈផងក៏មាន ។ ធាតុ ១៦ មិនគប្បីពោលថា ជានីវរណៈ ទាំងប្រកបដោយនីវរណៈផង ថាប្រកបដោយនីវរណៈ តែមិនមែននីវរណៈផងឡើយ មនោវិញ្ញាណធាតុ មិនគប្បីពោលថា ជានីវរណៈ ទាំងប្រកបដោយនីវរណៈទេ ប្រកបដោយនីវរណៈ តែមិនមែននីវរណៈក៏មាន មិនគប្បីពោលថា ប្រកបដោយនីវរណៈ តែមិនមែននីវរណៈក៏មាន ធម្មធាតុ ជានីវរណៈ ទាំងប្រកបដោយនីវរណៈក៏មាន ប្រកបដោយនីវរណៈ តែមិនមែននីវរណៈក៏មាន មិនគប្បីពោលថា ជានីវរណៈ ទាំងប្រកបដោយនីវរណៈផង ថាប្រកបដោយនីវរណៈ តែមិនមែននីវរណៈផងក៏មាន ។ ធាតុ ១៦ ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈ ធាតុ ២ ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈក៏មាន ប្រាសចាកនីវរណៈ ទាំងមិនជាប្រយោជន៍ដល់នីវរណៈក៏មាន មិនគប្បីពោលថា ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈផង ថាប្រាសចាកនីវរណៈ ទាំងមិនជាប្រយោជន៍ដល់នីវរណៈផងក៏មាន ។

[ ១៣៩ ] ធាតុ ១៧ មិនមែនបរាមាស ធម្មធាតុ ជាបរាមាសក៏មាន មិនមែនបរាមាសក៏មាន ។ ធាតុ ១៦ បរាមាសស្ទាបអង្អែល ធាតុ ២ បរាមាសស្ទាបអង្អែលក៏មាន បរាមាសមិនស្ទាបអង្អែលក៏មាន ។ ធាតុ

១៦ ប្រាសចាកបរាមាស មនោវិញ្ញាណធាតុ ប្រកបដោយបរាមាសក៏មាន ប្រាសចាកបរាមាសក៏មាន ធម្មធាតុ ប្រកបដោយបរាមាសក៏មាន ប្រាស ចាកបរាមាសក៏មាន មិនគប្បីពោលថា ប្រកបដោយបរាមាសផង ថាប្រាស ចាកបរាមាសផងក៏មាន ។ ធាតុ ១៦ មិនគប្បីពោលថា ជាបរាមាស ទាំងបរាមាសស្ទាបអង្អែលឡើយ បរាមាសស្ទាបអង្អែល តែមិនមែនបរា-មាស មនោវិញ្ញាណធាតុ មិនគប្បីពោលថា ជាបរាមាស ទាំងបរាមាស ស្ទាបអង្អែលទេ បរាមាសស្ទាបអង្អែល តែមិនមែនបរាមាសក៏មាន មិន គប្បីពោលថា បរាមាសស្ទាបអង្អែល តែមិនមែនបរាមាសក៏មាន ធម្មធាតុ ជាបរាមាស ទាំងបរាមាសស្ទាបអង្អែលក៏មាន បរាមាសស្ទាបអង្អែល តែមិនមែនបរាមាសក៏មាន មិនគប្បីពោលថា ជាបរាមាស ទាំងបរាមាស ស្ទាបអង្អែលផង ថាបរាមាសស្ទាបអង្អែល តែមិនមែនបរាមាសផងក៏ មាន ។ ធាតុ ១៦ ប្រាសចាកបរាមាស តែបរាមាសស្ទាបអង្អែល ធាតុ ២ ប្រាសចាកបរាមាស តែបរាមាសស្ទាបអង្អែលក៏មាន ប្រាសចាក បរាមាស ទាំងបរាមាសមិនស្ទាបអង្អែលក៏មាន មិនគប្បីពោលថា ប្រាស ចាកបរាមាស តែបរាមាសស្ទាបអង្អែលផង ថាប្រាសចាកបរាមាស ទាំង បរាមាសមិនស្ទាបអង្អែលផងក៏មាន ។

[ ១៤០ ] ធាតុ ១០ មិនមានអារម្មណ៍ ធាតុ ៧ ប្រព្រឹត្តទៅជាមួយនឹង អារម្មណ៍ ធម្មធាតុ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ក៏មាន មិនមានអារម្មណ៍ ក៏មាន ។ ធាតុ ១១ មិនមែនចិត្ត ធាតុ ៧ ជាចិត្ត ។ ធាតុ ១៧ មិនមែន

ចេតសិក ធម្មធាតុ ជាចេតសិកក៏មាន មិនមែនចេតសិកក៏មាន ។ ធាតុ ១០ ប្រាសចាកចិត្ត ធម្មធាតុ ប្រកបដោយចិត្តក៏មាន ប្រាសចាកចិត្តក៏មាន ធាតុ ៧ មិនគប្បីពោលថា ប្រកបដោយចិត្តផង ជាប្រាសចាកចិត្តផងឡើយ ។ ធាតុ ១០ មិនច្រឡំដោយចិត្ត ធម្មធាតុ ច្រឡំដោយចិត្តក៏មាន ប្រាសចាកចិត្តក៏មាន ធាតុ ៧ មិនគប្បីពោលថា ច្រឡំដោយចិត្តផង ជាមិនច្រឡំដោយចិត្តផងឡើយ ។ ធាតុ ១២ មិនតាំងឡើងដោយចិត្ត ធាតុ ៦ តាំងឡើងដោយចិត្តក៏មាន មិនតាំងឡើងដោយចិត្តក៏មាន ។ ធាតុ ១៧ មិនកើតជាមួយនឹងចិត្ត ធម្មធាតុ កើតជាមួយនឹងចិត្តក៏មាន មិនកើតជាមួយនឹងចិត្តក៏មាន ។ ធាតុ ១៧ មិនប្រព្រឹត្តទៅតាមចិត្ត ធម្មធាតុ ប្រព្រឹត្តទៅតាមចិត្តក៏មាន មិនប្រព្រឹត្តទៅតាមចិត្តក៏មាន ។ ធាតុ ១៧ មិនច្រឡំ មិនតាំងឡើងដោយចិត្ត ធម្មធាតុ ច្រឡំ ទាំងតាំងឡើងដោយចិត្តក៏មាន មិនច្រឡំ មិនតាំងឡើងដោយចិត្តក៏មាន ។ ធាតុ ១៧ មិនច្រឡំ មិនតាំងឡើង មិនកើតជាមួយនឹងចិត្ត ធម្មធាតុ ច្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្តក៏មាន មិនច្រឡំ មិនតាំងឡើង មិនកើតជាមួយនឹងចិត្តក៏មាន ។ ធាតុ ១៧ មិនច្រឡំ មិនតាំងឡើង មិនប្រព្រឹត្តទៅតាមចិត្ត ធម្មធាតុ ច្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្តក៏មាន មិនច្រឡំ មិនតាំងឡើង មិនប្រព្រឹត្តទៅតាមចិត្តក៏មាន ។ ធាតុ ១២ ជាខាងក្នុង ធាតុ ៦ ជាខាងក្រៅ ។ ធាតុ ៩ ជាឧបាទា ធាតុ ៨ មិនមែនឧបាទា ធម្មធាតុ ជាឧបាទាក៏មាន មិនមែនឧបាទាក៏មាន ។ ធាតុ ១០ ជាឧបាទិន្ន សទ្ទធាតុ ជាអនុបាទិន្ន ធាតុ ៧ ជាឧបាទិន្ន

ក៏មាន ជាអនុបាទិន្នក៏មាន ។

[ ១៤១ ] ធាតុ ១៧ មិនមែនឧបាទាន ធម្មធាតុ ជាឧបាទានក៏មាន មិនមែនឧបាទានក៏មាន ។ ធាតុ ១៦ ជាប្រយោជន៍ដល់ឧបាទាន ធាតុ ២ ជាប្រយោជន៍ដល់ឧបាទានក៏មាន មិនជាប្រយោជន៍ដល់ឧបាទានក៏មាន ។ ធាតុ ១៦ ប្រាសចាកឧបាទាន ធាតុ ២ ប្រកបដោយឧបាទានក៏មាន ប្រាសចាកឧបាទានក៏មាន ។ ធាតុ ១៦ មិនគប្បីពោលថា ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានឡើយ ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនឧបាទាន មនោ-វិញ្ញាណធាតុ មិនគប្បីពោលថា ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានទេ ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនឧបាទានក៏មាន មិនគប្បីពោលថា ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនឧបាទានក៏មាន ធម្មធាតុ ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនឧបាទានក៏មាន មិនគប្បីពោលថា ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានផង ថាជាប្រយោជន៍ដល់ឧបាទាន តែមិនមែនឧបាទានផងក៏មាន ។ ធាតុ ១៦ មិនគប្បីពោលថា ជាឧបាទាន ទាំងប្រកបដោយឧបាទានផង ថាប្រកបដោយឧបាទាន តែមិនមែនឧបាទានផងឡើយ មនោវិញ្ញាណធាតុ មិនគប្បីពោលថា ជាឧបាទាន ទាំងប្រកបដោយឧបាទានទេ ប្រកបដោយឧបាទាន តែមិនមែនឧបាទានក៏មាន មិនគប្បីពោលថា ប្រកបដោយឧបាទាន តែមិនមែនឧបាទានក៏មាន ធម្មធាតុ ជាឧបាទាន ទាំងប្រកបដោយឧបាទានក៏មាន ប្រកបដោយឧបាទាន តែមិនមែនឧបាទានក៏មាន មិនគប្បីពោលថា ជា

ឧបាទាន ទាំងប្រកបដោយឧបាទានផង ជាប្រកបដោយឧបាទាន តែមិនមែន ឧបាទានផងក៏មាន ។ ធាតុ ១៦ ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ ឧបាទាន ធាតុ ២ ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទានក៏មាន ប្រាសចាកឧបាទាន ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន មិនគប្បីពោល ថា ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទានផង ថាប្រាសចាក ឧបាទាន ទាំងមិនជាប្រយោជន៍ដល់ឧបាទានផងក៏មាន ។

[ ១៤២ ] ធាតុ ១៧ មិនមែនសេចក្តីសៅហ្មង ( កិលេស ) ធម្មធាតុ ជាសេចក្តីសៅហ្មងក៏មាន មិនមែនសេចក្តីសៅហ្មងក៏មាន ។ ធាតុ ១៦ គួរ ដល់សេចក្តីសៅហ្មង ធាតុ ២ គួរដល់សេចក្តីសៅហ្មងក៏មាន មិនគួរដល់ សេចក្តីសៅហ្មងក៏មាន ។ ធាតុ ១៦ មិនសៅហ្មងហើយ ធាតុ ២ សៅហ្មង ហើយក៏មាន មិនសៅហ្មងហើយក៏មាន ។ ធាតុ ១៦ ប្រាសចាកសេចក្តី សៅហ្មង ធាតុ ២ ប្រកបដោយសេចក្តីសៅហ្មងក៏មាន ប្រាសចាកសេចក្តី សៅហ្មងក៏មាន ។ ធាតុ ១៦ មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងគួរ ដល់សេចក្តីសៅហ្មងឡើយ គួរដល់សេចក្តីសៅហ្មង តែមិនមែនសេចក្តី សៅហ្មង មនោវិញ្ញាណធាតុ មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងគួរដល់ សេចក្តីសៅហ្មងទេ គួរដល់សេចក្តីសៅហ្មង តែមិនមែនសេចក្តីសៅហ្មងក៏ មាន មិនគប្បីពោលថា គួរដល់សេចក្តីសៅហ្មង តែមិនមែនសេចក្តីសៅហ្មង ក៏មាន ធម្មធាតុ ជាសេចក្តីសៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មងក៏មាន គួរ ដល់សេចក្តីសៅហ្មង តែមិនមែនសេចក្តីសៅហ្មងក៏មាន មិនគប្បីពោលថា ជា

សេចក្តីសៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មងផង ជាគួរដល់សេចក្តីសៅហ្មង តែមិនមែនសេចក្តីសៅហ្មងផងក៏មាន ។ ធាតុ ១៦ មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងសៅហ្មងហើយផង ជាសៅហ្មងហើយ តែមិនមែនសេចក្តីសៅហ្មងផងឡើយ មនោវិញ្ញាណធាតុ មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងសៅហ្មងហើយទេ សៅហ្មងហើយ តែមិនមែនសេចក្តីសៅហ្មងក៏មាន មិនគប្បីពោលថា សៅហ្មងហើយ តែមិនមែនសេចក្តីសៅហ្មងក៏មាន ធម្មធាតុ ជាសេចក្តីសៅហ្មង ទាំងសៅហ្មងហើយក៏មាន សៅហ្មងហើយ តែមិនមែនសេចក្តីសៅហ្មងក៏មាន មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងសៅហ្មងហើយផង ជាសៅហ្មងហើយ តែមិនមែនសេចក្តីសៅហ្មងផងក៏មាន ។ ធាតុ ១៦ មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងប្រកបដោយសេចក្តីសៅហ្មងផង ជាប្រកបដោយសេចក្តីសៅហ្មង តែមិនមែនសេចក្តីសៅហ្មងផងឡើយ មនោវិញ្ញាណធាតុ មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងប្រកបដោយសេចក្តីសៅហ្មងទេ ប្រកបដោយសេចក្តីសៅហ្មង តែមិនមែនសេចក្តីសៅហ្មងក៏មាន មិនគប្បីពោលថា ប្រកបដោយសេចក្តីសៅហ្មង តែមិនមែនសេចក្តីសៅហ្មងក៏មាន ធម្មធាតុ ជាសេចក្តីសៅហ្មង ទាំងប្រកបដោយសេចក្តីសៅហ្មងក៏មាន ប្រកបដោយសេចក្តីសៅហ្មង តែមិនមែនជាសេចក្តីសៅហ្មងក៏មាន មិនគប្បីពោលថា ជាសេចក្តីសៅហ្មង ទាំងប្រកបដោយសេចក្តីសៅហ្មងផង ជាប្រកបដោយសេចក្តីសៅហ្មង តែមិនមែនសេចក្តីសៅហ្មងក៏មាន ។ ធាតុ ១៦ ប្រាសចាកសេចក្តីសៅហ្មង តែគួរដល់សេចក្តី

សៅហ្មង ធាតុ ២ ប្រាសចាកសេចក្តីសៅហ្មង តែគួរដល់សេចក្តីសៅហ្មងក៏មាន ប្រាសចាកសេចក្តីសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន មិនគប្បីពោលថា ប្រាសចាកសេចក្តីសៅហ្មង តែគួរដល់សេចក្តីសៅហ្មងផង ជាប្រាសចាកសេចក្តីសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មងផងក៏មាន ។

[ ១៤៣ ] ធាតុ ១៦ មិនគួរលះដោយទស្សនៈ ធាតុ ២ គួរលះដោយទស្សនៈក៏មាន មិនគួរលះដោយទស្សនៈក៏មាន ។ ធាតុ ១៦ មិនគួរលះដោយភាវនា ធាតុ ២ គួរលះដោយភាវនាក៏មាន មិនគួរលះដោយភាវនាក៏មាន ។ ធាតុ ១៦ មានហេតុ មិនគួរលះដោយទស្សនៈ ធាតុ ២ មានហេតុគួរលះដោយទស្សនៈក៏មាន មានហេតុ មិនគួរលះដោយទស្សនៈក៏មាន ។ ធាតុ ១៦ មានហេតុ មិនគួរលះដោយភាវនា ធាតុ ២ មានហេតុ គួរលះដោយភាវនាក៏មាន មានហេតុ មិនគួរលះដោយភាវនាក៏មាន ។ ធាតុ ១៥ មិនមានវិតក្ក មនោវិញ្ញាណធាតុ ប្រព្រឹត្តទៅជាមួយនឹងវិតក្ក ធាតុ ២ ប្រព្រឹត្តទៅជាមួយនឹងវិតក្កក៏មាន មិនមានវិតក្កក៏មាន ។ ធាតុ ១៥ មិនមានវិចារ មនោធាតុ ប្រព្រឹត្តទៅជាមួយនឹងវិចារ ធាតុ ២ ប្រព្រឹត្តទៅជាមួយនឹងវិចារក៏មាន មិនមានវិចារក៏មាន ។ ធាតុ ១៦ មិនមានបីតិ ធាតុ ២ ប្រព្រឹត្តទៅជាមួយនឹងបីតិក៏មាន មិនមានបីតិក៏មាន ។ ធាតុ ១៦ មិនកើតព្រមដោយបីតិ ធាតុ ២ កើតព្រមដោយបីតិក៏មាន មិនកើតព្រមដោយបីតិក៏មាន ។ ធាតុ ១៥ មិនកើតព្រមដោយសុខ ធាតុ ៣ កើតព្រមដោយសុខក៏មាន មិនកើតព្រមដោយសុខក៏មាន ។ ធាតុ ១១ មិនកើតព្រមដោយឧបេក្ខា

ធាតុ ៥ កើតព្រមដោយឧបេក្ខា ធាតុ ២ កើតព្រមដោយឧបេក្ខាក៏មាន មិនកើតព្រមដោយឧបេក្ខាក៏មាន ។ ធាតុ ១៦ ជាកាមាវចរ ធាតុ ២ ជាកាមាវចរក៏មាន មិនមែនកាមាវចរក៏មាន ។ ធាតុ ១៦ មិនមែនរូបាវចរ ធាតុ ២ ជារូបាវចរក៏មាន មិនមែនរូបាវចរក៏មាន ។ ធាតុ ១៦ មិនមែនអរូបាវចរ ធាតុ ២ ជាអរូបាវចរក៏មាន មិនមែនអរូបាវចរក៏មាន ។ ធាតុ ១៦ ជាបរិយាបន្ន ធាតុ ២ ជាបរិយាបន្នក៏មាន ជាអបរិយាបន្នក៏មាន ។ ធាតុ ១៦ ជាអនិយ្យានិកៈ ធាតុ ២ ជានិយ្យានិកៈក៏មាន ជាអនិយ្យានិកៈក៏មាន ។ ធាតុ ១៦ មិនទៀង ធាតុ ២ ទៀងក៏មាន មិនទៀងក៏មាន ។ ធាតុ ១៦ ប្រកបដោយឧត្តរៈ ធាតុ ២ ប្រកបដោយឧត្តរៈក៏មាន មិនមានឧត្តរៈក៏មាន ។ ធាតុ ១៦ មិនមានរណៈ ធាតុ ២ ប្រកបដោយរណៈក៏មាន មិនមានរណៈក៏មាន ។

បញ្ហាបុច្ឆកៈ ចប់

ធាតុវិភង្គ ចប់

# អដ្ឋកថា

## បញ្ហាបុច្ឆកៈ

[ ១៣១-១៤៣ ] ក្នុងបញ្ហាបុច្ឆកៈ បណ្ឌិតគប្បីជ្រាបភាពដែលធាតុទាំង ១៨ ជាកុសលដោយទំនងន័យ ដែលពោលខាងដើមនោះឯង ឯក្នុងអារម្មណត្តិកៈទាំងឡាយ បទថា **ឆ ធាតុយោ បរិត្តារម្មណា** នេះ ព្រះមានព្រះភាគ ត្រាស់សំដៅយកការប្រព្រឹត្តទៅនៃវិញ្ញាណ ៥ មានចក្ខុវិញ្ញាណជាដើម និងនៃមនោធាតុ ក្នុងអារម្មណ៍ ៥ មានរូបារម្មណ៍ជាដើម ដោយចំណែកមួយ ។

គប្បីជ្រាបភាពដែលធម្មធាតុ និងមនោវិញ្ញាណធាតុ ដែលត្រាស់ថា **ទ្វេ ធាតុយោ** ដូច្នេះ ជាបរិត្តារម្មណៈជាដើម ដោយន័យដែលបានពោលហើយក្នុងមនាយតនៈ និងធម្មាយតនៈនោះឯង ។ ក្នុងបញ្ហាបុច្ឆកៈនេះ ព្រះមានព្រះភាគ ត្រាស់ធាតុដែលជាកាមាវចរ ១៦ ប្រព្រឹត្តទៅក្នុងភូមិ ៤ លាយឡំដោយលោកិយ និងលោកុត្តរ ២ យ៉ាង ដូចពណ៌នាមក ដូច្នេះ ។ ធាតុវិភង្គនេះ ព្រះមានព្រះភាគទ្រង់នាំចេញចែកសម្ដែង ៣ បរិវដ្ដ ( គឺសុត្តន្តភាជនីយ ១ អភិធម្មភាជនីយ ១ បញ្ហាបុច្ឆកៈ ១ ) ដោយប្រការដូច្នេះ ។

អដ្ឋកថាបញ្ហាបុច្ឆកៈ ចប់

ធាតុវិភង្គ ចប់

# អភិធម្មបិដក

## សច្ចវិភង្គ

[ ១៨៤ ] *អរិយសច្ច ៤ គឺទុក្ខអរិយសច្ច ទុក្ខសមុទយអរិយសច្ច ទុក្ខនិរោធអរិយសច្ច ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។*

[ ១៨៥ ] *បណ្តាអរិយសច្ច ៤ នោះ ទុក្ខអរិយសច្ច តើដូចម្តេច ។ ការកើតជាទុក្ខ ការចាស់គ្រាំគ្រាជាទុក្ខ សេចក្តីស្លាប់ជាទុក្ខ សេចក្តីសោក ខ្សឹកខ្សួល លំបាកកាយ អាក់អន់ចិត្ត តានតឹងចិត្តជាទុក្ខ ការជួបប្រសព្វដោយសត្វ និងសង្ខារមិនជាទីស្រឡាញ់ជាទុក្ខ ការព្រាត់ប្រាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ជាទុក្ខ បុគ្គលកាលចង់បានរបស់ណា តែមិនបានរបស់នោះ ការមិនបាននោះជាទុក្ខ ដោយបង្រួញ ឧបាទានក្ខន្ធទាំង ៥ ក៏ជាទុក្ខ ។*

[ ១៨៦ ] *បណ្តាទុក្ខទាំងនោះ ការកើត តើដូចម្តេច ។ ការកើត កិរិយាកើតព្រម ការចុះចាប់ផ្ទៃ ការកើតចំពោះ ការកើតប្រាកដនៃខន្ធទាំងឡាយ ការបានអាយតនៈទាំងឡាយណា របស់សត្វទាំងឡាយនោះៗ ក្នុងពួកសត្វនោះៗ នេះហៅថា ការកើត ។*

[ ១៨៧ ] *បណ្តាទុក្ខទាំងនោះ ការចាស់គ្រាំគ្រា តើដូចម្តេច ។ សេចក្តីគ្រាំគ្រា ភាពនៃការទ្រុឌទ្រោម ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញជ្រីវយុរយារ ការថយចុះនៃអាយុ ការចាស់ទុំនៃឥន្ទ្រិយទាំងឡាយណា របស់សត្វទាំងឡាយនោះៗ ក្នុងពួកសត្វនោះៗ នេះហៅថា ការចាស់គ្រាំគ្រា ។*

[ ១៨៨ ] *បណ្តាទុក្ខទាំងនោះ សេចក្តីស្លាប់ តើដូចម្តេច ។ ការឃ្លាត ភាពនៃចិត្តឃ្លាត ការបែកធ្លាយ សេចក្តីបាត់បង់ សេចក្តីវិនាសជីវិត សេចក្តី*

ស្លាប់ កាលកិរិយា ការបែកធ្លាយនៃខន្ធទាំងឡាយ ការដាក់ចុះនូវសាកសព ការផ្តាច់បង់ជីវិតិន្ទ្រិយណា របស់សត្វទាំងឡាយនោះៗ ក្នុងពួកសត្វនោះៗ នេះហៅថា សេចក្តីស្លាប់ ។

[ ១៤៩ ] បណ្តាទុក្ខទាំងនោះ សេចក្តីសោក តើដូចម្តេច ។ សេចក្តីជ្រប់ស្រពោន អាការនៃចិត្តជ្រប់ស្រពោន ភាពនៃចិត្តសង្រេងសង្រៃ សេចក្តីស្ងួតស្ងប់ សេចក្តីស្ងួតស្ងប់ខ្លាំង សេចក្តីក្រៀមក្រំនៃចិត្ត សេចក្តីអាក់អន់ចិត្តសរ គឺសោករបស់សត្វដែលត្រូវសេចក្តីវិនាសញាតិប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសភោគៈ ប៉ះពាល់ក្តី ត្រូវសេចក្តីវិនាស គឺរោគប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសសីលប៉ះពាល់ក្តី ត្រូវសេចក្តីវិនាស គឺទិដ្ឋិប៉ះពាល់ក្តី ( ឬ ) ដែលប្រកបដោយសេចក្តីវិនាសណាមួយ ឬទុក្ខធម៌ណាមួយប៉ះពាល់ហើយ នេះហៅថា សេចក្តីសោក ។

[ ១៥០ ] បណ្តាទុក្ខទាំងនោះ សេចក្តីខ្សឹកខ្សួល តើដូចម្តេច ។ ការទួញ ការទួញរៀបរាប់ អាការយំអណ្តឺតអណ្តក អាការយំបម្រះនទៀល ភាពនៃការទួញ ភាពនៃការទួញរៀបរាប់ ការនិយាយ ការពោលរៀបរាប់ ការនិយាយរវើរវាយ ការនិយាយប៉ប៉ាច់ប៉ប៉ោច កិរិយានិយាយដដែលៗ ភាពនៃការនិយាយប៉ប៉ាច់ប៉ប៉ោចរបស់សត្វ ដែលត្រូវសេចក្តីវិនាសញាតិប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសភោគៈប៉ះពាល់ក្តី ត្រូវសេចក្តីវិនាស គឺរោគប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសសីលប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសគឺទិដ្ឋិប៉ះពាល់ក្តី ( ឬ ) ដែលប្រកបដោយសេចក្តីវិនាសណាមួយ ឬទុក្ខធម៌ណាមួយប៉ះពាល់ហើយ

នេះហៅថា សេចក្តីខ្សឹកខ្សួល ។

[ ១៥១ ] បណ្តាទុក្ខទាំងនោះ ការលំបាកកាយ តើដូចម្តេច ។ សេចក្តីមិនស្រួលប្រព្រឹត្តទៅក្នុងកាយ សេចក្តីទុក្ខប្រព្រឹត្តទៅក្នុងកាយ ការទទួលនូវអារម្មណ៍មិនសប្បាយ ជាទុក្ខដែលកើតអំពីកាយសម្ផស្ស វេទនាមិនស្រួលជាទុក្ខ ដែលកើតអំពីកាយសម្ផស្សណា នេះហៅថា ការលំបាកកាយ ។

[ ១៥២ ] បណ្តាទុក្ខទាំងនោះ ការអាក់អន់ចិត្ត តើដូចម្តេច ។ សេចក្តីរំខានប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីទុក្ខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលនូវអារម្មណ៍មិនសប្បាយ ជាទុក្ខដែលកើតអំពីចេតោសម្ផស្ស វេទនាមិនសប្បាយ ជាទុក្ខដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា ការអាក់អន់ចិត្ត ។

[ ១៥៣ ] បណ្តាទុក្ខទាំងនោះ ការតានតឹងចិត្ត តើដូចម្តេច ។ សេចក្តីតានតឹងចិត្ត សេចក្តីទង្គឹះក្នុងចិត្ត ភាពនៃការតានតឹងចិត្ត ភាពនៃការទង្គឹះក្នុងចិត្តរបស់សត្វ ដែលត្រូវសេចក្តីវិនាសញាតិ ប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសភោគៈប៉ះពាល់ក្តី ត្រូវសេចក្តីវិនាស គឺរោគប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសសីលប៉ះពាល់ក្តី ត្រូវសេចក្តីវិនាស គឺទិដ្ឋិប៉ះពាល់ក្តី ( ឬ ) ដែលប្រកបដោយសេចក្តីវិនាសណាមួយ ឬទុក្ខធម៌ណាមួយប៉ះពាល់ហើយ នេះហៅថា ការតានតឹងចិត្ត ។

[ ១៥៤ ] បណ្តាទុក្ខទាំងនោះ ការជួបប្រសព្វដោយសត្វ និងសង្ខារមិនជាទីស្រឡាញ់ ជាទុក្ខ តើដូចម្តេច ។ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ទាំងឡាយណា មិនជាទីប្រាថ្នា មិនជាទីត្រេកអរ

មិនជាទីគាប់ចិត្តនៃបុគ្គលណា ក្នុងលោកនេះ ពុំនោះសោត ជនទាំងឡាយណា ប្រាថ្នាសេចក្តីមិនចម្រើន ប្រាថ្នាអំពើឥតប្រយោជន៍ ប្រាថ្នាសេចក្តីមិនសប្បាយ ប្រាថ្នាសេចក្តីមិនក្សេមចាកយោគៈ ចំពោះបុគ្គលនោះ ការជួបគ្នា ការជួបប្រសព្វគ្នា ការជួបជុំគ្នា ការនៅប្រឡូកគ្នាដោយអារម្មណ៍ទាំងឡាយនោះៗ នេះហៅថា ការជួបប្រសព្វដោយសត្វ និងសង្ខារ មិនជាទីស្រឡាញ់ជាទុក្ខ ។

[ ១៥៥ ] បណ្តាទុក្ខទាំងនោះ ការព្រាត់ប្រាសចាកសត្វ និងសង្ខារ ជាទីស្រឡាញ់ ជាទុក្ខ តើដូចម្តេច ។ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ទាំងឡាយណា ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្តនៃបុគ្គលណា ក្នុងលោកនេះ ពុំនោះសោត ជនទាំងឡាយណា គឺមាតាក្តី បិតាក្តី បងប្អូនប្រុសក្តី បងប្អូនស្រីក្តី មិត្តក្តី អាមាត្យក្តី ញាតិ-សាលោហិតក្តី ប្រាថ្នាសេចក្តីចម្រើន ប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្តីសប្បាយ ប្រាថ្នាសេចក្តីក្សេមចាកយោគៈចំពោះបុគ្គលនោះ ការមិនបានជួបគ្នា ការមិនជួបប្រសព្វគ្នា ការមិនបានជួបជុំគ្នា ការមិនបានមូលមិត្តគ្នាដោយអារម្មណ៍ទាំងឡាយនោះៗ ដោយជនទាំងឡាយនោះៗ នេះហៅថា ការព្រាត់ប្រាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ ជាទុក្ខ ។

[ ១៥៦ ] បណ្តាទុក្ខទាំងនោះ បុគ្គលកាលចង់បានរបស់ណា មិនបានរបស់នោះ ការមិនបាននោះ ជាទុក្ខ តើដូចម្តេច ។ ពួកសត្វមានជាតិជាធម្មតា តែងមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ពួកយើង

កុំបីមានជាតិជាធម្មតា ពុំនោះសោត ជាតិកុំបីមកកាន់យើងទាំងឡាយឡើយ សេចក្តីនេះ ពួកសត្វតែងមិនបានសម្រេចតាមប្រាថ្នាឡើយ នេះឯងហៅថា បុគ្គលកាលចង់បានរបស់ណា មិនបានរបស់នោះ ការមិនបាននោះ ជាទុក្ខ ពួកសត្វមានជរាជាធម្មតា ។បេ។ ពួកសត្វមានព្យាធិជាធម្មតា ។បេ។ ពួកសត្វមានមរណៈជាធម្មតា ។បេ។ ពួកសត្វមានសោក បរិទេវៈ ទុក្ខ ទោមនស្ស និងឧបាយាសជាធម្មតា តែងមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ពួកយើងកុំបីមានសោក បរិទេវៈ ទុក្ខ ទោមនស្ស និងឧបាយាសជាធម្មតា ពុំនោះសោត សោក បរិទេវៈ ទុក្ខ ទោមនស្ស និងឧបាយាស កុំបីមកកាន់យើងទាំងឡាយឡើយ សេចក្តីនេះ ពួកសត្វតែងមិនបានសម្រេចតាមប្រាថ្នាឡើយ នេះឯងហៅថា បុគ្គលកាលចង់បានរបស់ណា មិនបានរបស់នោះ ការមិនបាននោះ ជាទុក្ខ ។

[ ១៥៧ ] បណ្តាទុក្ខទាំងនោះ ដោយបង្រួញឧបាទានក្ខន្ធទាំង ៥ ក៏ជាទុក្ខ តើដូចម្តេច ។ ឧបាទានក្ខន្ធទាំង ៥ គឺរូបូបាទានក្ខន្ធ វេទនូបាទានក្ខន្ធ សញ្ញូបាទានក្ខន្ធ សង្ខារូបាទានក្ខន្ធ វិញ្ញាណូបាទានក្ខន្ធ នេះហៅថា ដោយបង្រួញឧបាទានក្ខន្ធទាំង ៥ ក៏ជាទុក្ខ ។

### នេះហៅថាទុក្ខអរិយសច្ច ។

[ ១៥៨ ] បណ្តាអរិយសច្ចទាំង ៤ នោះ ទុក្ខសមុទយអរិយសច្ច តើដូចម្តេច ។ តណ្ហាណា ដែលនាំសត្វឲ្យកើតក្នុងភពថ្មីទៀត ប្រកបដោយ

តម្រេក រីករាយ ជាធម្មជាតនាំសត្វឲ្យត្រេកត្រអាលក្នុងអារម្មណ៍នោះៗ ឬក្នុងភពនោះ គឺកាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។

[ ១៥៩ ] តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងទីណា កាលតាំងនៅ រមែងតាំងនៅក្នុងទីណា ។ អារម្មណ៍ណាមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងអារម្មណ៍នុ៎ះ កាលតាំងនៅ រមែងតាំងនៅក្នុងអារម្មណ៍នុ៎ះ ។ អារម្មណ៍អ្វីហ្ន៎មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក ។ ចក្ខុ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងចក្ខុនុ៎ះ កាលតាំងនៅ រមែងតាំងនៅក្នុងចក្ខុនុ៎ះ សោតៈ ។បេ។ ឃានៈ ជិវ្ហា កាយ មនោ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងមនោនុ៎ះ កាលតាំងនៅ រមែងតាំងនៅក្នុងមនោនុ៎ះ ។ រូបទាំងឡាយ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងរូបនុ៎ះ កាលតាំងនៅ រមែងតាំងនៅក្នុងរូបនុ៎ះ សំឡេង ។បេ។ ក្លិន រស ផ្សព្វ ធម៌ទាំងឡាយ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងធម៌នុ៎ះ កាលតាំងនៅ រមែងតាំងនៅក្នុងធម៌នុ៎ះ ។ ចក្ខុវិញ្ញាណ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងចក្ខុវិញ្ញាណនុ៎ះ កាលតាំងនៅ រមែងតាំងនៅក្នុងចក្ខុវិញ្ញាណនុ៎ះ សោតវិញ្ញាណ ។បេ។ ឃាន-

វិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងមនោវិញ្ញាណនុ៎ះ កាលតាំងនៅ រមែងតាំងនៅក្នុងមនោវិញ្ញាណនុ៎ះ ។ ចក្ខុ-សម្ផស្ស មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងចក្ខុសម្ផស្សនុ៎ះ កាលតាំងនៅ រមែងតាំងនៅក្នុងចក្ខុសម្ផស្សនុ៎ះ សោតសម្ផស្ស ។បេ។ ឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងមនោសម្ផស្សនុ៎ះ កាលតាំងនៅ រមែងតាំងនៅក្នុងមនោសម្ផស្សនុ៎ះ ។ វេទនាកើតអំពីចក្ខុសម្ផស្ស មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងវេទនា ដែលកើតអំពីចក្ខុសម្ផស្សនុ៎ះ កាលតាំងនៅ រមែងតាំងនៅក្នុងវេទនា ដែលកើតអំពីចក្ខុសម្ផស្សនុ៎ះ ។ វេទនាកើតអំពីសោតសម្ផស្ស ។បេ។ វេទនាកើតអំពីឃានសម្ផស្ស វេទនាកើតអំពីជិវ្ហា-សម្ផស្ស វេទនាកើតអំពីកាយសម្ផស្ស វេទនាកើតអំពីមនោសម្ផស្ស មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងវេទនា ដែលកើតអំពីមនោសម្ផស្សនុ៎ះ កាលតាំងនៅ រមែងតាំងនៅក្នុងវេទនា ដែលកើតអំពីមនោសម្ផស្សនុ៎ះ ។ រូបសញ្ញា មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងរូបសញ្ញានុ៎ះ កាលតាំងនៅ រមែងតាំងនៅក្នុងរូប-

សញ្ញានុ៎ះ សទ្ទសញ្ញា ។បេ។ គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា ធម្ម-សញ្ញា មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងធម្មសញ្ញានុ៎ះ កាលតាំងនៅ រមែងតាំងនៅក្នុងធម្មសញ្ញានុ៎ះ ។ រូបសញ្ចេតនា មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងរូបសញ្ចេតនានុ៎ះ កាលតាំងនៅ រមែងតាំងនៅក្នុងរូបសញ្ចេតនានុ៎ះ សទ្ទសញ្ចេតនា ។បេ។ គន្ធសញ្ចេតនា រសសញ្ចេតនា ផោដ្ឋព្វសញ្ចេតនា ធម្មសញ្ចេតនា មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងធម្មសញ្ចេតនានុ៎ះ កាលតាំងនៅ រមែងតាំងនៅក្នុងធម្មសញ្ចេតនានុ៎ះ ។ រូបតណ្ហា មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងរូបតណ្ហានុ៎ះ កាលតាំងនៅ រមែងតាំងនៅក្នុងរូបតណ្ហានុ៎ះ សទ្ទតណ្ហា ។បេ។ គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងធម្មតណ្ហានុ៎ះ កាលតាំងនៅ រមែងតាំងនៅ ក្នុងធម្មតណ្ហានុ៎ះ ។ សេចក្តីត្រិះរិះរូប មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងសេចក្តីត្រិះរិះរូបនុ៎ះ កាលតាំងនៅ រមែងតាំងនៅក្នុងសេចក្តីត្រិះរិះរូបនុ៎ះ ។ សេចក្តីត្រិះរិះសំឡេង ។បេ។ សេចក្តីត្រិះរិះក្លិន សេចក្តីត្រិះរិះរស សេចក្តីត្រិះរិះផោដ្ឋព្វៈ សេចក្តីត្រិះរិះធម៌ មានសភាពគួរ

ស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងសេចក្តីត្រិះរិះធម៌នុ៎ះ កាលតាំងនៅ រមែងតាំងនៅក្នុងសេចក្តីត្រិះរិះធម៌នុ៎ះ ។ ការពិចារណារូប មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងការពិចារណារូបនុ៎ះ កាលតាំងនៅ រមែងតាំងនៅក្នុងការពិចារណារូបនុ៎ះ ការពិចារណាសំឡេង ។បេ។ ការពិចារណាក្លិន ការពិចារណារស ការពិចារណាផ្សព្វ ការពិចារណាធម៌ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុងការពិចារណាធម៌នុ៎ះ កាលតាំងនៅ រមែងតាំងនៅក្នុងការពិចារណាធម៌នុ៎ះ ។

## នេះហៅថាទុក្ខសមុទយអរិយសច្ច ។

[ ១៦០ ] បណ្តាអរិយសច្ចទាំង ៤ នោះ ទុក្ខនិរោធអរិយសច្ច តើដូចម្តេច ។ ការវិនាស និងការរលត់ដោយឥតសេសសល់ សភាវៈលះបង់ ការទម្លាក់ចោល ការជម្រះចោល ការមិនមានអាល័យចំពោះតណ្ហានោះឯង ( នេះហៅថា ទុក្ខនិរោធអរិយសច្ច ) ។

[ ១៦១ ] តណ្ហានោះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងទីណា កាលរលត់ រមែងរលត់ក្នុងទីណា ។ អារម្មណ៍ណា មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងអារម្មណ៍នុ៎ះ កាលរលត់ រមែងរលត់ក្នុងអារម្មណ៍នុ៎ះ ។ អារម្មណ៍

អ្វីហ្ន៎ ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក ។ ចក្ខុ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងចក្ខុនុ៎ះ កាលរលត់ រមែងរលត់ក្នុងចក្ខុនុ៎ះ សោតៈ ។បេ។ ឃានៈ ជិវ្ហា កាយ មនោ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងមនោនុ៎ះ កាលរលត់ រមែងរលត់ក្នុងមនោនុ៎ះ ។ រូបទាំងឡាយ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងរូបនុ៎ះ កាលរលត់ រមែងរលត់ក្នុងរូបនុ៎ះ សំឡេង ។បេ។ ក្លិន រស ផ្សព្វ ធម៌ទាំងឡាយ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងធម៌នុ៎ះ កាលរលត់ រមែងរលត់ក្នុងធម៌នុ៎ះ ។ ចក្ខុវិញ្ញាណ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងចក្ខុវិញ្ញាណនុ៎ះ កាលរលត់ រមែងរលត់ក្នុងចក្ខុវិញ្ញាណនុ៎ះ សោតវិញ្ញាណ ។បេ។ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងមនោវិញ្ញាណនុ៎ះ កាលរលត់ រមែងរលត់ក្នុងមនោវិញ្ញាណនុ៎ះ ។ ចក្ខុសម្ផស្ស មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងចក្ខុសម្ផស្សនុ៎ះ កាលរលត់ រមែងរលត់ក្នុងចក្ខុសម្ផស្សនុ៎ះ សោត-

សម្ផស្ស ។បេ។ ឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងមនោសម្ផស្សនុ៎ះ កាលរលត់ រមែងរលត់ក្នុងមនោសម្ផស្សនុ៎ះ ។ វេទនា កើតអំពីចក្ខុសម្ផស្ស មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងវេទនាដែលកើតអំពីចក្ខុសម្ផស្សនុ៎ះ កាលរលត់ រមែងរលត់ក្នុងវេទនាដែលកើតអំពីចក្ខុសម្ផស្សនុ៎ះ វេទនាកើតអំពីសោតសម្ផស្ស ។បេ។ វេទនាកើតអំពីឃានសម្ផស្ស វេទនាកើតអំពីជិវ្ហាសម្ផស្ស វេទនាកើតអំពីកាយសម្ផស្ស វេទនាកើតអំពីមនោសម្ផស្ស មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងវេទនាដែលកើតអំពីមនោសម្ផស្សនុ៎ះ កាលរលត់ រមែងរលត់ក្នុងវេទនាដែលកើតអំពីមនោសម្ផស្សនុ៎ះ ។ រូបសញ្ញា មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងរូបសញ្ញានុ៎ះ កាលរលត់ រមែងរលត់ក្នុងរូបសញ្ញានុ៎ះ សទ្ទសញ្ញា ។បេ។ គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា ធម្មសញ្ញា មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងធម្មសញ្ញានុ៎ះ កាលរលត់ រមែងរលត់ក្នុងធម្មសញ្ញានុ៎ះ ។ រូបសញ្ចេតនា មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអ រក្នុងលោក តណ្ហានុ៎ះ កាល បុគ្គលលះបង់ រមែងលះបង់ក្នុងរូបសញ្ចេតនានុ៎ះ កាលរលត់ រមែងរលត់

ក្នុងរូបសញ្ចេតនានុ៎ះ សទ្ទសញ្ចេតនា ។បេ។ គន្ធសញ្ចេតនា រសសញ្ចេតនា ផោដ្ឋព្វសញ្ចេតនា ធម្មសញ្ចេតនា មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងធម្មសញ្ចេតនានុ៎ះ កាលរលត់ រមែងរលត់ក្នុងធម្មសញ្ចេតនានុ៎ះ ។ រូបតណ្ហា មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងរូបតណ្ហានុ៎ះ កាលរលត់ រមែងរលត់ក្នុងរូបតណ្ហានុ៎ះ សទ្ទតណ្ហា ។បេ។ គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងធម្មតណ្ហានុ៎ះ កាលរលត់ រមែងរលត់ក្នុងធម្មតណ្ហានុ៎ះ ។ រូបវិតក្ក មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងរូបវិតក្កនុ៎ះ កាលរលត់ រមែងរលត់ក្នុងរូបវិតក្កនុ៎ះ សទ្ទវិតក្ក ។បេ។ គន្ធវិតក្ក រសវិតក្ក ផោដ្ឋព្វវិតក្ក ធម្មវិតក្ក មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងធម្មវិតក្កនុ៎ះ កាលរលត់ រមែងរលត់ក្នុងធម្មវិតក្កនុ៎ះ ។ រូបវិចារ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងរូបវិចារនុ៎ះ កាលរលត់ រមែងរលត់ក្នុងរូបវិចារនុ៎ះ សទ្ទវិចារ ។បេ។ គន្ធវិចារ រសវិចារ ផោដ្ឋព្វវិចារ ធម្មវិចារ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលបុគ្គល

លះបង់ រមែងលះបង់ក្នុងធម្មវិចារនុ៎ះ កាលរលត់ រមែងរលត់ក្នុងធម្មវិចារនុ៎ះ ។

នេះហៅថាទុក្ខនិរោធអរិយសច្ច ។

[ ១៦២ ] បណ្តាអរិយសច្ចទាំង ៤ នោះ ទុក្ខនិរោធគាមិនីបដិបទា-អរិយសច្ច តើដូចម្តេច ។ មគ្គដ៏ប្រសើរ មានអង្គ ៨ ប្រការនេះឯង ។ មគ្គដ៏ប្រសើរ មានអង្គ ៨ ប្រការ តើដូចម្តេច ។ សម្មាទិដ្ឋិ សម្មាសង្កប្ប សម្មាវាចា សម្មាកម្មន្ត: សម្មាអាជីវ: សម្មាវាយាម: សម្មាសតិ សម្មា-សមាធិ ។

[ ១៦៣ ] បណ្តាមគ្គមានអង្គ ៨ នោះ សម្មាទិដ្ឋិ តើដូចម្តេច ។ ប្រាជ្ញាដឹងច្បាស់ក្នុងកងទុក្ខ ប្រាជ្ញាដឹងច្បាស់ក្នុងតណ្ហា ជាហេតុនៃទុក្ខ ប្រាជ្ញាដឹងច្បាស់ក្នុងព្រះនិព្វាន ជាគ្រឿងរលត់នៃទុក្ខ ប្រាជ្ញាដឹងច្បាស់ក្នុងផ្លូវប្រតិបត្តិជាដំណើរទៅកាន់ព្រះនិព្វាន ជាគ្រឿងរលត់នៃទុក្ខ នេះហៅថា សម្មាទិដ្ឋិ ។

[ ១៦៤ ] បណ្តាមគ្គ មានអង្គ ៨ នោះ សម្មាសង្កប្ប តើដូចម្តេច ។ សេចក្តីត្រិះរិះក្នុងការចេញចាកកាម សេចក្តីត្រិះរិះក្នុងការមិនព្យាបាទ សេចក្តីត្រិះរិះក្នុងការមិនបៀតបៀន នេះហៅថា សម្មាសង្កប្ប ។

[ ១៦៥ ] បណ្តាមគ្គ មានអង្គ ៨ នោះ សម្មាវាចា តើដូចម្តេច ។ ការវៀរចាកពាក្យកុហក ការវៀរចាកវាចាញុះញង់គេ ឲ្យបែកគ្នា ការវៀរចាកវាចាទ្រគោះអាក្រក់ ការវៀរចាកពាក្យរោយរាយឥតប្រយោជន៍ នេះហៅថា សម្មាវាចា ។

[ ១៦៦ ] បណ្តាមគ្គ មានអង្គ ៨ នោះ សម្មាកម្មន្តៈ តើដូចម្តេច ។ ការវៀរចាកបាណាតិបាត ការវៀរចាកអទិន្នាទាន ការវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ នេះហៅថា សម្មាកម្មន្តៈ ។

[ ១៦៧ ] បណ្តាមគ្គ មានអង្គ ៨ នោះ សម្មាអាជីវៈ តើដូចម្តេច ។ អរិយសាវកក្នុងសាសនានេះ លះបង់ការចិញ្ចឹមជីវិតខុស ហើយសម្រេចជីវិតដោយការចិញ្ចឹមជីវិតត្រូវ នេះហៅថា សម្មាអាជីវៈ ។

[ ១៦៨ ] បណ្តាមគ្គ មានអង្គ ៨ នោះ សម្មាវាយាមៈ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែងប្រារព្ធសេចក្តីព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែងប្រារព្ធសេចក្តីព្យាយាម ផ្គង់ចិត្ត តម្កល់ចិត្ត ដើម្បីលះបង់អកុសលធម៌ដ៏លាមកដែលកើតហើយ ។បេ។ ដើម្បីញុំាងពួកកុសលធម៌ដែលមិនទាន់កើត ឲ្យកើតឡើង ។បេ។ ដើម្បីញុំាងពួកកុសលធម៌ដែលកើតហើយ ឲ្យស្ថិតស្ថេរ មិនឲ្យវិនាស ឲ្យរឹងរឹតតែចម្រើនឡើង ឲ្យធំទូលាយឡើង ឲ្យចម្រើនពោរពេញឡើង នេះហៅថា សម្មាវាយាមៈ ។

[ ១៦៩ ] បណ្តាមគ្គ មានអង្គ ៨ នោះ សម្មាសតិ តើដូចម្តេច ។ ភិក្ខុ

ក្នុងសាសនានេះ ពិចារណាឃើញច្បាស់នូវកាយក្នុងកាយ មានព្យាយាម ញុំាងកិលេសឲ្យក្តៅ ជាអ្នកដឹងខ្លួនដោយល្អ មានស្មារតី មិនប្រមាទ កម្ចាត់បង់អភិជ្ឈា និងទោមនស្សក្នុងលោក ពិចារណាឃើញច្បាស់នូវវេទនា ក្នុងវេទនាទាំងឡាយ ។បេ។ នូវចិត្តក្នុងចិត្ត ។បេ។ ពិចារណាឃើញច្បាស់នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាម ញុំាងកិលេសឲ្យក្តៅ ជាអ្នកដឹងខ្លួនដោយល្អ មានស្មារតី មិនប្រមាទ កម្ចាត់បង់អភិជ្ឈា និងទោមនស្ស ក្នុងលោក នេះហៅថា សម្មាសតិ ។

[ ១៧០ ] បណ្តាមគ្គ មានអង្គ ៨ នោះ សម្មាសមាធិ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់ឈានទី ១ ប្រកបដោយវិតក្ក ប្រកបដោយវិចារ មានបីតិ និងសុខ កើតអំពីសេចក្តីស្ងប់ស្ងាត់ ភិក្ខុបានរម្ងាប់វិតក្ក និងវិចារអស់ហើយ បានដល់ឈានទី ២ ជាធម្មជាតកើតមានក្នុងសន្តានខ្លួន មានសេចក្តីជ្រះថ្លាដ៏ឧត្តម គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារ មានតែបីតិ និងសុខកើតអំពីសមាធិ ភិក្ខុមានចិត្តនឿយណាយចាកបីតិហើយប្រកបដោយឧបេក្ខា មានស្មារតីល្អ ជាអ្នកដឹងខ្លួនដោយប្រពៃ បានទទួលនូវសុខដោយនាមកាយ ព្រះអរិយៈទាំងឡាយ តែងសរសើរបុគ្គល

ដែលបានឈានទី ៣ នោះថា បុគ្គលដែលបានឈានទី ៣ រមែងប្រកប ដោយឧបេក្ខា មានស្មារតីល្អ មានធម៌ជាគ្រឿងនៅជាសុខ ដូច្នេះ ព្រោះហេតុនៃឈានទី ៣ ណា ក៏បានដល់នូវឈានទី ៣ នោះ ភិក្ខុបានលះបង់សុខ និងទុក្ខអស់ហើយ មានសោមនស្ស និងទោមនស្សអស់ហើយ ក្នុងកាលមុន ក៏បានដល់នូវឈានទី ៤ មានវេទនាមិនមែនទុក្ខ មិនមែនសុខ គឺឧបេក្ខា មានសតិដ៏បរិសុទ្ធ ដោយឧបេក្ខា ហើយសម្រេចសម្រាន្តនៅ នេះហៅថា សម្មាសមាធិ ។

***នេះហៅថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ***

***សុត្តន្តភាជនីយ ចប់***

# អដ្ឋកថា

## សច្ចវិភង្គ សុត្តន្តភាជនីយ

### ឧទ្ទេសវារ

[ ១៤៤ ] ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងសច្ចវិភង្គ បន្ទាប់អំពីលំដាប់នៃធាតុវិភង្គដូចតទៅ

បទថា **ចត្តារិ** ជាពាក្យកំណត់ចំនួន ។ បទថា **អរិយសច្ចានិ** ជាពាក្យសម្តែងលម្អិតធម៌ដែលបានកំណត់ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងឧទ្ទេសវារ មានពាក្យថា **ទុក្ខំ អរិយសច្ចំ** ជាដើមដូចតទៅ

បណ្ឌិតអ្នកដឹងច្បាស់ គប្បីជ្រាបវិនិច្ឆ័យក្នុងលំដាប់ពាក្យប្រៀនប្រដៅដោយវិភាគ ១ ដោយវិគ្គហសព្ទ ១ ដោយប្រភេទមានលក្ខណៈជាដើម ១ ដោយអត្ថ ១ ដោយការធ្វើឲ្យរាក់ ១ ដោយមិនខ្វះមិនលើស ១ ដោយលំដាប់ ១ ដោយកិច្ចនៃញាណក្នុងអរិយសច្ច ១ ដោយប្រភេទនៃធម៌ដែលឈមចុះខាងក្នុង ១ ដោយឧបមា ១ ដោយចតុក្កៈ ១ ដោយសុញ្ញតា ១ ដោយភាពជាធម៌តែមួយដូចគ្នានឹងខ្លួន ១ ដោយសភាគ និងវិសភាគ ១ ។

បណ្តាឧទ្ទេសទាំងនោះ ពាក្យថា **ដោយវិភាគ** បានដល់ អត្ថនៃអរិយសច្ច ៤ មានទុក្ខជាដើម ទ្រង់ចែកក្នុងសច្ចៈ ៤ ប្រការ ជារបស់ពិត ជារបស់មិនខុស មិនប្រែប្រួលទៅជាដទៃ ដែលកុលបុត្តអ្នកត្រាស់ដឹងទុក្ខ

ជាដើមគប្បីដឹងច្បាស់ ដូចព្រះសារីបុត្តពោល ( ក្នុងខុទ្ទកនិកាយ បដិសម្ភិ-ទាមគ្គ ) ថា ទុក្ខសច្ច មានអត្ថថា បៀតបៀន មានអត្ថថា ក្តៅក្រហាយ មានអត្ថថា បច្ច័យតាក់តែង មានអត្ថថា ប្រែប្រួល មានអត្ថថា គួរកំណត់ដឹង សមុទយសច្ច មានអត្ថថា ប្រមូលមក មានអត្ថថា ជាហេតុ មានអត្ថថា ប្រកបព្រម មានអត្ថថា កង្វល់ ។បេ។ និរោធសច្ច មានអត្ថថា រលាស់ចេញ មានអត្ថថា ស្ងាត់ មានអត្ថថា មិនមានបច្ច័យប្រជុំតាក់តែង មានអត្ថថា មិនស្លាប់ ។បេ។ មគ្គសច្ច មានអត្ថថា ស្រោចស្រង់ មានអត្ថថា ជាហេតុ មានអត្ថថា ឃើញ មានអត្ថថា ជាអធិបតី នេះអត្ថនៃមគ្គរបស់មគ្គ ៤ យ៉ាង ជាសភាពពិត មិនប្រែប្រួល មិនឃ្លៀងឃ្លាត ដូច្នេះ ។ និងដូចលោកពោលយ៉ាងនេះថា ទុក្ខ មានអត្ថថា បៀតបៀន ១ មានអត្ថថា បច្ច័យប្រជុំតាក់តែង ១ មានអត្ថថា ក្តៅក្រហាយ ១ មានអត្ថថា ប្រែប្រួល ១ មានអត្ថថា យល់ច្បាស់ ដូច្នេះ គប្បីជ្រាបទុក្ខសច្ចជាដើម ដោយអំណាចនៃអត្ថសច្ចៈនីមួយៗ ៤ ប្រការ តាមដែលចែកយ៉ាងនេះ ដោយប្រការដូច្នេះ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងអរិយសច្ចនេះ ដោយវិភាគប៉ុណ្ណោះសិន ។

ក្នុងពាក្យថា ដោយវិគ្គហសព្ទ និងដោយប្រភេទ មានលក្ខណៈជាដើមដូចតទៅ

គប្បីជ្រាបសច្ចៈដោយវិគ្គហសព្ទថា **ទុ** សព្ទនេះ ក្នុងបទថា **ទុក្ខំ** នេះ រមែងសម្តែងភាពគួរខ្ពើម ។ ពិតហើយ សត្វលោកហៅកូនដែលគួរស្អប់ថា **ទុបុត្តោ** ។ ចំណែកសព្ទថា **ខំ** រមែងប្រាកដក្នុងភាពទទេ ។ ពិតហើយ

អាកាសដែលទទេ គេសន្មតថា **ខំ ។** សច្ចៈទី ១ នេះ ឈ្មោះថា គួរខ្ពើម ព្រោះជាទីតាំងនៃឧបទ្រព មិនមែនតិច ៗ ឈ្មោះថា ទទេ ព្រោះវៀរចាក ការទៀង ស្អាត សុខ និងអត្តា ដែលជនពាលគិត ព្រោះហេតុនោះ ទើបព្រះ មានព្រះភាគត្រាស់ថា **ទុក្ខំ** ព្រោះជារបស់គួរខ្ពើម និងជារបស់ទទេ ។

សព្ទថា **សំ** ក្នុងពាក្យថា **សមុទយំ** នេះ រមែងសម្តែងការប្រកបព្រម ដូចក្នុងពាក្យជាដើមថា **សមាគមោ សមេតំ** ការប្រជុំគ្នារួមគ្នា ។ សព្ទថា **ឧទ** នេះ រមែងសម្តែងការកើតឡើង ដូចក្នុងពាក្យជាដើមថា **ឧប្បន្នំ ឧទិតំ** កើតឡើងហើយ តាំងឡើងហើយ តែសព្ទថា **អយ** រមែងសម្តែងដល់ហេតុ តែកាលមានការប្រកបព្រមដោយបច្ច័យដ៏សេស សច្ចៈទី ២ នេះ ក៏ជាហេតុ គឺកើតឡើងនៃទុក្ខ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ថា **ទុក្ខសមុទយំ** ព្រោះសច្ចៈទី ២ នេះ ជាហេតុនៃទុក្ខ ។ ទុក្ខព្រោះការប្រកបព្រម ។

ម្យ៉ាងទៀត សច្ចៈទី ៣ ព្រោះសព្ទថា **និ** រមែងសម្តែងដល់ភាពមិនមាន និងសព្ទថា **រោធ** រមែងសម្តែងដល់ការត្រាច់ទៅ ព្រោះហេតុនោះ ទើប សច្ចៈទី ៣ នេះ បានដល់ ភាពមិនមានការត្រាច់ទៅនៃទុក្ខ ពោល គឺការ ត្រាច់ទៅក្នុងសង្សារ ព្រោះទទេចាកគតិទាំងពួង ម្យ៉ាងទៀត កាលព្រះយោគាវចរ សម្រេចសច្ចៈទី ៣ នោះហើយ រមែងមិនមានការត្រាច់ទៅនៃទុក្ខ ពោល គឺការត្រាច់ទៅក្នុងសង្សារ ទើបព្រះមានព្រះភាគត្រាស់ថា **ទុក្ខនិរោធំ** ព្រោះជាបដិបក្ខចំពោះការត្រាច់ទៅនោះ ម្យ៉ាងទៀត ហៅថា **ទុក្ខនិរោធ**

ព្រោះជាបច្ច័យដល់ការមិនកើត គឺការរលត់ទៅឥតសេសសល់នៃទុក្ខ ។

ម្យ៉ាងទៀត សច្ចៈទី ៤ នេះ រមែងប្រព្រឹត្តទៅកាន់ការរលត់ទុក្ខ ព្រោះបែរមុខចំពោះព្រះនិព្វាននោះដោយអំណាចនៃអារម្មណ៍ និងជាបដិបទាដើម្បីដល់ការរលត់ទុក្ខ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា **ទុក្ខនិរោធគាមិនី-បដិបទា** ។

ព្រោះព្រះអរិយៈ មានព្រះពុទ្ធជាដើម រមែងចាក់ធ្លុះសច្ចៈទាំងនោះ ហេតុនោះ ទើបសច្ចៈទាំងនោះ ហៅថា **អរិយសច្ច** ដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ នេះ ។ អរិយសច្ច ៤ តើអ្វីខ្លះ គឺទុក្ខអរិយសច្ច ។បេ។ ទុក្ខនិរោធគាមិនីបដិ-បទាអរិយសច្ច ១ ម្នាលភិក្ខុទាំងឡាយ អរិយសច្ចមាន ៤ នេះឯង ព្រះអរិយៈទាំងឡាយ រមែងចាក់ធ្លុះនូវអរិយសច្ចទាំងនេះ ព្រោះហេតុនោះ ទើបតថាគតហៅថា **អរិយសច្ច** ដូច្នេះ ។

ម្យ៉ាងទៀត ឈ្មោះថា អរិយសច្ច ព្រោះអត្ថថា ជាសច្ចៈរបស់ព្រះអរិយៈ ដូចព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត ជាអរិយៈ ។បេ។ ក្នុងលោកព្រម ទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ និងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ព្រោះហេតុនោះ ទើបហៅអរិយៈ ៤ ប្រការ ថាជាសច្ចៈរបស់ព្រះអរិយៈ ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ អរិយសច្ចមាន ៤ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតដែលមានឈ្មោះថា អរហំសម្មាសម្ពុទ្ធ ព្រោះព្រះតថាគតបាន

ត្រាស់ដឹងនូវអរិយសច្ច ៤ នេះ តាមសេចក្ដីពិត ។

ម្យ៉ាងទៀត ឈ្មោះថា អរិយសច្ច ព្រោះអត្ថថា ជាសច្ចៈដ៏ប្រសើរ ពាក្យថា **អរិយ** នេះ មានអធិប្បាយថា ជារបស់ពិត ជារបស់មិនខុស មិនជារបស់ប្រែប្រួល ដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ នេះ ជារបស់ពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ ព្រោះហេតុនោះ បានជាតថាគតហៅថា អរិយ-សច្ច ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ នេះឯង ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអរិយសច្ចនេះ ដោយវិគ្គហសព្ទ មានប្រមាណប៉ុណ្ណេះ ។

គប្បីជ្រាបវិនិច្ឆ័យ ដោយប្រភេទ មានលក្ខណៈជាដើម ដូចម្ដេច ពិតហើយ ក្នុងសច្ចៈទាំង ៤ នេះ ទុក្ខសច្ច **ពាធនលក្ខណំ** មានការបៀតបៀនជាលក្ខណៈ **សន្តាបនរសំ** មានការឲ្យក្ដៅក្រហាយជាកិច្ច **បវត្តិបច្ចុប្បដ្ឋានំ** មានការប្រព្រឹត្តទៅជាអាការប្រាកដ ។ សមុទយសច្ច **បភវលក្ខណំ** មានហេតុជាដែនកើតជាលក្ខណៈ **អនុបច្ឆេទករណរសំ** មានការមិនចូលទៅកាត់ជាកិច្ច **បលិពោធប្បច្ចុប្បដ្ឋានំ** មានបលិពោធជាអាការប្រាកដ ។ និរោធ-សច្ច **សន្តិលក្ខណំ** មានការស្ងប់ជាលក្ខណៈ **អច្ចុតិរសំ** មានការមិនចុតិជាកិច្ច **អនិមិត្តបច្ចុប្បដ្ឋានំ** មានការមិនមាននិមិត្តជាអាការប្រាកដ ។ មគ្គ-សច្ច **និយ្យានលក្ខណំ** មានការនាំចេញជាលក្ខណៈ **កិលេសប្បហានករណរសំ** មានការប្រហារកិលេសជាកិច្ច **វុដ្ឋានប្បច្ចុប្បដ្ឋានំ** មានការចេញ

ជាអាការប្រាកដ ។

ម្យ៉ាងទៀត សច្ចៈ ៤ នេះ មានបវត្តិ គឺការប្រព្រឹត្តទៅ មានបវត្តនៈ គឺហេតុនៃការប្រព្រឹត្តទៅ មាននិវត្តិ គឺការត្រឡប់ មាននិវត្តនៈ គឺហេតុឲ្យត្រឡប់ជាលក្ខណៈដោយលំដាប់ និងមានសង្ខតៈ មានតណ្ហា មានអសង្ខតៈ មានទស្សនៈជាលក្ខណៈ តាមលំដាប់ដូចគ្នា ។

គប្បីជ្រាបវិនិច្ឆ័យដោយប្រភេទ មានលក្ខណៈជាដើមក្នុងអរិយសច្ចៈនេះ ដោយប្រការដូច្នេះ ។

ក្នុងពាក្យថា ដោយអត្ថ និងដោយការធ្វើឲ្យរាក់នេះ គប្បីជ្រាបដោយអត្ថមុន បើមានពាក្យសួរថា អ្វីជាអត្ថរបស់សច្ចៈ ក៏គប្បីមានពាក្យឆ្លើយយ៉ាងពិស្តារថា សភាវៈណា កាលបុគ្គលសម្លឹងដោយបញ្ញាចក្ខុ រមែងមិនវិបរិតដូចកលមាយា មិនបោកបញ្ឆោតភ្នែកដូចថ្ងៃបណ្ដើរកូន មិនជាសភាវៈដែលបុគ្គលណាម្នាក់ រកមិនបាន ដូចអត្តារបស់ពួកតិរ្ថិយ ដោយពិត ជាគោចរ ( អារម្មណ៍ ) របស់អរិយញ្ញាណ ដោយភាពជារបស់ពិត មិនវិបរិត ជារបស់ពិតដោយប្រការដែលមានការបៀតបៀន មានហេតុជាដែនកើត មានការស្ងប់ មានការនាំចេញ ភាវៈនោះ ជាភាវៈដែលជារបស់ពិត មិនវិបរិត ជារបស់ពិត ដូចលក្ខណៈរបស់ភ្លើង និងដូចការប្រព្រឹត្តរបស់សត្វលោក ( ដែលកើត ចាស់ ឈឺ ស្លាប់ ) បណ្ឌិតគប្បីជ្រាបថា ជាអត្ថរបស់សច្ចៈ ដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា នេះជាទុក្ខ នុ៎ះជាធម្មជាតពិតមិនប្រែប្រួល មិនក្លាយទៅជារបស់

ដទៃឡើយ ដូច្នេះ ។ ម្យ៉ាងទៀត គប្បីជ្រាបដូចគាថានេះថា

ក្រៅអំពីទុក្ខ អ្វីដែលបៀតបៀនមិនមាន គ្រឿងបៀតបៀន ដទៃក្រៅអំពីទុក្ខក៏មិនមាន ព្រោះហេតុនោះ ទុក្ខនេះ បណ្ឌិតគប្បីដឹងថា ជាសច្ចៈ ដោយកំណត់អត្ថថា ជាសភាវៈបៀតបៀន ។

វៀរចាកតណ្ហានោះហើយ ទុក្ខ មិនមានអំពីហេតុដទៃ ទុក្ខដទៃក្រៅអំពីតណ្ហា មិនមាន ព្រោះហេតុនោះ វិសត្តិកាតណ្ហាដែលបន្សាត់ទៅក្នុងអារម្មណ៍ផ្សេងៗនោះ បណ្ឌិតគប្បីដឹងថា ជាសច្ចៈ ដោយកំណត់អត្ថថា ជាហេតុនៃទុក្ខ ។

ការស្ងប់ដទៃ ក្រៅអំពីព្រះនិព្វាន មិនមាន ព្រះនិព្វាននោះមិនមែនក្រៅអំពីសេចក្ដីស្ងប់ឡើយ ព្រោះហេតុនោះ ព្រះនិព្វាននេះ បណ្ឌិតគប្បីដឹងថា ជាសច្ចៈ ដោយកំណត់ថា ជាសេចក្ដីស្ងប់ ។

ក្រៅអំពីមគ្គហើយ ធម៌ជាគ្រឿងនាំចេញចាកភពដទៃ មិនមាន មគ្គនោះ មិនជាគ្រឿងនាំចេញចាកភពក៏មិនមែន ព្រោះហេតុនោះ ទើបមគ្គ បណ្ឌិតគប្បីជ្រាបថាជាសច្ចៈ ព្រោះជាគ្រឿងនាំចេញចាកភពដោយពិត ។

បណ្ឌិតទាំងឡាយ ពោលសភាវៈដែលពិត មិនប្រែប្រួល ជារបស់ពិតក្នុងសច្ចៈទាំង ៤ មានទុក្ខជាដើម ដោយមិនប្លែក

គ្នាថា ជាអត្ថនៃសច្ចៈ ដោយប្រការដូច្នេះឯង ។

គប្បីជ្រាបវិនិច្ឆ័យដោយអត្ថ ដោយប្រការដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យ ដោយការធ្វើឲ្យរាក់ដូចម្ដេច **សច្ច** សព្ទ ក្នុងអធិការនេះ រមែងប្រាកដក្នុងអត្ថមិនមែនតិច ប្រាកដដូចម្ដេច គឺ **សច្ច** សព្ទ ប្រាកដក្នុងវាចាសច្ចៈ ដូចក្នុងប្រយោគជាដើមថា **សច្ចំ ភណេ ន កុជ្ឈេយ្យ** បុគ្គលគួរពោលពាក្យពិត ១ មិនគួរក្រោធ ១ ដូច្នេះ ។

ប្រាកដក្នុងវិរតិសច្ចៈ ដូចក្នុងប្រយោគជាដើមថា **សច្ចេ ឋិតា សមណព្រាហ្មណា** ពួកសមណៈ និងព្រាហ្មណ៍ ដែលតាំងនៅក្នុងសច្ចៈ ដូច្នេះ ។

ប្រាកដក្នុងទិដ្ឋិសច្ច ដូចក្នុងប្រយោគជាដើមថា **កស្មា នុ សច្ចានិ វទន្តិ នានា បវាទិយាសេ កុសលាទានា** ព្រោះហេតុអ្វីហ្ន៎ បានជាសមណ-ព្រាហ្មណ៍ទាំងឡាយ ដែលពោលលើកខ្លួនថាជាអ្នកឆ្លៀវឆ្លាស ជាអ្នកពោលតាមបំណងរបស់ខ្លួន តែងពោលសច្ចៈផ្សេងៗ គ្នា ដូច្នេះ ។

ប្រាកដក្នុងបរមសច្ច គឺព្រះនិព្វាន និងមគ្គ ដូចក្នុងប្រយោគជាដើមថា **ឯកញ្ហិ សច្ចំ ន ទុតិយមត្ថិ** ឯសច្ចៈនោះមានតែមួយ មិនមែនមានពីរឡើយ ដូច្នេះ ។

ប្រាកដក្នុងអរិយសច្ច ដូចក្នុងប្រយោគជាដើមថា **ចតុន្នំ អរិយសច្ចានំ កតិ កុសលា** បណ្ដាអរិយសច្ចទាំង ៤ អរិយសច្ចជាកុសលប៉ុន្មាន ដូច្នេះ ។ ក្នុងទីនេះ **សច្ច** សព្ទនេះ រមែងប្រព្រឹត្តទៅក្នុងអរិយសច្ច ។ គប្បីជ្រាបវិនិច្ឆ័យដោយការធ្វើឲ្យរាក់ក្នុងអរិយសច្ចៈនេះ ដោយប្រការដូច្នេះ ។

ក្នុងពាក្យថា ដោយមិនខ្វះ មិនលើសនេះ បើមានពាក្យសួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ ត្រាស់អរិយសច្ច ៤ ប៉ុណ្ណោះ មិនខ្វះមិនលើស ឆ្លើយថា ព្រោះមិនមានសច្ចៈដទៃទឹងនាំចេញ ( ដក ) មាតិកាណាមួយ ក៏មិនបាន ។ ពិតហើយ សច្ចៈដទៃក្រៅលែងជាងសច្ចៈ ៤ ឬបណ្ដាសច្ចៈ ៤ នេះ គប្បីនាំចេញត្រឹមតែមួយ មិនមាន ។ ដូចព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ក្នុងលោកនេះ គប្បីពោលយ៉ាងនេះថា សេចក្ដីទុក្ខណា ដែលព្រះសមណគោតមត្រាស់ហើយ សេចក្ដីទុក្ខនុ៎ះ មិនមែនជាអរិយសច្ចទេ ទុក្ខអរិយសច្ចជាដទៃ អញនឹងបដិសេធនូវសេចក្ដីទុក្ខដែលចាត់ជាអរិយសច្ចនោះ ហើយបញ្ញត្តសេចក្ដីទុក្ខដទៃថា ជាអរិយសច្ចវិញ ហេតុនុ៎ះ មិនមានឡើយ ដូច្នេះជាដើម ។ និងដូចព្រះតម្រាស់មួយទៀតថា ម្នាលភិក្ខុ ទោះបីសមណៈ ឬព្រាហ្មណ៍ ឯណានីមួយ គប្បីពោលយ៉ាងនេះថា សេចក្ដីទុក្ខណាដែលព្រះសមណគោតមត្រាស់ហើយ សេចក្ដីទុក្ខនុ៎ះ មិនមែនជាអរិយសច្ចទី ១ ទេ អញនឹងបដិសេធនូវសេចក្ដីទុក្ខដែលចាត់ជាអរិយសច្ចទី ១ នោះ ហើយបញ្ញត្តសេចក្ដីទុក្ខដទៃ ថាជាអរិយសច្ចទី ១ ដូច្នេះវិញ ហេតុនុ៎ះ មិនមានឡើយ ដូច្នេះជាដើម ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ កាលត្រាស់ការប្រព្រឹត្តទៅនៃទុក្ខ ក៏ត្រាស់ប្រាប់មួយអន្លើដោយហេតុ កាលត្រាស់ការមិនប្រព្រឹត្តទៅ ក៏ត្រាស់ប្រាប់មួយអន្លើដោយឧបាយ ព្រោះហេតុនោះ ទើបត្រាស់អរិយសច្ច ៤ ប៉ុណ្ណោះ ដោយមានការប្រព្រឹត្តទៅ ការមិនប្រព្រឹត្ត និងហេតុទាំង ២ នោះ យ៉ាង

ក្រៃលែង ។ មា៉ងទៀត ទ្រង់ត្រាស់អរិយសច្ច ៤ ប៉ុណ្ណោះ ដោយអំណាចនៃបរិញ្ញេយ្យធម៌ គឺធម៌ដែលគួរកំណត់ដឹង បហាតព្វធម៌ គឺធម៌ដែលគួរលះ សច្ឆិកាតព្វធម៌ គឺធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ភាវេតព្វធម៌ គឺធម៌ដែលគួរចម្រើន និងត្រាស់ ៤ ដោយអំណាចនៃតណ្ហា វត្ថុដែលអាស្រ័យកើតរបស់តណ្ហា ការរម្ងត់តណ្ហា និងឧបាយជាគ្រឿងរម្ងត់តណ្ហា និងត្រាស់ ៤ ដោយអំណាចនៃអាល័យ ហេតុដែលត្រេកអរក្នុងអាល័យ ការដកនូវអាល័យ និងឧបាយជាហេតុដកនូវអាល័យ ។

គប្បីជ្រាបវិនិច្ឆ័យដោយមិនខ្វះ មិនលើស ក្នុងអរិយៈនេះ ដោយប្រការដូច្នេះ ។

ក្នុងពាក្យថា ដោយលំដាប់នេះ បានដល់ លំដាប់នៃទេសនានោះឯង ។ ក្នុងអរិយសច្ចទាំង ៤ នេះ ទុក្ខសច្ច ជាសច្ចៈដែលដឹងបានងាយ ព្រោះជារបស់គ្រោតគ្រាត និងព្រោះជារបស់ទូទៅដល់សត្វទាំងអស់ ព្រោះហេតុនោះទើបត្រាស់ទុក្ខសច្ចមុនគេ សមុទយសច្ច ត្រាស់ក្នុងលំដាប់នៃទុក្ខសច្ចនោះ ដើម្បីសម្តែងហេតុនៃទុក្ខសច្ចនោះឯង និរោធសច្ចត្រាស់បន្ទាប់អំពីសមុទសច្ចនោះ ដើម្បីសម្តែងឲ្យដឹងថា ព្រោះហេតុរលត់ ទើបផលរលត់ មគ្គសច្ច ត្រាស់ក្នុងទីបំផុត ដើម្បីសម្តែងឧបាយជាគ្រឿងសម្រេចនិរោធ-សច្ចនោះ ។

មា៉ងទៀត ព្រះមានព្រះភាគ ត្រាស់ទុក្ខមុន ដើម្បីឲ្យកើតនូវសេចក្តីសង្វេគ ដល់ពួកសត្វដែលត្រេកអរ និងប្រាថ្នាសេចក្តីសុខក្នុងភព ត្រាស់

សមុទយសច្ចក្នុងលំដាប់នៃទុក្ខនោះ ដើម្បីឲ្យដឹងថា ទុក្ខនោះ តណ្ហាមិនបាន សាងហើយរមែងមិនមក ទុក្ខនោះ រមែងមាន ព្រោះហេតុខាងក្រៅ មានព្រះ ឥស្សរបណ្ដាលក៏មិនមែន ដែលពិត ទុក្ខនោះ រមែងមាន ព្រោះតណ្ហានេះ បន្ទាប់អំពីនោះ ក៏ត្រាស់និរោធដើម្បីឲ្យកើតនូវការស្រាកស្រាន្តនៃចិត្ត ដោយ ការឃើញឧបាយជាគ្រឿងរលាស់ចេញដល់សត្វដែលមានចិត្តសង្វេគ ហើយ ស្វែងរកឧបាយ ជាគ្រឿងចេញចាកទុក្ខ ព្រោះភាពជាអ្នកត្រូវទុក្ខ ព្រមទាំង ហេតុ គឺតណ្ហាគ្របសង្កត់ហើយ បន្ទាប់អំពីនោះ ក៏ត្រាស់មគ្គដែលជាធម៌ ឲ្យដល់និរោធដើម្បីសម្រេចនិរោធ ។

គប្បីជ្រាបវិនិច្ឆ័យដោយលំដាប់ក្នុងអរិយសច្ចនេះ ដោយប្រការដូច្នេះ ។

ក្នុងពាក្យថា ដោយកិច្ចនៃញាណក្នុងអរិយសច្ចនេះ អធិប្បាយថា គប្បី ជ្រាបវិនិច្ឆ័យដោយកិច្ចនៃសច្ចញ្ញាណ ។ ពិតហើយ សច្ចញ្ញាណ មាន ២ យ៉ាង គឺ **អនុពោធញ្ញាណ** គឺញាណដែលដឹងដោយលំដាប់ ១ **បដិវេធញ្ញាណ** គឺញាណដែលចាក់ធ្លុះ ១ បណ្ដាញាណទាំង ២ នោះ អនុពោធញ្ញាណជាលោកិយ រមែងប្រព្រឹត្តទៅក្នុងនិរោធ និងមគ្គដោយអំណាចនៃការ ស្ដាប់ជាដើម ។ បដិវេធញ្ញាណជាលោកុត្តរ ធ្វើនិរោធឲ្យជាអារម្មណ៍ហើយ ចាក់ធ្លុះនូវសច្ចៈទាំង ៤ ដោយកិច្ច ដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាឃើញទុក្ខ បុគ្គលនោះ ឈ្មោះថា ឃើញទុក្ខសមុទ័យផង ឃើញទុក្ខនិរោធផង ឃើញទុក្ខនិរោធគាមិនីបដិបទាផង ដូច្នេះ ។ គប្បីពោលពុទ្ធវចនៈ ក្នុងសូត្រនេះទាំង

អស់ ។

ម្យ៉ាងទៀត ក្នុងសច្ចញាណដែលជាលោកិយ ទុក្ខញ្ញាណ រមែងហាមសក្កាយទិដ្ឋិ ដែលកំពុងប្រព្រឹត្តទៅដោយអំណាចនៃការគ្របសង្កត់ ដោយបរិយុដ្ឋាន ។ សមុទយញ្ញាណ រមែងហាមឧច្ឆេទទិដ្ឋិ ។ និរោធញ្ញាណ រមែងហាមសស្សតទិដ្ឋិ ។ មគ្គញ្ញាណ រមែងហាមអកិរិយទិដ្ឋិ ។

ម្យ៉ាងទៀត ទុក្ខញ្ញាណ រមែងហាមការបដិបត្តិខុសក្នុងផល ពោល គឺការសម្គាល់ក្នុងបញ្ចក្ខន្ធដែលប្រាសចាកការទៀង ស្អាត សុខ និងអត្តា ថាមានការទៀង មានការស្អាត មានសុខ និងមានអត្តា ។ សមុទយញ្ញាណ រមែងហាមនូវការបដិបត្តិខុស ក្នុងហេតុដែលប្រព្រឹត្តទៅក្នុងការរាប់អានយ៉ាងក្រៃលែង ក្នុងវត្ថុដែលមិនមែនហេតុ ថាជាហេតុ ដោយយល់ថា លោករមែងប្រព្រឹត្តទៅដោយព្រះឥសូរ ដោយព្រះបធាន ព្រះកាល និងដោយសភាវៈជាដើម និរោធញ្ញាណ រមែងហាមនូវការបដិបត្តិខុសក្នុងនិរោធដែលប្រកាន់ក្នុងអរូបលោក និងក្នុងភូមិដែលជាកំពូលនៃលោកជាដើម ថាជាព្រះនិព្វាន[១] ។ មគ្គញ្ញាណ រមែងហាមនូវការបដិបត្តិខុសក្នុងឧបាយដែលប្រព្រឹត្តទៅដោយការប្រកាន់ក្នុងមគ្គដែលមិនបរិសុទ្ធ មានកាមសុខល្លិកានុយោគ និងអត្តកិលមថានុយោគ ថាជាផ្លូវបរិសុទ្ធ ព្រោះហេតុនោះ ទើបបណ្ឌិតចងគាថាទាំងនេះថា

---

១- ពួកឧទកតាបស និងអាឡារតាបសជាដើម កាន់យកអរូបលោក ថាជានិព្វាន ពួកនិគ្រន្ថ កាន់យកកំពូលភូមិ គឺលោកថូបិកា ថាជានិព្វាន ( ដីកា ) ។

នរជនមិនទាន់ដឹងច្បាស់សច្ចៈទាំងឡាយ ដរាបណា ក៏វង្វេងក្នុងលោក ( ទុក្ខ ) ក្នុងហេតុកើតនៃលោក ( សមុទយៈ ) ក្នុងនិព្វានដែលជាទីរម្ងាត់នៃលោក ( និរោធ ) និងក្នុងឧបាយនៃការរម្ងាត់លោក ( មគ្គ ) ដរាបនោះ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យ ដោយកិច្ចនៃញាណក្នុងអរិយសច្ចនេះ ដោយប្រការដូច្នេះ ។

ក្នុងពាក្យថា ដោយប្រភេទនៃធម៌ដែលឈមចុះខាងក្នុង សេចក្ដីថា ពិតហើយ វៀរតណ្ហា និងអនាសវធម៌ហើយ ធម៌ទាំងអស់ដ៏សេស រាប់ថាឈមចុះខាងក្នុងទុក្ខសច្ច ។ តណ្ហាវិចរិត ៣៦ ឈមចុះខាងក្នុងសមុទយសច្ច និរោធសច្ច មិនមានអ្វីលាយឡំ ធម៌ មានវិមង្សិទ្ធិបាទ បញ្ញិន្ទ្រិយ បញ្ញាពល និងធម្មវិចយសម្ពោជ្ឈង្គ ដោយបែរមុខឆ្ពោះសម្មាទិដ្ឋិ សង្គ្រោះចូលក្នុងមគ្គសច្ច ។ វិតក្ក ៣ មាននេក្ខម្មវិតក្កជាដើម ដោយមានសម្មាសង្កប្ប ជាគ្រឿងអាង វចីសុចរិត ៤ មានសម្មាវាចាជាគ្រឿងអាង កាយសុចរិត ៣ មានសម្មាកម្មន្តៈជាគ្រឿងអាង ការប្រាថ្នាតិច និងការសន្ដោស ដោយសំដៅដល់សម្មាអាជីវៈ សង្គ្រោះចូលក្នុងមគ្គសច្ច ។ ម្យ៉ាងទៀត ព្រោះសម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ទាំងអស់នេះ ជាអរិយកន្តសីល និងព្រោះសីលដែលបុគ្គលគប្បីទទួលដោយដៃ គឺសទ្ធា និងព្រោះកាលសទ្ធិន្ទ្រិយ សទ្ធាពល ឆន្ទិទ្ធិបាទ ទាំងនេះមាន ទើបសីលមាន សទ្ធិន្ទ្រិយ សទ្ធាពល ឆន្ទិទ្ធិបាទ ទើបជាធម៌សង្គ្រោះចូលក្នុងមគ្គសច្ចៈ ។ សម្មប្បធាន ៤ វីរិយិទ្ធិបាទ

វីរិយិន្ទ្រិយ វីរិយពល វីរិយសម្ពោជ្ឈង្គ ដោយមានសម្មាវាយាមៈ ជាគ្រឿងអាង សតិប្បដ្ឋាន ៤ សតិន្ទ្រិយ សតិពល និងសតិសម្ពោជ្ឈង្គ ដោយមានសម្មាសតិជាគ្រឿងអាង សមាធិនីមួយៗ ៣ គឺសមាធិ មានវិតក្ក និងមានវិចារជាដើម ចិត្តសមាធិ សមាធិន្ទ្រិយ សមាធិពល បីតិសម្ពោជ្ឈង្គ បស្សទ្ធិ-សម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ ឧបេក្ខាសម្ពោជ្ឈង្គ ដោយមានសម្មាសមាធិជាគ្រឿងអាង ជាធម៌សង្គ្រោះចូលក្នុងមគ្គ ។

គប្បីជ្រាបវិនិច្ឆ័យប្រភេទនៃធម៌ដែលឈមចុះក្នុងអរិយសច្ចនេះ ដោយប្រការដូច្នេះ ។

ក្នុងពាក្យថា ដោយឧបមានេះ គប្បីឃើញទុក្ខសច្ចដូចរបស់ធ្ងន់ សមុទយសច្ច ដូចការកាន់យកការៈធ្ងន់ និរោធសច្ច ដូចការដាក់ការៈធ្ងន់ មគ្គសច្ច ដូចឧបាយជាគ្រឿងដាក់នូវភារៈ ។ ម្យ៉ាងទៀត ទុក្ខសច្ច ដូចរោគ សមុទយសច្ច ដូចសមុដ្ឋានរបស់រោគ និរោធសច្ច ដូចការស្ងប់រោគ មគ្គសច្ចដូចថ្នាំ ។

ម្យ៉ាងទៀត ទុក្ខសច្ច ប្រៀបដូចកិក្ខារកបានដោយក្រ សមុទយសច្ច ប្រៀបដូចភ្លៀងមិនល្អ និរោធសច្ច ប្រៀបដូចកិក្ខារកបានងាយ មគ្គសច្ច ប្រៀបដូចភ្លៀងដែលធ្លាក់ល្អ ។

ម្យ៉ាងទៀត គប្បីជ្រាបសច្ចៈទាំងនេះ ដោយឧបមា ដោយបុគ្គលមានពៀរ មូលហេតុនៃពៀរ ការដកឡើងនូវពៀរ ឧបាយដកឡើងនូវពៀរ និងគប្បីជ្រាបដោយដើមឈើពុល ឫសរបស់ដើមឈើពុល ការគាស់រំលើង

ដើមឈើពុល ឧបាយនៃការកាត់រំលើងដើមឈើពុលនោះ និងគប្បីជ្រាបដោយភ័យ ហេតុដែលមានភ័យ ការរួចផុតអំពីភ័យ ឧបាយដែលឲ្យផុតភ័យ និងគប្បីជ្រាបដោយត្រើយអាយ អន្លង់ទឹកធំ ត្រើយនាយ និងបុគ្គលព្យាយាមឲ្យដល់ត្រើយនាយ ។

ពាក្យថា ដោយចតុក្កៈ សេចក្តីថា បណ្តាសច្ចៈ ៤ ធម៌ដែលជាទុក្ខតែមិនមែនទុក្ខអរិយសច្ចក៏មាន ធម៌ដែលជាអរិយសច្ច មិនជាទុក្ខក៏មាន ធម៌ដែលជាទុក្ខផង ដោយជាអរិយសច្ចផងក៏មាន ធម៌ដែលមិនជាទុក្ខផង មិនជាអរិយសច្ចផងក៏មាន ក្នុងសមុទយសច្ចជាដើមក៏ដូចគ្នា ។

ក្នុងចតុក្កៈនោះ ធម៌ទាំងឡាយដែលសម្បយុត្តដោយមគ្គ និងសាមញ្ញផលទាំងឡាយ ឈ្មោះថា ជាទុក្ខ ព្រោះជាសង្ខារទុក្ខ ដោយព្រះបាលីថា **យទនិច្ចំ តំ ទុក្ខំ** របស់ណាមិនទៀង របស់នោះជាទុក្ខ ។ តែមិនមែនអរិយសច្ច ។ និរោធ ជាអរិយសច្ច តែមិនជាទុក្ខ ឯអរិយសច្ចទាំង ២ ក្រៅអំពីនេះ គឺសមុទយៈ និងមគ្គ ជាទុក្ខ ព្រោះមិនទៀង តែមិនមែនទុក្ខ ដោយសភាវៈដែលកុលបុត្តអ្នកប្រព្រឹត្តព្រហ្មចរិយៈ ក្នុងព្រះមានព្រះភាគគប្បីកំណត់ដឹង ឯឧបាទានក្ខន្ធ ៥ វៀរតណ្ហាហើយ ជាទុក្ខផង ជាអរិយសច្ចផង ដោយប្រការទាំងពួង ។ ធម៌ទាំងឡាយដែលសម្បយុត្តដោយមគ្គ និងសាមញ្ញផលទាំងឡាយ មិនមែនទុក្ខ ដោយសភាវៈដែលកុលបុត្តអ្នកនៅប្រព្រឹត្តព្រហ្មចរិយៈ ក្នុងព្រះមានព្រះភាគដើម្បីកំណត់ដឹង ទាំងមិនមែនជាអរិយសច្ច ។

គប្បីជ្រាបការប្រកប តាមគួរក្នុងសមុទយៈជាដើម ហើយវិនិច្ឆ័យចតុក្កៈ

ក្នុងអរិយសច្ចនេះ ដោយប្រការដូច្នេះ ។

ក្នុងពាក្យថា ដោយសុញ្ញតា និងដោយភាពជាធម៌តែមួយដូចគ្នានឹងខ្លួនជាដើមនេះ គប្បីជ្រាបដោយសុញ្ញតាមុន ។ ពិតហើយ ដោយបរមត្ថសច្ច ទាំងអស់ គប្បីជ្រាបថា ជាសភាវៈទទេ ព្រោះមិនមានអ្នកសោយ មិនមានអ្នកធ្វើ មិនមានអ្នករម្លត់ មិនមានអ្នកទៅ ដោយហេតុនោះ ទើបអ្នកប្រាជ្ញចងគាថានេះថា

សេចក្ដីពិត ទុក្ខប៉ុណ្ណោះមាន តែបុគ្គលដែលកើតទុក្ខមិនមាន
ការធ្វើមាន តែអ្នកធ្វើមិនមាន ការរលត់មាន តែបុគ្គលអ្នក
រម្លត់មិនមាន ផ្លូវមាន តែបុគ្គលអ្នកដើរមិនមាន ។

ម្យ៉ាងទៀត

ភាពទទេក្នុងសច្ចៈ ៤ នោះ គប្បីជ្រាបយ៉ាងនេះ គឺសច្ចៈ ២
ដំបូង ទទេចាកការទៀង ការស្អាត សេចក្ដីសុខ និងអត្តា
អមតបទ គឺព្រះនិព្វាន ទទេចាកអត្តា មគ្គ ទទេចាកភាព
ទៀង សេចក្ដីសុខ និងអត្តា ដូច្នេះ ។

ម្យ៉ាងទៀត សច្ចៈ ៣ ទទេចាកនិរោធ និរោធ ក៏ទទេចាកសច្ចៈ ៣ ដ៏សេស ។ ម្យ៉ាងទៀត ក្នុងសច្ចៈ ៤ នេះ ហេតុ ទទេចាកផល ព្រោះមិនមានទុក្ខក្នុងសមុទយៈ និងមិនមាននិរោធក្នុងមគ្គ ហេតុមិនរួមនឹងផល ដូចបកតិរបស់ពួកបកតិវាទីទាំងឡាយ ។ ផលសោត ក៏ទទេចាកហេតុ ព្រោះសេចក្ដីទុក្ខ និងសមុទយៈ និរោធ និងមគ្គ មិនបានកើតជាមួយគ្នា ផលនោះ មិន

បានតែម្យ៉ាងជាមួយហេតុ ដូចអណ្ឌូ ២ របស់ហេតុផលនៃពួកសមវាយវាទី ព្រោះហេតុនោះ ទើបអ្នកប្រាជ្ញចងគាថានេះថា

បណ្ដាអរិយសច្ច ៤ នេះ សច្ចៈ ៣ ទទេចាកនិរោធ និរោធ ក៏ទទេចាកសច្ចៈ ៣ នោះ សច្ចៈដែលជាហេតុ ទទេចាកសច្ចៈ ដែលជាផល សច្ចៈដែលជាផលនោះ ក៏ទទេចាកសច្ចៈដែល ជាហេតុ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យដោយសុញ្ញតាយ៉ាងនេះប៉ុណ្ណោះ ។

ក្នុងពាក្យថា ដោយភាពជាធម៌តែមួយដូចគ្នាទីផងខ្លួន សេចក្ដីថា បណ្ដាសច្ចៈទាំង ៤ នោះ ទុក្ខទាំងអស់ ឈ្មោះថា មានតែមួយ ព្រោះជាបវត្តិ គឺជាធម៌វិលទៅក្នុងវដ្ដៈ ជា ២ យ៉ាង ដោយជានាម និងជារូប ជា ៣ យ៉ាង ដោយចែកជាឧបបត្តិភព គឺកាមភព រូបភព អរូបភព ជា ៤ យ៉ាង ដោយប្រភេទនៃអាហារ ៤ ជា ៥ យ៉ាង ដោយប្រភេទនៃឧបាទានក្ខន្ធ ៥ ។

សមុទយៈ ឈ្មោះថា មាន ១ ព្រោះជាបវត្តកៈ គឺជាហេតុឲ្យប្រព្រឹត្តទៅ ជា ២ ដោយជាធម៌ដែលសម្បយុត្តជាមួយទិដ្ឋិ និងមិនសម្បយុត្តជាមួយទិដ្ឋិ ជា ៣ ដោយចែកជាកាមតណ្ហា ភវតណ្ហា វិភវតណ្ហា ជា ៤ ព្រោះជាទោស ដែលមគ្គ ៤ គប្បីលះ ជា ៥ ដោយចែកអារម្មណ៍ មានការត្រេកអរក្រៃលែងក្នុងរូបក្ខន្ធជាដើម ជា ៦ ដោយប្រភេទនៃគំនរតណ្ហា ៦ ។

និរោធ ឈ្មោះថា មានតែ ១ ព្រោះជាអសង្ខតធាតុ តែដោយបរិយាយ គឺដោយអមនិរោធមាន ២ ជាឧបាទិសេសនិព្វាន និងអនុបាទិសេសនិព្វាន

មាន ៣ ព្រោះស្ងប់ភពទាំង ៣ មាន ៤ ព្រោះជាអារម្មណ៍ ឲ្យមគ្គ ៤ សម្រេច មាន ៥ ព្រោះស្ងប់សេចក្ដីត្រេកអរក្រៃលែងទាំង ៥ មានរូបារម្មណ៍ជាដើម មាន ៦ ដោយប្រភេទនៃការអស់ទៅនៃគំនរតណ្ហា ៦ ។

មគ្គសោត ក៏ឈ្មោះថា មានតែ ១ ព្រោះជាធម៌គួរបម្រើន មាន ២ ព្រោះចែកជាសមថៈ និងវិបស្សនា ម្យ៉ាងទៀត មាន ២ យ៉ាង ដោយប្រភេទនៃទស្សនៈ គឺសោតាបត្តិមគ្គ និងភាវនា គឺមគ្គ ៣ ដ៏សេស មាន ៣ ដោយប្រភេទនៃធម្មក្ខន្ធ ៣ មានសីលក្ខន្ធជាដើម ។

ពិតហើយ មគ្គនេះព្រោះជាសប្បទេសធម៌ គឺធម៌ដែលទ្រង់សម្ដែងដោយចំណែកខ្លះ ទើបសង្គ្រោះដោយខន្ធ ៣ ដែលជានិប្បទេសធម៌ គឺធម៌ដែលទ្រង់សម្ដែងដោយចំណែកច្រើន ដូចនគរដែលជាប្រធានសង្គ្រោះចូលដោយរាជអាណាចក្រ ដូច្នោះ សមដូចពាក្យដែលព្រះនាងធម្មទិន្នាថេរី ពោលឆ្លើយបញ្ហានឹងវិសាខឧបាសក ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលអាវុសោវិសាខ ខន្ធទាំង ៣ ប្រការ លោកមិនបានសង្គ្រោះចូលក្នុងអដ្ឋង្គិកមគ្គដ៏ប្រសើរទេ ម្នាលអាវុសោវិសាខ តែអដ្ឋង្គិកមគ្គទាំង ៨ ប្រការ ដ៏ប្រសើរ លោកសង្គ្រោះចូលក្នុងខន្ធទាំង ៣ ប្រការវិញ ម្នាលអាវុសោវិសាខ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ ធម៌ទាំង ( ៣ ) នេះ លោកសង្គ្រោះចូលក្នុងសីលក្ខន្ធ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ ធម៌ទាំង ( ៣ ) នេះ លោកសង្គ្រោះចូលក្នុងសមាធិក្ខន្ធ សម្មាទិដ្ឋិ ១ សម្មាសង្កប្ប ១ ធម៌ទាំង ( ២ ) នេះ លោកសង្គ្រោះចូល

ក្នុងបញ្ហាខន្ធ ដូច្នេះ ។

ដ្បិតថា ក្នុងអរិយមគ្គមានអង្គ ៨ នេះ មគ្គមានសម្មាវាចាជាដើម ជាសីលតែម្យ៉ាង ព្រោះហេតុនោះ ទើបមគ្គ ៣ មានសម្មាវាចាជាដើមនោះ ទ្រង់សង្គ្រោះដោយសីលក្ខន្ធ ដោយកំណើតរបស់ខ្លួន ក្នុងព្រះបាលី ទ្រង់ធ្វើនិទ្ទេសដោយសត្តមីវិភត្តិថា **សីលក្ខន្ធេ** ដូច្នេះ ក៏ពិត តែគប្បីជ្រាបដោយអំណាចនៃតតិយាវិភត្តិនោះ ។ ម្យ៉ាងទៀត ក្នុងមគ្គ ៣ មានសម្មាវាយាមៈជាដើម សមាធិមិនអាចជាអប្បនាដោយមានអារម្មណ៍តែ ១ ក្នុងអារម្មណ៍តាមធម្មតារបស់ខ្លួនបាន តែកាលវីរិយៈញុំាងកិច្ច គឺការផ្គងចិត្តឲ្យសម្រេច កាលសតិញុំាងកិច្ច គឺការរឭកបាន ឲ្យសម្រេច សមាធិបានឧបការៈហើយ ក៏រមែងជាអប្បនាបាន ។

ក្នុងសេចក្តីនោះ មានឧបមាដូចតទៅនេះ ប្រៀបដូចសម្លាញ់ ៣ នាក់ចូលទៅកាន់ឧទ្យានដោយបំណងថា ពួកយើងនឹងលេងនក្ខត្តឫក្ស បុរសម្នាក់ឃើញដើមចម្ប៉ា មានផ្ការីកស្កុសស្កាយ កាលលូកដៃទៅ ក៏មិនអាចបេះបានពេលនោះ សម្លាញ់ទី ២ ក៏ឱនខ្នងឲ្យសម្លាញ់ទី ១ នោះឈរលើខ្នងរបស់សម្លាញ់ទី ២ ហើយក៏មិនអាចទប់ខ្លួនបាន មិនអាចបេះផ្កាបាន ពេលនោះសម្លាញ់ទី ៣ ក៏ផ្ទៀងស្មាឲ្យ សម្លាញ់ទី ១ នោះ ក៏ជាន់លើខ្នងសម្លាញ់ទី ២ តោងស្មារបស់សម្លាញ់ទី ៣ ទើបបេះផ្កាទាំងឡាយបានតាមគាប់ចិត្ត តាក់តែងកាយ លេងនក្ខត្តឫក្ស យ៉ាងណា ឧបមេយ្យនេះ ក៏គប្បីឃើញយ៉ាងនោះ ។

ពិតហើយ ធម៌ ៣ មានសម្មាវាយាមៈជាដើម កើតព្រមគ្នា ដូចជាសម្លាញ់ ៣ នាក់ ចូលទៅកាន់ឧទ្យានព្រមគ្នា អារម្មណ៍ដូចដើមចម្ប៉ាមានផ្ការីកស្គុសស្គាយ សមាធិមិនអាចតាំងនៅដោយអារម្មណ៍ ១ ក្នុងអារម្មណ៍តាមធម្មតារបស់ខ្លួន ដូចសម្លាញ់ទី ១ ដែលឈោងដៃទៅ ក៏មិនអាចបេះផ្កាបាន វាយាមៈដូចសម្លាញ់ដែលឱនខ្នងឲ្យ សតិដូចសម្លាញ់ដែលឈរហុចស្មាឲ្យ បណ្តាសម្លាញ់ ៣ នាក់នោះ សម្លាញ់ទី ១ ដែលឈរលើខ្នងសម្លាញ់ទី ២ គោងស្មាសម្លាញ់ទី ៣ រមែងអាចបេះផ្កាបានតាមប្រាថ្នា យ៉ាងណា សមាធិក៏យ៉ាងនោះដូចគ្នា កាលសេចក្តីព្យាយាមញ៉ាំងកិច្ច គឺការផ្គងចិត្តឲ្យសម្រេច កាលសតិញ៉ាំងកិច្ច គឺការរឭកបាន ដើម្បីជាឧបការៈហើយ រមែងអាចតាំងមាំក្នុងអារម្មណ៍ ១ ព្រោះហេតុនោះ ក្នុងមគ្គទាំង ៣ នេះ មគ្គ គឺសមាធិប៉ុណ្ណោះ ទ្រង់សង្គ្រោះដោយសមាធិក្ខន្ធដោយកំណើតរបស់ខ្លួន ឯមគ្គមានវាយាមៈ និងសតិ ទ្រង់សង្គ្រោះជាសមាធិក្ខន្ធដោយកិរិយា គឺដោយធម៌មានឧបការៈ ។

ក្នុងសម្មាទិដ្ឋិ និងសម្មាសង្កប្បសោត បញ្ញា គឺសម្មាទិដ្ឋិ មិនអាចវិនិច្ឆ័យអារម្មណ៍ថា មិនទៀង ជាទុក្ខ ជាអនត្តា តាមធម្មតារបស់ខ្លួនបាន តែកាលវិតក្ក គឺសម្មាសង្កប្បប៉ះខ្ទប់រឿយៗ ក៏អាចកាត់សម្រេចបាន ។ សេចក្តីនេះដូចអ្វី ប្រៀបដូចហិរញ្ញិក ដាក់ហិរញ្ញកហាបណៈក្នុងដៃ សូម្បីជាអ្នកប្រាថ្នាដើម្បីពិនិត្យចំណែកទាំងពួងរបស់ហិរញ្ញ ក៏មិនអាចប្រើភ្នែក មើលដោយជុំវិញបាន តែកាលយកម្រាមដៃត្រឡប់ទៅត្រឡប់មក ក៏អាចមើលដោយជុំ

វិញបាន យ៉ាងណា បញ្ញាក៏យ៉ាងនោះដូចគ្នា មិនអាចវិនិច្ឆ័យអារម្មណ៍ដោយអំណាចភាពជារបស់មិនទៀងជាដើម តាមធម្មតារបស់ខ្លួន តែអាចវិនិច្ឆ័យអារម្មណ៍ដែលវិតក្ក ដែលមានការលើកចិត្តឡើងកាន់អារម្មណ៍ ជាលក្ខណៈ មានការធ្វើចិត្តឲ្យប៉ះខ្ទប់អារម្មណ៍រឿយៗ ជាកិច្ច ដូចការប៉ះខ្ទប់ និងដូចចាប់បង្វិលទៅមកឲ្យនោះឯង ព្រោះហេតុនោះ ក្នុងអធិការនេះ សម្មាទិដ្ឋិប៉ុណ្ណោះទ្រទ្រង់សង្គ្រោះដោយបញ្ញាខន្ធ ព្រោះកំណើតរបស់ខ្លួន ឯសម្មាសង្កប្ប ជាធម៌ដែលទ្រទ្រង់សង្គ្រោះដោយកិរិយា ។ មគ្គ រមែងដល់នូវការសង្គ្រោះ ដោយខន្ធទាំង ៣ នេះ ដោយប្រការដូច្នេះ ដោយហេតុនោះ ទើបពោលថា មគ្គមាន ៣ យ៉ាង ដោយប្រភេទនៃខន្ធ ៣ ។ មគ្គមាន ៤ យ៉ាង ដោយប្រភេទនៃមគ្គ ៤ មានសោតាបត្តិមគ្គជាដើម ។

ម្យ៉ាងទៀត សច្ចៈទាំងឡាយនោះឯងមានតែ ១ ព្រោះជាភាវៈដែលមានដោយពិត ឬព្រោះជាអភិញ្ញេយ្យធម៌ មាន ២ យ៉ាង ដោយជាលោកិយ និងលោកុត្តរ និងជាសង្ខតៈ និងអសង្ខតៈ មាន ៣ យ៉ាង ដោយជាធម៌ដែលគប្បីលះដោយទស្សនៈ និងភាវនា និងជាធម៌ដែលមិនគប្បីលះដោយទស្សនៈនិងភាវនា និងដោយជាធម៌ដែលគប្បីលះក៏មិនមែន មិនគប្បីលះក៏មិនមែន មាន ៤ យ៉ាង ដោយប្រភេទបរិញ្ញេយ្យធម៌ជាដើម ដូច្នេះឯង ។

គប្បីជ្រាបវិនិច្ឆ័យដោយភាពជាធម៌តែមួយដូចគ្នានឹងខ្លួន ក្នុងអរិយសច្ចៈនេះ ដោយប្រការដូច្នេះ ។

ក្នុងពាក្យថា ដោយសភាគ និងវិសភាគ សេចក្តីថា សច្ចៈទាំងអស់នោះ

ឯង ឈ្មោះថា ជាសភាគ គឺមានចំណែកស្មើគ្នានិងគ្នា ដោយជារបស់ពិត ដោយជារបស់ទទេចាកអត្តា និងដោយជាវត្ថុដែលចាក់ធ្លុះបានដោយក្រ ដូចព្រះមានព្រះភាគត្រាស់ ( ក្នុងសំយុត្តនិកាយ មហាវារវគ្គ ) ថា ម្នាលអានន្ទ អ្នកសម្គាល់ហេតុនោះដូចម្តេច អំពើដូចម្តេចហ្ន៎ ដែលបុគ្គលធ្វើបានដោយកម្រក្រៃលែងផង ហេតុកើតឡើងព្រមដោយកម្រផង ។ ជនណាបាញ់សរតាមរន្ធចន្ទោងដ៏តូចអំពីចម្ងាយ ឲ្យចេញទៅតៗ គ្នា មិនឲ្យដាច់ ឬក៏ជនណា បាញ់ទម្លុះនូវចុងនៃចុងរោមកន្ទុយ ដែលប្រៀកជា ៧ ចម្រៀក ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណាបាញ់ទម្លុះនូវចុងនៃចុងរោមកន្ទុយ ដែលប្រៀកជា ៧ ចម្រៀក ហេតុនុ៎ះដែលបុគ្គលធ្វើបានដោយកម្រ ឬជាហេតុកើតឡើងព្រមដោយកម្រ ។ ម្នាលអានន្ទ ពួកជនណាចាក់ធ្លុះតាមសេចក្តីពិតថា នេះជាទុក្ខ ។បេ។ ចាក់ធ្លុះតាមសេចក្តីពិតថា នេះជាទុក្ខនិរោធគាមិនីបដិបទា ពួកជនទាំងនោះ ទើបឈ្មោះថា ចាក់ធ្លុះនូវហេតុដែលបុគ្គលចាក់ធ្លុះបានដោយកម្រ ដូច្នេះ ។

ឈ្មោះថា វិសភាគ គឺចំណែកមិនស្មើគ្នា ដោយការកំណត់លក្ខណៈរបស់ខ្លួន សច្ចៈ ២ ដំបូង ឈ្មោះថា ជាសភាគ ព្រោះជារបស់ជ្រាលជ្រៅដោយអត្ថថា ឈមចុះបានដោយក្រ ព្រោះជាលោកិយ និងព្រោះជាអារម្មណ៍របស់អាសវៈ ឈ្មោះថា វិសភាគ ព្រោះចែកជាផល និងហេតុ និងព្រោះជាធម៌ដែលគួរកំណត់ដឹង និងជាធម៌ដែលគួរលះ ។ សច្ចៈ ២ ខាងក្រោយក៏ជាសភាគ គឺមានចំណែកស្មើគ្នា ព្រោះឈមចុះបានដោយក្រ ព្រោះជាធម៌

ជ្រាលជ្រៅ និងព្រោះជាលោកុត្តរ និងព្រោះជាអនាសវៈ ។ មួយវិញទៀត សច្ចៈ ២ ខាងក្រោយជាវិសភាគ ព្រោះចែកជាវិស័យ ( ជាអារម្មណ៍ ) និងវិសយី ( ជាធម៌មានអារម្មណ៍ ) និងព្រោះជាសច្ឆិកាតព្វៈ គឺធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ និងភាវេតព្វៈ គឺធម៌ដែលគួរចម្រើន មួយវិញទៀត សច្ចៈ ទី ១ និងទី ៣ ឈ្មោះថា ជាសភាគ ព្រោះអាងដល់ផល ឈ្មោះថា ជាវិសភាគ ព្រោះជាសង្ខតៈ និងអសង្ខតៈ ។ មួយវិញទៀត សច្ចៈទី ២ និងទី ៤ ឈ្មោះថា ជាសភាគ ព្រោះអាងដល់ហេតុ ឈ្មោះថា ជាវិសភាគ ព្រោះជាអកុសល និងកុសលដោយចំណែកមួយ សច្ចៈទី ១ និងទី ៤ ឈ្មោះថា ជាសភាគនឹងគ្នា ព្រោះជាសង្ខតៈ ឈ្មោះថា ជាវិសភាគនឹងគ្នា ព្រោះជាលោកិយ និងលោកុត្តរ សច្ចៈទី ២ និងទី ៣ ជាសភាគនឹងគ្នា ព្រោះជានេវសេក្ខានាសេក្ខា និងឈ្មោះថា ជាវិសភាគ ព្រោះជាសារម្មណៈ និងអនារម្មណៈ ។

បណ្ឌិតគប្បីដឹងច្បាស់នូវភាព ដែលអរិយសច្ចទាំងឡាយ ជាសភាគ និងជាវិសភាគ ដោយប្រការ និងដោយន័យទាំងឡាយ យ៉ាងនេះ ដោយប្រការដូច្នេះ ។

# ទុក្ខសច្ចនិទ្ទេស

## អធិប្បាយ ជាតិ

[ ១៤៥ ] ឥឡូវនេះ ព្រះមានព្រះភាគដើម្បីទ្រង់ចែកសច្ចៈ ៤ មានទុក្ខជាដើម ដែលទ្រង់លើកឡើងសម្ដែងដោយសង្ខេប ទើបផ្ដើមនិទ្ទេសវារនេះថា **តត្ថ កតមំ ទុក្ខំ អរិយសច្ចំ ជាតិបិ ទុក្ខា** ដូច្នេះជាដើម ក្នុងនិទ្ទេសនៃទុក្ខអរិយសច្ចនេះ បណ្ឌិតគប្បីជ្រាបជាតិ គប្បីជ្រាបអត្ថនៃជាតិជាទុក្ខ គប្បីជ្រាបជរា គប្បីជ្រាបអត្ថនៃជរាជាទុក្ខ គប្បីជ្រាបមរណៈ គប្បីជ្រាបអត្ថនៃមរណៈជាទុក្ខ គប្បីជ្រាបសោក គប្បីជ្រាបអត្ថនៃសោកជាទុក្ខ គប្បីជ្រាបបរិទេវៈ គប្បីជ្រាបអត្ថនៃបរិទេវៈជាទុក្ខ គប្បីជ្រាបទុក្ខ គប្បីជ្រាបអត្ថនៃទុក្ខជាទុក្ខ គប្បីជ្រាបទោមនស្ស គប្បីជ្រាបអត្ថនៃទោមនស្សជាទុក្ខ គប្បីជ្រាបឧបាយាស គប្បីជ្រាបអត្ថនៃឧបាយាសជាទុក្ខ គប្បីជ្រាបអប្បិយសម្បយោគ គប្បីជ្រាបអត្ថអប្បិយសម្បយោគជាទុក្ខ គប្បីជ្រាបបិយវិប្បយោគ គប្បីជ្រាបអត្ថបិយវិប្បយោគជាទុក្ខ គប្បីជ្រាបឥច្ឆា គឺសេចក្ដីប្រាថ្នា គប្បីជ្រាបអត្ថនៃសេចក្ដីប្រាថ្នាជាទុក្ខ គប្បីជ្រាបខន្ធ គប្បីជ្រាបអត្ថនៃខន្ធជាទុក្ខ នេះជាមាតិកា ដើម្បីជាប្រយោជន៍ក្នុងការពោលទុក្ខអរិយសច្ច ក្នុងនិទ្ទេសវារនេះ ។

ពិតហើយ ឈ្មោះថា ទុក្ខ មានប្រការផ្សេងៗ ជាអនេក គឺទុក្ខទុក្ខ ទុក្ខព្រោះអត់ធន់បានដោយលំបាក ១ វិបរិណាមទុក្ខ ទុក្ខព្រោះប្រែប្រួល ១ សង្ខារទុក្ខ ទុក្ខព្រោះសង្ខារ ១ បដិច្ឆន្នទុក្ខ ទុក្ខព្រោះបិទបាំង ១ អប្បដិច្ឆន្ន-

ទុក្ខ ទុក្ខមិនបិទបាំង ១ បរិយាយទុក្ខ ទុក្ខដោយអម ១ និប្បរិយាយទុក្ខ ទុក្ខដោយត្រង់ ១ ។

បណ្តាទុក្ខទាំងនោះ ទុក្ខវេទនា ដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងចិត្ត ឈ្មោះថា **ទុក្ខទុក្ខ** ព្រោះជាទុក្ខទាំងដោយសភាវៈ និងដោយឈ្មោះ ។ សុខ-វេទនា ឈ្មោះថា **វិបរិណាមទុក្ខ** ព្រោះជាហេតុឲ្យកើតទុក្ខដោយការប្រែប្រួល ។ ឧបេក្ខាវេទនា និងសង្ខារទាំងឡាយដ៏សេស ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា **សង្ខារទុក្ខ** ព្រោះត្រូវការកើត និងការរលត់បៀតបៀន ។ ឯការបៀតបៀនដោយការកើត និងការរលត់ រមែងមានដល់មគ្គ និងផលទាំងឡាយដូចគ្នា ព្រោះហេតុនោះ គប្បីជ្រាបថា ធម៌ទាំងនោះ ឈ្មោះថា **សង្ខារ-ទុក្ខ** ដោយអត្ថថា ទាក់ទងក្នុងទុក្ខសច្ច ។ ជំងឺតម្កាត់ផ្លូវកាយ និងចិត្ត មានឈឺត្រចៀក ឈឺធ្មេញ ការក្តៅក្រហាយកើតអំពីរាគៈ ការក្តៅក្រហាយកើតអំពីទោសៈជាដើម ឈ្មោះថា **បដិច្ឆន្នទុក្ខ** ព្រោះត្រូវសាកសួរ ទើបដឹង និងព្រោះឈានទៅ ( កើតឡើង ) ហើយ ក៏មិនប្រាកដ លោកហៅថា **អបាកដទុក្ខ** ក៏មាន ។ ឯជំងឺមានការត្រូវនូវកម្មករណៈទាំង ៣២ ជាដើម ជាសមុដ្ឋាន ឈ្មោះថា **អប្បដិច្ឆន្នទុក្ខ** ព្រោះមិនសួរក៏ដឹងបាន និងព្រោះចូល គឺឈានដល់ហើយក៏ប្រាកដ លោកហៅថា **បាកដទុក្ខ** ( ទុក្ខប្រាកដ ) ក៏មាន ។ វៀរទុក្ខទុក្ខចេញ ទុក្ខទាំងអស់ មានជាតិជាដើម ដែលមកហើយក្នុងវិភង្គនៃទុក្ខសច្ច ឈ្មោះថា **បរិយាយទុក្ខ** ព្រោះជាវត្ថុ ( ទីអាស្រ័យកើត ) នៃទុក្ខនោះៗ ។ ទុក្ខទុក្ខ ឈ្មោះថា **និប្បរិយាយទុក្ខ** ។

បណ្ដាទុក្ខទាំងនោះ គប្បីពោលទុក្ខអរិយសច្ច សង្គ្រោះចូលក្នុងបទ ២ នេះ គឺបរិយាយទុក្ខ និងនិប្បរិយាយទុក្ខ ។ ធម្មតាអរិយសច្ចនេះ រមែងមកក្នុងព្រះបាលីដោយសង្ខេបខ្លះ ដោយពិស្ដារខ្លះ ។ ក្នុងទីដែលមកដោយសង្ខេប គួរពោលដោយសង្ខេបក៏បាន ដោយពិស្ដារក៏បាន តែក្នុងទីមកដោយពិស្ដារ សមគួរពោលដោយពិស្ដារប៉ុណ្ណោះ មិនគួរពោលដោយសង្ខេបឡើយ ក្នុងទីនេះ ទុក្ខនេះ មកដោយពិស្ដារ ហេតុនោះ គប្បីពោលដោយពិស្ដារតែម្យ៉ាង ព្រោះហេតុនោះ ពាក្យណាដែលខ្ញុំពោលថា គប្បីជ្រាបជាតិ គប្បីជ្រាបអត្ថនៃជាតិជាទុក្ខ ព្រោះកាន់យកព្រះបាលី ក្នុងនិទ្ទេសវារជាដើមថា **តត្ថ កតមំ ទុក្ខំ អរិយសច្ចំ ជាតិបិ ទុក្ខា** បណ្ដាអរិយសច្ច ៤ នោះ ទុក្ខអរិយសច្ច តើដូចម្ដេច ការកើតជាទុក្ខ ដូច្នេះ ។ បណ្ដាទុក្ខ-អរិយសច្ចនោះ គប្បីជ្រាបពាក្យថា **ជាតិ** ជាដើមមុន ។

[ ១៤៦ ] បណ្ឌិតគប្បីជ្រាបពាក្យថា ជាតិ ជាដើម ដោយអំណាចនៃបទភាជនីយថា **តត្ថ កតមា ជាតិ យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជាតិ** ដូច្នេះជាដើម ។

ការអធិប្បាយសេចក្ដីក្នុងបទភាជនីយនោះមានដូចតទៅ

បទថា **តេសំ តេសំ សត្តានំ** នេះ ជាអត្ថសម្ដែងដល់សេចក្ដីទូទៅដល់សត្វមិនមែនតិច ដោយសង្ខេប គឺកាលពោលពាក្យយ៉ាងនេះថា ការកើតរបស់ទេវទត្ត ការកើតរបស់សោមទត្ត សូម្បីអស់មួយថ្ងៃ ក៏ពោលដល់សត្វទាំងឡាយមិនអស់ ការសម្ដែងក្នុងសត្វដទៃទៀតទាំងអស់ក៏មិនសម្រេច តែ

ដោយបទ ២ នេះ សត្វពួកខ្លះក៏ជាការកំណត់កាន់យកបាន ការសម្តែងដល់សត្វដទៃទៀតយ៉ាងណាៗ នឹងសម្រេច ។ ប្រយោជន៍អ្វីដោយសត្វដទៃទៀតនោះ ព្រោះហេតុនោះ ទើបត្រាស់ថា **យា តេសំ តេសំ សត្តានំ** របស់សត្វទាំងឡាយនោះៗ ។ បទថា **តម្ហិ តម្ហិ** នេះ ជាអត្ថសម្តែងការទូទៅរបស់សត្តនិកាយមិនមែនតិច ដោយអំណាចនៃគតិ និងជាតិ ។ ពាក្យថា **សត្តនិកាយេ** បានដល់ ក្នុងពួកសត្វទាំងឡាយ អធិប្បាយថា ក្នុងក្រុមនៃសត្វ ក្នុងប្រជុំនៃសត្វ ។

**ជាតិ** សព្ទ ក្នុងពាក្យថា **ជាតិ** មានអត្ថច្រើនយ៉ាង ។ ពិតហើយ **ជាតិ** សព្ទនេះ មកក្នុងអត្ថថា ភព ដូចក្នុងប្រយោគជាដើមថា **ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ** គឺរឭកបាន ១ ជាតិ ២ ជាតិ ដូច្នេះ ។ មកក្នុងអត្ថថា និកាយ ដូចក្នុងប្រយោគជាដើមថា **អត្ថិ វិសាខេ និគ្គណ្ឋា នាម សមណជាតិ** ម្នាលនាងវិសាខា មានពួកសមណៈ ហៅថា និគ្គណ្ឋៈ សមណៈអម្បាលនោះ ដូច្នេះ ។ មកក្នុងបញ្ញត្តិ ដូចក្នុងប្រយោគនេះជាដើមថា **តិរិយា នាម តិណជាតិ នាភិយា ឧគ្គន្ត្វា នភំ អហច្ច ឋិតា អហោសិ** មានស្មៅចិញ្ចៀន ១ សរសៃ ដុះលេចអំពីផ្ចិតទៅទល់នឹងអាកាស ដូច្នេះ ។ មកក្នុងអត្ថថា សង្ខតលក្ខណៈ ដូចក្នុងប្រយោគជាដើមថា **ជាតិ ទ្វីហិ ខន្ធេហិ សង្គហិតា** ជាតិសង្គ្រោះដោយខន្ធ ២ ដូច្នេះ ។ មកក្នុងអត្ថថា បដិសន្ធិ ដូចក្នុងប្រយោគជាដើមថា **យំ ភិក្ខវេ មាតុ កុច្ឆិស្មឹ បឋមំ ចិត្តំ ឧប្បន្នំ បឋមំ វិញ្ញាណំ បាតុភូតំ តទុបាទាយ សាវស្ស ជាតិ** ម្នាលភិក្ខុទាំង

ឡាយ បឋមចិត្តណា ដែលកើតឡើងហើយ បឋមវិញ្ញាណណា ដែលកើតឡើងប្រាកដហើយក្នុងផ្ទៃនៃមាតា បដិសន្ធិនោះឯង អាស្រ័យចិត្តដែលកើតឡើង និងវិញ្ញាណនោះ ដូច្នេះ ។ មកក្នុងអត្ថថា ប្រសូត ដូចក្នុងប្រយោគជាដើមថា **សម្បតិជាតោ អានន្ទ ពោធិសត្តោ** ម្នាលអានន្ទ កាលដែលពោធិសត្វចេញចាកផ្ទៃមាតា ក៏ចេញមកស្អាតវិសេស ដូច្នេះ ។ មកក្នុងអត្ថថា ត្រកូល ដូចក្នុងប្រយោគជាដើមថា **អក្ខុបក្កុដ្ឋោ ជាតិវាទេន** មិនដែលមាននរណាម្នាក់ពោលតិះដៀល ដោយពោលដល់ជាតិកំណើតបាន ដូច្នេះ ។ មកក្នុងអត្ថថា អរិយសីល ក្នុងប្រយោគនេះថា **យតោហំ ភគិនិ អរិយាយ ជាតិយា ជាតោ** នៃនាង តាំងអំពីអាត្មាកើតហើយក្នុងអរិយជាតិ ដូច្នេះ ។

តែ **ជាតិ** សព្ទ ក្នុងអធិការនេះ រមែងគួរក្នុងខន្ធដែលកើតដំបូង មួយអន្លើដោយវិការ ព្រោះហេតុនោះ ទើបពាក្យថា **ជាតិ** នេះ ក្នុងអាការនេះ ជាពាក្យប្រាប់សភាវៈចំពោះ សេចក្ដីថា ការកើតរបស់សត្វដែលកំពុងកើត ។ បទថា **សញ្ជាតិ** មានពាក្យឧបសគ្គបន្ថែមចូលមក ដោយអំណាចនៃការកើតព្រម ។ ឈ្មោះថា **ឱក្កន្តិ** ដោយអំណាចការឈមចុះ ។ ម្យ៉ាងទៀតឈ្មោះថា **ជាតិ** ដោយអត្ថថា ការកើត ។ ជាតិនោះ ប្រកបដោយអំណាចនៃសត្វដែលមានអាយតនៈខ្វះខាត ។ ឈ្មោះថា **សញ្ជាតិ** ដោយអត្ថថា កើតដោយល្អ ។ សញ្ជាតិនោះ ប្រកបដោយអំណាចនៃសត្វដែលមានអាយតនៈបរិបូណ៌ ។ ឈ្មោះថា **ឱក្កន្តិ** ដោយអត្ថថា ឈមចុះ ។ **ឱក្កន្តិ** នោះ ប្រកបដោយអំណាចសត្វដែលកើតក្នុងស៊ុត និងកើតក្នុងផ្ទៃ

ព្រោះសត្វទាំងនោះ រមែងឈមចុះក្នុងស៊ុត និងស្បូន កាលឈមចុះ រមែងបដិសន្ធិ ដូចសត្វទាំងឡាយ ដែលចូលទៅនៅ ។ ឈ្មោះថា **អភិនិព្វត្តិ** ដោយអត្ថថា កើតចំពោះ ការកើតចំពោះនោះ ប្រកបដោយអំណាចនៃសត្វដែលកើតក្នុងញើសក្អែល និងជាឱបបាតិកសត្វ ព្រោះសត្វទាំងនោះ រមែងកើតប្រាកដមួយរំពេច ។ នេះជាសម្មុតិកថា មានប្រមាណប៉ុណ្ណេះ ។

ឥឡូវនេះ ជាកថាពោលដោយបរមត្ថ ពិតហើយ ដោយបរមត្ថ ខន្ធទាំងឡាយនោះឯង រមែងប្រាកដ មិនមែនសត្វប្រាកដ ។

ក្នុងព្រះបាលីនោះ បទថា **ខន្ធានំ** គប្បីជ្រាបការកាន់យកខន្ធ ១ ក្នុងឯកវោការភព ខន្ធ ៤ ក្នុងចតុវោការភព ខន្ធ ៥ ក្នុងបញ្ចវោការភព ។ បទថា **ធាតុភាវោ** បានដល់ ការកើតឡើង ។ ក្នុងបទថា **អាយតនានំ** នេះ គប្បីជ្រាបការសង្គ្រោះដោយអំណាចនៃអាយតនៈដែលកើតឡើងក្នុងភពនោះៗ ។ បទថា **បដិលាភោ** ការប្រាកដក្នុងការបន្តនោះឯង ព្រោះអាយតនៈដែលប្រាជកនោះឯង ឈ្មោះថា បានចំពោះហើយ ។ បទថា **អយំ វុច្ចតិ ជាតិ** សេចក្តីថា នេះតថាគតហៅថា ជាតិ ។ ជាតិនោះ **តត្ថ តត្ថ ភវេ បឋមាភិនិព្វត្តិលក្ខណា** មានការកើតក្នុងគ្រាដំបូង ក្នុងភពនោះៗ ជាលក្ខណៈ **និយ្យាតនរសា** មានការប្រគល់ឲ្យជាកិច្ច **អតីតភវតោ ឥធ ឧម្មុជ្ជនបច្ចុបដ្ឋានា** មានការឃ្លាតអំពីភពអតីត មកផុសឡើងក្នុងភពនេះជាអាការប្រាកដ **ផលវសេន ទុក្ខវិចិត្តតាបច្ចុបដ្ឋានា វា** ឬមានភាពវិចិត្រគឺប្រមូលនូវទុក្ខដោយអំណាចផលជាហេតុជិត ។

ឥឡូវនេះ គប្បីជ្រាបពាក្យថា គប្បីជ្រាបអត្ថនៃជាតិជាទុក្ខដូច្នេះថា ពិតហើយ ជាតិនេះ ខ្លួនឯងមិនជាទុក្ខ តែត្រាស់ថា ជាទុក្ខ ព្រោះជាទីតាំងឲ្យទុក្ខកើត ។ សួរថា ជាតិនេះជាទីតាំងនៃទុក្ខប្រភេទណា ឆ្លើយថា ជាតិនេះ ជាទីតាំងនៃទុក្ខទាំងអស់នោះ គឺទុក្ខដែលប្រព្រឹត្តទៅក្នុងអបាយដែលព្រះមានព្រះភាគ ទ្រង់ប្រកាសដោយអំណាចឧបមា ក្នុងពាលបណ្ឌិតសូត្រជាដើម និងទុក្ខដែលកើតឡើងក្នុងសុគតិភូមិ មានទុក្ខ គឺការឈមចុះកាន់គភ៌ជាមូលជាដើមក្នុងមនុស្សលោក ។ ក្នុងអធិការនេះ គប្បីជ្រាបទុក្ខ មានទុក្ខព្រោះការឈានចុះកាន់គភ៌ជាមូលជាដើមដូចតទៅ

ពិតហើយ សត្វដែលកើតក្នុងឧទរមាតា មិនមែនកើតក្នុងទីទាំងឡាយមានផ្កាឧប្បល ផ្កាឈូកក្រហម និងផ្កាឈូក-សជាដើមឡើយ ដោយពិតរមែងកើតក្នុងបរិវេណពោះដែលគួរខ្ពើមរអើមក្រៃលែង ជាការកប់ក្នុងព្រៃធំ គឺវត្ថុមិនស្អាត មានក្លិនស្អុយក្រៃលែង អប់ដោយក្លិនសាកសពផ្សេងៗ ជាទីងងឹត ចង្អៀតក្រៃលែង ត្រង់កណ្ដាលផ្ទៃពោះ និងឆ្អឹងទ្រនុងខ្នង អង្គុយលើអាហារចាស់ ទូលអាហារថ្មី ដូចដង្កូវកើតក្នុងត្រីស្អុយ ក្នុងនំផ្អូម និងក្នុងទឹកជ្រាំជាដើម ។ សត្វនោះ កើតក្នុងផ្ទៃហើយ ត្រូវកម្ដៅដែលកើតក្នុងផ្ទៃមាតាអស់ ១០ ខែ ក្ដៅងំដូចកញ្ចប់បាយ ចំហុយដូចដុំម្សៅ មិនបានលាតអង្កុញដៃជើងជាដើម សោយទុក្ខមានប្រមាណក្រៃលែង ។

នេះជាទុក្ខ មានការឈានចុះកាន់គភ៌ជាមូល ។

ម្យ៉ាងទៀត សត្វនោះ រមែងសោយទុក្ខមានប្រមាណក្រៃលែង ដោយ

សេចក្តីព្យាយាមរបស់មាតា មានការប្រានទៅ អូសទៅ អន្ទយចុះ ងើបឡើងជាដើម ក្នុងឥរិយាបថទាំងឡាយ មានការលោត ការដើរ ការអន្ទយ ការក្រោក និងការបង្វិលខ្លួនជាដើម ដោយរហ័ស ហាក់បីដូចកូនពពែ នៅក្នុងកណ្តាប់ដៃរបស់អ្នកលេងសុរា និងដូចកូនពស់ នៅក្នុងកណ្តាប់ដៃអាលម្ពាយ ។ ម្យ៉ាងទៀត សត្វនោះ រមែងសោយទុក្ខវេទនាខ្លាំងក្លាឯណា គឺក្នុងពេលមាតាផឹកទឹកត្រជាក់ ក៏ហាក់បីដូចនៅក្នុងសីតនរក ក្នុងគ្រាដែលមាតាលេបបបរក្តៅ និងកត្តក្តៅជាដើម ក៏ដូចរងើកភ្លើងនៅជុំវិញ ក្នុងកាលដែលមាតាលេបរបស់ប្រៃ និងរបស់ជូរជាដើម ដូចសត្វដែលត្រូវនូវកម្មករណ៍ មានការធូតសាច់ប្រឡាក់ដោយទឹកក្បុងជាដើម ។

នេះជាទុក្ខ មានការបរិហារគព្ភ៌ជាមូល ។

ម្យ៉ាងទៀត កាលមាតារបស់សត្វនោះវង្វេងគព្ភ៌ ទុក្ខណារមែងកើតឡើងដោយអាការ មានការវះកាត់ជាដើម ក្នុងទីជាទីកើតនៃទុក្ខដែលមិនគួរឃើញសូម្បីតែមិត្តអមាត្យ និងសម្លាញ់ជាដើម ។

នេះជាទុក្ខ មានវិបត្តិនៃគព្ភ៌ជាមូល ។

កាលមាតាកំពុងប្រសូត ទុក្ខណា កើតឡើងដល់សត្វ ដែលត្រូវខ្យល់កម្មជវាត បក់ត្រឡប់ឲ្យក្បាលចុះទៅកាន់ទ្វារកំណើត ដែលគួរខ្លាចក្រៃលែងដូចមាត់ជ្រោះ ហើយខ្យល់នោះបក់ផាត់ បញ្ចេញមកតាមទ្វារកំណើតដែលចង្អៀតក្រៃលែង ដូចដំរីធំត្រូវគេរុញច្រាន បន្តិ៍ឲ្យចេញតាមរន្ធរនុកទ្វារ និងដូចសត្វនរកត្រូវគេបុកឲ្យបែកជាលម្អិតតូចធំ ។

ទុក្ខនេះ ឈ្មោះថា មានការប្រសូតិជាមូល ។

ម្យ៉ាងទៀត ទុក្ខណាកើតដល់សត្វដែលប្រសូតហើយ ដែលមានសរីរៈនៅខ្ចី ដូចគ្នានឹងផ្លែឈើទុំ ក្នុងកាលដែលគេយកដៃចាប់ឲ្យងូតទឹកជម្រះ និងជូតដោយសំពត់ជាដើម ក៏ដូចគ្នានឹងការចាក់ដោយម្ជុល និងវះដោយកាំបិតកោរ ។

នេះជាទុក្ខ មានការចេញចាកគភ៌មាតាជាមូល ។

ខាងមុខអំពីនេះទៅ ក្នុងបវត្តិកាល ទុក្ខណាមានដល់បុគ្គលដែលសម្លាប់ខ្លួនឯងក្តី ដែលប្រកបសេចក្តីព្យាយាមដោយការធ្វើខ្លួនឲ្យក្តៅ ឲ្យក្តៅទូទៅដោយអំណាចនៃវត្ត មានអាចេលកវត្តជាដើមក្តី អ្នកបង្អត់អាហារ និងបុគ្គលដែលព្យួរខ្លួន ដោយអំណាចសេចក្តីក្រោធក្តី ។

ទុក្ខនេះ ជាទុក្ខមានការព្យាយាមរបស់ខ្លួនជាមូល ។

ម្យ៉ាងទៀត ទុក្ខណា កើតដល់បុគ្គលសោយទុក្ខ មានត្រូវសម្លាប់ និងចងជាដើម អំពីអ្នកដទៃ ទុក្ខនេះ ជាទុក្ខ មានការព្យាយាមរបស់អ្នកដទៃជាមូល ។

ជាតិជាវត្ថុ ជាទីតាំងនៃទុក្ខទាំងអស់ ដោយប្រការដូច្នេះ ព្រោះហេតុនោះទើបលោកពោលគាថានេះថា

> បើសត្វ មិនគប្បីកើតក្នុងនរកសោត សត្វនោះ តាំងនៅក្នុងទីណា ក៏មិនបានទុក្ខ មានការត្រូវដុតក្នុងនរកនោះជាដើម ដែលបុគ្គលណាម្នាក់អត់ធន់មិនបាន ព្រោះហេតុនោះ ទើបព្រះមុនី

ពោលថា ការកើតក្នុងនរក នេះជាទុក្ខ ។
សេចក្តីទុក្ខ ក្នុងពួកសត្វតិរច្ឆាន មានការត្រូវវាយដោយ ត្បោង ជន្លួញ ដំបងជាដើម មិនមែនតិច វៀរជាតិហើយ ទុក្ខនឹងមានក្នុងទីនោះបានដូចម្តេច ព្រោះហេតុនោះ ទើបការកើតក្នុងពួកសត្វតិរច្ឆាននោះ ឈ្មោះថា ជាទុក្ខ ។
ម្យ៉ាងទៀត ទុក្ខផ្សេងៗ ក្នុងពួកប្រេត ដែលមានការស្រេកឃ្លាន ខ្យល់ និងកម្តៅថ្ងៃជាដែនកើត រមែងមិនមានដល់សត្វដែលមិនកើតក្នុងពួកប្រេតនោះ ព្រោះហេតុនោះ ទើបអ្នកប្រាជ្ញពោលថា ការកើត ជាទុក្ខ ។
ម្យ៉ាងទៀត ព្រោះការកើតមិនមាន ទុក្ខក្នុងពួកអសុរដែលមានក្នុងលោកន្តរដែលអត់ធន់មិនបាន ផងឹតឈ្លប ក៏មិនគប្បីមាន ក្នុងពួកអសុរនោះ ព្រោះហេតុនោះ ទើបការកើតនេះឈ្មោះថា ជាទុក្ខ ។
ម្យ៉ាងទៀត សត្វក្នុងផ្ទៃមាតា ហាក់បីដូចគូថនរក ដោយការនៅខាងក្នុងអស់កាលយូរក្តី ចេញចាកផ្ទៃមកខាងក្រៅក្តី រមែងដល់នូវសេចក្តីទុក្ខដ៏ខ្លាំងក្លា ទុក្ខនេះ វៀរចាកការកើតរមែងមិនមាន ព្រោះហេតុនោះ ការកើតនោះឯង ឈ្មោះថា ជាទុក្ខ ។
ប្រយោជន៍អ្វីដោយការពោលច្រើន ទុក្ខណាមួយ ក្នុងលោក

នេះ ដែលមានក្នុងទីណាមួយ មិនមានក្នុងកាលណាមួយ ព្រោះវៀរចាកការកើតមិនមាន មិនមែនឬ ព្រោះហេតុនោះ ទើបព្រះមហេសី ត្រាស់ការកើត ថាជាទុក្ខ មុនទុក្ខទាំងពួង ដូច្នេះ ។

[ ១៤៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងជរានិទ្ទេសដូចតទៅ

បទថា **ជរា** ជាពាក្យប្រាប់សភាវៈដោយចំពោះ ។ បទថា **ជីរណតា** ជាសព្ទសម្ដែងដល់អាការ ។ សព្ទទាំង ៣ មានពាក្យថា **ខណ្ឌិច្ចំ** ជាដើម ជាសព្ទសម្ដែងដល់កិច្ចក្នុងកាលកន្លងទៅ ២ សព្ទខាងក្រោយ ជាការអធិប្បាយតាមប្រក្រតី ។

ពិតហើយ ជរានេះ ព្រះមានព្រះភាគ ទ្រង់សម្ដែងដោយភាវៈ ដោយបទថា **ជីរណតា** នេះ ព្រោះហេតុនោះ ទើបបទថា **ជីរណតា** នេះ ជាពាក្យប្រាប់សភាវៈចំពោះ **ជីរណតា** នោះ ។ ទ្រង់សម្ដែងជរានោះដោយអាការ ដោយបទថា **ជីរណតា** នេះ ព្រោះហេតុនោះ ទើបសព្ទថា **ជីរណតា** នេះ ជាការអធិប្បាយដល់អាការរបស់ជរានោះ ។

ដោយបទថា **ខណ្ឌិច្ចំ** នេះ ព្រះមានព្រះភាគទ្រង់សម្ដែងជរាដោយកិច្ច គឺការធ្វើនូវភាពជាបុគ្គលមានធ្មេញបាក់ និងក្រចកបាក់ក្នុងកាលកន្លងទៅ ។ ដោយបទថា **បាលិច្ចំ** ទ្រង់សម្ដែងជរាដោយកិច្ច គឺការធ្វើនូវភាពជាបុគ្គលមានសក់ និងរោមស្កូវ ។ ដោយបទថា **វលិត្តចតា** ទ្រង់សម្ដែងជរាដោយកិច្ច គឺការធ្វើភាពជាបុគ្គលមានសាច់ក្រៀមស្វិតហើយ យារហើយ ។

ព្រោះហេតុនោះ សព្ទទាំង ៣ មាន **ខណ្ឌិច្ចំ** ជាដើម ជាសព្ទសម្តែងកិច្ចក្នុងកាលដែលកន្លងទៅនៃជរានោះ ៗ ដោយសព្ទទាំង ៣ នោះ ទ្រង់សម្តែងបាកដជរាថា ជរានោះ ជាធម្មជាតិប្រាកដហើយ ដោយអំណាចនៃការសម្តែងវិការទាំងនេះ ប្រៀបដូចផ្លូវរបស់ទឹក ផ្លូវខ្យល់ ផ្លូវភ្លើង រមែងប្រាកដព្រោះភាពដែលស្មៅ និងដើមឈើជាដើម បាក់គល់រលំហើយ ឬត្រូវភ្លើងឆេះ តែផ្លូវដែលប្រព្រឹត្តទៅហើយនោះ មិនមែនទឹកជាដើមនោះ ដោយត្រង់សេចក្តីនេះ យ៉ាងណា ផ្លូវរបស់ជរាក៏យ៉ាងនោះដូចគ្នា រមែងប្រាកដក្នុងទីដែលមានធ្មេញបាក់ជាដើម ដោយអំណាចលក្ខណៈ មានភាវៈដែលបាក់ជាដើម បុគ្គលណាម្នាក់សូម្បីបើកភ្នែកមើលក៏ដឹងបាន តែលក្ខណៈ មានភាវៈដែលធ្មេញបាក់ជាដើមប៉ុណ្ណោះ មិនមែនជរា ព្រោះជរា មិនមែនវត្ថុដែលគប្បីដឹងបានដោយភ្នែក ៗ

ម្យ៉ាងទៀត ដោយបទថា **អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ** នេះ ទ្រង់សម្តែងជរានោះ ដោយប្រក្រតី ពោល គឺការអស់អាយុ និងការចាស់នៃឥន្ទ្រិយ មានចក្ខុជាដើម ដែលប្រាកដចំពោះក្នុងកាលកន្លងកាលទៅប៉ុណ្ណោះ ព្រោះហេតុនោះ ២ សព្ទ ខាងក្រោយនេះ គប្បីជ្រាបថា ជាសព្ទអធិប្បាយសេចក្តីតាមប្រក្រតី របស់ជរានោះ ៗ បណ្តាបទទាំង ២ នោះ ព្រោះអាយុរបស់បុគ្គលដែលដល់ជរាហើយ រមែងវិនាស ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ជរាដោយផលូបចារន័យ ( ពោលដល់ហេតុតែចង្អុលដល់ផល ) ថា ការអស់ទៅនៃអាយុ ៗ ម្យ៉ាងទៀត ព្រោះឥន្ទ្រិយ មាន

ចក្ខុជាដើម ក្នុងវេលាដែលនៅក្មេង ជារបស់ផូរផង់ល្អ អាចទទួលវិស័យរបស់ខ្លួន សូម្បីតូចល្អិតបានដោយងាយនោះឯង កាលចូលដល់ជរាហើយ ជាឥន្ទ្រិយឆ្អិនហើយ ច្របូកច្របល់ មិនភ្លៀវក្លា មិនអាចទទួលវិស័យរបស់ខ្លួន សូម្បីគ្រោតគ្រាតបាន ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា **ឥន្ទ្រិយានំ បរិបាកោ** ដោយផលូបចារន័យនោះឯង ។

ម្យ៉ាងទៀត ជរាទាំងអស់ដែលទ្រង់លើកឡើងសម្តែងយ៉ាងនេះ មាន ២ យ៉ាង គឺបាកដជរា ១ បដិច្ឆន្នជរា ១ ។ បណ្តាជរាទាំង ២ នោះ ជរាក្នុងរូបធម៌ ឈ្មោះថា **បាកដជរា** ព្រោះសម្តែងភាវៈមានការបាក់ជាដើម ក្នុងអវយវៈ មានធ្មេញជាដើម ឯជរាក្នុងអរូបធម៌ ឈ្មោះថា **បដិច្ឆន្នជរា** ព្រោះមិនបង្ហាញវិការណាមួយបែបនោះ ។

ក្នុងជរាទាំង ២ នោះ ភាវៈមានធ្មេញបាក់ជាដើម ដែលប្រាកដនេះ ជាវណ្ណៈ ( ពណ៌ ) នោះឯង ព្រោះថា អវយវៈ មានធ្មេញបាក់ជាដើមបែបនោះ ជាវត្ថុដែលគួរដឹងបានងាយ បុគ្គលឃើញពណ៌នោះហើយដោយចក្ខុ ក៏គិតដោយមនោទ្វារ រមែងដឹងជរាថា ខន្ធទាំងនេះ ត្រូវជរាទម្លាយហើយ ដូចការមើលវត្ថុទាំងឡាយ មានស្មៅគោជាដើម ដែលគេចងក្នុងទីមានទឹក ក៏ដឹងបានថា ខាងក្រោមមានទឹក ដូច្នេះ ។

ជរាមាន ២ យ៉ាងទៀត គឺអវីចិជរា ១ សវីចិជរា ១ ។

បណ្តាជរាទាំង ២ នោះ ជរារបស់កែវមណី មាស ប្រាក់ កែវប្រពាល ព្រះចន្ទ និងព្រះអាទិត្យជាដើម ឈ្មោះថា **អវីចិជរា** គឺជរាមិនមានស្លាកស្នាម

ព្រោះភាពវិសេសនៃពណ៌ជាដើម ក្នុងចន្លោះៗ ជារបស់ដែលដឹងបានដោយក្រ ដូចការប្លែកនៃពណ៌ជាដើម របស់សត្វមានជីវិត ក្នុងពួកមនុស្សកៈជាដើម និងវត្ថុមិនមានជីវិត ក្នុងពួកដែលជាផ្កា ផ្លែឈើ និងស្លឹកឈើជាដើម ។ មានអធិប្បាយថា ជានិរន្តរជរា គឺជរាមិនមានចន្លោះ ។ តែជរាក្នុងវត្ថុដទៃៗ ក្រៅអំពីវត្ថុ មានកែវមណីជាដើម តាមដែលពោលមកហើយនោះ ឈ្មោះថា **សវីចិជរា** ព្រោះការប្លែកនៃពណ៌ជាដើម ក្នុងចន្លោះៗ ជារបស់ដែលដឹងបានងាយ ។

ក្នុងជរាទាំង ២ នោះ **សវីចិជរា** គប្បីជ្រាបយ៉ាងនេះ ដោយអំណាចនៃឧបាទិន្នករូប និងអនុបាទិន្នករូប ។ ពិតហើយ ឈ្មោះថា ធ្មេញទឹកដោះ ( ធ្មេញព្រៃ ) របស់កុមារតូចៗ រមែងកើតមុននោះឯង ធ្មេញនោះ មិនជាវរៈ តែកាលធ្មេញទាំងនោះបាក់ទៅហើយ ធ្មេញក៏នឹងដុះឡើងទៀត ធ្មេញដែលដុះក្រោយនោះ មានពណ៌សរមែងក្លាយជាពណ៌ខ្មៅក្នុងកាលត្រូវខ្យល់ គឺជរាប៉ះខ្ទប់ ។ មួយវិញទៀត សក់ដំបូង រមែងពណ៌ក្រហមខ្លះ ពណ៌ខ្មៅខ្លះ ពណ៌សខ្លះ ឯស្បែក រមែងមានពណ៌ក្រហម កាលបុគ្គលកំពុងចម្រើនជំពាត់ បុគ្គល-សក៏ប្រាកដជាពណ៌ស បុគ្គលខ្មៅក៏ប្រាកដជាពណ៌ខ្មៅ តែកាលត្រូវខ្យល់ គឺជរាប៉ះខ្ទប់ហើយ ស្បែកនោះ ក៏នឹងយុរយារ ។ សន្ទូងទាំងអស់ក្នុងពេលដែលសាបព្រោះហើយ រមែងដុះដាលជាពណ៌ស ក្រោយមក ជាពណ៌ខៀវ តែពេលត្រូវខ្យល់ គឺជរាប៉ះខ្ទប់ហើយ ក៏ជាពណ៌លឿង សេចក្ដីនេះ បើសម្ដែងដោយពន្លកនៃស្វាយ ក៏គួរដូចគ្នា ។ ពាក្យថា **អយំ វុច្ចតិ ជរា**

សេចក្តីថា នេះគឺជាគតឲ្យឈ្មោះថា **ជរា** ។

ក្នុងជរានេះ **ខន្ធបរិបាកលក្ខណា** មានការចាស់របស់ខន្ធជាលក្ខណៈ **មរណូបនយនរសា** មានការនាំចូលទៅរកសេចក្តីស្លាប់ជាកិច្ច **យោព្វន-វិនាសបច្ចុប្បដ្ឋានា** មានការវិនាសនៃវ័យក្មេងជាអាការប្រាកដ ។

គប្បីជ្រាបជរាដោយអត្ថថា ជាទុក្ខដូចតទៅ

ជរានេះ ខ្លួនឯងមិនជាទុក្ខ តែព្រះមានព្រះភាគត្រាស់ថា ជាទុក្ខ ព្រោះជាទីតាំងរបស់ទុក្ខ ។

សួរថា ជាទីតាំងនៃទុក្ខមួយណា ឆ្លើយថា របស់ទុក្ខផ្លូវកាយ និងទុក្ខ គឺទោមនស្ស ពិតហើយ អត្តភាពនៃមនុស្សជរាហើយ រមែងទុព្វល ដូចរទេះចាស់ កាលបុគ្គលនោះព្យាយាមដើម្បីឈរ ដើរ ឬអង្គុយ រមែងកើតទុក្ខផ្លូវកាយដ៏ខ្លាំងក្លា ។ កាលបុត្ត និងភរិយា មិនសូវយកចិត្តទុកដាក់ដូចក្នុងកាលមុន ក៏កើតទោមនស្ស ។ គប្បីជ្រាបជរាជាទុក្ខដោយភាពជាទីតាំងនៃទុក្ខទាំង ២ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត លោកបានចងគាថាដូច្នេះថា

សត្វរមែងដល់នូវទុក្ខណា ទាំងផ្លូវកាយ និងផ្លូវចិត្ត ព្រោះភាពដែលអវយវៈជ្រីវជ្រួញ ព្រោះវិការនៃឥន្ទ្រិយ ព្រោះការវិនាសទៅនូវវ័យក្មេង ព្រោះកម្លាំងត្រូវថមថយ ព្រោះប្រាសចាកគុណ មានសតិជាដើម ព្រោះបុត្តភរិយារបស់ខ្លួន ក៏មិនជ្រះថ្លា និងព្រោះដល់ភាពជាបុគ្គលថមថយកម្លាំងក្រៃលែង ទុក្ខទាំងអស់នេះ មានជរាជាហេតុ ព្រោះហេតុនោះ ទើបជរាជាទុក្ខ ។

[ ១៤៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមរណនិទ្ទេសដូចតទៅ

ឈ្មោះថា **ចុតិ** ដោយអំណាចនៃសត្វដែលឃ្លាតចាកភព ពាក្យថា **ចុតិ** នេះ ជាពាក្យទូទៅសម្រាប់ការឃ្លាតនៃខន្ធ ១ ខន្ធ ៤ និងខន្ធ ៥ ។ បទថា **ចវនតា** ជាពាក្យសម្តែងលម្អិតលក្ខណៈ ដោយពោលដល់ភាវៈ ។ បទថា **ភេទោ** ជាពាក្យអធិប្បាយការកើតឡើងនៃកង្គះរបស់ខន្ធដែលចុតិ ។ បទថា **អន្តរធានំ** ជាពាក្យអធិប្បាយនូវការមិនមានទីតាំង ដោយបរិយាយណាមួយនៃចុតិក្ខន្ធដែលបែកធ្លាយ ដូចក្អមដែលបែកទៅ ដូច្នោះ ។ បទថា **មច្ចុ-មរណំ** បានដល់ សេចក្តីស្លាប់ គឺមច្ចុ ។ មច្ចុដែលធ្វើនូវទីបំផុត ឈ្មោះថា **កាល** ការធ្វើរបស់កាលៈនោះ ឈ្មោះថា **កាលកិរិយា** ។ មរណៈដោយសន្មត ជាពាក្យដែលខ្ញុំសម្តែងហើយ មានប្រមាណប៉ុណ្ណេះ ។

ឥឡូវនេះ ដើម្បីកំណត់មរណៈដោយបរមត្ថ ទើបព្រះមានព្រះភាគត្រាស់ថា **ខន្ធានំ ភេទោ** ជាដើម ។ ពិតហើយ ពោលដោយបរមត្ថ ខន្ធទាំងឡាយប៉ុណ្ណោះ រមែងបែកទៅ ឈ្មោះថា សត្វណាម្នាក់ស្លាប់ មិនមាន តែកាលខន្ធទាំងឡាយកំពុងបែក សត្វ ក៏រមែងមានវោហារ កំពុងស្លាប់ កាលខន្ធបែកហើយ ក៏មានវោហារថា សត្វស្លាប់ហើយ ។ ក្នុងអធិការនេះ ការបែកធ្លាយនៃខន្ធទាំងឡាយ គប្បីជ្រាបដោយអំណាចចតុវោការភព និងបញ្ច-វោការភព ការដាក់ចុះនូវកឡេវរៈ គឺសាកសពដោយអំណាចឯកវោការភពម្យ៉ាងទៀត ការបែកធ្លាយនៃខន្ធទាំងឡាយ គប្បីជ្រាបដោយអំណាចចតុ-វោការភព ការដាក់ចុះនូវសាកសព គប្បីជ្រាបដោយអំណាចភពទាំង ២

ដ៏សេស ព្រោះហេតុអ្វី ព្រោះមានសាកសព ពោល គឺរូបកាយក្នុងភពទាំង ២ ។ ម្យ៉ាងទៀត ព្រោះខន្ធទាំងឡាយ ក្នុងចាតុម្មហារាជិកាជាដើម រមែងបែកធ្លាយទៅមួយរំពេច មិនមានអ្វីត្រូវបោល ដូច្នោះ ការបែកធ្លាយនៃខន្ធទាំងឡាយ គប្បីជ្រាបដោយអំណាចនៃខន្ធ ក្នុងចាតុម្មហារាជិកាជាដើមនោះ ការដាក់ចុះនូវសាកសព គប្បីជ្រាបក្នុងពួកមនុស្សជាដើម ក្នុងនិទ្ទេសនេះ ព្រះមានព្រះភាគ ត្រាស់ការស្លាប់ ដោយហេតុនៃការដាក់ចុះនូវរាងកាយថា ការដាក់ចុះនូវសាកសព ដូច្នេះ ។

ដោយបទថា **ជីវិតិន្ទ្រិយស្ស ឧបច្ឆេទោ** នេះ ព្រះមានព្រះភាគ ទ្រង់សម្តែងថា ឈ្មោះថា ការស្លាប់ រមែងមានដល់ខន្ធដែលទាក់ទងដោយឥន្ទ្រិយប៉ុណ្ណោះ ឈ្មោះថា ការស្លាប់ រមែងមិនមានដល់ខន្ធដែលមិនទាក់ទងដោយឥន្ទ្រិយ ។ ពាក្យថា សន្ទូងងាប់ ដើមឈើងាប់ នេះត្រឹមតែជាវោហារប៉ុណ្ណោះ តែបើពោលដោយអត្ថហើយ វាចាបែបនេះ រមែងសម្តែងដល់ភាពដែលវត្ថុសព្វយ៉ាង មានសន្ទូងជាដើមជារបស់អស់ទៅ សូន្យទៅនោះឯង ។ បទថា **ឥទំ វុច្ចតិ មរណំ** សេចក្តីថា ទាំងអស់នេះ តថាគតក៏ឲ្យឈ្មោះថា **មរណៈ** ។

ម្យ៉ាងទៀត ក្នុងពាក្យថា **មរណ** នេះ គប្បីជ្រាបប្រភេទនេះ គឺខណិកមរណៈ គឺការស្លាប់ដោយខណៈ ១ សម្មុតិមរណៈ គឺការស្លាប់ដោយសន្មត ១ សមុច្ឆេទមរណៈ គឺការស្លាប់ដោយដាច់ខាត ១ ។

បណ្តាមរណៈទាំងនោះ ការបែកធ្លាយនៃរូបធម៌ និងអរូបធម៌ ក្នុង

បវត្តិកាល ឈ្មោះថា **ខណិកមរណ** ការស្លាប់នេះថា តិស្សៈស្លាប់ បុស្សៈស្លាប់ជាដើម ឈ្មោះថា **សម្មុតិមរណ** ។ ការធ្វើកាលកិរិយាដែលមិនមានបដិសន្ធិរបស់ព្រះខីណាស្រព ឈ្មោះថា **សមុច្ឆេទមរណ** ។ តែក្នុងនិទ្ទេសនេះ ព្រះមានព្រះភាគទ្រង់សំដៅយកសម្មុតិលក្ខណៈ ។ ពាក្យថា ការស្លាប់ព្រោះការកើតជាបច្ច័យ ការស្លាប់ដោយសេចក្ដីព្យាយាម ការស្លាប់ដោយសភាវៈ ការស្លាប់ព្រោះអស់អាយុ ដូច្នេះ ជាឈ្មោះនៃការស្លាប់ដោយសម្មុតនោះឯង ។

ការស្លាប់ដោយសម្មុតនេះ **ចុតិលក្ខណំ** មានការឃ្លាតចាកភពជាលក្ខណៈ **វិយោគរសំ** មានការព្រាសទៅជាកិច្ច **វិប្បវាសបច្ចុប្បដ្ឋានំ** មានការមិននៅក្នុងភពចាស់ជាអាការប្រាកដ ។

ម្យ៉ាងទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនេះថា គប្បីជ្រាបអត្ថនៃមរណៈជាទុក្ខដូចតទៅ

មរណៈនេះ ខ្លួនឯងក៏មិនជាទុក្ខ តែព្រះអង្គត្រាស់ថា ឈ្មោះថា ជាទុក្ខព្រោះជាទីតាំងនៃទុក្ខ ព្រោះវេទនាដែលមានក្នុងសរីរៈ សូម្បីមានការស្លាប់ទីបំផុត រមែងដុតសរីរៈ ដូចគប់ស្មៅឆេះដោយភ្លើងដែលគេកាន់ប្រាសខ្យល់ក្នុងពេលដែលនិមិត្តនៃនរកជាដើមប្រាកដ ទោមនស្សដ៏ខ្លាំងក្លា រមែងកើតឡើង ។ គប្បីជ្រាបមរណៈថា ជាទុក្ខ ដោយជាទីតាំងនៃទុក្ខទាំង ២ នេះដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត លោកចងគាថាដូច្នេះថា

ព្រោះការស្លាប់នេះ ជាទីតាំងនៃទុក្ខផ្លូវចិត្ត សម្រាប់បុគ្គលជិតស្លាប់ ដែលជាបុគ្គលលាមក ឃើញនិមិត្ត មានកម្មដ៏លាមកជាដើម សម្រាប់បុគ្គលល្អ មិនអាចសង្កត់នូវភាពប្រាសព្រាត់ដែលមានវត្ថុជាទីស្រឡាញ់ ជាអារម្មណ៍បាន សូម្បីទុក្ខដែលកើតក្នុងសរីរៈ មានរោគខ្យល់ដែលកាត់ទី-ត និងសរសៃជាដើមដែលគ្របសង្កត់មិនបាន ព្យាបាលមិនបាន ដែលមានដល់ពួកសត្វទាំងពួង ដែលកំពុងត្រូវរោគចាក់ដោតជាធម្មតា ដោយមិនប្លែកគ្នានេះ ហេតុនោះ ទើបមរណៈនេះ ព្រះមានព្រះភាគត្រាស់ថា ជាទុក្ខដោយពិត ដូច្នេះ ។

ម្យ៉ាងទៀត ឈ្មោះថា ជាតិ ជរា និងមរណៈនេះ រមែងត្រាច់ស្វែងរកឱកាស ដូចបច្ចាមិត្តជាអ្នកសម្លាប់សត្វទាំងនេះ គឺប្រៀបដូចសត្រូវ ៣ នាក់របស់បុរសដែលឃ្លាំចាំមើលឱកាស បុរសម្នាក់ពោលថា អញនឹងពោលសរសើរព្រៃនោះ ហើយនឹងនាំបុរសនោះចូលទៅក្នុងព្រៃនោះ ក្នុងរឿងនេះមិនមានអ្វីធ្វើបានលំបាកសម្រាប់អញឡើយ បុរសទី ២ ពោលថា ក្នុងពេលដែលបុរសនេះទៅ អញនឹងវាយដំ ធ្វើឲ្យទុព្វលភាព ក្នុងរឿងនេះ គ្មានអ្វីលំបាកសម្រាប់អញឡើយ បុរសទី ៣ ពោលថា បើឯងវាយបុរសនេះឲ្យខ្សោយកម្លាំងហើយ រឿងយកដាវកាត់ក្បាល ជានាទីរបស់អញចុះ ដូច្នេះ សត្រូវទាំង ៣ នោះ កាលពោលយ៉ាងនេះហើយ ក៏ធ្វើយ៉ាងនោះ ។

ក្នុងការឧបមានោះ ឈ្មោះថា ការទាញចេញពីវង្សសម្មាញ់ និងញាតិ

ហើយឲ្យកើតក្នុងកពណាមួយ ដូចពេលដែលសត្រូវទី ១ ពោលសរសើរព្រៃ ហើយនាំបុរសនោះទៅក្នុងព្រៃនោះ គប្បីជ្រាបថា ជានាទីរបស់ជាតិ ។ ការធ្វើឲ្យដួលចុះ ត្រូវអាស្រ័យអ្នកដទៃ និងមានត្រឹមតែគ្រែដេក ជាទីទៅខាងមុខ ក្នុងខន្ធដែលកើតឡើងហើយ ដូចសត្រូវទី ២ វាយធ្វើឲ្យទុព្វលភាព គប្បីជ្រាបថា ជាកិច្ចរបស់ជរា ការឲ្យដល់នូវការអស់ជីវិត ដូចសត្រូវទី ៣ យកដាវកាត់ក្បាល គប្បីជ្រាបថា ជាកិច្ចរបស់មរណៈ ដូច្នោះ ។

ម្យ៉ាងទៀត ក្នុងទុក្ខទាំង ៣ នេះ គប្បីឃើញជាតិទុក្ខ ដូចការចូលកាន់ផ្លូវកន្តារធំដែលមានទោស គប្បីឃើញជរាទុក្ខ ដូចភាពជាបុគ្គលទុព្វលដែលអត់បាយទឹកក្នុងផ្លូវកន្តារនោះ គប្បីឃើញមរណទុក្ខ ដូចការធ្វើបុរសនោះឲ្យទុព្វល ត្រូវកម្ចាត់នូវសេចក្តីព្យាយាម ក្នុងការកម្រើកឥរិយាបថ ឲ្យដល់នូវសេចក្តីវិនាស ដោយចំណងជាដើម ។

[ ១៤៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសោកនិទ្ទេសដូចតទៅ

ឈ្មោះថា ព្យសនៈ ព្រោះអត្ថថា ដល់នូវការព្រាត់ប្រាស អធិប្បាយថា បន្សាត់ទៅ គឺកម្ចាត់ប្រយោជន៍ និងសេចក្តីសុខ ។ ការវិនាសនៃញាតិឈ្មោះថា **ញាតិព្យសនំ** អធិប្បាយថា ការអស់ញាតិ គឺការវិនាសនៃញាតិដោយភ័យអំពីចោរ និងភ័យអំពីរោគជាដើម ដោយការវិនាសនៃញាតិនោះ ។

បទថា **ផុដ្ឋស្ស** សេចក្តីថា របស់បុគ្គលដែលការវិនាសលិចលង់ហើយគ្របសង្កត់ហើយ គឺប្រកបព្រមហើយ ។ ក្នុងពាក្យដ៏សេស ក៏ន័យនេះឯង ។

តែការប្លែកគ្នា មានដូចតទៅនេះ

ការវិនាសនៃភោគៈទាំងឡាយ ឈ្មោះថា **ភោគព្យសនំ** អធិប្បាយថា ការអស់នូវភោគៈ ការវិនាសនូវភោគៈដោយអំណាចនៃភ័យ មានរាជភ័យ និងចោរភ័យជាដើម ។ ការវិនាស គឺរោគ ឈ្មោះថា **រោគព្យសនំ** ។ ពិតហើយ រោគ រមែងញ៉ាំងការមិនមានរោគឲ្យប្រាសទៅ គឺរមែងឲ្យវិនាសទៅ ព្រោះហេតុនោះ ទើបឈ្មោះថា **ព្យសន** ។ សេចក្ដីវិនាសនៃសីល ឈ្មោះថា **សីលព្យសនំ** ។ ពាក្យថា **សីលព្យសនំ** នេះ ជាឈ្មោះនៃបុគ្គលទ្រុស្តសីល ។ ការវិនាស គឺទិដ្ឋិដែលកើតឡើង ញ៉ាំងសម្មាទិដ្ឋិឲ្យវិនាស ឈ្មោះថា **ទិដ្ឋិព្យសនំ** ម្យ៉ាងទៀត បណ្ដាសេចក្ដីវិនាសទាំង ៥ នេះ ការវិនាស ២ ខាងដើម ជារបស់មិនសម្រេច តែការវិនាស ៣ ខាងក្រោយ ជារបស់ការសម្រេច គឺត្រូវត្រៃលក្ខណ៍ប៉ះខ្ទប់ហើយ ។ ម្យ៉ាងទៀត ការវិនាស ៣ យ៉ាងដំបូង មិនជាកុសល មិនជាអកុសល ការវិនាស ២ គឺ សីល និងទិដ្ឋិ ទើបជាអកុសល ។

បទថា **អញ្ញតរញ្ញតរេន** បានដល់ ដោយសេចក្ដីវិនាសណាមួយ បណ្ដាការវិនាសទាំងឡាយ ៥ ដែលព្រះមានព្រះភាគ កាន់យកហើយ ឬ ដោយសេចក្ដីជ្រះថ្លាឯណានីមួយ មានការវិនាសបាកមិត្ត និងការវិនាសបាក អមាត្យជាដើម ដែលទ្រង់មិនប្រាព្ធយកហើយ ។

បទថា **សមន្នាគតស្ស** បានដល់ របស់បុគ្គលដែលជាប់ជំពាក់ គឺ បុគ្គលមិនទាន់ផុតទៅ ។

បទថា **អញ្ញតរញ្ញតរេន ទុក្ខធម្មេន** បានដល់ ហេតុកើតឡើងនៃទុក្ខ គឺសេចក្ដីសោកណាមួយ ។

បទថា **សោកោ** បានដល់ ឈ្មោះថា សោក ដោយអំណាចសេចក្ដីសោក ពាក្យថា សោកនេះ ជាបទចំពោះខ្លួនដោយសភាវៈនៃសេចក្ដីសោក ដែលកើតឡើងដោយហេតុទាំងនេះ ។ បទថា **សោចនា** បានដល់ អាការរបស់សេចក្ដីសោកខ្សឹកខ្សួល ។ ភាពនៃសេចក្ដីសោក ឈ្មោះថា **សោចិ-តត្តំ** ។

បទថា **អន្តោ សោកោ** បានដល់ សេចក្ដីសោកខាងក្នុង ។ បទទី ២ គឺ **អន្តោបរិសោកោ** ទ្រង់បន្ថែមបទឧបសគ្គ ។ ពិតហើយ សេចក្ដីសោកនោះកើតឡើង ញុំាំងធម៌ខាងក្នុងឲ្យស្ងិតស្រពោន ឲ្យក្រៀមក្រំដោយជុំវិញ ព្រោះហេតុនោះ ទើបត្រាស់ហៅថា **អន្តោសោកោ អន្តោបរិសោកោ** ។

បទថា **ចេតសោ បរិជ្ឈាយនា** បានដល់ អាការដែលដុតចិត្ត ។ ព្រោះសេចក្ដីសោក កាលកើតឡើង រមែងដុតចិត្ត រមែងឆេះចិត្តយ៉ាងក្រៃលែង រមែងញុំាំងបុគ្គលឲ្យរវើរវាយថា ចិត្តរបស់ខ្ញុំក្រៀមក្រំហើយ មិនមានអ្វីជ្រះថ្លា ដូច្នេះ ។ ចិត្តដែលជួបនូវទុក្ខ ឈ្មោះថា ទុម្មនៈ ភាវៈនៃទុម្មនៈនោះ ឈ្មោះថា ទោមនស្ស ។ កូនសរ គឺសេចក្ដីសោក ដោយអត្ថថា ស្ទុះចូលទៅ ព្រោះហេតុនោះ ទើបឈ្មោះថា **សោកសល្លំ** ។

បទថា **អយំ វុច្ចតិ សោកោ** សេចក្ដីថា នេះតថាគតហៅថា **សោក** ។ សេចក្ដីសោកនេះ ពោលដោយអត្ថ ក៏បានដល់ទោមនស្សវេទនាតែម្យ៉ាង

ប៉ុណ្ណោះក៏ពិត កាលបើដូច្នោះ សេចក្តីសោកនោះ **អន្តោនិជ្ឈានលក្ខណោ** មានការដុតរោលខាងក្នុងជាលក្ខណៈ **ចេតសោ បរិនិជ្ឈាយនរសោ** មានការក្តៅក្រហាយចិត្តជាកិច្ច **អនុសោចនបច្ចុប្បដ្ឋានោ** មានសេចក្តីសោករឿយៗ ជាអាការប្រាកដ ។

គប្បីជ្រាបវិនិច្ឆ័យសេចក្តីសោក ដោយអត្ថថា ជាទុក្ខដូចតទៅ

សោកនេះ ព្រះមានព្រះភាគត្រាស់ថា ជាទុក្ខ ព្រោះសេចក្តីសោកនោះ ជាសភាវៈនៃទុក្ខ និងព្រោះជាទីតាំងនៃទុក្ខ ។

សួរថា របស់ទុក្ខណា ឆ្លើយថា របស់ទុក្ខកាយ និងទុក្ខ គឺទោមនស្ស ក្នុងខណៈនៃជវ័ន ។ ពិតហើយ ដោយកម្លាំងនៃសេចក្តីសោក បួសធំរមែងកើតឡើងត្រង់ហទយៈ ទុំហើយរមែងបែកហូរចេញក្តី ឈាមខ្មៅរមែងហូរចេញតាមមាត់ក្តី ទុក្ខផ្លូវកាយដ៏ខ្លាំងក្លា រមែងកើតឡើង ។ កាលចិត្តគិតថា ញាតិរបស់អញប៉ុណ្ណោះ អស់ទៅហើយ ភោគៈរបស់អញប៉ុណ្ណោះ អស់ទៅហើយ ដូច្នោះ ទោមនស្សដ៏ខ្លាំងក្លា ក៏កើតឡើងបាន ។

គប្បីជ្រាបសោកនេះថាជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខទាំង ២ នេះ ដោយប្រការដូច្នេះឯង ។ ម្យ៉ាងទៀត

សេចក្តីសោក រមែងចាក់ទម្លុះហទយៈរបស់ពួកសត្វ ដូចកូន-
សរ រមែងដុតយ៉ាងខ្លាំងក្លាទៀត ដូចលំពែងដែកដុតដោយ
ភ្លើងហើយប្រហារ ព្រោះសោកនោះ រមែងនាំមកព្រមនូវទុក្ខ
ប្រភេទផ្សេងៗ មានព្យាធិ ជរា និងមរណៈ ហេតុនោះ ទើប

សេចក្តីសោកនោះ ព្រះមានព្រះភាគត្រាស់ថាជាទុក្ខ ដូច្នេះ ។

[ ១៥០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបរិទេវនិទ្ទេសដូចតទៅ

បទថា **អាទេវោ** ការទ្រហោយំ ព្រោះអត្ថថា ជាហេតុឲ្យសត្វបន្លឺសំឡេងស្រែកយំ ដោយអាងថា ធីតារបស់ខ្ញុំ បុត្តរបស់ខ្ញុំ ដូច្នេះ ដែលឈ្មោះថា **បរិទេវោ** ព្រោះអត្ថថា ជាហេតុឲ្យសត្វខ្សឹកខ្សួល ប្រកាសដល់កូនស្រី និងកូនប្រុសនោះៗ ។ បទ ២ គូខាងក្រោយ បន្ទាប់អំពី ២ បទខាងមុខ ព្រះមានព្រះភាគត្រាស់ដោយការពង្រីកអាការ និងភាវៈរបស់បទ ២ ខាងដើមនោះឯង ។ បទថា **វាចា** គឺជាពាក្យពោល ។ ពាក្យដែលពោលទទេមិនមានប្រយោជន៍ ឈ្មោះថា **បលាបោ** ។ ការពោលពាក្យប៉ប៉ាច់-ប៉ប៉ោចដោយអំណាចការពាក់កណ្តាលៗ និងពោលផ្តេសផ្តាស់ជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា **វិបលាបោ** ។ បទថា **លាលបោ** បានដល់ ការនិយាយដដែលៗ ។ អាការនៃការពោលដដែលៗ ឈ្មោះថា **លាលប្បនា** ។ ភាវៈនៃកិរិយានិយាយដដែលៗ ឈ្មោះថា **លាលប្បិតត្តំ** ។ ពាក្យថា **អយំ វុច្ចតិ បរិទេវោ** សេចក្តីថា នេះតថាគត ហៅថា **បរិទេវោ** ។ បរិទេវៈនោះ **លាលប្បនលក្ខណោ** មានការយំរៀបរាប់ជាលក្ខណៈ **គុណទោស-បរិកិត្តនរសោ** មានការយំរៀបរាប់ដល់គុណ និងទោសជាកិច្ច **សម្ភមបច្ចុ-ប្បដ្ឋានោ** មានការវឹកវរ មិនតាំងមាំជាអាការប្រាកដ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបរិទេវៈ ដោយអត្ថថាជាទុក្ខដូចតទៅ

បរិទេវៈនេះខ្លួនឯងមិនជាទុក្ខ តែព្រះមានព្រះភាគត្រាស់ថាជាទុក្ខ ព្រោះ

ជាទីតាំងនៃទុក្ខកាយ និងទុក្ខទោមនស្ស ។ ពិតហើយ បុគ្គលកំពុងខ្សឹកខ្សួល រមែងយកដៃវាយខ្លួនរបស់ខ្លួន រមែងយកដៃទាំង ២ គក់ទ្រូង រឹតទ្រូង រមែងយកក្បាលជល់ជញ្ជាំងក៏បាន ព្រោះហេតុនោះ ទុក្ខកាយដ៏ខ្លាំងក្លា រមែងកើតដល់បុគ្គលនោះបាន បុគ្គលនោះ តែងគិតថា ញាតិរបស់អញប៉ុណ្ណេះ អស់ហើយ វិនាសហើយ តាំងនៅមិនបានហើយ ព្រោះហេតុនោះ ទើបទោមនស្សដ៏ខ្លាំងក្លា កើតឡើងដល់បុគ្គលនោះ ។

គប្បីជ្រាបបរិទេវៈថា ជាទុក្ខ ព្រោះភាពជាទីតាំងនៃទុក្ខទាំង ២ នេះ ដោយប្រការដូច្នេះ ។ ន័យម្យ៉ាងទៀត

> បុគ្គលដែលត្រូវសរ គឺសេចក្ដីសោកមុតហើយ កន្ទក់កន្ទេញ រមែងជួបនូវទុក្ខណា ដែលអត់ធន់មិនបាន ដែលកើតអំពីការស្ងួត-ក បបូរមាត់ និងពិតានយ៉ាងក្រៃលែង ពន់ប្រមាណ ដោយទុក្ខនោះ ទើបព្រះមានព្រះភាគត្រាស់ថា បរិទេវៈ គឺការកន្ទក់កន្ទេញ ថាជាទុក្ខ ដូច្នេះ ។

[ ១៥១-១៥២ ] និទ្ទេសនៃទុក្ខ និងទោមនស្ស ប្រាកដច្បាស់ហើយ ព្រោះខ្ញុំបានពណ៌នាក្នុងអដ្ឋកថាធម្មសង្គហៈ ( អដ្ឋសាលិនី ) ខាងដើមនោះឯង និងលក្ខណាទិចតុក្កៈរបស់ទុក្ខ និងទោមនស្ស ខ្ញុំក៏បានពោលហើយក្នុងទីនោះដូចគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងទុក្ខ ដោយអត្ថថា ជាទុក្ខ និងទោមនស្ស ដោយអត្ថថាជាទុក្ខដូចតទៅ

ទុក្ខ និងទោមនស្សទាំង ២ នេះ ព្រះមានព្រះភាគត្រាស់ថាជាទុក្ខ ព្រោះខ្លួនជាទុក្ខផង ជាទីតាំងនៃទុក្ខកាយ និងទុក្ខចិត្តផង ។ ពិតហើយ កាលបុគ្គលជួបនូវទុក្ខដោយទុក្ខ គឺការកាត់ដៃ កាត់ជើង កាត់ត្រចៀក កាត់ច្រមុះ ដាក់អំបែងស្ងួមទានអំពីខាងមុខ ដេកក្នុងសាលារបស់មនុស្សអនាថា កាលមានពួកដង្កូវចេញអំពីមុខដំបៅទាំងឡាយ ទុក្ខកាយដ៏ខ្លាំងក្លា រមែងកើតឡើង ។ ទោមនស្សដ៏ខ្លាំងក្លារមែងកើត ព្រោះឃើញមហាជនដែលមានសំពត់ជ្រលក់ដោយពណ៌ផ្សេងៗ មានគ្រឿងអលង្ការគួរជាទីពេញចិត្ត លេងនក្ខត្តឫក្ស ។

គប្បីជ្រាបភាពដែលទុក្ខ ទីតាំងនៃទុក្ខ ទាំង ២ យ៉ាង ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ទុក្ខផ្លូវកាយនេះ រមែងបៀតបៀន និងរមែងឲ្យកើតទុក្ខផ្លូវចិត្តយ៉ាងក្រៃលែង ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ថា ជាទុក្ខដោយវិសេស ។

ម្យ៉ាងទៀត បុគ្គលដែលដល់ព្រមដោយទុក្ខផ្លូវចិត្ត រមែងរំសាយសក់រំពឹងទ្រូង បម្រះនទៀលទៅមក លោតចូលក្នុងជ្រោះខ្លះ នាំសស្ត្រាមកសម្លាប់ខ្លួនខ្លះ បរិភោគថ្នាំពុលខ្លះ យកខ្សែមកចង-កខ្លះ លោតចូលគំនរភ្លើងខ្លះ ជាអ្នកមានសេចក្តីក្តៅក្រហាយ ជាអ្នកមានចិត្តក្តៅក្រហាយ ដោយប្រការនោះៗ រមែងគិតដល់រឿងវិបរិតនោះៗ ។ គប្បីជ្រាបភាពដែលទោមនស្សជាទីតាំងនៃទុក្ខទាំង ២ យ៉ាង ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត

ព្រោះទោមនស្ស រមែងបៀតបៀនចិត្ត និងរមែងនាំមកនូវការ
បៀតបៀន ដល់រាងកាយ ហេតុនោះ ទើបបណ្ឌិតទាំងឡាយ
ពោលទោមនស្សថាជាទុក្ខ ព្រោះទោមនស្សនោះឯង ដូច្នេះ ។

[ ១៥៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧបាយាសនិទ្ទេសដូចតទៅ

ឈ្មោះថា **អាយាសោ** ព្រោះអត្ថថា លំបាក ពាក្យនេះ ជាឈ្មោះរបស់សេចក្ដីលំបាកចិត្ត ដែលប្រព្រឹត្តទៅដោយអាការតក់ស្លុត និងសោកសៅ ។ ការបង្អៀតបង្អល់ចិត្តដ៏ខ្លាំងក្លា ឈ្មោះថា **ឧបាយាសោ** ។ ភាវៈនៃបុគ្គលដែលតានតឹងក្នុងចិត្ត ឈ្មោះថា **អាយាសិតត្តំ** ។ ភាវៈនៃបុគ្គលបង្អៀតបង្អល់ក្នុងចិត្ត ឈ្មោះថា **ឧបាយាសិតត្តំ** ។

បទថា **អយំ វុច្ចតិ ឧបាយាសោ** សេចក្ដីថា នេះតថាគត ហៅថា **ឧបាយាស** ។ ឧបាយាសនេះ **ព្យាសត្តិលក្ខណោ** មានការជាប់ក្នុងអារម្មណ៍ផ្សេងៗ ជាលក្ខណៈ **និត្ថុននរសោ** មានការរួញរាចិត្តជាកិច្ច **វិសាទបច្ចុប្បដ្ឋានោ** មានការតានតឹងជាអាការប្រាកដ ។

ម្យ៉ាងទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា គប្បីជ្រាបអត្ថនៃឧបាយាសជាទុក្ខដូចតទៅ

ឧបាយាសនេះ ខ្លួនឯងមិនជាទុក្ខ តែព្រះមានព្រះភាគត្រាស់ថា ជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខទាំង ២ ។ ពិតហើយ កាលបុគ្គលមានបុត្ត និងបងប្រុសប្អូនប្រុស ត្រូវព្រះរាជាពិរោធ ដកយសហើយប្រហារ ខ្លួនឯងសោត ក៏ត្រូវសម្លាប់ ទើបគេចចូលទៅកាន់ព្រៃព្ធនព្រោះភ័យ ដល់នូវភាពជាអ្នកតានតឹង

ក្នុងចិត្តជំកនួង រមែងកើតទុក្ខកាយដ៏មានកម្លាំង ព្រោះឈរជាទុក្ខ ដេកជាទុក្ខ អង្គុយជាទុក្ខ កាលគិតថា ពួកញាតិរបស់អញប៉ុណ្ណេះ ភោគទ្រព្យប៉ុណ្ណេះ វិនាសហើយ រមែងកើតទោមនស្សដ៏មានកម្លាំង ។

គប្បីជ្រាបឧបាយាសថាជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខទាំង ២ នេះ ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត

ឧបាយាស រមែងញុំាងទុក្ខ មានប្រមាណក្រៃលែងឯណាឲ្យ
កើតឡើង ព្រោះការដុតចិត្ត និងធ្វើកាយឲ្យសៅហ្មង ហេតុ
នោះ ទើបព្រះមានព្រះភាគត្រាស់ឧបាយាស ថាជាទុក្ខ ។

ម្យ៉ាងទៀត បណ្តាទុក្ខ ៣ យ៉ាង មានសោកជាដើមនេះ គប្បីឃើញសោក ដូចការចម្អិនប្រេងជាដើម ខាងក្នុងភាជនៈដោយភ្លើងដែលដុតតិចៗ គប្បីឃើញបរិទេវៈ ដូចការផុរចេញខាងក្រៅភាជនៈរបស់ប្រេងដែលដាំដោយភ្លើងខ្លាំង គប្បីឃើញឧបាយាស ដូចការរម្ងាស់ប្រេងទាល់តែរីងក្នុងភាជនៈនោះឯង រហូតដល់ប្រេងដែលសល់មិនអាចហូរចេញមកខាងក្រៅ មិនអាចផុរបាន ។

[ ១៥៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសអប្បិយសម្បយោគទុក្ខដូចតទៅ

បទថា **យស្ស** កាត់បទជា **យេ អស្ស** ។ បទថា **អនិដ្ឋា** បានដល់ដែលគេមិនស្វែងរក គឺដែលគេស្វែងរកក្តី មិនស្វែងរកក្តី ។ ម្យ៉ាងទៀត បទថា **អនិដ្ឋា** នេះ ជាឈ្មោះរបស់អារម្មណ៍ មិនជាទីគាប់ចិត្តដែលមិនគប្បី

ស្វែងរក ។

ធម៌មានរូបជាដើមពួកណា រមែងមិនឈានទៅ គឺរមែងមិនចូលទៅក្នុងចិត្ត ព្រោះហេតុនោះ ធម៌មានរូបជាដើមនោះ ឈ្មោះថា **អកន្តា** គឺមិនជាទីប្រាថ្នា ។ ធម៌ពួកណា មិនជិតស្និទ្ធក្នុងចិត្ត ឬមិនធ្វើចិត្តឲ្យចម្រើន ព្រោះហេតុនោះ ទើបធម៌ទាំងនោះឈ្មោះថា **អមនាបា** គឺមិនជាទីគាប់ចិត្ត ។ បទថា **រូបា** ជាដើម ជាពាក្យពង្រីកសភាវៈនៃធម៌ទាំងនោះ ។ បុគ្គលពួកណា រមែងស្រឡាញ់ គឺរមែងប្រាថ្នាវត្ថុដែលមិនមែនប្រយោជន៍ ព្រោះហេតុនោះ ទើបបុគ្គលទាំងនោះ ឈ្មោះថា **អនត្ថកាមា** គឺប្រាថ្នាសេចក្តីមិនចម្រើន ។ បុគ្គលពួកណារមែងស្រឡាញ់ គឺប្រាថ្នាវត្ថុដែលមិនមែនជាប្រយោជន៍ ព្រោះហេតុនោះ ទើបបុគ្គលទាំងនោះ ឈ្មោះថា **អហិតកាមា** គឺប្រាថ្នាអំពើឥតប្រយោជន៍ ។ បុគ្គលពួកណា រមែងស្រឡាញ់ គឺរមែងប្រាថ្នានូវការមិនផាសុក គឺការនៅជាទុក្ខ ព្រោះហេតុនោះ ទើបបុគ្គលទាំងនោះ ឈ្មោះថា **អផាសុកាមា** គឺប្រាថ្នាសេចក្តីមិនសប្បាយ ។ បុគ្គលពួកណា រមែងមិនប្រាថ្នានូវដែនក្សេមចាកយោគៈ គឺវិវដ្ដៈដែលប្រាសចាកភ័យ គឺរមែងស្រឡាញ់ រមែងប្រាថ្នាវដ្ដៈ ដែលមានភ័យនោះឯង ដើម្បីយោគៈ ៤ ព្រោះហេតុនោះ ទើបបុគ្គលទាំងនោះ ឈ្មោះថា **អយោគក្ខេមកាមា** គឺប្រាថ្នាសេចក្តីមិនក្សេមចាកយោគៈ ។

មួយវិញទៀត គប្បីឃើញអត្ថក្នុងបទទាំង ៨ មានបទថា **អនត្ថកាមា** ជាដើមនេះយ៉ាងនេះថា បុគ្គលឈ្មោះថា **អនត្ថកាមា** ព្រោះមិនប្រាថ្នាចំពោះ

*ប្រយោជន៍ ពោល គឺសេចក្ដីចម្រើនក្នុងធម៌ មានសទ្ធាជាដើម និងព្រោះប្រាថ្នាចំពោះវត្ថុដែលមិនមែនប្រយោជន៍ ពោល គឺការវិនាសនៃសទ្ធាជាដើមទាំងនោះឯង ។ ដែលឈ្មោះថា* **អហិតកាមា** *ព្រោះមិនប្រាថ្នាចំពោះប្រយោជន៍ ដែលជាឧបាយនៃសទ្ធាជាដើមនោះឯង និងព្រោះប្រាថ្នាចំពោះវត្ថុដែលមិនមែនប្រយោជន៍ដែលជាឧបាយនៃអកុសល មានការវិនាសសទ្ធាជាដើម ។ ដែលឈ្មោះថា* **អផាសុកាមា** *ព្រោះមិនប្រាថ្នាចំពោះការនៅជាផាសុក និងព្រោះប្រាថ្នាចំពោះការនៅដោយមិនជាផាសុក ។ ដែលឈ្មោះថា* **អយោគក្ខេមកាមា** *ព្រោះមិនប្រាថ្នាចំពោះការក្សេមណាមួយ និងព្រោះប្រាថ្នាចំពោះភ័យ ដូច្នេះ ។*

*ការទៅប្រកបព្រមគ្នា ឈ្មោះថា* **សង្គតិ** ។ *ការមករួមគ្នា ឈ្មោះថា* **សមាគមោ** ។ *ការៈដែលព្រមគ្នាក្នុងការឈរ ការអង្គុយជាដើម ឈ្មោះថា* **សមោធានំ** ។ *ការធ្វើរួមគ្នានូវកិច្ចទាំងពួង ឈ្មោះថា* **មិស្សីភាវោ** *នេះជាយោជនា គឺការប្រកបដោយអំណាចនៃសត្វ ។*

*ឯយោជនាដោយអំណាចនៃសង្ខារ គប្បីកាន់យកសេចក្ដីតាមដែលបាន ។ បទថា* **អយំ វុច្ចតិ** *សេចក្ដីថា នេះតថាគត ឲ្យឈ្មោះថា* **អប្បិយសម្បយោគទុក្ខ** *អប្បិយសម្បយោគទុក្ខនោះ* **អនិដ្ឋសមោធានលក្ខណោ** *មានការប្រជុំចុះនូវវត្ថុ ដែលមិនគួរប្រាថ្នាជាលក្ខណៈ* **ចិត្តវិឃាតករណរសោ** *មានការធ្វើនូវការពិឃាតចិត្តជាកិច្ច* **អនត្ថភាវបច្ចុប្បដ្ឋានោ** *មានភាវៈដែលឥតប្រយោជន៍ជាអាការប្រាកដ ។ អប្បិយសម្បយោគទុក្ខនោះ ដោយអត្ថ*

ចាត់ជាធម៌មួយ ហៅបានត្រឹមតែថា ជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខទាំង ២ យ៉ាង ដល់បុគ្គលដែលប្រកបដោយអារម្មណ៍មិនជាទីស្រឡាញ់ ព្រោះវត្ថុទាំងឡាយ ដែលមិនគួរប្រាថ្នា ដល់នូវការប្រជុំចុះហើយ រមែងញុំាងទុក្ខផ្លូវកាយឲ្យកើតឡើងដោយការចាក់ ដោយការកាប់ ដោយការវះជាដើម រមែងញុំាងទុក្ខផ្លូវចិត្តឲ្យកើតឡើង ដោយការឲ្យកើតនូវការតក់ស្លុត ព្រោះហេតុនោះ ទើបលោកពោលថា

ព្រោះឃើញសត្វដែលមិនជាទីស្រឡាញ់ ទើបជាទុក្ខត្រង់ផ្លូវចិត្តមុននោះឯង ឯការកើតទុក្ខដោយសេចក្ដីព្យាយាម របស់សត្វដែលមិនជាទីស្រឡាញ់នោះ ក្នុងកាយ ព្រោះហេតុណា ព្រោះហេតុនោះ គប្បីជ្រាបការសមាគមជាមួយសត្វ ដែលមិនជាទីស្រឡាញ់នោះ ព្រះមហេសីត្រាស់ថា ជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខទាំង ២ ដូច្នេះ ។

[ ១៥៥ ] និទ្ទេសនៃបិយវិប្បយោគទុក្ខ គប្បីជ្រាបដោយន័យផ្ទុយគ្នានឹងពាក្យដែលពោលហើយនោះឯង ក្នុងនិទ្ទេសនេះ ព្រះមានព្រះភាគ ត្រាស់បទថា **មាតា វា** ជាដើម ដើម្បីទ្រង់សម្ដែងដល់បុគ្គល ដែលប្រាថ្នាប្រយោជន៍ដោយសង្ខេប ។

ក្នុងព្រះបាលីនោះ មានវិគ្គហៈថា ដែលឈ្មោះថា **មាតា** ព្រោះអត្ថថា រមែងថ្នាក់ថ្នម ។ ដែលឈ្មោះថា **បិតា** ព្រោះអត្ថថា រមែងពេញចិត្ត ។ ដែលឈ្មោះថា **ភាតា** ព្រោះអត្ថថា រមែងស្និទ្ធស្នាល ។ ដែលឈ្មោះថា

**ភគនី** ក៏ដូចគ្នា ។ ដែលឈ្មោះថា **មិត្តា** ព្រោះអត្ថថា ប្រព្រឹត្តមេត្តា ឬព្រោះអត្ថថា រាប់អាន អធិប្បាយថា រមែងលាក់នូវអាថ៌កំបាំងទាំងអស់ទុកខាងក្នុង ។ ដែលឈ្មោះថា **អមច្ចា** ព្រោះអត្ថថា ជាអ្នករួមគ្នា ដោយអត្ថថា ជាបុគ្គលព្រមព្រៀងគ្នាក្នុងករណីយកិច្ចទាំងឡាយ ។ ដែលឈ្មោះថា **ញាតិ** ព្រោះអត្ថថា រមែងដឹង ឬជ្រាបយ៉ាងនេះថា បុគ្គលនេះ ជាមនុស្សខាងក្នុងរបស់ពួកយើង ។ ដែលឈ្មោះថា **សាលោហិតា** ព្រោះអត្ថថា ជាបុគ្គលសម្ពន្ធគ្នាដោយខ្សែស្រឡាយ ។

គប្បីជ្រាបបទទាំងនេះដោយអត្ថ ដោយប្រការដូច្នេះ ។

បទថា **អយំ វុច្ចតិ** សេចក្ដីថា នេះតថាគត ហៅថា **បិយេហិវិប្បយោគទុក្ខ** បិយេហិវិប្បយោគទុក្ខនោះ **ឥដ្ឋវត្ថុវិយោគលក្ខណោ** មានការព្រាត់ប្រាសចាកវត្ថុ ដែលគួរប្រាថ្នាជាលក្ខណៈ **សោកុប្បាទនរសោ** មានការឲ្យកើតឡើងនៃសេចក្ដីសោកជាកិច្ច **ព្យសនបច្ចុប្បដ្ឋានោ** មានការវិនាសជាអាការប្រាកដ ។

**បិយេហិវិប្បយោគទុក្ខ** នោះ ដោយអត្ថ ចាត់ជាធម៌មួយ ក៏មិនមាន ហៅបានត្រឹមតែជាទុក្ខព្រោះជាទីតាំងនៃទុក្ខទាំង ២ យ៉ាង ដល់បុគ្គលដែលព្រាត់ប្រាសចាកវត្ថុជាទីស្រឡាញ់ ព្រោះវត្ថុដែលគួរប្រាថ្នាទាំងឡាយ កាលព្រាត់ប្រាសទៅ រមែងញុំាងទុក្ខផ្លូវកាយឲ្យកើតឡើង ដោយភាពជាបុគ្គលដែលមានសរីរៈស្គាំងស្គម និងរីងស្ងួតជាដើម រមែងញុំាងទុក្ខផ្លូវចិត្ត ឲ្យកើតដោយការឲ្យនូវសេចក្ដីសោកថា វត្ថុដែលមានដល់ពួកយើងនោះ ក៏មិនមាន

ហើយ ដោយហេតុនោះ ទើបលោកពោលដូច្នេះថា

ព្រោះព្រាត់ប្រាសចាកញាតិ និងទ្រព្យជាដើម ពួកបុគ្គលពាល ដល់ព្រមដោយកូនសរ គឺសេចក្ដីសោកចាក់ដោត ព្រោះហេតុណា ព្រោះហេតុនោះ ការព្រាត់ប្រាសចាកវត្ថុជាទីស្រឡាញ់ ទើបសន្មតថា ជាទុក្ខ ដូច្នេះ ។

[ ១៥៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឥច្ឆានិទ្ទេស គឺនិទ្ទេសនៃសេចក្ដីប្រាថ្នាដូចតទៅ

បទថា **ជាតិធម្មានំ** បានដល់ មានការកើតជាសភាវៈ មានការកើតជាប្រក្រតី ។ បទថា **ឥច្ឆា ឧប្បជ្ជតិ** បានដល់ តណ្ហា រមែងកើតឡើង ។ សព្ទថា **អហោ វត** នេះ ជាការប្រាថ្នា ។ បទថា **ន ខោ បនេតំ ឥច្ឆាយ បត្តព្វំ** សេចក្ដីថា ការមិនកើតជាធម្មតា ដែលមាននៅក្នុងពួកសាធុជនដែលលះសមុទយៈបានហើយ និងការមិនមកនៃជាតិដែលនៅមានក្នុងបុគ្គលដែលបរិនិព្វានហើយ ដែលសត្វទាំងឡាយប្រាថ្នាហើយ យ៉ាងនេះថា ឱហ្ន៎ សូមពួកយើងកុំមានការកើតជាធម្មតា ឬការកើតកុំបីមកដល់ពួកយើងឡើយ ដូច្នេះ ឈ្មោះថា រមែងមិនសម្រេចតាមសេចក្ដីប្រាថ្នាបាន ព្រោះបុគ្គលប្រាថ្នាវៀរចាកមគ្គភាវនា ក៏មិនសម្រេច ព្រោះបុគ្គលដែលមិនប្រាថ្នា ជាធម៌គប្បីដល់ដោយមគ្គភាវនា ។

បទថា **ឥទម្បិ** បានដល់ សូម្បីនោះ ។ **បិ** អក្ខរៈ សំដៅយកបទដែលប្លែកគ្នាខាងមុខ ។ បទថា **យម្បិច្ឆំ** សេចក្ដីថា កាលបុគ្គលប្រាថ្នាវត្ថុ

ដែលមិនគប្បីបានដោយធម៌ណា រមែងមិនបាននូវសេចក្ដីប្រាថ្នា ក្នុងវត្ថុដែលមិនគប្បីបាននោះ គប្បីជ្រាបថា ជាទុក្ខ ។ ក្នុងបទថា **ជរាធម្មានំ** ជាដើម ក៏មានន័យនេះដូចគ្នា ។ សេចក្ដីប្រាថ្នាក្នុងវត្ថុដែលមិនគប្បីបាន ក្នុងនិទ្ទេសនេះ ព្រះមានព្រះភាគត្រាស់ថា **យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ** ដោយប្រការដូច្នេះ ។

សេចក្ដីប្រាថ្នានោះ **អលព្ភនេយ្យវត្ថុ ឥច្ឆនលក្ខណា** មានការចង់បានក្នុងវត្ថុដែលមិនគប្បីបានជាលក្ខណៈ **តប្បរិយេសនរសា** មានការស្វែងរកវត្ថុនោះជាកិច្ច **តេសំ អប្បត្តិប្បច្ចុប្បដ្ឋានា** មានការមិនសម្រេចវត្ថុទាំងនោះជាអាការប្រាកដ ។

សេចក្ដីប្រាថ្នានោះ ព្រះមានព្រះភាគ ត្រាស់ថាជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខទាំង ២ យ៉ាង ។ ពិតហើយ បុគ្គលខ្លះ បានទទួលការសរសើរថានឹងបានជាព្រះរាជា ត្រូវចោមរោមដោយគណៈដែលផ្ដាច់ខ្លួន ចូលទៅកាន់ភ្នំដែលមិនរាបស្មើ ឬដងព្រៃ ។ ពេលនោះ ព្រះរាជាទ្រង់ជ្រាបព្រឹត្តិការណ៍នោះហើយ ទើបបញ្ជូនពួកពលទៅ ។ បុរសនោះ មានបរិវារត្រូវរាជបុរសកម្ចាត់ហើយ សូម្បីខ្លួនឯងក៏ត្រូវបៀតបៀន ទើបគេចចូលទៅកាន់ចន្លោះដើមឈើខ្លះ ចន្លោះថ្មខ្លះ ។ សម័យនោះ ពពកធំតាំងឡើង មានភ្លៀងធ្លាក់យ៉ាងខ្លាំង ខណៈនោះហ្វូងសត្វ មានស្រមោចខ្មៅជាដើម ក៏ចោមរោមតោងបុរសនោះដោយជុំវិញ ដោយហេតុនោះ ទើបសេចក្ដីទុក្ខកាយដ៏មានកម្លាំង កើតដល់បុរសនោះ កាលបុរសនោះគិតថា ពួកញាតិប៉ុណ្ណេះ និងភោគទ្រព្យ

ប៉ុណ្ណោះវិនាសហើយ ព្រោះអាស្រ័យអញម្នាក់ដូច្នេះ ទោមនស្សដ៏មានកម្លាំង រមែងកើតឡើង ។ សេចក្ដីប្រាថ្នានេះ គប្បីជ្រាបថា ជាទុក្ខ ព្រោះជាទីតាំង នៃទុក្ខទាំង ២ យ៉ាង ដោយប្រការដូច្នេះ ។ម្យ៉ាងទៀត

កាលសត្វប្រាថ្នាវត្ថុទាំងនោះ ព្រោះមិនបានវត្ថុនោះៗ សេចក្ដី
ទុក្ខឯណា ដែលកើតអំពីការមិនបានដូចបំណង រមែងកើត
ឡើងដល់ពួកសត្វក្នុងលោកនេះ សេចក្ដីប្រាថ្នាវត្ថុដែលបុគ្គល
មិនគប្បីបាន ជាហេតុនៃទុក្ខនោះ ព្រោះហេតុនោះ ទើបព្រះ
ជិនស្រីត្រាស់ការមិនបានតាមសេចក្ដីប្រាថ្នាថាជាទុក្ខ ដូច្នេះ ។

[ ១៥៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃឧបាទានក្ខន្ធដូចតទៅ

បទថា **សង្ខិត្តេន** នេះ ព្រះមានព្រះភាគត្រាស់ជាទេសនា ។ ពិតហើយ បុគ្គលណាម្នាក់ មិនអាចសង្ខេបទុក្ខបានថា ទុក្ខមាន ១០០ ឬថា ទុក្ខមាន ១០០០ តែទេសនាអាចសង្ខេបបាន ព្រោះហេតុនោះ កាលទ្រង់សង្ខេបទេសនាថា ឈ្មោះថា **ទុក្ខ** មិនមែនអ្វីដទៃ ដោយសង្ខេប ឧបាទានក្ខន្ធ ៥ ជាទុក្ខ ដូច្នេះ ទើបត្រាស់យ៉ាងនោះ ។ សព្ទថា **សេយ្យថីទំ** ជានិបាត ។ អត្ថនៃនិបាតនោះ មានអធិប្បាយថា បើមានបុគ្គលសួរថា ឧបាទានក្ខន្ធទាំង ៥ នោះ តើដូចម្ដេច ដូច្នេះ ។ អត្ថនៃបទថា **រូបូបាទានក្ខន្ធោ** ជាដើម ខ្ញុំបានពណ៌នាហើយ ក្នុងខន្ធវិភង្គ ។

ម្យ៉ាងទៀត គប្បីជ្រាបវិនិច្ឆ័យក្នុងខន្ធដោយអត្ថថាជាទុក្ខដូចតទៅនេះ
ព្រោះទុក្ខ មានជាតិជាដែនកើតឯណា ដែលព្រះពុទ្ធជាតាទិ

ត្រាស់ក្នុងលោកនេះ និងទុក្ខណា ដែលមិនបានត្រាស់ ទុក្ខទាំងអស់នោះ វៀរឧបាទានក្ខន្ធ ៥ ហើយ រមែងមិនមាន ហេតុនោះ ទើបព្រះមហេសី ទ្រង់សម្តែងនូវទីបំផុតនៃទុក្ខ ទើបត្រាស់ថា ដោយបង្រួញឧបាទានក្ខន្ធទាំង ៥ ក៏ជាទុក្ខ ដូច្នេះ ។

ពិតហើយ ជាតិជាដើម បៀតបៀននូវឧបាទានក្ខន្ធ ៥ នោះឯង ដោយប្រការផ្សេងៗ ដូចភ្លើងព្រៃបៀតបៀនកំញម ដូចគ្រឿងប្រហារ បៀតបៀនក្តារបន្ទោង ដូចរបោម និងមូសជាដើមបៀតបៀនគោ ដូចបុគ្គលអ្នកច្រូតស្រូវ បៀតបៀនស្រែ ដូចចោរប្លន់ស្រុក បៀតបៀនស្រុក រមែងកើតឡើងក្នុងឧបាទានក្ខន្ធ ៥ នោះឯង ដូចស្មៅ និងវល្លិជាដើម រមែងកើតឡើងត្រង់ផែនដី ដូចផ្កា និងផ្លែស្លឹកខ្ចីជាដើម កើតត្រង់ដើមឈើ ដូច្នោះ ។ ម្យ៉ាងទៀត ទុក្ខដែលជាខាងដើមនៃឧបាទានក្ខន្ធ គឺជាតិ ទុក្ខក្នុងកណ្តាល គឺជរា ទុក្ខក្នុងទីបំផុត គឺមរណៈ ព្រោះជួបនូវទុក្ខ មានការស្លាប់ជាទីបំផុត ទើបមានទុក្ខដុតរោល គឺសោក ព្រោះការអត់សង្កត់សេចក្តីសោកនោះមិនបាន ទើបមានទុក្ខ ជាហេតុយំរៀបរាប់ គឺបរិទេវៈ ។ បន្ទាប់អំពីនោះ ទុក្ខដែលបៀតបៀនកាយ ព្រោះប្រកបជាមួយផោដ្ឋារម្មណ៍ ដែលមិនគួរប្រាថ្នា ពោល គឺធាតុកម្រើក គឺទុក្ខ ។ ព្រោះការកើតបដិឃៈក្នុងឧបាទានក្ខន្ធនោះនៃបុថុជ្ជនដែលត្រូវទុក្ខកាយនោះបៀតបៀន ទើបមានទុក្ខដែលបៀតបៀនផ្លូវចិត្ត គឺទោមនស្ស ។ ទុក្ខ មានការតានតឹងក្នុងចិត្តនៃបុគ្គលដែលតានតឹង ក្នុងចិត្តកើតអំពី

សេចក្ដីចម្រើនរបស់សោកជាដើម គឺឧបាយាស ។ ទុក្ខ ព្រោះការអស់សង្ឃឹមនៃបុគ្គលដែលមនោរថ មិនបានសម្រេច គឺការមិនបានវត្ថុដែលខ្លួនប្រាថ្នា ហេតុនោះ ឧបាទានក្ខន្ធដែលបុគ្គលមានបញ្ញាចូលទៅពិចារណាដោយប្រការផ្សេងៗ យ៉ាងនេះឯង ឈ្មោះថា ជាទុក្ខ ព្រោះហេតុនោះ បុគ្គលណាម្នាក់ ប្រើពេលវេលាច្រើនកប្ប ក៏មិនអាចពោលទុក្ខដែលពោលសូម្បីត្រឹមតែមួយ ឲ្យអស់ទៅបាន ដើម្បីទ្រង់សម្ដែងសង្ខេបនូវទុក្ខទាំងអស់នោះ ទុក្ខក្នុងឧបាទានក្ខន្ធ ៥ ឯណាមួយ ដូចទ្រង់បង្រួមទឹកក្នុងមហាសមុទ្ទទាំងមូលឲ្យទៅជាទឹកតំណក់ ទើបព្រះមានព្រះភាគត្រាស់ថា **សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា** ដូច្នេះ ។

ទុក្ខសច្ចនិទ្ទេស ចប់

# សមុទយសច្ចនិទ្ទេស

[ ១៥៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសមុទយសច្ចនិទ្ទេសដូចតទៅ

បទថា **យាយំ តណ្ហា** កាត់បទជា **យា អយំ តណ្ហា** ។ បទថា **បោនោព្ភវិកា** មានវិគ្គហៈថា ហេតុធ្វើនូវភពថ្មី ឈ្មោះថា **បុនព្ភវ** ហេតុធ្វើនូវភពថ្មី ជាប្រក្រតីរបស់តណ្ហានោះមាន ព្រោះហេតុនោះ ទើបតណ្ហានោះ ឈ្មោះថា **បោនោព្ភវា** គឺជាហេតុកើតក្នុងភពថ្មី ម្យ៉ាងទៀត តណ្ហាណា រមែងឲ្យនូវភពថ្មី រមែងប្រព្រឹត្តទៅព្រម ដើម្បីភពថ្មី រមែងឲ្យកើតក្នុងភពរឿយៗ ព្រោះហេតុនោះ ទើបតណ្ហានោះ ឈ្មោះថា **បោនោព្ភវា** ។ ម្យ៉ាងទៀត តណ្ហានោះ ជាធម្មជាតឲ្យនូវភពថ្មីក៏មាន មិនឲ្យភពថ្មីក៏មាន ប្រព្រឹត្តទៅដើម្បីភពថ្មីក៏មាន មិនប្រព្រឹត្តទៅដើម្បីភពថ្មីក៏មាន គ្រាន់តែឲ្យឧបធិក្នុងកាលតណ្ហានោះ ឲ្យបដិសន្ធិហើយក៏មាន តណ្ហានោះ កាលឲ្យនូវភពថ្មីក្តី មិនឲ្យក្តី ប្រព្រឹត្តទៅដើម្បីភពថ្មីក្តី មិនប្រព្រឹត្តទៅដើម្បីភពថ្មីក្តី ឲ្យនូវឧបធិក្នុងកាលតណ្ហាឲ្យបដិសន្ធិហើយក្តី បានឈ្មោះថា **បោនោព្ភវិកា** ដូចគ្នា ។

ដែលឈ្មោះថា **នន្ទិរាគសហគតា** ព្រោះអត្ថថា ទៅព្រមជាមួយនន្ទិ-រាគៈ ពោល គឺសេចក្តីត្រេកអរក្រៃលែង មានពាក្យអធិប្បាយថា ទៅកាន់ភាពតែមួយដោយអត្ថជាមួយនន្ទិរាគៈនោះឯង ។ បទថា **តត្រតត្រា ភិនន្ទិនី** បានដល់ ភាពជាអត្តា មាននៅក្នុងទីណាមួយ ក៏មានការត្រេកអរក្រៃលែងក្នុងទីនោះៗ ឬថា មានការត្រេកអរក្នុងអារម្មណ៍ មានរូបជាដើមនោះៗ

អធិប្បាយថា មានសេចក្តីត្រេកអរក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និង ធម្មារម្មណ៍ ។

សព្ទថា **សេយ្យថីទំ** ជានិបាត អត្ថនៃសព្ទថា **សេយ្យថីទំ** នោះថា បើមានពាក្យសួរថា តណ្ហានោះ ដូចម្តេច ។

បទថា **កាមតណ្ហា** មានវិគ្គហៈថា តណ្ហាក្នុងកាម ឈ្មោះថា **កាម-តណ្ហា** ។ ពាក្យថា **កាមតណ្ហា** នេះ ជាឈ្មោះនៃរាគៈដែលប្រកបដោយកាមគុណ ៥ ។ តណ្ហាក្នុងភព ឈ្មោះថា **ភវតណ្ហា** ។ ពាក្យថា ភវតណ្ហា នេះ ជាឈ្មោះនៃរាគៈក្នុងរូបភព អរូបភព និងការពេញចិត្តក្នុងឈានដែលសហគតៈដោយសស្សតទិដ្ឋិដែលកើតឡើងហើយ ដោយអំណាចប្រាថ្នាភព ។ តណ្ហាក្នុងការប្រាសចាកនៃភព ឈ្មោះថា **វិភវតណ្ហា** ។ ពាក្យថា **វិភវ-តណ្ហា** នេះ ជាឈ្មោះនៃរាគៈដែលសហគតៈដោយឧច្ឆេទទិដ្ឋិ ។

[ ១៥៩ ] ឥឡូវនេះ ព្រះមានព្រះភាគដើម្បីទ្រង់សម្តែងទីតាំងនៃតណ្ហានោះដោយពិស្តារ ទើបត្រាស់ពាក្យជាដើមថា **សា ខោ បនេសា** ។ ក្នុងព្រះបាលីនោះ បទថា **ឧប្បជ្ជតិ** បានដល់ រមែងកើត ។ បទថា **និវិសតិ** បានដល់ រមែងតាំងមាំដោយអំណាចការប្រព្រឹត្តទៅរឿយៗ ។ បទថា **យំ លោកេ បិយរូបំ សាតរូបំ** បានដល់ វត្ថុណាជាសភាវៈគួរស្រឡាញ់ និងជាសភាវៈផ្អែមល្ហែមក្នុងលោក ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទជាដើមថា **ចក្ខុំ លោកេ** ដូចតទៅនេះថា ពិតហើយ សត្វទាំងឡាយប្រកាន់មាំក្នុងចក្ខុជាដើម ដោយភាពជារបស់អញ ជា

ខ្លួនរបស់អញ ក្នុងលោក តាំងមាំក្នុងសម្បត្តិហើយ រមែងសម្គាល់ចក្ខុរបស់ខ្លួនជាដើម ថាជាបសាទ ៥ ដែលផូរផង់ដោយទំនងនៃការកាន់យកនិមិត្តក្នុងកញ្ចក់ជាដើម ដូចសីហបញ្ជរកែវមណី ដែលបើកក្នុងវិមានមាស រមែងសម្គាល់សោតៈ ដូចជាឡូតប្រាក់ និងដូចខ្សែស្ពាន់ រមែងសម្គាល់ឃានៈដែលបានពោលហាវថា មានច្រមុះកោង ដូចក្លែបហរតាលដែលលញ់តម្កល់ទុក រមែងសម្គាល់ជិវ្ហាដែលទន់ ឲ្យនូវសេចក្ដីស្និទ្ធ ឆ្ងាញ់ ដូចសំពត់កម្ពលក្រហម រមែងសម្គាល់កាយដូចសសរខ្លឹម និងដូចសសរមាស រមែងសម្គាល់ចិត្តថាឧឡារ មិនដូចចិត្តរបស់ជនដទៃ រមែងសម្គាល់រូប ដូចពណ៌មាស និងពណ៌ផ្កាកណិការជាដើម រមែងសម្គាល់សំឡេង ដូចសំឡេងរងាវរបស់ករ-វិកបក្សី និងដូចតាវៅដែលកំពុងត្រេកអរ និងដូចសំឡេងខ្លុយកែវមណីដែលផ្លុំល្វើយៗ រមែងសម្គាល់អារម្មណ៍ មានក្លិនជាដើម ដែលកើតអំពីសមុដ្ឋាន ៤ ដែលខ្លួនបានចំពោះហើយថា បុគ្គលដទៃណាសោត មានអារម្មណ៍បែបនេះ ។ កាលជនទាំងនោះសម្គាល់យ៉ាងនេះ អាយតនៈទាំងនោះ មានចក្ខុជាដើម ក៏រមែងជាបិយរូប និងសាតរូប កាលបើដូច្នោះ តណ្ហារបស់ជនទាំងនោះដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងក្នុងចក្ខុជាដើមនោះ ដែលកើតហើយ ក៏រមែងតាំងមាំដោយអំណាចដែលប្រព្រឹត្តទៅរឿយៗ ព្រោះហេតុនោះទើបព្រះមានព្រះភាគត្រាស់បទជាដើមថា **ចក្ខុំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ** ចក្ខុ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតក្នុង

ចក្ខុំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧប្បជ្ជមានា** សេចក្ដីថា កាលណាតណ្ហារមែងកើត កាលនោះ ក៏រមែងកើតក្នុងចក្ខុនេះ ។ ក្នុងបទទាំងពួងក៏ន័យនេះឯង ។

អដ្ឋកថាសមុទយសច្ចនិទ្ទេស ចប់

## និរោធសច្ចនិទ្ទេស

[ ១៦០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិរោធសច្ចនិទ្ទេសដូចតទៅ

ក្នុងបទថា **យោ តស្សាយេវ តណ្ហាយ** សេចក្ដីថា កាលព្រះមានព្រះភាគគួរត្រាស់ថា **យោ តស្សេវ ទុក្ខស្ស** តែព្រោះទុក្ខរលត់ទៅ ព្រោះការរលត់សមុទយៈ មិនមែនរលត់ដោយប្រការដទៃ ដូចព្រះតម្រាស់ថា

កាលបើឫសឈើមិនមានសេចក្ដីអន្តរាយ នៅមាំមួនទេ ដើមឈើទុកជាកាប់ចោលហើយ ក៏តែងដុះឡើងទៀតបាន មានឧបមាដូចម្ដេចមិញ កាលបើតណ្ហានុសយ បុគ្គលកម្ចាត់មិនទាន់បានហើយ ទុក្ខ ( មានជាតិទុក្ខជាដើម ) នេះ ក៏តែងកើតរឿយៗ មានឧបមេយ្យដូច្នោះឯង ដូច្នេះ ។

ហេតុនោះ កាលទ្រង់សម្ដែងការរម្ងត់ទុក្ខនោះ ទើបត្រាស់ទុក្ខយ៉ាងនេះ

ដើម្បីទ្រង់សម្តែងដោយការរម្ងត់សមុទយៈ ។ ពិតហើយ ព្រះតថាគតទាំងឡាយ ទ្រង់ប្រព្រឹត្តប្រៀបដូចសីហរាជ ព្រះតថាគតទាំងឡាយ កាលទ្រង់រម្ងត់ទុក្ខ និងកាលទ្រង់សម្តែងការរម្ងត់ទុក្ខ រមែងបដិបត្តិក្នុងហេតុមិនមែនក្នុងផល តែពួកតិត្ថិយ មានការប្រព្រឹត្តប្រៀបដូចសុនខ ពួកជនទាំងនោះ កាលរម្ងត់ទុក្ខក្តី កាលនឹងសម្តែងការរម្ងត់ទុក្ខក្តី រមែងបដិបត្តិក្នុងផល ដោយប្រកបការព្យាយាមក្នុងការធ្វើខ្លួនឲ្យលំបាក ( អត្តកិលមថានុយោគ ) និងដោយការសម្តែងការប្រកបសេចក្តីព្យាយាម ក្នុងការធ្វើខ្លួនឲ្យលំបាកនោះឯង មិនបដិបត្តិក្នុងហេតុ ព្រោះហេតុនោះ ព្រះសាស្តា ដែលបដិបត្តិក្នុងហេតុ ព្រោះទ្រង់ប្រព្រឹត្តដូចសីហៈ ទើបត្រាស់ពាក្យជាដើមថា **យោ តស្សាយេវ** ដូច្នេះ ។

ក្នុងព្រះបាលីនោះ បទថា **តស្សាយេវ** បានដល់ នៃតណ្ហានោះឯង ដែលទ្រង់បានប្រកាសខាងដើម ដោយអំណាចនៃការកើត និងការតាំងមាំ ។ ក្នុងបទថា **អសេសវិរាគនិរោធោ** ជាដើម បទទាំងអស់នេះជាវេវចនៈនៃព្រះនិព្វាន ព្រោះអាស្រ័យព្រះនិព្វាន ។ តណ្ហាដល់និព្វានហើយ រមែងប្រាសទៅ រមែងរលត់ដោយមិនសេសសល់ ព្រោះហេតុនោះ ទើបព្រះនិព្វាននោះ ព្រះមានព្រះភាគត្រាស់ថា **អសេសវិរាគនិរោធោ** ដូច្នេះ ។ តណ្ហា ដល់ព្រះនិព្វានហើយ រមែងត្រូវលះបង់ ត្រូវទម្លាក់ចោល ត្រូវជម្រុះចោល ត្រូវមិនមានអាល័យ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ហៅនិព្វានថា **ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ** ដូច្នេះ ។

សេចក្ដីពិត ព្រះនិព្វានមានតែម្យ៉ាងប៉ុណ្ណោះ តែព្រះនិព្វាននោះ មានឈ្មោះហៅជំនួសព្រះនិព្វានជាអនេក ដោយអំណាចនៃឈ្មោះដែលជាបដិបក្ខចំពោះសង្ខតធម៌ទាំងអស់ ឈ្មោះទាំងនោះ ដូចម្ដេច គឺឈ្មោះមានជាដើមថា **អសេសតោ វិរាគោ** គឺការប្រាសចាករាគៈដោយមិនមានសេសសល់ ១ **និរោធោ** គឺការរម្ងត់ ១ **ចាគោ** គឺការលះបង់ ១ **បដិនិស្សគ្គោ** គឺការលោះបង់ចោល ១ **មុត្តិ** គឺការរួចផុត ១ **អនាលយោ** គឺការមិនមានអាល័យ ១ **រាគក្ខយោ** គឺអស់នូវរាគៈ ១ **ទោសក្ខយោ** គឺការអស់នូវទោសៈ ១ **មោហក្ខយោ** គឺការអស់នូវមោហៈ ១ **តណ្ហក្ខយោ** គឺការអស់នូវតណ្ហា ១ **អនុប្បាទោ** គឺការមិនកើតឡើង ១ **អប្បវត្តំ** គឺការមិនប្រព្រឹត្តទៅ ១ **អនិមិត្តំ** គឺការមិនមានគ្រឿងសម្គាល់ ១ **អប្បណិហិតំ** គឺការមិនមានទីតាំង ១ **អនាយូហនំ** គឺការមិនប្រមូលមក ១ **អប្បដិសន្ធិ** គឺការមិនមានបដិសន្ធិ ១ **អប្បដិវត្តិ** គឺការមិនត្រឡប់ ១ **អគតិ** គឺការមិនមានគតិ ១ **អជាតំ** គឺការមិនកើត ១ **អជរំ** គឺការមិនចាស់ ១ **អព្យាធិ** គឺការមិនឈឺ ១ **អមតំ** គឺការមិនស្លាប់ ១ **អសោកំ** គឺការមិនសោក ១ **អបរិទេវំ** គឺការមិនមានបរិទេវៈ ១ **អនុបាយាសំ** គឺការមិនមានឧបាយាស ១ **អសង្កិលិដ្ឋំ** គឺការមិនសៅហ្មង ១ ៗ

[ ១៦១ ] ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់សម្ដែងការមិនមាននៃតណ្ហាដែលមគ្គកាត់ហើយ និងដែលដល់ព្រះនិព្វានហើយ ក៏ដល់នូវការមិនប្រព្រឹត្តទៅក្នុងវត្ថុដែលជាទីតាំង ដែលទ្រង់សម្ដែងការកើតឡើងនៃតណ្ហានោះ

នោះឯង ទើបត្រាស់ថា **សា ខោ បនេសា** ដូច្នេះជាដើម ។

ក្នុងព្រះតម្រាស់នោះ មានវិនិច្ឆ័យដូចតទៅនេះ

បុរសឃើញនទោងព្រៃកើតក្នុងស្រែហើយ គប្បីស្វែងរកឫស តាំងអំពីត្រួយទៅ ហើយក៏កាត់នទោងព្រៃនោះក៏ក្រៀមស្វិត តាមលំដាប់ ដល់នូវការមិនមានបញ្ញត្តិ បន្ទាប់អំពីនោះ នទោងព្រៃក្នុងស្រែនោះ បុគ្គលក៏គប្បីពោលបានថា អន្តរធានទៅហើយ ត្រូវទម្លាយហើយ យ៉ាងណា តណ្ហាក្នុងអារម្មណ៍ទាំងឡាយ មានចក្ខុជាដើម ក៏យ៉ាងនោះដូចគ្នា ដូចនទោងព្រៃក្នុងស្រែ តណ្ហានោះត្រូវអរិយមគ្គកាត់ឫសហើយ ដល់ព្រះនិព្វានហើយ ក៏ដល់នូវការប្រព្រឹត្តទៅមិនបាន ។ តណ្ហានោះ ដល់នូវការប្រព្រឹត្តទៅយ៉ាងនេះ ក៏រមែងមិនប្រាកដក្នុងវត្ថុទីតាំងទាំងនោះ ដូចនទោងព្រៃក្នុងស្រែ មិនប្រាកដដូច្នោះ ។

ម្យ៉ាងទៀត ពួករាជបុរសនាំពួកចោរមកអំពីព្រៃហើយ គប្បីប្រហារជីវិតត្រង់ទ្វារទិសទក្សិណនៃព្រះនគរ បន្ទាប់អំពីនោះ បុគ្គលណាម្នាក់ ក៏គប្បីពោលថា ចោរក្នុងព្រៃស្លាប់ហើយ ឬចោរត្រូវរាជបុរសសម្លាប់ហើយ យ៉ាងណា តណ្ហាក្នុងចក្ខុជាដើម ក៏ដូចពួកចោរក្នុងព្រៃយ៉ាងនោះដូចគ្នា ឈ្មោះថារលត់ទៅហើយក្នុងព្រះនិព្វាន ព្រោះដល់និព្វានហើយ ក៏រលត់ទៅ ដូចពួកចោរ ត្រូវប្រហារត្រង់ទ្វារទិសទក្សិណ ។ តណ្ហានោះ ដែលរលត់ហើយយ៉ាងនេះ រមែងមិនប្រាកដក្នុងវត្ថុទីតាំងទាំងនោះ ដូចពួកចោរមិនប្រាកដក្នុងព្រៃដូច្នោះ ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងការរលត់តណ្ហា

នោះ ក្នុងចក្ខុជាដើមនោះឯង ទើបត្រាស់ពាក្យជាដើមថា **ចក្ខុំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ** ចក្ខុមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងចក្ខុនុ៎ះ កាលរលត់ រមែងរលត់ក្នុងចក្ខុនុ៎ះ ដូច្នេះ ។ ពាក្យដ៏សេសក្នុងនិទ្ទេសនេះ មានអត្ថងាយយល់ហើយ ។

អដ្ឋកថានិរោធសច្ចនិទ្ទេស ចប់

# មគ្គសច្ចនិទ្ទេស

[ ១៦២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមគ្គសច្ចនិទ្ទេសដូចតទៅ

បទថា **អយមេវ** ជាពាក្យកំណត់ពិតប្រាកដ ដើម្បីបដិសេធមគ្គដទៃ ។ បទថា **អរិយោ** បានដល់ ឈ្មោះថា **អរិយ** ព្រោះឆ្ងាយចាកកិលេសទាំងឡាយដែលសម្លាប់ដោយមគ្គនោះៗ ព្រោះធ្វើនូវភាពជាអរិយៈ និងព្រោះធ្វើឲ្យបានចំពោះនូវអរិយផល ។ អង្គ ៨ របស់មគ្គនោះមាន ព្រោះហេតុនោះទើបមគ្គនោះ ឈ្មោះថា **អដ្ឋង្គិកោ** ។ អង្គ ៨ របស់មគ្គនោះ ត្រឹមតែជាអង្គប៉ុណ្ណោះ ដូចសេនាមានអង្គ ៤ និងតន្ត្រីមានអង្គ ៥ ផុតចាកអង្គ មិនមាន ។ ដែលឈ្មោះថា **មគ្គ** ព្រោះអត្ថថា ជាវត្ថុដែលបុគ្គលត្រូវការព្រះនិព្វានគប្បី

ស្វែងរក ឬស្វែងរកនូវព្រះនិព្វាន ឬសម្លាប់កិលេសទាំងឡាយ ត្រាច់ទៅ ។ សព្ទថា **សេយ្យថីទំ** សេចក្តីថា បើមានអ្នកសួរថា អដ្ឋមគ្គនោះ តើដូចម្តេច ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងថា **មគ្គ** ក៏គឺអង្គប្រកបនោះឯង មគ្គដែលផុតចាកអង្គប្រកប រមែងមិនមាន ទើបត្រាស់ថា **សម្មា-ទិដ្ឋិ ។បេ។ សម្មាសមាធិ** ដូច្នេះ ។ បណ្តាអដ្ឋមគ្គទាំង ៨ នោះ សម្មាទិដ្ឋិមានការឃើញដោយប្រពៃជាលក្ខណៈ សម្មាសង្កប្ប មានការលើកសម្ប-យុត្តធម៌ឡើងដោយប្រពៃជាលក្ខណៈ សម្មាវាចា មានការកំណត់កាន់យកដោយប្រពៃជាលក្ខណៈ សម្មាកម្មន្តៈ មានការឲ្យការងារតាំងឡើងដោយប្រពៃជាលក្ខណៈ សម្មាអាជីវៈ មានអាជីវៈដែលផូរផង់ហើយដោយប្រពៃជាលក្ខណៈ សម្មាវាយាមៈ មានការផ្គងទុកដោយប្រពៃជាលក្ខណៈ សម្មា-សតិ មានការប្រាកដដោយប្រពៃជាលក្ខណៈ សម្មាសមាធិ មានការតាំងចិត្តមាំដោយប្រពៃជាលក្ខណៈ ដូច្នេះ ។

បណ្តាអដ្ឋមគ្គ ៨ នោះ អង្គនីមួយៗ មានកិច្ច ៣ សេចក្តីនេះ ដូចម្តេច យើងនឹងអធិប្បាយសម្មាទិដ្ឋិមុន សម្មាទិដ្ឋិរមែងលះមិច្ឆាទិដ្ឋិ និងកិលេសដែលជាសត្រូវរបស់ខ្លួនដទៃៗ បាន ១ រមែងធ្វើនិរោធឲ្យជាអារម្មណ៍ ១ រមែងឃើញសម្បយុត្តធម៌ទាំងឡាយ ព្រោះមិនរវើរវាយដោយអំណាចកម្ចាត់មោហៈដែលបិទបាំងសម្បយុត្តធម៌នោះៗ បាន ១ សម្មាសង្កប្បជាដើម ក៏យ៉ាងនោះដូចគ្នា រមែងលះមិច្ឆាសង្កប្បជាដើម រមែងធ្វើនិរោធឲ្យជាអារម្មណ៍ តែក្នុងសម្មាសង្កប្បជាដើមនេះ ពោលដោយការប្លែកគ្នា សម្មាសង្កប្ប រមែងលើក

ឡើងនូវសហជាតធម៌ សម្មាវាចា រមែងកំណត់កាន់យកដោយប្រពៃ សម្មា-កម្មន្តៈ រមែងញុំាងការងារឲ្យតាំងឡើងដោយប្រពៃ សម្មាអាជីវៈ រមែងឲ្យអាជីវៈផូរផង់ហើយដោយប្រពៃ សម្មាវាយាមៈ រមែងផ្គងដោយប្រពៃ សម្មាសតិ រមែងប្រាកដដោយប្រពៃ សម្មាសមាធិ រមែងតាំងមាំដោយប្រពៃ ដូច្នេះ ។ម្យ៉ាងទៀត ឈ្មោះថា សម្មាទិដ្ឋិនេះ ក្នុងចំណែកខាងដើម ( លោកិយមគ្គ ) មានខណៈផ្សេងគ្នា មានអារម្មណ៍ផ្សេងគ្នា ក្នុងកាលនៃមគ្គមានខណៈតែមួយ មានអារម្មណ៍តែមួយ បើពោលដោយកិច្ច រមែងបានឈ្មោះ ៤ យ៉ាង មាន **ទុក្ខេញាណំ** ញាណដឹងក្នុងទុក្ខជាដើម ។ សម្មា-សង្កប្បជាដើម ក្នុងចំណែកខាងដើម មានខណៈផ្សេងគ្នា មានអារម្មណ៍ផ្សេងគ្នា ក្នុងកាលនៃមគ្គមានខណៈតែមួយ មានអារម្មណ៍តែមួយ ។ បណ្ដាអង្គមគ្គ ៧ មានសម្មាសង្កប្បជាដើមនោះ ពោលដោយកិច្ច សម្មាសង្កប្បរមែងបានឈ្មោះ ៣ យ៉ាងថា នេក្ខម្មសង្កប្បជាដើម ។ អង្គមគ្គ ៣ មានសម្មាវាចាជាដើម ក្នុងចំណែកខាងដើម មានខណៈផ្សេងគ្នា មានអារម្មណ៍ផ្សេងគ្នា គឺរមែងជាវិរតិខ្លះ ជាចេតនាខ្លះ ក្នុងខណៈនៃមគ្គ ជាវិរតិតែម្យ៉ាង ។ អង្គមគ្គ ២ គឺសម្មាវាយាមៈ ១ សម្មាសតិ ១ បើពោលដោយកិច្ច រមែងបានឈ្មោះ ៤ យ៉ាង តាមសម្មប្បធាន និងសតិប្បដ្ឋាន ឯសម្មាសមាធិ ក្នុងចំណែកខាងដើមក្ដី ក្នុងខណៈនៃមគ្គក្ដី ក៏ឈ្មោះថា សម្មាសមាធិដដែលនោះឯង ។

ក្នុងធម៌ ៨ តាមដែលសម្ដែងមកនេះ ព្រះមានព្រះភាគ ទ្រង់សម្ដែង

សម្មាទិដ្ឋិមុន ព្រោះជាធម៌មានឧបការៈច្រើន ដល់ព្រះយោគី ដែលបដិបត្តិ ដើម្បីសម្រេចព្រះនិព្វាន ព្រោះសម្មាទិដ្ឋិនេះ ទ្រង់ត្រាស់ហៅថា គ្រឿងបំភ្លឺ គឺបញ្ញា សត្ថា គឺបញ្ញាជាដើម ហេតុនោះ ព្រះយោគាវចរដែលទម្លាយងងឹត គឺអវិជ្ជាដោយសម្មាទិដ្ឋិ ពោលគឺវិបស្សនាញាណក្នុងកាលខាងដើមនេះហើយ សម្លាប់ចោរ គឺកិលេស រមែងសម្រេចព្រះនិព្វានបាន ដោយផុតភ័យ ដោយហេតុនោះ ទើបខ្ញុំពោលថា ព្រះមានព្រះភាគទ្រង់សម្ដែងសម្មាទិដ្ឋិមុន ព្រោះជាធម៌មានឧបការៈច្រើន ដល់ព្រះយោគាវចរ ដែលបដិបត្តិ ដើម្បីសម្រេចព្រះនិព្វាន ដូច្នេះ ។

ឯសម្មាសង្កប្ប ជាធម៌មានឧបការៈច្រើនដល់សម្មាទិដ្ឋិនោះ ព្រោះហេតុនោះ ទើបត្រាស់ក្នុងលំដាប់នៃសម្មាទិដ្ឋិនោះ ប្រៀបដូចហិរញ្ញិក ប្រើដៃត្រឡប់ប្រាក់ទៅមក ពិនិត្យមើលកហាបណៈ ដោយភ្នែក រមែងដឹងថា កហាបណៈនេះក្លែងក្លាយ កហាបណៈនេះពិតយ៉ាងណា ព្រះយោគាវចរក៏យ៉ាង នោះ ប្រើវិតក្កត្រិះរិះហើយត្រិះរិះទៀត ក្នុងចំណែកខាងដើម ហើយពិនិត្យមើលដោយវិបស្សនាបញ្ញា ក៏ដឹងបានថា ធម៌ទាំងនេះជាកាមាវចរ ធម៌ទាំងនេះជារូបាវចរជាដើម ឬប្រៀបដូចជាងឈើប្រើកាំបិតចាំងឈើធំ ដែលបុរសចាប់ត្រង់ចុងប្រមៀលទៅមកដោយជុំវិញឲ្យហើយ រមែងនាំទៅប្រើក្នុងការងារបានយ៉ាងណា ព្រះយោគាវចរ ក៏យ៉ាងនោះ កំណត់ធម៌ទាំងឡាយ ដែលវិតក្កត្រិះរិះហើយ ឲ្យហើយ ដោយន័យជាដើមថា ធម៌ទាំងនេះជាកាមាវចរ ធម៌ទាំងនេះជារូបាវចរ ដោយបញ្ញាហើយ រមែងបង្អោនទៅក្នុងការងារបាន

ព្រោះហេតុនោះ ទើបពោលថា សម្មាសង្កប្ប ជាធម៌មានឧបការៈច្រើនដល់សម្មាទិដ្ឋិនោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ក្នុងលំដាប់នៃសម្មាទិដ្ឋិនោះ ។

សម្មាសង្កប្បនេះ ជាធម៌មានឧបការៈច្រើន ដល់សម្មាវាចា ដូចមានឧបការៈច្រើនដល់សម្មាទិដ្ឋិ ដូចព្រះតម្រាស់ដែលត្រាស់ ( ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ ) ថា ម្នាលគហបតី បុគ្គលត្រិះរិះពិចារណាជាមុនហើយ ទើបបញ្ចេញនូវវាចាជាខាងក្រោយ ដូច្នេះ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់សម្មាវាចា ក្នុងលំដាប់នៃសម្មាសង្កប្បនោះ ។

ម្យ៉ាងទៀត ព្រោះជនទាំងឡាយចាត់ចែងដោយវាចាមុនថា ពួកយើងនឹងធ្វើវត្ថុនេះមួយៗ ហើយទើបប្រកបការងារក្នុងលោក ហេតុនោះ ទើបវាចាជាធម៌មានឧបការៈច្រើន ដល់កាយកម្ម ព្រោះហេតុនោះ ទើបទ្រង់ត្រាស់សម្មាកម្មន្តៈ ក្នុងលំដាប់នៃសម្មាវាចា ។

ម្យ៉ាងទៀត ព្រោះអាជីវដ្ឋមកសីល គឺសីល មានអាជីវៈជាគម្រប់ ៨ រមែងពេញបរិបូណ៌ដល់បុគ្គលដែលលះវចីទុច្ចរិត ៤ កាយទុច្ចរិត ៣ ញុំាងសុចរិត ២ ឲ្យបរិបូណ៌នោះឯង មិនមែនពេញបរិបូណ៌ដល់បុគ្គលក្រៅអំពីនេះឡើយ ព្រោះហេតុនោះ ទើបទ្រង់តាស់សម្មាអាជីវៈក្នុងលំដាប់សុចរិតទាំង ២ នោះ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងថា បុគ្គលមានអាជីវៈបរិសុទ្ធហើយយ៉ាងនេះ មិនសមគួរពេញចិត្តត្រឹមប៉ុណ្ណេះ ហើយប្រមាទដូចបុគ្គលដេកលក់

ដោយគិតថា អាជីវៈរបស់អញបរិសុទ្ធហើយដោយពិត គួរផ្ដើមព្យាយាម គ្រប់ឥរិយាបថ ទើបទ្រង់ត្រាស់សម្មាវាយាមៈ ក្នុងលំដាប់សម្មាអាជីវៈនោះ ។

បន្ទាប់អំពីនោះ ដើម្បីទ្រង់សម្ដែងថា ព្រះយោគាវចរមានការព្យាយាម ផ្ដើមហើយ ក៏គប្បីធ្វើសតិឲ្យតាំងមាំយ៉ាងល្អ ក្នុងវត្ថុ ៤ មានកាយជាដើម ទើបទ្រង់សម្ដែងសម្មាសតិ ក្នុងលំដាប់នៃសម្មាវាយាមៈនោះ ។

ម្យ៉ាងទៀត ព្រោះសតិតាំងមាំល្អយ៉ាងនេះហើយ ក៏គួរត្រួតមើលគតិទាំង ឡាយនៃធម៌ទាំងឡាយ ដែលមានឧបការៈ និងមិនមានឧបការៈដល់សមាធិ ទើបគ្រប់គ្រាន់ដើម្បីនឹងតាំងចិត្តមាំ ក្នុងអារម្មណ៍ជាឯកគ្គតាបាន ហេតុនោះ គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់សម្ដែងសម្មាសមាធិ ក្នុងលំដាប់សម្មាសតិ ដូច្នេះ ។

[ ១៦៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មាទិដ្ឋិនិទ្ទេសដូចតទៅ

ព្រះមានព្រះភាគ ទ្រង់សម្ដែងកម្មដ្ឋានក្នុងសច្ចៈ ៤ ដោយព្រះតម្រាស់ មានជាដើមថា **ទុក្ខេញាណំ** ដូច្នេះ បណ្ដាសច្ចៈទាំង ៤ នោះ សច្ចៈ ២ ខាងដើមជាវដ្ដៈ សច្ចៈ ២ ខាងចុងជាវិវដ្ដៈ ក្នុងសច្ចៈដែលជាវដ្ដៈ និងវិវដ្ដៈ ទាំងនោះ ភិក្ខុរមែងមានការប្រកាន់មាំកម្មដ្ឋានក្នុងសច្ចៈដែលជាវដ្ដៈ មិនមាន ការប្រកាន់មាំក្នុងសច្ចៈដែលជាវិវដ្ដៈ ។ ពិតហើយ ព្រះយោគាវចររៀនទូវ សច្ចៈ ២ ខាងដើម ក្នុងសម្នាក់របស់អាចារ្យដោយសង្ខេបយ៉ាងនេះថា ខន្ធ ៥ ជាទុក្ខ តណ្ហាជាសមុទយៈ ដូច្នេះ និងដោយពិស្ដារ តាមន័យជាដើមថា ខន្ធ ៥ ដូចម្ដេច គឺរូបក្ខន្ធ ដូច្នេះហើយ ទន្ទេញដោយវាចារឿយៗ រមែង

បំពេញព្យាយាម ។ តែក្នុងសច្ចៈ ២ ក្រៅអំពីនេះ ព្រះយោគាវចរ រមែងធ្វើបំពេញព្យាយាម ដោយការស្តាប់យ៉ាងនេះថា និរោធសច្ចគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត មគ្គសច្ច គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត កាលលោកបំពេញព្យាយាមយ៉ាងនេះ រមែងចាក់ធ្លុះសច្ចៈទាំង ៤ បានដោយការចាក់ធ្លុះតែម្តងដូចគ្នា រមែងត្រាស់ដឹងដោយការត្រាស់ដឹង ក្នុងគ្រាតែមួយ គឺចាក់ធ្លុះនូវទុក្ខ ដោយការចាក់ធ្លុះ គឺការកំណត់ដឹង រមែងចាក់ធ្លុះសមុទយៈ ដោយការចាក់ធ្លុះ គឺការលះ រមែងចាក់ធ្លុះនិរោធ ដោយការចាក់ធ្លុះ គឺការធ្វើឲ្យជាក់ច្បាស់ រមែងចាក់ធ្លុះមគ្គ ដោយការចាក់ធ្លុះ គឺការចម្រើន រមែងត្រាស់ដឹងទុក្ខ ដោយការត្រាស់ដឹង គឺការកំណត់ដឹង ។បេ។ រមែងត្រាស់ដឹងមគ្គ ដោយការត្រាស់ដឹង គឺការចម្រើន ។

ក្នុងកាលជាចំណែកខាងដើម ព្រះយោគាវចរ មានការចាក់ធ្លុះដោយការរៀន ការសាកសួរ ការស្តាប់ ការទ្រទ្រង់ចាំ និងការពិចារណាក្នុងសច្ចៈ ២ ( ខាងដើម ) រមែងមានការចាក់ធ្លុះបាន ដោយការស្តាប់តែម្យ៉ាង ក្នុងសច្ចៈ ២ ( ខាងចុង ) ក្នុងកាលតមក រមែងមានការចាក់ធ្លុះដោយកិច្ច ក្នុងសច្ចៈ ៣ រមែងចាក់ធ្លុះដោយអារម្មណ៍ ក្នុងនិរោធ ក្នុងការចាក់ធ្លុះដោយកិច្ច និងដោយអារម្មណ៍ ។ បដិវេធញ្ញាណទាំងអស់ ជាលោកុត្តរ ញាណក្នុងការស្តាប់ ការចាំ និងការពិចារណា ជាលោកិយ ខាងកាមាវចរ ។ ឯបច្ចវេក្ខណញ្ញាណ រមែងមានដល់ព្រះយោគាវចរ ដែលបានមគ្គសច្ច និងព្រះយោគាវចរដែលជាអាទិកម្មិកបុគ្គល ព្រោះហេតុនោះ ទើបបច្ចវេក្ខណញ្ញាណនោះ ខ្ញុំមិនបាន

ពោលក្នុងទីនេះ ។ម្យ៉ាងទៀត ការក្ដួចចិត្ត ការដាក់ចិត្ត កិរិយាមនសិការ និងការពិចារណាថា អញនឹងកំណត់ដឹងទុក្ខ នឹងលះសមុទយៈ នឹងធ្វើនិរោធឲ្យជាក់ច្បាស់ នឹងចម្រើននូវមគ្គ រមែងមិនមានដល់ភិក្ខុនេះ ដែលកំណត់ខាងដើម តែរមែងមានខាងក្រោយអំពីការកំណត់កាន់យក ។ ចំណែកក្នុងកាលតមក ទុក្ខ ឈ្មោះថា លោកកំណត់ដឹងហើយដោយពិត ។បេ។ មគ្គក៏ឈ្មោះថា លោកចម្រើនហើយដូចគ្នា ។

បណ្ដាសច្ចៈទាំងនោះ សច្ចៈ ២ ជាធម៌ជ្រាលជ្រៅ ព្រោះសត្វឃើញបានលំបាក សច្ចៈ ២ ដែលឈ្មោះថាឃើញបានលំបាក ព្រោះជ្រាលជ្រៅ ។ ពិតហើយ ទុក្ខសច្ចជារបស់ប្រាកដច្បាស់ ព្រោះការកើតឡើង រមែងដល់នូវពាក្យដែលបុគ្គលគប្បីពោលថា ទុក្ខហ្ន៎ ក្នុងពេលជង់ជង្គត់ ឬមុតបន្លាជាដើម ។ សូម្បីសមុទយៈ ក៏ប្រាកដដោយការកើតឡើង ដោយអំណាចនៃបុគ្គលដែលបំណងនឹងទំពា ឬបរិភោគជាដើម សច្ចៈទាំង ២ នោះ ពោលដោយការចាក់ចុះលក្ខណៈ ក៏ជាធម៌ជ្រាលជ្រៅ ។ សច្ចៈទាំង ២ នោះ ឈ្មោះថា ជ្រាលជ្រៅ ព្រោះឃើញបានដោយក្រ ដោយប្រការដូច្នេះ ។ ការព្យាយាមដើម្បីឃើញសច្ចៈ ២ ក្រៅអំពីនេះ គឺនិរោធ និងមគ្គ ដូចការលាដៃទៅដើម្បីចាប់ភវគ្គព្រហ្ម ដូចការសណ្ដូកជើងដើម្បីពាល់ត្រូវអវីចិនរក និងដូចជាយកចុងរោមទ្រាយ ទល់ចុងរោមទ្រាយ ដែលគេច្រៀកហើយ ១០០ ចំណែក ។ សច្ចៈទាំង ២ នោះ ឈ្មោះថា ជាធម៌ឃើញបានដោយក្រ ព្រោះជ្រាលជ្រៅ ដោយប្រការដូច្នេះ ។ ពាក្យដែលព្រះមានព្រះភាគត្រាស់

ថា **ទុក្ខេញាណំ** នេះ ទ្រង់សំដៅយកការកើតឡើងនៃញាណក្នុងបុព្វភាគ ដោយអំណាចនៃការរៀនជាដើម ក្នុងសច្ចៈ ៤ ជាធម៌ជ្រាលជ្រៅ ព្រោះឃើញបានដោយក្រ និងជាធម៌ឃើញបានដោយលំបាក ព្រោះជ្រាលជ្រៅដោយប្រការដូច្នេះ ។ តែក្នុងខណៈនៃការចាក់ធ្លុះញាណនោះ រមែងមានត្រឹមតែម្តងនោះឯង ។

[ ១៦៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មាសង្កប្បនិទ្ទេសដូចតទៅ

ឈ្មោះថា **នេក្ខម្មសង្កប្បោ** ព្រោះអត្ថថា រលាស់ចេញចាកកាម ។ ឈ្មោះថា **អព្យាទសង្កប្បោ** ព្រោះអត្ថថា រលាស់ចេញចាកសេចក្តីព្យាបាទ ឈ្មោះថា **អវិហិង្សាសង្កប្បោ** ព្រោះអត្ថថា រលាស់ចេញចាកការបៀតបៀន ។ បណ្តាសង្កប្បទាំង ៣ នោះ នេក្ខម្មវិតក្កកើតឡើង ធ្វើនូវការកាត់ផ្លូវ គឺទម្លាយផ្លូវសញ្ចររបស់កាមវិតក្ក អព្យាបាទវិតក្កកើតឡើង ធ្វើការកាត់ផ្លូវ គឺទម្លាយផ្លូវសញ្ចររបស់ព្យាបាទវិតក្ក អវិហិង្សាវិតក្កកើតឡើង ធ្វើនូវការកាត់ផ្លូវ គឺទម្លាយផ្លូវសញ្ចររបស់វិហិង្សាវិតក្ក ។ម្យ៉ាងទៀត នេក្ខម្មវិតក្កកើតឡើង ជាសត្រូវចំពោះកាមវិតក្ក អព្យាបាទវិតក្ក និងអវិហិង្សាវិតក្កកើតឡើង ជាសត្រូវចំពោះព្យាបាទវិតក្ក និងវិហិង្សាវិតក្ក ។

ក្នុងវិតក្កទាំងនោះ ព្រះយោគាវចរ រមែងពិចារណាកាមវិតក្ក ឬសង្ខារដទៃណាមួយ ដើម្បីទម្លាយផ្លូវរបស់កាមវិតក្ក បន្ទាប់អំពីនោះ ការត្រិះរិះនៃភិក្ខុនោះដែលសម្បយុត្តដោយវិបស្សនា ក្នុងខណៈនៃវិបស្សនាកើតឡើង ធ្វើនូវការកាត់ផ្លូវ គឺទម្លាយផ្លូវរបស់កាមវិតក្ក ដោយអំណាចតទង្គប្បហាន ភិក្ខុ

នោះខ្វល់ខ្វាយក្នុងវិបស្សនា ក៏សម្រេចមគ្គបាន លំដាប់នោះ សង្កប្បរបស់លោកដែលសម្បយុត្តដោយមគ្គក្នុងខណៈនៃមគ្គ ក៏នឹងកើតឡើង ធ្វើនូវការកាត់ផ្លូវ គឺទម្លាយផ្លូវសញ្ចររបស់កាមវិតក្កដោយអំណាចនៃសមុច្ឆេទប្បហាន ។ ម្យ៉ាងទៀត ព្រះយោគាវចររមែងពិចារណាព្យាបាទវិតក្ក ឬសង្ខារដទៃ ដើម្បីទម្លាយផ្លូវព្យាបាទវិតក្ក ឬរមែងពិចារណាវិហិង្សាវិតក្ក ឬសង្ខារដទៃ ដើម្បីទម្លាយផ្លូវរបស់វិហិង្សាវិតក្ក គប្បីប្រកបពាក្យទាំងពួងថា បន្ទាប់អំពីនោះការត្រិះរិះរបស់លោក ដែលសម្បយុត្តដោយវិបស្សនា ... ក្នុងខណៈនៃវិបស្សនា ដោយន័យដែលមានក្នុងកាលមុននោះឯង ។

ម្យ៉ាងទៀត ក្នុងអារម្មណ៍កម្មដ្ឋាន ៣៨ ដែលទ្រង់ចែកនៅក្នុងព្រះបាលី មិនមានកម្មដ្ឋានសូម្បី ១ ឈ្មោះថា មិនជាសត្រូវចំពោះអកុសលវិតក្ក ៣ មានកាមវិតក្កជាដើម ។ បឋមជ្ឈានក្នុងអសុភទាំងឡាយ ជាសត្រូវចំពោះកាមវិតក្កដោយចំណែកមួយ ឈានពួក ៣ ឈានពួក ៤ ក្នុងមេត្តាភាវនាជាបដិបក្ខចំពោះព្យាបាទវិតក្ក ឈានពួក ៣ ឬពួក ៤ ក្នុងករុណា ជាបដិបក្ខចំពោះវិហិង្សាវិតក្ក ព្រោះហេតុនោះ កាលព្រះយោគាវចរធ្វើបរិកម្មក្នុងអសុភចូលឈានហើយ ការត្រិះរិះដែលសម្បយុត្តដោយឈានក្នុងខណៈនៃសមាបត្តិក៏នឹងកើតឡើង ជាសត្រូវចំពោះកាមវិតក្កដោយអំណាចនៃវិក្ខម្ភនប្បហាន កាលព្រះយោគាវចរ ធ្វើឈានឲ្យជាបាទ ផ្តើមតាំងវិបស្សនា សេចក្តីត្រិះរិះដែលសម្បយុត្តដោយវិបស្សនា ក្នុងខណៈនៃវិបស្សនា ក៏នឹងកើតឡើង ជាសត្រូវចំពោះកាមវិតក្កដោយអំណាចនៃតទង្គប្បហាន ។ កាលភិក្ខុនោះ ខ្វល់

ខ្វាយក្នុងវិបស្សនា សម្រេចមគ្គហើយ សេចក្ដីត្រិះរិះដែលសម្បយុត្តដោយមគ្គក្នុងខណៈនៃមគ្គ ក៏នឹងកើតឡើង ជាសត្រូវចំពោះកាមវិតក្កដោយអំណាចនៃសមុច្ឆេទប្បហាន ការត្រិះរិះដែលកើតឡើងយ៉ាងនេះ គប្បីជ្រាបថា ទ្រង់ត្រាស់ហៅថា **នេក្ខម្មសង្កប្ប** ។

ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបយោជនាទាំងពួងថា ព្រះយោគាវចរ ធ្វើបរិកម្មក្នុងមេត្តាភាវនា ធ្វើបរិកម្មក្នុងករុណាភាវនា ចូលឈានជាដើមដោយន័យមុនទោះឯង សង្កប្បដែលកើតឡើងយ៉ាងនេះ គប្បីជ្រាបថា ទ្រង់ត្រាស់ថា អព្យាបាទសង្កប្ប និងអវិហិង្សាសង្កប្ប ។ សង្កប្បទាំងនេះ មាននេក្ខម្មសង្កប្បជាដើម ឈ្មោះថា ផ្សេងគ្នាក្នុងចំណែកខាងដើម ព្រោះមានការកើតឡើងផ្សេងគ្នា ដោយអំណាចនៃវិបស្សនា និងឈាន ដោយអាការយ៉ាងនេះ ។ តែក្នុងខណៈនៃមគ្គរមែងកើតកុសលសង្កប្ប តែម្យ៉ាងប៉ុណ្ណោះដែលធ្វើអង្គមគ្គឲ្យបរិបូណ៌ ដោយអំណាចធ្វើអកុសល សង្កប្បដែលកើតឡើងក្នុងឋានៈទាំង ៣ នេះ មិនឲ្យសម្រេចការកើតឡើង ព្រោះកាត់ផ្លូវសញ្ចរចោលនេះ ឈ្មោះថា **សម្មាសង្កប្ប** ។

[ ១៦៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មាវាចានិទ្ទេសដូចតទៅ

ព្រោះបុគ្គលរមែងវៀរមុសាវាទដោយចិត្ត ១ ដួង រមែងវៀរបិសុណាវាចាដោយចិត្ត ១ ដួង ហេតុនោះ ទើបចេតនាជាគ្រឿងវៀរទាំង ៤ នេះ ផ្សេងគ្នាក្នុងចំណែកខាងដើម តែក្នុងខណៈនៃមគ្គ រមែងកើតចេតនាវៀរដែលជាកុសល ពោល គឺសម្មាវាចាតែម្យ៉ាងប៉ុណ្ណោះ ដែលធ្វើអង្គមគ្គឲ្យបរិបូណ៌

ដោយអំណាចធ្វើចេតនាជាហេតុទ្រុស្តសីល ដែលជាអកុសល ៤ យ៉ាង ពោល គឺមិច្ឆាវាចា មិនឲ្យសម្រេចការកើតឡើង ព្រោះកាត់ផ្លូវសព្វរបោល នេះ ឈ្មោះថា **សម្មាវាចា** ។

[ ១៦៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មាកម្មន្តនិទ្ទេសដូចតទៅ

ព្រោះបុគ្គលរមែងវៀរបាណាតិបាតដោយចិត្ត ១ ដួង រមែងវៀរអទិន្នាទានដោយចិត្ត ១ ដួង រមែងវៀរកាមេសុមិច្ឆាចារដោយចិត្ត ១ ដួង ហេតុនោះ ទើបចេតនាជាគ្រឿងវៀរទាំង ៣ នេះ ផ្សេងគ្នាក្នុងចំណែកខាងដើម តែក្នុងខណៈនៃមគ្គ រមែងកើតជាចេតនាវៀរដែលជាកុសល ពោល គឺសម្មាកម្មន្តៈ តែម្យ៉ាងប៉ុណ្ណោះដែលធ្វើអង្គមគ្គឲ្យបរិបូណ៌ ដោយអំណាចធ្វើចេតនាជាហេតុទ្រុស្តសីល ដែលជាអកុសល ៣ យ៉ាង ពោល គឺមិច្ឆាកម្មន្តៈមិនឲ្យកើតឡើងបាន ព្រោះកាត់ផ្លូវសព្វរបោល នេះឈ្មោះថា **សម្មាកម្មន្តៈ** ។

[ ១៦៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មាអាជីវនិទ្ទេសដូចតទៅ

បទថា **ឥធ** បានដល់ ក្នុងសាសនានេះ ។ បទថា **អរិយសាវកោ** បានដល់ សាវករបស់ព្រះពុទ្ធដែលជាអរិយៈ ។ បទថា **មិច្ឆាអាជីវំ បហាយ** បានដល់ លះផ្តាច់នូវអាជីវៈដ៏លាមក ។ បទថា **សម្មាអាជីវេន** បានដល់ ដោយអាជីវៈជាកុសលដែលព្រះពុទ្ធទ្រង់សរសើរហើយ ។ បទថា **ជីវិតំ កប្បេតិ** បានដល់ ញុំាងការរស់នៅនៃជីវិតឲ្យប្រព្រឹត្តទៅ ។ ក្នុងសម្មាអាជីវៈនេះ ព្រោះបុគ្គលរមែងវៀរចាកការឈានកន្លងកាយទ្វារ ដោយចិត្ត ១ ដួង រមែងវៀរចាកការឈានកន្លងវចីទ្វារដោយចិត្ត ១ ដួង ហេតុ

នោះ ទើបក្នុងចំណែកខាងដើម ចេតនាជាគ្រឿងវៀរកើតឡើងក្នុងខណៈផ្សេង តែក្នុងខណៈនៃមគ្គ រមែងកើតកុសលចេតនា ជាគ្រឿងវៀរចាក ពោល គឺសម្មាអាជីវៈតែម្យ៉ាងប៉ុណ្ណោះ ដែលធ្វើអង្គមគ្គឲ្យបរិបូណ៌ ដោយអំណាចធ្វើចេតនាជាហេតុទ្រុស្តសីលក្នុងមិច្ឆាអាជីវៈ ដែលកើតឡើងដោយអំណាចកម្មបថ ៧ ក្នុងទ្វារទាំង ២ មិនឲ្យកើតឡើងបាន ព្រោះកាត់ផ្លូវសញ្ចរចោល នេះឈ្មោះថា **សម្មាអាជីវៈ** ។

[ ១៦៨ ] សម្មាវាយាមនិទ្ទេសនឹងមានជាក់ច្បាស់ដោយអំណាចពណ៌នា តាមបទក្នុងសម្មប្បធានវិភង្គ ។ សម្មាវាយាមៈនេះ រមែងបានក្នុងចិត្តផ្សេងៗ ក្នុងចំណែកខាងដើម ព្រោះថា បុគ្គលរមែងធ្វើសេចក្តីព្យាយាម ដើម្បីការមិនកើតនៃអកុសលធម៌ដ៏លាមកទាំងឡាយ ដែលមិនទាន់កើតឡើងដោយចិត្ត ១ ដួង ដើម្បីលះអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយដោយចិត្ត ១ ដួង និងដើម្បីការកើតឡើងនៃកុសលធម៌ ដែលមិនទាន់កើតឡើងដោយចិត្ត ១ ដួង ដើម្បីការតាំងនៅនៃកុសលធម៌ដែលកើតឡើងហើយដោយចិត្ត ១ ដួង តែក្នុងខណៈនៃមគ្គ សម្មាវាយាមៈ រមែងបានក្នុងចិត្ត ១ ដួងប៉ុណ្ណោះ ព្រោះថា សេចក្តីព្យាយាមដែលសម្បយុត្តដោយមគ្គ ១ ប៉ុណ្ណោះ រមែងបានឈ្មោះ ៤ យ៉ាង ដោយអត្ថថា ញុំាងកិច្ច ៤ យ៉ាងឲ្យសម្រេច ។

[ ១៦៩ ] សម្មាសតិនិទ្ទេសនឹងមានជាក់ច្បាស់ ដោយអំណាចពណ៌នា តាមបទក្នុងសតិប្បដ្ឋានវិភង្គ ។ ម្យ៉ាងទៀត សម្មាសតិនេះ រមែងមានក្នុងចិត្តផ្សេងៗ ក្នុងចំណែកខាងដើម ព្រោះថា បុគ្គលរមែងកំណត់កាយជាអារម្មណ៍

ដោយចិត្ត ១ ដួង រមែងកំណត់វេទនាជាដើម ដោយចិត្ត ១ ដួង តែក្នុងខណៈនៃមគ្គ សម្មាសតិ រមែងបានក្នុងចិត្ត ១ ដួងប៉ុណ្ណោះ ព្រោះថា សតិដែលសម្បយុត្តដោយមគ្គ ១ ដួងប៉ុណ្ណោះរមែងបានឈ្មោះ ៤ យ៉ាង ដោយអត្ថថា ញ៉ាំងកិច្ច ៤ ឲ្យសម្រេច ។

[ ១៧០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មាសមាធិនិទ្ទេសដូចតទៅ

ឈាន ៤ មានការផ្សេងគ្នាសូម្បីក្នុងចំណែកខាងដើម សូម្បីក្នុងខណៈនៃមគ្គ ។ ក្នុងចំណែកខាងដើម ឈាន ៤ ផ្សេងគ្នាដោយអំណាចសមាបត្តិ ក្នុងខណៈនៃមគ្គផ្សេងគ្នាដោយអំណាចនៃមគ្គ ។ ព្រោះថា បឋមមគ្គនៃបុគ្គលម្នាក់ រមែងជាធម៌ប្រកបដោយបឋមជ្ឈាន សូម្បីទុតិយមគ្គជាដើម ក៏ជាធម៌ប្រកបដោយបឋមជ្ឈាន ឬប្រកបដោយឈានណាមួយ មានទុតិយជ្ឈានជាដើម ។ បឋមមគ្គនៃបុគ្គលម្នាក់ ក៏ប្រកបដោយឈានណាមួយ មានទុតិ-យជ្ឈានជាដើម ។ សូម្បីទុតិយមគ្គជាដើមក៏ជាធម៌ប្រកបដោយឈានណាមួយនៃទុតិយជ្ឈានជាដើម ឬថា ប្រកបដោយបឋមជ្ឈាន ។ ដោយអាការយ៉ាងនេះ មគ្គទាំង ៤ រមែងដូចគ្នាខ្លះ មិនដូចគ្នាខ្លះ ឬដូចគ្នាដោយចំណែកខ្លះ ដោយអំណាចឈាន ។

ឯការប្លែកគ្នានៃមគ្គនោះ រមែងមានដោយការកំណត់ឈានដែលជាបាទ ។ ពោលដោយការកំណត់ឈាន ដែលជាបាទមុន កាលបុគ្គលបានបឋមជ្ឈាន ចេញចាកបឋមជ្ឈានហើយ ពិចារណាឃើញច្បាស់ មគ្គដែលកើតឡើងជាមគ្គប្រកបដោយបឋមជ្ឈាន ។ ម្យ៉ាងទៀតក្នុងមគ្គនេះ អង្គមគ្គ និងពោជ្ឈង្គ

រមែងជាធម៌បរិបូណ៌នោះឯង កាលបុគ្គលបាននូវទុតិយជ្ឈាន ចេញចាកទុតិ-យជ្ឈានហើយ ពិចារណាឃើញច្បាស់មគ្គដែលកើតឡើង ជាមគ្គប្រកបដោយទុតិយជ្ឈាន តែក្នុងមគ្គនេះ អង្គមគ្គ រមែងមាន ៧ កាលបានតតិយជ្ឈាន ចេញចាកតតិយជ្ឈានហើយ ពិចារណាឃើញច្បាស់ មគ្គដែលកើតឡើងជាមគ្គប្រកបដោយតតិយជ្ឈាន តែក្នុងមគ្គនេះ អង្គមគ្គរមែងមាន ៧ ពោជ្ឈង្គមានអង្គ ៦ ។ រាប់តាំងអំពីចតុត្ថជ្ឈាន រហូតដល់នេវសញ្ញានាសញ្ញាយត-នជ្ឈាន ក៏មានន័យនេះ ។ ឈានដែលជាចតុក្កន័យ និងបញ្ចកន័យ រមែងកើតឡើងក្នុងអរូបភព ។ ឈាននោះឯង ត្រាស់ហៅថា លោកុត្តរ មិនមែនលោកិយ ។ សួរថា ក្នុងអធិការនេះ ដូចម្ដេច ឆ្លើយថា ក្នុងអធិការនេះ ព្រះយោគាវចរ ចេញចាកឈានណា បណ្ដាបឋមជ្ឈានជាដើម បានចំពោះនូវសោតាបត្តិមគ្គហើយ ចម្រើនអរូបសមាបត្តិ កើតឡើងក្នុងអរូបភព មគ្គ ៣ ខាងចុងនៃបុគ្គលនោះ ប្រកបដោយឈាននោះឯង រមែងកើតឡើងក្នុងអរូប-ភពនោះ ដោយអាការយ៉ាងនេះ ឈានដែលជាបាទនោះឯង រមែងកំណត់មគ្គ ។ តែព្រះថេរៈពួកខ្លះ រមែងពោលថា ខន្ធទាំងឡាយដែលជាអារម្មណ៍នៃវិបស្សនា រមែងកំណត់ ។ ពួកខ្លះ ពោលថា អជ្ឈាស្រ័យនៃបុគ្គលរមែងកំណត់ ពួកខ្លះ ពោលថា វិបស្សនាដែលជាវុដ្ឋានគាមិនីរមែងកំណត់ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យវាទៈរបស់ព្រះថេរៈទាំងនោះ ដោយន័យដែលខ្ញុំបានពោលហើយក្នុងកិច្ចពណ៌នាបទភាជនីយដោយលោកុត្តរ ក្នុងចិត្តុប្បាទកណ្ឌខាងដើមនោះឯង ។

បទថា **អយំ វុច្ចតិ សម្មាសមាធិ** សេចក្ដីថា ឯកគ្គតាក្នុងឈានទាំង ៤ នេះ តថាគតហៅថា សម្មាសមាធិ ជាលោកិយក្នុងចំណែកខាងដើម តែជាលោកុត្តរក្នុងកាលខាងក្រោយ ។ ព្រះមានព្រះភាគ ទ្រង់សម្ដែងមគ្គសច្ច ដោយអំណាចជាលោកិយ និងលោកុត្តរ ដោយប្រការដូច្នេះ ។

បណ្ដាមគ្គដែលជាលោកិយ និងលោកុត្តរទាំងនោះ ក្នុងលោកិយមគ្គ អង្គមគ្គទាំងអស់ រមែងមានអារម្មណ៍ណាមួយក្នុងអារម្មណ៍ ៦ តាមសមគួរ ។ តែក្នុងលោកុត្តរមគ្គ បញ្ញាចក្ខុដែលមាននិព្វានជាអារម្មណ៍ ដែលដកចោលនូវអវិជ្ជានុស័យនៃព្រះអរិយសាវក ដែលប្រព្រឹត្តដើម្បីចាក់ធ្លុះនូវសច្ចៈ ៤ ជាសម្មាទិដ្ឋិ ។ម្យ៉ាងទៀត ការលើកចិត្តឡើងកាន់គន្លងព្រះនិព្វានដែលសម្បយុត្តដោយសម្មាទិដ្ឋិនោះ ហើយដកនូវសម្មាសង្កប្ប ៣ យ៉ាង របស់បុគ្គលដែលដល់ព្រមដោយទិដ្ឋិ ជាសម្មាសង្កប្ប ។ ម្យ៉ាងទៀត ចេតនាជាគ្រឿងវៀរចាកមិច្ឆាវាចា ដែលសម្បយុត្តដោយសម្មាសង្កប្បនោះឯង ដកឡើងនូវវចីទុច្ចរិត ៤ នៃបុគ្គលដែលឃើញ និងកំពុងត្រិះរិះ ជាសម្មាវាចា ។ ចេតនាជាគ្រឿងវៀរចាកកាយទុច្ចរិត ៣ យ៉ាង ដែលសម្បយុត្តដោយសម្មាវាចានោះឯង កាត់ផ្ដាច់នូវមិច្ឆាសម្មាកម្មន្តៈនៃបុគ្គលដែលកំពុងវៀរ ជាសម្មាកម្មន្តៈ ។ ចេតនាជាគ្រឿងវៀរមិច្ឆាអាជីវៈដែលជាធម្មជាតផូរផង់របស់សម្មាវាចា និងសម្មាកម្មន្តៈទាំងនោះឯង ដែលសម្បយុត្តដោយសម្មាវាចា និងសម្មាកម្មន្តៈនោះៗ ឯង ដែលកាត់ផ្ដាច់អកុសល មានការបោកបញ្ឆោតជាដើម ជាសម្មាអាជីវៈ ។ វីរិយារម្ភៈរបស់បុគ្គលដែលតាំងមាំក្នុងភូមិសីល ពោលគឺសម្មា-

វាចា សម្មាកម្មន្តៈ សម្មាអាជីវៈនេះ ដែលសមគួរដល់សីលនោះ ដែលសម្បយុត្តដោយសីលនោះៗ ឯង កាត់ផ្តាច់នូវការខ្ជិលច្រអូស និងដែលឲ្យសម្រេចការមិនកើតរបស់អកុសល ដែលមិនទាន់កើត លះអកុសលដែលកើតឡើងហើយ ញុំាងកុសលដែលមិនទាន់កើត ឲ្យកើតឡើង ដែលកើតហើយ ឲ្យតាំងនៅ ជាសម្មាវាយាមៈ ។ ភាពដែលចិត្តមិនវង្វេងរបស់បុគ្គលអ្នកព្យាយាមយ៉ាងនេះ ដែលសម្បយុត្តដោយសម្មាវាយាមៈនោះ ដកឡើងនូវមិច្ឆាសតិឲ្យសម្រេចជាកាយានុបស្សនាជាដើម ក្នុងអារម្មណ៍ មានកាយជាដើម ជាសម្មាសតិ ភាពដែលចិត្តមានអារម្មណ៍តែមួយ របស់បុគ្គលអ្នករក្សាចិត្ត ដែលសតិដ៏ប្រសើរ ចាត់ចែងល្អហើយ ដែលសម្បយុត្តដោយសម្មាសតិនោះឯង ដែលដកឡើងនូវមិច្ឆាសមាធិ ជាសម្មាសមាធិ ដោយប្រការដូច្នេះ ។

នេះជាអរិយមគ្គ មានអង្គ ៨ ជាលោកុត្តរ ។

ម្យ៉ាងទៀត លោកុត្តរមគ្គណា ព្រមទាំងលោកិយមគ្គ ដល់នូវការរាប់ថាជាទុក្ខនិរោធគាមិនីបដិបទា មគ្គនោះឯង ជាវិជ្ជាផង និងចរណៈផង ព្រោះសម្មាទិដ្ឋិ និងសម្មាសង្កប្ប ទ្រង់សង្គ្រោះដោយវិជ្ជា ធម៌ដ៏សេស សង្គ្រោះដោយចរណៈ ។ ម្យ៉ាងទៀត មគ្គនោះ ជាសមថៈផង វិបស្សនាផង ព្រោះសម្មាទិដ្ឋិ និងសម្មាសង្កប្បទាំង ២ នោះ ទ្រង់សង្គ្រោះដោយវិបស្សនាញាណ ធម៌ក្រៅអំពីនេះ សង្គ្រោះដោយសមថញ្ញាណ ។ ម្យ៉ាងទៀត មគ្គនោះ ជាខន្ធទាំង ៣ ផង ជាសិក្ខា ៣ ផង ព្រោះសម្មាទិដ្ឋិ និងសម្មាសង្កប្បទាំង ២

នោះ ទ្រង់សង្គ្រោះដោយបញ្ញាខន្ធ ធម៌ ៣ ក្នុងលំដាប់បន្ទាប់អំពីសម្មាទិដ្ឋិ និងសម្មាសង្កប្បនោះ សង្គ្រោះដោយសីលក្ខន្ធ អង្គមគ្គដ៏សេស សង្គ្រោះដោយសមាធិក្ខន្ធ ហើយធម៌ទាំងនោះឯង សង្គ្រោះដោយអធិបញ្ញាសិក្ខា អធិ-សីលសិក្ខា និងអធិចិត្តសិក្ខា ។ ព្រះអរិយសាវកប្រកបដោយមគ្គណា ជាអ្នកដល់ព្រមដោយវិជ្ជា និងចរណៈ ដូចបុគ្គលដើរផ្លូវឆ្ងាយ ប្រកបដោយចក្ខុទាំង ២ ដែលអាចក្នុងការឃើញ និងជើងទាំង ២ ដែលអាចក្នុងការដើរ វៀរអន្តធម៌ ២ យ៉ាង គឺកាមសុខល្លិកានុយោគដោយវិបស្សនាញាណ និងអត្ត-កិលមថានុយោគដោយសមថញ្ញាណ ប្រព្រឹត្តទៅកាន់មជ្ឈិមប្បដិបទា ទម្លាយនូវគំនរមោហៈដោយបញ្ញាខន្ធ នូវគំនរនៃទោសៈ ដោយសីលក្ខន្ធ នូវគំនរលោភៈដោយសមាធិក្ខន្ធ សម្រេចសម្បត្តិ ៣ គឺបញ្ញាសម្បទាដោយអធិ-ប្បញ្ញាសិក្ខា នូវសីលសម្បទាដោយអធិសីលសិក្ខា នូវសមាធិសម្បទាដោយអធិចិត្តសិក្ខា រមែងធ្វើឲ្យជាក់ច្បាស់នូវអមតៈ ពោល គឺព្រះនិព្វាន ឈ្មោះថាឈមចុះកាន់អរិយភូមិ ពោល គឺសម្មត្តនិយាម ដែលវិចិត្រដោយរតនៈ គឺពោធិបក្ខិយធម៌ ៣៧ ប្រការ ដែលមានលម្អខាងដើម កណ្តាល និងខាងចុងដូច្នេះឯង ។

អដ្ឋកថាសុត្តន្តភាជនីយ ចប់

# អភិធម្មបិដក

## អភិធម្មភាជនីយ

[ ១៧១ ] សច្ចៈ ៤ គឺទុក្ខ ១ ទុក្ខសមុទ័យ ១ ទុក្ខនិរោធ ១ ទុក្ខនិរោធគាមិនីបដិបទា ១ ។

[ ១៧២ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខសមុទ័យ តើដូចម្តេច ។ តណ្ហា នេះហៅថា ទុក្ខសមុទ័យ ។

[ ១៧៣ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខ តើដូចម្តេច ។ ពួកកិលេសដ៏សេសក្តី ពួកអកុសលធម៌ដ៏សេសក្តី ពួកកុសលមូលទាំង ៣ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្តី ពួកកុសលធម៌ប្រព្រឹត្តទៅជាមួយនឹងអាសវៈដ៏សេសក្តី ពួកវិបាកនៃកុសលធម៌ និងអកុសលធម៌ទាំងឡាយ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្តី ទាំងពួកធម៌ណាដែលជាកិរិយាមិនមែនកុសល មិនមែនអកុសល មិនមែនកម្មវិបាកក្តី រូបទាំងអស់ក្តី នេះហៅថា ទុក្ខ ។

[ ១៧៤ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខនិរោធ តើដូចម្តេច ។ ការលះបង់តណ្ហា នេះហៅថា ទុក្ខនិរោធ ។

[ ១៧៥ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខនិរោធគាមិនីបដិបទា តើដូចម្តេច ។ សម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជាទីស្រោចស្រង់ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់ទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ក៏បានដល់នូវបឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា សម័យនោះ មគ្គមានអង្គ ៨ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិក៏កើតមាន ។

[ ១៧៦ ] បណ្ដាមគ្គមានអង្គ ៨ នោះ សម្មាទិដ្ឋិតើ ដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ធម្មវិចយសម្ពោជ្ឈង្គជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាទិដ្ឋិ ។

[ ១៧៧ ] បណ្ដាមគ្គមានអង្គ ៨ នោះ សម្មាសង្កប្ប តើដូចម្ដេច ។ សេចក្ដីត្រិះរិះ សេចក្ដីត្រិះរិះផ្សេងៗ ។បេ។ សេចក្ដីត្រិះរិះត្រូវ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាសង្កប្ប ។

[ ១៧៨ ] បណ្ដាមគ្គមានអង្គ ៨ នោះ សម្មាវាចា តើដូចម្ដេច ។ ការវាង ការគេចចេញ ការចៀស ការវៀរចាកវចីទុច្ចរិតទាំង ៤ គឺកិរិយាមិនធ្វើ កិរិយាមិនសាង កិរិយាមិនល្មើស ការមិនប្រព្រឹត្តកន្លងវេលា ការសម្លាប់ហេតុ ការពោលត្រូវជាអង្គនៃមគ្គរាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាវាចា ។

[ ១៧៩ ] បណ្ដាមគ្គមានអង្គ ៨ នោះ សម្មាកម្មន្តៈ តើដូចម្ដេច ។ ការវាង ការគេចចេញ ការចៀស ការវៀរចាកកាយទុច្ចរិតទាំង ៣ គឺកិរិយាមិនធ្វើ កិរិយាមិនសាង កិរិយាមិនល្មើស ការមិនប្រព្រឹត្តកន្លងវេលា ការសម្លាប់ហេតុ ការងារត្រូវជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាកម្មន្តៈ ។

[ ១៨០ ] បណ្ដាមគ្គមានអង្គ ៨ នោះ សម្មាអាជីវៈ តើដូចម្ដេច ។ ការវាង ការគេចចេញ ការចៀស ការវៀរចាកការចិញ្ចឹមជីវិតខុស គឺកិរិយា

មិនធ្វើ កិរិយាមិនសាង កិរិយាមិនល្មើស ការមិនប្រព្រឹត្តកន្លងវេលា ការសម្លាប់ហេតុ ការចិញ្ចឹមជីវិតត្រូវជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាអាជីវៈ ។

[ ១៨១ ] បណ្តាមគ្គមានអង្គ ៨ នោះ សម្មាវាយាមៈ តើដូចម្តេច ។ ការប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សេចក្តីព្យាយាមត្រូវ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាវាយាមៈ ។

[ ១៨២ ] បណ្តាមគ្គមានអង្គ ៨ នោះ សម្មាសតិ តើដូចម្តេច ។ ការរឭក ការនឹកឃើញ ។បេ។ សតិត្រឹមត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាសតិ ។

[ ១៨៣ ] បណ្តាមគ្គមានអង្គ ៨ នោះ សម្មាសមាធិ តើដូចម្តេច ។ ការតម្កល់ចិត្ត ។បេ។ សមាធិត្រូវ សមាធិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាសមាធិ ។

នេះហៅថា ទុក្ខនិរោធគាមិនីបដិបទា ពួកធម៌ដ៏សេស ដែលសម្បយុត្តដោយទុក្ខនិរោធគាមិនីបដិបទា ( ក៏ហៅថាទុក្ខនិរោធគាមិនីបដិបទាដែរ ) ។

[ ១៨៤ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខសមុទ័យ តើដូចម្តេច ។ តណ្ហា និងពួកកិលេសដ៏សេស នេះហៅថា ទុក្ខសមុទ័យ ។

[ ១៨៥ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខ តើដូចម្តេច ។ ពួកអកុសលធម៌ដ៏សេសក្តី ពួកកុសលមូលទាំង ៣ ប្រព្រឹត្តទៅជាមួយនឹងអាសវៈដ៏សេស

ក្តី ពួកកុសលធម៌ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្តី ពួកវិបាកនៃកុសលធម៌និងអកុសលធម៌ទាំងឡាយ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្តី ទាំងពួកធម៌ណា ដែលជាកិរិយាមិនមែនកុសល មិនមែនអកុសល មិនមែនកម្មវិបាកក្តី រូបទាំងអស់ក្តី នេះហៅថា ទុក្ខ ។

[ ១៨៦ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខនិរោធ តើដូចម្តេច ។ កិរិយាលះនូវតណ្ហាផង នូវកិលេសទាំងឡាយដ៏សេសផង នេះហៅថា ទុក្ខនិរោធ ។

[ ១៨៧ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខនិរោធគាមិនីបដិបទា តើដូចម្តេច ។ សម័យណា ភិក្ខុក្នុងសាសនានេះចម្រើនលោកុត្តរជ្ឈាន ជាទីស្រោចស្រង់ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ក៏បានដល់នូវបឋមជ្ឈានជាទុក្ខាបដិបទាទន្ធាភិញ្ញា សម័យនោះ មគ្គមានអង្គ ៨ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ក៏កើតមាន នេះហៅថា ទុក្ខនិរោធគាមិនីបដិបទា ពួកធម៌ដ៏សេសដែលសម្បយុត្តដោយទុក្ខនិរោធគាមិនីបដិបទា ( ក៏ហៅថាទុក្ខនិរោធ-គាមិនីបដិបទាដែរ ) ។

[ ១៨៨ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខសមុទ័យ តើដូចម្តេច ។ តណ្ហាក្តី ពួកកិលេសដ៏សេសក្តី ពួកអកុសលធម៌ដ៏សេសក្តី នេះហៅថា ទុក្ខសមុទ័យ ។

[ ១៨៩ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខ តើដូចម្តេច ។ ពួកកុសល-មូលទាំង ៣ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្តី ពួកកុសលធម៌ប្រព្រឹត្តទៅជា

មួយនឹងអាសវៈដ៏សេសក្តី ពួកវិបាកនៃកុសលធម៌ និងអកុសលធម៌ទាំងឡាយ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្តី ទាំងពួកធម៌ណាដែលជាកិរិយាមិនមែនកុសល មិនមែនអកុសល មិនមែនកម្មវិបាកក្តី រូបទាំងអស់ក្តី នេះហៅថា ទុក្ខ ។

[ ១៩០ ] បណ្តាសច្ចៈទាំង ៤ ទុក្ខនិរោធ តើដូចម្តេច ។ កិរិយាលះនូវតណ្ហាក្តី នូវពួកកិលេសដ៏សេសក្តី នូវពួកអកុសលធម៌ដ៏សេសក្តី នេះហៅថា ទុក្ខនិរោធ ។

[ ១៩១ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខនិរោធគាមិនីបដិបទា តើដូចម្តេច ។ សម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ក៏បានដល់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា សម័យនោះ មគ្គមានអង្គ ៨ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ក៏កើតមាន នេះហៅថា ទុក្ខនិរោធគាមិនីបដិបទា ពួកធម៌ដ៏សេសដែលសម្បយុត្តដោយទុក្ខនិរោធគាមិនីបដិបទា ( ក៏ហៅថាទុក្ខនិរោធគាមិនីបដិបទាដែរ ) ។

[ ១៩២ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខសមុទ័យ តើដូចម្តេច ។ តណ្ហាក្តី ពួកកិលេសដ៏សេសក្តី ពួកអកុសលធម៌ដ៏សេសក្តី កុសលមូលទាំង ៣ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្តី នេះហៅថា ទុក្ខសមុទ័យ ។

[ ១៩៣ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខ តើដូចម្តេច ។ ពួកកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈដ៏សេសក្តី ពួកវិបាកនៃកុសលធម៌ និង

អកុសលធម៌ទាំងឡាយ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្តី ទាំងពួកធម៌ណា ដែលជាកិរិយាមិនមែនកុសល មិនមែនអកុសល មិនមែនកម្មវិបាកក្តី រូបទាំងអស់ក្តី នេះហៅថា ទុក្ខ ។

[ ១៩៤ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខនិរោធ តើដូចម្តេច ។ កិរិយាលះនូវតណ្ហាក្តី នូវពួកកិលេសដ៏សេសក្តី នូវពួកអកុសលធម៌ដ៏សេសក្តី នូវពួកកុសលមូលទាំង ៣ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្តី នេះហៅថា ទុក្ខ-និរោធ ។

[ ១៩៥ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខនិរោធគាមិនីបដិបទា តើដូចម្តេច ។ សម័យណា ភិក្ខុក្នុងសាសនានេះចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ក៏បានដល់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា សម័យនោះ មគ្គមានអង្គ ៨ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ក៏កើតមាន នេះហៅថា ទុក្ខនិរោធគាមិនីបដិបទា ពួកធម៌ដ៏សេស ដែលសម្បយុត្តដោយទុក្ខនិរោធគាមិនីបដិបទា ( ក៏ហៅថាទុក្ខនិរោធ-គាមិនីបដិបទាដែរ ) ។

[ ១៩៦ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខសមុទ័យ តើដូចម្តេច ។ តណ្ហាក្តី ពួកកិលេសដ៏សេសក្តី ពួកអកុសលធម៌ដ៏សេសក្តី ពួកកុសលមូលទាំង ៣ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្តី ពួកកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈដ៏សេសក្តី នេះហៅថា ទុក្ខសមុទ័យ ។

[ ១៩៧ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខ តើដូចម្តេច ។ ពួកវិបាកនៃកុសលធម៌ និងអកុសលធម៌ទាំងឡាយ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្តី ទាំងពួកធម៌ណា ដែលជាកិរិយាមិនមែនកុសល មិនមែនអកុសល មិនមែនកម្មវិបាកក្តី រូបទាំងអស់ក្តី នេះហៅថា ទុក្ខ ។

[ ១៩៨ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខនិរោធ តើដូចម្តេច ។ កិរិយាលះនូវតណ្ហាក្តី នូវពួកកិលេសដ៏សេសក្តី នូវពួកអកុសលធម៌ដ៏សេសក្តី នូវពួកកុសលមូលទាំង ៣ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្តី នូវពួកកុសលធម៌ប្រព្រឹត្តទៅជាមួយនឹងអាសវៈដ៏សេសក្តី នេះហៅថា ទុក្ខនិរោធ ។

[ ១៩៩ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខនិរោធគាមិនីបដិបទា តើដូចម្តេច ។ សម័យណាភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈានជានិយ្យានិកៈដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់ទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ក៏បានដល់បឋមជ្ឈានជាទុក្ខាបដិបទាទន្ធាភិញ្ញា សម័យនោះមគ្គ មានអង្គ ៨ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ក៏កើតមាន នេះហៅថា ទុក្ខនិរោធគាមិនីបដិបទា ពួកធម៌ដ៏សេសដែលសម្បយុត្តដោយទុក្ខនិរោធគាមិនីបដិបទា ( ក៏ហៅថាទុក្ខនិរោធ-គាមិនីបដិបទាដែរ ) ។

[ ២០០ ] សច្ចៈ ៤ គឺទុក្ខ ១ ទុក្ខសមុទ័យ ១ ទុក្ខនិរោធ ១ ទុក្ខ-និរោធគាមិនីបដិបទា ១ ។

[ ២០១ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខសមុទ័យ តើដូចម្តេច ។ តណ្ហា

នេះហៅថា ទុក្ខសមុទ័យ ។

[ ២០២ ] បណ្ដាសច្ចៈទាំង ៤ នោះ ទុក្ខ តើដូចម្ដេច ។ ពួកកិលេសដ៏សេសក្ដី ពួកអកុសលធម៌ដ៏សេសក្ដី ពួកកុសលមូលទាំង ៣ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្ដី ពួកកុសលធម៌ប្រព្រឹត្តទៅជាមួយនឹងអាសវៈដ៏សេសក្ដី ពួកវិបាកនៃកុសលធម៌ និងអកុសលធម៌ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្ដី ទាំងពួកធម៌ណា ដែលជាកិរិយាមិនមែនកុសល មិនមែនអកុសល មិនមែនកម្មវិបាកក្ដី រូបទាំងអស់ក្ដី នេះហៅថា ទុក្ខ ។

[ ២០៣ ] បណ្ដាសច្ចៈទាំង ៤ នោះ ទុក្ខនិរោធតើដូចម្ដេច ។ កិរិយាលះបង់នូវតណ្ហា នេះហៅថា ទុក្ខនិរោធ ។

[ ២០៤ ] បណ្ដាសច្ចៈទាំង ៤ នោះ ទុក្ខនិរោធគាមិនីបដិបទា តើដូចម្ដេច ។ សម័យណាភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈានជានិយ្យានិកៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ក៏បានដល់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា សម័យនោះ មគ្គមានអង្គ ៥ គឺសម្មាទិដ្ឋិ សម្មាសង្កប្ប សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិក៏កើតមាន ។

[ ២០៥ ] បណ្ដាមគ្គមានអង្គ ៥ នោះ សម្មាទិដ្ឋិ តើដូចម្ដេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវ ធម្មវិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាទិដ្ឋិ ។

[ ២០៦ ] បណ្ដាមគ្គមានអង្គ ៥ នោះ សម្មាសង្កប្ប តើដូចម្ដេច ។ សេចក្ដីជញ្ជឹង សេចក្ដីត្រិះរិះ សេចក្ដីត្រិះរិះត្រូវ ។បេ។ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាសង្កប្ប ។

[ ២០៧ ] បណ្ដាមគ្គមានអង្គ ៥ នោះ សម្មាវាយាមៈ តើដូចម្ដេច ។ ការប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សេចក្ដីព្យាយាមត្រូវ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាវាយាមៈ ។

[ ២០៨ ] បណ្ដាមគ្គមានអង្គ ៥ នោះ សម្មាសតិ តើដូចម្ដេច ។ ការរឭក ការនឹកឃើញ ។បេ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាសតិ ។

[ ២០៩ ] បណ្ដាមគ្គមានអង្គ ៥ នោះ សម្មាសមាធិ តើដូចម្ដេច ។ ការតម្កល់ចិត្ត ។បេ។ សមាធិត្រូវ សមាធិសម្ពោជ្ឈង្គជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា សម្មាសមាធិ ។

នេះហៅថា ទុក្ខនិរោធគាមិនីបដិបទា ពួកធម៌ដ៏សេស ដែលសម្បយុត្តដោយទុក្ខនិរោធគាមិនីបដិបទា ( ក៏ហៅថាទុក្ខនិរោធគាមិនីបដិបទាដែរ ) ។បេ។

[ ២១០ ] បណ្ដាសច្ចៈទាំង ៤ នោះ ទុក្ខសមុទ័យ តើដូចម្ដេច ។ តណ្ហាក្ដី ពួកកិលេសដ៏សេសក្ដី ពួកអកុសលធម៌ដ៏សេសក្ដី ពួកកុសលមូលទាំង ៣ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្ដី ពួកកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈដ៏សេសក្ដី នេះហៅថា ទុក្ខសមុទ័យ ។

[ ២១១ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខ តើដូចម្តេច ។ ពួកវិបាកនៃកុសលធម៌ និងអកុសលធម៌ទាំងឡាយ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្តី ទាំងពួកធម៌ណា ដែលជាកិរិយាមិនមែនកុសល មិនមែនអកុសល មិនមែនកម្មវិបាកក្តី រូបទាំងអស់ក្តី នេះហៅថា ទុក្ខ ។

[ ២១២ ] បណ្តាសច្ចៈទាំង ៤ ទុក្ខនិរោធ តើដូចម្តេច ។ កិរិយាលះបង់នូវតណ្ហាក្តី នូវពួកកិលេសដ៏សេសក្តី នូវពួកអកុសលធម៌ដ៏សេសក្តី នូវពួកកុសលមូលទាំង ៣ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្តី នូវពួកកុសលធម៌ប្រព្រឹត្តទៅជាមួយនឹងអាសវៈដ៏សេសក្តី នេះហៅថា ទុក្ខនិរោធ ។

[ ២១៣ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខនិរោធគាមិនីបដិបទា តើដូចម្តេច ។ សម័យណាភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈាន ជានិយ្យានិកៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ក៏បានដល់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា សម័យនោះ មគ្គមានអង្គ ៥ គឺសម្មាទិដ្ឋិ សម្មាសង្កប្ប សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិក៏កើតមាន នេះហៅថា ទុក្ខនិរោធ-គាមិនីបដិបទា ពួកធម៌ដ៏សេសដែលសម្បយុត្តដោយទុក្ខនិរោធគាមិនីបដិបទា ( ក៏ហៅថា ទុក្ខនិរោធគាមិនីបដិបទាដែរ ) ។

[ ២១៤ ] សច្ចៈ ៤ គឺទុក្ខ ១ ទុក្ខសមុទ័យ ១ ទុក្ខនិរោធ ១ ទុក្ខ-និរោធគាមិនីបដិបទា ១ ។

[ ២១៥ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខសមុទ័យ តើដូចម្តេច ។

តណ្ហា នេះហៅថា ទុក្ខសមុទ័យ ។

[ ២១៦ ] បណ្ដាសច្ចៈទាំង ៤ នោះ ទុក្ខ តើដូចម្ដេច ។ ពួកកិលេសដ៏សេសក្ដី ពួកអកុសលធម៌ដ៏សេសក្ដី ពួកកុសលមូលទាំង ៣ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្ដី ពួកកុសលធម៌ប្រព្រឹត្តទៅជាមួយនឹងអាសវៈដ៏សេសក្ដី ពួកវិបាកនៃកុសលធម៌ និងអកុសលធម៌ទាំងឡាយ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្ដី ទាំងពួកធម៌ណាដែលជាកិរិយាមិនមែនកុសល មិនមែនអកុសល មិនមែនកម្មវិបាកក្ដី រូបទាំងអស់ក្ដី នេះហៅថា ទុក្ខ ។

[ ២១៧ ] បណ្ដាសច្ចៈទាំង ៤ នោះ ទុក្ខនិរោធ តើដូចម្ដេច ។ កិរិយាលះបង់នូវតណ្ហា នេះហៅថា ទុក្ខនិរោធ ។

[ ២១៨ ] បណ្ដាសច្ចៈទាំង ៤ នោះ ទុក្ខនិរោធគាមិនីបដិបទា តើដូចម្ដេច ។ សម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈានជានិយ្យានិកៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់ទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ក៏បានដល់នូវបឋមជ្ឈានជាទុក្ខាបដិបទាទន្ធាភិញ្ញា សម័យនោះ ផស្សៈក៏កើតមាន ។បេ។ សេចក្ដីមិនរាយមាយក៏កើតមាន នេះហៅថា ទុក្ខនិរោធគាមិនីបដិបទា ។បេ។

[ ២១៩ ] បណ្ដាសច្ចៈទាំង ៤ នោះ ទុក្ខសមុទ័យ តើដូចម្ដេច ។ តណ្ហាក្ដី ពួកកិលេសដ៏សេសក្ដី ពួកអកុសលធម៌ដ៏សេសក្ដី ពួកកុសលមូលទាំង ៣ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្ដី ពួកកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈដ៏សេសក្ដី នេះហៅថា ទុក្ខសមុទ័យ ។

[ ២២០ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខ តើដូចម្តេច ។ ពួកវិបាកនៃធម៌ទាំងឡាយជាកុសល និងអកុសល ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្តី ទាំងពួកធម៌ណា ដែលជាកិរិយាមិនមែនកុសល មិនមែនអកុសល មិនមែនកម្មវិបាកក្តី រូបទាំងអស់ក្តី នេះហៅថា ទុក្ខ ។

[ ២២១ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខនិរោធ តើដូចម្តេច ។ កិរិយាលះនូវតណ្ហាក្តី នូវពួកកិលេសដ៏សេសក្តី នូវពួកអកុសលធម៌ដ៏សេសក្តី នូវពួកកុសលមូលទាំង ៣ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក្តី នូវពួកកុសលធម៌ប្រព្រឹត្តទៅជាមួយនឹងអាសវៈដ៏សេសក្តី នេះហៅថា ទុក្ខនិរោធ ។

[ ២២២ ] បណ្តាសច្ចៈទាំង ៤ នោះ ទុក្ខនិរោធគាមិនីបដិបទា តើដូចម្តេច ។ សម័យណា ភិក្ខុក្នុងសាសនានេះ ចម្រើនលោកុត្តរជ្ឈានជានិយ្យានិកៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់ទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ក៏បានដល់នូវបឋមជ្ឈានជាទុក្ខាបដិបទាទន្ធាភិញ្ញា សម័យនោះ ផស្សៈក៏កើតមាន ។បេ។ សេចក្តីមិនរាយមាយក៏កើតមាន នេះហៅថា ទុក្ខនិរោធគាមិនីបដិបទា ។

**អភិធម្មភាជនីយ ចប់**

# អដ្ឋកថា

## អភិធម្មភាជនីយ

[ ១៧១ ] ឥឡូវនេះ ជាអភិធម្មភាជនីយ ។ ក្នុងអភិធម្មភាជនីយនេះ ព្រះមានព្រះភាគ មិនត្រាស់ថា អរិយសច្ចទាំងឡាយឡើយ ត្រាស់ថា សច្ចៈ ៤ ដូច្នេះ ដើម្បីទ្រង់សម្តែងសមុទយៈ ពោល គឺធម៌ដែលជាបច្ច័យដោយមិនបែកគ្នា ។

ពិតហើយ កាលទ្រង់ត្រាស់ថា **អរិយសច្ច** ដូច្នេះ កិលេសដ៏សេស កុសលធម៌ដ៏សេស កុសលមូល ៣ ដែលជាអារម្មណ៍របស់អាសវៈ កុសល-ធម៌ដ៏សេសដែលជាអារម្មណ៍របស់អាសវៈ រមែងសង្គ្រោះមិនបាន ព្រោះថា តណ្ហាតែម្យ៉ាងប៉ុណ្ណោះ រមែងឲ្យទុក្ខតាំងឡើង ក៏មិនមែន ធម៌ដែលជាបច្ច័យទាំងនោះ មានកិលេសជាដើមដ៏សេស រមែងញ៉ាំងទុក្ខឲ្យកើតឡើងបានដូចគ្នា ព្រោះហេតុនោះ ដើម្បីទ្រង់សម្តែងសមុទយៈ ពោល គឺធម៌ដែលជាបច្ច័យដោយឥតសេសសល់ថា ធម៌ដែលជាបច្ច័យទាំងនេះ រមែងឲ្យទុក្ខកើតឡើងបានដូចគ្នា ទើបមិនត្រាស់ថា អរិយសច្ចទាំងឡាយ តែត្រាស់សច្ចៈ ៤ ដូច្នេះ ។

[ ១៧២-១៨៩ ] ក្នុងនិទ្ទេសវារនៃសច្ចៈទាំង ៤ នោះ ទ្រង់មិនបានសម្តែងទុក្ខមុន តែទ្រង់លើកទុក្ខសមុយៈឡើងសម្តែង ដើម្បីសម្តែងទុក្ខនោះឯងឲ្យយល់ដោយងាយ ព្រោះកាលទ្រង់សម្តែងទុក្ខសមុទយៈហើយ ទុក្ខសច្ចដោយន័យជាដើមថា **អវសេសា ច កិលេសា** រមែងជាការសម្តែង

បានឆាយ និរោធសច្ចក្នុងនិទ្ទេសវារនេះ ទ្រង់សម្ដែងដោយអាការ ៥[១] ដោយអំណាចនៃការលះសមុទយៈ តាមដែលត្រាស់យ៉ាងនេះថា **តណ្ហាយ អវសេសានញ្ច កិលេសានំ បហានំ** កិរិយាលះនូវតណ្ហាផង នូវកិលេសទាំងឡាយដ៏សេសផង ដូច្នេះជាដើម ។ ឯមគ្គសច្ច ក្នុងនិទ្ទេសវារនេះ កាលទ្រង់សម្ដែង ក៏សម្ដែងត្រឹមតែមាតិការបស់ន័យទេសនា ដែលចែកក្នុងធម្មសង្គណីដោយអំណាចសោតាបត្តិមគ្គ ដែលប្រកបដោយបឋមជ្ឈាន ។ ក្នុងមគ្គសច្ចនោះ បណ្ឌិតគប្បីជ្រាបការផ្សេងគ្នារបស់ន័យដែលខ្ញុំប្រកាសខាងមុខ ។

[ ២០០-២២២ ] ម្យ៉ាងទៀត មគ្គប្រកបដោយអង្គ ៨ ជាបដិបទា តែម្យ៉ាងប៉ុណ្ណោះក៏មិនមែន តែព្រោះព្រះបាលី ( ក្នុងមជ្ឈិមនិកាយ ឧបរិ-បណ្ណាសក ) ថា បុគ្គលនោះឯងឈ្មោះថា មានកាយកម្ម វចីកម្ម និងអាជីវៈដ៏បរិសុទ្ធល្អ ក្នុងកាលមុនពិត ដូច្នេះ ។ មគ្គសូម្បីប្រកបដោយអង្គ ៥ ទ្រង់រមែងសម្ដែងថា ជាបដិបទាដូចគ្នា ដោយអំណាចអធ្យាស្រ័យរបស់បុគ្គល ព្រោះហេតុនោះ ដើម្បីទ្រង់សម្ដែងន័យនោះ ទើបទ្រង់សម្ដែងបញ្ចង្គិកវារ គឺវារៈពោលដោយអង្គមគ្គ ៥ ផងដែរ ។ ម្យ៉ាងទៀត ព្រោះមគ្គប្រកបដោយអង្គ ៨ និងអង្គ ៥ ជាបដិបទាតែម្យ៉ាងក៏មិនមែន សូម្បីសម្បយុត្ត-ធម៌ទាំងឡាយជាង ៥០ ក៏ជាបដិបទាដូចគ្នា ហេតុនោះ ដើម្បីសម្ដែងន័យនោះ ទើបទ្រង់សម្ដែងសព្វសង្គាហិកវារ ( វារៈពោលអំពីធម៌ដែលសង្គ្រោះចូល

១- គឺលេខឃ្នាប ១៧៤ ១៨៦ ១៩០ ១៩៤ ១៩៨ ។

ជាមួយគ្នាទាំងអស់ ) ទី ៣ ផងដែរ ។ ក្នុងសព្វសង្គាហិកវារនោះ រមែង កាត់នូវពាក្យថា ធម៌ទាំងឡាយដ៏សេសដែលសម្បយុត្តដោយទុក្ខនិរោធគាមិ- នីបដិបទានេះ ។ ពាក្យដ៏សេសដូចគ្នាទាំងអស់ក្នុងវារៈទាំងពួង ។

ក្នុងវារៈទាំង ៣ គឺអដ្ឋង្គិកវារ ១ បញ្ចង្គិកវារ ១ សព្វសង្គាហិកវារ ១ ទាំងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងកោដ្ឋាសដំបូង ក្នុងកោដ្ឋាស ៥ ដែល មានពាក្យថា កិរិយាលះនូវតណ្ហាផង នូវកិលេសទាំងឡាយដ៏សេសផង ដូច្នេះជាដើម នៃបញ្ចង្គិកវារមុន ។ ក្នុងការអាស្រ័យឈាន ក្នុងសោតាបត្តិ- មគ្គ មាន ១០ ន័យ ដោយអំណាចឈានដែលជាចតុក្កន័យ និងបញ្ចកន័យ នីមួយៗ ២ ក្នុងឋានៈទាំង ៥ គឺសុទ្ធិកប្បដិបទា ១ សុទ្ធិសុញ្ញតា ១ សុញ្ញតបដិបទា ១ សុទ្ធិកអប្បណិហិត ១ អប្បណិហិតបដិបទា ១ ។ ក្នុង ការអាស្រ័យន័យដ៏សេស ក៏យ៉ាងនេះ ព្រោះហេតុនោះ ក្នុងការអាស្រ័យ ឈាន ២០ ន័យ ទើបជា ២០០ ន័យ ។ ន័យ ២០០ នោះ គុណដោយ អធិបតី ៤ ជា ៨០០ ន័យ រួមន័យទាំងអស់ គឺសុទ្ធិកន័យ ២០០ សាធិ- បតិន័យ ៨០០ ជា ១០០០ ន័យ ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត ក្នុងសោតាបត្តិមគ្គយ៉ាងណា មគ្គដ៏សេសក៏យ៉ាងនោះ ព្រោះហេតុនោះ ទើប ត្រូវជា ៤០០០ ន័យ ។ ម្យ៉ាងទៀត ក្នុងកោដ្ឋាសដំបូង មាន ៤០០០ ន័យ យ៉ាងណា ក្នុងកោដ្ឋាសដ៏សេស ក៏យ៉ាងនោះដូចគ្នា ព្រោះហេតុនោះ ទើប ក្នុងកោដ្ឋាសទាំង ៥ ក្នុងអដ្ឋង្គិកវារ ត្រូវជា ២ ម៉ឺនន័យ ក្នុងបញ្ចង្គិកវារ និងសព្វសង្គាហិកវារក៏ដូចគ្នា ព្រោះហេតុនោះ ទើបន័យទាំងអស់ ព្រះ

សាស្តាចែកជា ៦ ម៉ឺនន័យ តែក្នុងព្រះបាលីមកហើយដោយសង្ខេប បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា អភិធម្មភាជនីយនេះ មានមហាវារៈ ៣ មានកោដ្ឋាស ១៥ ប្រដាប់ដោយន័យ ៦ ម៉ឺន ជាធម៌ដែលព្រះមានព្រះភាគនាំចេញសម្តែងហើយ ដោយប្រការដូច្នេះ ។

**អធិប្បាយ អភិធម្មភាជនីយ ចប់**

# អភិធម្មបិដក

## បញ្ហាបុច្ឆកៈ

[ ២២៣ ] អរិយសច្ច ៤ គឺទុក្ខអរិយសច្ច ១ ទុក្ខសមុទយអរិយសច្ច ១ ទុក្ខនិរោធអរិយសច្ច ១ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។ បណ្ដាអរិយសច្ចទាំង ៤ អរិយសច្ចជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។បេ។ ប្រកបដោយសត្រូវប៉ុន្មាន មិនមានសត្រូវប៉ុន្មាន ។

[ ២២៤ ] សមុទយសច្ចជាអកុសល មគ្គសច្ចជាកុសល និរោធសច្ចជាអព្យាក្រឹត ទុក្ខសច្ច ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ សច្ចៈ ២ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខ-វេទនាក៏មាន និរោធសច្ចមិនគួរពោលថា ប្រកបដោយសុខវេទនាផង ជាប្រកបដោយទុក្ខវេទនាផង ជាប្រកបដោយអទុក្ខមសុខវេទនាផងឡើយ ទុក្ខ-សច្ច ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ។ មិនគួរពោលថា ប្រកបដោយសុខវេទនាផង ជាប្រកបដោយទុក្ខវេទនាផង ជាប្រកបដោយអទុក្ខមសុខវេទនាផងក៏មាន ។ សច្ចៈ ២ មានវិបាកធម៌ជាប្រក្រតី និរោធសច្ច មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ទុក្ខសច្ច ជាវិបាកក៏មាន មានវិបាកជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន ។ សមុទយសច្ច ជាធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនបានកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន សច្ចៈ ២ ជាធម៌ដែល

កម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនបានកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ទុក្ខសច្ច ជាធម៌ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន ជាធម៌ដែលកម្មប្រកបដោយកិលេស មានតណ្ហាជាដើម មិនបានកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទានក៏មាន ។ សមុទយសច្ច ជាធម៌សៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មង សច្ចៈ ២ ជាធម៌មិនសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មង ទុក្ខសច្ច ជាធម៌សៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មងក៏មាន ជាធម៌មិនសៅហ្មង តែគួរដល់សេចក្តីសៅហ្មងក៏មាន ។ សមុទយសច្ច ជាធម៌ប្រព្រឹត្តទៅជាមួយនឹងវិតក្ក ទាំងជាមួយនឹងវិចារ និរោធសច្ចជាធម៌មិនមានវិតក្ក ទាំងមិនមានវិចារ មគ្គសច្ច ជាធម៌ប្រព្រឹត្តទៅជាមួយនឹងវិតក្ក ទាំងជាមួយនឹងវិចារក៏មាន ជាធម៌មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន ជាធម៌មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន ទុក្ខសច្ច ជាធម៌ប្រព្រឹត្តទៅជាមួយនឹងវិតក្កទាំងជាមួយនឹងវិចារក៏មាន ជាធម៌មិនមានវិតក្ក មានត្រឹមតែវិចារក៏មាន ជាធម៌មិនមានវិតក្ក ទាំងមិនមានវិចារក៏មាន មិនគួរពោលថា ប្រព្រឹត្តទៅជាមួយនឹងវិតក្ក ទាំងជាមួយនឹងវិចារផង ថាមិនមានវិតក្ក មានត្រឹមតែវិចារផង ថាមិនមានវិតក្ក ទាំងមិនមានវិចារផងក៏មាន ។ សច្ចៈ ២ ជាធម៌កើតព្រមដោយបីតិក៏មាន កើតព្រមដោយសុខក៏មាន កើតព្រមដោយឧបេក្ខាក៏មាន និរោធសច្ច មិនគួរពោលថា កើតព្រមដោយបីតិផង ថាកើតព្រមដោយសុខផង ថាកើតព្រមដោយឧបេក្ខាផងឡើយ ទុក្ខសច្ច កើតព្រមដោយបីតិក៏មាន

កើតព្រមដោយសុខក៏មាន កើតព្រមដោយឧបេក្ខាក៏មាន មិនគួរពោលថា កើតព្រមដោយបីតិផង ថាកើតព្រមដោយសុខផង ថាកើតព្រមដោយឧបេក្ខាផងក៏មាន ។ សច្ចៈ ២ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា សមុទយសច្ច គួរលះដោយទស្សនៈក៏មាន គួរលះដោយភាវនាក៏មាន ទុក្ខសច្ច គួរលះដោយទស្សនៈក៏មាន គួរលះដោយភាវនាក៏មាន មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន ។ សច្ចៈ ២ មានហេតុ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា សមុទយសច្ច មានហេតុ គួរដោយទស្សនៈក៏មាន មានហេតុ គួរលះដោយភាវនាក៏មាន ទុក្ខសច្ច មានហេតុ គួរលះដោយទស្សនៈក៏មាន មានហេតុ គួរលះដោយភាវនាក៏មាន មានហេតុ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន ។ សមុទយសច្ច ដល់នូវការសន្សំកពូនឡើង មគ្គសច្ច ដល់នូវការមិនសន្សំកពូនឡើង និរោធសច្ច មិនដល់នូវការសន្សំកពូនឡើង ទាំងមិនដល់នូវការមិនសន្សំកពូនឡើង ទុក្ខសច្ច ដល់នូវការសន្សំកពូនឡើងក៏មាន មិនដល់នូវការសន្សំកពូនឡើង ទាំងមិនដល់នូវការមិនសន្សំកពូនឡើងក៏មាន ។ មគ្គសច្ច ជារបស់សេក្ខបុគ្គល សច្ចៈ ៣ មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល ។ សមុទយសច្ច មានសភាពតូចឆ្មារ សច្ចៈ ២ ប្រមាណមិនបាន ទុក្ខសច្ច មានសភាពតូចឆ្មារក៏មាន ដល់នូវសភាពធំក៏មាន ។ និរោធសច្ច មិនមានអារម្មណ៍ មគ្គសច្ច មានអារម្មណ៍ប្រមាណមិនបាន សមុទយសច្ច មានអារម្មណ៍តូចឆ្មារក៏មាន មានអារម្មណ៍ដល់នូវសភាព

ធំ តែមិនមែនមានអារម្មណ៍ប្រមាណមិនបានក៏មាន មិនគួរពោលថា មាន អារម្មណ៍តូចថ្នាផង ថាមានអារម្មណ៍ដល់នូវសភាពធំផងក៏មាន ទុក្ខសច្ច មានអារម្មណ៍តូចថ្នាក៏មាន មានអារម្មណ៍ដល់នូវសភាពធំក៏មាន មានអា- រម្មណ៍ប្រមាណមិនបានក៏មាន មិនគួរពោលថា មានអារម្មណ៍តូចថ្នាផង ថា មានអារម្មណ៍ដល់នូវសភាពធំផង ថាមានអារម្មណ៍ប្រមាណមិនបានផងក៏ មាន ។ សមុទយសច្ច ថោកទាប សច្ចៈ ២ ដ៏ឧត្តម ទុក្ខសច្ច ថោកទាបក៏ មាន យ៉ាងកណ្តាលក៏មាន ។ និរោធសច្ច មិនទៀង មគ្គសច្ច មានសភាព ត្រូវ និងទៀង សច្ចៈ ២ មានសភាពខុស និងទៀងក៏មាន មិនទៀងក៏មាន ។ និរោធសច្ច មិនមានអារម្មណ៍ សមុទយសច្ច មិនគួរពោលថា មានមគ្គជា អារម្មណ៍ផង ថាមានមគ្គជាហេតុផង ថាមានមគ្គជាអធិបតីផងឡើយ មគ្គសច្ច មិនមែនមានមគ្គជាអារម្មណ៍ តែមានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគួរពោលថា មានមគ្គជាហេតុផង ថាមានមគ្គជាអធិបតីផងក៏មាន ទុក្ខ- សច្ច មានមគ្គជាអារម្មណ៍ តែមិនមែនមានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតី ក៏មាន មិនគួរពោលថា មានមគ្គជាអារម្មណ៍ផង ថាមានមគ្គជាអធិបតីផង ក៏មាន ។ សច្ចៈ ២ កើតឡើងហើយក៏មាន មិនទាន់កើតឡើង តែមិនគួរ ពោលថា ប្រុងនឹងកើតឡើងក៏មាន និរោធសច្ច មិនគួរពោលថា កើតឡើងហើយ ផង ថាមិនទាន់កើតឡើងផង ថាប្រុងនឹងកើតឡើងផងទេ ទុក្ខសច្ច កើតឡើង ហើយក៏មាន មិនទាន់កើតឡើងក៏មាន ប្រុងនឹងកើតឡើងក៏មាន ។ សច្ចៈ ៣ ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន និរោធសច្ច មិនគួរ

ពោលថា ជាអតីតផង ថាជាអនាគតផង ថាជាបច្ចុប្បន្នផងឡើយ ។ និរោធ-សច្ច មិនមានអារម្មណ៍ មគ្គសច្ច មិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថាមានអារម្មណ៍ជាអនាគតផង ថាមានអារម្មណ៍ជាបច្ចុប្បន្នផងឡើយ សច្ចៈ ២ មានអារម្មណ៍ជាអតីតក៏មាន មានអារម្មណ៍ជាអនាគតក៏មាន មានអា-រម្មណ៍ជាបច្ចុប្បន្នក៏មាន មិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថាមានអារម្មណ៍ជាអនាគតផង ថាមានអារម្មណ៍ជាបច្ចុប្បន្នផងក៏មាន ។ និរោធ-សច្ច ជាខាងក្រៅ សច្ចៈ ៣ ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ។ និរោធសច្ច មិនមានអារម្មណ៍ មគ្គសច្ច មានអារម្មណ៍ខាងក្រៅ សមុទយសច្ច មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន ទុក្ខសច្ច មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅក៏មាន មិនគួរពោលថា មានអារម្មណ៍ខាងក្នុងផង ថាមានអារម្មណ៍ខាងក្រៅផង ថាមានអារម្មណ៍ទាំងខាងក្នុង ទាំងខាងក្រៅផងក៏មាន ។ សច្ចៈ ៣ មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ ទុក្ខសច្ច ប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ក៏មាន មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ក៏មាន មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ក៏មាន ។

[ ២២៥ ] សមុទយសច្ច ជាហេតុ និរោធសច្ច មិនមែនហេតុ សច្ចៈ ២ ជាហេតុក៏មាន មិនមែនហេតុក៏មាន ។ សច្ចៈ ២ ប្រព្រឹត្តទៅជាមួយនឹង

ហេតុ និរោធសច្ច មិនមានហេតុ ទុក្ខសច្ច ប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមានហេតុក៏មាន ។ សច្ចៈ ២ ប្រកបដោយហេតុ និរោធសច្ច ប្រាសចាកហេតុ ទុក្ខសច្ច ប្រកបដោយហេតុក៏មាន ប្រាសចាកហេតុក៏មាន ។ សមុទយ-សច្ច ជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផង និរោធសច្ចមិនគួរពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុផង ថាប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុផងឡើយ មគ្គសច្ច ជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផងក៏មាន ប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុក៏មាន ទុក្ខសច្ច ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន ប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុក៏មាន មិនគួរពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុផង ថាប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុផងក៏មាន ។ សមុទយសច្ច ជាហេតុផង ប្រកបដោយហេតុផង និរោធសច្ច មិនគួរពោលថា ជាហេតុ ទាំងប្រកបដោយហេតុផង ថាប្រកបដោយហេតុ តែមិនមែនហេតុផងឡើយ មគ្គសច្ច ជាហេតុផង ប្រកបដោយហេតុផងក៏មាន ប្រកបដោយហេតុ តែមិនមែនហេតុផងក៏មាន ទុក្ខសច្ច ជាហេតុផង ប្រកបដោយហេតុផងក៏មាន ប្រកបដោយហេតុ តែមិនមែនជាហេតុផងក៏មាន មិនគួរពោលថាជាហេតុ ប្រកបដោយហេតុផង ថាប្រកបដោយហេតុ តែមិនមែនហេតុផងក៏មាន ។ និរោធសច្ច មិនមែនហេតុ ទាំងមិនប្រព្រឹត្តទៅជាមួយនឹងហេតុ សមុ-ទយសច្ច មិនគួរពោលថា មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុផង ថាមិនមែនហេតុ ទាំងមិនប្រព្រឹត្តទៅជាមួយនឹងហេតុផងឡើយ មគ្គសច្ច មិន

មែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនគួរពោលថា មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុផង ជាមិនមែនហេតុ ទាំងមិនប្រព្រឹត្តទៅជាមួយនឹងហេតុផងក៏មាន ទុក្ខសច្ច មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមែនហេតុ ទាំងមិនប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនគួរពោលថា មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុផង ជាមិនមែនហេតុ ទាំងមិនប្រព្រឹត្តទៅជាមួយនឹងហេតុផងក៏មាន ។

[ ២២៦ ] សច្ចៈ ៣ ប្រព្រឹត្តទៅជាមួយនឹងបច្ច័យ និរោធសច្ច មិនមានបច្ច័យ ។ សច្ចៈ ៣ មានបច្ច័យប្រជុំតាក់តែង និរោធសច្ចមិនមានបច្ច័យប្រជុំតាក់តែង ។ សច្ចៈ ៣ មិនប្រកបដោយការឃើញ ទុក្ខសច្ច ប្រកបដោយការឃើញក៏មាន មិនប្រកបដោយការឃើញក៏មាន ។ សច្ចៈ ៣ មិនប្រកបដោយការប៉ះពាល់ ទុក្ខសច្ច ប្រកបដោយការប៉ះពាល់ក៏មាន មិនប្រកបដោយការប៉ះពាល់ក៏មាន ។ សច្ចៈ ៣ ជារូប ទុក្ខសច្ច ជារូបក៏មាន ជាអរូបក៏មាន ។ សច្ចៈ ២ ជាលោកិយ សច្ចៈ ២ ទៀត ជាលោកុត្តរ ។ សច្ចៈទាំងនោះ គួរដឹងច្បាស់ដោយវិញ្ញាណណាមួយក៏មាន មិនគួរដឹងច្បាស់ដោយវិញ្ញាណណាមួយក៏មាន ។

[ ២២៧ ] សមុទយសច្ច ជាអាសវៈ សច្ចៈ ២ មិនមែនអាសវៈ ទុក្ខ-សច្ច ជាអាសវៈក៏មាន មិនមែនអាសវៈក៏មាន ។ សច្ចៈ ២ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ សច្ចៈ ២ មិនមានអាសវៈ ។ សមុទយសច្ច ប្រកបដោយអាសវៈ សច្ចៈ ២ ប្រាសចាកអាសវៈ ទុក្ខសច្ចប្រកបដោយអាសវៈក៏មាន

ប្រាសចាកអាសវៈក៏មាន ។ សមុទយសច្ច ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ សច្ចៈ ២ មិនគួរពោលថាជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ជាប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈផងឡើយ ទុក្ខសច្ច ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈក៏មាន ។ សមុទយសច្ច ជាអាសវៈ ទាំងប្រកបដោយអាសវៈ សច្ចៈ ២ មិនគួរពោលថាជាអាសវៈ ទាំងប្រកបដោយអាសវៈផង ជាប្រកបដោយអាសវៈ តែមិនមែនអាសវៈផងឡើយ ទុក្ខសច្ច ជាអាសវៈ ទាំងប្រកបដោយអាសវៈក៏មាន ប្រកបដោយអាសវៈ តែមិនមែនអាសវៈក៏មាន មិនគួរពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផង ជាប្រកបដោយអាសវៈ តែមិនមែនអាសវៈផងក៏មាន ។ សច្ចៈ ២ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ សមុទយសច្ច មិនគួរពោលថាប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ជាប្រាសចាកអាសវៈ ទាំងមិនមានអាសវៈផងឡើយ ទុក្ខសច្ច ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន មិនគួរពោលថា ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ជាប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ជាប្រាសចាកអាសវៈ ទាំងមិនមានអាសវៈផងក៏មាន ។

[ ២២៨ ] សមុទយសច្ច ជាសញ្ញោជនៈ សច្ចៈ ២ មិនមែនសញ្ញោជនៈ ទុក្ខសច្ច ជាសញ្ញោជនៈក៏មាន មិនមែនសញ្ញោជនៈក៏មាន ។ សច្ចៈ ២ ជាប្រយោជន៍ដល់សញ្ញោជនៈ សច្ចៈ ២ មិនមែនជាប្រយោជន៍ដល់សញ្ញោជនៈ ។

សមុទយសច្ច ប្រកបដោយសញ្ញោជនៈ សច្ចៈ ២ ប្រាសចាកសញ្ញោជនៈ ទុក្ខសច្ច ប្រកបដោយសញ្ញោជនៈក៏មាន ប្រាសចាកសញ្ញោជនៈក៏មាន ។ សមុទយសច្ច ជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈ សច្ចៈ ២ មិនគួរពោលថា ជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈផង ជា ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនសញ្ញោជនៈផងឡើយ ទុក្ខសច្ច ជាសញ្ញោជនៈ ទាំងជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ជាប្រយោជន៍ ដល់សញ្ញោជនៈ តែមិនមែនសញ្ញោជនៈក៏មាន ។ សមុទយសច្ច ជា សញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈ សច្ចៈ ២ មិនគួរពោលថា ជា សញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈផង ជាប្រកបដោយសញ្ញោជនៈ តែមិនមែនសញ្ញោជនៈផងឡើយ ទុក្ខសច្ច ជាសញ្ញោជនៈ ទាំងប្រកបដោយ សញ្ញោជនៈក៏មាន ប្រកបដោយសញ្ញោជនៈ តែមិនមែនសញ្ញោជនៈក៏មាន មិនគួរពោលថា ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈផង ជាប្រកប ដោយសញ្ញោជនៈ តែមិនមែនសញ្ញោជនៈផងក៏មាន ។ សច្ចៈ ២ ប្រាស ចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈ សមុទយសច្ច មិន គួរពោលថា ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈផង ជាប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ ដល់សញ្ញោជនៈផងឡើយ ទុក្ខសច្ច ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន មិន គួរពោលថា ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈផង ជាប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈផងក៏មាន ។

[ ២២៩ ] សមុទយសច្ច ជាគន្ថៈ សច្ចៈ ២ មិនមែនគន្ថៈ ទុក្ខសច្ច ជាគន្ថៈក៏មាន មិនមែនគន្ថៈក៏មាន ។ សច្ចៈ ២ គន្ថៈគប្បីជោតក្រែង សច្ចៈ ២ គន្ថៈមិនគប្បីជោតក្រែង ។ សច្ចៈ ២ ប្រាសចាកគន្ថៈ សច្ចៈ ២ ប្រកបដោយគន្ថៈក៏មាន ប្រាសចាកគន្ថៈក៏មាន ។ សមុទយសច្ច ជាគន្ថៈផង គន្ថៈគប្បីជោតក្រែងផង សច្ចៈ ២ មិនគួរពោលថា ជាគន្ថៈ ទាំងគន្ថៈគប្បីជោតក្រែងផង ជាគន្ថៈគប្បីជោតក្រែង តែមិនមែនគន្ថៈផងឡើយ ទុក្ខសច្ច ជាគន្ថៈ ទាំងគន្ថៈគប្បីជោតក្រែងក៏មាន គន្ថៈគប្បីជោតក្រែង តែមិនមែនគន្ថៈក៏មាន ។ សមុទយសច្ច ជាគន្ថៈ ទាំងប្រកបដោយគន្ថៈក៏មាន មិនគួរពោលថាជាគន្ថៈ ទាំងប្រកបដោយគន្ថៈផង ជាប្រកបដោយគន្ថៈ តែមិនមែនគន្ថៈផងក៏មាន សច្ចៈ ២ មិនគួរពោលថាជាគន្ថៈ ទាំងប្រកបដោយគន្ថៈផង ជាប្រកបដោយគន្ថៈ តែមិនមែនគន្ថៈផងឡើយ ទុក្ខសច្ច ជាគន្ថៈ ទាំងប្រកបដោយគន្ថៈក៏មាន ប្រកបដោយគន្ថៈ តែមិនមែនគន្ថៈក៏មាន មិនគួរពោលថាជាគន្ថៈ ទាំងប្រកបដោយគន្ថៈផង ជាប្រកបដោយគន្ថៈ តែមិនមែនគន្ថៈផងក៏មាន ។ សច្ចៈ ២ ប្រាសចាកគន្ថៈ ទាំងគន្ថៈមិនគប្បីជោតក្រែង សច្ចៈ ២ ប្រាសចាកគន្ថៈ តែគន្ថៈគប្បីជោតក្រែងក៏មាន មិនគួរពោលថាប្រាសចាកគន្ថៈ តែគន្ថៈគប្បីជោតក្រែងផង ជាប្រាសចាកគន្ថៈ ទាំងគន្ថៈមិនគប្បីជោតក្រែងផងក៏មាន ។

[ ២៣០ ] សមុទយសច្ច ជាឱឃៈ ។បេ។ ជាយោគៈ ។បេ។ ជានីវរណៈ សច្ចៈ ២ មិនមែននីវរណៈ ទុក្ខសច្ច ជានីវរណៈក៏មាន មិនមែននីវរណៈក៏មាន ។ សច្ចៈ ២ ជាប្រយោជន៍ដល់នីវរណៈ សច្ចៈ ២ មិនមែនជា

ប្រយោជន៍ដល់នីវរណៈ ។ សមុទយសច្ច ប្រកបដោយនីវរណៈ សច្ចៈ ២ ប្រាសចាកនីវរណៈ ទុក្ខសច្ច ប្រកបដោយនីវរណៈក៏មាន ប្រាសចាកនីវរណៈក៏មាន ។ សមុទយសច្ច ជានីវរណៈ ទាំងជាប្រយោជន៍ដល់នីវរណៈ សច្ចៈ ២ មិនគួរពោលថា ជានីវរណៈ ទាំងជាប្រយោជន៍ដល់នីវរណៈផង ថាជាប្រយោជន៍ដល់នីវរណៈ តែមិនមែននីវរណៈផងឡើយ ទុក្ខសច្ច ជានីវរណៈទាំងជាប្រយោជន៍ដល់នីវរណៈក៏មាន ជាប្រយោជន៍ដល់នីវរណៈ តែមិនមែននីវរណៈក៏មាន ។ សមុទយសច្ច ជានីវរណៈ ទាំងប្រកបដោយនីវរណៈ សច្ចៈ ២ មិនគួរពោលថា ជានីវរណៈ ទាំងប្រកបដោយនីវរណៈផង ថាប្រកបដោយនីវរណៈ តែមិនមែននីវរណៈផងឡើយ ទុក្ខសច្ច ជានីវរណៈទាំងប្រកបដោយនីវរណៈក៏មាន ប្រកបដោយនីវរណៈ តែមិនមែននីវរណៈក៏មាន មិនគួរពោលថា ជានីវរណៈ ទាំងប្រកបដោយនីវរណៈផង ថាប្រកបដោយនីវរណៈ តែមិនមែននីវរណៈផងក៏មាន ។ សច្ចៈ ២ ប្រាសចាកនីវរណៈ ទាំងមិនជាប្រយោជន៍ដល់នីវរណៈ សមុទយសច្ច មិនគួរពោលថា ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈផង ថាប្រាសចាកនីវរណៈទាំងមិនជាប្រយោជន៍ដល់នីវរណៈផងឡើយ ទុក្ខសច្ច ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈក៏មាន មិនគួរពោលថា ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈផង ថាប្រាសចាកនីវរណៈ ទាំងមិនជាប្រយោជន៍ដល់នីវរណៈផងក៏មាន ។

[ ២៣១ ] សច្ចៈ ៣ មិនមែនបរាមាស ទុក្ខសច្ច ជាបរាមាសក៏មាន

មិនមែនបរាមាសក៏មាន ។ សច្ចៈ ២ បរាមាសស្ទាបអង្អែលហើយ សច្ចៈ ២ បរាមាសមិនស្ទាបអង្អែលហើយ ។ សច្ចៈ ២ ប្រាសចាកបរាមាស សមុទយសច្ច ប្រកបដោយបរាមាសក៏មាន ប្រាសចាកបរាមាសក៏មាន ទុក្ខសច្ច ប្រកបដោយបរាមាសក៏មាន ប្រាសចាកបរាមាសក៏មាន មិនគួរពោលថា ប្រកបដោយបរាមាសផង ថាប្រាសចាកបរាមាសផងក៏មាន ។ សមុទយសច្ច មិនគួរពោលថា ជាបរាមាស ទាំងបរាមាសស្ទាបអង្អែលឡើយ បរាមាសស្ទាបអង្អែលហើយ តែមិនមែនជាបរាមាស សច្ចៈ ២ មិនគួរពោលថា ជាបរាមាស ទាំងបរាមាសស្ទាបអង្អែលផង ជាបរាមាសស្ទាបអង្អែលហើយ តែមិនមែនបរាមាសផងឡើយ ទុក្ខសច្ច ជាបរាមាស ទាំងបរាមាសស្ទាបអង្អែលហើយក៏មាន បរាមាសស្ទាបអង្អែលហើយ តែមិនមែនបរាមាសក៏មាន ។ សច្ចៈ ២ ប្រាសចាកបរាមាស ទាំងបរាមាសមិនស្ទាបអង្អែលហើយ សច្ចៈ ២ ប្រាសចាកបរាមាស តែបរាមាសស្ទាបអង្អែលហើយក៏មាន មិនគួរពោលថា ប្រាសចាកបរាមាស តែបរាមាសស្ទាបអង្អែលហើយផង ថាប្រាសចាកបរាមាស ទាំងបរាមាសមិនស្ទាបអង្អែលផងក៏មាន ។

[ ២៣២ ] សច្ចៈ ២ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ និរោធសច្ច មិនមានអារម្មណ៍ ទុក្ខសច្ច ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ក៏មាន មិនមានអារម្មណ៍ក៏មាន ។ សច្ចៈ ៣ មិនមែនចិត្ត ទុក្ខសច្ច ជាចិត្តក៏មាន មិនមែនចិត្តក៏មាន ។ សច្ចៈ ២ ជាចេតសិក និរោធសច្ច មិនមែនចេតសិក ទុក្ខសច្ច ជា

ចេតសិកក៏មាន មិនមែនចេតសិកក៏មាន ។ សច្ចៈ ២ ប្រកបដោយចិត្ត និរោធសច្ច ប្រាសចាកចិត្ត ទុក្ខសច្ច ប្រកបដោយចិត្តក៏មាន ប្រាសចាកចិត្តក៏មាន មិនគួរពោលថា ប្រកបដោយចិត្តផង ជាប្រាសចាកចិត្តផងក៏មាន ។ សច្ចៈ ២ ប្រឡំដោយចិត្ត និរោធសច្ច មិនប្រឡំដោយចិត្ត ទុក្ខសច្ច ប្រឡំដោយចិត្តក៏មាន មិនប្រឡំដោយចិត្តក៏មាន មិនគួរពោលថា ប្រឡំដោយចិត្តផង ជាមិនប្រឡំដោយចិត្តផងក៏មាន ។ សច្ចៈ ២ តាំងឡើងអំពីចិត្ត និរោធសច្ច មិនតាំងឡើងអំពីចិត្ត ទុក្ខសច្ច តាំងឡើងអំពីចិត្តក៏មាន មិនតាំងឡើងអំពីចិត្តក៏មាន ។ សច្ចៈ ២ កើតជាមួយនឹងចិត្ត និរោធសច្ច មិនកើតជាមួយនឹងចិត្ត ទុក្ខសច្ច កើតជាមួយនឹងចិត្តក៏មាន មិនកើតជាមួយនឹងចិត្តក៏មាន ។ សច្ចៈ ២ ប្រព្រឹត្តទៅតាមចិត្ត និរោធសច្ច មិនប្រព្រឹត្តទៅតាមចិត្ត ទុក្ខសច្ច ប្រព្រឹត្តទៅតាមចិត្តក៏មាន មិនប្រព្រឹត្តទៅតាមចិត្តក៏មាន ។ សច្ចៈ ២ ប្រឡំ ទាំងតាំងឡើងអំពីចិត្ត និរោធសច្ច មិនប្រឡំ មិនតាំងឡើងអំពីចិត្ត ទុក្ខសច្ច ប្រឡំ ទាំងតាំងឡើងអំពីចិត្តក៏មាន មិនប្រឡំ មិនតាំងឡើងអំពីចិត្តក៏មាន ។ សច្ចៈ ២ ប្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត និរោធ-សច្ច មិនប្រឡំ មិនតាំងឡើង មិនកើតជាមួយនឹងចិត្ត ទុក្ខសច្ច ប្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្តក៏មាន មិនប្រឡំ មិនតាំងឡើង មិនកើតជាមួយនឹងចិត្តក៏មាន ។ សច្ចៈ ២ ប្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត និរោធសច្ច មិនប្រឡំ មិនតាំងឡើង មិនប្រព្រឹត្តទៅតាមចិត្ត ទុក្ខ-សច្ច ប្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្តក៏មាន មិនប្រឡំ មិនតាំង

ឡើង មិនប្រព្រឹត្តទៅតាមចិត្តក៏មាន ។ សច្ចៈ ៣ ជាខាងក្រៅ ទុក្ខសច្ច ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ។ សច្ចៈ ៣ មិនមែនឧបាទា ទុក្ខសច្ច ជាឧបាទាក៏មាន មិនមែនឧបាទាក៏មាន ។ សច្ចៈ ៣ ត្រូវកម្មប្រកបដោយកិលេស មានតណ្ហាជាដើមមិនបានកាន់យកហើយ ទុក្ខសច្ច ត្រូវកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយក៏មាន ត្រូវកម្មប្រកបដោយកិលេស មានតណ្ហាជាដើម មិនបានកាន់យកហើយក៏មាន ។

[ ២៣៣ ] សមុទយសច្ច ជាឧបាទាន សច្ចៈ ២ មិនមែនឧបាទាន ទុក្ខសច្ច ជាឧបាទានក៏មាន មិនមែនឧបាទានក៏មាន ។ សច្ចៈ ២ ជាប្រយោជន៍ដល់ឧបាទាន សច្ចៈ ២ មិនជាប្រយោជន៍ដល់ឧបាទាន ។ សច្ចៈ ២ ប្រាសចាកឧបាទាន សច្ចៈ ២ ប្រកបដោយឧបាទានក៏មាន ប្រាសចាកឧបាទានក៏មាន ។ សមុទយសច្ច ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទាន សច្ចៈ ២ មិនគួរពោលថា ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានផង ថាជាប្រយោជន៍ដល់ឧបាទាន តែមិនមែនឧបាទានផងឡើយ ទុក្ខសច្ច ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនឧបាទានក៏មាន ។ សមុទយសច្ច ជាឧបាទាន ទាំងប្រកបដោយឧបាទានក៏មាន មិនគួរពោលថា ជាឧបាទាន ទាំងប្រកបដោយឧបាទានផង ថាប្រកបដោយឧបាទាន តែមិនមែនឧបាទានផងក៏មាន សច្ចៈ ២ មិនគួរពោលថា ជាឧបាទាន ទាំងប្រកបដោយឧបាទានផង ថាប្រកបដោយឧបាទាន តែមិនមែនឧបាទានផងឡើយ ទុក្ខសច្ច ជាឧបាទាន ទាំងប្រកបដោយឧបាទានក៏មាន

ប្រកបដោយឧបាទាន តែមិនមែនឧបាទានក៏មាន មិនគួរពោលថាជាឧបាទាន ទាំងប្រកបដោយឧបាទានផង ថាប្រកបដោយឧបាទាន តែមិនមែនឧបាទានផងក៏មាន ។ សច្ចៈ ២ ប្រាសចាកឧបាទាន ទាំងមិនជាប្រយោជន៍ដល់ឧបាទាន សច្ចៈ ២ ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទានក៏មាន មិនគួរពោលថា ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទានផង ថាប្រាសចាកឧបាទាន ទាំងមិនជាប្រយោជន៍ដល់ឧបាទានផងក៏មាន ។

[ ២៣៤ ] សមុទយសច្ច ជាកិលេស សច្ចៈ ២ មិនមែនកិលេស ទុក្ខសច្ច ជាកិលេសក៏មាន មិនមែនកិលេសក៏មាន ។ សច្ចៈ ២ គួរដល់សេចក្ដីសៅហ្មង សច្ចៈ ២ មិនគួរដល់សេចក្ដីសៅហ្មង ។ សមុទយសច្ច ប្រកបដោយសេចក្ដីសៅហ្មង សច្ចៈ ២ មិនប្រកបដោយសេចក្ដីសៅហ្មង ទុក្ខសច្ច ប្រកបដោយសេចក្ដីសៅហ្មងក៏មាន មិនប្រកបដោយសេចក្ដីសៅហ្មងក៏មាន ។ សមុទយសច្ច ប្រកបដោយកិលេស សច្ចៈ ២ ប្រាសចាកកិលេស ទុក្ខសច្ច ប្រកបដោយកិលេសក៏មាន ប្រាសចាកកិលេសក៏មាន ។ សមុទយសច្ច ជាកិលេស ទាំងគួរដល់សេចក្ដីសៅហ្មង សច្ចៈ ២ មិនគួរពោលថាជាកិលេស ទាំងគួរដល់សេចក្ដីសៅហ្មងផង ថាគួរដល់សេចក្ដីសៅហ្មង តែមិនមែនកិលេសផងឡើយ ទុក្ខសច្ច ជាកិលេស ទាំងគួរដល់សេចក្ដីសៅហ្មងក៏មាន គួរដល់សេចក្ដីសៅហ្មង តែមិនមែនកិលេសក៏មាន ។ សមុទយសច្ច ជាកិលេស ទាំងប្រកបដោយសេចក្ដីសៅហ្មង សច្ចៈ ២ មិនគួរពោលថាជាកិលេស ទាំងប្រកបដោយសេចក្ដីសៅហ្មងផង ថាប្រកបដោយសេចក្ដី

សៅហ្មង តែមិនមែនកិលេសផងឡើយ ទុក្ខសច្ច ជាកិលេស ទាំងប្រកប ដោយសេចក្ដីសៅហ្មងក៏មាន ប្រកបដោយសេចក្ដីសៅហ្មង តែមិនមែន កិលេសក៏មាន មិនគួរពោលថា ជាកិលេស ទាំងប្រកបដោយសេចក្ដីសៅហ្មង ផង ថាប្រកបដោយសេចក្ដីសៅហ្មង តែមិនមែនកិលេសផងក៏មាន ។ សមុទយសច្ច ជាកិលេស ទាំងប្រកបដោយកិលេស សច្ចៈ ២ មិនគួរពោល ថាជាកិលេស ទាំងប្រកបដោយកិលេសផង ថាប្រកបដោយកិលេស តែមិន មែនកិលេសផងឡើយ ទុក្ខសច្ច ជាកិលេស ទាំងប្រកបដោយកិលេសក៏មាន ប្រកបដោយកិលេស តែមិនមែនកិលេសក៏មាន មិនគួរពោលថា ជាកិលេស ទាំងប្រកបដោយកិលេសផង ថាប្រកបដោយកិលេស តែមិនមែនកិលេស ផងក៏មាន ។ សច្ចៈ ២ ប្រាសចាកកិលេស ទាំងមិនគួរដល់សេចក្ដីសៅហ្មង សមុទយសច្ច មិនគួរពោលថា ប្រាសចាកកិលេស តែគួរដល់សេចក្ដីសៅហ្មង ផង ថាប្រាសចាកកិលេស ទាំងមិនគួរដល់សេចក្ដីសៅហ្មងផងឡើយ ទុក្ខ- សច្ច ប្រាសចាកកិលេស តែគួរដល់សេចក្ដីសៅហ្មងក៏មាន មិនគួរពោលថា ប្រាសចាកកិលេស តែគួរដល់សេចក្ដីសៅហ្មងផង ថាប្រាសចាកកិលេស ទាំងមិនគួរដល់សេចក្ដីសៅហ្មងផងក៏មាន ។

[ ២៣៥ ] សច្ចៈ ២ មិនគួរលះដោយទស្សនៈ សច្ចៈ ២ គួរលះដោយ ទស្សនៈក៏មាន មិនគួរលះដោយទស្សនៈក៏មាន ។ សច្ចៈ ២ មិនគួរលះ ដោយភាវនា សច្ចៈ ២ គួរលះដោយភាវនាក៏មាន មិនគួរលះដោយភាវនា ក៏មាន ។ សច្ចៈ ២ មានហេតុ មិនគួរលះដោយទស្សនៈ សច្ចៈ ២ មាន

ហេតុ គួរលះដោយទស្សនៈក៏មាន មានហេតុ មិនគួរលះដោយទស្សនៈក៏មាន ។ សច្ចៈ ២ មានហេតុ មិនគួរលះដោយភាវនា សច្ចៈ ២ មានហេតុ គួរលះដោយភាវនាក៏មាន មានហេតុ មិនគួរលះដោយភាវនាក៏មាន ។ សមុទយសច្ច ប្រព្រឹត្តទៅជាមួយនឹងវិតក្ក និរោធសច្ច មិនមានវិតក្ក សច្ចៈ ២ ប្រព្រឹត្តទៅជាមួយនឹងវិតក្កក៏មាន មិនមានវិតក្កក៏មាន ។ សមុទយសច្ច ប្រព្រឹត្តទៅជាមួយនឹងវិចារ និរោធសច្ច មិនមានវិចារ សច្ចៈ ២ ប្រព្រឹត្តទៅជាមួយនឹងវិចារក៏មាន មិនមានវិចារក៏មាន ។ និរោធសច្ច មិនមានបីតិ សច្ចៈ ៣ ប្រព្រឹត្តទៅជាមួយនឹងបីតិក៏មាន មិនមានបីតិក៏មាន ។ និរោធសច្ច មិនកើតព្រមដោយសុខ សច្ចៈ ៣ កើតព្រមដោយសុខក៏មាន មិនកើតព្រមដោយសុខក៏មាន ។ និរោធសច្ច មិនកើតព្រមដោយឧបេក្ខា សច្ចៈ ៣ កើតព្រមដោយឧបេក្ខាក៏មាន មិនកើតព្រមដោយឧបេក្ខាក៏មាន ។ សមុទយសច្ច ជាកាមាវចរ សច្ចៈ ២ មិនមែនកាមាវចរ ទុក្ខសច្ច ជាកាមាវចរក៏មាន មិនមែនកាមាវចរក៏មាន ។ សច្ចៈ ៣ មិនមែនរូបាវចរ ទុក្ខសច្ច ជារូបាវចរក៏មាន មិនមែនរូបាវចរក៏មាន ។ សច្ចៈ ៣ មិនមែនអរូបាវចរ ទុក្ខសច្ច ជាអរូបាវចរក៏មាន មិនមែនអរូបាវចរក៏មាន ។ សច្ចៈ ២ ជាបរិយាបន្ន ( រាប់បញ្ចូលក្នុងតេភូមិកវដ្ដៈ ) សច្ចៈ ២ ជាអបរិយាបន្ន

( មិនរាប់បញ្ចូលក្នុងតេភូមិកវដ្តៈ ) ។ មគ្គសច្ច ជានិយ្យានិកៈ ( ធម៌ជាគ្រឿងចេញចាកវដ្តៈ ) សច្ចៈ ៣ ជាអនិយ្យានិកៈ ។ មគ្គសច្ច ជានិយតៈ ( ទៀង ) និរោធសច្ច ជាអនិយតៈ ( មិនទៀង ) សច្ចៈ ២ ជានិយតៈក៏មាន ជាអនិយតៈក៏មាន ។ សច្ចៈ ២ ជាសឧត្តរៈ ( ធម៌ជាគ្រឿងរើខ្លួន ) សច្ចៈ ២ ជាអនុត្តរៈ ( ធម៌មិនមែនជាគ្រឿងរើខ្លួន ) ។ សមុទយសច្ច ជាសរណៈ ( ធម៌ប្រកបដោយសត្រូវ ) សច្ចៈ ២ ជាអរណៈ ( មិនប្រកបដោយសត្រូវ ) ទុក្ខសច្ច ជាសរណៈក៏មាន ជាអរណៈក៏មាន ។

បញ្ហាបុច្ឆកៈ ចប់

សច្ចវិភង្គ ចប់

# អដ្ឋកថា

## បញ្ហាបុច្ឆកៈ

[ ២២៣-២៣៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបញ្ហាបុច្ឆកៈដូចតទៅ

បណ្ឌិតគប្បីជ្រាបភាពដែលសច្ចៈទាំង ៤ ជាកុសលជាដើម ដោយទំនង នៃអត្ថដែលបានពោលហើយ ក្នុងខន្ធវិភង្គនោះឯង តែក្នុងអារម្មណត្តិកៈ ទាំងឡាយ សមុទយសច្ច ជាបរិត្តារម្មណៈដល់បុគ្គលដែលត្រេកអរក្នុងកាមាវចរធម៌ ជាមហគ្គតារម្មណៈ ដល់បុគ្គលដែលត្រេកអរក្នុងមហគ្គតធម៌ ជានវត្តព្វារម្មណៈ ដល់បុគ្គលដែលត្រេកអរក្នុងបញ្ញត្តិធម៌ ។ ទុក្ខសច្ច ដែលប្រារព្ធកាមាវចរធម៌កើតឡើង ជាបរិត្តារម្មណៈ ជាមហគ្គតារម្មណៈក្នុងកាលប្រារព្ធរូបាវចរធម៌ និងអរូបាវចរធម៌ កើតឡើង ជាអប្បមាណារម្មណៈក្នុងវេលាពិចារណាលោកុត្តរធម៌ ៩ ជានវត្តព្វារម្មណៈក្នុងវេលាពិចារណាបញ្ញត្តិ ។ មគ្គសច្ច ជាមគ្គហេតុកៈក្នុងកាលទាំងពួង ដោយអំណាចជាសហជាតហេតុ ជាមគ្គាធិបតិ ក្នុងវេលាចម្រើនមគ្គធ្វើវិរិយៈ ឬវិមំសាឲ្យជាធំ ឈ្មោះថា ជានវត្តព្វធម៌ ក្នុងវេលាដែលឆន្ទៈ និងចិត្តណាមួយជាអធិបតី ។ ទុក្ខសច្ច ជាមគ្គារម្មណៈ ក្នុងវេលាពិចារណាមគ្គនៃព្រះអរិយៈ ជាមគ្គាធិបតី ក្នុងពេលពិចារណាមគ្គឲ្យច្រើនរបស់ព្រះអរិយៈទាំងនោះឯង ជានវត្តព្វធម៌ ក្នុងវេលាពិចារណាធម៌ដ៏សេស ។

បទថា **ទ្វេ សច្ចានិ** បានដល់ ទុក្ខសច្ច និងសមុទយសច្ច ព្រោះសច្ចៈទាំង ២ នេះ ជាអតីតារម្មណ៍ជាដើម ក្នុងវេលាដែលប្រារព្ធធម៌ មានអតីតជាដើមកើតឡើង សមុទយសច្ច ជាអជ្ឈត្តារម្មណ៍ជាដើម ដល់បុគ្គលដែល

ត្រេកអរក្នុងធម៌ មានអជ្ឈត្តធម៌ជាដើម ទុក្ខសច្ច ក្នុងវេលាជាអាកិញ្ចញ្ញា-យតនៈ គប្បីជ្រាបថាជានវត្តព្វារម្មណ៍ក៏មាន ព្រោះហេតុនោះ ក្នុងបញ្ហាបុច្ឆកៈនេះ សច្ចៈ ២ ខាងដើមជាលោកិយ សច្ចៈ ២ ខាងក្រោយជាលោកុត្តរ ក្នុងបញ្ហាបុច្ឆកៈនេះយ៉ាងណា ក្នុងសុត្តន្តភាជនីយ និងអភិធម្មភាជនីយទាំង ២ ក្នុងកាលមុនក៏យ៉ាងនោះ ព្រោះថា សច្ចៈដែលជាលោកិយ និងលោកុត្តរ ព្រះសម្មាសម្ពុទ្ធ ត្រាស់ហើយក្នុងវារៈទាំង ៣ មានសុត្តន្តភាជនីយជាដើម ។ សច្ចវិភង្គនេះ ទ្រង់ក៏នាំចេញចែកសម្តែង ៣ បរិវដ្ដ ដោយប្រការដូច្នេះឯង ។

បញ្ហាបុច្ឆកៈ ចប់

អដ្ឋកថាសច្ចវិភង្គ ចប់

# អភិធម្មបិដក

## ឥន្ទ្រិយវិភង្គ

[ ២៣៦ ] ឥន្ទ្រិយ ២២ គឺចក្ខុន្ទ្រិយ ( ឥន្ទ្រិយ គឺភ្នែក ) សោតិន្ទ្រិយ ( ឥន្ទ្រិយ គឺត្រចៀក ) ឃានិន្ទ្រិយ ( ឥន្ទ្រិយ គឺច្រមុះ ) ជិវ្ហិន្ទ្រិយ ( ឥន្ទ្រិយ គឺអណ្តាត ) កាយិន្ទ្រិយ ( ឥន្ទ្រិយ គឺកាយ ) មនិន្ទ្រិយ ( ឥន្ទ្រិយ គឺចិត្ត ) ឥត្ថិន្ទ្រិយ ( ឥន្ទ្រិយ គឺភេទស្រី ) បុរិសិន្ទ្រិយ ( ឥន្ទ្រិយ គឺភេទប្រុស ) ជីវិតិន្ទ្រិយ ( ឥន្ទ្រិយ គឺជីវិត ) សុខិន្ទ្រិយ ( ឥន្ទ្រិយ គឺសុខ ) ទុក្ខិន្ទ្រិយ ( ឥន្ទ្រិយ គឺទុក្ខ ) សោមនស្សិន្ទ្រិយ ( ឥន្ទ្រិយ គឺសោមនស្ស ) ទោមនស្សិន្ទ្រិយ ( ឥន្ទ្រិយ គឺទោមនស្ស ) ឧបេក្ខិន្ទ្រិយ ( ឥន្ទ្រិយ គឺឧបេក្ខា ) សទ្ធិន្ទ្រិយ ( ឥន្ទ្រិយ គឺសទ្ធា ) វីរិយិន្ទ្រិយ ( ឥន្ទ្រិយ គឺវីរិយៈ ) សតិន្ទ្រិយ ( ឥន្ទ្រិយ គឺសតិ ) សមាធិន្ទ្រិយ ( ឥន្ទ្រិយ គឺសមាធិ ) បញ្ញិន្ទ្រិយ ( ឥន្ទ្រិយ គឺបញ្ញា ) អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ អញ្ញិន្ទ្រិយ អញ្ញាតាវិន្ទ្រិយ ។

[ ២៣៧ ] បណ្តាឥន្ទ្រិយទាំងនោះ ចក្ខុន្ទ្រិយ តើដូចម្តេច ។ ចក្ខុណា គឺប្រសាទអាស្រ័យមហាភូតទាំង ៤ ។បេ។ ហៅថា ស្រុកទំនេរក៏បាន នេះហៅថា ចក្ខុន្ទ្រិយ ។ បណ្តាឥន្ទ្រិយទាំងនោះ សោតិន្ទ្រិយ ។បេ។ ឃានិន្ទ្រិយ ។បេ។ ជិវ្ហិន្ទ្រិយ ។បេ។ កាយិន្ទ្រិយ តើដូចម្តេច ។ កាយណា គឺប្រសាទអាស្រ័យមហាភូតទាំង ៤ ។បេ។ ហៅថា ស្រុកទំនេរក៏បាន នេះហៅថា កាយិន្ទ្រិយ ។ បណ្តាឥន្ទ្រិយទាំងនោះ មនិន្ទ្រិយ តើដូចម្តេច ។ មនិន្ទ្រិយ មានប្រការមួយដ៏សម្បយុត្តដោយផស្សៈ ។បេ។ មនិន្ទ្រិយ មានច្រើនប្រការយ៉ាងនេះឯង នេះហៅថា មនិន្ទ្រិយ ។

[ ២៣៨ ] បណ្ដាឥន្រ្ទិយទាំងនោះ ឥត្ថិន្រ្ទិយ តើដូចម្ដេច ។ ភេទនៃស្រ្តី និមិត្តនៃស្រ្តី លំនាំនៃស្រ្តី អាកប្បកិរិយានៃស្រ្តី ភាពនៃស្រ្តី បែបភាពនៃស្រ្តីណា របស់ស្រ្តី នេះហៅថា ឥត្ថិន្រ្ទិយ ។ បណ្ដាឥន្រ្ទិយទាំងនោះ បុរិសិន្រ្ទិយ តើដូចម្ដេច ។ ភេទនៃបុរស និមិត្តនៃបុរស លំនាំនៃបុរស ឫកពានៃបុរស ភាពនៃបុរស បែបភាពនៃបុរសណា របស់បុរស នេះហៅថា បុរិសិន្រ្ទិយ ។ បណ្ដាឥន្រ្ទិយទាំងនោះ ជីវិតិន្រ្ទិយ តើដូចម្ដេច ។ ជីវិតិន្រ្ទិយមានប្រការ ២ គឺរូបជីវិតិន្រ្ទិយ ១ អរូបជីវិតិន្រ្ទិយ ។ បណ្ដាជីវិតិន្រ្ទិយទាំងនោះ រូបជីវិតិន្រ្ទិយ តើដូចម្ដេច ។ អាយុ ការស្ថិតនៅ ការតាំងនៅ ការញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ការរំកិលទៅ ការប្រព្រឹត្តទៅ ការរក្សា ការរស់នៅ ធម្មជាតជាធំក្នុងការរស់នៅណា នៃធម៌ដែលមានរូបទាំងនោះ នេះហៅថា រូបជីវិតិន្រ្ទិយ ។ បណ្ដាជីវិតិន្រ្ទិយទាំងនោះ អរូប-ជីវិតិន្រ្ទិយ តើដូចម្ដេច ។ អាយុ ការស្ថិតនៅ ការតាំងនៅ ការញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ការរំកិលទៅ ការប្រព្រឹត្តទៅ ការរក្សា ការរស់នៅ ធម្ម-ជាតជាធំ ក្នុងការរស់នៅណានៃធម៌ ដែលមិនមានរូបទាំងនោះ នេះហៅថា អរូបជីវិតិន្រ្ទិយ ។

[ ២៣៩ ] បណ្ដាឥន្រ្ទិយទាំងនោះ សុខិន្រ្ទិយ តើដូចម្ដេច ។ ការឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងកាយ សេចក្ដីសុខប្រព្រឹត្តទៅក្នុងកាយ ការទទួលអា-រម្មណ៍ដ៏ឆ្ងាញ់ពិសាជាសុខ ដែលកើតអំពីកាយសម្ផស្ស វេទនាដ៏ឆ្ងាញ់ពិសាជាសុខដែលកើតអំពីកាយសម្ផស្សណា នេះហៅថា សុខិន្រ្ទិយ ។ បណ្ដា

ឥន្ទ្រិយទាំងនោះ ទុក្ខិន្ទ្រិយ តើដូចម្តេច ។ ការមិនឆ្ងាញ់ពិសា ប្រព្រឹត្តទៅក្នុងកាយ សេចក្តីទុក្ខប្រព្រឹត្តទៅក្នុងកាយ ការទទួលអារម្មណ៍មិនឆ្ងាញ់ពិសា ជាទុក្ខដែលកើតអំពីកាយសម្ផស្ស វេទនាមិនឆ្ងាញ់ពិសា ជាទុក្ខដែលកើតអំពីកាយសម្ផស្សណា នេះហៅថា ទុក្ខិន្ទ្រិយ ។ បណ្តាឥន្ទ្រិយទាំងនោះ សោមនស្សិន្ទ្រិយ តើដូចម្តេច ។ ការឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសា ជាសុខដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាដ៏ឆ្ងាញ់ពិសា ជាសុខដែលកើតអំពីសម្ផស្សនៃចិត្តណា នេះហៅថា សោមនស្សិន្ទ្រិយ ។ បណ្តាឥន្ទ្រិយទាំងនោះ ទោមនស្សិន្ទ្រិយ តើដូចម្តេច ។ ការមិនឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីទុក្ខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនឆ្ងាញ់ពិសា ជាទុក្ខដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាមិនឆ្ងាញ់ពិសា ជាទុក្ខដែលកើតអំពីសម្ផស្សនៃចិត្តណា នេះហៅថា ទោមនស្សិន្ទ្រិយ ។ បណ្តាឥន្ទ្រិយទាំងនោះ ឧបេក្ខិន្ទ្រិយ តើដូចម្តេច ។ ការមិនឆ្ងាញ់ពិសា មិនមែនជាមិនឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនជាទុក្ខ មិនជាសុខដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាមិនជាទុក្ខ មិនជាសុខដែលកើតអំពីសម្ផស្សនៃចិត្តណា នេះហៅថា ឧបេក្ខិន្ទ្រិយ ។

[ ២៤០ ] បណ្តាឥន្ទ្រិយទាំងនោះ សទ្ធិន្ទ្រិយ តើដូចម្តេច ។ សទ្ធា ការជឿ ការញុំាងចិត្តឲ្យចុះស៊ប់ សេចក្តីជ្រះថ្លាខ្លាំង គឺសទ្ធា សទ្ធិន្ទ្រិយ សទ្ធាពលណា នេះហៅថា សទ្ធិន្ទ្រិយ ។ បណ្តាឥន្ទ្រិយទាំងនោះ វីរិយិន្ទ្រិយ

តើដូចម្តេច ។ ការប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត ការឧហាត សន្ធាត ឧឃ្ឃាត ព្យាយាម ឧិតខំ ខំពេញទំហឹង ខ្នះខ្នែង ខ្ជាប់ខ្ជួន សេចក្តីសន្ធាត មិនបន្ធូរបន្ថយ ការមិនដាក់ចុះនូវសេចក្តីប្រាថ្នា ការមិនដាក់ធុរៈចោល ការផ្គងធុរៈ គឺវីរិយៈ វីរិយិន្ទ្រិយ វីរិយពល សម្មាវាយាមៈណា នេះហៅថា វីរិយិន្ទ្រិយ ។ បណ្តាឥន្ទ្រិយទាំងនោះ សតិន្ទ្រិយ តើដូចម្តេច ។ ស្មារតី ការនឹកឃើញ ការនឹកទាន់ ការរឭកឃើញ ភាពនៃការរឭកឃើញ ការចងចាំ ការមិនភ្លេច ការមិនភាន់ច្រឡំ គឺសតិ សតិន្ទ្រិយ សតិពល សម្មាសតិណា នេះហៅថា សតិន្ទ្រិយ ។ បណ្តាឥន្ទ្រិយទាំងនោះ សមាធិន្ទ្រិយ តើដូចម្តេច ។ ការតាំងនៅ ការតាំងនៅស៊ប់ ការតម្កល់ស៊ប់ ការមិនរសេមរសាម ការមិនរាយមាយ ភាពនៃចិត្តមិនរសេមរសាម គឺសមថៈ សមាធិន្ទ្រិយ សមាធិពល សម្មាសមាធិណា នេះហៅថា សមាធិន្ទ្រិយ ។ បណ្តាឥន្ទ្រិយទាំងនោះ បញ្ញិន្ទ្រិយ តើដូចម្តេច ។ បញ្ញា ការដឹងសព្វ ការពិចារណា ការពិចារណាសព្វ ។បេ។ សេចក្តីមិនវង្វេង គឺធម្មវិចយៈ សម្មាទិដ្ឋិណា នេះហៅថា បញ្ញិន្ទ្រិយ ។

[ ២៤១ ] បណ្តាឥន្ទ្រិយទាំងនោះ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។បេ។ សេចក្តីមិនវង្វេង គឺធម្មវិចយៈ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះដែលខ្លួនមិនធ្លាប់ដឹង មិនធ្លាប់ឃើញ មិនធ្លាប់បានដល់ មិនធ្លាប់យល់ មិនទាន់ធ្វើឲ្យជាក់ច្បាស់ នេះហៅថា អនញ្ញាតញ្ញស្សា-

មីតិន្ទ្រិយ ។ បណ្ដាឥន្ទ្រិយទាំងនោះ អញ្ញិន្ទ្រិយ តើដូចម្ដេច ។ បញ្ញា ការដឹងសព្វ ។បេ។ សេចក្ដីមិនវង្វេង គឺធម្មវិចយៈ សម្មាទិដ្ឋិ ធម្មវិចយ-សម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះ ដែលខ្លួនធ្លាប់ដឹង ធ្លាប់ឃើញ ធ្លាប់ដល់ ធ្លាប់យល់ ធ្លាប់ធ្វើឲ្យជាក់ច្បាស់ នេះហៅថា អញ្ញិន្ទ្រិយ ។ បណ្ដាឥន្ទ្រិយទាំងនោះ អញ្ញា-តាវិន្ទ្រិយ តើដូចម្ដេច ។ សេចក្ដីដឹងច្បាស់ បញ្ញា ការដឹងសព្វនូវធម៌ទាំងនោះ របស់បុគ្គលអ្នកដឹងច្បាស់ទាំងឡាយ ។បេ។ សេចក្ដីមិនវង្វេង គឺធម្ម-វិចយៈ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះហៅថា អញ្ញាតាវិន្ទ្រិយ ។

**អភិធម្មភាជនីយ ចប់**

# អដ្ឋកថា

## ឥន្ទ្រិយវិភង្គ

## អភិធម្មភាជនីយ

[ ២៣៦ ] ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងឥន្ទ្រិយវិភង្គ បន្ទាប់អំពីសច្ចវិភង្គដូចតទៅ

បទថា **ពាវីសតិ** ជាពាក្យកំណត់ចំនួន ។ បទថា **ឥន្ទ្រិយានិ** ជាពាក្យអធិប្បាយធម៌ដែលទ្រង់កំណត់ទុក ។ ឥឡូវនេះ ព្រះមានព្រះភាគ កាលសម្ដែងឥន្ទ្រិយទាំងនោះដោយសង្ខេប ទើបត្រាស់បទថា **ចក្ខុន្ទ្រិយំ** ជាដើម ។

ក្នុងឥន្ទ្រិយទាំងនោះ ដែលឈ្មោះថា **ចក្ខុន្ទ្រិយំ** ព្រោះអត្ថថា គ្រប់គ្រងនូវភាពជាធំក្នុងចក្ខុទ្វារ ។ ដែលឈ្មោះថា **សោតិន្ទ្រិយំ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងសោតទ្វារ ។ ដែលឈ្មោះថា **ឃានិន្ទ្រិយំ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងឃានទ្វារ ។ ដែលឈ្មោះថា **ជិវ្ហិន្ទ្រិយំ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងជិវ្ហាទ្វារ ។ ដែលឈ្មោះថា **កាយិន្ទ្រិយំ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងកាយទ្វារ ។ ដែលឈ្មោះថា **មនិន្ទ្រិយំ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈនៃការដឹងច្បាស់នូវអារម្មណ៍ ។ ដែលឈ្មោះថា **ឥត្ថិន្ទ្រិយំ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំ ក្នុងភាពជាស្រី ។ ដែលឈ្មោះថា **បុរិសិន្ទ្រិយំ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងភាពជាបុរស ។ ដែលឈ្មោះថា **ជីវិតិន្ទ្រិយំ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈនៃការអនុបាល គឺតាមរក្សា ។ ដែលឈ្មោះថា **សុខិន្ទ្រិយំ** ព្រោះអត្ថថា គ្រប់

គ្រងភាពជាធំក្នុងលក្ខណៈសុខ ។ ដែលឈ្មោះថា **ទុក្ខិន្ទ្រិយំ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំ ក្នុងលក្ខណៈទុក្ខ ។ ដែលឈ្មោះថា **សោមនស្សិន្ទ្រិយំ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំ ក្នុងលក្ខណៈសោមនស្ស ។ ដែលឈ្មោះថា **ទោមនស្សិន្ទ្រិយំ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈទោមនស្ស ។ ដែលឈ្មោះថា **ឧបេក្ខិន្ទ្រិយំ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈឧបេក្ខា ។ ដែលឈ្មោះថា **សទ្ធិន្ទ្រិយំ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈបង្អោនចិត្តជឿ ។ ដែលឈ្មោះថា **វីរិយិន្ទ្រិយំ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈព្យាយាម ។ ដែលឈ្មោះថា **សតិន្ទ្រិយំ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈនៃការប្រាកដរបស់អារម្មណ៍ ។ ដែលឈ្មោះថា **សមាធិន្ទ្រិយំ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈមិនរាយមាយ ។ ដែលឈ្មោះថា **បញ្ញិន្ទ្រិយំ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈដឹង ។ ដែលឈ្មោះថា **អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈនៃការដឹងដែលប្រព្រឹត្តទៅថា អាត្មាអញ នឹងដឹងទូទៅដល់វត្ថុដែលមិនទាន់ដឹង ( សោតាបត្តិមគ្គ ) ។ ដែលឈ្មោះថា **អញ្ញិន្ទ្រិយំ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងការដឹងទូទៅនូវធម៌ដែលដឹងហើយនោះឯង ( សោតាបត្តិផល ដល់អរហត្តមគ្គ ) ។ ដែលឈ្មោះថា **អញ្ញាតាវិន្ទ្រិយំ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងភាពជាអ្នកដឹងទូទៅ ( អរហត្តផល ) ។

ក្នុងឥន្ទ្រិយវិភង្គនេះ សុត្តន្តភាជនីយ ទ្រង់មិនពោល ព្រោះហេតុអ្វី

ព្រោះឥន្ទ្រិយ ២២ ដោយលំដាប់នេះ មិនបានមកក្នុងព្រះសូត្រ ព្រោះក្នុងព្រះសូត្រ ទីខ្លះ ទ្រង់ត្រាស់ឥន្ទ្រិយ ២ ទីខ្លះ ត្រាស់ ៣ ទីខ្លះ ត្រាស់ ៤ ដោយហេតុនេះ ឥន្ទ្រិយ ២២ ជាប់តគ្នាបែបនេះ មិនមាន នេះជាន័យរបស់អដ្ឋកថាក្នុងឥន្ទ្រិយវិភង្គប៉ុណ្ណោះ ។

ន័យម្យ៉ាងទៀត គប្បីជ្រាបដូចតទៅនេះថា ពិតហើយ ក្នុងឥន្ទ្រិយទាំងនេះ

> គប្បីជ្រាបវិនិច្ឆ័យដោយអត្ថ ដោយលក្ខណៈជាដើម ដោយ
> លំដាប់ ដោយការផ្សេងគ្នា និងមិនផ្សេងគ្នា ដោយកិច្ច
> និងដោយភូមិ ដូច្នេះ ។

បណ្ដាពាក្យវិនិច្ឆ័យទាំងនោះ អត្ថនៃឥន្ទ្រិយ មានចក្ខុជាដើម ខ្ញុំប្រកាសមុនហើយដោយន័យជាដើមថា ដែលឈ្មោះថា **ចក្ខុ** ព្រោះអត្ថថា ឃើញ ។ តែក្នុងឥន្ទ្រិយដែលជាលោកុត្តរ ៣ ខាងក្រោយ លោកុត្តរឥន្ទ្រិយដំបូង ព្រះមានព្រះភាគ ត្រាស់ហៅថា **អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ** ដូច្នេះ ព្រោះការកើតឡើង និងព្រោះការកើតព្រមនៃអត្ថរបស់ឥន្ទ្រិយ ដល់ព្រះអរិយៈដែលដល់ហើយក្នុងចំណែកខាងដើមយ៉ាងនេះថា អញនឹងដឹងអមតបទ ឬសច្ចធម៌ ៤ ដែលមិនទាន់ដឹង ដូច្នេះ ។ លោកុត្តរឥន្ទ្រិយទី ២ ត្រាស់ហៅថា **អញ្ញិន្ទ្រិយំ** ព្រោះការដឹងទូទៅ និងព្រោះការកើតព្រមនៃអត្ថរបស់ឥន្ទ្រិយ ។ លោកុត្តរឥន្ទ្រិយទី ៣ ទ្រង់ត្រាស់ហៅថា **អញ្ញាតាវិន្ទ្រិយំ** ព្រោះការកើតឡើង និងព្រោះការកើតព្រមនៃអត្ថរបស់ឥន្ទ្រិយដល់ព្រះខីណាស្រព ដែល

ដឹងច្បាស់ ដែលមានកិច្ចនៃញាណក្នុងសច្ចៈ ៤ សម្រេចហើយ ។

ឈ្មោះថា **អត្ថនៃឥន្ទ្រិយនោះ** ដូចម្តេច អត្ថនៃឥន្ទ្រិយ មានអត្ថថា ជាគ្រឿងសម្គាល់នៃភាពជាធំ អត្ថនៃឥន្ទ្រិយ មានអត្ថថា ដែលបុគ្គលជាធំសម្តែងហើយ អត្ថនៃឥន្ទ្រិយ មានអត្ថថា ដែលបុគ្គលជាធំឃើញហើយ អត្ថនៃឥន្ទ្រិយមានអត្ថថា ដែលបុគ្គលជាធំប្រកាសហើយ អត្ថនៃឥន្ទ្រិយមានអត្ថថា ដែលបុគ្គលជាធំសេពហើយ អត្ថនៃឥន្ទ្រិយទាំងអស់នោះ រមែងសមគួរតាមសមគួរក្នុងទីនេះ ។

ពិតហើយ ព្រះពុទ្ធមានព្រះភាគ ឈ្មោះថា ជាកំពូល គឺជាធំ ព្រោះជាបុគ្គលដែលធំបំផុត ។ កម្មដែលជាកុសល និងអកុសល ឈ្មោះថា ជាធំ ព្រោះក្នុងកម្មទាំងឡាយ មិនមានអ្វីមួយមានភាពជាធំជាង ដោយហេតុនោះឯង ក្នុងអធិការនេះ ឥន្ទ្រិយទាំងឡាយ ដែលកើតព្រមដោយកម្ម រមែងសម្តែងនូវធម៌ដែលជាកុសល និងអកុសល និងឥន្ទ្រិយទាំងនោះ ដែលព្រះសម្មាសម្ពុទ្ធជាកំពូលនោះ ទ្រង់ទូន្មានហើយ ព្រោះហេតុនោះ ទើបឈ្មោះថា **ឥន្ទ្រិយំ** ដោយអត្ថថា ជាគ្រឿងសម្គាល់ភាពជាធំ និងដោយអត្ថថា ជាវត្ថុដែលព្រះមានព្រះភាគជាធំសម្តែងហើយ ។ ម្យ៉ាងទៀត ឥន្ទ្រិយទាំងឡាយនោះឯង ដែលព្រះមានព្រះភាគ ទ្រង់ប្រកាស និងត្រាស់ដឹងក្រៃលែងតាមសេចក្តីពិត ព្រោះហេតុនោះ ទើបឈ្មោះថា ឥន្ទ្រិយ ព្រោះអត្ថថា ដែលបុគ្គលជាធំសម្តែងហើយ និងព្រោះអត្ថថា ដែលបុគ្គលជាធំឃើញហើយ ។ ព្រះមានព្រះភាគដែលជាកំពូលនៃមុនីអង្គនោះ ទ្រង់សេពដោយការសេពជា

អារម្មណ៍ និងទ្រង់សេពឥន្ទ្រិយ ដោយការសេព គឺការនា ព្រោះហេតុនោះ ទើបឈ្មោះថា ឥន្ទ្រិយ ដោយអត្ថថា ដែលអគ្គបុគ្គលសេពហើយខ្លះ ។ ម្យ៉ាងទៀត ឥន្ទ្រិយទាំងនេះ ឈ្មោះថា ឥន្ទ្រិយ ដោយអត្ថថា ជាឥស្សរៈ ពោល គឺភាពជាអធិបតីក៏បាន ដ្បិតថា ភាពជាអធិបតីនៃចក្ខុជាដើម សម្រេចហើយក្នុងការប្រព្រឹត្តទៅនៃចក្ខុវិញ្ញាណជាដើម ព្រោះកាលឥន្ទ្រិយនោះចាស់ក្លា ចក្ខុវិញ្ញាណជាដើមក៏ចាស់ក្លា កាលឥន្ទ្រិយទាំងឡាយទន់ខ្សោយ ចក្ខុវិញ្ញាណជាដើមក៏ទន់ខ្សោយនោះឯង ។

នេះវិនិច្ឆ័យដោយអត្ថនៃឥន្ទ្រិយ មានប្រមាណប៉ុណ្ណេះ ។

ពាក្យថា **ដោយលក្ខណៈជាដើម** មានអធិប្បាយថា បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យឥន្ទ្រិយ មានចក្ខុជាដើមដោយលក្ខណៈ ដោយកិច្ច ដោយបច្ចុប្បដ្ឋាន និងដោយបទដ្ឋាន ។ លក្ខណៈនៃធម៌ មានចក្ខុជាដើមនោះ ខ្ញុំបានពោលខាងដើម គឺក្នុងអដ្ឋសាលិនីទាំងអស់ហើយ ឥន្ទ្រិយ ៤ មានបញ្ញិន្ទ្រិយជាដើម ដោយអត្ថ បានដល់ អមោហៈនោះឯង ឥន្ទ្រិយដ៏សេស មកហើយក្នុងព្រះបាលីនោះដោយសង្ខេបហើយ ។

ពាក្យថា **ដោយលំដាប់** នេះ ជាលំដាប់នៃទេសនានោះឯង ។ ក្នុងលំដាប់នោះ ការបានចំពោះនូវអរិយភូមិ រមែងមានដោយការកំណត់ដឹងធម៌ ដែលជាខាងក្នុង ព្រោះហេតុនោះ ទើបទ្រង់សម្តែងចក្ខុន្ទ្រិយជាដើម ដែលទាក់ទងដោយអត្តភាពមុន ឯអត្តភាពនោះ អាស្រ័យធម៌ណា រមែងដល់នូវការរាប់ថាជាស្រី ឬជាបុរស ដើម្បីទ្រង់បង្ហាញថា ធម៌នោះ គឺអត្តភាពនេះ បន្ទាប់

អំពីនោះ ទើបទ្រង់សម្តែងឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ ។ ដើម្បីឲ្យដឹងថា អត្ត-ភាពទាំង ២ នោះ មានការប្រព្រឹត្តទៅទាក់ទងដោយជីវិតិន្ទ្រិយ បន្ទាប់អំពីនោះ ទើបទ្រង់សម្តែងជីវិតិន្ទ្រិយ ។ ដរាបណាដែលជីវិតិន្ទ្រិយនោះ នៅប្រព្រឹត្តទៅ ដរាបនោះ ការមិនឈប់នៃអារម្មណ៍ដែលសោយហើយ ( វេទនា ) ទាំងនោះក៏មាន ដើម្បីឲ្យដឹងថា ការសោយអារម្មណ៍ទាំងអស់ជាសុខវេទនា ឬជាទុក្ខវេទនា បន្ទាប់អំពីនោះ ទើបទ្រង់សម្តែងសុខិន្ទ្រិយជាដើម ។

ម្យ៉ាងទៀត ដើម្បីសម្តែងបដិបទាថា ធម៌ទាំងនេះ គប្បីចម្រើនដើម្បីការរម្ងាត់សុខិន្ទ្រិយជាដើម បន្ទាប់អំពីនោះ ទើបទ្រង់សម្តែងពាក្យថា សទ្ធាជាដើម ។ ដើម្បីសម្តែងភាពមិនជាមោឃៈនៃបដិបទាថា ដោយបដិបទានេះ ធម៌ឯក រមែងប្រាកដក្នុងខ្លួនមុន បន្ទាប់អំពីនោះ ទើបទ្រង់សម្តែងអនញ្ញ-តញ្ញស្សាមីតិន្ទ្រិយ ទ្រង់សម្តែងអញ្ញិន្ទ្រិយបន្ទាប់អំពីអនញ្ញតញ្ញស្សាមីតិន្ទ្រិយនោះ ព្រោះភាពដែលអញ្ញិន្ទ្រិយនោះ ជាផលនៃអនញ្ញតញ្ញស្សាមីតិន្ទ្រិយនោះឯង និងជាឥន្ទ្រិយដែលគប្បីចម្រើន ក្នុងលំដាប់បន្ទាប់អំពីអនញ្ញតញ្ញស្សាមី-តិន្ទ្រិយនោះ ។ ខាងមុខអំពីនេះ ដើម្បីឲ្យដឹងថា ការសម្រេចឥន្ទ្រិយនេះបានដោយភាវនា កាលសម្រេចឥន្ទ្រិយហើយ ឥន្ទ្រិយណាមួយ ដែលធ្វើឲ្យចម្រើនក្រៃលែងមិនមាន ទើបត្រាស់អញ្ញាតាវិន្ទ្រិយ ដែលជាការលួងលោមចិត្តយ៉ាងក្រៃលែង ក្នុងទីបំផុត នេះជាលំដាប់ក្នុងឥន្ទ្រិយទាំងនេះ ដោយប្រការដូច្នេះ ។

ពាក្យថា **ដោយការផ្សេងគ្នា និងមិនផ្សេងគ្នា**នោះ បានដល់ ក្នុងឥន្ទ្រិយ

២២ នេះ ការផ្សេងគ្នារមែងមានដល់ជីវិតិន្ទ្រិយតែម្យ៉ាង ដ្បិតថា ជីវិតិន្ទ្រិយនោះ មាន ២ យ៉ាង គឺរូបជីវិតិន្ទ្រិយ ១ អរូបជីវិតិន្ទ្រិយ ១ ។ ឥន្ទ្រិយទាំងអស់មិនផ្សេងគ្នា ។

គប្បីជ្រាបវិនិច្ឆ័យដោយការផ្សេងគ្នា និងមិនផ្សេងគ្នា ក្នុងឥន្ទ្រិយទាំងនេះដោយប្រការដូច្នេះ ។

ពាក្យថា **ដោយកិច្ច**នេះ បើមានអ្នកសួរថា កិច្ចនៃឥន្ទ្រិយទាំងឡាយដូចម្ដេច ឆ្លើយថា គប្បីជ្រាបកិច្ចរបស់ចក្ខុន្ទ្រិយជាមុនសិន ព្រោះព្រះបាលីថា **ចក្ខាយតនំ ចក្ខុវិញ្ញាណធាតុយា តំ សម្បយុត្តកានញ្ច ធម្មានំ ឥន្ទ្រិយប្បច្ចយេន បច្ចយោ** ចក្ខាយតនៈជាបច្ច័យនៃចក្ខុវិញ្ញាណផង នៃពួកធម៌ដែលប្រកបដោយចក្ខុវិញ្ញាណធាតុនោះផង ដោយឥន្ទ្រិយប្បច្ច័យ ដូច្នេះ ចក្ខុន្ទ្រិយនោះ គប្បីឲ្យសម្រេចដោយភាពជាឥន្ទ្រិយប្បច្ច័យដល់ធម៌ មានចក្ខុវិញ្ញាណជាដើម ដោយភាពជាឥន្ទ្រិយចាស់ក្លា និងទន់ខ្សោយជាដើមរបស់ខ្លួន ជាការអនុលោមតាមអាការរបស់ខ្លួន ពោល គឺជាសភាវៈចាស់ក្លា និងទន់ខ្សោយជាដើម នេះជាកិច្ចនៃចក្ខុន្ទ្រិយនោះ ។ កិច្ចរបស់សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ និងកាយិន្ទ្រិយក៏យ៉ាងនោះ ។ តែការឲ្យសហជាតធម៌ទាំងឡាយប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន ជាកិច្ចនៃមនិន្ទ្រិយ ។ ការតាមរក្សាសហជាតធម៌ ជាកិច្ចនៃជីវិតិន្ទ្រិយ ។ ទ្រង់ទ្រាយ គ្រឿងសម្គាល់ កិរិយាអាការរបស់ស្រី និងបុរស ជាកិច្ចនៃឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ ។ ការគ្របសង្កត់សហជាតធម៌ហើយ ឲ្យដល់លំដាប់តាមអាការដែលគ្រោតគ្រាត តាម

សភាវៈរបស់ខ្លួនជាកិច្ចនៃសុខិន្ទ្រិយ ទុក្ខិន្ទ្រិយ សោមនស្សិន្ទ្រិយ និងទោមនស្សិន្ទ្រិយ ការឲ្យដល់នូវអាការជាមជ្ឈត្តតា គឺឧបេក្ខាដែលស្ងប់ និងប្រណីត ជាកិច្ចនៃឧបេក្ខិន្ទ្រិយ ការគ្របសង្កត់ធម៌ដែលជាបដិបក្ខចំពោះសទ្ធាជាដើម និងការឲ្យសម្បយុត្តធម៌ ដល់នូវភាពជាភាវៈ មានអាការផូរផង់ជាដើម ជាកិច្ចនៃសទ្ធិន្ទ្រិយជាដើម ការលះសំយោជនៈ ៣ មានទិដ្ឋិសំយោជនៈជាដើម និងការធ្វើឲ្យសម្បយុត្តធម៌បែរមុខចំពោះការលះសំយោជនៈ ៣ នោះ ជាកិច្ចនៃអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ការលះ ធ្វើឲ្យស្រាលស្តើងនូវកាមរាគៈ ព្យាបាទជាដើម និងការធ្វើសហជាតធម៌ឲ្យប្រព្រឹត្តទៅតាមអំណាចរបស់ខ្លួន ជាកិច្ចនៃអញ្ញិន្ទ្រិយ ការលះនូវការខ្វល់ខ្វាយក្នុងកិច្ចទាំងអស់ និងជាបច្ច័យឲ្យសម្បយុត្តធម៌បែរមុខទៅកាន់អមតៈ ជាកិច្ចនៃអញ្ញាតាវិន្ទ្រិយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងឥន្ទ្រិយទាំងនោះ ដោយកិច្ចយ៉ាងនេះ ដោយប្រការដូច្នេះ ។

ពាក្យថា **ដោយភូមិ** សេចក្តីថា បណ្តាឥន្ទ្រិយទាំងនោះ ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ និងទោមនស្សិន្ទ្រិយ ជាកាមាវចរតែម្យ៉ាង មនិន្ទ្រិយ ជីវិតិន្ទ្រិយ ឧបេក្ខិន្ទ្រិយ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ជាឥន្ទ្រិយទាក់ទងក្នុងភូមិ ៤ សោមនស្សិន្ទ្រិយ ជាប់ទាក់ទងដោយភូមិ ៣ គឺកាមាវចរ រូបាវចរ និងលោកុត្តរ ឥន្ទ្រិយ ៣ ខាងចុង ជាលោកុត្តរតែម្យ៉ាង ។

គប្បីជ្រាបវិនិច្ឆ័យដោយភូមិ ដោយប្រការដូច្នេះ ។

ពិតហើយ កាលភិក្ខុដឹងយ៉ាងនេះថា

ភិក្ខុដែលច្រើនដោយសេចក្តីសង្វេគ តាំងនៅក្នុងឥន្ទ្រិយសំវរៈ កំណត់ដឹងនូវឥន្ទ្រិយទាំងឡាយបានហើយ រមែងចូលដល់ទីបំផុតនៃទុក្ខបាន ដូច្នេះ ។

[ ២៣៧-២៤១ ] ក្នុងនិទ្ទេសវារ គប្បីជ្រាបពាក្យទាំងពួងជាដើមថា **យំ ចក្ខុ ចតុន្នំ មហាភូតានំ** ដោយន័យដែលបានពោលក្នុងការចែកបទក្នុងធម្មសង្គណីនោះឯង ។

ម្យ៉ាងទៀត ក្នុងនិទ្ទេសទាំងឡាយ មានវីរិយិន្ទ្រិយ សមាធិន្ទ្រិយជាដើម ទ្រង់មិនបានត្រាស់ថា សម្មាវាយាមៈ មិច្ឆាវាយាមៈ សម្មាសមាធិ មិច្ឆាសមាធិជាដើមឡើយ ព្រោះហេតុអ្វី ព្រោះជាសព្វសង្គាហិកវារ គឺវារៈពោលដោយធម៌ដែលសង្គ្រោះចូលគ្នាទាំងអស់ ពិតហើយ ឥន្ទ្រិយទាំងឡាយដែលសង្គ្រោះចូលជាមួយគ្នាបានទាំងអស់ ព្រះមានព្រះភាគត្រាស់ក្នុងឥន្ទ្រិយវិភង្គនេះ កាលបើដូច្នេះ បណ្តាឥន្ទ្រិយ ២២ នេះ ឥន្ទ្រិយ ១០ ជាលោកិយជាកាមាវចរតែម្យ៉ាង ឥន្ទ្រិយ ៣ ជាលោកុត្តរ ឥន្ទ្រិយ ៩ ជាលោកិយនិងលោកុត្តរលាយឡំគ្នា ដូច្នេះឯង ។

**អដ្ឋកថា អភិធម្មភាជនីយ ចប់**

# អភិធម្មបិដក

## បញ្ហាបុច្ឆកៈ

[ ២៤២ ] ឥន្ទ្រិយ ២២ គឺចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ មនិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ សោមនស្សិន្ទ្រិយ ទោមនស្សិន្ទ្រិយ ឧបេក្ខិន្ទ្រិយ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ អញ្ញិន្ទ្រិយ អញ្ញាតាវិន្ទ្រិយ ។ បណ្តាឥន្ទ្រិយ ២២ ឥន្ទ្រិយជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។បេ។ ប្រកបដោយសត្រូវប៉ុន្មាន មិនមានសត្រូវប៉ុន្មាន ។

[ ២៤៣ ] ឥន្ទ្រិយ ១០ ជាអព្យាក្រឹត ទោមនស្សិន្ទ្រិយ ជាអកុសល អនញ្ញាតញ្ញស្សាមីតិន្ទ្រិយជាកុសល ឥន្ទ្រិយ ៤ ជាកុសលក៏មាន ជាអព្យាក្រឹតក៏មាន ឥន្ទ្រិយ ៦ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ ឥន្ទ្រិយ ១២ មិនគួរពោលថា ប្រកបដោយសុខវេទនាផង ជាប្រកបដោយទុក្ខវេទនាផង ជាប្រកបដោយអទុក្ខមសុខវេទនាផងឡើយ ឥន្ទ្រិយ ៦ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ឥន្ទ្រិយ ៣ ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ជីវិតិន្ទ្រិយប្រកបដោយសុខវេទនាក៏មាន ប្រកបដោយទុក្ខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន មិនគួរពោលថា ប្រកបដោយសុខវេទនាផង ជាប្រកបដោយទុក្ខវេទនាផង ជាប្រកបដោយអទុក្ខមសុខវេទនាផងក៏មាន ។ ឥន្ទ្រិយ ៧ មិនមែនវិបាក

ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ឥន្ទ្រិយ ៣ ជាវិបាក ឥន្ទ្រិយ ២ មានវិបាកធម៌ជាប្រក្រតី អញ្ញិន្ទ្រិយជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតីក៏មាន ឥន្ទ្រិយ ៩ ជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន ។ ឥន្ទ្រិយ ៩ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ទោមនស្សិន្ទ្រិយ មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន ឥន្ទ្រិយ ៣ មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ឥន្ទ្រិយ ៩ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ តែជាប្រយោជន៍ដល់ឧបា-ទានក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន ។ ឥន្ទ្រិយ ៩ មិនសៅហ្មង តែគួរដល់សេចក្តីសៅហ្មង ទោមនស្សិន្ទ្រិយសៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មង ឥន្ទ្រិយ ៣ មិនសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មង ឥន្ទ្រិយ ៣ មិនសៅហ្មង តែគួរដល់សេចក្តីសៅហ្មងក៏មាន មិនសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន ឥន្ទ្រិយ ៦ សៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មងក៏មាន មិនសៅហ្មង តែគួរដល់សេចក្តីសៅហ្មងក៏មាន មិនសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន ។ ឥន្ទ្រិយ ៩ មិនមាន

វិតក្កៈ ទាំងមិនមានវិចារ ទោមនស្សិន្ទ្រិយ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងជាមួយនឹងវិចារ ឧបេក្ខិន្ទ្រិយ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងជាមួយនឹងវិចារក៏មាន មិនមានវិតក្កៈ ទាំងមិនមានវិចារក៏មាន ឥន្ទ្រិយ ១១ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទាំងជាមួយនឹងវិចារក៏មាន មិនមានវិតក្កៈ មានត្រឹមតែវិចារក៏មាន មិនមានវិតក្កៈ ទាំងមិនមានវិចារក៏មាន ។ ឥន្ទ្រិយ ១១ មិនគួរពោលថា កើតព្រមដោយបីតិផង ថាកើតព្រមដោយសុខផង ថាកើតព្រមដោយឧបេក្ខាផងឡើយ សោមនស្សិន្ទ្រិយ កើតព្រមដោយបីតិ មិនកើតព្រមដោយសុខ មិនកើតព្រមដោយឧបេក្ខាក៏មាន មិនគួរពោលថា កើតព្រមដោយបីតិក៏មាន ឥន្ទ្រិយ ៦ កើតព្រមដោយបីតិក៏មាន កើតព្រមដោយសុខក៏មាន កើតព្រមដោយឧបេក្ខាក៏មាន ឥន្ទ្រិយ ៤ កើតព្រមដោយបីតិក៏មាន កើតព្រមដោយសុខក៏មាន កើតព្រមដោយឧបេក្ខាក៏មាន មិនគួរពោលថា កើតព្រមដោយបីតិផង ថាកើតព្រមដោយសុខផង ថាកើតព្រមដោយឧបេក្ខាផងក៏មាន ។ ឥន្ទ្រិយ ១៥ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា ទោមនស្សិន្ទ្រិយ គួរលះដោយទស្សនៈក៏មាន គួរលះដោយភាវនាក៏មាន ឥន្ទ្រិយ ៦ គួរលះដោយទស្សនៈក៏មាន គួរលះដោយភាវនាក៏មាន មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន ។ ឥន្ទ្រិយ ១៥ មានហេតុ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា ទោមនស្សិន្ទ្រិយ មានហេតុ គួរលះដោយទស្សនៈក៏មាន មានហេតុ គួរលះដោយភាវនាក៏មាន ឥន្ទ្រិយ ៦ មានហេតុ គួរលះដោយទស្សនៈក៏មាន មានហេតុ

គួរលះដោយភាវនាក៏មាន មានហេតុ មិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនាក៏មាន ។ ឥន្ទ្រិយ ១០ មិនដល់នូវការសន្សំកពូនឡើង ទាំងមិនដល់នូវការមិនសន្សំកពូនឡើង ទោមនស្សិន្ទ្រិយ ដល់នូវការសន្សំកពូនឡើង អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ដល់នូវការមិនសន្សំកពូនឡើង អញ្ញិន្ទ្រិយ ដល់នូវការមិនសន្សំកពូនឡើងក៏មាន មិនដល់នូវការសន្សំកពូនឡើង ទាំងមិនដល់នូវការមិនសន្សំកពូនឡើងក៏មាន ឥន្ទ្រិយ ៩ ដល់នូវការសន្សំកពូនឡើងក៏មាន ដល់នូវការមិនសន្សំកពូនឡើងក៏មាន មិនដល់នូវសន្សំកពូនឡើង ទាំងមិនដល់នូវការមិនសន្សំកពូនឡើងក៏មាន ។ ឥន្ទ្រិយ ១០ មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល ឥន្ទ្រិយ ២ ជារបស់សេក្ខបុគ្គល អញ្ញាតាវិន្ទ្រិយជារបស់អសេក្ខបុគ្គល ឥន្ទ្រិយ ៩ ជារបស់សេក្ខបុគ្គលក៏មាន ជារបស់អសេក្ខបុគ្គលក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គលក៏មាន ។ ឥន្ទ្រិយ ១០ មានសភាពតូចឆ្មារ ឥន្ទ្រិយ ៣ ប្រមាណមិនបាន ឥន្ទ្រិយ ៩ មានភាពតូចឆ្មារក៏មាន ដល់នូវភាពធំក៏មាន ប្រមាណមិនបានក៏មាន ។ ឥន្ទ្រិយ ៧ មិនមានអារម្មណ៍ ឥន្ទ្រិយ ២ មានអារម្មណ៍តូចឆ្មារ ឥន្ទ្រិយ ៣ មានអារម្មណ៍ប្រមាណមិនបាន ទោមនស្សិន្ទ្រិយ មានអារម្មណ៍តូចឆ្មារក៏មាន មានអារម្មណ៍ដល់នូវភាពធំ តែមិនមែនមានអារម្មណ៍ប្រមាណមិនបានក៏មាន មិនគួរពោលថា មានអារម្មណ៍តូចឆ្មារផង ថាមានអារម្មណ៍ដល់នូវភាពធំផងក៏មាន ឥន្ទ្រិយ ៩ មានអារម្មណ៍តូចឆ្មារក៏មាន មានអារម្មណ៍ដល់នូវភាពធំ

ក៏មាន មានអារម្មណ៍ប្រមាណមិនបានក៏មាន មិនគួរពោលថា មានអារម្មណ៍តូចថ្ញារផង ថាមានអារម្មណ៍ដល់នូវភាពធំផង ថាមានអារម្មណ៍ប្រមាណមិនបានផងក៏មាន ។ ឥន្ទ្រិយ ៩ កណ្តាល ទោមនស្សិន្ទ្រិយថោកទាប ឥន្ទ្រិយ ៣ ឧត្តម ឥន្ទ្រិយ ៣ កណ្តាលក៏មាន ឧត្តមក៏មាន ឥន្ទ្រិយ ៦ ថោកទាបក៏មាន កណ្តាលក៏មាន ឧត្តមក៏មាន ។ ឥន្ទ្រិយ ១០ មិនទៀង អនញ្ញ-តញ្ញស្សាមីតិន្ទ្រិយ មានភាពត្រូវ និងទៀង ឥន្ទ្រិយ ៤ មានភាពត្រូវ និងទៀងក៏មាន មានភាពមិនទៀងក៏មាន ទោមនស្សិន្ទ្រិយ មានភាពខុស និងទៀងក៏មាន មានភាពមិនទៀងក៏មាន ឥន្ទ្រិយ ៦ មានភាពខុស និងទៀងក៏មាន មានភាពត្រូវ និងទៀងក៏មាន មានភាពមិនទៀងក៏មាន ។ ឥន្ទ្រិយ ៧ មិនមានអារម្មណ៍ ឥន្ទ្រិយ ៤ មិនគួរពោលថា មានមគ្គជាអារម្មណ៍ផង ថាមានមគ្គជាហេតុផង ថាមានមគ្គជាអធិបតីផងឡើយ អនញ្ញតញ្ញស្សាមីតិន្ទ្រិយមិនមានមគ្គជាអារម្មណ៍ តែមានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគួរពោលថា មានមគ្គជាហេតុផង ថាមានមគ្គជាអធិបតីផងក៏មាន អញ្ញិន្ទ្រិយមិនមានមគ្គជាអារម្មណ៍ តែមានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគួរពោលថា មានមគ្គជាហេតុផង ថាមានមគ្គជាអធិបតីផងក៏មាន ឥន្ទ្រិយ ៩ មានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគួរពោលថា មានមគ្គជាអារម្មណ៍ផង ថាមានមគ្គជាហេតុផង ថាមានមគ្គជាអធិបតីផងក៏មាន ។ ឥន្ទ្រិយ ១០ កើតឡើងហើយក៏មាន ប្រុងនឹងកើតឡើង តែមិនគួរពោលថា មិនទាន់កើតឡើងក៏មាន ឥន្ទ្រិយ ២ កើត

ឡើងហើយក៏មាន មិនទាន់កើតឡើង តែមិនគួរពោលថា ប្រុងនឹងកើតឡើង ក៏មាន ឥន្ទ្រិយ ១០ កើតឡើងហើយក៏មាន មិនទាន់កើតឡើងក៏មាន ប្រុងនឹងកើតឡើងក៏មាន ។ ឥន្ទ្រិយជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន ។ ឥន្ទ្រិយ ៧ មិនមានអារម្មណ៍ ឥន្ទ្រិយ ២ មានអារម្មណ៍ជាបច្ចុប្បន្ន ឥន្ទ្រិយ ៣ មិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថាមានអារម្មណ៍ជាអនាគតផង ថាមានអារម្មណ៍ជាបច្ចុប្បន្នផងទេ ឥន្ទ្រិយ ១០ មានអារម្មណ៍ជាអតីតក៏មាន មានអារម្មណ៍ជាអនាគតក៏មាន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន មិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថាមានអារម្មណ៍ជាអនាគតផង ថាមានអារម្មណ៍ជាបច្ចុប្បន្នផងក៏មាន ។ ឥន្ទ្រិយខាងក្នុងក៏មាន ខាងក្រៅក៏មាន ខាងក្នុង ទាំងខាងក្រៅក៏មាន ។ ឥន្ទ្រិយ ៧ មិនមានអារម្មណ៍ ឥន្ទ្រិយ ៣ មានអារម្មណ៍ខាងក្រៅ ឥន្ទ្រិយ ៤ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ខាងក្នុង ទាំងខាងក្រៅក៏មាន ឥន្ទ្រិយ ៨ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ខាងក្នុង ទាំងខាងក្រៅក៏មាន មិនគួរពោលថា មានអារម្មណ៍ខាងក្នុងផង ថាមានអារម្មណ៍ខាងក្រៅផង ថាមានអារម្មណ៍ខាងក្នុងទាំងខាងក្រៅផងក៏មាន ។ ឥន្ទ្រិយ ៥ មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ឥន្ទ្រិយ ១៧ មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ ។

[ ២៤៤ ] ឥន្ទ្រិយ ៤ ជាហេតុ ឥន្ទ្រិយ ១៨ មិនមែនហេតុ ។ ឥន្ទ្រិយ

៧ ប្រព្រឹត្តទៅជាមួយនឹងហេតុ ឥន្ទ្រិយ ៩ មិនប្រព្រឹត្តទៅជាមួយនឹងហេតុ ឥន្ទ្រិយ ៦ ប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន ។ ឥន្ទ្រិយ ៧ ប្រកបដោយហេតុ ឥន្ទ្រិយ ៩ ប្រាសចាកហេតុ ឥន្ទ្រិយ ៦ ប្រកបដោយហេតុក៏មាន ប្រាសចាកហេតុក៏មាន ។ ឥន្ទ្រិយ ៤ ជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផង ឥន្ទ្រិយ ៩ មិនគួរពោលថាជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុផង ថាប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុផងឡើយ ឥន្ទ្រិយ ៣ មិនគួរពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ ប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ ឥន្ទ្រិយ ៦ មិនគួរពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុឡើយ ប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុក៏មាន មិនគួរពោលថា ប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុក៏មាន ។ ឥន្ទ្រិយ ៤ ជាហេតុផង ប្រកបដោយហេតុផង ឥន្ទ្រិយ ៩ មិនគួរពោលថា ជាហេតុ ទាំងប្រកបដោយហេតុផង ថាប្រកបដោយហេតុ តែមិនមែនហេតុផងឡើយ ឥន្ទ្រិយ ៣ មិនគួរពោលថា ជាហេតុ ទាំងប្រកបដោយហេតុទេ ប្រកបដោយហេតុ តែមិនមែនហេតុ ឥន្ទ្រិយ ៦ មិនគួរពោលថាជាហេតុ ទាំងប្រកបដោយហេតុឡើយ ប្រកបដោយហេតុ តែមិនមែនហេតុក៏មាន មិនគួរពោលថា ប្រកបដោយហេតុ តែមិនមែនហេតុក៏មាន ។ ឥន្ទ្រិយ ៩ មិនមែនហេតុ ទាំងឥតហេតុ ឥន្ទ្រិយ ៣ មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ឥន្ទ្រិយ ៤ មិនគួរពោលថា មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុផង ថាមិនមែនហេតុ

ទាំងឥតហេតុផងឡើយ ឥន្ទ្រិយ ៦ មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុក៏មាន មិនមែនហេតុ ទាំងឥតហេតុក៏មាន ។

[ ២៨៥ ] ឥន្ទ្រិយទាំងឡាយ ប្រព្រឹត្តទៅជាមួយនឹងបច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ ។ ឥន្ទ្រិយ ៥ ប្រកបដោយការប៉ះពាល់ ឥន្ទ្រិយ ១៧ មិនប្រកបដោយការប៉ះពាល់ ។ ឥន្ទ្រិយ ៧ មានរូប ឥន្ទ្រិយ ១៤ មិនមានរូប ជីវិតិន្ទ្រិយ មានរូបក៏មាន មិនមានរូបក៏មាន ។ ឥន្ទ្រិយ ១០ ជាលោកិយ ឥន្ទ្រិយ ៣ ជាលោកុត្តរ ឥន្ទ្រិយ ៩ ជាលោកិយក៏មាន ជាលោកុត្តរក៏មាន ។ ឥន្ទ្រិយ គួរដឹងច្បាស់ដោយវិញ្ញាណណាមួយក៏មាន មិនគួរដឹងច្បាស់ដោយវិញ្ញាណណាមួយក៏មាន ។

[ ២៨៦ ] ឥន្ទ្រិយទាំងឡាយ មិនមែនអាសវៈ ។ ឥន្ទ្រិយ ១០ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ឥន្ទ្រិយ ៣ មិនមានអាសវៈ ឥន្ទ្រិយ ៩ ប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន មិនមានអាសវៈក៏មាន ។ ឥន្ទ្រិយ ១៥ ប្រាសចាកអាសវៈ ទោមនស្សិន្ទ្រិយ ប្រកបដោយអាសវៈ ឥន្ទ្រិយ ៦ ប្រកបដោយអាសវៈក៏មាន ប្រាសចាកអាសវៈក៏មាន ។ ឥន្ទ្រិយ ១០ មិនគួរពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈទេ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈ ឥន្ទ្រិយ ៣ មិនគួរពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ថាប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈផងឡើយ ឥន្ទ្រិយ ៩ មិនគួរពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈទេ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈ

ក៏មាន មិនគួរពោលថា ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈក៏មាន ។ ឥន្ទ្រិយ ១៥ មិនគួរពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផង ជាប្រកបដោយអាសវៈ តែមិនមែនអាសវៈផងឡើយ ទោមនស្សិន្ទ្រិយ មិនគួរពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈទេ ប្រកបដោយអាសវៈ តែមិនមែនអាសវៈ ឥន្ទ្រិយ ៦ មិនគួរពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈឡើយ ប្រកបដោយអាសវៈ តែមិនមែនអាសវៈក៏មាន មិនគួរពោលថា ប្រកបដោយអាសវៈ តែមិនមែនអាសវៈក៏មាន ឥន្ទ្រិយ ៩ ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ ឥន្ទ្រិយ ៣ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ទោមនស្សិន្ទ្រិយ មិនគួរពោលថា ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ជាប្រាសចាកអាសវៈ ទាំងមិនមានអាសវៈផងឡើយ ឥន្ទ្រិយ ៣ ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈក៏មាន ឥន្ទ្រិយ ៦ ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈក៏មាន មិនគួរពោលថា ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ជាប្រាសចាកអាសវៈ ទាំងមិនមានអាសវៈផងក៏មាន ។

[ ២៤៧ ] ឥន្ទ្រិយទាំងឡាយ មិនមែនសញ្ញោជនៈ ។ ឥន្ទ្រិយ ១០ ជាប្រយោជន៍ដល់សញ្ញោជនៈ ឥន្ទ្រិយ ៣ មិនមែនជាប្រយោជន៍ដល់សញ្ញោជនៈ ឥន្ទ្រិយ ៩ ជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន មិនមែនជាប្រយោជន៍

ដល់សញ្ញោជនៈក៏មាន ។ ឥន្ទ្រិយ ១៥ ប្រាសចាកសញ្ញោជនៈ ទោមនស្សិន្ទ្រិយ ប្រកបដោយសញ្ញោជនៈ ឥន្ទ្រិយ ៦ ប្រកបដោយសញ្ញោជនៈក៏មាន ប្រាសចាកសញ្ញោជនៈក៏មាន ឥន្ទ្រិយ ១០ មិនគួរពោលថា ជាសញ្ញោជនៈទាំងជាប្រយោជន៍ដល់សញ្ញោជនៈទេ ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ឥន្ទ្រិយ ៣ មិនគួរពោលថា ជាសញ្ញោជនៈទាំងជាប្រយោជន៍ដល់សញ្ញោជនៈផង ថាជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនសញ្ញោជនៈផងឡើយ ឥន្ទ្រិយ ៩ មិនគួរពោលថា ជាសញ្ញោជនៈទាំងជាប្រយោជន៍ដល់សញ្ញោជនៈទេ ជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនសញ្ញោជនៈក៏មាន មិនគួរពោលថា ជាប្រយោជន៍ដល់សញ្ញោជនៈ ទាំងមិនមែនសញ្ញោជនៈក៏មាន ។ ឥន្ទ្រិយ ១៥ មិនគួរពោលថា ជាសញ្ញោជនៈទាំងប្រកបដោយសញ្ញោជនៈផង ថាប្រកបដោយសញ្ញោជនៈ តែមិនមែនសញ្ញោជនៈផងឡើយ ទោមនស្សិន្ទ្រិយ មិនគួរពោលថាជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈទេ ប្រកបដោយសញ្ញោជនៈ តែមិនមែនសញ្ញោជនៈ ឥន្ទ្រិយ ៦ មិនគួរពោលថា ជាសញ្ញោជនៈ ទាំងប្រកបដោយសញ្ញោជនៈឡើយ ប្រកបដោយសញ្ញោជនៈ តែមិនមែនសញ្ញោជនៈក៏មាន មិនគួរពោលថា ប្រកបដោយសញ្ញោជនៈ ទាំងមិនមែនសញ្ញោជនៈក៏មាន ។ ឥន្ទ្រិយ ៩ ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈ ឥន្ទ្រិយ ៣ ប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈ ទោមនស្សិន្ទ្រិយ មិនគួរពោលថា ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈផង

ជាប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈផងឡើយ ឥន្ទ្រិយ ៣ ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ឥន្ទ្រិយ ៦ ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន ប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈក៏មាន មិនគួរពោលថា ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈផង ជាប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈផងក៏មាន ។

[ ២៤៨ ] ឥន្ទ្រិយទាំងឡាយ មិនមែនគន្ថៈ ។ ឥន្ទ្រិយ ១០ គន្ថៈគប្បីដោតក្រង ឥន្ទ្រិយ ៣ គន្ថៈមិនគប្បីដោតក្រង ឥន្ទ្រិយ ៩ គន្ថៈគប្បីដោតក្រងក៏មាន គន្ថៈមិនគប្បីដោតក្រងក៏មាន ។ ឥន្ទ្រិយ ១៥ ប្រាសចាកគន្ថៈ ទោមនស្សិន្ទ្រិយ ប្រកបដោយគន្ថៈ ឥន្ទ្រិយ ៦ ប្រកបដោយគន្ថៈក៏មាន ប្រាសចាកគន្ថៈក៏មាន ។ ឥន្ទ្រិយ ១០ មិនគួរពោលថា ជាគន្ថៈ ទាំងគន្ថៈគប្បីដោតក្រងទេ គន្ថៈគប្បីដោតក្រង តែមិនមែនគន្ថៈ ឥន្ទ្រិយ ៣ មិនគួរពោលថាជាគន្ថៈ ទាំងគន្ថៈគប្បីដោតក្រងផង ជាគន្ថៈគប្បីដោតក្រង តែមិនមែនគន្ថៈផងឡើយ ឥន្ទ្រិយ ៩ មិនគួរពោលថាជាគន្ថៈ ទាំងគន្ថៈគប្បីដោតក្រងទេ គន្ថៈគប្បីដោតក្រង តែមិនមែនគន្ថៈក៏មាន មិនគួរពោលថា គន្ថៈគប្បីដោតក្រង តែមិនមែនគន្ថៈក៏មាន ។ ឥន្ទ្រិយ ១៥ មិនគួរពោលថា ជាគន្ថៈ ទាំងប្រកបដោយគន្ថៈផង ជាប្រកបដោយគន្ថៈ តែមិនមែនគន្ថៈផងឡើយ ទោមនស្សិន្ទ្រិយ មិនគួរពោលថា ជាគន្ថៈ ទាំងប្រកបដោយគន្ថៈទេ ប្រកប

ដោយគន្ថៈ តែមិនមែនគន្ថៈ ឥន្ទ្រិយ ៦ មិនគួរពោលថាជាគន្ថៈ ទាំងប្រកប ដោយគន្ថៈឡើយ ប្រកបដោយគន្ថៈ តែមិនមែនគន្ថៈក៏មាន មិនគួរពោលថា ប្រកបដោយគន្ថៈ តែមិនមែនគន្ថៈក៏មាន ។ ឥន្ទ្រិយ ៩ ប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រង ឥន្ទ្រិយ ៣ ប្រាសចាកគន្ថៈ ទាំងគន្ថៈមិនគប្បីដោត ក្រង ទោមនស្សិន្ទ្រិយ មិនគួរពោលថា ប្រាសចាកគន្ថៈ ទាំងគន្ថៈគប្បីដោត ក្រងផង ជាប្រាសចាកគន្ថៈ ទាំងគន្ថៈមិនគប្បីដោតក្រងផងឡើយ ឥន្ទ្រិយ ៣ ប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រងក៏មាន ប្រាសចាកគន្ថៈ តែគន្ថៈមិន គប្បីដោតក្រងក៏មាន ឥន្ទ្រិយ ៦ ប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រងក៏ មាន ប្រាសចាកគន្ថៈ ទាំងគន្ថៈមិនគប្បីដោតក្រងក៏មាន មិនគួរពោលថា ប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រងផង ជាប្រាសចាកគន្ថៈ ទាំងគន្ថៈមិន គប្បីដោតក្រងផងក៏មាន ។

[ ២៤៩ ] ឥន្ទ្រិយទាំងឡាយ មិនមែនឱឃៈ ។បេ។ ឥន្ទ្រិយទាំងឡាយ មិនមែនយោគៈ ។បេ។ ឥន្ទ្រិយទាំងឡាយ មិនមែននីវរណៈ ។ ឥន្ទ្រិយ ១០ ជាប្រយោជន៍ដល់នីវរណៈ ឥន្ទ្រិយ ៣ មិនជាប្រយោជន៍ដល់នីវរណៈ ឥន្ទ្រិយ៩ ជាប្រយោជន៍ដល់នីវរណៈក៏មាន មិនជាប្រយោជន៍ដល់នីវរណៈក៏ មាន ។ ឥន្ទ្រិយ ១៥ ប្រាសចាកនីវរណៈ ទោមនស្សិន្ទ្រិយ ប្រកបដោយ នីវរណៈ ឥន្ទ្រិយ ៦ ប្រកបដោយនីវរណៈក៏មាន ប្រាសចាកនីវរណៈក៏ មាន ។ ឥន្ទ្រិយ ១០ មិនគួរពោលថា ជានីវរណៈ ទាំងជាប្រយោជន៍ដល់ នីវរណៈទេ ជាប្រយោជន៍ដល់នីវរណៈ តែមិនមែនជានីវរណៈ ឥន្ទ្រិយ ៣

មិនគួរពោលថា ជានីវរណៈ ទាំងជាប្រយោជន៍ដល់នីវរណៈផង ថាជាប្រយោជន៍ដល់នីវរណៈ តែមិនមែននីវរណៈផងឡើយ ឥន្ទ្រិយ ៩ មិនគួរពោលថា ជានីវរណៈ ទាំងជាប្រយោជន៍ដល់នីវរណៈទេ ជាប្រយោជន៍ដល់នីវរណៈ តែមិនមែននីវរណៈក៏មាន មិនគួរពោលថា ជានីវរណៈ តែមិនមែននីវរណៈក៏មាន ។ ឥន្ទ្រិយ ១៥ មិនគួរពោលថា ជានីវរណៈ ទាំងប្រកបដោយនីវរណៈផង ថាប្រកបដោយនីវរណៈ តែមិនមែននីវរណៈផងឡើយ ទោមនស្សិន្ទ្រិយ មិនគួរពោលថា ជានីវរណៈ ទាំងប្រកបដោយនីវរណៈផង ថាប្រកបដោយនីវរណៈ តែមិនមែននីវរណៈផងទេ ឥន្ទ្រិយ ៦ មិនគួរពោលថា ជានីវរណៈ ទាំងប្រកបដោយនីវរណៈឡើយ ប្រកបដោយនីវរណៈ តែមិនមែននីវរណៈក៏មាន មិនគួរពោលថា ប្រកបដោយនីវរណៈ តែមិនមែននីវរណៈក៏មាន ។ ឥន្ទ្រិយ ៩ ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈ ឥន្ទ្រិយ ៣ ប្រាសចាកនីវរណៈ ទាំងមិនជាប្រយោជន៍ដល់នីវរណៈ ទោមនស្សិន្ទ្រិយមិនគួរពោលថា ប្រាសចាកនីវរណៈតែជាប្រយោជន៍ដល់នីវរណៈផង ថាប្រាសចាកនីវរណៈ ទាំងមិនជាប្រយោជន៍ដល់នីវរណៈផងឡើយ ឥន្ទ្រិយ ៣ ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈក៏មាន ប្រាសចាកនីវរណៈទាំងមិនជាប្រយោជន៍ដល់នីវរណៈក៏មាន ឥន្ទ្រិយ ៦ ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈក៏មាន ប្រាសចាកនីវរណៈ ទាំងមិនជាប្រយោជន៍ដល់នីវរណៈក៏មាន មិនគួរពោលថា ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈផង ថាប្រាសចាកនីវរណៈ ទាំង

មិនជាប្រយោជន៍ដល់នីវរណៈផងក៏មាន ។

[ ២៥០ ] ឥន្ទ្រិយទាំងឡាយ មិនមែនបរាមាស ។ ឥន្ទ្រិយ ១០ បរាមាសស្ទាបអង្អែល ឥន្ទ្រិយ ៣ បរាមាសមិនបានស្ទាបអង្អែល ឥន្ទ្រិយ ៩ បរាមាសៈស្ទាបអង្អែលក៏មាន បរាមាសមិនបានស្ទាបអង្អែលក៏មាន ។ ឥន្ទ្រិយ ១៦ ប្រាសចាកបរាមាស ឥន្ទ្រិយ ៦ ប្រកបដោយបរាមាសក៏មាន ប្រាសចាកបរាមាសក៏មាន ។ ឥន្ទ្រិយ ១០ មិនគួរពោលថា ជាបរាមាស ទាំងបរាមាសស្ទាបអង្អែលទេ ជាធម៌ដែលបរាមាសស្ទាបអង្អែល តែមិនមែនបរាមាស ឥន្ទ្រិយ ៣ មិនគួរពោលថា ជាបរាមាស ទាំងជាធម៌ដែលបរាមាសស្ទាបអង្អែលផង ថាជាធម៌ដែលបរាមាសស្ទាបអង្អែល តែមិនមែនបរាមាសផងឡើយ ឥន្ទ្រិយ ៩ មិនគួរពោលថា ជាបរាមាស ទាំងជាធម៌ដែលបរាមាសស្ទាបអង្អែលទេ ជាធម៌ដែលបរាមាសស្ទាបអង្អែល តែមិនមែនបរាមាសក៏មាន មិនគួរពោលថា ជាធម៌ ដែលបរាមាសស្ទាបអង្អែល តែមិនមែនបរាមាសក៏មាន ។ ឥន្ទ្រិយ ១០ ប្រាសចាកបរាមាស តែជាធម៌ដែលបរាមាសស្ទាបអង្អែល ឥន្ទ្រិយ ៣ ប្រាសចាកបរាមាស តែជាធម៌ដែលបរាមាសមិនបានស្ទាបអង្អែល ឥន្ទ្រិយ ៣ ប្រាសចាកបរាមាស តែជាធម៌ដែលបរាមាសស្ទាបអង្អែលក៏មាន ប្រាសចាកបរាមាសទាំងជាធម៌ដែលបរាមាសមិនបានស្ទាបអង្អែលក៏មាន ឥន្ទ្រិយ ៦ ប្រាសចាកបរាមាស តែជាធម៌ដែលបរាមាសស្ទាបអង្អែលក៏មាន ប្រាសចាកបរាមាសទាំងជាធម៌ដែលបរាមាស មិនបានស្ទាបអង្អែលក៏មាន មិនគួរពោលថា

ប្រាសចាកបរាមាស ទាំងជាធម៌ដែលបរាមាសស្ទាបអង្អែលផង ជាប្រាស ចាកបរាមាស តែជាធម៌ដែលបរាមាសមិនបានស្ទាបអង្អែលផងក៏មាន ។

[ ២៥១ ] ឥន្ទ្រិយ ៧ មិនមានអារម្មណ៍ ឥន្ទ្រិយ ១៤ ប្រកបដោយ អារម្មណ៍ ជីវិតិន្ទ្រិយប្រកបដោយអារម្មណ៍ក៏មាន មិនមានអារម្មណ៍ក៏មាន ។ ឥន្ទ្រិយ ២១ មិនមែនចិត្ត មនិន្ទ្រិយជាចិត្ត ។ ឥន្ទ្រិយ ១៣ ជាចេតសិក ឥន្ទ្រិយ ៨ មិនមែនចេតសិក ជីវិតិន្ទ្រិយ ជាចេតសិកក៏មាន មិនមែន ចេតសិកក៏មាន ។ ឥន្ទ្រិយ ១៣ ប្រកបដោយចិត្ត ឥន្ទ្រិយ ៧ ប្រាសចាកចិត្ត ជីវិតិន្ទ្រិយ ប្រកបដោយចិត្តក៏មាន ប្រាសចាកចិត្តក៏មាន មនិន្ទ្រិយ មិនគួរ ពោលថា ប្រកបដោយចិត្តផង ជាប្រាសចាកចិត្តផងឡើយ ។ ឥន្ទ្រិយ ១៣ ប្រឡំដោយចិត្ត ឥន្ទ្រិយ ៧ មិនប្រឡំដោយចិត្ត ជីវិតិន្ទ្រិយ ប្រឡំដោយចិត្ត ក៏មាន មិនប្រឡំដោយចិត្តក៏មាន មនិន្ទ្រិយ មិនគួរពោលថា ប្រឡំដោយចិត្ត ផង ជាមិនប្រឡំដោយចិត្តផងឡើយ ។ ឥន្ទ្រិយ ១៣ តាំងឡើងដោយចិត្ត ឥន្ទ្រិយ ៨ មិនតាំងឡើងដោយចិត្ត ជីវិតិន្ទ្រិយ តាំងឡើងដោយចិត្តក៏មាន មិនតាំងឡើងដោយចិត្តក៏មាន ។ ឥន្ទ្រិយ ១៣ កើតជាមួយនឹងចិត្ត ឥន្ទ្រិយ ៨ មិនកើតជាមួយនឹងចិត្ត ជីវិតិន្ទ្រិយកើតជាមួយនឹងចិត្តក៏មាន មិនកើត ជាមួយនឹងចិត្តក៏មាន ។ ឥន្ទ្រិយ ១៣ ប្រព្រឹត្តទៅតាមចិត្ត ឥន្ទ្រិយ ៨ មិន ប្រព្រឹត្តទៅតាមចិត្ត ជីវិតិន្ទ្រិយប្រព្រឹត្តទៅតាមចិត្តក៏មាន មិនប្រព្រឹត្តទៅតាម ចិត្តក៏មាន ។ ឥន្ទ្រិយ ១៣ ប្រឡំ ទាំងតាំងឡើងដោយចិត្ត ឥន្ទ្រិយ ៨

មិនប្រឡំ មិនតាំងឡើងដោយចិត្ត ជីវិតិន្ទ្រិយ ប្រឡំ ទាំងតាំងឡើងដោយចិត្តក៏មាន មិនប្រឡំ មិនតាំងឡើងដោយចិត្តក៏មាន ។ ឥន្ទ្រិយ ១៣ ប្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ឥន្ទ្រិយ ៨ មិនប្រឡំ មិនតាំងឡើង មិនកើតជាមួយនឹងចិត្ត ជីវិតិន្ទ្រិយ ប្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្តក៏មាន មិនប្រឡំ មិនតាំងឡើង មិនកើតជាមួយនឹងចិត្តក៏មាន ។ ឥន្ទ្រិយ ១៣ ប្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ឥន្ទ្រិយ ៨ មិនប្រឡំ មិនតាំងឡើង មិនប្រព្រឹត្តទៅតាមចិត្ត ជីវិតិន្ទ្រិយ ប្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្តក៏មាន មិនប្រឡំ មិនតាំងឡើង មិនប្រព្រឹត្តទៅតាមចិត្តក៏មាន ឥន្ទ្រិយ ៦ ខាងក្នុង ឥន្ទ្រិយ ១៦ ខាងក្រៅ ។ ឥន្ទ្រិយ ៧ ជាឧបាទា ឥន្ទ្រិយ ១៤ មិនមែនឧបាទា ជីវិតិន្ទ្រិយ ជាឧបាទាក៏មាន មិនមែនឧបាទាក៏មាន ។ ឥន្ទ្រិយ ៩ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ឥន្ទ្រិយ ៤ មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកទេ ឥន្ទ្រិយ ៩ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយក៏មាន មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកទេក៏មាន ។

[ ២៥២ ] ឥន្ទ្រិយទាំងឡាយ មិនមែនឧបាទាន ។ ឥន្ទ្រិយ ១០ ជាប្រយោជន៍ដល់ឧបាទាន ឥន្ទ្រិយ ៣ មិនមែនជាប្រយោជន៍ដល់ឧបាទាន ឥន្ទ្រិយ ៩ ជាប្រយោជន៍ដល់ឧបាទានក៏មាន មិនមែនជាប្រយោជន៍ដល់ឧបាទានក៏មាន ។ ឥន្ទ្រិយ ១៦ ប្រាសចាកឧបាទាន ឥន្ទ្រិយ ៦ ប្រកប

ដោយឧបាទានក៏មាន ប្រាសចាកឧបាទានក៏មាន ។ ឥន្ទ្រិយ ១០ មិនគួរពោលថា ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានទេ ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនឧបាទាន ឥន្ទ្រិយ ៣ មិនគួរពោលថា ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានផង ថាជាប្រយោជន៍ដល់ឧបាទាន តែមិនមែនឧបាទានផងឡើយ ឥន្ទ្រិយ ៩ មិនគួរពោលថា ជាឧបាទាន ទាំងជាប្រយោជន៍ដល់ឧបាទានទេ ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនឧបាទានក៏មាន មិនគួរពោលថា ជាប្រយោជន៍ដល់ឧបាទាន តែមិនមែនឧបាទានក៏មាន ។ ឥន្ទ្រិយ ១៦ មិនគួរពោលថា ជាឧបាទាន ទាំងប្រកបដោយឧបាទានផង ថាប្រកបដោយឧបាទាន តែមិនមែនឧបាទានផងឡើយ ឥន្ទ្រិយ ៦ មិនគួរពោលថា ជាឧបាទាន ទាំងប្រកបដោយឧបាទានទេ ប្រកបដោយឧបាទាន តែមិនមែនឧបាទានផងក៏មាន មិនគួរពោលថា ប្រកបដោយឧបាទាន តែមិនមែនឧបាទានក៏មាន ។ ឥន្ទ្រិយ ១០ ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទាន ឥន្ទ្រិយ ៣ ប្រាសចាកឧបាទាន ទាំងមិនមែនជាប្រយោជន៍ដល់ឧបាទាន ឥន្ទ្រិយ ៣ ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទានក៏មាន ប្រាសចាកឧបាទាន ទាំងមិនមែនជាប្រយោជន៍ដល់ឧបាទានក៏មាន ឥន្ទ្រិយ ៦ ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទានក៏មាន ប្រាសចាកឧបាទាន ទាំងមិនមែនជាប្រយោជន៍ដល់ឧបាទានក៏មាន មិនគួរពោលថា ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទានផង ថាប្រាសចាកឧបាទាន ទាំងមិនមែនជាប្រយោជន៍ដល់ឧបាទានផងក៏មាន ។

[ ២៥៣ ] ឥន្ទ្រិយទាំងឡាយ មិនមែនកិលេស ។ ឥន្ទ្រិយ ១០ គួរដល់នូវសេចក្តីសៅហ្មង ឥន្ទ្រិយ ៣ មិនគួរដល់នូវសេចក្តីសៅហ្មង ឥន្ទ្រិយ ៩ គួរដល់នូវសេចក្តីសៅហ្មងក៏មាន មិនគួរដល់នូវសេចក្តីសៅហ្មងក៏មាន ។ ឥន្ទ្រិយ ១៥ មិនប្រកបដោយសេចក្តីសៅហ្មង ទោមនស្សិន្ទ្រិយ ប្រកបដោយសេចក្តីសៅហ្មង ឥន្ទ្រិយ ៦ ប្រកបដោយសេចក្តីសៅហ្មងក៏មាន មិនប្រកបដោយសេចក្តីសៅហ្មងក៏មាន ។ ឥន្ទ្រិយ ១៥ ប្រាសចាកកិលេស ទោមនស្សិន្ទ្រិយ ប្រកបដោយកិលេស ឥន្ទ្រិយ ៦ ប្រកបដោយកិលេសក៏មាន ប្រាសចាកកិលេសក៏មាន ។ ឥន្ទ្រិយ ១០ មិនគួរពោលថាជាកិលេស ទាំងគួរដល់នូវសេចក្តីសៅហ្មងទេ គួរដល់នូវសេចក្តីសៅហ្មង តែមិនមែនកិលេស ឥន្ទ្រិយ ៣ មិនគួរពោលថា ជាកិលេស ទាំងគួរដល់នូវសេចក្តីសៅហ្មងផង ជាគួរដល់នូវសេចក្តីសៅហ្មង តែមិនមែនកិលេសផងឡើយ ឥន្ទ្រិយ ៩ មិនគួរពោលថា ជាកិលេស ទាំងគួរដល់នូវសេចក្តីសៅហ្មងទេ គួរដល់នូវសេចក្តីសៅហ្មង តែមិនមែនកិលេសក៏មាន មិនគួរពោលថា គួរដល់នូវសេចក្តីសៅហ្មង តែមិនមែនកិលេសក៏មាន ។ ឥន្ទ្រិយ ១៥ មិនគួរពោលថា ជាកិលេស ទាំងប្រកបដោយសេចក្តីសៅហ្មងផង ជាប្រកបដោយសេចក្តីសៅហ្មង តែមិនមែនកិលេសផងឡើយ ទោមនស្សិន្ទ្រិយ មិនគួរពោលថាជាកិលេស ទាំងប្រកបដោយសេចក្តីសៅហ្មងទេ ប្រកបដោយសេចក្តីសៅហ្មង តែមិនមែនកិលេស ឥន្ទ្រិយ ៦ មិនគួរពោលថា ជាកិលេស ទាំងប្រកបដោយសេចក្តីសៅហ្មងឡើយ ប្រកបដោយសេចក្តីសៅហ្មង តែមិនមែន

កិលេសផងក៏មាន មិនគួរពោលថា ប្រកបដោយសេចក្តីសៅហ្មង តែមិនមែនកិលេសក៏មាន ។ ឥន្ទ្រិយ ១៥ មិនគួរពោលថា ជាកិលេស ទាំងប្រកបដោយកិលេសផង ថាប្រកបដោយកិលេស តែមិនមែនកិលេសផងឡើយ ទោមនស្សិន្ទ្រិយ មិនគួរពោលថា ជាកិលេស ទាំងប្រកបដោយកិលេសទេ ប្រកបដោយកិលេស តែមិនមែនកិលេស ឥន្ទ្រិយ ៦ មិនគួរពោលថា ជាកិលេស ទាំងប្រកបដោយកិលេសឡើយ ប្រកបដោយកិលេស តែមិនមែនកិលេសក៏មាន មិនគួរពោលថា ប្រកបដោយកិលេស តែមិនមែនកិលេសក៏មាន ។ ឥន្ទ្រិយ ៩ ប្រាសចាកកិលេស តែគួរដល់នូវសេចក្តីសៅហ្មង ឥន្ទ្រិយ ៣ ប្រាសចាកកិលេស ទាំងមិនគួរដល់នូវសេចក្តីសៅហ្មង ទោមនស្សិន្ទ្រិយ មិនគួរពោលថា ប្រាសចាកកិលេស តែគួរដល់នូវសេចក្តីសៅហ្មងផង ថាប្រាសចាកកិលេស ទាំងមិនគួរដល់នូវសេចក្តីសៅហ្មងផងឡើយ ឥន្ទ្រិយ ៣ ប្រាសចាកកិលេស តែគួរដល់នូវសេចក្តីសៅហ្មងក៏មាន ប្រាសចាកកិលេស ទាំងមិនគួរដល់នូវសេចក្តីសៅហ្មងក៏មាន ឥន្ទ្រិយ ៦ ប្រាសចាកកិលេស តែគួរដល់នូវសេចក្តីសៅហ្មងក៏មាន ប្រាសចាកកិលេស ទាំងមិនគួរដល់នូវសេចក្តីសៅហ្មងក៏មាន មិនគួរពោលថា ប្រាសចាកកិលេស តែគួរដល់នូវសេចក្តីសៅហ្មងផង ថាប្រាសចាកកិលេស ទាំងមិនគួរដល់នូវសេចក្តីសៅហ្មងផងក៏មាន ។

[ ២៥៤ ] ឥន្ទ្រិយ ១៥ មិនគួរលះដោយទស្សនៈ ឥន្ទ្រិយ ៧ គួរលះដោយទស្សនៈក៏មាន មិនគួរលះដោយទស្សនៈក៏មាន ។ ឥន្ទ្រិយ ១៥ មិន

គួរលះដោយភាវនា ឥន្ទ្រិយ ៧ គួរលះដោយភាវនាក៏មាន មិនគួរលះដោយភាវនាក៏មាន ។ ឥន្ទ្រិយ ១៥ មិនមានហេតុ គួរលះដោយទស្សនៈ ឥន្ទ្រិយ ៧ មានហេតុ គួរលះដោយទស្សនៈក៏មាន មិនមានហេតុ គួរលះដោយទស្សនៈក៏មាន ។ ឥន្ទ្រិយ ១៥ មិនមានហេតុ គួរលះដោយភាវនា ឥន្ទ្រិយ ៧ មានហេតុ គួរលះដោយភាវនាក៏មាន មិនមានហេតុ គួរលះដោយភាវនាក៏មាន ។ ឥន្ទ្រិយ ៩ មិនមានវិតក្កៈ ទោមនស្សិន្ទ្រិយ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ឥន្ទ្រិយ ១២ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈក៏មាន មិនមានវិតក្កៈក៏មាន ។ ឥន្ទ្រិយ ៩ មិនមានវិចារៈ ទោមនស្សិន្ទ្រិយ ប្រព្រឹត្តទៅជាមួយនឹងវិចារៈ ឥន្ទ្រិយ ១២ ប្រព្រឹត្តជាមួយនឹងវិចារៈក៏មាន មិនមានវិចារៈក៏មាន ។ ឥន្ទ្រិយ ១១ មិនមានបីតិ ឥន្ទ្រិយ ១១ ប្រព្រឹត្តទៅជាមួយនឹងបីតិក៏មាន មិនមានបីតិក៏មាន ។ ឥន្ទ្រិយ ១១ មិនកើតព្រមដោយបីតិ ឥន្ទ្រិយ ១១ កើតព្រមដោយបីតិក៏មាន មិនកើតព្រមដោយបីតិក៏មាន ។ ឥន្ទ្រិយ ១២ កើតព្រមដោយសុខ ឥន្ទ្រិយ ១០ កើតព្រមដោយសុខក៏មាន មិនកើតព្រមដោយសុខក៏មាន ។ ឥន្ទ្រិយ ១២ មិនកើតព្រមដោយឧបេក្ខា ឥន្ទ្រិយ ១០ កើតព្រមដោយឧបេក្ខាក៏មាន មិនកើតព្រមដោយឧបេក្ខាក៏មាន ។ ឥន្ទ្រិយ ១០ ជាកាមាវចរ ឥន្ទ្រិយ ៣ មិនមែនកាមាវចរ ឥន្ទ្រិយ ៩ ជាកាមាវចរក៏មាន មិនមែនកាមាវចរក៏មាន ។ ឥន្ទ្រិយ ១៣ មិនមែនរូបាវចរ ឥន្ទ្រិយ ៩ ជារូបាវចរក៏មាន មិនមែនរូបាវចរក៏មាន ។ ឥន្ទ្រិយ ១៤ មិនមែនអរូបាវចរ ឥន្ទ្រិយ ៨ ជាអរូបាវចរក៏មាន មិនមែនអរូបាវចរក៏មាន ។ ឥន្ទ្រិយ ១០ ជាបរិ-

យាបន្ន ឥន្ទ្រិយ ៣ ជាអបរិយាបន្ន ឥន្ទ្រិយ ៩ ជាបរិយាបន្នក៏មាន ជាអបរិយាបន្នក៏មាន ។ ឥន្ទ្រិយ ១១ ជាអនិយ្យានិកៈ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ជានិយ្យានិកៈ ឥន្ទ្រិយ ១០ ជានិយ្យានិកៈក៏មាន ជាអនិយ្យានិកៈក៏មាន ។ ឥន្ទ្រិយ ១០ មិនទៀង អនញ្ញាតញ្ញស្សាមីតិន្ទ្រិយទៀង ឥន្ទ្រិយ ១១ ទៀងក៏មាន មិនទៀងក៏មាន ។ ឥន្ទ្រិយ ១០ ប្រព្រឹត្តទៅជាមួយនឹងឧត្តរៈ ( ការរើឡើងនូវខ្លួន ) ឥន្ទ្រិយ ៣ មិនមានឧត្តរៈ ឥន្ទ្រិយ ៩ ប្រព្រឹត្តទៅជាមួយនឹងឧត្តរៈក៏មាន មិនមានឧត្តរៈក៏មាន ។ ឥន្ទ្រិយ ១៥ មិនប្រកបដោយសត្រូវ ទោមនស្សិន្ទ្រិយ ប្រកបដោយសត្រូវ ឥន្ទ្រិយ ៦ ប្រកបដោយសត្រូវក៏មាន មិនមានសត្រូវក៏មាន ។

បញ្ហាបុច្ឆកៈ ចប់

ឥន្ទ្រិយវិភង្គ ចប់

# អដ្ឋកថា

## បញ្ហាបុច្ឆកៈ

[ ២៤២-២៥៤ ] ក្នុងបញ្ហាបុច្ឆកៈ គប្បីជ្រាបការចែកឥន្ទ្រិយទាំងអស់ថាជាកុសលជាដើម ដោយទំនងរបស់ន័យក្នុងព្រះបាលីនោះឯង ។

ក្នុងអារម្មណត្តិកៈទាំងឡាយ បទថា **សត្តិន្ទ្រិយា អនារម្មណា** នោះ ត្រាស់សំដៅយកចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ ។ តែជីវិតិន្ទ្រិយមិនមកក្នុងឋានៈនេះឡើយ ព្រោះលាយឡំដោយអរូប ។

បទថា **ទ្វិន្ទ្រិយា** បានដល់ ឥន្ទ្រិយ ២ ពាក្យនេះ ទ្រង់ត្រាស់សំដៅយកឥន្ទ្រិយ ២ គឺសុខិន្ទ្រិយ និងទុក្ខិន្ទ្រិយ ព្រោះឥន្ទ្រិយ ២ នោះ ជាបរិត្តារម្មណ៍ដោយចំណែក ១ ។ បទថា **ទោមនស្សិន្ទ្រិយំ សិយា បរិត្តារម្មណំ សិយា មហគ្គតារម្មណំ** សេចក្ដីថា ក្នុងពេលប្រារព្ធកាមាវចរធម៌ប្រព្រឹត្តទៅ ក៏ជាបរិត្តារម្មណ៍ តែក្នុងវេលាដែលប្រារព្ធរូបាវចរ អរូបាវចរ ប្រព្រឹត្តទៅ ក៏ជាមហគ្គតារម្មណ៍ និងក្នុងពេលដែលប្រារព្ធបញ្ញត្តិប្រព្រឹត្តទៅ ក៏ជានវត្តព្វារម្មណ៍ ។

បទថា **នវិន្ទ្រិយា សិយា បរិត្តារម្មណា** នេះ ព្រះមានព្រះភាគត្រាស់សំដៅយកមនិន្ទ្រិយ ជីវិតិន្ទ្រិយ សោមនស្សិន្ទ្រិយ ឧបេក្ខិន្ទ្រិយ និងឥន្ទ្រិយពួក ៥ មានសទ្ធិន្ទ្រិយជាដើម ។ ពិតហើយ ជីវិតិន្ទ្រិយ សូម្បីសង្គ្រោះក្នុងរូបធម៌ដែលមិនមានអារម្មណ៍ ព្រោះលាយឡំដោយរូប ក៏សង្គ្រោះក្នុងចំណែក

*ដែលពោលហើយថា* **សិយា** *ដោយចំណែកនៃអរូប ។*

*បទថា* **ចត្តារិ ឥន្ទ្រិយានិ** *បានដល់ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ ទោមនស្សិន្ទ្រិយ និងអញ្ញាតាវិន្ទ្រិយ ព្រោះឥន្ទ្រិយទាំងនោះ មិនសង្គ្រោះចូលក្នុងមគ្គារម្មណត្តិកៈ ។*

*បទថា* **មគ្គហេតុកំ** *នេះ ទ្រង់ត្រាស់សំដៅយកហេតុដែលជាសហជាតក្នុងពេលដែលវីរិយៈ ឬវិមង្សា ជាធំ ជាមគ្គាធិបតី តែក្នុងពេលដែលឆន្ទៈ ឬចិត្តជាធំ ក៏ជានវត្តព្វធម៌ ។*

*បទថា* **ឧប្បន្នា សិយា ឧប្បន្នា សិយា ឧប្បាទិនោ** *នេះ ព្រះមានព្រះភាគត្រាស់សំដៅយករូបឥន្ទ្រិយ ៧ និងវិបាកឥន្ទ្រិយ ៣ ។ ឥន្ទ្រិយ ១០ ទ្រង់ត្រាស់ខាងដើម មួយអន្លើដោយទោមនស្សិន្ទ្រិយនោះឯង ។ ក្នុងឥន្ទ្រិយទាំង ១០ នោះ ទោមនស្សិន្ទ្រិយ ក្នុងពេលដែលប្រារព្ធបញ្ញត្តិប្រព្រឹត្តទៅ ក៏ជានវត្តព្វារម្មណ៍ ឥន្ទ្រិយដ៏សេស ក្នុងពេលដែលពិចារណានិព្វាន ក៏ជានវត្តព្វារម្មណ៍ ។*

*បទថា* **តីណិន្ទ្រិយា ពហិទ្ធារម្មណានិ** *បានដល់ ឥន្ទ្រិយ ៣ ដែលជា**លោកុត្តរ* *។*

*បទថា* **ចត្តារិ** *បានដល់ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ សោមនស្សិន្ទ្រិយ ទោមនស្សិន្ទ្រិយ ព្រោះឥន្ទ្រិយទាំង ៤ នោះ រមែងប្រព្រឹត្តទៅប្រារព្ធអជ្ឈត្តធម៌ខ្លះ ក្នុងពហិទ្ធាធម៌ខ្លះ ។*

*បទថា* **អជ្ឈត្តិន្ទ្រិយា** *បានដល់ មនិន្ទ្រិយ ជីវិតិន្ទ្រិយ ឧបេក្ខិន្ទ្រិយ និង*

ឥន្ទ្រិយពួក ៥ មានសទ្ធាជាដើម បណ្តាឥន្ទ្រិយទាំង ៨ នោះ ភាពជានវត្តព្វារម្មណ៍ គប្បីជ្រាបក្នុងពេលជាអាកិញ្ចញ្ញាយតនៈ ។

ក្នុងបញ្ហាបុច្ឆកៈនេះ ព្រះមានព្រះភាគត្រាស់ឥន្ទ្រិយ ១០ ជាកាមាវចរ ឥន្ទ្រិយ ៣ ជាលោកុត្តរ ឥន្ទ្រិយ ៩ ជាឥន្ទ្រិយដែលលាយឡំទាំងលោកិយនិងលោកុត្តរ ដោយប្រការដូច្នេះ បញ្ហាបុច្ឆកៈនេះ ក៏ជាបរិច្ឆេទមួយជាមួយនឹងអភិធម្មភាជនីយនោះឯង ។ ឯឥន្ទ្រិយវិភង្គនេះ ព្រះមានព្រះភាគ ទ្រង់នាំចេញចែកសម្តែងហើយដោយបរិវដ្ត ២ ដោយប្រការដូច្នេះ ។

អដ្ឋកថា បញ្ហាបុច្ឆកៈ ចប់

ឥន្ទ្រិយវិភង្គ ចប់

# ក្បាលទី ៦៧

# អភិធម្មបិដក បាលីប្រែ -៨០

## សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា ទំព័រ

### ខន្ធវិភង្គ

អភិធម្មបិដក សុត្តន្តភាជនីយ .......... .......... .......... ..... ២
អដ្ឋកថាសុត្តន្តភាជនីយ .......... .......... .............. ២៤
រូបក្ខន្ធនិទ្ទេស .......... .......... .............. ២៨
វេទនាខន្ធនិទ្ទេស .......... .......... .............. ៥១
សញ្ញាខន្ធនិទ្ទេស .......... .......... ............. ៦៤
សង្ខារក្ខន្ធនិទ្ទេស .......... .......... .............. ៦៧
វិញ្ញាណក្ខន្ធនិទ្ទេស .......... .......... .............. ៦៨
បកិណ្ណកកថា .......... .......... .............. ៦៩
កថាពោលដោយលំដាប់ជាដើម .......... .......... .............. ៨៦
អធិប្បាយ គប្បីឃើញដោយឧបាយ ២ យ៉ាង .......... .......... .............. ៩២
អភិធម្មបិដក អភិធម្មភាជនីយ .......... .......... ........... ១០០
អដ្ឋកថាអភិធម្មភាជនីយ .......... .......... ........... ១៧១
អភិធម្មបិដក បញ្ហាបុច្ឆកៈ .......... .......... ........... ១៨៦
អដ្ឋកថាបញ្ហាបុច្ឆកៈ .......... .......... ........... ២០៣

### អាយតនវិភង្គ

អភិធម្មបិដក សុត្តន្តភាជនីយ .......... .......... ........... ២០៦
អដ្ឋកថាសុត្តន្តភាជនីយ .......... .......... ........... ២០៧

អភិធម្មបិដក អភិធម្មភាជនីយ .......... .......... .......... ២២៣

អដ្ឋកថាអភិធម្មភាជនីយ .......... .......... .......... .......... .......... ២២៥

អភិធម្មបិដក បញ្ហាបុច្ឆកៈ .......... .......... .......... .......... .......... ២៣២

អដ្ឋកថាបញ្ហាបុច្ឆកៈ .......... .......... .......... .......... .......... ២៥១

## ធាតុវិភង្គ

អភិធម្មបិដក សុត្តន្តភាជនីយ .......... .......... .......... .......... .......... ២៥៣

អដ្ឋកថាសុត្តន្តភាជនីយ .......... .......... .......... .......... .......... ២៦៣

អភិធម្មបិដក អភិធម្មភាជនីយ .......... .......... .......... .......... .......... ៣០៦

អដ្ឋកថាអភិធម្មភាជនីយ .......... .......... .......... .......... .......... ៣១២

អភិធម្មបិដក បញ្ហាបុច្ឆកៈ .......... .......... .......... .......... .......... ៣២៤

អដ្ឋកថាបញ្ហាបុច្ឆកៈ .......... .......... .......... .......... .......... ៣៤៣

## សច្ចវិភង្គ

អភិធម្មបិដក សុត្តន្តភាជនីយ .......... .......... .......... .......... .......... ៣៤៤

អដ្ឋកថាសុត្តន្តភាជនីយ .......... .......... .......... .......... .......... ៣៦០

អត្ថរបស់ សច្ច សព្ទ .......... .......... .......... .......... .......... ៣៦៧

ទុក្ខសច្ចនិទ្ទេស .......... .......... .......... .......... .......... ៣៨៣

សមុទយសច្ចនិទ្ទេស .......... .......... .......... .......... .......... ៤២០

និរោធសច្ចនិទ្ទេស .......... .......... .......... .......... .......... ៤២៣

មគ្គសច្ចនិទ្ទេស .......... .......... .......... .......... .......... ៤២៧

អភិធម្មបិដក អភិធម្មភាជនីយ .......... .......... .......... .......... .......... ៤៤៥

អដ្ឋកថាអភិធម្មភាជនីយ .......... .......... .......... .......... .......... ៤៥៧

អភិធម្មបិដក បញ្ហាបុច្ឆកៈ .......... .......... .......... .......... .......... ៤៦១

អដ្ឋកថាបញ្ហាបុច្ឆកៈ .......... .......... .......... .......... .......... ៤៧៩

# ឥន្ទ្រិយវិភង្គ

*អភិធម្មបិដក អភិធម្មកាជនីយ* .......... .......... .......... .......... .......... ៤៨១

*អដ្ឋកថាអភិធម្មកាជនីយ* .......... .......... .......... .......... .......... ៤៨៦

*អភិធម្មបិដក បញ្ហាបុច្ឆកៈ* .......... .......... .......... .......... .......... ៤៩៥

*អដ្ឋកថាបញ្ហាបុច្ឆកៈ* .......... .......... .......... .......... .......... ៥១៦